Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

ISBN: 1-932827-00-5

33276

# ចំណែកស្មើភាព
# សំរាប់នារី

## ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

កិច្ចសហការរវាងមូលនិធិសហប្រជាជាតិដើម្បីស្ត្រី ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី
កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស
និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

# ចំណែកស្មើភាពសំរាប់នារី

## ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

**ឯកសារនេះ ត្រូវបានបោះពុម្ពផ្សាយនៅរាជធានីភ្នំពេញ ដោយ**
**មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសំរាប់ស្ត្រី (UNIFEM) ធនាគារពិភពលោក (WB)**
**ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និង**
**ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID/UK)**

**ខែ មេសា ឆ្នាំ ២០០៤**

ឯកសារនេះ មានលើកឡើងនូវឈ្មោះ ដូចជា មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសំរាប់ស្ត្រី (UNIFEM) ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និង ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID/UK) ឆ្នាំ២០០៤ ។ **ចំណែកស្មើភាពគ្នាសំរាប់នារី :** ការប៉ាន់ប្រមាណអំពីបញ្ហាយេនឌ័រនៅកម្ពុជា - មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសំរាប់ស្ត្រី ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និង ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស - ទីក្រុងភ្នំពេញ ISBN: 1-932827-00-5

រៀបចំរចនាក្រប និង សៀវភៅ ដោយ Boonruang Song-ngam

**រក្សាសិទ្ធិ :** មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសំរាប់ស្ត្រី (UNIFEM) ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និង ក្រសួងអភិវឌ្ឍន៍អន្តរជាតិ នៃចក្រភពអង់គ្លេស (DFID/UK) ឆ្នាំ២០០៤

**រក្សាសិទ្ធិគ្រប់បែបយ៉ាង។**

បោះពុម្ពនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទស្សនៈដែលបានបង្ហាញជូននៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នករៀបរៀង មិនមែនជាទស្សនៈរបស់មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសំរាប់ស្ត្រី ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេសទេ។

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាអ្នកផ្តល់ជំនួយ កាន់តែទទួលស្គាល់អំពីសារៈសំខាន់នៃការដោះស្រាយបញ្ហាយេនឌ័រនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍ ដើម្បីលើកកំពស់កិច្ចអភិវឌ្ឍន៍ឱ្យមាននិរន្តរភាពសំរាប់នារី និងសំរាប់ប្រជាពលរដ្ឋទូទៅ ។ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ចាំបាច់ត្រូវតែលុបបំបាត់គំលាតយេនឌ័រក្នុងការទទួលបាន និងគ្រប់គ្រងឱកាស និងធនធានមនុស្ស សេដ្ឋកិច្ច និងសង្គម ។ ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការ និងលទ្ធផលរំពឹងទុកក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការកំណត់អំពីចំណុចដៅ គោលដៅ និងសូចនាករនៃការអភិវឌ្ឍន៍ គឺត្រូវការចាំបាច់នូវយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រដែលមានគ្រប់ទិដ្ឋភាព ។ រាជរដ្ឋាភិបាលដើរតួយ៉ាងសំខាន់នៅក្នុងការលើកកំពស់សមភាពយេនឌ័រ ។ ដូចច្នេះត្រូវការចាំបាច់នូវការប្តេជ្ញាចិត្តពីស្ថាប័នរដ្ឋនៅគ្រប់វិស័យ និងគ្រប់កំរិត ក្នុងការពិនិត្យ និងកែលំអឡើងវិញនូវគោលនយោបាយ និងការអនុវត្តន៏របស់ស្ថាប័នទាំងនោះ ដើម្បីដោះស្រាយបញ្ហាវិសមភាពយេនឌ័រ ។

នៅក្នុងរបាយការណ៏អភិវឌ្ឍន៏មនុស្សឆ្នាំ១៩៩៥ របស់កម្មវិធីអភិវឌ្ឍន៏សហប្រជាជាតិ (UNDP) បានបង្ហាញឱ្យឃើញថា កម្មវិធីនេះទទួលស្គាល់ថា ការប្តេជ្ញាចិត្តរបស់ស្ថាប័នរដ្ឋមានសារៈសំខាន់ណាស់ក្នុងការនាំមកនូវសមភាពយេនឌ័រ ។ របាយការណ៏នេះបានសន្និដ្ឋានថា ដោយសារតែមានវិសមភាពនៅក្នុងរចនាសម្ព័ន្ធ អំណាច ហេតុដូច្នេះហើយ ដំណើរការសេដ្ឋកិច្ច និងនយោបាយអព្យាក្រឹតយេនឌ័រ នឹងពុំអាចនាំមកនូវសមភាពយេនឌ័រឡើយ ។ រាជរដ្ឋាភិបាលចាំបាច់ត្រូវតែរៀបចំគោលនយោបាយ និងសកម្មភាពវិជ្ជមាន ដើម្បីលើកកំពស់សមភាព និងធានាឱ្យបានថា នារី ទទួលបានធនធានផលិតកម្ម (**Kabeer** ឆ្នាំ២០០៣) ។

ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៏អាស៊ី ក៏បានធ្វើការសន្និដ្ឋានថា ទីផ្សារប្រកួតប្រជែង ពុំអាចលុបបំបាត់ការរើសអើងយេនឌ័របានឡើយ ។ រដ្ឋាភិបាល មានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យទីផ្សា និងរៀបចំហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសំខាន់ៗ ។ ការស្រាវជ្រាវរបស់ធនាគារពិភពលោក នាពេលថ្មីៗនេះ បានបង្ហាញឱ្យឃើញថា បើសិនជានារី និងបុរសទទួលបានឱកាសស្មើគ្នានឹងធ្វើឱ្យសេដ្ឋកិច្ចរីកចំរើនបានឆាប់រហ័ស ប្រជាពលរដ្ឋ នឹងរួចផុតពីភាពក្រីក្របានឆាប់រហ័ស សុខុមាលភាពរបស់បុរសនារី និងកុមារ នឹងកាន់តែល្អប្រសើរឡើង ។ (ដកស្រង់ចេញពីការបញ្ជ្រាបយេនឌ័រទៅក្នុងកិច្ចអភិវឌ្ឍន៏របស់ធនាគារពិភពលោក ឆ្នាំ២០០០) ។

ភ្នាក់ងារទាំងអស់ទទួលស្គាល់ថា មានយុទ្ធវិធីពីរយ៉ាងក្នុងការទទួលបានសមភាពយេនឌ័រ គឺ : យុទ្ធវិធីផ្អែកលើសិទ្ធិមនុស្ស ដោយយល់ឃើញថា សមភាពយេនឌ័រ គឺជាបញ្ហាសិទ្ធិមនុស្ស និងការផ្តោតលើតួនាទីរបស់នារីនៅក្នុងកិច្ចអភិវឌ្ឍន៏ ដោយយោងថា ការលើកកំពស់សមភាពយេនឌ័រ នឹងធ្វើឱ្យកំណើនសេដ្ឋកិច្ច និងដំណើរការកាត់បន្ថយភាពក្រីក្រកាន់តែមានភាពល្អប្រសើរឡើង ។

ទស្សនៈវិស័យទាំងពីរនេះ ត្រូវបានយកទៅអនុវត្តក្នុងការវិភាគយេនឌ័រ នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ម្យ៉ាងទៀត ការប៉ាន់ប្រមាណលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ គួរតែពិចារណាលើបញ្ហាផ្សេងៗដែលត្រូវដោះស្រាយនៅក្នុងគោលដៅនីមួយៗសំរាប់នារី ដើម្បីធានាឱ្យបានថា សិទ្ធិរបស់នារីត្រូវបានទទួលស្គាល់ ហើយម្យ៉ាងទៀត ការរៀបចំគោលនយោបាយ គួរតែពិចារណាទៅលើការចូលរួមរបស់នារី នៅក្នុងដំណើរការសំរេចគោលដៅនីមួយៗ ។ ដូច្នេះ ការបញ្ចូលទស្សនៈផ្អែកសិទ្ធិមនុស្ស ជាមួយនឹងយុទ្ធវិធីផ្អែកច្បាប់ផ្សេងទៀត នឹងធានាបានថា នារីនឹងទទួលបានផលប្រយោជន៍ច្រើនជាងមុន និងកាន់តែបានចូលរួមចំណែកច្រើនជាងមុន នៅក្នុងដំណើរការសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។

នៅកម្ពុជា ការប្រមូលពត៌មានស្តីពីបញ្ហាយេនឌ័រ ត្រូវបានរៀបចំធ្វើឡើងជាមួយនឹងការរៀបចំយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រក្នុងឆ្នាំ២០០២ និងដោយមានការឧបត្ថម្ភពីមូលនិធិអូស្ត្រាលី ។ ក្នុងខែតុលា ឆ្នាំ២០០២ ឯកសារស្តីពីការធ្វើផែនការ និងថវិកាយេនឌ័រ ត្រូវបានរៀបចំនៅក្នុងដំណើរការត្រួតពិនិត្យចំណាយសាធារណៈ និងត្រូវបានគេយកទៅពិភាក្សានៅក្នុងសិក្ខាសាលាជាមួយក្រសួងហិរញ្ញវត្ថុ និងភ្នាក់ងារតាមវិស័យផ្សេងៗទៀត ។ លទ្ធផលស្រាវជ្រាវអំពីយេនឌ័រសំរាប់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងឯកសារស្តីពីចំណាយសាធារណៈ ត្រូវបានប្រមូលចងក្រងដាក់ទៅក្នុងសេចក្តីព្រាងលើកដំបូងនៃការប៉ាន់ប្រមាណនេះ ។ នៅពេលដែលកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ចាប់ផ្តើមជួយក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ក្នុងការធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅកម្ពុជា មូលនិធិសហប្រជាជាតិដើម្បីនារី ត្រូវបានចុះកិច្ចសន្យាដើម្បីជួយផ្តល់អនុសាសន៍សំរាប់ការបញ្ជ្រាបបញ្ហាយេនឌ័រ ទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ស្របពេលជាមួយគ្នានេះ កម្មវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីផ្អែកផ្តល់ជំនួយបច្ចេកទេសដល់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក៏បានចូលរួមក្នុងការវិភាគបញ្ហាយេនឌ័រពាក់ព័ន្ធនឹងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច ការប្រកបរបរចិញ្ចឹមជីវិត និងការងារ ។

ការប៉ាន់ប្រមាណនេះ ប្រមូលទិន្នន័យពីប្រភពតែមួយ ពីការសិក្សាពាក់ព័ន្ធផ្សេងៗទៀត និងប្រមូលមកពីដំណើរការធ្វើផែនការថ្នាក់ជាតិ ប៉ុន្តែបានធ្វើការវិភាគដោយផ្អែកលើទស្សនៈវិស័យយេនឌ័រ ។ ក្នុងបណ្តាឆ្នាំកន្លងមកនេះ ពត៌មានបរិមាណត្រូវបានប្រមូលកាន់តែច្រើននៅក្នុងការអង្កេតថ្នាក់ជាតិ ( ឧទាហរណ៍ : ជំរឿន អង្កេតស្តីពីកំលាំងពលកម្ម អង្កេតប្រជាជន និងសុខភាព) និងនៅក្នុងប្រព័ន្ធពត៌មានរបស់ក្រសួងពាក់ព័ន្ធមួយចំនួន ( ក្រសួងដែលគួរឱ្យកត់សំគាល់គឺ ក្រសួងសុខាភិបាល និងក្រសួងអប់រំ) ។ ពត៌មានគុណភាពដកស្រង់ចេញពីឯកសារវាយតំលៃអំពីភាពក្រីក្រ ដោយមានការចូលរួមដែលត្រូវបានរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី សំរាប់ការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទីពីរ ។ លើសពីនេះទៀត ធនាគារពិភពលោក បានឧបត្ថម្ភដល់ការពិគ្រោះយោបល់មួយចំនួននៅក្នុងសហគមន៍ សំរាប់ការរៀបចំយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលត្រូវបានរៀបចំដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សហការជាមួយអង្គការក្រៅរដ្ឋាភិបាល ២ទៀត គឺអង្គការចំរើនស្ត្រី និងអង្គការអមរា ។ ដោយទទួលស្គាល់ពីតំលៃនៃការប៉ាន់ប្រមាណយេនឌ័ររួម ស្ថាប័នទាំងបួន គឺធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងមូលនិធិសហប្រជាជាតិដើម្បីនារី បានព្រមព្រៀងប្រមូលផ្តុំចូលគ្នានូវលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន ។ របាយការណ៍នេះ ឆ្លើយតបទៅនឹងតម្រូវការស្ថាប័នរបស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ព្រោះថា របាយការណ៍ប៉ាន់ប្រមាណអំពីយេនឌ័រនេះ មានលក្ខណៈល្អិតល្អន់ សំរាប់ដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រនៅក្នុងអង្គការរបស់ខ្លួន នៅក្នុងប្រទេសកម្ពុជា ។

**ចំណែកស្មើភាពសំរាប់នារី** ត្រូវបានរៀបចំឡើង ដោយផ្អែកលើទិន្នន័យ និងការពិនិត្យឡើងវិញលើលទ្ធផលនៃការស្រាវជ្រាវ និងការងាររបស់រាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល ។ ការស្រាវជ្រាវ និងការងារទាំងនោះដំណើរការឡើងតាមរយៈ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ពន្ធ័ និងអ្នកតស៊ូមតិ យេនឌ័រសំខាន់ៗនៅក្នុងជួររាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល ។ ការពិគ្រោះយោបល់ផ្លូវការមួយចំនួន ត្រូវបានរៀបចំឡើងជាមួយនឹងមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត តំណាងអង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ភ្នាក់ងារអ្នកផ្តល់ជំនួយ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសមាជិកអភិវឌ្ឍន៍ភូមិ ។ កិច្ចពិគ្រោះយោបល់ទាំងនោះ ពុំមានគោលបំណងជំរុញឱ្យមានការព្រមព្រៀងជារួមនោះទេ ប៉ុន្តែគឺដើម្បីធានាឱ្យបានថា ទស្សនៈ និងផលប្រយោជន៍របស់ក្រុមអ្នកពាក់ពន្ធ័ ត្រូវបានឆ្លុះបញ្ចាំង និងដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការដោះស្រាយបញ្ហាយេនឌ័រ នៅក្នុងដំណើរការរៀបចំ គោលនយោបាយ ។ ចុងក្រោយបង្អស់ក្នុងខែធ្នូ ឆ្នាំ២០០៣ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានរៀបចំកិច្ចប្រជុំ ពិគ្រោះយោបល់ថ្នាក់ជាតិមួយ ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុសាសន៍ ដែលត្រូវបានរៀបចំនៅក្នុងឯកសារប៉ាន់ប្រមាណនេះ ។ នៅក្នុងកិច្ចប្រជុំរយៈពេល២ថ្ងៃ មានការចូលរួមពីតំណាងមន្ទីរខេត្តចំនួន៦ មកពីខេត្ត-ក្រុងចំនួន ២៤ នៅព្រះរាជាណាចក្រកម្ពុជា ក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ហើយបានពិនិត្យ និងធ្វើវិសោធនកម្មលើសេចក្តីព្រាងអនុសាសន៍ និងដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការពិចារណានៅពេលអនាគត ។

ទោះបីជាពតិមាននៅមានភាពខ្វះចន្លោះ ហើយបញ្ហាខ្វះចន្លោះនេះ នឹងត្រូវដោះស្រាយនៅពេលរៀបចំប្រព័ន្ធស្ថិតិជាតិឱ្យកាន់តែល្អប្រសើរក៏ដោយ ក៏ការប៉ាន់ប្រមាណនេះ បានប្រមូលផ្តុំនូវពតិមានសំខាន់បំផុត ដែលមាននៅពេលបច្ចុប្បន្ននេះ ។ យើងសង្ឃឹមថា ឯកសារប៉ាន់ប្រមាណនេះ នឹងជាមូលដ្ឋានគ្រឹះសំរាប់អ្នកវិភាគ និងអ្នកតស៊ូមតិលើបញ្ហាយេនឌ័រ អាចស្រាវជ្រាវរកពតិមានបន្ថែមទៀត ដើម្បីបង្កើនលទ្ធភាពនៃការវិភាគអំពីភាពក្រីក្រ និងបញ្ហាយេនឌ័រនៅកម្ពុជា ។ ជាចុងក្រោយ ឯកសារប៉ាន់ប្រមាណនេះ សង្កត់ធ្ងន់ទៅលើភាពចាំបាច់ ក្នុងការរៀបចំយន្តការប្រមូល និងវិភាគពតិមានឆ្លើយតបយេនឌ័រ ដែលជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យការអនុវត្តន៍ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

ចំណុចចាប់ផ្តើមសំខាន់មួយទៀតសំរាប់ការតស៊ូមតិ ឱ្យមានគោលនយោបាយឆ្លើយតបទៅនឹងយេនឌ័រ និងជួយដល់ជនក្រីក្រ គឺការពិនិត្យលើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ថាតើរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយកំពុងធ្វើអ្វី និងផ្តល់ផលប៉ះពាល់អ្វីខ្លះ ដោយផ្អែកលើទស្សនៈយេនឌ័រ ។ របាយការណ៍យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដំណើរការត្រួតពិនិត្យ និងការសរសេររបាយការណ៍ គឺជាឱកាសជាយុទ្ធសាស្ត្រសំរាប់អ្នកតស៊ូមតិយេនឌ័រ ទទួលបានឱកាសកាន់តែច្រើនចូលរួមក្នុងការពិភាក្សា និងជំរុញឱ្យមានការប្តេជ្ញាចិត្តទូលំទូលាយនៅថ្នាក់ជាតិក្នុងការលើកកំពស់សិទ្ធិរបស់នារី និងសមភាពយេនឌ័រ ជាពិសេសតាមរយៈការចូលរួមនៅក្នុងការរៀបចំរបាយការណ៍ស្តីពីការរីកចំរើនប្រចាំឆ្នាំនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងការពិនិត្យឡើងវិញលើម៉ាទ្រិកគោលនយោបាយសកម្មភាព ។ ការរៀបចំរបាយការណ៍យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅកម្ពុជាគួរតែមានការចូលរួមពីសំណាក់អ្នកអនុវត្តន៍ទូលំទូលាយថ្នាក់ជាតិ រួមមាន សហគមន៍ សង្គមស៊ីវិល និងសារពតិមាន ។ នៅក្នុងការរៀបចំរបាយការណ៍ទាំងនេះ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សា

អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចនៃក្រសួងផែនការ គួរតែផ្តួចផ្តើមដំណើរការពិភាក្សាទូលំទូលាយ ជុំវិញជំរើសសំខាន់ៗសំរាប់ការអភិវឌ្ឍន៍ និងធ្វើឱ្យប្រជាពលរដ្ឋអាចទាមទារឱ្យមានការទទួលខុសត្រូវពីរាជរដ្ឋាភិបាល។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅកម្ពុជា ដែលបានបញ្ចូលបញ្ហាយេនឌ័ររួចហើយ បានបង្ហាញយ៉ាងច្បាស់អំពីទស្សនៈរបស់រាជរដ្ឋាភិបាលដើម្បីឱ្យមាន "**ចំណែកស្មើគ្នាសំរាប់នារី**" នៅក្នុងពេលអនាគត និងបានបញ្ចូលជាចំណុចដៅ និងសូចនាករ នៅក្នុងការពិនិត្យឡើងវិញលើម៉ាទ្រិកគោលនយោបាយសកម្មភាព នៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។

ការសរសេរបញ្ចប់ឯកសារ "**ចំណែកស្មើភាពសំរាប់នារី**" ការប៉ាន់ប្រមាណអំពីយេនឌ័រនេះ ពុំមែនមានន័យថា ការងារនេះត្រូវបញ្ចប់ត្រឹមនេះនោះទេ ប៉ុន្តែនេះគឺជាចំណុចចាប់ផ្តើមសកម្មភាពប៉ុណ្ណោះ។ ដៃគូដែលបានចូលរួមនៅក្នុងការរៀបចំឯកសារនេះ បានប្តេជ្ញាចិត្តធ្វើការជាមួយអ្នកពាក់ពន្ធ័ទាំងអស់ ក្នុងការប្រែក្លាយលទ្ធផលនៃការវិភាគ និងអនុសាសន៍ទាំងនេះ ឱ្យទៅជាការផ្លាស់ប្តូរយ៉ាងម៉ឺងមាត់ ដើម្បីទទួលបានសមភាពយេនឌ័រនៅកម្ពុជា។ ឧទាហរណ៍ភ្លាមៗដែលឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តនេះ គឺថា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស នឹងបញ្ចូលផែនការសកម្មភាពយេនឌ័រ ទៅក្នុងយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ខ្លួនដល់ប្រទេសកម្ពុជា តាមរយៈកម្មវិធីរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ ដែលមានលើកឡើងនៅក្នុងឯកសារប៉ាន់ប្រមាណនេះ។

# សេចក្តីថ្លែងអំណរគុណ

ការរៀបចំឯកសារប៉ាន់ប្រមាណអំពីយេនឌ័រនេះ ត្រូវបានធ្វើឡើងជាច្រើនដំណាក់កាល ដោយទីប្រឹក្សា និងបុគ្គលិកភ្នាក់ងារផ្តល់ជំនួយចំនួន៤ ដែលជាដៃគូរបស់រាជរដ្ឋាភិបាល ។ អ្នករៀបចំសេចក្តីព្រាងឯកសារនេះ សូមថ្លែងអំណរគុណដល់មន្ត្រីមួយចំនួនរបស់រាជរដ្ឋាភិបាលកម្ពុជា នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ក៏ដូចជាអង្គការស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ដែលបានរួមវិភាគទានទាំងពេលវេលា កំលាំងកាយ និងយោបល់ ប្រកបដោយទឹកចិត្តសប្បុរសធម៌ សំរាប់ការរៀបចំរបាយការណ៍នេះ ។ សូមថ្លែងអំណរគុណជាពិសេសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសមាជិកសហគមន៍ ដែលបានចូលរួមពិគ្រោះយោបល់ និងបានផ្តល់យោបល់ដ៏មានតំលៃថ្លៃថ្លា ដែលយើងខ្ញុំបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ ។ មូលនិធិឧបត្ថម្ភដំណើរការរៀបចំរបាយការណ៍នេះ គឺទទួលបានពីស្ថាប័នអភិវឌ្ឍន៍អន្តរជាតិរបស់អូស្ត្រាលី (**AusAID**) ធនាគារពិភពលោក (**WB**) មូលនិធិសហប្រជាជាតិដើម្បីស្ត្រី (**UNIFEM**) / កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (**UNDP**) ធនាគារអភិវឌ្ឍន៍អាស៊ី (**ADB**) និង ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (**DfID**) ។

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជាពិសេសលោកជំទាវ ***មូរ សុខហួរ*** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងលោកជំទាវរដ្ឋលេខាធិការទាំងពីររូប គឺលោកជំទាវ **អ៊ឹង កន្ថាផាវី** និងលោកជំទាវ **យូ អយ** បានផ្តល់នូវការលើកទឹកចិត្ត យោបល់ និងការគាំទ្រដ៏មានតំលៃបំផុតសំរាប់ការរៀបចំរបាយការណ៍នេះ នៅគ្រប់ដំណាក់កាលទាំងអស់ ។ លោកជំទាវ **កេត សំអាត** ជាអនុរដ្ឋលេខាធិការ បានដឹកនាំគណៈកម្មការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធមន្ទីរខេត្ត នានា អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ក្នុងខែធ្នូ ឆ្នាំ២០០៣ ។ លោកស្រី **ញាណ សុចិត្រា** អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ កញ្ញា **កក់ កណ្ណិកា** និងលោកស្រី **នួន ចិន្តា** បុគ្គលិកគំរោងភាពជាដៃគូដើម្បីសមធម៌យេនឌ័ររបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិដែលជាដៃគូរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងលោក ***សាយ សំភា*** បុគ្គលិកគំរោងតស៊ូមតិ និងសុខភាពបន្តពូជរបស់មូលនិធិសហប្រជាជាតិដើម្បីប្រជាជន (**UNFPA**) ដែលជាដៃគូរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានរួមចំណែកយ៉ាងសំខាន់នៅក្នុងដំណើរការរៀបចំរបាយការណ៍នេះ ។ លោកស្រី **Elaine McKay** ប្រធានគំរោង "***ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ***" របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានជួយពិនិត្យ និងផ្តល់ប្រឹក្សាផ្នែកបច្ចេកទេស និងរដ្ឋបាល និងការគាំទ្រដ៏មានតំលៃបំផុតជាបន្តបន្ទាប់ នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការស្រាវជ្រាវ ពិគ្រោះយោបល់ និងការបោះពុម្ពផ្សាយ ។

***ចំណែកស្មើភាពសំរាប់នារី*** ត្រូវបានរៀបចំឡើងជាពីរដំណាក់កាល ។ សេចក្តីព្រាងរបាយការណ៍ ស្តីពីការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា ត្រូវបានរៀបចំឡើងនៅដើមឆ្នាំ២០០៣ ដោយលោកស្រី **Helen Brereton** ទីប្រឹក្សាគំរោងមូលនិធិរបស់ **AusAID** និងលោកស្រី **Gillian Brown** អ្នកសំរបសំរួលយេនឌ័រប្រចាំតំបន់របស់ធនាគារពិភពលោក ។ សេចក្តីព្រាងរបាយការណ៍នេះ ត្រូវបានធ្វើបច្ចុប្បន្នភាព និងវិភាគកាន់តែទូលំទូលាយដោយលោកស្រី **Mia Hyun** (ជំពូកទី១-៣-៧-៨-៩) លោកស្រី **Ritu Shroff** (ជំពូកទី៤-៥-៦-៧) តាមរយៈ គំរោងរបស់មូលនិធិសហប្រជាជាតិ

ដើម្បីស្ត្រី ដោយមានការឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សំដៅបញ្ជ្រាបបញ្ហាយេនឌ័រ ទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ លោកស្រី **Cheryl Urashima** ទីប្រឹក្សាគំរោងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានផ្តល់យោបល់ទាក់ទងនឹងជំពូកទី២ និងទី៣។ លោកស្រី **Lorraine Corner** ទីប្រឹក្សាសេដ្ឋកិច្ចប្រចាំតំបន់របស់មូលនិធិសហប្រជាជាតិដើម្បីស្ត្រី បានផ្តល់ការណែនាំ និងយោបល់យ៉ាងច្រើន នៅក្នុងដំណាក់កាលរៀបចំតាក់តែងសេចក្តីព្រាងរបាយការណ៍នេះ ក៏ដូចជាការបោះពុម្ពផ្សាយ និងការរៀបចំគោលនយោបាយសង្ខេប ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ និងអនុសាសន៍នៅក្នុងរបាយការណ៍នេះ។

លោក **Michael J. Brereton, Karen Emmons, Michael A. Cohen** និង **Michael Wild** បានជួយពិនិត្យកែសំរួល និងស្រាវជ្រាវ។ លោក **អ៊ូច សៀ** អ្នកបកប្រែប្រចាំកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានបកប្រែរបាយការណ៍នេះទៅជាភាសាខ្មែរ។ លោក **Boonruang Song-ngam** ជាអ្នកទទួលខុសត្រូវលើការរៀបចំក្រាហ្វិក និងរចនារបាយការណ៍ ហើយលោកស្រី **Ann Bishop** ជាអ្នកសំរបសំរួលក្នុងការពិនិត្យបញ្ចប់លើរបាយការណ៍នេះ និងការបោះពុម្ពផ្សាយជាភាសាខ្មែរ និងអង់គ្លេស។

ឯកសារប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍នេះ បានមកពីប្រភពជាច្រើន ដូចដែលបានរៀបរាប់នៅក្នុងទំព័រឯកសារយោង។ ឯកសារនេះ ត្រូវបានពិនិត្យដោយលោកស្រី **Susan R. Razzaz** ជាសេដ្ឋកិច្ចវិទូ នៅក្នុងផ្នែកយេនឌ័រ និងអភិវឌ្ឍន៍របស់ធនាគារពិភពលោក លោក **Chaogang Wang** មន្ត្រីផ្នែកអភិវឌ្ឍន៍សង្គមកិច្ច នៃការិយាល័យធនាគារពិភពលោក ប្រចាំប្រទេសចិន និងលោកស្រី **Dagmar Oberlies** ជាទីប្រឹក្សាផ្នែកច្បាប់របស់គំរោង **GTZ "លើកកំពស់សិទ្ធិរបស់ស្ត្រី"**។

អ្នករៀបរៀងរបាយការណ៍នេះ សូមថ្លែងអំណរគុណចំពោះការជួយឧបត្ថម្ភ និងការគាំទ្ររបស់លោកស្រី អស់លោកដែលមានរាយនាមដូចតទៅ: លោកស្រី **Nisha Agrawal** ប្រធានការិយាល័យធនាគារពិភពលោក ប្រចាំកម្ពុជា លោកស្រី **Dominique Ait-Ouyahia McAdams** អតីតតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំកម្ពុជា និងជាប្រធានសំរបសំរួលប្រព័ន្ធសហប្រជាជាតិ លោក **Ladislaus Byenkya-Abwooli** តំណាងរងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំកម្ពុជា លោក **Urooj Malik** ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំកម្ពុជា លោកស្រី **Ingrid Cyimana** ប្រធានកម្មវិធីកាត់បន្ថយភាពក្រីក្រនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ លោកស្រី **Shireen Lateef** អ្នកឯកទេសផ្នែកអភិវឌ្ឍន៍សង្គមកិច្ច មកពីនាយកដ្ឋានអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពប្រចាំតំបន់ នៃធនាគារអភិវឌ្ឍន៍អាស៊ី។

ក្រុមអ្នករៀបចំរបាយការណ៍នេះ ក៏ទទួលបានយោបល់កែលំអពីមន្ត្រីធនាគារពិភពលោក និងទីភ្នាក់ងារសហប្រជាជាតិនានា។ បុគ្គលិកដទៃទៀត ក៏បានចូលរួមពិគ្រោះយោបល់ និងផ្តល់យោបល់ផងដែរ ដូចជា លោកស្រី **Yuriko Uehara** អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គមកិច្ច នៃនាយកដ្ឋានទន្លេមេគង្គ របស់ធនាគារអភិវឌ្ឍន៍អាស៊ី លោកស្រី **ខេង សំវ៉ាន់ដា** អ្នកឯកទេសផ្នែកយេនឌ័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី លោកស្រី **និល វណ្ណា** មន្ត្រីអភិវឌ្ឍន៍សង្គមកិច្ច របស់ធនាគារពិភពលោក ប្រចាំកម្ពុជា លោកស្រី **Henny Anderson** ទីប្រឹក្សាបច្ចេកទេសនៃអង្គភាពបច្ចេកទេសតាមដាន និងវិភាគភាពក្រីក្រ (**PMATU**) វិទ្យាស្ថានអភិវឌ្ឍន៍ និងស្រាវជ្រាវនៅកម្ពុជា (**CDRI**) និងក្រុមរបស់

លោកស្រី ដូចជា លោក **សុខ ណារិន** លោកស្រី **វណ្ណ វីណារី** លោកស្រី **ទេព សារ៉ាវី** លោក **ឱប ចន្ទ័វិទ្ធិ** លោក **ឡាយ ច័ន្ទ** និងលោក **ហង្ស ភូមិន្ទ** លោក **ទិត វង្ស** នៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ លោកស្រី **ប៉ុក ណណ្តា** អង្គការចំរើនស្ត្រី លោកស្រី **Joanne Morrison** គំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន (កម្មវិធីសិលា) លោកស្រី **ប៊ូ ចន្ទូ** អង្គការ **Padek** លោកស្រី **ឯក សុផាន់ណា** វេទិកាអង្គការក្រៅរដ្ឋាភិបាល **មិញ ណារី** អង្គការយេនឌ័រ និងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា **Judy Ledgerwood** សាលាភូមិន្ទវិចិត្រសិល្បៈ លោក **Willi Zimmerman** សាលាភូមិន្ទ វិចិត្រសិល្បៈ មកពីកម្មវិធី **LMAP/GTZ** លោកស្រី **Liz Giles** និងលោកស្រី **ហោ ផល្លី** មកពីគំរោងប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារ លោក **David Wilkinson** ទីប្រឹក្សាឯករាជ្យ គណៈកម្មាធិការទីប្រឹក្សា ផ្នែកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៃប្រព័ន្ធសហប្រជាជាតិ លោកស្រី **Beate Trankmann** ប្រធានកម្មវិធីអភិបាលកិច្ចនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ លោកស្រី **Blandine Bouniol** មកពីសាលាភូមិន្ទរដ្ឋបាល លោកស្រី **Olga Torres** អង្គការ **Concern Worldwide** លោកស្រី **Mirna Yacoub** លោកស្រី **Desiree Jongsma** លោក **Nyunt Nyunt Li** លោក **Graham Long** និងលោក **Chris Perry** មកពី **UNICEF** លោក **Maha Ahmed** មកពីកម្មវិធីស្បៀងអាហារពិភពលោក វេជ្ជបណ្ឌិត **Juliet Fleischl** លោកស្រី **Jenny Busch-Hallen** វេជ្ជបណ្ឌិត **Severin Von Xylander** វេជ្ជបណ្ឌិត **គឹមសុវណ្ណ យ៉ាដានី** និងវេជ្ជបណ្ឌិត **Reiko Tsuyuoka** មកពីអង្គការសុខភាពពិភពលោក លោកស្រី **Jesse Rattan** អង្គការ **CARE** លោកស្រី **Geeta Sethi** មកពី **UNAIDS** លោក **Chris Ward** គំរោងគោលនយោបាយ លោក **Dave Quinn** ក្រសួងអភិវឌ្ឍន៍អន្តរជាតិ លោកស្រី **Nelien Haspels** អង្គការពលកម្មអន្តរជាតិ ។

# មាតិកា


ខ្លឹមសារសង្ខេប ............................................................ ១

ជំពូកទី១ ៖ ទំនាក់ទំនងយេនឌ័រក្នុងទិដ្ឋភាពសេដ្ឋកិច្ច-សង្គមកិច្ច និង វប្បធម៌ ............ ២៩

កម្ពុជានាពេលបច្ចុប្បន្ន ............................................................ ២៩

១.១ ស្ថានភាព និន្នាការ និង បញ្ហា ............................................................ ៣០

១.១.១ ទំនៀមទំលាប់ប្រពៃណីតឹងរ៉ឹង បានធ្វើឱ្យនារីមានឋានៈក្នុងសង្គម ទាបជាងបុរស ............ ៣១

១.១.២ ការបែងចែកកំលាំងពលកម្ម កំពុងតែមានការប្រែប្រួល ............ ៣២

១.១.៣ នារី នៅតែមានបន្ទុកការងារធ្ងន់ធ្ងរជាងបុរស ............ ៣២

១.១.៤ បុរស នៅតែមានសិទ្ធិច្រើនបំផុតក្នុងការសំរេចលើកិច្ចការគ្រួសារ ............ ៣៣

១.១.៥ ទំនាក់ទំនងយេនឌ័រ រវាងនារី និងបុរសកំពុងតែប្រែប្រួល ............ ៣៤

១.១.៦ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) រង្វាស់សិទ្ធិអំណាចយេនឌ័រ (GEM) និងសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) ស្ថិតនៅក្នុងចំណោមសន្ទស្សន៍ និងរង្វាស់ដែលទាបជាងគេបំផុតនៅអាស៊ី ............ ៣៥

១.១.៧ សន្ទស្សន៍ភាពក្រីក្រមនុស្សរបស់នារី មានទំហំធំជាងបុរស ............ ៣៦

១.១.៨ គ្រួសារដែលមាននារីជាមេគ្រួសារ ស្ថិតនៅក្នុងចំណោមគ្រួសារក្រីក្របំផុតនៅក្នុងសហគមន៍ ............ ៣៧

ជំពូកទី២ ៖ ទស្សនៈវិស័យយេនឌ័រ នៅលើទីផ្សារពលកម្ម ............ ៤៣

កម្ពុជានាពេលបច្ចុប្បន្ន ............................................................ ៤៣

២.១ ស្ថានភាព និន្នាការ និង បញ្ហា ............................................................ ៤៣

២.១.១ កំលាំងពលកម្ម កំពុងកើនឡើងយ៉ាងឆាប់រហ័ស ............ ៤៤

២.១.២ អត្រាចូលរួមក្នុងកំលាំងពលកម្មកំពុងតែកើនឡើង ក្នុងនោះអត្រារបស់នារីមានកំរិតខ្ពស់បើធៀបទៅនឹងស្តង់ដារក្នុងតំបន់ ............ ៤៦

២.១.៣ យុវវ័យភាគច្រើន មិនមានការងារធ្វើ ............ ៤៨

២.១.៤ អត្រានារីធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារមានចំនួនច្រើន ប៉ុន្តែអត្រាបុរសធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ កំពុងកើនឡើង ............ ៥០

២.១.៥ អត្រានារីក្នុងការងារមានប្រាក់កំរៃ កំពុងតែកើនឡើង ប៉ុន្តែអតុល្យភាពយេនឌ័រនៅតែកើតមាន ..... ៥២

២.១.៦ ប្រភេទការងារ និងឧស្សាហកម្ម ដែលបែងចែកតាមភេទ ............ ៥៤

២.១.៧ ការគាំទ្របន្តិចបន្តួចចំពោះការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច/អាជីវកម្មខ្នាតតូចដែលពុំត្រូវបានគេយកចិត្តទុកដាក់ មានសារៈសំខាន់បំផុតចំពោះនារី ............ ៥៦

២.១.៨ នារី មានចំនួនតិចតួចនៅក្នុងការងារវិជ្ជាជីវៈ និងក្នុងតំណែងធ្វើសេចក្តីសំរេច ............ ៥៦

២.១.៩ កំរិតវប្បធម៌ មានផលប៉ះពាល់លើប្រាក់កំរៃ និង ឱកាសការងារ ...... ៥៧
២.១.១០ នារីទទួលបានប្រាក់កំរៃតិចជាងបុរស ...... ៥៨
២.១.១១ យុវវ័យក្នុងចំនួនកាន់តែច្រើនឡើង កំពុងមករកការងារធ្វើនៅទីក្រុង ...... ៥៩
២.១.១២ ឧស្សាហកម្មកាត់ដេរ មានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើជីវិតរស់នៅរបស់នារី ...... ៦០
២.១.១៣ គោលនយោបាយការងារ និងពាណិជ្ជកម្ម មានឥទ្ធិពលខុសគ្នាលើបុរស និងនារី ...... ៦៣
២.១.១៤ តើតំបន់ប្រតិបត្តិការនាំចេញ ដែលត្រូវបានស្នើឡើង ផ្តល់ផលប្រយោជន៏ដល់នារីដែរឬទេ? ...... ៦៦
២.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ...... ៦៧

**ជំពូកទី៣ : នារី កសិកម្ម និង ធនធានជនបទ ...... ៧១**
កម្ពុជានាពេលបច្ចុប្បន្ន ...... ៧១
៣.១ ស្ថានភាព និន្នាការ និង បញ្ហា ...... ៧២
៣.១.១ នារីមានតួនាទីសំខាន់នៅក្នុងផលិតកម្មកសិកម្ម ...... ៧៤
៣.១.២ នារីមានតួនាទីប្រកបដោយសក្តានុពលភាពយ៉ាងសំខាន់ ក្នុងការកាត់បន្ថយអសន្តិសុខស្បៀង ...... ៧៥
៣.១.៣ សេវាផ្សព្វផ្សាយមានកំរិតអប្បបរមា នារីទទួលបានសេវាផ្សព្វផ្សាយតិចជាងបុរស ...... ៧៦
៣.១.៤ ឱកាសតិចតួចក្នុងការទទួលបានធនធានធម្មជាតិ កំពុងគំរាមកំហែងដល់ការប្រកបរបរចិញ្ចឹមជីវិត ...... ៧៩
៣.១.៥ ទោះបីជាមានច្បាប់ដីធ្លីថ្មីដែលយកចិត្តទុកដាក់លើយេនឌ័រ ប៉ុន្តែនារីនៅតែងាយរងគ្រោះ
ដោយសារតែសិទ្ធិនារីក្នុងការទទួលបានដី មិនត្រូវបានគេយកចិត្តទុកដាក់ ...... ៧៩
៣.១.៦ ឱកាសទទួលបានសេវាហិរញ្ញវត្ថុ និងសេវាមិនមែនហិរញ្ញវត្ថុ មានកំរិតតិចតួចបំផុត ...... ៨២
៣.១.៧ ផ្លូវ និងគមនាគមន៏ជនបទជាអាទិភាពសំរាប់នារី និងបុរស ...... ៨៣
៣.១.៨ នារីផ្តល់អាទិភាពលើការផ្គត់ផ្គង់ទឹកស្អាត ...... ៨៤
៣.១.៩ នារីមិនមានតំណាងរបស់ខ្លួននៅក្នុងតួនាទីធ្វើសេចក្តីសំរេចក្នុងវិស័យកសិកម្ម និងជួរមន្ត្រីរាជការស៊ីវិល ៨៥
៣.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ...... ៨៦

**ជំពូកទី៤ : គំលាតយេនឌ័រ នៅក្នុងវិស័យអប់រំ ...... ៩៣**
កម្ពុជានាពេលបច្ចុប្បន្ន ...... ៩៣
៤.១ ស្ថានភាព និន្នាការ និង បញ្ហា ...... ៩៣
៤.១.១ គំលាតយេនឌ័រនៅក្នុងវិស័យអប់រំ កើនឡើងទៅតាមកំរិតនៃការសិក្សា ...... ៩៤
៤.១.២ ការចុះឈ្មោះចូលរៀនកំពុងកើនឡើងនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ...... ៩៥
៤.១.៣ ការកើនឡើងយ៉ាងឆាប់រហ័សនៃការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីមកពីឃុំដែលក្រីក្របំផុត ...... ៩៦
៤.១.៤ អត្រាគង់វង្ស និងបញ្ចប់ការសិក្សារបស់ក្មេងស្រីមានកំរិតទាបជាងក្មេងប្រុស ...... ៩៧
៤.១.៥ មានការខ្វះខាតគ្រូបង្រៀនខ្លាំងនៅជនបទ ជាពិសេសគ្រូបង្រៀនជានារី ...... ៩៩
៤.១.៦ គំលាតយេនឌ័រ និងភាពខុសគ្នានៃប្រាក់ចំណូល នៅតែពុំមានការផ្លាស់ប្តូរ
នៅក្នុងកំរិតមធ្យមសិក្សាទុតិយភូមិ ...... ១០០

៤.១.៧ អត្រាចុះឈ្មោះចូលរៀនពិតធ្លាក់ចុះនៅកំរិតមធ្យមសិក្សាទុតិយភូមិ ជាពិសេសក្មេងប្រុស .......... ១០១
៤.១.៨ មូលហេតុដែលនាំឱ្យមានគំលាតយេនឌ័រនៅកំរិតមធ្យមសិក្សា ............................................ ១០២
៤.១.៩ គំលាតយេនឌ័រ មានទំហំកាន់តែធំ នៅកំរិតឧត្តមសិក្សា ................................................... ១០៥
៤.១.១០ គំលាតយេនឌ័រនៅក្នុងអត្រាអក្ខរកម្ម កើនឡើងទៅតាមអាយុរបស់ប្រជាជន ........................ ១០៦
៤.១.១១ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅមានកំរិត ជាពិសេសសំរាប់នារី ..................................... ១០៧
៤.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ......................................................... ១០៨

**ជំពូកទី៥ : បញ្ហាយេនឌ័រ ក្នុងវិស័យសុខាភិបាល ...................................................... ១១៥**

កម្ពុជានាពេលបច្ចុប្បន្ន ............................................................................................................... ១១៥
៥.១ ស្ថានភាព និន្នាការ និង បញ្ហា ................................................................................................. ១១៥
៥.១.១ នារីបាត់បង់ឧត្តមភាពនៅក្នុងលទ្ធភាពទទួលបានសេវាសុខភាពជាមូលដ្ឋាន ............................. ១១៧
៥.១.២ លទ្ធភាពទាបក្នុងការទទួលបានសេវាសុខភាព មានទំនាក់ទំនងជិតស្និទទៅនឹងភាពក្រីក្រ និងការអប់រំរបស់នារី ........................................................................................................ ១១៧
៥.១.៣ អត្រាមរណភាពមាតានៅកម្ពុជា គឺមានកំរិតខ្ពស់បំផុតនៅក្នុងតំបន់ ....................................... ១១៩
៥.១.៤ ស្ថានភាពអាហារូបត្ថម្ភរបស់នារី មានកំរិតទាប ..................................................................... ១២១
៥.១.៥ តំរូវការផែនការគ្រួសារ និងការពន្យារកំណើតដែលមិនទាន់ឆ្លើយតប នៅតែមានកំរិតខ្ពស់ .......... ១២២
៥.១.៦ នារីមិនបានទទួលការថែទាំក្នុងពេលមានផ្ទៃពោះ និងពេលសំរាលកូនប្រកបដោយសុវត្ថិភាពទេ ... ១២៥
៥.១.៧ កង្វះបុគ្គលិកឆ្មបជំនាញ និងការបែងចែកបុគ្គលិកពេទ្យមិនបានគ្រប់គ្រាន់ ................................. ១២៥
៥.១.៨ យុវជនក្មេងៗក្នុងចំនួនច្រើនជាងនារីត្រូវស្លាប់ ឬទទួលគ្រោះថ្នាក់ជាយថាហេតុ ........................ ១២៧
៥.១.៩ ពិការភាព និងការញៀនថ្នាំញៀន មានផលប៉ះពាល់លើបុរសច្រើនជាងនារី .............................. ១២៧
៥.២ យុទ្ធសាស្ត្រ និង គោលនយោបាយរបស់រាជរដ្ឋាភិបាល ......................................................... ១២៨

**ជំពូកទី៦ : បញ្ហាយេនឌ័រ និង ជំងឺអេដស៍ ............................................................ ១៣៣**

កម្ពុជានាពេលបច្ចុប្បន្ន ............................................................................................................... ១៣៣
៦.១ ស្ថានភាព បញ្ហា និង និន្នាការ ................................................................................................. ១៣៣
៦.១.១ អត្រាឆ្លងថ្មីបានថយចុះនៅក្នុងចំណោមបុរស ចំណែកនៅក្នុងចំណោមនារីវិញ អត្រានេះនៅថេរ ... ១៣៤
៦.១.២ អត្រាឆ្លងមេរោគអេដស៍ក្នុងចំណោមនារីរកស៊ីផ្លូវភេទ បានថយចុះនៅពេលដែលមានការកើនឡើងនូវការប្រើប្រាស់ស្រោមអនាម័យ ............................................................................. ១៣៦
៦.១.៣ អត្រានៃការឆ្លងមេរោគអេដស៍ មានការថយចុះក្នុងចំណោមនារីដែលទទួលសេវាថែរក្សាគភ៌ ...... ១៣៧
៦.១.៤ ផ្លូវនៃការចំលងមេរោគអេដស៍ កំពុងតែមានការផ្លាស់ប្តូរ ......................................................... ១៣៩
៦.១.៥ នារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ នៅតែប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍ ................. ១៤០
៦.១.៦ នារីរៀបការរួច ប្រឈមមុខនឹងគ្រោះថ្នាក់ច្រើន .................................................................... ១៤០
៦.១.៧ ទស្សនះយេនឌ័រមិនត្រឹមត្រូវ មានឥទ្ធិពលលើការប្រព្រឹត្តិផ្លូវភេទរបស់បុរស .......................... ១៤១

៦.១.៨ នារីទទួលបន្ទុកថៃទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ........................... ១៤១
៦.១.៩ លទ្ធភាពទទួលបានការព្យាបាលប្រឆាំងនឹងមេរោគអេដស៍នៅមានកំរិត ................................. ១៤២
៦.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ........................................................... ១៤២

**ជំពូកទី៧ : អំពើហឹង្សាលើនារី ........................................................................ ១៤៧**
កម្ពុជានាពេលបច្ចុប្បន្ន ........................................................................................ ១៤៧
៧.១ ស្ថានភាព និន្នាការ និង បញ្ហា ............................................................................ ១៤៧
៧.១.១ ការទទួលយកអំពើហឹង្សាក្នុងគ្រួសារ ................................................................ ១៤៨
៧.១.២ នារីរងគ្រោះដោយការបំពារបំពាន ពុំមានផ្លូវចេញឱ្យផុតពីអំពើហឹង្សានេះ ................................ ១៤៩
៧.១.៣ អំពើរំលោភៈ អំពើហឹង្សាក្នុងបរិដ្ឋាននៃការមិនយកទោសពៃរ៍ ............................................ ១៥០
៧.១.៤ ជនរងគ្រោះដោយការជួញដូរ ទទួលយកការស្តីបន្ទោស ..................................................... ១៥២
៧.១.៥ ភាពក្រីក្រ និងបញ្ហាសង្គម នាំឱ្យមានការកើនឡើងនៃអាជីវកម្មផ្លូវភេទ ................................ ១៥៤
៧.១.៦ តម្រូវការអាជីវកម្មរកស៊ីផ្លូវភេទ កើនឡើង ........................................................... ១៥៤
៧.១.៧ ការផ្លាស់ប្តូររូបភាពនៃការងាររកស៊ីផ្លូវភេទ ......................................................... ១៥៥
៧.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ........................................................... ១៥៦

**ជំពូកទី៨ : សំលេងរបស់នារីនៅក្នុងឆាកនយោបាយ និង ការធ្វើសេចក្តីសំរេច ......................... ១៦១**
កម្ពុជានាពេលបច្ចុប្បន្ន ........................................................................................ ១៦១
៨.១ ស្ថានភាព និន្នាការ និង បញ្ហា ............................................................................ ១៦២
៨.១.១ របនាសម្ព័ន្ធរាជរដ្ឋាភិបាល និងប្រព័ន្ធវិមជ្ឈការ ................................................... ១៦២
៨.១.២ តំណាងរបស់នារីជាមធ្យមនៅក្នុងសភា មានតិចជាងតំណាងរបស់នារីជាមធ្យមប្រចាំតំបន់.......... ១៦៣
៨.១.៣ ចំនួននារីចូលរួមក្នុងរដ្ឋសភា មានការកើនឡើងតិចតួច ............................................... ១៦៤
៨.១.៤ បញ្ជីគណបក្ស និងលទ្ធផលនៃការបោះឆ្នោត .......................................................... ១៦៤
៨.១.៥ នៅពេលត្រូវបានជ្រើសតាំង នារី គឺជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងរដ្ឋសភា ......................... ១៦៧
៨.១.៦ នារីចំនួនតិចតួចបំផុត កាន់មុខតំណែងតាមការតែងតាំងដោយគណបក្សនយោបាយ
នៅថ្នាក់ជាតិ និងខេត្ត ...................................................................................... ១៦៨
៨.១.៧ នារីមានចំនួនតិចបំផុត នៅក្នុងប្រព័ន្ធតុលាការ .................................................... ១៦៩
៨.១.៨ នារីត្រូវប្រឈមមុខនឹងការរើសអើងក្នុងជួរមន្ត្រីរាជការ ................................................. ១៧០
៨.១.៩ កំណែទម្រង់រដ្ឋបាលសាធារណៈ - ឱកាស ឬហានិភ័យ? ................................................ ១៧១
៨.១.១០ នារីជាមន្ត្រីរាជការ ខ្វះលទ្ធភាពទទួលបានការបណ្តុះបណ្តាល ....................................... ១៧២
៨.១.១១ លទ្ធផលនៃការចូលរួមរបស់នារីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ដំបូងបង្អស់ ពុំទាន់បានពេញចិត្តនៅឡើយ ១៧៨
៨.១.១២ ការចូលរួមរបស់នារីនៅថ្នាក់ភូមិ មានលក្ខណៈល្អប្រសើរបំផុត ...................................... ១៨០
៨.២ គោលនយោបាយ និង យុទ្ធសាស្ត្ររាជរដ្ឋាភិបាល ................................................................ ១៨១

៨.២.១ ផែនការសកម្មភាពអភិបាលកិច្ច ..... ១៨១
៨.២.២ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក) ..... ១៨២
៨.២.៣ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់កម្មវិធីសិលា ..... ១៨៣
**ឧបសម្ព័ន្ធ:** បេក្ខភាពនារីនៅក្នុងបញ្ជីគណបក្ស ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅខែកក្កដា ឆ្នាំ២០០៣ ..... ១៨៤

**ជំពូកទី៩ : ការបញ្ជ្រាបយេនឌ័រ: បរិបទស្ថាប័ន និង គោលនយោបាយ ..... ១៩១**
៩.១ ក្របខណ្ឌច្បាប់ ..... ១៩១
៩.២ ក្របខណ្ឌស្ថាប័ន ..... ១៩៣
៩.២.១ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ..... ១៩៣
៩.២.២ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ..... ១៩៧
៩.២.៣ បទពិសោធន៍របស់ក្រសួងពាក់ពន្ធ័ក្នុងការបញ្ជ្រាបយេនឌ័រ ..... ១៩៨
៩.២.៤ អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល ..... ១៩៩
៩.៣ គោលនយោបាយជាតិ និង ដំណើរការធ្វើផែនការយុទ្ធសាស្ត្រ ..... ២០០
៩.៣.១ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចលើកទី២ (SEDP II) ..... ២០១
៩.៣.២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (យ.ជ.ក.ភ) ..... ២០១
៩.៣.៣ ក្របខណ្ឌការងាររួមបញ្ចូលគ្នា — យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មដល់ជនក្រីក្រ ..... ២០៣
៩.៣.៤ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក) ..... ២០៤
៩.៣.៥ ការគ្រោងថវិកា និង ការវិភាជថវិកា ..... ២០៤
៩.៣.៦ ប្រពន្ធ័ស្ថិតិជាតិ ..... ២០៥

**ជំពូកទី១០ : សេចក្តីសន្និដ្ឋាន និង អនុសាសន៍ ..... ២១៣**
១០.១ បញ្ហាប្រឈមទាក់ទងនឹងការផ្តល់អំណាចក្នុងវិស័យសេដ្ឋកិច្ច នឹងកើនឡើង ព្រោះអត្រាមនុស្សពេញវ័យកាន់តែកើនឡើង ..... ២១៤
១០.១.១ ចាំបាច់ត្រូវបង្កើនការងារផ្លូវការដែលមានប្រាក់កំរៃជាបន្ទាន់ ដើម្បីស្រូបទាញយកកំលាំងពលកម្មដែលកំពុងកើនឡើង ..... ២១៤
១០.១.២ ជំរើសការងារផ្លូវការមួយចំនួនធំ ជាតំរូវការចាំបាច់សំរាប់បុរស និងនារី ..... ២១៤
១០.១.៣ ឱកាសការងារនៅតំបន់ជនបទមានកំរិត និងមិនអាចបំពេញតាមតំរូវការ ..... ២១៥
១០.១.៤ ឱកាសកើនឡើង ប៉ុន្តែនារីពុំមានសមត្ថភាពប្រកួតប្រជែងចាប់យកឱកាសទាំងនោះ ..... ២១៥
១០.១.៥ អនុសាសន៍ ..... ២១៦
១០.២ នារីជនបទពុំមានលទ្ធភាពទទួលបាននូវធនធាន និង សេវាកម្មនានា ដែលអាចជួយពួកគេក្នុងការកាត់បន្ថយភាពក្រីក្រ និង ការធានាបាននូវសន្តិសុខស្បៀង ..... ២១៨
១០.២.១ ភាគច្រើននៃកសិករនៅកម្ពុជា គឺជានារីដែលពុំមានលទ្ធភាពទទួលបានធនធានដែលពួកគាត់ត្រូវការ . ២១៨

១០.២.២ សេវាកម្មជាមូលដ្ឋានដូចជា ផ្លូវថ្នល់ និងការផ្គត់ផ្គង់ទឹក គឺជាអាទិភាពសំរាប់នារី និងបុរសក្រីក្រ .២១៨
១០.២.៣ អនុសាសន៍ ..........២១៨
១០.៣ វិសមភាពយេនឌ័រក្នុងលទ្ធភាពទទួលបានសេវាសុខភាព និង អប់រំ គឺមានសភាពធ្ងន់ធ្ងរបំផុត ក្នុងចំណោមប្រជាជនក្រីក្រនៅតាមតំបន់ជនបទ ..........២១៩
១០.៣.១ វិសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ មានសភាពធ្ងន់ធ្ងរបំផុតនៅតាមតំបន់ជនបទ និង ក្នុងចំណោមប្រជាជនក្រីក្រនៅជនបទ ..........២១៩
១០.៣.២ សេវាសុខភាពបច្ចុប្បន្នពុំបានទៅដល់តំបន់ជនបទ ជាពិសេសទៅដល់នារី និងក្មេងស្រីនៅជនបទ ២២០
១០.៣.៣ អនុសាសន៍ ..........២២០
១០.៤ ប្រជាជនដែលងាយរងគ្រោះទទួលបានការគាំទ្រតិចតួច ហើយពុំដឹងថាត្រូវទៅរកជំនួយនៅកន្លែងណា. ២២២
១០.៤.១ ការចម្លងមេរោគអេដស៍/ជំងឺអេដស៍កំពុងកាត់បន្ថយ ប៉ុន្តែការចម្លងកំពុងតែឈានទៅរក ក្រុមប្រជាជនផ្សេងទៀតនៅក្នុងសង្គម ..........២២២
១០.៤.២ អំពើហឹង្សាលើនារី កើតឡើងជាច្រើនរូបភាព ហើយសេវាសំរាប់ជួយជនរងគ្រោះ មានតិចតួចប៉ុណ្ណោះ ..........២២២
១០.៤.៣ អនុសាសន៍ ..........២២៣
១០.៥ ស្ថាប័នសង្គម ផ្លូវច្បាប់ និង នយោបាយ បន្តឱ្យមានការរើសអើងយេនឌ័រ និង ភាពងាយរងគ្រោះ ........២២៥
១០.៥.១ បទដ្ឋានសង្គម និងឥរិយាបថដែលពាក់ព័ន្ធនឹងយេនឌ័រ អាចមានឥទ្ធិពលអវិជ្ជមានលើបុរស និងនារី... ២២៥
១០.៥.២ ការចូលរួមរបស់នារីនៅក្នុងការធ្វើសេចក្ដីសំរេច នៅគ្រប់កំរិតទាំងអស់ គឺមានសារៈសំខាន់ ក្នុងការនាំមក នូវការរីកចំរើន ..........២២៥
១០.៥.៣ ប្រព័ន្ធតុលាការ និងស្ថាប័នអនុវត្តច្បាប់ ចាំបាច់ត្រូវមានការទទួលខុសត្រូវតាមរយៈ ការបង្កើនការត្រួតពិនិត្យ និងធ្វើរបាយការណ៍អំពីសកម្មភាពរបស់ខ្លួន ..........២២៦
១០.៥.៤ អនុសាសន៍ ..........២២៦
១០.៦ ស្ថាប័ននៅតែប្រឹងប្រែងក្នុងការបញ្ជ្រាបយេនឌ័រឱ្យមានប្រសិទ្ធិភាព ..........២២៧
១០.៦.១ អភិបាលកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុនៅទន់ខ្សោយ គឺជាឧបសគ្គចំបងក្នុងការបង្កើន សមភាពយេនឌ័រ ..........២២៧
១០.៦.២ ប្រសិទ្ធិភាពរបស់យន្តការបច្ចុប្បន្ន ក្នុងការបញ្ចូលបញ្ហាយេនឌ័រ ទៅក្នុងដំណើរការធ្វើថវិកា និងផែនការ គឺនៅមានកំរិត ..........២២៧
១០.៦.៣ យន្តការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងពាក់ព័ន្ធនៅទន់ខ្សោយ និងដំណើរការតាមផ្នែក១ប៉ុណ្ណោះ .....២២៧
១០.៦.៤ សមត្ថភាពរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុង ដំណើរការរៀបចំគោលនយោបាយ នៅទន់ខ្សោយ ..........២២៨
១០.៦.៥ អនុសាសន៍ ..........២២៨

# ក្រាហ្វិក

ក្រាហ្វិក ១.១ : នារី និងក្មេងស្រី ធ្វើការច្រើនម៉ោងជាងបុរស និងក្មេងប្រុស ........ ៣៣
ក្រាហ្វិក ១.២ : សន្ទស្សន៍ភាពក្រីក្រមនុស្សតាមភេទ និងចំណាយសំរាប់មនុស្សម្នាក់ ទៅតាមបញ្ចូភាគផ្សេងៗឆ្នាំ១៩៩៩ ........ ៣៧
ក្រាហ្វិក ១.៣ : អត្រាពលកម្មកុមារ ក្នុងចំណោមកុមារអាយុ ១៤-១៧ឆ្នាំ ទៅតាមភេទនៃមេគ្រួសារ ឆ្នាំ១៩៩៩ ........ ៣៩
ក្រាហ្វិក ២.១ : កំណើនកំលាំងពលកម្មតាមក្រុមអាយុ ពីឆ្នាំ១៩៩៧ ដល់ ២០០១ ........ ៤៥
ក្រាហ្វិក ២.២ : ការបែងចែកការងាររវាងតំបន់ទីក្រុង និងជនបទ នៅឆ្នាំ១៩៩៧ និងឆ្នាំ២០០១ ........ ៤៦
ក្រាហ្វិក ២.៣ : អត្រាចូលរួមក្នុងកំលាំងពលកម្មនៅក្នុងតំបន់ ........ ៤៧
ក្រាហ្វិក ២.៤ : ចំនួនមនុស្សនៅក្នុងកំលាំងពលកម្ម តាមក្រុមអាយុ និង ភេទ ........ ៤៧
ក្រាហ្វិក ២.៥ : កំលាំងពលកម្មកុមារនិងយុវជន នៅក្នុងទីក្រុង/ទីប្រជុំជន និងតំបន់ជនបទ ........ ៤៨
ក្រាហ្វិក ២.៦ : ស្ថានភាពការងារ តាមភេទ និងក្រុមឧស្សាហកម្មចំបង ........ ៥០
ក្រាហ្វិក ២.៧ : អ្នកធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០១ ........ ៥១
ក្រាហ្វិក ២.៨ : ស្ថានភាពការងារក្នុងវិស័យផ្សេងៗក្រៅពីកសិកម្ម តាមទីកន្លែង និងភេទ ឆ្នាំ២០០១ ........ ៥១
ក្រាហ្វិក ២.៩: ភាគរយនៃកំលាំងពលកម្មក្នុងការងារមានប្រាក់កំរៃ ........ ៥២
ក្រាហ្វិក ២.១០: អត្រានារីក្នុងការងារមានប្រាក់កំរៃ ........ ៥២
ក្រាហ្វិក ២.១១: ចំនួនអ្នកមានការងារមានប្រាក់កំរៃធ្វើ ពីឆ្នាំ១៩៩៨ ដល់ ២០០១ ........ ៥៣
ក្រាហ្វិក ២.១២: ការងារតាមប្រភេទមុខរបរ ........ ៥៥
ក្រាហ្វិក ២.១៣: កំរិតវប្បធម៌កាន់តែខ្ពស់ ទទួលបានឱកាសការងារកាន់តែច្រើន ........ ៥៧
ក្រាហ្វិក ៣.១: នារីក្នុងវិស័យកសិកម្ម: ជាកសិករមានចំនួនច្រើន មន្ត្រីការិយាល័យមានចំនួនតិច ........ ៨៦
ក្រាហ្វិក ៤.១: សមភាពយេនឌ័រនៅក្នុងគ្រប់កំរិតទាំងអស់នៃការអប់រំ ........ ៩៥
ក្រាហ្វិក ៤.២: អត្រាចុះឈ្មោះចូលរៀនពិត ពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ២០០១ ........ ៩៦
ក្រាហ្វិក ៤.៣: អត្រាគង់វង្សរបស់ក្មេងប្រុស/ក្មេងស្រីនៅតាមថ្នាក់ ( ពីថ្នាក់ទី១ ដល់ថ្នាក់ទី៧) ........ ៩៨
ក្រាហ្វិក ៤.៤: អត្រាសិស្សបោះបង់ចោលការសិក្សានៅកំរិតមធ្យមសិក្សាបឋមភូមិ ........ ៩៩
ក្រាហ្វិក ៤.៥: ចំនួនសិស្សដែលបានចុះឈ្មោះនៅកំរិតមធ្យមសិក្សាទុតិយភូមិ ........ ១០០
ក្រាហ្វិក ៤.៦: ការប្រៀបធៀបអត្រាក្មេងប្រុស ជាមួយនឹងក្មេងស្រី ទៅតាមតំបន់ ........ ១០១
ក្រាហ្វិក ៤.៧: អត្រាចុះឈ្មោះចូលរៀនពិត នៅកំរិតមធ្យមសិក្សាទុតិយភូមិ ........ ១០២
ក្រាហ្វិក ៤.៨: សមាមាត្រសិស្សនារី នៅកំរិតឧត្តមសិក្សា ........ ១០៥
ក្រាហ្វិក ៤.៩: អត្រាអក្ខរកម្ម បែងចែកតាមអាយុ ........ ១០៦

ក្រាហ្វិក ៥.១: លទ្ធភាពទទួលបានសេវាថែទាំសុខភាពរបស់នារី តាមកំរិតនៃប្រាក់ចំណូល.......................... ១១៨
ក្រាហ្វិក ៥.២: លទ្ធភាពទទួលបានសេវាសុខភាព ទៅតាមកំរិតសិក្សារបស់នារី ...................................... ១១៩
ក្រាហ្វិក ៥.៣: ការប្រៀបធៀបអត្រាមរណៈភាពមាតា និងទារកនៅក្នុងតំបន់....................................... ១២០
ក្រាហ្វិក ៥.៤: ស្ថានភាពអាហារូបត្ថម្ភរបស់នារីសំរាប់សូចនាករមួយចំនួន............................................... ១២២
រូបភាព ៥.៥: អត្រាកំណើតសរុប បែងចែកទៅតាមខេត្ត ......................................................................... ១២៣
រូបភាព ៥.៦: ការប្រើប្រាស់មធ្យោបាយពន្យារកំណើត បែងចែកទៅតាមខេត្ត ........................................ ១២៤
រូបភាព ៥.៧: ការសំរាលកូន ដែលមានជំនួយពីឆ្មបជំនាញ ................................................................ ១២៦
ក្រាហ្វិក ៦.១: អត្រាមនុស្សពេញវ័យឆ្លងមេរោគអេដស៍ ..................................................................១៣៤
ក្រាហ្វិក ៦.២: ចំនួននារីដែលឆ្លងមេរោគអេដស៍...............................................................................១៣៥
ក្រាហ្វិក ៦.៣: ចំនួនបុរសដែលឆ្លងមេរោគអេដស៍ ...........................................................................១៣៥
ក្រាហ្វិក ៦.៤: អត្រាឆ្លងមេរោគអេដស៍ និងការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមនារីរកស៊ីផ្លូវភេទផ្ទាល់ . ១៣៧
ក្រាហ្វិក ៦.៥: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីដែលទទួលការថែរក្សាគភ៌ ........................១៣៨
ក្រាហ្វិក ៦.៦: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងតំបន់ ក្នុងចំណោមនារីមានផ្ទៃពោះដែលទទួលការថែរក្សាគភ៌.. ១៣៨
ក្រាហ្វិក ៦.៧: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីមានផ្ទៃពោះ ............................................ ១៣៩
ក្រាហ្វិក ៦.៨: ផ្លូវនៃការចំលងមេរោគអេដស៍ទៅតាមពេលវេលា ....................................................... ១៣៩
ក្រាហ្វិក ៨.១ : ភាគរយរបស់នារីនៅក្នុងរដ្ឋសភា នៅក្នុងតំបន់នាឆ្នាំ២០០២...........................................១៦៣
ក្រាហ្វិក ៨.២ : នារីជាសមាជិកសភា តាំងពីឆ្នាំ១៩៩៣ មក ............................................................... ១៦៤
ក្រាហ្វិក ៨.៣: ភាគរយនៃបេក្ខភាពនារីនៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្រ្ត ខែកក្កដា ឆ្នាំ២០០៣
នៅតាមខេត្ត-ក្រុង (គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សហ្វ៊ុនស៊ិនប៉ិច) ..... ១៦៥
ក្រាហ្វិក ៨.៤ : បេក្ខភាពនារីតាមតំណែងក្នុងបញ្ជីគណបក្ស ខែមិថុនា ឆ្នាំ២០០៣.................................... ១៦៧
ក្រាហ្វិក ៨.៥: នារីក្នុងមុខតំណែងចាត់តាំងដោយគណបក្សនយោបាយ នៅថ្នាក់ជាតិ ................................១៦៩
ក្រាហ្វិក ៨.៦: ការប៉ាន់ប្រមាណអំពីចំនួននារីនៅក្នុងតំណែងមន្រ្តីរាជការជាន់ខ្ពស់ នៅឆ្នាំ២០០៣ ................ ១៧១
ក្រាហ្វិក ៨.៧ : ការប្រៀបធៀបបុរស និងនារីដែលមានកំរិតវប្បធម៌ថ្នាក់ឧត្តមសិក្សា នៅក្នុងកំលាំងពលកម្ម. ១៧៣
ក្រាហ្វិក ៨.៨ : ការចូលរួមរបស់បុរស និងនារីនៅក្នុងវគ្គបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ............ ១៧៦
ក្រាហ្វិក ៨.៩ : ការចូលរួមរបស់បុរស និងនារីនៅក្នុងវគ្គបណ្តុះបណ្តាលបន្តនៅសាលាភូមិន្ទរដ្ឋបាល............... ១៧៦

# តារាង


តារាង ២.១ : កំលាំងពលកម្មតាមក្រុមអាយុ ពីឆ្នាំ១៩៩៧ ដល់ ២០០១ ........................................................ ៤៥

តារាង ២.២ : អត្រាអ្នកអត់ការងារធ្វើនៅឆ្នាំ២០០១ (%កំលាំងពលកម្ម) .................................................. ៤៩

តារាង ២.៣ : ម៉ោងធ្វើការ និងប្រាក់កំរៃនៅក្នុងឧស្សាហកម្មកាត់ដេរ នៅតាមបណ្តាប្រទេសអាស៊ានមួយចំនួន ... ៦២

តារាង ៣.១ : ការបែងចែកពលកម្មការងារយេនឌ័រ .................................................................................. ៧៧

តារាង ៤.១ : ការបែងចែកមូលនិធិចរន្តសាធារណៈ តាមអនុវិស័យ (គិតជា១០០០លានរៀល) (BILLION *RIELS*) . ១០៩

តារាង ៥.១ : កំលាំងពលកម្មរបស់ក្រសួងសុខាភិបាលនៅឆ្នាំ១៩៩៦-២០០១ ........................................... ១២៦

តារាង ៨.១ : បេក្ខភាពនារីក្នុងបញ្ជីគណបក្ស និង ភាគរយបេក្ខភាពនារី នៅតាមខេត្ត-ក្រុង ........................ ១៦៦

តារាង ៨.២ : ការបញ្ចូលនារីសមាជិករដ្ឋសភា ទៅក្នុងជួរគណៈកម្មការរដ្ឋសភា ខែមិថុនា ឆ្នាំ២០០៣ ............ ១៦៨

តារាង ៨.៣ : ស្ថានភាពរីកចំរើនក្នុងការសំរេចបានគោលដៅសមធមិយេនឌ័រនៃផែនការសកម្មភាពអភិបាលកិច្ច . ១៨២

តារាង ៩.១ : គំរោងអ្នកផ្តល់ជំនួយដែលកំពុងដំណើរការនៅក្នុងក្រសួងក.ន.អ ២០០៣-០៤ ...................... ២០៦

# ពាក្យសរសេរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ART | ការព្យាបាលប្រឆាំងនឹងមេរោគអេដស៍ |
| ASDP | កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម |
| ASEAN | សមាគមប្រជាជាតិអាស៊ីភាគអាគ្នេយ៍ (អាស៊ាន) |
| BMC | មជ្ឈមណ្ឌលគ្រប់គ្រងថវិកា |
| BMI | សន្ទស្សន៍ម៉ាសរាងកាយ |
| BSS | អង្កេតតាមដានការប្រព្រឹត្តិ |
| CAMBOW | គណៈកម្មាធិការកម្ពុជាដើម្បីស្ត្រី |
| CAR | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| CDHS | អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា (សូមមើល **NIS 2001a** នៅក្នុងបញ្ជីឯកសារយោង) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍នៅកម្ពុជា |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទំរង់រើសអើងប្រឆាំងនឹងនារីភេទ |
| CENAT | មជ្ឈមណ្ឌលជាតិកំចាត់ជំងឺរបេង និងឃ្លង់ |
| CFR | អត្រាស្លាប់ដោយករណីគ្រោះថ្នាក់ |
| CG | ក្រុមពិគ្រោះយោបល់ |
| CHDR | របាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CNCW | ក្រុមប្រឹក្សាកម្ពុជាដើម្បីស្ត្រី |
| CNIP | ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា |
| CNM | មជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ |
| CPA | កញ្ចប់សកម្មភាពបន្ថែម |
| CSD | ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច |
| CSES | អង្កេតសង្គមកិច្ច-សេដ្ឋកិច្ច កម្ពុជា |
| CSW | អ្នករកស៊ីផ្លូវភេទ |
| DFID/UK | ក្រសួងអភិវឌ្ឍន៍អន្តរជាតិ នៃចក្រភពអង់គ្លេស |
| DAFF | នាយកដ្ឋានកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| EFA | ការអប់រំសំរាប់ទាំងអស់គ្នា |
| EMIS | ប្រព័ន្ធពត៌មានគ្រប់គ្រងការអប់រំ |
| EPZs | តំបន់កែច្នៃសំរាប់ការនាំចេញ |

| | |
|---|---|
| **ESI** | ស្ថិតិនិងសូចនាករអប់រំ |
| **ESP** | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| **ESSP** | កម្មវិធីគាំទ្រវិស័យអប់រំ |
| **FAO** | អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ |
| **FDI** | ការវិនិយោគផ្ទាល់ពីបរទេស |
| **FFW** | អង្គុរពលកម្ម |
| **FPL** | បន្ទាត់ភាពក្រីក្រស្បៀង |
| **GAD/C** | យេនឌ័រ និង កិច្ចអភិវឌ្ឍន៍ នៅកម្ពុជា |
| **GAP** | ផែនការសកម្មភាពអភិបាលកិច្ច |
| **GDI** | សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទងនឹងយេនឌ័រ |
| **GDP** | ផលិតផលក្នុងស្រុកសរុប |
| **GEM** | រង្វាស់សិទ្ធិអំណាចយេនឌ័រ |
| **GNP** | ផលិតផលជាតិសរុប |
| **GS-CSD** | អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច |
| **GSNA** | អគ្គលេខាធិការដ្ឋានរដ្ឋសភា |
| **GTZ** | សហប្រតិបត្តិការបច្ចេកទេសរបស់អាល្លឺម៉ង់ |
| **HC** | មណ្ឌលសុខភាព |
| **HDI** | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស |
| **HIV/AIDS** | វីរុសដែលបំផ្លាញប្រព័ន្ធភាពស៊ាំនៃរាងកាយមនុស្ស/សហរោគសញ្ញានៃការចុះខ្សោយប្រព័ន្ធភាពស៊ាំរបស់មនុស្ស |
| **HP** | ប្រៃសណីយ៍ផ្នែកសុខភាព |
| **HPI** | សន្ទស្សន៍ភាពក្រីក្រមនុស្ស |
| **IDA** | ជំងឺស្លេកស្លាំងខ្វះជាតិដែក |
| **IEC** | ពត៌មាន អប់រំ និងគមនាគមន៍ |
| **IPRSP** | ឯកសារបណ្តោះអាសន្នស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ |
| **ISIC** | បទដ្ឋានអន្តរជាតិនៃចំណាត់ថ្នាក់ឧស្សាហកម្ម |
| **ITN** | បណ្តាញព្យាបាលដោយប្រើថ្នាំកំចាត់សត្វល្អិត |
| **KAPE** | សមាគមកម្ពុជាសំរាប់ការអប់រំនៅបឋមសិក្សា |
| **LFS** | អង្កេតកំលាំងពលកម្ម (សូមមើល NIS 2001b និង NIS 2002 នៅក្នុងបញ្ជីឯកសារយោង) |
| **MAFF** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MDGs** | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| **MIME** | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| **MLMUPC** | ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ |

| | |
|---|---|
| **MMR** | អត្រាមរណភាពរបស់មាតា |
| **MoC** | ក្រសួងពាណិជ្ជកម្ម |
| **MoE** | ក្រសួងបរិស្ថាន |
| **MoEYS** | ក្រសួងអប់រំ យុវជន និងកីឡា |
| **MoH** | ក្រសួងសុខាភិបាល |
| **MoI** | ក្រសួងមហាផ្ទៃ |
| **MoP** | ក្រសួងផែនការ |
| **MoRD** | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **MoSALVY** | ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា |
| **MoWVA** | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន |
| **MPA** | កញ្ចប់សកម្មភាពអប្បបរមា |
| **MTCT** | ការចំលងពីម្តាយទៅកូន |
| **MTEF** | ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម |
| **MTEP** | ផែនការចំណាយរយៈពេលមធ្យម |
| **NAA** | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| **NCHADS** | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ |
| **NFE** | អប់រំក្រៅប្រព័ន្ធ |
| **NGOs** | អង្គការក្រៅរដ្ឋាភិបាល |
| **NHS** | អង្កេតសុខភាពជាតិ |
| **NIS** | វិទ្យាស្ថានជាតិស្ថិតិ |
| **NMC** | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| **NPF** | វេទិកាជាតិស្តីពីភាពក្រីក្រ |
| **NPRS** | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| **OD** | ស្រុកប្រតិបត្តិ |
| **ODA** | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| **OSE** | ការិយាល័យអប់រំពិសេស |
| **PAPs** | កម្មវិធីសកម្មភាពជាអាទិភាព |
| **PC6-14OS** | សមាមាត្រកុមារអាយុ ៦-១៤ឆ្នាំ មិនបានចូលរៀន |
| **PDWVA** | មន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត |
| **PER** | ការត្រួតពិនិត្យចំណាយសាធារណៈ |
| **PGER** | អត្រាចុះឈ្មោះចូលរៀនសរុបនៅបឋមសិក្សា |
| **PLWHA** | អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ |
| **PMATU** | អង្គភាពបច្ចេកទេសត្រួតពិនិត្យ និងវិភាគភាពក្រីក្រ |

| | |
|---|---|
| **PPA** | ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម |
| **PRSP** | ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ |
| **PIR** | ផលធៀបសិស្សនិងគ្រូ |
| **PVI** | សូចនាករភាពក្រីក្រនិងភាពងាយរងគ្រោះ |
| **RAU** | សកលវិទ្យាល័យភូមិន្ទកសិកម្ម |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **RLFM** | ផលធៀបមនុស្សស្រីនិងប្រុសដែលចេះអក្សរ |
| **RSA** | សាលាភូមិន្ទរដ្ឋបាល |
| **RWSS** | យុទ្ធសាស្ត្រទឹកស្អាតនិងអនាម័យនៅជនបទ |
| **SEDPII** | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី ២ |
| **SPQ** | ចំណែកបញ្ចភាគក្រីក្របំផុត |
| **STD** | ជំងឺកាមរោគ |
| **STI** | ការឆ្លងជំងឺកាមរោគ |
| **SWOT** | ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង |
| **TB** | ជំងឺរបេង |
| **TBA** | ឆ្មបបូរាណ |
| **TTC** | សាលាគរុកោសល្យ |
| **TVET** | អប់រំបច្ចេកទេស  និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **UNCT** | ក្រុមប្រទេសនៃប្រព័ន្ធសហប្រជាជាតិ |
| **UNDP** | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| **UNESCO** | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃអង្គការសហប្រជាជាតិ |
| **UNGASS** | សម័យប្រជុំពិសេសនៃមហាសន្និបាតអង្គការសហប្រជាជាតិ |
| **UNICEF** | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| **UNTAC** | អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា |
| **VCT** | ការផ្តល់ការប្រឹក្សានិងការធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត |
| **VDCs** | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| **WATSAN** | ទឹក និង អនាម័យ |
| **WFP** | កម្មវិធីស្បៀងអាហារពិភពលោក |
| **WHO** | អង្គការសុខភាពពិភពលោក |
| **WID** | ស្ត្រី និង ការអភិវឌ្ឍន៍ |
| **WTO** | អង្គការពាណិជ្ជកម្មពិភពលោក |

# ខ្លឹមសារសង្ខេប


សេចក្តីផ្តើម ..... ៣

១. បរិបទសង្គម និង វប្បធម៌ ..... ៣

២. ទស្សនៈវិស័យយេនឌ័រចំពោះទីផ្សារពលកម្ម ..... ៤

៣. នារី កសិកម្ម និង ធនធាននៅជនបទ ..... ៧

៤. គំលាតយេនឌ័រក្នុងវិស័យអប់រំ ..... ៩

៥. បញ្ហាយេនឌ័រនៅក្នុងវិស័យសុខាភិបាល ..... ១១

៦. យេនឌ័រ និង ជំងឺអេដស៍ ..... ១២

៧. អំពើហឹង្សាលើនារី ..... ១៣

៨. សំលេងរបស់នារីនៅលើឆាកនយោបាយ និង ការធ្វើសេចក្តីសំរេច ..... ១៤

៩. ក្របខ័ណ្ឌផ្លូវច្បាប់ និង ច្បាប់ ..... ១៥

១០. ស្ថាប័ន និងគោលនយោបាយលើកកំពស់សមភាពយេនឌ័រ ..... ១៥

១១. ការសន្និដ្ឋាន និង អនុសាសន៍ ..... ១៧

១១.១ បញ្ហាប្រឈមទាក់ទងនឹងការផ្តល់សិទ្ធិអំណោចសេដ្ឋកិច្ចកើនឡើង ព្រោះអត្រាមនុស្ស ពេញវ័យកាន់តែកើនឡើង ..... ១៨

១១.២ នារីជនបទពុំមានលទ្ធភាពទទួលបាននូវធនធាន និងសេវាកម្មនានា ដែលអាចជួយពួកគេ ក្នុងការកាត់បន្ថយភាពក្រីក្រ និងការធានាបាននូវសន្តិសុខស្បៀង ..... ២០

១១.៣ វិសមភាពយេនឌ័រក្នុងលទ្ធភាពទទួលបានសេវាសុខភាព និងអប់រំ គឺមានសភាពធ្ងន់ធ្ងរបំផុត ក្នុងចំណោមប្រជាជនក្រីក្រនៅតាមតំបន់ជនបទ ..... ២១

១១.៤ ប្រជាជនដែលងាយរងគ្រោះ ទទួលបានការគាំទ្រតិចតួច ហើយពុំដឹងថា ត្រូវទៅរកជំនួយនៅកន្លែងណា ..... ២២

១១.៥ ស្ថាប័នសង្គម ច្បាប់ និងនយោបាយ បន្តឱ្យមានការរើសអើងយេនឌ័រ និងភាពងាយរងគ្រោះ ..... ២៤

១១.៦ ស្ថាប័ននៅតែប្រឹងប្រែងក្នុងការបញ្ជ្រាបយេនឌ័រឱ្យមានប្រសិទ្ធិភាព ..... ២៥

# ខ្លឹមសារសង្ខេប

## សេចក្តីផ្តើម

របាយការណ៍នេះ ផ្តោតទៅលើការប៉ាន់ប្រមាណអំពី "បញ្ហា" យេនឌ័រនៅកម្ពុជា ។ ការប៉ាន់ប្រមាណនេះ ត្រូវបានធ្វើឡើង ដោយពឹងផ្អែកទៅលើការពិនិត្យមើលឡើងវិញ លើពត៌មានដែលទទួលបានពីរាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងពត៌មានទទួលបានពីការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធនានា ។ ដំណើរការប៉ាន់ប្រមាណនេះ បានធ្វើការវិភាគដំបូងតិចតួចប៉ុណ្ណោះ ដូច្នេះហើយនៅមានផ្នែកមួយចំនួនដូចជា ការផ្លាស់ប្តូរទំនាក់ទំនងយេនឌ័រ និងបញ្ហាដែលមានផលប៉ះពាល់លើបុរស ពុំទាន់បានដាក់បញ្ចូលនៅឡើយ ដោយសារកង្វះពត៌មាន ឬពេលវេលា ។

សេចក្តីព្រាងដំបូង ត្រូវបានរៀបចំឡើងដោយធនាគារពិភពលោក ដោយប្រើប្រាស់ពត៌មានដែលរាជរដ្ឋាភិបាលប្រមូលបាន និងប្រើប្រាស់នៅក្នុងការរៀបចំយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។ សេចក្តីព្រាងចុងក្រោយនៃរបាយការណ៍នេះ បានដាក់បញ្ចូលពត៌មាន និងការវិភាគបន្ថែមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងមូលនិធិសហប្រជាជាតិសំរាប់នារី (UNIFEM) ដែលបានព្រមព្រៀងសហការក្នុងការជួយរៀបចំឯកសារនេះ ឱ្យបានគ្រប់ជ្រុងជ្រោយ ។ ពត៌មាន និងទិន្នន័យដែលធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ជូននៅក្នុងជំពូកទាក់ទងនឹងកំលាំងពលកម្ម គឺជាលទ្ធផលនៃជំនួយបច្ចេកទេសដែលបានផ្តល់ដល់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ហើយពត៌មាននិងទិន្នន័យដែលកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/UNIFEM ដែលបានផ្តល់ជូនសំរាប់ជំពូកផ្សេងទៀត គឺជាលទ្ធផលនៃការងារដែលបានធ្វើជាមួយនឹងរាជរដ្ឋាភិបាល ក្នុងការកំណត់អំពីចំណុចដៅទាក់ទងនឹងយេនឌ័រ សំរាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។

## ១. បរិបទសង្គម និង វប្បធម៌

នៅឆ្នាំ២០០១ ប្រជាជនកម្ពុជាមានចំនួន ១៣.១លាននាក់ ក្នុងនោះ ៥២ភាគរយ ជានារី ហើយ ៨០ភាគរយនៃប្រជាជនសរុប រស់នៅក្នុងតំបន់ជនបទ ។ តាមការប៉ាន់ស្មានចំនួនប្រជាជននឹងកើនឡើងដល់ទៅ ១៦.៦លាននាក់នៅត្រឹមឆ្នាំ២០០៦ ។ ប្រជាជនចំនួន ៣៦ភាគរយ មានជីវភាពក្រីក្រ ហើយ ៩០ភាគរយ នៃប្រជាជនក្រីក្រ រស់នៅក្នុងតំបន់ជនបទ ។

ចំនួនទារកដែលបានកើនឡើងយ៉ាងលឿននៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ បានធ្វើឱ្យចំនួនប្រជាជនកើនឡើងយ៉ាងច្រើន ហើយឥឡូវនេះ ពួកគេឈានដល់អាយុមួយដែលចូលទៅក្នុងកំលាំងពលកម្ម និងបន្តពូជ ។ ប្រជាជន ៥៥ភាគរយ មានអាយុក្រោម២០ឆ្នាំ ទោះបីជាអត្រាកំណើតក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ បានថយចុះពី ៥.៤នាក់ មកនៅត្រឹម ៤នាក់ ក្នុងនារីម្នាក់ នៅក្នុងក្រុមអាយុ ១៥-៤៩ ក៏ដោយ ។

ផលវិបាកនៃសង្គ្រាម និងអំពើហិង្សារយៈពេល ៣០ឆ្នាំនៅកម្ពុជា បានបន្សល់ទុកនូវស្លាកស្នាមខ្ទេចខ្ទាំចំពោះបុរស និងនារីនៅទូទាំងប្រទេស ។ ធនធានសង្គមនៅកម្ពុជា ត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទីដោយរបបខ្មែរក្រហម និងសង្គ្រាមស៊ីវិលអូសបន្លាយ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ។ សព្វថ្ងៃនេះ ស្ត្រីមេម៉ាយដោយសារសង្គ្រាម និងនារីផ្សេងទៀត ត្រូវទទួលភារកិច្ចជាអ្នកគ្រប់គ្រងគ្រួសារ ដោយគ្រួសារចំនួនជាង ១/៤ (មួយភាគបួន) នៅកម្ពុជា មាននារីជាមេគ្រួសារ ។

ល័ក្ខខ័ណ្ឌមួយ ដែលបានកើតមានក្នុងរយៈពេលជាច្រើនទសវត្សរ៍នៃចលាចល ហើយឥឡូវនេះបានក្លាយជាឧបសគ្គចំពោះការអភិវឌ្ឍន៍ប្រទេសជាតិ គឺលំដាប់ឋានានុក្រមនៃសង្គមជាតិ ជាមួយសញ្ញាណនៃអំណាច និងឋានៈក្នុងសង្គមដែលកំណត់ល័ក្ខខ័ណ្ឌចំពោះទំនាក់ទំនងសង្គម និងយេនឌ័រ ។ នៅក្នុងសង្គម នារីត្រូវបានចាត់ទុកថា មានឋានៈទាបជាងបុរស ។

ទំនាក់ទំនងយេនឌ័រនៅកម្ពុជា កំពុងមានការប្រែប្រួលយ៉ាងខ្លាំង ។ ទោះបីជាបទដ្ឋាននៃការប្រព្រឹត្តិសំរាប់នារី ដែលត្រូវបានកំណត់ទៅតាមវប្បធម៌ដែលហៅថា "ច្បាប់ស្រី" បានរារាំងដល់ឱកាសរបស់នារីនៅក្រៅគ្រួសារក៏ដោយ ក៏ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងនយោបាយ កំពុងបើកចំហឱកាសថ្មីសំរាប់នារីផងដែរ ។ លើសពីនេះទៀត នៅពេលដែលនារីខ្មែរទទួលបាននូវឱកាសនេះ នារីបានក្លាយជាផ្នែកសំខាន់មួយនៃដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ។

ទន្ទឹមនឹងនេះ ក៏មានភស្តុតាងបញ្ជាក់ថា ក្នុងខណៈដែលបុរស និងនារីភាគច្រើន កំពុងជួបប្រទះនឹងភាពក្រីក្រ យេនឌ័រនៅតែមានឥទ្ធិពលនៅក្នុងបញ្ហាភាពក្រីក្រនេះដែរ ។ ការផ្លាស់ប្តូរ និងឱកាសសំរាប់យុវជនក្មេងៗ ជួនកាលមានការវិវឌ្ឍន៍យឺតជាងការផ្លាស់ប្តូរ និងឱកាសសំរាប់នារី ហើយការផ្លាស់ប្តូរតួនាទីយេនឌ័រ កំពុងតែមានផលប៉ះពាល់ទៅលើទំនាក់ទំនងរវាងបុរស និងនារី ។ ការផ្លាស់ប្តូទាំងនេះ អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសង្គម ប៉ុន្តែពុំទាន់មានការស្វែងយល់ឱ្យបានច្បាស់អំពីការផ្លាស់ប្តូទាំងនេះនៅឡើយ ។

## ២. ទស្សនៈវិស័យយេនឌ័រចំពោះទីផ្សារពលកម្ម

វិសមភាពយេនឌ័រ កំពុងរីករាលដាលនៅក្នុងទីផ្សារពលកម្មនៅព្រះរាជាណាចក្រកម្ពុជា ។ តាំងពីបូរាណកាលមកឥរិយាបថចំពោះការអប់រំរបស់ក្មេងស្រី និងមុខងារ "សមស្រប" សំរាប់នារី និងបុរស បានធ្វើឱ្យមានវិសមភាពនេះឡើង ហើយបន្តធ្វើឱ្យមានគំលាតយេនឌ័រនេះ នៅក្នុងវិស័យការងារទៀតផង ។ ការបង្កើនសមភាពយេនឌ័រ ជាកិច្ចការមួយដែលលំបាកណាស់នៅក្នុងបរិបទនៃការផ្លាស់ប្តូរទិសដៅ ទៅរកសេដ្ឋកិច្ចទីផ្សារដែលកំលាំងពលកម្ម មានការកើនឡើងយ៉ាងឆាប់រហ័ស ប៉ុន្តែឱកាសការងារថ្មីមានតិចតួច ។

បញ្ហាប្រឈមចំបងបំផុតមួយរបស់កម្ពុជា គឺការពង្រីកឱកាសការងារឱ្យបានលឿន ដើម្បីស្រូបទាញយកប្រជាពលរដ្ឋចំនួន ២៥០,០០០នាក់ក្នុងមួយឆ្នាំ ដែលកំពុងឈានចូលអាយុធ្វើការ និងចូលក្នុងទីផ្សារការងារ ។ កំលាំងពលកម្មនៅក្នុងក្រុមអាយុ ២០-២៤ឆ្នាំ តាមការប៉ាន់ស្មាននៅចន្លោះឆ្នាំ១៩៩៧ និង ២០០១ មាន ៦៦ភាគរយ ហើយចំនួនយុវជននៅក្នុងក្រុមអាយុធ្វើការ ១៥-១៩ឆ្នាំនៅក្នុងកំលាំងពលកម្ម បានកើនឡើង ៥៨ភាគរយ ។

នារីមាន៥២ភាគរយ នៃកំលាំងពលកម្មសរុប ហើយអត្រានារីចូលរួមក្នុងកំលាំងពលកម្មនៅកម្ពុជាមាន ៨២ភាគរយដែលជាចំនួនខ្ពស់ជាងគេបំផុតនៅក្នុងតំបន់ ។ នារីមានចំនួនច្រើនជាងបុរសនៅក្នុងកំលាំងពលកម្ម នៅគ្រប់ក្រុមអាយុទាំងអស់ចាប់ពី ១៥ ដល់ ៥៤ឆ្នាំ លើកលែងតែនៅក្នុងក្រុមអាយុ ២៥-២៩ឆ្នាំ ។ ដោយសារតែកំលាំងពលកម្មមានច្រើនលើសលុបនៅក្នុងតំបន់ជនបទៈ ៨៥ភាគរយ នៃកំលាំងពលកម្មសរុប រស់នៅក្នុងតំបន់ជនបទ ក្នុងឆ្នាំ២០០១ ហើយ ៥៣ភាគរយ នៃកំលាំងពលកម្មនៅតំបន់ជនបទ គឺជានារី ។

សំរាប់រយៈពេលវែង ការបង្កើនសមធម៌មិយេនឱ្យនៅក្នុងផ្នែកអប់រំក្នុងប្រព័ន្ធ គឺត្រូវការចាំបាច់ដើម្បីបង្កើនសមភាពឱកាសការងារ ។ សំខាន់ជាងនេះទៀត ដើម្បីបង្កើនឱកាសការងារសំរាប់នារីដែលកំពុងស្ថិតនៅក្នុងកំលាំងពលកម្ម តំរូវឱ្យមានការផ្តោតការយកចិត្តទុកដាក់ឱ្យបានកាន់តែខ្លាំងក្លា ទៅលើការកាត់បន្ថយគំលាតកំរិតអក្ខរកម្ម ការអប់រំ និងបង្កើនជំរើសការងារ ។

ជាមធ្យម (ដោយពិចារណាទៅលើបទពិសោធន៍ អាយុ និងការអប់រំ) ប្រាក់កំរៃរបស់បុរស ខ្ពស់ជាងប្រាក់កំរៃរបស់នារីចំនួន ៣៣ភាគរយ ។ ប្រាក់កំរៃខុសគ្នាច្រើនបំផុត កើតមានរវាងយុវជន និងនារីក្នុងក្រុមអាយុ ១៥-២៩ ដែលគ្មានកំរិតវប្បធម៌ ។ កំរិតខុសគ្នានៃប្រាក់កំរៃទៅតាមកំរិតវប្បធម៌សំរាប់បុរស គឺតិចជាងនារី ហើយបុរស និងនារីដែលមានកំរិតវប្បធម៌មធ្យមសិក្សាទុតិយភូមិ និងក្រោយមធ្យមសិក្សា អាចទទួលបានប្រាក់កំរៃសំរាប់ការងារ ៤២ភាគរយ និង ៨០ភាគរយច្រើនជាងប្រាក់កំរៃរបស់បុរស និងនារី ដែលគ្មានកំរិតវប្បធម៌ ។

ទោះបីជាពុំសូវឃើញមាននៅក្នុងស្ថិតិការងារផ្លូវការក៏ដោយ ក៏ឧស្សាហកម្មផ្លូវភេទដែលកំពុងតែរីកដុះដាលនេះ គឺជាបញ្ហាមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស ។ តាមការប៉ាន់ស្មាននៅកម្ពុជា មាននារីចំនួនរហូតដល់ទៅ ១០០,០០០នាក់ ដែលកំពុងធ្វើការនៅក្នុងឧស្សាហកម្មផ្លូវភេទ ។ ដូចនារីដទៃទៀតដែលនៅក្នុងផ្នែកមិនផ្លូវការផងដែរ នារីទាំងនេះ ងាយនឹងទទួលរងនូវការរំលោភបំពានដូចជា ការបំពារបំពានរហូតដល់ការធ្វើអាជីវកម្ម ។ ផ្នែកការងារមិនផ្លូវការមិនត្រូវបានកំណត់ដោយច្បាប់ការងារ ឬទទួលបានការការពារពីសង្គមទេ ។ នារីរកស៊ីផ្លូវភេទ ដែលភាគច្រើន ត្រូវបានគេបង្ខំ ឬលក់ឱ្យទៅប្រកបមុខរបរនេះ បណ្តាលមកពីភាពក្រីក្រនោះ មិនត្រូវបានគ្រួសារ និងសហគមន៍របស់ពួកគេរាប់រក ។

ទីផ្សារពលកម្មនៅជនបទនៃប្រទេសកម្ពុជា ត្រូវប្រេះស្រាំ និងប្រែប្រួលយ៉ាងលឿន ។ ប្រសិនបើល័ក្ខខ័ណ្ឌការងារនៅមូលដ្ឋាន មានលក្ខណៈសមស្រប និងពេញលេញ ការមករកការងារធ្វើនៅទីក្រុងក៏មានកំរិតទាបដែរ ។ នៅពេលដែលតំរូវការពលកម្មនៅក្នុងមូលដ្ឋានមានកំរិតទាប ការមករកការងារធ្វើនៅទីក្រុង គឺជាដំណោះស្រាយតែមួយគត់សំរាប់អ្នកដែលគ្មានការងារធ្វើ ។ តាមជំរឿនប្រជារាស្ត្រឆ្នាំ១៩៩៨ ទេសន្តរប្រវេសន៍ជនជាង ៨០ភាគរយ គឺជាក្រុមក្នុងអាយុធ្វើការ (១៥-៦៤ឆ្នាំ) ។ នារីដែលមករកការងារធ្វើនៅទីក្រុង មានចំនួនច្រើនជាងបុរសនៅក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ ។ ទោះជាយ៉ាងណាក៏ដោយ ចំនួននៃនារីដែលមករកការងារធ្វើនៅទីក្រុងក្នុងក្រុមអាយុ ២០-៣៩ឆ្នាំ បានធ្លាក់ចុះ ។

ទីផ្សារការងារផ្លូវការ មានការលំបាកក្នុងការស្រូបទាញកំលាំងពលកម្មថ្មី បើសិនជាគ្មានការវិនិយោគទុនថ្មីៗ ។ ការខិតខំប្រឹងប្រែងបង្កើតការងារ ដើម្បីផ្តល់នូវមុខរបរចិញ្ចឹមជីវិតឱ្យបានគ្រប់គ្រាន់ ដល់កំលាំងពលកម្មភាគច្រើន មិនត្រូវមើលតែលើផ្នែកផ្លូវការប៉ុណ្ណោះទេ ។

រាជរដ្ឋាភិបាល កំពុងធ្វើការងារជាមួយនឹងអង្គការពហុភាគីដូចជា អង្គការពាណិជ្ជកម្មពិភពលោក ធនាគារពិភពលោក សន្និសិទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD) អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ក្នុងគោលបំណងរៀបចំឱ្យមានក្របខ័ណ្ឌរួមមួយ សំរាប់ជំនួយបច្ចេកទេសទាក់ទងនឹងពាណិជ្ជកម្ម សំដៅគាំទ្រដល់ការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា ។

ទោះបីជាកសិកម្មមានសារៈសំខាន់យ៉ាងណាក៏ដោយ ក៏មានកសិករតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានលទ្ធភាពទទួលបានទុនសំភារៈ ឥណទាន ឬពត៌មានទាក់ទងនឹងបច្ចេកទេសកសិកម្ម និងទីផ្សារ ជាពិសេសសំរាប់កសិករនារី។ ផលិតភាពកសិកម្មទាប និងការកើនឡើងនូវបញ្ហាដីធ្លី បានធ្វើឱ្យកសិករភាគច្រើនដែលមានដីធ្លីតិចតួច ជួបប្រទះការលំបាកក្នុងការប្រកបរបរចិញ្ចឹមជីវិត។ លទ្ធភាពប្រើប្រាស់សេវាផ្សព្វផ្សាយកសិកម្ម ពត៌មានស្តីពីទីផ្សារ និងសេវាហិរញ្ញវត្ថុរបស់កសិករទាំងអស់នៅមានកំរិត ហើយចំពោះនារីជាកសិករ រឹតតែមានការលំបាក។

គ្រួសារដែលមាននារីជាមេគ្រួសារ ទំនងជាធ្វើការនៅក្នុងវិស័យកសិកម្ម ច្រើនជាងគ្រួសារដែលបុរសជាមេគ្រួសារ ហើយទំនងជាមិនមានដីធ្លី ឬក៏មានដីធ្លីតិចតួច។ ជិត ៨០ភាគរយ នៃកសិករទាំងនេះ ប្រកបរបរកសិកម្មលក្ខណៈគ្រួសារ។ នារីចំនួន ៥៦ភាគរយ ជាកំលាំងពលកម្មនៅក្នុងកសិកម្មលក្ខណៈគ្រួសារ និងមានកំលាំងពលកម្មចំនួន ៥៤ភាគរយ នៅក្នុងកសិកម្មសំរាប់ទីផ្សារ។ នារីភាគច្រើនធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ។

នារី មានចំនួនតិចតួចប៉ុណ្ណោះទទួលផលពីសេវាផ្សព្វផ្សាយកសិកម្ម ឬឥណទាននៅជនបទ ទោះបីជាការពិតភាគច្រើននៃកសិករ និងអ្នកធ្វើការនៅក្នុងវិស័យមិនផ្លូវការ ជានារីក៏ដោយ។ ការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្ម មិនបានផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពរបស់កសិករនារី ឬជំនាញការងារផ្សេងពីគ្នារបស់បុរស និងនារីឡើយ។

បុគ្គលិកផ្សព្វផ្សាយបច្ចេកទេសកសិកម្មភាគច្រើនគឺជាបុរស ហើយដោយសារទំនៀមទំលាប់ប្រពៃណី ធ្វើឱ្យមានការរិបាកក្នុងការទំនាក់ទំនងផ្ទាល់ជាមួយនឹងកសិករនារី។ ដោយហេតុនេះ កសិករនារីមិនទទួលបានពត៌មាន ដែលពួកគេត្រូវការ ដើម្បីកែលំអ ឬបង្កើនផលិតផល និងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។

លទ្ធភាពតិចតួចរបស់នារីក្នុងការការពារសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ ក៏មានផលប៉ះពាល់លើផលិតកម្មកសិកម្ម និងសន្តិសុខស្បៀងដែរ។ លទ្ធភាពទទួលបានដីដែលមានគុណភាព និងសិទ្ធិកាន់កាប់ដីធ្លី ដែលមានសុវត្ថិភាព គឺជាបញ្ហាចំបងមួយទាក់ទងនឹងការអភិវឌ្ឍន៍និងបញ្ហាយេនឌ័រ។ តាមការប៉ាន់ប្រមាណផ្នែកសង្គមកិច្ចនាពេលកន្លងមកថ្មី១នេះ បានឱ្យដឹងថាសិទ្ធិរបស់នារីពុំត្រូវបានគេអើពើទេ ជាពិសេសនារីជាមេគ្រួសារ ដោយសារកង្វះចំណេះដឹងអំពីសិទ្ធិកាន់កាប់ដីធ្លី និងនីតិវិធីផ្តល់សិទ្ធិកាន់កាប់ដីធ្លី។

ការផ្តល់កម្មសិទ្ធិដីក្នុងឆ្នាំ១៩៨៩ និងភាពច្របូកច្របល់ដែលជាលទ្ធផលនៃការផ្តល់កម្មសិទ្ធិដី ដោយសារដំណើរការចុះឈ្មោះមិនច្បាស់លាស់ ធ្វើឱ្យផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិនារីលើកម្មសិទ្ធិដីធ្លី ជាពិសេសនារីជាមេគ្រួសារ។ "ស្ត្រីមេម៉ាយ" ដោយសារសង្គ្រាម មានដីតិចជាងប្រជាជនទូទៅៈ ក្នុងចំណោមអ្នកមានដីទាំងអស់មាន ៨៤ភាគរយដែលមានដីធ្លីតិចជាងកន្លះហិកតា។ នារីនៅក្នុងគ្រួសារដែលបុរសជាមេគ្រួសារ ប្រឈមមុខនឹងបញ្ហាមួយចំនួន ទាក់ទងនឹងដីធ្លី។ សិទ្ធិកាន់កាប់ដីធ្លីរបស់នារី មានភាពទន់ខ្សោយ ដោយសារពួកគេមានឋានៈទាបនៅក្នុងគ្រួសារ ពីព្រោះសិទ្ធិកាន់កាប់ដីធ្លី ត្រូវស្ថិតនៅលើបុរសដែលជាមេគ្រួសារ។ ក្នុងករណីលែងលះ ប្តីប្រពន្ធស្លាប់ ឬបែកបាក់គ្រួសារ នារីអាចបាត់បង់សិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួន ដែលនាំឱ្យនារី និងកុមារធ្លាក់ខ្លួនក្រ។ ច្បាប់ភូមិបាលដែលត្រូវបានអនុម័តនៅឆ្នាំ២០០១ បានចែងអំពីវិធានការសមស្របមួយដែលធានាថា ទាំងបុរស និងនារី ត្រូវបានកំណត់ថាជាម្ចាស់កម្មសិទ្ធិដីធ្លី ប៉ុន្តែដោយសារនារីមានកំរិតវប្បធម៌ទាប ធ្វើឱ្យនារីទទួលបានពត៌មានតិចតួចទាក់ទងនឹងបញ្ហាដីធ្លី ការលក់ដូរ និងសិទ្ធិកាន់កាប់ដីធ្លី។

ការចុះឈ្មោះចូលរៀននៅបឋមសិក្សារបស់ក្មេងស្រី មកពីឃុំដែលស្ថិតក្នុងក្រុមបញ្ចភាគក្រីក្របំផុត មានអត្រាកើនឡើងខ្ពស់ជាងក្រុមណា១ទាំងអស់។ នៅឆ្នាំ២០០១ អត្រាចុះឈ្មោះចូលរៀនរបស់ក្រុមនេះគឺ ២៦ភាគរយ ដែលខ្ពស់ជាងឆ្នាំមុន។ ជាទូទៅ អត្រាកំណើននៃការចុះឈ្មោះចូលរៀនរបស់កុមារ មកពីឃុំដែលស្ថិតក្នុងឃុំក្រីក្របំផុត គឺ២៤ភាគរយ។ តាមការប្រៀបធៀបកំណើនអត្រាកុមារចុះឈ្មោះចូលរៀន មកពីឃុំដែលស្ថិតក្នុងក្រុមបញ្ចភាគមានបំផុតគឺ ៧ភាគរយ។ ទោះបីជាការចុះឈ្មោះចូលរៀន មានការរីកចំរើនក៏ដោយ ក៏អត្រាក្មេងស្រីដែលបោះបង់ចោលការសិក្សា ទំនងជាមានកំរិតខ្ពស់ជាងក្មេងប្រុស។ អត្រាក្មេងស្រីរៀនត្រួតថ្នាក់មានកំរិតខ្ពស់ ហើយវត្តមាននៅក្នុងថ្នាក់មានកំរិតទាប។

គំលាតយេនឌ័រ កើនឡើងជាលំដាប់នៅកំរិតមធ្យមសិក្សាបឋមភូមិ។ ភាគរយក្មេងស្រីដែលស្ថិតនៅក្នុងការសិក្សា ធ្លាក់ចុះពី ៥០ភាគរយ នៅបឋមសិក្សា មកនៅត្រឹម ៣៧ភាគរយ នៅមធ្យមសិក្សាបឋមភូមិ និង៣២ភាគរយ នៅមធ្យមសិក្សាទុតិយភូមិ។ នៅទូទាំងប្រទេស ការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាបឋមភូមិ គឺមាន១៩ភាគរយ ក្នុងឆ្នាំសិក្សា ២០០១-២០០២ ហើយក្មេងស្រីមានតែ ១៦ភាគរយប៉ុណ្ណោះ។ នៅតំបន់ដាច់ស្រយាល មានសិស្សតែ ១ភាគរយប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀននៅមធ្យមសិក្សាបឋមភូមិ។

អត្រាចុះឈ្មោះចូលរៀននៅមធ្យមសិក្សាទុតិយភូមិ មិនគ្រាន់តែមានកំរិតទាបប៉ុណ្ណោះទេ គឺថែមទាំងកំពុងតែថយចុះទៀតផង ហើយអត្រាចុះឈ្មោះចូលរៀនរបស់ក្មេងប្រុស ធ្លាក់ចុះយ៉ាងខ្លាំង។ នៅឆ្នាំ១៩៩៩ កុមារដែលបានចុះឈ្មោះចូលរៀនទាំងអស់មាន ៩.៣ភាគរយ ក្នុងនោះក្មេងប្រុសមាន ១១.៨ភាគរយ ហើយក្មេងស្រីមាន៦.៨ភាគរយ។ នៅឆ្នាំ២០០១ តួលេខនេះ បានធ្លាក់ចុះមកនៅត្រឹម៧.៤ភាគរយ ចំពោះកុមារទាំងអស់ ក្នុងនោះក្មេងប្រុសមាន ៩.៤ភាគរយ និងក្មេងស្រីមាន ៥.៤ភាគរយ។ គំលាតយេនឌ័រនៅក្នុងអត្រាចុះឈ្មោះចូលរៀន បានថយចុះ ដែលបណ្តាលមកពីអត្រាចុះឈ្មោះចូលរៀនរបស់ក្មេងប្រុសបានថយចុះយ៉ាងលឿន ពុំមែនបណ្តាលមកពីអត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រីកើនឡើងនោះទេ។

អត្រាអនក្ខរកម្ម មានកំរិតយ៉ាងខ្ពស់ៈ បុរស ២៩ភាគរយ និងនារី ៤៥ភាគរយ ដែលមិនចេះអាន មិនចេះសរសេរសោះ ចំណែកឯនារី ៧១ភាគរយ និងបុរស ៥០ភាគរយ ដែលចេះអាន ចេះសរសេរបានខ្លះ១។ គុណវិបត្តិដែលកើតមាននៅក្នុងប្រព័ន្ធអប់រំក្នុងប្រព័ន្ធ ក៏បានកើតមាននៅក្នុងប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ ដែលនារីទទួលបានឱកាសបណ្តុះបណ្តាល "ជំនាញរបស់នារី" តែប៉ុណ្ណោះ ដូចជាការកាត់ដេរសំលៀកបំពាក់ជាដើម។

រាជរដ្ឋាភិបាល គ្រោងនឹងដោះស្រាយបញ្ហាអតុល្យភាពយេនឌ័រ តាមរយៈការកសាងសាលារៀនមធ្យមសិក្សាបន្ថែមទៀតនៅជិតផ្ទះរបស់កុមារ ដើម្បីកុំឱ្យកុមារធ្វើដំណើរទៅសាលារៀនឆ្ងាយ ព្រមទាំងបង្កើតឱ្យមានកម្មវិធីអាហារូបករណ៍សំរាប់ក្មេងស្រីក្រីក្រ។ ទោះជាយ៉ាងណាក៏ដោយ ការប្តេជ្ញាចិត្ត និងការវិនិយោគបន្ថែម គឺត្រូវការចាំបាច់ ដើម្បីលើកកំពស់សមភាពនៅក្នុងការអប់រំ។

គំលាតយេនឌ័រក្នុងវិស័យអប់រំ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី២ និងទី៣ ដែលទាក់ទងនឹងការអប់រំ។ កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទាំងពីរ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីអប់រំសំរាប់ទាំងអស់គ្នារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណងសំរេចឱ្យបាននូវការអប់រំ

ទទួលបានជំនួយពីបុគ្គលិកសុខាភិបាលមានការបណ្ដុះបណ្ដាលត្រឹមត្រូវមានតែ ៣២ភាគរយប៉ុណ្ណោះ។ ទោះបីជាមានយុទ្ធសាស្រ្តបណ្ដុះបណ្ដាលជាមូលដ្ឋានដើម្បីបង្កើនចំនួនឆ្មបក៏ដោយ ក៏ចំនួនគិលានុបដ្ឋាក/គិលានុបដ្ឋាកយិការ និងឆ្មបនៅក្នុងប្រព័ន្ធសុខាភិបាលមានការថយចុះ។

បុរសទំនងជាស្លាប់ច្រើនជាងនារី ក្នុងអាយុចន្លោះពី ១៥ឆ្នាំ ទៅ ៤៩ឆ្នាំ។ អត្រាស្លាប់របស់បុរសក្នុងអាយុចន្លោះពី ១៥-៤៩ឆ្នាំ គឺ ៤.៨/ភាគ១០០០ ចំណែកនារីមានតែ ៣.៥/ភាគ១០០០ ប៉ុណ្ណោះ។ ចំពោះបុរស បញ្ហាសុខភាពរួមមានគ្រោះថ្នាក់ឧបត្តិហេតុក្នុងកំរិតមួយខ្ពស់។ បើប្រៀបជាមួយនារី បុរស មានគ្រោះថ្នាក់ច្រើនជាង២ដង ហើយមូលហេតុចំបងនៃគ្រោះថ្នាក់ ឬការស្លាប់នោះ គឺគ្រោះថ្នាក់ចរាចរ។ បុរសដែលពិការផ្នែកកាយសម្បទា មានចំនួនច្រើនជាងនារី ២ដងពោលគឺ គ្រោះថ្នាក់ដោយសារគ្រាប់មីន។

ក្រសួងសុខាភិបាល បានរៀបចំយុទ្ធសាស្រ្តទូទាំងវិស័យសំរាប់ឆ្នាំ២០០៣-២០០៧ ដែលផ្ដោតជាសំខាន់ទៅលើការលើកកំពស់សុខភាពមាតា និងទារក សិទ្ធិទទួលបានការថែទាំសុខភាព និងការផ្ដល់សេវាដល់ប្រជាជនក្រីក្រ។ យុទ្ធសាស្រ្តនេះទទួលស្គាល់ថា កម្ពុជានឹងមិនអាចសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទាក់ទងនឹងសុខភាពបានទេ ព្រោះថាបានកំណត់ចំណុចដៅមួយចំនួនដែលមានទំហំធំធេងពេក។ យុទ្ធសាស្រ្តវិស័យសុខាភិបាល បានលើកឡើងពីការព្រួយបារម្ភមួយចំនួនដោយផ្អែកលើទស្សនៈវិស័យយេនឌ័រ។ ទោះបីជារាជរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយ បានខិតខំប្រឹងប្រែងរួមគ្នាក្នុងការដោះស្រាយបញ្ហាសុខភាពបន្តពូជក៏ដោយ ក៏យុទ្ធសាស្រ្តរបស់វិស័យសុខាភិបាល ទំនងជា "មិនបង្ហាញអំពីបញ្ហាយេនឌ័រ" ដែលមានន័យថា គ្មានការយកចិត្តទុកដាក់អំពីភាពខុសគ្នារបស់បុរស និងនារីក្នុងការទទួលបានសេវាសុខភាពឡើយ។ លទ្ធភាពទទួលបានសេវាសុខភាពជាមូលដ្ឋាន គឺជាបញ្ហាយេនឌ័រ ដែលតំរូវឱ្យមានយុទ្ធសាស្រ្ត វិធានការ និងសូចនាករ ដែលឆ្លើយតបទៅនឹងយេនឌ័រ។

## ៦. យេនឌ័រ និង ជំងឺអេដស៍

ការរីករាលដាលនៃមេរោគអេដស៍ គឺជាការគំរាមកំហែងមួយយ៉ាងធ្ងន់ធ្ងរចំពោះការអភិវឌ្ឍន៍មនុស្សនៅកម្ពុជា។ កម្ពុជាមានអត្រាឆ្លងមេរោគហ៊ីវ/អេដស៍ខ្ពស់ជាងគេនៅអាស៊ីភាគអាគ្នេយ៍ ទោះបីជាអត្រារីករាលដាលនៃមេរោគអេដស៍មានការថយចុះក៏ដោយ។ ចាប់តាំងពីឆ្នាំ១៩៩៧ មក អត្រាឆ្លងមេរោគអេដស៍ នៅទូទាំងប្រទេសក្នុងចំណោមមនុស្សពេញវ័យ បានថយចុះជាលំដាប់ ពោលគឺពី ៣.៩ភាគរយ មកនៅត្រឹម ២.៨ភាគរយ។ ចំនួនអ្នកទើបតែឆ្លងមេរោគហ៊ីវ/អេដស៍ថ្មី បានធ្លាក់ចុះជារៀងរាល់ឆ្នាំ ក្នុងចំណោមបុរសចាប់តាំងពីឆ្នាំ១៩៩៤ មក និងក្នុងចំណោមនារីចាប់តាំងពីឆ្នាំ១៩៩៦ មក។ ចំនួនបុរស ដែលមានផ្ទុកមេរោគហ៊ីវ/អេដស៍ បាន និងកំពុងថយចុះ ចាប់តាំងពីឆ្នាំ១៩៩៧មក ចំណែកឯចំនួននារីដែលមានផ្ទុកមេរោគហ៊ីវ/អេដស៍វិញ បែរជាបន្តកើនឡើងទៅវិញ ហើយឥឡូវនេះ បានចាប់ផ្ដើមនៅថេរ។

ទោះបីជាមានការរីកចំរើន ជាពិសេសក្នុងការដោះស្រាយបញ្ហាចំលងមេរោគអេដស៍ រវាងនារីរកស៊ីផ្លូវភេទ និងអតិថិជនរបស់ពួកគេក៏ដោយ ក៏នៅមានការព្រួយបារម្ភកាន់តែខ្លាំងឡើងចំពោះកំណើនអត្រាចំលងរវាងប្តី និងប្រពន្ធ រវាងម្ដាយនិងកូន។ យុទ្ធសាស្រ្តថ្មី គឺជាតំរូវការបន្ទាន់ចំពោះមុខ សំរាប់ទប់ស្កាត់ការចំលងនៅក្នុងក្រុមមនុស្សទាំងនេះ ប៉ុន្តែជំរើសនៅ

ក្រុមអ្នកស្វែងរកការគាំទ្រមតិយេនឌ័រនៅកម្ពុជា និងជាពិសេស ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន យល់ឃើញថា ការបំបាត់ការភ័យខ្លាច និងអំពើហឹង្សានៅក្នុងផ្ទះ និងសហគមន៍ គឺជាល័ក្ខខ័ណ្ឌចាំបាច់ដំបូងមួយសំរាប់ការអភិវឌ្ឍន៍ ដែលឆ្លើយតបនឹងយេនឌ័រ ។ ហេតុដូច្នេះ កម្ពុជាបានបន្ថែមចំណុចដៅមួយទៀត ទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៣ គឺលុបបំបាត់ចោលរាល់ទម្រង់នៃអំពើហឹង្សាលើនារីៈ អំពើហឹង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការជួញដូរផ្លូវភេទ ។

ដើម្បីសំរេចចំណុចដៅនេះ ចាំបាច់ត្រូវមានអន្តរាគមន៍បី ។ **ទីមួយៈ** ការបង្កើតឱ្យមានក្របខ័ណ្ឌច្បាប់ គឺជាកត្តាចាំបាច់ណាស់ ប៉ុន្តែក្របខ័ណ្ឌច្បាប់អាចនឹងមិនមានប្រសិទ្ធិភាព ហើយអាចនឹងបញ្ជូនសារខុស ប្រសិនបើគេមិនបានអនុវត្តវាឱ្យបានត្រឹមត្រូវទេនោះ ។ មានតែការបង្កើតច្បាប់ដែលអាចអនុវត្តបាន និងការផ្សព្វផ្សាយច្បាប់នេះឱ្យបានទូលំទូលាយប៉ុណ្ណោះ ដែលនឹងអាចយកឈ្នះលើវប្បធម៌មិនយកទោសបាន ។

**ទីពីរៈ** ជាការចាំបាច់ត្រូវមានវិធានការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ការរំលោភសន្ថវៈ និងការជួញដូរមនុស្ស រួមទាំងផែនការសកម្មភាពទប់ស្កាត់ ការកែសំរួលកម្មវិធីសិក្សាដើម្បីដាក់បញ្ចូលបញ្ហាទាំងនេះ ការរៀបចំកម្មវិធីនៅថ្នាក់ឃុំ-សង្កាត់ សំរាប់ទប់ស្កាត់អំពើហឹង្សាលើនារី និងការអប់រំតាមរូបភាពផ្សេងទៀតនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ។

**ទីបីៈ** សមាហរណកម្មសង្គម និងសេដ្ឋកិច្ច និងការស្តារនីតិសម្បទាជនរងគ្រោះ ត្រូវតែដោះស្រាយឱ្យបាន ។ ការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាល និងបុគ្គលិកផ្នែកសង្គមកិច្ច ដើម្បីផ្តល់ការប្រឹក្សាដល់ជនរងគ្រោះ ដែលការបណ្តុះបណ្តាលនេះទើបតែចាប់ផ្តើមនៅកម្ពុជា ដូច្នេះគួរតែពង្រីកឱ្យបានទូលំទូលាយ ។ បច្ចុប្បន្នសេវាសំរាប់ជនរងគ្រោះ អន្តរាគមន៍នៅក្នុងសហគមន៍ ដើម្បីធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរចូលទៅក្នុងសហគមន៍ ការបណ្តុះបណ្តាលជំនាញដល់អតីតនារីរកស៊ីផ្លូវភេទ និងអន្តរាគមន៍ផ្សេងទៀត កំពុងតែដំណើរការជាលក្ខណៈសាកល្បងតែប៉ុណ្ណោះ ភាគច្រើនគឺតាមរយៈអង្គការក្រៅរដ្ឋាភិបាល ។ សកម្មភាពទាំងនេះ ចាំបាច់ត្រូវពង្រីកបន្ថែម និងយកទៅអនុវត្តបន្តទៀត ។

## ៨. សំលេងរបស់នារីនៅលើឆាកនយោបាយ និង ការធ្វើសេចក្តីសំរេច

ការវាស់ស្ទង់អំពីការផ្តល់អំណាចយេនឌ័រនៅកម្ពុជា បង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសដែលមានកំរិតនៃការផ្តល់អំណាចយេនឌ័រទាបបំផុតនៅអាស៊ី នេះឆ្លុះបញ្ចាំងឱ្យឃើញថា នារីមានតំណាងទាបនៅក្នុងជួររាជរដ្ឋាភិបាល និងរដ្ឋសភា ប៉ុន្តែរហូតមកដល់ពេលនេះ មានការរីកចំរើនខ្លះៗលើការបែងចែកអំណាចយេនឌ័រ ។ បន្ទាប់ពីការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្នុងចំណោមរដ្ឋមន្ត្រីចំនួន ២៥រូប មាននារី ២រូប ហើយក្នុងចំណោមរដ្ឋលេខាធិការចំនួន ៥០រូប មាននារី ៤រូប ។ នេះគឺជាការរីកចំរើនមួយ បើប្រៀបធៀបជាមួយនឹងរាជរដ្ឋាភិបាលឆ្នាំ១៩៩៣-១៩៩៧ ដែលមាននារីតែ ៤រូបប៉ុណ្ណោះ នៅក្នុងមុខតំណែងដែលត្រូវតែងតាំង ដោយគណបក្សនយោបាយ ហើយនៅក្នុងមុខតំណែង រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬអភិបាលខេត្ត-ក្រុង គ្មាននារីទេ ។ នៅក្នុងការបោះឆ្នោតឆ្នាំ២០០៣ នារីចំនួន១៩រូប (១២ភាគរយ) ត្រូវបានជាប់ឆ្នោតជាសមាជិកសភា ក្នុងចំណោមសមាជិកសភាទាំងអស់ចំនួន១២៣រូប ។

ការបញ្ជ្រាបយេនឌ័រទៅក្នុងក្រសួងនានា ទំនងជាដំណើរបានដោយមានការជំរុញពីអ្នកផ្តល់ជំនួយ ឬដំណើរការដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ប៉ុន្តែក្រសួងដែលជាអ្នកប្រតិបត្តិផ្ទាល់ មានភាពម្ចាស់ការតិចតួច ។ ទោះបីជាក្រសួងមួយចំនួន មានការយល់ដឹងខ្ពស់អំពីតម្រូវការក្នុងការដោះស្រាយបញ្ហាយេនឌ័រ ប៉ុន្តែក្រសួងទាំងនោះ ពុំទាន់មានសមត្ថភាពក្នុងការអនុវត្តន៍កិច្ចការនេះនៅឡើយ ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបានបង្កើតឡើងនៅខែ មីនា ឆ្នាំ២០០១ ហើយមានភារកិច្ចក្នុងការធ្វើការតស៊ូមតិ ការពិនិត្យតាមដាន និងការវាយតំលៃលើច្បាប់ បទបញ្ញត្តិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើទស្សនៈយេនឌ័រ ព្រមទាំងធ្វើការពិនិត្យតាមដានលើការអនុវត្តន៍អនុសញ្ញាអន្តរជាតិនានា ។ ក្រុមប្រឹក្សានេះ មានសមាជិកដែលជារដ្ឋលេខាធិការ មកពីក្រសួងចំនួន ១៤ ដូច្នេះ ក្រុមប្រឹក្សានេះមានសក្តានុពលក្នុងការមានឥទ្ធិពលទៅលើការរៀបចំ និងការអនុវត្តន៍គោលនយោបាយ និងកម្មវិធីដែលឆ្លើយតបទៅនឹងយេនឌ័រនៅតាមបណ្តាក្រសួងទាំងនេះ ។

តាមរយៈដំណើរការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ទទួលបានឱកាសជាច្រើនក្នុងការផ្តល់ទិន្នន័យសំរាប់ការរៀបចំយុទ្ធសាស្ត្រជាតិ ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក៏បានផ្តល់ទិន្នន័យជាច្រើន ទាក់ទងនឹងយេនឌ័រដែរ ។ ប៉ុន្តែការបញ្ចូលយេនឌ័រទៅក្នុងគោលនយោបាយ គឺមិនដូចគ្នា នៅគ្រប់ផ្នែកទាំងអស់ទេ ឧទាហរណ៍ៈ សិទ្ធិកាន់កាប់ដីធ្លី កំណែទំរង់វិស័យច្បាប់ និងអភិបាលកិច្ច ផ្តោតការយកចិត្តទុកដាក់តិចតួចលើបញ្ហាយេនឌ័រ ។ ការបន្តតួនាទីរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការពិនិត្យតាមដាន លើការអនុវត្តន៍យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ នឹងជាបញ្ហាប្រឈមមុខមួយ ។

ផែនការសកម្មភាពស្តីពីអភិបាលកិច្ច ដែលត្រូវបានបោះពុម្ពផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០០១ បានដាក់បញ្ចូលសមធម៌យេនឌ័រ ជាផ្នែកមួយនៃផ្នែកអន្តរវិស័យទាំង៥ និងបានកំណត់អំពីទិសដៅសមធម៌យេនឌ័រ ដែលមានលក្ខណៈទូលំទូលាយចំនួន៤ គឺៈ

១) ដើម្បីអនុវត្ត និងសំរបសំរួលកម្មវិធី សំដៅលើកកំពស់សិទ្ធិរបស់នារីនិងកុមារ ។

២) ដើម្បីមានឥទ្ធិពលទៅលើកម្មវិធីកំណែទំរង់នានា ដើម្បីឱ្យកម្មវិធីទាំងនោះពិចារណាឱ្យបានល្អិតល្អន់ ទៅលើតំរូវការដោយឡែករបស់នារី និងកុមារ ។

៣) ដើម្បីទទួលស្គាល់ការរួមចំណែករបស់នារីជាសមាជិកពេញសិទ្ធិរបស់សង្គមជាតិ និង

៤) ដើម្បីវិនិយោគលើការលើកកំពស់តួនាទីដឹកនាំរបស់នារី ។ មានការរីកចំរើនលើវិស័យមួយចំនួន ប៉ុន្តែពុំទាន់បានបង្កើនចំនួននារីនៅក្នុងមុខតំណែងជាអ្នកធ្វើសេចក្តីសំរេចនៅឡើយ ។

ដើម្បីធ្វើការបញ្ជ្រាបយេនឌ័រទៅក្នុងក្រសួងពាក់ព័ន្ធ គឺត្រូវការពេលវេលាយូរ ។ ទាក់ទងនឹងអាទិភាព និងតំរូវការចំពោះមុខផ្សេងៗទៀត បញ្ហាយេនឌ័រមិនត្រូវបានគេឱ្យអាទិភាព ហើយការងារយេនឌ័រ ភាគច្រើនត្រូវបានដំណើរការដោយសារអ្នកផ្តល់ជំនួយជាអ្នកជំរុញ ។ ក្រសួងអប់រំយុវជន និងកីឡា គឺជាក្រសួងតែមួយគត់ ដែលមានយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ខ្លួនផ្ទាល់ ចំណែកឯជំនាញ និងសមត្ថភាពរបស់ក្រសួងដទៃទៀត ក្នុងការរៀបចំ និងក្នុងការអនុវត្តន៍ការងារ

បញ្ហាប្រឈមចំបងមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីសំរេចឱ្យបាននូវសមភាពយេនឌ័រនៅកម្ពុជា ត្រូវបានបង្ហាញជូននៅក្នុងជំពូកនេះ ជាមួយនឹងអនុសាសន៍សំរាប់ជួយដល់ការកំណត់អាទិភាពសកម្មភាព ដែលត្រូវអនុវត្តដើម្បីដោះស្រាយបញ្ហាទាំងនោះ ។

## ១១.១ បញ្ហាប្រឈមទាក់ទងនឹងការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចកើនឡើង ព្រោះអត្រាមនុស្សពេញវ័យកាន់តែកើនឡើង

### ចាំបាច់ត្រូវបង្កើតការងារផ្លូវការដែលមានប្រាក់កំរៃជាបន្ទាន់ ដើម្បីស្រូបទាញយកកំលាំងពលកម្មដែលកំពុងកើនឡើង

កំលាំងពលកម្ម កំពុងតែកើនឡើងក្នុងអត្រា ៣.៥ភាគរយ (ឬមួយភាគបួននៃប្រជាជនចំនួន ១លាននាក់) ក្នុង១ឆ្នាំ ប៉ុន្តែការងារដែលមានប្រាក់កំរៃមានតិចតួចណាស់ និងពុំអាចឆ្លើយតបទៅនឹងកំណើននៃកំលាំងពលកម្មបានឡើយ ។ លទ្ធភាពរបស់ប្រទេសក្នុងការទាក់ទាញវិនិយោគបរទេស គឺជាបញ្ហាសំខាន់ ប៉ុន្តែថ្មីៗនេះ មានការបង្ហាញឱ្យឃើញថា មានការថយចុះនូវការវិនិយោគដោយផ្ទាល់ពីបរទេស ។ អភិបាលកិច្ចទន់ខ្សោយ និងការរីករាលដាលនៃអំពើពុករលួយ គឺជាបញ្ហាចំបងដែលបង្អាក់ទឹកចិត្តរបស់អ្នកវិនិយោគ ។

### ជំរើសការងារផ្លូវការមួយចំនួនធំ ជាតំរូវការចាំបាច់សំរាប់បុរស និង នារី

នៅពេលដែលវិស័យកសិកម្មត្រូវបានផ្លាស់ប្តូរពី កសិកម្មជាលក្ខណៈគ្រួសារ ទៅជាកសិកម្មទីផ្សារ ទាំងបុរស និង នារី កំពុងឈានចូលទៅក្នុងការងារមានប្រាក់កំរៃ នៅក្នុងវិស័យនេះ ។ ក្រៅពីវិស័យកសិកម្ម មានឱកាសការងារថ្មីមួយចំនួនតូចប៉ុណ្ណោះ សំរាប់បុរសដែលជាមុខរបរតាមលក្ខណៈ "ប្រពៃណី" ដែលផ្សារភ្ជាប់ទៅនឹងការរំពឹងទុកកើនឡើង នៅក្នុងសេដ្ឋកិច្ចទីផ្សារ ដែលនេះគឺជាប្រភពនៃការខកចិត្តយ៉ាងខ្លាំង ។ ការទទួលខុសត្រូវរបស់នារីក្នុងការងារប្រកបរបរចិញ្ចឹមជីវិតនៅក្នុងការងារតាមលក្ខណៈ "ប្រពៃណី" របស់នារី កាន់តែកើនឡើង ក្នុងខណៈដែលនារីនៅតែមានការទទួលខុសត្រូវលើកិច្ចការផ្ទះ និងការថែទាំកូន ឬការមករកការងារធ្វើនៅទីក្រុង ដែលនៅទីនោះនារីនឹងងាយទទួលរងគ្រោះបំផុត ដោយសារការកេងប្រវ័ញ្ច ។ នារីពឹងផ្អែកទាំងស្រុងលើការងារមានប្រាក់កំរៃនៅក្នុងឧស្សាហកម្មកាត់ដេរ ប៉ុន្តែនេះជាការងារមិនទៀងទាត់ ហើយអនាគតនៅពុំទាន់ច្បាស់លាស់នៅឡើយ ។ ប្រសិនបើឧស្សាហកម្មកាត់ដេរនេះត្រូវបរាជ័យ លទ្ធផលដែលនារីទទួលបានក្នុងវិស័យការងារមានប្រាក់កំរៃ នឹងត្រូវបាត់បង់ទៅវិញ ។ ស្របពេលជាមួយគ្នានេះផងដែរ ឧស្សាហកម្មកាត់ដេរនេះ ពុំបានផ្តល់ការងារដល់យុវជនក្មេងៗទេ ហើយបុរសដែលមានវ័យក្មេង ពុំចូលចិត្តធ្វើការងារនៅក្នុងវិស័យសាធារណៈដែលជាការងាររបស់ "បុរស" ទៀតឡើយ ។ ដោយសារការកាត់រំសាយទ័ព កំណែទម្រង់រដ្ឋបាល និងការធ្វើឯកជនភាវូបនីយកម្មសេវាកម្ម ធ្វើឱ្យឱកាសការងារនៅក្នុងវិស័យសាធារណៈធ្លាក់ចុះ ។ ភាពអត់ការងារធ្វើ គឺជាកត្តាសំខាន់ដែលបណ្តាលឱ្យមានអសន្តិសុខ និងអស្ថេរភាពសង្គម ដូច្នេះសង្គមនឹងត្រូវប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរ បើសិនជាមនុស្សវ័យក្មេង ជាពិសេសយុវជន ពុំអាចរកការងារមានប្រាក់កំរៃធ្វើបាន ។

## ១១.២ នារីជនបទពុំមានលទ្ធភាពទទួលបាននូវធនធាន និងសេវាកម្មនានា ដែលអាចជួយពួកគេក្នុងការកាត់បន្ថយភាពក្រីក្រ និងការធានាបាននូវសន្តិសុខស្បៀង

### ភាគច្រើននៃកសិករនៅកម្ពុជា គឺជានារី ដែលពុំមានលទ្ធភាពទទួលបានធនធានដែលពួកគាត់ត្រូវការ

ក្រៅពីការងារផ្លូវការ ចំនួនអ្នកមានការងារធ្វើដែលកើនឡើង ៨០ភាគរយ នៅចន្លោះពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៩ ដែលស្មើនឹង ១.២៨លាននាក់ ហើយក្នុងនោះ ៥៣ភាគរយ ជានារី នៅក្នុងវិស័យកសិកម្ម និងនេសាទ។ ប្រសិនបើនិន្នាការនេះ បន្តកើនឡើង ពេលនោះសេវាកម្មនានា (ប្រឹក្សាយោបល់ ទីផ្សារ និងបច្ចេកវិទ្យា) និងធនធានផ្សេងៗ (ឥណទាន ជីធ្លី ទុន) សំរាប់កសិករដែលភាគច្រើនជានារី ចាំបាច់ត្រូវពង្រីក និងធ្វើឱ្យកាន់តែល្អប្រសើរជាងមុន។ តាមធម្មតា នារីមានលទ្ធភាពទាបជាងបុរស ក្នុងការទទួលបានសេវាផ្សព្វផ្សាយជីធ្លី និងធនធានផ្សេងទៀត។ នារីហាក់ដូចជាចូលរួមច្រើនជាងបុរស នៅក្នុងការងារកែច្នៃម្ហូបពីផលិតផលកសិកម្ម អាជីវកម្ម ចិញ្ចឹមសត្វ និងសកម្មភាពផ្សេងៗទៀត សំរាប់ការនាំចេញ។

### សេវាកម្មជាមូលដ្ឋានដូចជា ផ្លូវថ្នល់ និងការផ្គត់ផ្គង់ទឹក គឺជាអាទិភាពសំរាប់នារីក្រីក្រ និងបុរសក្រីក្រ

ការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន មានផលប៉ះពាល់យ៉ាងខ្លាំងនៅក្នុងសង្គម។ ការទៅរែក/ដឹកទឹក គ្រាន់តែជាបន្ទុកលើពេលវេលារបស់នារីប៉ុណ្ណោះទេ ប៉ុន្តែការខ្វះខាតទឹកស្អាតសំរាប់ប្រើប្រាស់ គឺធ្វើឱ្យមានបញ្ហាសុខភាព និងបណ្តាលឱ្យតួលេខនៃមរណភាពមាតា និងកុមារមានសភាពធ្ងន់ធ្ងរ។ ការផ្តល់ទឹកស្អាតសំរាប់ប្រើប្រាស់ ធ្វើឱ្យក្មេងស្រីមានឱកាសបានទៅសាលារៀន ហើយផ្លូវថ្នល់ល្អ នឹងជួយបង្កើនលទ្ធភាពក្នុងការធ្វើដំណើរទៅសាលារៀន និងមជ្ឈមណ្ឌលសុខភាព។

### អនុសាសន៍

- ចាំបាច់ត្រូវបង្កើតវិធីថ្មីៗ ក្នុងការផ្តល់សេវាកម្ម ការផ្សព្វផ្សាយ និងព័ត៌មានកសិកម្មដល់នារី
- ផ្តល់ដល់នារីនូវលទ្ធភាពដែលមានការធានា និងមានលក្ខណៈល្អប្រសើរក្នុងការទទួលបានជីធ្លី និងធនធានធម្មជាតិ
- ចាំបាច់ត្រូវបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលបានធ្វើផែនការនៅថ្នាក់មូលដ្ឋាន ដើម្បីទទួលស្គាល់ និងដោះស្រាយតម្រូវការរបស់បុរស និងនារី។

## ១១.៤ ប្រជាជនដែលងាយរងគ្រោះ ទទួលបានការគាំទ្រតិចតួច ហើយពុំដឹងថា ត្រូវទៅរកជំនួយនៅកន្លែងណា

### ការចម្លងមេរោគអេដស៍/ជំងឺអេដស៍កំពុងកាត់បន្ថយ ប៉ុន្តែការចម្លងកំពុងតែឈានទៅរកក្រុមប្រជាជនផ្សេងទៀតនៅក្នុងសង្គម

ចំនួននារី និងកុមារីកម្ពុជា កាន់តែច្រើន កំពុងប្រឈមមុខនឹងការឆ្លងជំងឺអេដស៍។ នៅក្នុងប្រទេសដែលលទ្ធភាពទាបក្នុងការទទួលបានពត៌មាន ការថែទាំ និងការគាំទ្រ និងការព្យាបាល ឥរិយាបថផ្លូវភេទរបស់បុរសដែលប្រថុយនឹងគ្រោះថ្នាក់ មានកំរិតខ្ពស់ និងបញ្ហាយេនឌ័រនៅក្នុងវប្បធម៌របស់ប្រទេសកម្ពុជា គឺធ្វើឱ្យនារីមានការលំបាកក្នុងការចរចារជាមួយបុរសឱ្យប្រើស្រោមអនាម័យ កត្តាទាំងនេះធ្វើឱ្យនារីជាអ្នកទទួលរងគ្រោះដោយសារការឆ្លងជំងឺអេដស៍។

រូបភាពនៃការចម្លងជំងឺអេដស៍កំពុងតែផ្លាស់ប្តូរៈ ប្រេវ៉ាឡង់បង្ហាញឱ្យឃើញនូវការកើនឡើងនៅក្នុងគ្រប់ក្រុមទាំងអស់ ប៉ុន្តែនៅពេលជាមួយគ្នានេះផងដែរ នារីដែលរៀបការរួច និងនារីដែលមានទំនាក់ទំនងផ្លូវភេទយូរអង្វែងនៅតែជាក្រុមដែលរងគ្រោះបំផុត និងមានការកើនឡើងយ៉ាងរហ័ស។ ការចម្លងពីម្តាយទៅទារក ពីប្តីទៅភរិយា គឺកំពុងតែកើនឡើងយ៉ាងខ្លាំង។ វិធីសាស្រ្តសំរាប់ទប់ស្កាត់ការរីករាលដាលនៅក្នុងចំណោមក្រុមរងគ្រោះទាំងនេះមានកំរិត ប៉ុន្តែត្រូវការចាំបាច់ជាបន្ទាន់។

ប្រជាជនកម្ពុជាភាគច្រើន មិនមានលទ្ធភាពទទួលថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ទេ (ART-ថ្នាំពន្យារការស្លាប់) ឬសូម្បីតែការព្យាបាលជំងឺឆ្លងផ្សេងៗទៀត ឱ្យបានទៀងទាត់ក៏គ្មានដែរ ដូចជាជំងឺរលាកសួត ជំងឺរាគរូស និងជំងឺពុលអាហារ។ ការមើលថែទាំសមាជិកគ្រួសារដែលទទួលរងគ្រោះ ដោយសារជំងឺទាំងអស់នេះ គឺជាបន្ទុកយ៉ាងធ្ងន់ធ្ងរលើពេលវេលា និងធនធានរបស់នារី ដែលធ្វើឱ្យគ្រួសារកាន់តែធ្លាក់ក្នុងសភាពក្រីក្រឡើង។ នារីទទួលបានឱកាសតិចតួចក្នុងការទទួលបានការព្យាបាល ការតាមដាន និងការពិគ្រោះយោបល់។

ការរៀបចំស្ថាប័នបច្ចុប្បន្ន អាចនឹងគ្មានប្រសិទ្ធិភាពក្នុងការទប់ស្កាត់ ពីព្រោះថាការរីករាលដាលនេះ បានប្តូរពីនារីរកស៊ីផ្លូវភេទ ទៅក្នុងក្រុមផ្សេងៗទៀតក្នុងសង្គម ព្រមទាំងគ្មានប្រសិទ្ធិភាពក្នុងការផ្សព្វផ្សាយ ឱ្យបានគ្រប់គ្រាន់អំពីការថែទាំ។

### អំពើហឹង្សាលើនារី កើតឡើងជាច្រើនរូបភាព ហើយសេវាសំរាប់ជួយជនរងគ្រោះមានតិចតួចប៉ុណ្ណោះ

នារី និងកុមារីកម្ពុជា ជាអ្នករងគ្រោះដោយសារអំពើហឹង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការបំពារបំពានផ្លូវភេទ និងការជួញដូរពលកម្ម ឬដើម្បីបំរើការងារផ្លូវភេទ។ ក្របខណ្ឌផ្លូវច្បាប់ទន់ខ្សោយ និងគ្មានប្រសិទ្ធិភាពបណ្តាលឱ្យមានវប្បធម៌មិនយកទោស ហើយសេវាកម្ម និងការគាំទ្រមិនគ្រប់គ្រាន់ធ្វើឱ្យជនរងគ្រោះ មានជំរើសតិចតួចប៉ុណ្ណោះ។

## ១១.៥. ស្ថាប័នសង្គម ច្បាប់ និងនយោបាយ បន្តឱ្យមានការរើសអើងយេនឌ័រ និងភាពងាយរងគ្រោះ

### បទដ្ឋានសង្គម និងឥរិយាបថដែលពាក់ព័ន្ធនឹងយេនឌ័រ អាចមានឥទ្ធិពលអវិជ្ជមានលើបុរស និងនារី

បទដ្ឋានសង្គម ឥរិយាបថ និងកត្តាវប្បធម៌ ជំរុញឱ្យមានការឆ្លងមេរោគអេដស៍ អំពើហិង្សាយេនឌ័រ (ការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ ការរំលោភ និងអាជីវកម្មផ្លូវភេទ) ហើយក៏ជំរុញឱ្យបុរសប្រឈមមុខនឹងភាពងាយរងគ្រោះផងដែរ ។ តួនាទី និងវិសមភាពនៅក្នុងសង្គមនៅតែបន្តកើតមាន ទោះបីជានៅក្នុងសង្គមដែលមានសេដ្ឋកិច្ចរីកចំរើនក៏ដោយ ។ ការផ្លាស់ប្តូរជាវិជ្ជមាន មិនចាំបាច់យកមកពីវប្បធម៌ខាងក្រៅឡើយ ។ នៅក្នុងសង្គមណាមួយក៏ដោយ នារី និងបុរសមានទស្សនៈខុសៗគ្នាអំពីបទដ្ឋាន និងឥរិយាបថ ។ ការស្វែងរកតុល្យភាពរវាងទស្សនៈទាំងនេះ នឹងជួយលប់បំបាត់និន្នាការអវិជ្ជមាន ។

វិសមភាពដែលបណ្តាលមកពីឥរិយាបថតាមទំនៀមទំលាប់ ចំពោះតួនាទីយេនឌ័រ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងការបែងចែកការងាររវាងនារី និងបុរស និងឋានៈតួនាទីរបស់ពួកគេនៅក្នុងឧស្សាហកម្មផ្សេងៗ ។ តាមទំនៀមទំលាប់ប្រពៃណី ក្មេងប្រុសត្រូវបានគេជំរុញលើកទឹកចិត្តឱ្យទៅសាលារៀន ដូច្នេះក្មេងប្រុសអាចមានសមត្ថភាពទទួលបានតួនាទីខ្ពស់តាមបំណងនៅក្នុងស្ថាប័នរដ្ឋាភិបាល ដូចជាការគ្រប់គ្រងរបស់បុរសនៅក្នុងជួរមន្រ្តីរាជការ និងតួនាទីជាអ្នកធ្វើសេចក្តីសំរេច ។ ការអប់រំរបស់ក្មេងស្រី ត្រូវបានគេមើលឃើញថា មិនសូវមានសារៈសំខាន់ឡើយ នៅក្នុងសង្គមកម្ពុជាដែលពឹងផ្អែកលើវិស័យកសិកម្ម ព្រោះថាក្មេងស្រីទាំងនោះ ធ្វើការតែនៅក្នុងវាលស្រែ មើលថែទាំផ្ទះ និងកូនក្មេង ហើយអាចធ្វើជាអ្នកលក់ដូរតូចតាចនៅក្នុងផ្សារ ឬធ្វើសិប្បកម្មនានា ។

### ការចូលរួមរបស់នារីនៅក្នុងការធ្វើសេចក្តីសំរេចនៅគ្រប់កំរិតទាំងអស់ គឺមានសារៈសំខាន់ក្នុងការនាំមកនូវការរីកចំរើន

ការចូលរួមរបស់នារីនៅមានចំនួនតិចតួច នៅក្នុងគ្រប់កំរិតទាំងអស់នៃការធ្វើសេចក្តីសំរេចៈ ក្នុងស្ថាប័នរដ្ឋាភិបាល រដ្ឋសភា តុលាការ និងនៅថ្នាក់ឃុំសង្កាត់ និងភូមិ ។ លុះត្រាណាការចូលរួមរបស់នារី ពុំកើនឡើងទេនោះ បរិដ្ឋានសង្គម និងការទទួលខុសត្រូវដើម្បីសមភាពយេនឌ័រ នឹងពុំមានការផ្លាស់ប្តូរឡើយ ។ រដ្ឋាភិបាលបានដាក់ចេញនូវគោលដៅយ៉ាងខ្ពស់សំរាប់នារី នៅក្នុងតួនាទីជាអ្នកធ្វើសេចក្តីសំរេច ដែលរដ្ឋាភិបាលទំនងជាពុំអាចនឹងទទួលបានជោគជ័យឡើយ ។

### ប្រព័ន្ធតុលាការ និងស្ថាប័នអនុវត្តច្បាប់ ចាំបាច់ត្រូវមានការទទួលខុសត្រូវ តាមរយៈការបង្កើន ការត្រួតពិនិត្យ និងធ្វើរបាយការណ៍អំពីសកម្មភាពរបស់ខ្លួន

ទោះបីជាបច្ចុប្បន្នមានក្របខ័ណ្ឌផ្លូវច្បាប់សមរម្យ ដើម្បីលើកស្ទួយសិទ្ធិនារី ប៉ុន្តែការអនុវត្តន៍ច្បាប់ នៅទន់ខ្សោយ វប្បធម៌មិនយកទោសចំពោះជនល្មើសដែលត្រូវចោទប្រកាន់ និងការជ្រុំគំនិតរបស់អ្នកអនុវត្តន៍ច្បាប់ ធ្វើឱ្យប្រជាជនក្រីក្រ ជាពិសេសនារី កាន់តែងាយទទួលរងគ្រោះ ។ នៅក្នុងបរិស្ថានពុករលួយ នារីទទួលបានការគាំទ្រតិចតួចបំផុតពីប្រព័ន្ធច្បាប់ ហើយនារីមានធនធានតិចតួចបំផុត សំរាប់ដំណើរការទៅតាមផ្លូវច្បាប់ ។

## សមត្ថភាពរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រប្រកបដោយនិរន្តរភាពទៅក្នុងដំណើរការរៀបចំគោលនយោបាយនៅទន់ខ្សោយ

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានដំណើរការជាជំហាន១ក្នុងការបង្កើតបណ្តាញការងារ នៅក្នុងក្រសួងពាក់ព័ន្ធតាមវិស័យ ប៉ុន្តែជនបង្គោលយេនឌ័រដែលបានជ្រើសរើស មានតួនាទីទាប និងពុំសូវមានឥទ្ធិពល។ ទោះបីជាជនបង្គោលយេនឌ័រទាំងនោះ ទទួលបានឱកាសចូលរួមក្នុងការពិភាក្សាអំពីគោលនយោបាយ ប៉ុន្តែសមត្ថភាពរបស់ពួកគេក្នុងការធ្វើឱ្យមានឥទ្ធិពលប្រកបដោយប្រសិទ្ធិភាព គឺនៅមានកំរិត ដោយសារពុំទាន់មានសមត្ថភាពក្នុងការវិភាគ និងត្រួតពិនិត្យផលប៉ះពាល់របស់គោលនយោបាយ និងច្បាប់នានា និងសមត្ថភាពក្នុងការស្វែងរកការគាំទ្រមតិឱ្យមានការផ្លាស់ប្តូរ។

### អនុសាសន៍

- ត្រូវគាំទ្រយ៉ាងខ្លាំងក្លាដល់ការខិតខំប្រឹងប្រែង ដើម្បីបង្កើនការគ្រប់គ្រងការចំណាយសាធារណៈ និងបង្កើនការទទួលខុសត្រូវរបស់អ្នកផ្តល់សេវា
- បង្កើនយន្តការក្នុងការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងដំណើរការធ្វើផែនការ និងថវិកា
- បង្កើនការប្រមូល និងការវិភាគទិន្នន័យ ដើម្បីធ្វើការពិនិត្យលើគោលដៅយេនឌ័រប្រកបដោយប្រសិទ្ធិភាព
- ស្ថាប័នពាក់ពន្ធ័គួរតែបង្កើតផែនការបញ្ជ្រាបយេនឌ័ររបស់ខ្លួនផ្ទាល់ ដោយមានសូចនាករដែលអាចដំណើរការត្រួតពិនិត្យបាន
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន គួរតែបន្តកសាងសមត្ថភាពរបស់ក្រសួងក្នុងការវិភាគគោលនយោបាយ និងការតស៊ូមតិ ក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រ ប្រកបដោយនិរន្តរភាពទៅក្នុងដំណើរការរៀបចំគោលនយោបាយ
- អ្នកផ្តល់ជំនួយ គួរតែបន្តធ្វើការក្នុងភាពជាដៃគូជាមួយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដើម្បីបង្កើនសហប្រតិបត្តិការ និងប្រសិទ្ធិភាពក្នុងគ្រប់ការងាររួមទាំងអស់របស់ពួកគេ។

# ជំពូកទី ១

# ទំនាក់ទំនងយេនឌ័រ ក្នុងទិដ្ឋភាពសេដ្ឋកិច្ច-សង្គមកិច្ច និង វប្បធម៌


កម្ពុជានាពេលបច្ចុប្បន្ន ........ ២៩

១.១ ស្ថានភាព និន្នាការ និង បញ្ហា ........ ៣០

១.១.១ ទំនៀមទំលាប់ប្រពៃណីតឹងរ៉ឹង បានធ្វើឱ្យនារីមានឋានៈក្នុងសង្គម ទាបជាងបុរស ........ ៣១

១.១.២ ការបែងចែកកំលាំងពលកម្ម កំពុងតែមានការប្រែប្រួល ........ ៣២

១.១.៣ នារី នៅតែមានបន្ទុកការងារធ្ងន់ធ្ងរជាងបុរស ........ ៣២

១.១.៤ បុរស នៅតែមានសិទ្ធិច្រើនបំផុតក្នុងការសំរេចលើកិច្ចការគ្រួសារ ........ ៣៣

១.១.៥ ទំនាក់ទំនងយេនឌ័រ រវាងនារី និងបុរសកំពុងតែប្រែប្រួល ........ ៣៤

១.១.៦ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) រង្វាស់សិទ្ធិអំណាចយេនឌ័រ (GEM) និងសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) ស្ថិតនៅក្នុងចំណោមសន្ទស្សន៍ និងរង្វាស់ដែលទាបជាងគេបំផុតនៅអាស៊ី ........ ៣៥

១.១.៧ សន្ទស្សន៍ភាពក្រីក្រមនុស្សរបស់នារីមានទំហំធំជាងបុរស ........ ៣៦

១.១.៨ គ្រួសារដែលមាននារីជាមេគ្រួសារ ស្ថិតនៅក្នុងចំណោមគ្រួសារក្រីក្របំផុតនៅក្នុងសហគមន៍ ........ ៣៧

# ជំពូកទី ១ : ទំនាក់ទំនងយេនឌ័រ ក្នុងទិដ្ឋភាពសេដ្ឋកិច្ច-សង្គមកិច្ច និង វប្បធម៌

## កម្ពុជានាពេលបច្ចុប្បន្ន[១]

| សូចនាករ | តំលៃ |
|---|---|
| ផលិតផលក្នុងស្រុកសរុប (សំរាប់មនុស្សម្នាក់ គិតជាដុល្លាអាមេរិក) ឆ្នាំ២០០១ | ២៥៩ |
| អត្រាកំណើនភាគរយប្រចាំឆ្នាំនៃផលិតផលក្នុងស្រុកសរុប ១៩៩០-២០០០ | ៥ |
| ភាគរយផលិតផលក្នុងស្រុកសរុប តាមវិស័យ | |
| វិស័យកសិកម្ម | ៣៨ |
| វិស័យឧស្សាហកម្ម | ២៣,៥ |
| វិស័យសេវាកម្ម | ៣៥ |
| ភាគរយការងារតាមវិស័យ ឆ្នាំ២០០០ | |
| វិស័យកសិកម្ម | ៧៤ |
| វិស័យឧស្សាហកម្ម | ៨ |
| វិស័យសេវាកម្ម | ១៨ |
| ចំនួនប្រជាជនក្នុងជំរឿនប្រជារាស្ត្រឆ្នាំ១៩៩៨ | ១១.៤៣៧.៦៥៦នាក់ |
| ភាគរយនារីក្នុងចំណោមប្រជាជនទាំងអស់ | ៥២ |
| អត្រាកំណើនប្រជាជនប្រចាំឆ្នាំ-ជំរឿនប្រជារាស្ត្រឆ្នាំ១៩៩៨ | ២,៥ |
| អត្រាកំណើតឆ្នាំ២០០២ | ៤ |
| ចំនួនប្រជាជនតាមការប៉ាន់ស្មាននៅឆ្នាំ២០០៦ | ១៦លាននាក់ |
| ភាគរយប្រជាជននៅតំបន់ជនបទ នៅឆ្នាំ១៩៩៨ | ៨៤ |
| ភាគរយប្រជាជនអាយុក្រោម ២០ឆ្នាំ | ៥៥ |
| លំដាប់ថ្នាក់នៃសន្ទស្សន៍ការអភិវឌ្ឍន៍មនុស្សឆ្នាំ២០០០ | ទី១៣០ ក្នុងចំណោម ១៧៤ |
| សន្ទស្សន៍អភិវឌ្ឍន៍មនុស្សឆ្នាំ២០០០ | ០,៥៤៣ |
| អាយុមធ្យម - ឆ្នាំ១៩៩៨ | ៥៤ |
| ភាគរយប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ឆ្នាំ១៩៩៧ និង ១៩៩៩ | ៣៦ |
| សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រឆ្នាំ១៩៩៨ | ០,៥៣៧ |

[១] ប្រភព : ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ២០០២ : យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥។ ក្រសួងផែនការ-នាយកដ្ឋានផែនការ និងពតិមានសុខភាព ឆ្នាំ១៩៩៩ : ឯកសារស្តីពីជំហររបស់ក្រុមពិគ្រោះយោបល់។ អង្កេតប្រជារាស្ត្រ និងសុខភាព ២០០១ ជំរឿន ឆ្នាំ១៩៩៨។ រាជរដ្ឋាភិបាល ឆ្នាំ២០០២ : ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចលើកទី II ឆ្នាំ២០០១-២០០៥។ UNDP ២០០១ : របាយការណ៍អភិវឌ្ឍន៍មនុស្ស

## ១.១ ស្ថានភាព និន្នាការ និង បញ្ហា

សោកនាដកម្មនៅចន្លោះឆ្នាំ១៩៧០ និង ១៩៧៥ និងសង្គ្រាមអូសបន្លាយរហូតមកដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរយូរអង្វែងទៅលើជីវិតរបស់នារី និងបុរសកម្ពុជា។ បញ្ញវន្តខ្មែរ និងបរទេសមួយចំនួន (ដូចជា Pok ឆ្នាំ១៩៩៣ Ledgerwood ឆ្នាំ១៩៩៦ និង Kumar et al. ឆ្នាំ២000) បានធ្វើការវិភាគលើផលប៉ះពាល់ ពិសេសទៅលើនារី។ សេចក្តីសន្និដ្ឋានរួមដែលត្រូវបានធ្វើឡើងដោយបញ្ញវន្តទាំងនេះ រួមមាន:

- សង្គ្រាមរយៈពេលបីទសវត្សរ៍នៅកម្ពុជា បានបន្សល់ទុកនូវនារីពេញវ័យ (មានអាយុលើសពី ១៨ឆ្នាំ) ចំនួន ៦០-៦៥ភាគរយនៃចំនួនប្រជាជនសរុប។ កត្តានេះ បានធ្វើឱ្យតំលៃរបស់នារីធ្លាក់ចុះដោយសារចំនួននារីដែលដល់អាយុគ្រប់ការ មានច្រើនលើសលប់ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០។ ផ្អែកតាមការសន្និដ្ឋានរបស់ Ledgerwood នៅឆ្នាំ១៩៩៦ ឋានៈរបស់នារីក្នុងគ្រួសារបានធ្លាក់ចុះ ចំណែកបុរសវិញយល់ឃើញថា ខ្លួនស្ថិតក្នុងស្ថានភាពមួយល្អប្រសើរក្នុងការចរចារ។ នារីដែលគ្មានប្តី ត្រូវគេមើលងាយ និងរុញច្រានឱ្យរស់នៅក្រៅសង្គមខ្មែរ។

- របបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) បានបំផ្លាញចោលស្ថាប័នគ្រួសារ ដោយពង្រាត់កុមារពីគ្រួសាររបស់ពួកគេ។ របបខ្មែរក្រហម បានចាប់បង្ខំមនុស្សឱ្យរៀបការទាំងហ្វូង១ដែលក្នុងនោះ នារី និងយុវជនត្រូវបានគេជ្រើសរើសឱ្យរៀបការដោយមិនបានស្គាល់គ្នាមុនសោះ។

- បន្ទាប់ពីការចូលគ្រប់គ្រងនៃរបបសង្គមនិយម ដែលមានវៀតណាមជាបង្អែក (ឆ្នាំ១៩៧៩-១៩៨៩) គោលនយោបាយផ្លូវការបានចែងថា នារី និងបុរសមានសិទ្ធិស្មើគ្នា។ គណបក្សកុម្មុយនីស្ត បានលើកស្ទួយនារីមួយចំនួនឱ្យចូលកាន់មុខតំណែង ដែលមានសិទ្ធិសំរេចលើកិច្ចការនានា។ ប៉ុន្តែស្ថានភាពនេះ មានការផ្លាស់ប្តូរក្នុងអំឡុងពេលអន្តរកាលឈានទៅរកលទ្ធិប្រជាធិបតេយ្យ ដោយគេបានកត់សំគាល់ឃើញថា ការចូលរួមរបស់នារីក្នុងសកម្មភាពនយោបាយ បានថយចុះ (Ledgerwood ឆ្នាំ១៩៩៦)។

- ទន្ទឹមនឹងធ្វើឱ្យនារីរងទុក្ខវេទនា សង្គ្រាមស៊ីវិលក៏បានបង្កើតឱ្យមានឱកាសថ្មី១ សំរាប់នារីចូលរួមក្នុងវិស័យសាធារណៈផងដែរ (kumar ឆ្នាំ២000)។ ដោយសារការកែណ្ឌបុរសឱ្យចូលបំរើក្នុងជួរកងទ័ព ការសំលាប់រង្គាលកំណើនតំរូវការកំលាំងសំរាប់ធ្វើសង្គ្រាម និងការងារស្តានីតិសម្បទា នារីត្រូវបំពេញតួនាទីក្នុងវិស័យសេដ្ឋកិច្ចដែលពីមុនជាការងាររបស់បុរស។ ក្នុងជំរុំជនភៀសខ្លួនដែលត្រូវបានបង្កើតឡើងនៅលើទឹកដីថៃ នារីត្រូវបានលើកទឹកចិត្តឱ្យចូលសិក្សា ក្នុងវគ្គបណ្តុះបណ្តាលជំនាញក្នុងការរកប្រាក់ចំណូល និងជំនាញដទៃទៀត។ រចនាសម្ព័ន្ធរដ្ឋបាលនៃជំរុំជនភៀសខ្លួន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងារអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបានលើកទឹកចិត្តឱ្យនារីបានចូលបំរើការងារនៅក្នុងជំរុំ ដែលនេះជាការផ្តល់ភាពអង់អាចដល់នារី នៅពេលដែលនារីត្រលប់មកកម្ពុជាវិញបន្ទាប់ពីពេលបិទជំរុំជនភៀសខ្លួន។ ការវិវឌ្ឍន៍ទាំងអស់នេះ បានរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរលើប្រពៃណីតួនាទីយេនឌ័រ និងការបែងចែកកំលាំងពលកម្ម។

- ការមកដល់នៃអាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) និង ទីភ្នាក់ងារអភិវឌ្ឍន៍ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ជានិមិត្តរូបនៃសន្តិភាព ការវិលត្រលប់មកវិញនូវគោលគំនិតសមភាពយេនឌ័រ និង ការបង្កើតឡើងនូវអង្គការនារីជាច្រើន (ជាមួយនឹងមូលនិធិថ្មី)។ ការមកដល់នៃកងកំលាំងរក្សាសន្តិភាព អង្គការសហប្រជាជាតិចំនួន ២២.០០០នាក់ ក៏បានធ្វើឱ្យបញ្ហាពេស្យាចារ មានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើងថែម ទៀតផងដែរ។ ទាហានមិនគ្រាន់តែបង្កើតឱ្យមានតំរូវការថ្មី ចំពោះស្រីរកស៊ីផ្លូវភេទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង បានធ្វើឱ្យឧស្សាហកម្មភេទដែលរកស៊ីលាក់កំបាំងតាំងពីមុនមកនោះ មានលក្ខណៈស្របច្បាប់។

ទំនាក់ទំនងយេនឌ័រនៅកម្ពុជា នៅមិនទាន់មានការកែប្រែប៉ុន្មានទេៈ បទដ្ឋានវប្បធម៌ខ្មែរ នៅតែដាក់នារីនៅក្នុង ឋានៈទាបជាងបុរសនៅក្នុងសង្គម ។ បញ្ហានេះ នៅតែកើតមានទោះបីជាជាក់ស្តែង នារីកំពុងតែបង្ហាញឱ្យឃើញក្នុងតួនាទី យ៉ាងសំខាន់ជាអ្នករកចំណូលសំរាប់គ្រួសារ និង ជាកំលាំងចលករសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចក៏ដោយ។

## ១.១.១ ទំនៀមទំលាប់ប្រពៃណីតឹងរ៉ឹង បានធ្វើឱ្យនារីមានឋានៈក្នុងសង្គម ទាបជាងបុរស

វិសមភាពយេនឌ័រដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ គឺជាបទដ្ឋានវប្បធម៌ និង ប្រពៃណីដែលក៏រិតលើ សិទ្ធិជ្រើសរើសរបស់ក្មេងស្រី និងនារី ។ សង្គមកម្ពុជា គឺជាសង្គមដែលមានលំដាប់ឋានានុក្រម ព្រមទាំងមានសញ្ញាណ អំណាច និងឋានៈរឹងមាំដែលកំណត់លក្ខណៈល័ក្ខខ័ណ្ឌទំនាក់ទំនងក្នុងសង្គម។ ទោះបីជាឋានៈរបស់បុគ្គលម្នាក់ៗនៅ ក្នុងសង្គមត្រូវបានកំណត់ទៅតាមអាយុ និងលក្ខណៈពិសេសរួមទាំងទ្រព្យសម្បត្តិផងក៏ដោយ ប៉ុន្តែនារីត្រូវបាន ចាត់ទុកថា មានឋានៈក្នុងសង្គមទាបជាងបុរស (Gorman ឆ្នាំ១៩៩៩)។

ការរើសអើងយេនឌ័រ បានចាក់រឹសយ៉ាងជ្រៅ និងកាន់តែរឹងមាំដោយសារឥរិយាបថសង្គម។ ក្រមសីលធម៌ ឬហៅ ម្យ៉ាងទៀតថា "ច្បាប់" ដែលរៀបរាប់អំពីចរិយាសម្បត្តិសមសួនរបស់នារីខ្មែរ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សា បឋមសិក្សា។ ច្បាប់នេះចែងថា "នារី ត្រូវចេះរក្សាភាពស្ងៀមស្ងាត់ និងមិនត្រូវដើរឱ្យឮសូរសំពត់ដូចស្លឹកឈើត្រូវ ខ្យល់បក់នោះទេ។ នារី មានការអៀនខ្មាស់ច្រើន មិនសូវរវៀសរវៃ និងត្រូវការការពារ។ មុនពេលរៀបការ នារី មិនត្រូវដើរចេញទៅណាឆ្ងាយដោយពុំមានសមាជិកគ្រួសារទៅជាមួយឡើយ" (Ledgerwood ឆ្នាំ១៩៩៦) ។

សង្គម មិនទទួលស្គាល់នារីខ្មែរ ដែលរៀបការជាមួយបុរសមានកំរិតវប្បធម៌ទាបជាងទេ ចំណុចនេះបានបង្អាក់ ទឹកចិត្តនារីក្នុងការបន្តការសិក្សាឱ្យបានខ្ពង់ខ្ពស់។ មានការលំបាកចំពោះនារីដែលមានមុខតំណែងខ្ពស់ជាងប្ដីរបស់ខ្លួន។ ប៉ុន្តែសង្គមអាចទទួលយកបាននៅពេលដែល នារីត្រូវចូលប្រឡូកក្នុងការងារជំនួញដើម្បីចិញ្ចឹមគ្រួសារ ហើយទុក ឱកាសឱ្យប្តីរបស់ខ្លួនធ្វើការងារដែលមានប្រាក់បៀវត្សរ៍តិច តែមានឋានៈក្នុងសង្គមខ្ពស់ក្នុងជួររដ្ឋាភិបាល។ ប៉ុន្តែចំណុច ដែលច្រាសមកវិញ មិនត្រូវបានគេទទួលស្គាល់ឡើយ។ ឋានៈក្នុងសង្គមទាបរបស់ប្រពន្ធ ធៀបជាមួយនឹងឋានៈក្នុង សង្គមរបស់ប្តី ត្រូវបានបង្ហាញជូនតាមរយៈឧទាហរណ៍ ដែលបានពិគ្រោះយោបល់ជាមួយនឹងក្រុមនារី។ នៅក្នុង បទបញ្ញត្តិរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ប្តីដែលជាមន្ត្រីរាជការមានសិទ្ធិទទួល "ប្រាក់ឧបត្ថម្ភសំរាប់អ្នកក្នុងបន្ទុក" ប្រសិនបើប្រពន្ធជាមេផ្ទះ ប៉ុន្តែប្រសិនបើប្រពន្ធជាមន្ត្រីរាជការវិញ ពុំបានទទួលប្រាក់ឧបត្ថម្ភនេះទេ ដោយផ្អែកទៅលើ

ការសន្មត់ថា នារីមិនដែលមានជំនាញវិជ្ជាជីវៈ "ខ្ពស់" ជាងប្តីរបស់ខ្លួនទេ។ ឧទាហរណ៍មួយទៀត ទាក់ទងនឹងនារីដែលមានមុខតំណែងនៅក្នុងក្រុមប្រឹក្សាមូលដ្ឋាន (នារីម្នាក់ សូម្បីតែត្រូវបានតែងតាំងជាអភិបាលរងខេត្តហើយ) ប៉ុន្តែបានលាលែងពីតំណែងនេះវិញ ដោយសារតែប្តីរបស់ខ្លួន មិនជួយគាំទ្រ ។

## ១.១.២ ការបែងចែកកំលាំងពលកម្ម កំពុងតែមានការប្រែប្រួល

ទំនៀមទំលាប់ប្រពៃណីខ្មែរ បានចាត់ទុកបុរសជាអ្នករកស៊ីចិញ្ចឹមគ្រួសារ ចំណែកនារីវិញ ទទួលខុសត្រូវមើលថែទាំកូន និងគ្រប់គ្រងផ្ទះសំបែង។ គំនិតទូទៅទាក់ទងនឹងការងារដែលនារី និងបុរសត្រូវធ្វើបង្ហាញឱ្យឃើញថា បុរសត្រូវទទួលខុសត្រូវចំពោះការងារធំៗ និងការងារដែលទាមទារឱ្យមាន "សមត្ថភាពបច្ចេកទេស"។ ប៉ុន្តែតាមការអនុវត្តន៍ជាក់ស្តែង ការបែងចែកការងារនៅតាមគ្រួសារ មានការផ្លាស់ប្តូរ ដោយនារី ទំនងជាចូលរួមកាន់តែច្រើនក្នុង ការងារធំៗ រួមទាំងការងាររបស់បុរសផងដែរ ។

តាមតថភាពជាក់ស្តែង នារីខ្មែរមានការទទួលខុសត្រូវដូចបុរសដែរ ក្នុងការរកស៊ីចិញ្ចឹមគ្រួសារ ជាពិសេសក្នុងគ្រួសារក្រីក្រ ដូចដែលបានឃើញតាមរយៈការចូលរួមដោយស្មើភាពគ្នារបស់នារីក្នុងកំលាំងពលកម្ម (សូមមើលជំពូកទី២) ។បទដ្ឋានវប្បធម៌ទូទៅ បានជំរុញឱ្យបុរសដើររកការងារមានប្រាក់កំរៃធ្វើ ប៉ុន្តែបានរារាំងមិនឱ្យនារីធ្វើដូច្នេះឡើយ ។ ទោះបីជាមានការទទួលស្គាល់កាន់តែច្រើនឡើងថា នារីអាចទទួលបានឱកាសការងារមានប្រាក់កំរៃច្រើនជាងបុរស ប៉ុន្តែប្រជាជននៅតែមានអារម្មណ៍ថា ក្មេងស្រីដែលរកការងារធ្វើនៅរោងចក្រកាត់ដេរ គួរតែធ្វើការនៅក្នុងភូមិរបស់ពួកគេវិញប្រសើរជាង ។ គ្រួសារតែងតែមានអារម្មណ៍ភ័យខ្លាចថា ក្មេងស្រីដែលធ្វើដំណើរទៅទីក្រុង នឹងត្រូវគេបោកប្រាស់ និងបាត់បង់ព្រហ្មចារីយ៏មុនពេលរៀបការ (ADB ឆ្នាំ២០០១)។

## ១.១.៣ នារី នៅតែមានបន្ទុកការងារធ្ងន់ធ្ងរជាងបុរស

កត្តាទាំងអស់នេះ រួមចំណែកធ្វើឱ្យបន្ទុកការងាររបស់នារីកាន់តែកើនឡើង។ អ្នកដែលបានចូលរួមផ្តល់ការសំភាសន៏នៅក្នុងដំណើរការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (ADB ឆ្នាំ២០០១) បានរាយការណ៍ថា នារីមានតួនាទីក្នុង និងក្រៅផ្ទះច្រើនជាងបុរស។ នារីត្រូវភ្ញាក់ពីដំណេកមុនបុរស និងចូលដំណេកក្រោយបុរស។ នារីទទួលខុសត្រូវការងារផ្ទះចំនួន ៩០ភាគរយ រួមទាំងការមើលថែទាំអ្នកក្នុងបន្ទុកគ្រួសារ និងអ្នកជំងឺផងដែរ។ ដោយសារមានអត្រាកំណើតខ្ពស់ ហើយមានកំណើនប្រជាជនក្នុងទសវត្សរ៏ឆ្នាំ១៩៨០ ប្រជាជនក្មេងៗនៅកម្ពុជា មានច្រើនៈ នៅឆ្នាំ១៩៩៨ ប្រជាជនអាយុក្រោម ១៥ឆ្នាំ មានចំនួន ៤៣ភាគរយ ដូច្នេះអត្រាអ្នកក្នុងបន្ទុកគ្រួសារមានកំរិតខ្ពស់ដែលជាហេតុធ្វើឱ្យបន្ទុកការងាររបស់នារីកើនឡើង។ សមាជិកគ្រួសារ ជាពិសេសនារី និងក្មេងស្រី ត្រូវចំណាយពេលវេលាចំនួនពី ១ ទៅ ២ម៉ោងក្នុងមួយថ្ងៃ ដើម្បីទៅដឹក ឬរែកទឹកសំរាប់ប្រើប្រាស់ក្នុងគ្រួសារ។ នារី និងក្មេងស្រី ធ្វើការងារច្រើនម៉ោងជាងបុរស និងក្មេងប្រុស (សូមមើលក្រាហ្វិក ១.១)។ គេសង្កេតឃើញមានកំណើនទំនាក់ទំនងរវាងការថយចុះនូវមូលដ្ឋានធនធានធម្មជាតិនៅទូទាំងប្រទេស និងការកើនឡើងនូវទំហំការងារប្រចាំថ្ងៃដែលនារីត្រូវធ្វើ

ដើម្បីបំពេញតំរូវការជាមូលដ្ឋាន។ កត្តានេះ ក៏មានឥទ្ធិពលលើបុរសផងដែរ ប៉ុន្តែបុរសមានទំនោររួមចំណែកក្នុងការងារតំរូវការចិញ្ចឹមជីវិតតែក្នុងកាលៈទេសៈមួយចំនួនប៉ុណ្ណោះ ដូចជាការងារមិនទៀងទាត់ ឬទៅតាមរដូវកាល។

នារីចង់ឱ្យបុរសជួយបន្ទុកកិច្ចការផ្ទះរបស់ខ្លួន៖ ៨៩ភាគរយនៃនារីដែលបានធ្វើអង្កេត យល់ឃើញថា ប្តី របស់ពួកគេគួរតែជួយការងារផ្ទះរបស់ពួកគេឱ្យបានច្រើន (ការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០០)។ លទ្ធផលពីកិច្ចពិគ្រោះយោបល់របស់ក្រសួងក.ន.អ ជាមួយនឹងនារីជាមន្ត្រីរាជការ ក៏បានបញ្ជាក់ឡើងវិញថា នារីចង់ឱ្យបុរសជួយធ្វើកិច្ចការក្នុងផ្ទះដែរ ។

**ក្រាហ្វិក ១.១ : នារី និងក្មេងស្រី ធ្វើការច្រើនម៉ោងជាងបុរស និងក្មេងប្រុស**




ប្រភព: CDHS ឆ្នាំ២០០០

## ១.១.៤ បុរស នៅតែមានសិទ្ធិច្រើនបំផុតក្នុងការសំរេចលើកិច្ចការគ្រួសារ

នៅក្នុងការអង្កេតដដែលនេះ នារីជាច្រើនមានជំនឿថា បុរសគួរតែធ្វើសេចក្តីសំរេចលើកិច្ចការសំខាន់ៗ (៥២ភាគរយ) កូនប្រុសគួរតែរៀនសូត្រឱ្យបានច្រើនជាងកូនស្រី (៥៩ភាគរយ) ហើយនារីដែលរៀបការរួច មិនគួរអនុញ្ញាតឱ្យធ្វើការនៅក្រៅផ្ទះឡើង (៣៣ភាគរយ ) (ការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០០)។

នារីគ្រប់គ្រងទាំងស្រុងលើធនធាន ប៉ុន្តែសិទ្ធិក្នុងការធ្វើសេចក្តីសំរេចនៅមានកំរិតនៅឡើយ (CDHS ឆ្នាំ២០០០)។ ការសំរេចចិត្តទៅធ្វើការ ឬមិនធ្វើការមិនមែនស្ថិតនៅលើនារីតែម្នាក់ឯងនោះទេ (៩ភាគរយ)។ នារីមួយចំនួនមាន

ទ្រព្យផ្ទាល់ខ្លួនយ៉ាងតិចក៏មួយមុខដែរ ដែលនារីទាំងនោះមានសិទ្ធិលក់ទ្រព្យនោះ ដោយមិនបាច់សុំការអនុញ្ញាតពីបុរស (២៨ភាគរយ) ។ ការយល់ដឹងអំពីកម្មវិធីឥណទាននៅមានកំរិត (៣៧ភាគរយ) ហើយចំណេះដឹងទាក់ទងនឹងរបៀបខ្ចីប្រាក់សំរាប់ចាប់ផ្តើម ឬពង្រីកអាជីវកម្មនៅមានកំរិតទាបណាស់ (១០ភាគរយ) ។

នារីពុំបានគ្រប់គ្រងលើការលក់ដីធ្លីទេ ទោះបីជាប័ណ្ណកម្មសិទ្ធិដីធ្លីមានឈ្មោះរបស់នារី និងឈ្មោះប្តីរបស់គាត់ក៏ដោយ ។ តាមការវាយតំលៃអំពីយេនឌ័រ ដែលត្រូវបានធ្វើឡើងនៅខេត្តស្វាយរៀង និងព្រៃវែង (IFAD ឆ្នាំ២០០៣) បានបង្ហាញថា បុរសនៅតែមានសិទ្ធិក្នុងការសំរេចលើការទិញ និងការលក់ដូរសំខាន់ៗរួមទាំងការទិញ និងលក់ដូរដីធ្លីផង ។ ប៉ុន្តែនារីដែលរកប្រាក់បានដោយខ្លួនឯង អាចមានសិទ្ធិច្រើនក្នុងការធ្វើសេចក្តីសំរេចលើការចំណាយប្រាក់នោះ ។ នៅឆ្នាំ ២០០០ ក្នុងចំណោមនារីរៀបការរួច ដែលរកប្រាក់បានដោយខ្លួនឯងមាន ៤៧ភាគរយ បានរាយការណ៍ថា ពួកគេជាអ្នកសំរេចតែម្នាក់ឯងលើការចាយវាយប្រាក់ដែលខ្លួនរកបាន ចំណែកនារីចំនួន ៥០ភាគរយ បានរាយការណ៍ថា គាត់ និង ប្តីរបស់គាត់ជាអ្នកសំរេចរួមគ្នាលើការចាយវាយប្រាក់នោះ (CDHS- ឆ្នាំ២០០០) ។

ប្រាក់របស់នារី ត្រូវបានប្រើប្រាស់សំរាប់ចាយវាយក្នុងគ្រួសារ ច្រើនជាងប្រាក់របស់បុរស ពោលគឺប្រាក់ចំណូលជាងពាក់កណ្តាលរបស់គ្រួសារ ជាប្រាក់ដែលនារីរកបាន (IFAD ឆ្នាំ២០០៣) ។ នេះជាបញ្ហាសំខាន់ចំពោះការរៀបចំអនុសាសន៍គោលនយោបាយ ថាតើត្រូវផ្តោតគោលដៅទៅលើនារីយ៉ាងដូចម្តេច ដើម្បីអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី១ ដែលផ្តោតទៅលើការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន ។

មានការនិយាយជាទូទៅថា នារីជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រួសារ និងមានសិទ្ធិសំរេចលើការចំណាយប្រចាំថ្ងៃសំរាប់គ្រួសារ ។ ប៉ុន្តែនៅក្នុងគ្រួសារក្រីក្រភាគច្រើន ការទទួលខុសត្រូវក្នុងការប្រើប្រាស់ថវិកាគ្រួសារដ៏តិចតួចនេះឱ្យឆ្លើយតបទៅនឹងតំរូវការរបស់គ្រួសារ ពុំមែនជា "ការផ្តល់អំណាចក្នុងផ្នែកសេដ្ឋកិច្ច" ឡើយ ។ ជាញឹកញាប់វាជាប្រភពដែលបង្កឱ្យមានជំលោះក្នុងគ្រួសារ ដែលនាំឱ្យកើតមានអំពើហឹង្សា ព្រមទាំងជាបន្ទុកធ្ងន់ធ្ងរទៅលើនារីដែលនារីត្រូវតែបំពេញការខ្វះខាត នៅពេលប្រាក់ដែលបុរសរកបាន មិនគ្រប់គ្រាន់សំរាប់ការចំណាយចាំបាច់ ។

## ១.១.៥ ទំនាក់ទំនងយេនឌ័រ រវាងនារី និងបុរសកំពុងតែប្រែប្រួល

ពត៌មាន ឬការវិភាគអំពីយេនឌ័របុរសនៅកម្ពុជា មានតិចតួចប៉ុណ្ណោះ ។ ឧទាហរណ៍ៈ តើតួនាទី និងអត្តសញ្ញាណរបស់បុរស មានការប្រែប្រួលយ៉ាងណាខ្លះ? តើការប្រែប្រួលទីផ្សារពលកម្ម និងរចនាសម្ព័ន្ធសង្គម មានផលប៉ះពាល់លើបុរសដូចម្តេច? តើការប្រព្រឹត្តប្រកបដោយគ្រោះថ្នាក់ បទឧក្រិដ្ឋ និងអំពើហឹង្សា គ្រោះថ្នាក់នៅក្នុងការងារ ជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន មានផលប៉ះពាល់ដូចម្តេចខ្លះលើបុរស (ធនធានមនុស្ស)? តើអត្រាអំពើហឹង្សាក្នុងគ្រួសារ និងអំពើហឹង្សាផ្លូវភេទជាសាធារណៈ (រួមទាំងការរំលោភសន្ទុះផង) មានការកើនឡើងដែរឬទេ? ហើយប្រសិនបើមានការកើនឡើង តើបណ្តាលមកពីមូលហេតុអ្វី?

ទោះបីជាមានការយល់ដឹងតិចតួចអំពីផលប៉ះពាល់នៃស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចទៅលើបុរស និងតួនាទី និងការទទួលខុសត្រូវរបស់ពួកគេក៏ដោយ ក៏មានសញ្ញានៃផលប៉ះពាល់របស់ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចទៅលើទំនាក់ទំនងរវាងបុរស និងនារីផងដែរ ។ ឧទាហរណ៍ៈ យោបល់របស់នារីនៅក្នុងកិច្ចពិគ្រោះយោបល់ សំរាប់ការវាយតំលៃនេះបង្ហាញឱ្យឃើញថា ការងារពាក់កណ្តាលពេល និងការបាត់បង់អំណាចសេដ្ឋកិច្ចរបស់បុរស ដែលត្រូវបានគិតថាដោយសារតែការបង្កើនការផ្តល់អំណាចសេដ្ឋកិច្ចដល់នារី ត្រូវបានបុរសមួយចំនួនចាត់ទុកថា ជាការរំលោភទៅលើបទដ្ឋានយេនឌ័រ ។ ការខកចិត្តដែលកើតឡើងដោយសារបញ្ហានេះ ត្រូវបានបង្ហាញឱ្យឃើញតាមរយៈការកើនឡើងនូវរបាយការណ៍ស្តីពីអំពើហឹង្សាក្នុងគ្រួសារ ។ ប៉ុន្តែការកើនឡើងនៃស្វ័យភាពសេដ្ឋកិច្ចរបស់នារី អាចធ្វើឱ្យនារីមានលទ្ធភាពចាកចេញពីអំពើហឹង្សា ឬទំនាក់ទំនងដែលមានការរំលោភបំពាន និងចៀសផុតពីការងារដែលមានការកេងប្រវ័ញ្ច និងប្រកបដោយគ្រោះថ្នាក់ ដូចជាអាជីវកម្មផ្លូវភេទជាដើម ។

តាមការអង្កេតប្រជាសាស្រ្ត និងសុខភាពបានបង្ហាញថា នារីដែលចូលរួមសំភាសន៍ចំនួន ៨៦ភាគរយយល់ឃើញថា នារីមិនគួរស៊ូទ្រាំអត់ធ្មត់នឹងការវាយដំ ដើម្បីរក្សាគ្រួសារឱ្យគង់វង្សនោះទេ ។ នារី ៨៩ភាគរយ ក៏យល់ឃើញថា បុរសមិនត្រូវមានទំនាក់ទំនងផ្លូវភេទជាមួយនារីផ្សេងក្រៅពីប្រពន្ធខ្លួននោះទេ ប៉ុន្តែករណីបុរសមានដៃគូច្រើន មិនត្រឹមតែត្រូវបានអនុវត្តយ៉ាងទូលំទូលាយប៉ុណ្ណោះទេ ថែមទាំងត្រូវបានគេលើកលែងឱ្យទៀតផង (CDHS-២០០០) ។ ក្នុងខណៈដែលសង្គមពុំទទួលយកបញ្ហានេះ ប៉ុន្តែបញ្ហាបុរសមានដៃគូរួមភេទច្រើននេះ ក៏ពុំត្រូវបានគេចាត់ទុកថាជាបញ្ហាយេនឌ័រឡើយ ។ ប៉ុន្តែបញ្ហានេះជាបុព្វហេតុចំបងនាំឱ្យមានការរីករាលដាលនៃមេរោគអេដស៍ និងការជួញដូរផ្លូវភេទដោយបង្ខំ ដែលមានផលប៉ះពាល់លើនារី និងក្មេងស្រីមួយចំនួនធំ ។

## ១.១.៦ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) រង្វាស់សិទ្ធិអំណាចយេនឌ័រ (GEM) និងសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) ស្ថិតនៅក្នុងចំណោមសន្ទស្សន៍ និងរង្វាស់ដែលទាបជាងគេបំផុតនៅអាស៊ី

សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) និងរង្វាស់សិទ្ធិអំណាចយេនឌ័រ (GEM) ត្រូវបានរៀបចំឡើងដើម្បីវាស់ស្ទង់ការអភិវឌ្ឍន៍មនុស្សនៅក្នុងប្រទេស (UNDP ឆ្នាំ១៩៩០) ។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) គឺជារង្វាស់រួមមួយស្តីអំពីអាយុកាល ការអប់រំ និងកំរិតជីវភាពរស់នៅ ។ រង្វាស់សិទ្ធិអំណាចយេនឌ័រ (GEM) វាស់ស្ទង់កំរិតនៃការចូលរួមរបស់នារីធៀបនឹងបុរស នៅក្នុងសកម្មភាពនយោបាយ និងសេដ្ឋកិច្ច ចំណែកវិសមភាពយេនឌ័រ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) ។

សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) របស់កម្ពុជាគឺ ០,៤២៧ ដែលស្ថិតនៅក្នុងចំណោមសន្ទស្សន៍ទាបបំផុតនៅអាស៊ី ។ សន្ទស្សន៍នេះប្រហាក់ប្រហែលនឹងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI : ០,៤២១) ដែរ គឺការប្រៀបធៀបអាយុកាលរបស់នារី ជាមួយនឹងវិសមភាពយេនឌ័រ ក្នុងការទទួលបានការអប់រំ និងកំរិតនៃអក្ខរកម្ម ។ រង្វាស់សិទ្ធិអំណាចយេនឌ័រ (GEM) គឺ ០,២៨៣ ពោលគឺស្ថិតក្នុងចំណោមរង្វាស់ទាបបំផុតនៅអាស៊ីដោយសារ នារី មានតំណាងរបស់ខ្លួនទាបនៅក្នុងស្ថាប័នថ្នាក់ជាតិក្នុងតួនាទីធ្វើសេចក្តីសំរេច និងមុខតំណែងវិជ្ជាជីវៈ ។

## ១.១.៧ សន្ទស្សន៍ភាពក្រីក្រមនុស្សរបស់នារីមានទំហំធំជាងបុរស

សន្ទស្សន៍ភាពក្រីក្រមនុស្ស (HPI) វាស់ស្ទង់ភាពខ្វះខាត អាយុកាល ចំណេះដឹង និងកំរិតជីវភាពរស់នៅ។ សន្ទស្សន៍នេះជារង្វាស់រួមមួយ គិតជាភាគរយនៃប្រជាជនដែលមិនមានអាយុកាលដល់ ៤០ឆ្នាំ ដែលមិនចេះអក្សរ មិនមានទឹកស្អាតប្រើប្រាស់ និងមិនមានលទ្ធភាពទទួលបានសេវាសុខភាព ព្រមទាំងភាគរយនៃកុមារអាយុក្រោម ៥ឆ្នាំដែលខ្វះទំងន់ជាមធ្យម និងខ្វះទំងន់ខ្លាំង។ ដូចដែលបានរំពឹងទុក បើពិចារណាទៅលើអត្រាមរណភាពទារក និងកុមារដែលមានកំរិតខ្ពស់ និងកង្វះអាហារូបត្ថម្ភ ព្រមទាំងកង្វះសេវាសាធារណៈ (សូចនាករដែលត្រូវបានប្រើនៅក្នុងការរៀបចំសន្ទស្សន៍ភាពក្រីក្រមនុស្ស) បង្ហាញឱ្យឃើញថា កម្ពុជាមានសន្ទស្សន៍ភាពក្រីក្រមនុស្សខ្ពស់ បើប្រៀបធៀបជាមួយនឹងប្រទេសផ្សេងទៀតនៅអាស៊ី។ មានតែប្រទេសបង់ក្លាដេស និងប៉ាគីស្ថានប៉ុណ្ណោះ ដែលមានសន្ទស្សន៍ភាពក្រីក្រខ្ពស់ជាងប្រទេសកម្ពុជា។ ភាពក្រីក្រមនុស្សនៅក្នុងចំណោមនារីខ្មែរ ខ្ពស់ជាងនៅក្នុងចំណោមបុរសខ្មែរ នៅក្នុងគ្រប់ក្រុមតាមកំរិតនៃសេដ្ឋកិច្ច។ វិសមភាពយេនឌ័រនៅក្នុងភាពក្រីក្រមនុស្ស នៅតែកើតមាន សូម្បីតែនៅក្នុងចំណោមអ្នកមានបំផុត ២០ភាគរយ ដែលនេះបង្ហាញឱ្យឃើញថា កំណើនសេដ្ឋកិច្ច និងកំរិតជីវភាពរស់នៅល្អប្រសើរ ពុំអាចកាត់បន្ថយវិសមភាពយេនឌ័រ ជាស្វ័យប្រវត្តិបានឡើយ និងបង្ហាញឱ្យឃើញថា ចាំបាច់ត្រូវមានអន្តរាគមន៍គោលនយោបាយជាក់លាក់ ដើម្បីកាត់បន្ថយវិសមភាពយេនឌ័រនេះ (CHDR ឆ្នាំ២០០០)។

សម្មតិកម្មសំខាន់មួយនៃការវិភាគយេនឌ័រនៅក្នុងបញ្ហានៃភាពក្រីក្រគឺថា ភាពលំអៀងនៃយេនឌ័រ មានឥទ្ធិពលលើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ពីព្រោះបទពិសោធន៍របស់នារី ទទួលរងផលប៉ះពាល់ពីភាពក្រីក្រខុសពីបុរស។ មិនអាចសន្មត់បានថា ធនធានទាំងអស់ត្រូវបានដាក់បញ្ចូលគ្នា និងប្រើប្រាស់ដោយស្មើភាពគ្នានៅក្នុងផ្ទះ និងគ្រួសារឡើយ។ របាយការណ៍ស្តីពី*ការរួមចំណែករបស់នារីក្នុងកិច្ចអភិវឌ្ឍន៍* បានរៀបរាប់ថា "មានការរើសអើងបន្តិចបន្តួចចំពោះទារិកា និងក្មេងស្រីក្នុងការបែងចែកអាហារចាំបាច់ (ដូចជា បាយ) នៅក្នុងគ្រួសារ ប៉ុន្តែមនុស្សប្រុសពេញវ័យចាប់ពីអាយុ ១៥ឆ្នាំ និងលើសពីនេះ ទទួលបានអាហារចាំបាច់ច្រើនជាងនារីពេញវ័យ... ហើយមនុស្សប្រុសទទួលបានមុខម្ហូបអាហារសំរាប់ទទួលទានច្រើនជាងនារី ដូចជាសាច់ និងស៊ុតជាដើម (CHDR-ឆ្នាំ១៩៩៨)។ ហេតុដូច្នេះនារីអាចនឹងត្រូវប្រឈមមុខនឹងភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ច្រើនជាងមនុស្សប្រុស។

គោលដៅទីមួយ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក មិនបានបញ្ចូលសូចនាករស្តីពីកង្វះអាហារូបត្ថម្ភរបស់នារីទេ ហើយបញ្ហាកង្វះអាហារូបត្ថម្ភនេះ ក៏មិនត្រូវបានគេបញ្ចូលទៅក្នុងគោលដៅទីប្រាំនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក ដែលនិយាយអំពីសុខភាពមាតាដែរ។ ប៉ុន្តែគោលដៅទីប្រាំនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា បានដាក់បញ្ចូលសូចនាករស្តីពីសន្ទស្សន៍ម៉ាសរាងកាយ (Body Mass Index) និងជំងឺស្លេកស្លាំងខ្វះជាតិដែករបស់នារីដែលមិនមានគភ៌។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា កំពុងពិនិត្យលើសូចនាករទាំងនេះ ហើយក្រសួងសុខាភិបាលមានចំណុចដៅមួយសំរាប់កត្តាទាំងពីរនេះ (សូមមើលជំពូកទី៥)។ ជាការសំខាន់គឺថា សុខភាព និងសុខុមាលភាពរបស់នារីរួមទាំងអាហារូបត្ថម្ភផង ត្រូវបានឆ្លើយតបនៅក្នុងបរិបទសិទ្ធិនារី និងពុំគួរឆ្លើយតបតែបញ្ហាសុខភាពមាតា ដែលផ្តោតលើនារីជាអ្នកទទួលផល ដោយសារនារីមានតួនាទីជាអ្នកបង្កើតកូន ដោយមិនបានគិតអំពីតំលៃនៃសិទ្ធិរបស់នារីនោះទេ។

**ក្រាហ្វិក ១.២ : សន្ទស្សន៍ភាពក្រីក្រមនុស្សតាមភេទ និងចំណាយសំរាប់មនុស្សម្នាក់ទៅតាមបញ្ចូភាគផ្សេងៗ ឆ្នាំ១៩៩៩**




ប្រភព: UNDP ពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩

ឧទាហរណ៍មួយទៀតស្តីពីផលប៉ះពាល់នៃភាពក្រីក្រទៅលើយេនឌ័រ គឺថាអត្រាពលកម្មកុមារនៅក្នុងចំណោមក្មេងស្រីខ្ពស់ជាងនៅក្នុងចំណោមក្មេងប្រុស (សូមមើលជំពូកទី២): ក្មេងស្រី ៥០ភាគរយ និងក្មេងប្រុស ៣៦ភាគរយ នៅក្នុងក្រុម អាយុ ១៤-១៧ឆ្នាំ មានអត្រាពលកម្មកុមារខ្ពស់បំផុតពោលគឺ ខ្ពស់ជាងក្រុមអាយុផ្សេងៗទៀត (CHDR ឆ្នាំ២០០០)។ ភាពក្រីក្រ គឺជាបុព្វហេតុចំបងមួយដែលនាំឱ្យមានពលកម្មកុមារ។

## ១.១.៨ គ្រួសារដែលមាននារីជាមេគ្រួសារ ស្ថិតនៅក្នុងចំណោមគ្រួសារក្រីក្របំផុតនៅក្នុងសហគមន៍

ដោយសារទិន្នន័យស្តីពីភាពក្រីក្រ ប្រមូលបានតែនៅត្រឹមកំរិតគ្រួសារ ដូច្នេះការវិភាគយេនឌ័រមួយចំនួន ផ្តោតតែទៅលើការវិភាគទិន្នន័យគ្រួសារ ដោយផ្អែកទៅលើភេទនៃមេគ្រួសារ។ របាយការណ៍ភាពក្រីក្រកម្ពុជាឆ្នាំ១៩៩៩ (ក្រសួងផែនការឆ្នាំ១៩៩៩) បង្ហាញថា ទោះបីជាសន្ទស្សន៍រាប់ចំនួនអ្នកក្រីក្រសំរាប់គ្រួសារ ដែលមាននារីជាមេគ្រួសារ (៣៤ភាគរយ) មានកំរិតទាបជាងសន្ទស្សន៍រាប់ចំនួនអ្នកក្រីក្រសំរាប់គ្រួសារដែលមាន បុរសជាមេគ្រួសារតែបន្តិចបន្តួចប៉ុណ្ណោះ (៣៦ភាគរយ) ប៉ុន្តែភាពខុសគ្នាដែលសំខាន់នោះ គឺមិនមែនជាស្ថិតិទេ។ របាយការណ៍ភាពក្រីក្របានសន្និដ្ឋានថា "អត្រាភាពក្រីក្ររវាងគ្រួសារដែលមានបុរសជាមេគ្រួសារ និងគ្រួសារដែលមាននារីជាមេគ្រួសារ មិនខុសគ្នាទេ"។

ពាក្យថា មេគ្រួសារ ដែលត្រូវបានគេយកមកប្រើប្រាស់ ដើម្បីវាស់ស្ទង់ផលប៉ះពាល់នៃភាពក្រីក្រលើយេនឌ័រ នៅមានចំណុចខ្សោយមួយចំនួន។ នារីភាគច្រើនដែលជាមេគ្រួសារ ជាស្ត្រីមេម៉ាយ និងស្ថិតនៅក្នុងក្រុមមនុស្សដែលមាន

វ័យចំណាស់។ នៅក្នុងគ្រួសារដែលមាននារីជាមេគ្រួសារទាំងនេះ មានសមាជិកពេញវ័យផ្សេងទៀតដែលជាអ្នករកចំណូល ប៉ុន្តែនៅក្នុងបរិបទកម្ពុជា សមាជិកគ្រួសារដែលមានវ័យចាស់ជាងគេ និងមានការគោរពច្រើនបំផុត ត្រូវបានចាត់ទុកថាជាមេគ្រួសារ។ នេះអាចជាមូលហេតុដែលធ្វើឱ្យប្រាក់ចំណូលជាមធ្យមរបស់គ្រួសារដែលមាននារីជាមេគ្រួសារ ខ្ពស់ជាងប្រាក់ចំណូលជាមធ្យមរបស់គ្រួសារដែលមានបុរសជាមេគ្រួសារ។

គ្រួសារដែលមាននារីជាមេគ្រួសារ មានមួយភាគបួននៃគ្រួសារទាំងអស់នៅកម្ពុជា។ សង្គ្រាមអូសបន្លាយរយៈពេលជាច្រើនទសវត្សរ៍ បានធ្វើឱ្យនារីមួយចំនួន ក្លាយជានារីមេម៉ាយ។ នារីមួយចំនួនត្រូវប្តីលែង ឬបោះបង់ចោល។ ទោះបីជាគ្រួសារដែលមាននារីជាមេគ្រួសារពុំសូវក្រីក្រខ្លាំង ប៉ុន្តែគ្រួសារទាំងនេះមានតម្រូវការ ជួបឧបសគ្គ និងភាពងាយរងគ្រោះមួយចំនួន ដោយឡែកខុសពីគ្រួសារដែលមានបុរសជាមេគ្រួសារ។ មិនតែប៉ុណ្ណោះគ្រួសារទាំងនេះ ត្រូវបានសហគមន៍កំណត់ជាទូទៅថា ជាគ្រួសារដែលស្ថិតនៅក្នុងចំណោមគ្រួសារក្រីក្របំផុតនៅក្នុងសហគមន៍ទៀតផង។ លទ្ធផលនៃការវាយតំលៃភាពក្រីក្រដោយមានការចូលរួមបានបង្ហាញថា ក្រុមដែលត្រូវបានចាត់ទុកថា ជាក្រុមងាយនឹងរងគ្រោះដោយសារភាពក្រីក្របំផុតនៅតំបន់ជនបទ គឺស្ត្រីមេម៉ាយដែលមានកូនតូចៗក្នុងបន្ទុក ហើយគ្មានកំលាំងពលកម្មមនុស្សពេញវ័យនៅក្នុងគ្រួសារ។ ស្ត្រីទាំងនេះ ត្រូវខិតខំប្រឹងប្រែងរកស៊ីចិញ្ចឹមគ្រួសារដោយគ្មានជំនួយ ឬការជួយជ្រោមជ្រែងថែទាំកូនៗរបស់ពួកគេ ពីនរណាផ្សេងទៀតនៅក្នុងគ្រួសារឡើយ (ADB, ឆ្នាំ២០០១)។

នារីមេគ្រួសារដែលធ្វើការងារកសិកម្ម ទំនងជាមានចំនួនច្រើនជាងបុរសមេគ្រួសារ។ ប៉ុន្តែគ្រួសារដែលមាននារីជាមេគ្រួសារ ទំនងជាមានកម្មសិទ្ធិដីធ្លីតិចជាង ងាយនឹងបាត់បង់ដីធ្លីរបស់ខ្លួននៅពេលមានវិបត្តិសេដ្ឋកិច្ចគ្រួសារ និងមានអត្រាពលកម្មកុមារខ្ពស់ជាងគ្រួសារដែលមានបុរសជាមេគ្រួសារ។ កុមារទាំងពីរភេទដែលធ្វើការងារពលកម្មទំនងជាចេញមកពីគ្រួសារដែលមាននារីជាមេគ្រួសារ ច្រើនជាងមកពីគ្រួសារដែលមានបុរសជាមេគ្រួសារៈ ក្នុងចំណោមកុមារធ្វើការងារពលកម្ម ក្មេងស្រី ៦០ភាគរយ និងក្មេងប្រុស ៤៨ភាគរយ មកពីគ្រួសារដែលមាននារីជាមេគ្រួសារ បើប្រៀបធៀបជាមួយនឹងក្មេងស្រី ៤៣ភាគរយ និងក្មេងប្រុស ៣៤ភាគរយ មកពីគ្រួសារដែលមានបុរសជាមេគ្រួសារ (CHDR ស្តីពីពលកម្មកុមារ - UNDP ឆ្នាំ២០០០)។ ទោះបីជាអត្រាពលកម្មកុមារនៅក្នុងគ្រួសារដែលមាននារីជាមេគ្រួសារ មិនសូវខុសគ្នាប៉ុន្មានពីគ្រួសារដែលមានបុរសជាមេគ្រួសារ ប៉ុន្តែគ្រួសារដែលមាននារីជាមេគ្រួសារ ពឹងផ្អែកទាំងស្រុងលើយន្តការដោះស្រាយផ្អែកលើយេនឌ័រដូចជា ពលកម្មកុមារ ជាពិសេសពលកម្មរបស់ក្មេងស្រី។

**ក្រាហ្វិក ១.៣ : អត្រាពលកម្មកុមារ ក្នុងចំណោមកុមារអាយុ ១៤-១៧ឆ្នាំ នៅតាមភេទនៃមេគ្រួសារ ឆ្នាំ១៩៩៩**




**ប្រភព:** UNDP, CHDR, ឆ្នាំ២០០០

គ្រួសារដែលមាននារីជាមេគ្រួសារ ក៏ពុំអាចទទួលបានផលប្រយោជន៍ស្មើគ្នាពីអន្តរាគមន៍អភិវឌ្ឍន៍ដែរ។ ការវិភាគយេនឌ័រលើកម្មវិធីអង្ករពលកម្មរបស់កម្មវិធីស្បៀងអាហារពិភពលោក បានរកឃើញថា នារីមេគ្រួសារភាគច្រើន មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកម្មវិធីអង្ករពលកម្ម និងដំណើរការធ្វើសេចក្តីសំរេចនានាទេ (WFP ឆ្នាំ២០០១)។ មូលហេតុដែលរារាំងមិនឱ្យនារីចូលរួមក្នុងកម្មវិធីអង្ករពលកម្មរួមមាន ឧបសគ្គជាក់ស្តែងក្នុងការធ្វើដំណើរ និងពេលវេលារបស់នារី ព្រមទាំងឧបសគ្គផ្នែករចនាសម្ព័ន្ធកម្មវិធីគឺ: ការគ្រប់គ្រងកម្មវិធីអង្ករពលកម្មនេះ មានទំនាក់ទំនងទៅនឹងឋានានុក្រមផ្លូវការរបស់រាជរដ្ឋាភិបាល ហើយឋានានុក្រមនេះ ជាឋានានុក្រមដែលគ្រប់គ្រងដោយបុរស។ របាយការណ៍បានសន្និដ្ឋានថា ទាក់ទងនឹងការចូលរួមរបស់នារីក្រីក្រ ឧបសគ្គដែលនារីក្រីក្រប្រឈមមុខ គឺបញ្ហាអនុវត្តជាក់ស្តែងច្រើនជាងឧបសគ្គផ្នែកវប្បធម៌។ នារីមេគ្រួសារ ក៏ត្រូវបានគេផ្តាច់ចេញពីបណ្តាញសហគមន៍ ដូចជា "ក្រុមមិត្តភាពបុរស" (male friendship circles) ផងដែរ និងមិនទទួលបានពត៌មានទាក់ទងនឹងសកម្មភាពអភិវឌ្ឍន៍ក្នុងមូលដ្ឋាន រួមទាំងកម្មវិធីអង្ករពលកម្មផងដែរ។

គ្រួសារដែលមាននារីជាមេគ្រួសារ ត្រូវបានកំណត់ថាជាផ្នែកមួយនៃប្រជាជនដែលងាយរងគ្រោះ នៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) និងផែនការអភិវឌ្ឍន៍សង្គមកិច្ច សេដ្ឋកិច្ច ប្រាំឆ្នាំលើកទី២ ឆ្នាំ២០០១-២០០៥ (SEDPII)។ ប៉ុន្តែយុទ្ធសាស្ត្រ និងផែនការនេះ មិនបានកំណត់អំពីការឆ្លើយតប ឬសកម្មភាពជាយុទ្ធសាស្ត្រសំរាប់ដោះស្រាយតម្រូវការណាមួយ និងបានបង្ហាញបន្តិចបន្តួចអំពីគំរោងដែលស្ថិតនៅក្រោមការឧបត្ថម្ភរបស់អ្នកផ្តល់ជំនួយ ឬគំរោងរបស់អង្គការក្រៅរដ្ឋាភិបាល ដែលបានកំណត់យកគ្រួសារទាំងនោះជាក្រុមគោលដៅ។

គ្រួសារដែលនារីជាមេគ្រួសារ មានលក្ខណៈពិសេសនៃផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចមួយចំនួនដែលមានឥទ្ធិពលលើការអភិវឌ្ឍន៍របស់ពួកគេ ប៉ុន្តែបើសិនជាយើងផ្តោតការយកចិត្តទុកដាក់ត្រឹមតែទៅលើគ្រួសារទាំងនោះ នោះយើងនឹងពុំអាចបានយល់ដឹងអំពីបញ្ហាយេនឌ័រ និងភាពក្រីក្ររបស់នារីដែលរស់នៅក្នុងគ្រួសារមានបុរសជាមេគ្រួសារកំពុងតែប្រឈមមុខនោះទេ។ នារីមានចំនួន ៥០ភាគរយ នៃចំនួនប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រស្បៀងអាហារ និងមានចំនួន ៥១ភាគរយ នៃចំនួនប្រជាជនរស់នៅចន្លោះបន្ទាត់ភាពក្រីក្រស្បៀងអាហារ និងបន្ទាត់ភាពក្រីក្រ។ តាមការប៉ាន់ស្មាន ៨២ភាគរយ នៃនារីក្រីក្ររស់នៅក្នុងគ្រួសារដែលមានបុរសជាមេគ្រួសារ។ ការកំណត់គ្រួតពិនិត្យ និងដោះស្រាយបញ្ហាក្រីក្រនៅក្នុងគ្រួសារ គឺជាការងារលំបាក។ សូចនាករជាតិស្តីពីភាពក្រីក្រ រៀបចំឡើងដោយផ្អែកលើគ្រួសារ ពុំបានបញ្ចូលសូចនាករឆ្លើយតបទៅនឹងយេនឌ័រទេ (លើកលែងតែសូចនាករសំរាប់គ្រួសារដែលមាននារីជាមេគ្រួសារ)។ នារីនៅក្នុងគ្រួសារក្រីក្រដែលមានបុរសជាមេគ្រួសារ ក៏មាន តម្រូវការយេនឌ័រជាក់លាក់និងសំខាន់ដូចគ្នា មានឧបសគ្គរារាំង និងភាពងាយរងគ្រោះទាក់ទងនឹងតួនាទី និងឋានៈរបស់ពួកគេនៅក្នុងគ្រួសារ និងសង្គមផងដែរ។ កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ចាំបាច់ត្រូវពិចារណាទៅលើតម្រូវការជាក់លាក់ និងភាពងាយរងគ្រោះរបស់គ្រួសារដែលមាននារីជាមេគ្រួសារ នារី និងក្មេងស្រីនៅក្នុងគ្រួសារក្រីក្រដែលមានបុរសជាមេគ្រួសារ។

# ជំពូកទី ២

# ទស្សនៈវិស័យយេនឌ័រ នៅលើទីផ្សារពលកម្ម

**កម្ពុជានាពេលបច្ចុប្បន្ន** .......... ៤៣

**២.១ ស្ថានភាព និន្នាការ និង បញ្ហា** .......... ៤៣

២.១.១ កំលាំងពលកម្ម កំពុងកើនឡើងយ៉ាងឆាប់រហ័ស .......... ៤៤

២.១.២ អត្រាចូលរួមក្នុងកំលាំងពលកម្មកំពុងតែកើនឡើង ក្នុងនោះអត្រារបស់នារីមានកំរិតខ្ពស់ បើធៀបទៅនឹងស្តង់ដារក្នុងតំបន់ .......... ៤៦

២.១.៣ យុវវ័យភាគច្រើន មិនមានការងារធ្វើ .......... ៤៨

២.១.៤ អត្រានារីធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារមានចំនួនច្រើន ប៉ុន្តែអត្រាបុរសធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ កំពុងកើនឡើង .......... ៥០

២.១.៥ អត្រានារីក្នុងការងារមានប្រាក់កំរៃ កំពុងតែកើនឡើង ប៉ុន្តែអតុល្យភាពយេនឌ័រនៅតែកើតមាន .. ៥២

២.១.៦ ប្រភេទការងារ និងឧស្សាហកម្ម ដែលបែងចែកតាមភេទ .......... ៥៤

២.១.៧ ការគាំទ្របន្តិចបន្តួចចំពោះការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច/អាជីវកម្មខ្នាតតូច ដែលពុំត្រូវបានគេយកចិត្តទុកដាក់ មានសារៈសំខាន់បំផុតចំពោះនារី .......... ៥៦

២.១.៨ នារី មានចំនួនតិចតួចនៅក្នុងការងារវិជ្ជាជីវៈ និងក្នុងតំណែងធ្វើសេចក្តីសំរេច .......... ៥៦

២.១.៩ កំរិតវប្បធម៌ មានផលប៉ះពាល់លើប្រាក់កំរៃ និង ឱកាសការងារ .......... ៥៧

២.១.១០ នារីទទួលបានប្រាក់កំរៃតិចជាងបុរស .......... ៥៨

២.១.១១ យុវជនក្នុងចំនួនកាន់តែច្រើនឡើង កំពុងមករកការងារធ្វើនៅទីក្រុង .......... ៥៩

២.១.១២ ឧស្សាហកម្មកាត់ដេរ មានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើជីវិតរស់នៅរបស់នារី .......... ៦០

២.១.១៣ គោលនយោបាយការងារ និងពាណិជ្ជកម្ម មានឥទ្ធិពលខុសគ្នាលើបុរស និងនារី .......... ៦៣

២.១.១៤ តើតំបន់ប្រតិបត្តិការនាំចេញ ដែលត្រូវបានស្នើឡើង ផ្តល់ផលប្រយោជន៍ដល់នារីដែរឬទេ? .......... ៦៦

**២.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល** .......... ៦៧

# ជំពូកទី ២ : ទស្សនៈវិស័យយេនឌ័រនៅលើទីផ្សារពលកម្ម

## កម្ពុជានាពេលបច្ចុប្បន្ន[១]

| សូចនាករ | តំលៃ |
|---|---|
| ភាគរយនារីដែលសកម្មក្នុងវិស័យសេដ្ឋកិច្ច | ៥២ |
| អត្រានារីអាយុ ១៥ឆ្នាំឡើង នៅក្នុងកំលាំងពលកម្មសរុប | ៨២ |
| អត្រានារី/បុរសអាយុ ១៥-១៩ឆ្នាំ នៅក្នុងកំលាំងពលកម្ម | ៧២/៦២ |
| ភាគរយនារី/បុរសដែលធ្វើការងារមានប្រាក់កំរៃ | ១៤/១៩ |
| ភាគរយនារីនៅក្នុងការងារមានប្រាក់កំរៃសរុប | ៤៣ |
| ភាគរយនារីដែលធ្វើការងារកសិកម្មមានប្រាក់កំរៃ | ៥១ |
| ភាគរយនារីដែលធ្វើការងារមានប្រាក់កំរៃនៅក្នុងឧស្សាហកម្មកាត់ដេរ | ៨៤ |
| ភាគរយនារីដែលធ្វើការងារមានប្រាក់កំរៃនៅក្នុងវិស័យឧស្សាហកម្មផ្សេងទៀត | ៣១ |
| ភាគរយនារីដែលធ្វើការងារមានប្រាក់កំរៃនៅក្នុងវិស័យសេវាសាធារណៈ | ២២ |
| ភាគរយនារីដែលធ្វើការងារមានប្រាក់កំរៃនៅក្នុងសេវាផ្សេងទៀត | ២៥ |
| ភាគរយវិស័យឧស្សាហកម្មកាត់ដេរនៅក្នុងកំណើននៃវិស័យឧស្សាហកម្ម | ៩៤ |
| ភាពខុសគ្នារវាងភាគរយប្រាក់កំរៃរបស់ បុរស និង នារី | ៣៣ |

## ២.១ ស្ថានភាព និន្នាការ និង បញ្ហា

វិសមភាពយេនឌ័រ កំពុងរីករាលដាលនៅក្នុងទីផ្សារពលកម្ម នៅព្រះរាជាណាចក្រកម្ពុជា។ ដោយសារឥរិយាបថប្រពៃណីចំពោះការអប់រំរបស់ក្មេងស្រី និងមុខរបរ "សមរម្យ" សំរាប់នារី និងបុរសបានធ្វើឱ្យមានវិសមភាពនេះឡើង ហើយបន្តធ្វើឱ្យមានគំលាតយេនឌ័រនេះនៅក្នុងវិស័យការងារ។ ការសំរេចបាននូវសមភាពយេនឌ័រ ជាកិច្ចការមួយដែលលំបាកណាស់នៅក្នុងបរិបទនៃការផ្លាស់ប្តូរទិសដៅទៅរកសេដ្ឋកិច្ចទីផ្សារ ដែលកំលាំងពលកម្មមានការកើនឡើងយ៉ាងឆាប់រហ័ស ប៉ុន្តែឱកាសការងារថ្មីមានតិចតួច។ ទោះបីជាមាននារីដែលមានកំរិតវប្បធម៌ខ្ពស់ អាចទទួលបានមុខតំណែងខ្ពស់ៗ ក៏ដោយ ក៏កំរិតនៃអក្ខរភាព និងការអប់រំទាបរបស់នារី ដែលមានជាទូទៅនៅក្នុងកំលាំងពលកម្មបច្ចុប្បន្ន គឺជាឧបសគ្គរារាំងដល់នារីភាគច្រើន មិនឱ្យទទួលបានឱកាសការងារ។ សូម្បីតែនារីដែលមានកំរិតវប្បធម៌ខ្ពស់ ក៏មានតំណាងតិចតួចនៅក្នុងតំណែងគ្រប់គ្រង និងតំណែងធ្វើសេចក្តីសំរេចជាន់ខ្ពស់។ ជាការចាំបាច់ ត្រូវចាត់វិធានការឱ្យបានសកម្មជាមុន ដើម្បីលើកកំពស់ការផ្តល់អំណាចខាងសេដ្ឋកិច្ចដល់នារី ហើយពង្រឹងតួនាទី និងស្ថានភាពក្នុងសង្គមរបស់នារីកម្ពុជា។

១ ប្រភព : [a] ជំរឿនឆ្នាំ១៩៩៨ [b] LFS អង្កេតកំលាំងពលកម្មឆ្នាំ២០០១ [c] CDRI ឆ្នាំ២០០៣

ការកើនឡើងយ៉ាងឆាប់រហ័ស នូវកំលាំងពលកម្មសរុប និងចំនួនយុវវ័យចូលទៅក្នុងកំលាំងពលកម្ម បានដាក់សំពាធយ៉ាងធ្ងន់ធ្ងរទៅលើរាជរដ្ឋាភិបាល ដើម្បីឱ្យបង្កើនឱកាសការងាររកប្រាក់កំរៃ។ ជោគជ័យក្នុងការបង្កើនឱកាសការងារនឹងកំណត់អំពីទស្សនៈវិស័យសេដ្ឋកិច្ចរបស់កម្ពុជា។ ប៉ុន្តែនឹងមានហានិភ័យខ្ពស់ បើសិនជាកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យមានកំណើនសេដ្ឋកិច្ច និងបង្កើតឱ្យមានការងារ មើលរំលងស្ថានភាពរងគ្រោះរបស់នារីនៅក្នុងកំលាំងពលកម្ម ហើយនឹងបន្តឬបង្កើនវិសមភាពយេនឌ័រ។

កំលាំងពលកម្មភាគច្រើន គឺនៅតំបន់ជនបទ។ ដោយសារសមត្ថភាពមានកំរិតនៃវិស័យកសិកម្មក្នុងការស្រូបយកកំលាំងពលកម្មដែលចេះតែកើនឡើងនេះ បានជំរុញឱ្យយុវវ័យហូរចូលមកក្នុងទីក្រុង ដែលនៅទីនោះ ឱកាសការងារថ្មីៗក៏នៅមានកំរិតដែរ។ ឥទ្ធិពលសង្គមនៃការមករកការងារធ្វើនៅទីក្រុង គឺជាបញ្ហាមួយដែលកំពុងតែមានការបារម្ភ ដោយសារបញ្ហានេះ មានឥទ្ធិពលខុសគ្នាទៅលើយុវនារី និងយុវជន។ ជាការចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើការពង្រីកឱកាសការងារនៅតំបន់ជនបទ។

ក្នុងពេលកន្លងទៅថ្មីៗនេះ មានការកើនឡើងនូវការងារមានប្រាក់កំរៃនៅក្នុងវិស័យកាត់ដេរ ប៉ុន្តែអនាគតរបស់ឧស្សាហកម្មកាត់ដេរ នៅមិនទាន់ច្បាស់លាស់នៅឡើយ។ នៅពេលដែលកម្ពុជា ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅឆ្នាំនេះ កាលបរិច្ឆេទផុតកំណត់នៃកិច្ចព្រមព្រៀងវាយនភណ្ឌនៅចុងឆ្នាំ២០០៤ (Multi Fibers Agreement) នឹងលុបបំបាត់ចោលកូតាសំរាប់ការនាំចេញសំលៀកបំពាក់ ពីកម្ពុជាទៅសហរដ្ឋអាមេរិក។ កាលបរិច្ឆេទផុតកំណត់នៃកិច្ចព្រមព្រៀង ដែលអនុវត្តចំពោះគ្រប់សមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់ ដែលពីមុនបានកំណត់អំពីបរិមាណក្រណាត់ និងសំលៀកបំពាក់ដែលត្រូវនាំចេញពីទីផ្សារប្រទេសកំពុងអភិវឌ្ឍន៍ ទៅប្រទេសអភិវឌ្ឍន៍ ដែលកត្តានេះបានអនុញ្ញាតិឱ្យអ្នកផលិតដែលចំណាយទាប មានលទ្ធភាពគ្រប់យ៉ាងពង្រីកផលិតកម្ម និងបានទាញយកវិនិយោគនេះពីប្រទេសកម្ពុជា។ មានការសន្និដ្ឋានជាច្រើន អំពីផលប៉ះពាល់នៃការប្រែប្រួលលើឧស្សាហកម្មកាត់ដេររបស់កម្ពុជា។ ទោះជាយ៉ាងនេះក្តី ការបិទទ្វាររោងចក្រកាត់ដេរ គឺជាបញ្ហាយេនឌ័រមួយជាចំបងដោយសាររោងចក្រទាំងនេះ ជាប្រភពចំណូលសំខាន់របស់យុវនារីក្នុងពេលបច្ចុប្បន្ននេះ។

មុនពេលមានវត្តមាននៃវិស័យកាត់ដេរ បុរសមានចំនួនច្រើនជាងនារីនៅក្នុងការងារមានប្រាក់កំរៃ ពោលគឺ ជាង ២នាក់ធៀបនឹង ១នាក់។ ក្រៅពីកសិកម្ម និងការងារមានប្រាក់កំរៃ នារីបន្តប្រកបអាជីពផ្ទាល់ខ្លួននៅក្នុងសហគ្រាសខ្នាតតូចមិនផ្លូវការ ឬធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ។ ទោះបីជាសហគ្រាសខ្នាតតូច មានសារៈសំខាន់ចំពោះនារី (និងបុរសជាច្រើន) នៅគ្រប់តំបន់ទាំងអស់នៃប្រទេសក៏ដោយ ប៉ុន្តែគេសង្កេតឃើញថា នៅមានការយកចិត្តទុកដាក់តិចតួចលើការអភិវឌ្ឍន៍វិស័យនេះនៅឡើយ។

## ២.១.១ កំលាំងពលកម្ម កំពុងកើនឡើងយ៉ាងឆាប់រហ័ស

បញ្ហាចំបងបំផុតមួយដែលប្រទេសជាតិកំពុងតែប្រឈមមុខ គឺការកើនឡើងនូវពលករថ្មីៗនៅក្នុងកំលាំងពលកម្មដែលទើបកើតក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ (ក្រាហ្វិក ២.១ និងតារាង ២.១)។ តាមការប៉ាន់ស្មាន កំលាំងពលកម្មនៃក្រុម អាយុ ២០-២៤ឆ្នាំ បានកើនឡើង ៦៦ភាគរយ នៅចន្លោះឆ្នាំ១៩៩៧ និង ២០០១ ហើយចំនួនយុវវ័យអាយុ

១៥-១៩ឆ្នាំ នៅក្នុងកំលាំងពលកម្ម បានកើនឡើង ៥៨ភាគរយ ។ សមាមាត្រកំលាំងពលកម្មក្រោមអាយុ ២៥ឆ្នាំ បានកើនឡើងពី ២៧ ទៅ ៣៦ភាគរយ ក្នុងអំឡុងពេលជាង ៤ឆ្នាំកន្លងមកនេះ ។

### តារាង ២.១ : កំលាំងពលកម្មតាមក្រុមអាយុ ពីឆ្នាំ១៩៩៧ ដល់ ២០០១

| ក្រុមអាយុ | កំលាំងពលកម្ម ឆ្នាំ ១៩៩៧ | កំលាំងពលកម្ម ឆ្នាំ ២០០១ | កំណើន (%) |
|---|---|---|---|
| ១៥-១៩ | ៦៦១.៤២២ | ១.០៤៣.១៦៣ | ៥៨ |
| ២០-២៤ | ៦២៦.៥៦៥ | ១.០៤២.៣៦៤ | ៦៦ |
| ២៥-២៩ | ៧៨៣.៩៩៩ | ៦៤១.៦៣៣ | -១៨ |
| ៣០-៣៤ | ៦៣៥.២៦៥ | ៦៤៩.៥១៣ | ២ |
| ៣៥-៣៩ | ៥៧៩.៨៧៥ | ៦៣៦.៤៩៩ | ១០ |
| ៤០-៤៤ | ៤១៥.៩៥៥ | ៥៦០.២៧៧ | ៣៥ |
| ៤៥-៤៩ | ៣៦០.៣០១ | ៤៦៦.២៤៦ | ២៩ |
| ៥០-៥៤ | ២៨៦.៣៣៧ | ៣៨៥.៣៦៩ | ៣៥ |
| ៥៥-៥៩ | ២៣៧.១៤១ | ២៤៩.៥៨០ | ៥ |
| ៦០-៦៤ | ១៥៣.៨៨៨ | ១៧២.៥៣៥ | ១២ |
| **ក្រុមទាំងអស់** | **៤.៧៤០.៧៨៨** | **៥.៨៤៧.១៧៩** | **២៣** |

ប្រភព: CSES ឆ្នាំ១៩៩៧, LFS ឆ្នាំ២០០១

### ក្រាហ្វិក ២.១ : កំណើនកំលាំងពលកម្មតាមក្រុមអាយុ ពីឆ្នាំ១៩៩៧ ដល់ ២០០១




ប្រភព: CSES ឆ្នាំ១៩៩៧, LFS ឆ្នាំ២០០១

**ក្រាហ្វិក ២.២ : ការបែងចែកការងាររវាងតំបន់ទីក្រុង និងជនបទ នៅឆ្នាំ១៩៩៧ និងឆ្នាំ២០០១**




ប្រភព: CSES ឆ្នាំ១៩៩៧; LFS, ឆ្នាំ២០០១

កំលាំងពលកម្មមានច្រើនលើសលុបនៅតំបន់ជនបទ: ៨៥ភាគរយ នៃកំលាំងពលកម្មសរុបរស់នៅតំបន់ជនបទ នៅឆ្នាំ២០០១ ហើយនៅក្នុងកំលាំងពលកម្មនៅតំបន់ជនបទ មាន ៥៣ភាគរយ ជានារី ( ក្រាហ្វិក ២.២) ។

## ២.១.២ អត្រាចូលរួមក្នុងកំលាំងពលកម្មកំពុងតែកើនឡើង ក្នុងនោះអត្រារបស់នារីមានកំរិតខ្ពស់ បើធៀបនៅនឹងស្តង់ដារក្នុងតំបន់

កម្ពុជាមានអត្រាកំលាំងពលកម្មនារីចំនួន ៨២ភាគរយ ដែលខ្ពស់ជាងគេបំផុតនៅក្នុងតំបន់ បើប្រៀបធៀបទៅនឹងប្រទេសថៃដែលមាន ៦៤ភាគរយ និងឥណ្ឌូនេស៊ីដែលមាន ៥២ភាគរយ ( ក្រាហ្វិក ២.៣) ។ អត្រានេះ បាននិងកំពុងកើនឡើង ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ មក។ ក្នុងចំណោមប្រជាជនអាយុចាប់ពី ១០ឆ្នាំឡើងអត្រាកំលាំងពលកម្មនារី បានកើនឡើងពី ៥៥ភាគរយ ក្នុងឆ្នាំ១៩៩៣/១៩៩៤ ទៅដល់ ៧១ភាគរយ ក្នុងឆ្នាំ២០០១។ ក្នុងអំឡុងពេលដូចគ្នានេះ អត្រាកំលាំងពលកម្មបុរស បានកើនឡើងពី ៥៨ ទៅ ៧២ភាគរយ ។ ស្ថិតិកំលាំងពលកម្មក៏បានបង្ហាញផងដែរថា អត្រាចូលរួមក្នុងកំលាំងពលកម្មនៅតំបន់ជនបទ ខ្ពស់ជាងនៅតំបន់ទីក្រុង/ទីប្រជុំជន ជាពិសេសអត្រានារី ។

**ក្រាហ្វិក ២.៣ : អត្រាចូលរួមក្នុងកំលាំងពលកម្មនៅក្នុងតំបន់**




ប្រភព: World Employment Report (ILO ឆ្នាំ២០០១) LFS ឆ្នាំ២០០១

**ក្រាហ្វិក ២.៤ : ចំនួនមនុស្សនៅក្នុងកំលាំងពលកម្ម តាមក្រុមអាយុ និង ភេទ**




ប្រភព: LFS ឆ្នាំ២០០១

នារីមាន ៥២ភាគរយនៃចំនួនប្រជាជនសរុប (ជំរឿនប្រជារាស្ត្រឆ្នាំ១៩៩៨) នៅកម្ពុជា និងមាន ៥២ភាគរយនៃចំនួនប្រជាជនដែលសកម្មក្នុងវិស័យសេដ្ឋកិច្ច (LFS ឆ្នាំ២០០១)។ ទោះបីជាអត្រាកំលាំងពលកម្មបុរស ខ្ពស់ជាងនារីនៅគ្រប់ក្រុមអាយុពី២៥ឆ្នាំក៏ដោយ ក៏ចំនួនដ៏លើសលប់របស់នារីនៅក្នុងចំណោមប្រជាជនសរុប ដែលមានអាយុចាប់ពី ១៥ ឡើង បានធ្វើឱ្យនារីមានចំនួនច្រើនជាងបុរសនៅក្នុងកំលាំងពលកម្ម នៅគ្រប់ក្រុមអាយុទាំងអស់ ចាប់ពី ១៥-៥៤ លើកលែងតែក្រុមអាយុ ២៥-២៩។

នារីទំនងជាចូលរួមក្នុងកំលាំងពលកម្មមុនបុរស ។ អត្រាកំលាំងពលកម្មក្មេងស្រីអាយុ ១៥-១៩ឆ្នាំ មាន ៧២ភាគរយ ពោលគឺ ខ្ពស់ជាងក្មេងប្រុសដែលមាន ៦២ភាគរយ (LFS ២០០១) ។ នេះបញ្ជាក់ថា សមាមាត្ររបស់ក្មេងប្រុសដែលនៅបន្តការសិក្សា មានកំរិតខ្ពស់ជាងក្មេងស្រី ដោយសារក្មេងស្រីបោះបង់ចោលការសិក្សា ហើយចាប់ផ្តើមចូលធ្វើការងារ ។

កំណើនកុមារ និងយុវជននៅក្នុងកំលាំងពលកម្មបានកើនឡើង ជាពិសេសនៅក្នុងតំបន់ជនបទ (ក្រាហ្វិក ២.៥) ។ ការចូលរួមក្នុងកំលាំងពលកម្ម នៅតែមានកំរិតខ្ពស់ចំពោះនារីក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ ទាំងនៅក្នុងទីក្រុង/ទីប្រជុំជន និងតំបន់ជនបទ ។ ប៉ុន្តែនៅក្នុងក្រុមអាយុ ១០-១៤ឆ្នាំ ក្មេងប្រុសចូលរួមក្នុងកំលាំងពលកម្ម មានចំនួនច្រើនជាងក្មេងស្រីបន្តិច ។ ចំណុចនេះ ហាក់ដូចជាសមស្របទៅនឹងនិន្នាការចុះឈ្មោះចូលរៀននៅមធ្យមសិក្សា រហូតដល់ឆ្នាំ ២០០១ (សូមមើលជំពូកទី៤) ។

**ក្រាហ្វិក ២.៥ : កំលាំងពលកម្មកុមារនិងយុវជន នៅក្នុងទីក្រុង/ទីប្រជុំជន និងតំបន់ជនបទ**




ប្រភព: LFS, ឆ្នាំ២០០១

## ២.១.៣ យុវវ័យភាគច្រើន មិនមានការងារធ្វើ

តាមរបាយការណ៍នៅក្នុងអង្កេតកំលាំងពលកម្មបានឱ្យដឹងថា អ្នកគ្មានការងារធ្វើក្នុងក្រុមអាយុ ១៥ឆ្នាំឡើង មាន ១,៧ភាគរយ នៅឆ្នាំ២០០១ ក្នុងនោះនារីមាន ២,២ភាគរយ ហើយបុរសមាន ១,៥ភាគរយ (តារាង ២.២) ។ ការកំណត់អំពីនិន្នាការអ្នកអត់ការងារធ្វើ ទំនងជាមានលក្ខណៈខុសប្លែកគ្នាទៅតាមប្រភពពិតមាន ដូច្នេះធ្វើឱ្យមានការលំបាកក្នុងការតាមដាននិន្នាការនេះ ។ ជំរឿនប្រជារាស្ត្រឆ្នាំ១៩៩៨ បានរាយការណ៍អំពីអត្រាអ្នកអត់ការងារធ្វើសរុប ចំនួន ៥,៣ភាគរយ ហើយការអង្កេតកំលាំងពលកម្មនៅឆ្នាំ២០០០ បានបញ្ជាក់ថា អត្រាអ្នកអត់ការងារធ្វើ មាន ២,៥ភាគរយ ដែលបង្ហាញឱ្យឃើញពីការធ្លាក់ចុះជាទូទៅនូវអត្រាអ្នកអត់ការងារធ្វើ ។ ទោះបីជាមានការកំណត់ខុសៗគ្នាក៏ដោយ

ក៏ប្រភពទាំងអស់បានបង្ហាញថា អត្រាអ្នកអត់ការងារធ្វើនៅទីក្រុង/ទីប្រជុំជន ខ្ពស់ជាងនៅតំបន់ជនបទ ហើយអត្រាអត់ការងារធ្វើក្នុងចំណោមនារី ខ្ពស់ជាងបុរស ។ អត្រាអ្នកអត់ការងារធ្វើក្នុងចំណោមយុវជន ក៏មានកំរិតខ្ពស់ផងដែរ ។ ក្នុងអត្រាអ្នកអត់ការងារធ្វើសរុបឆ្នាំ២០០១ មានយុវជនចំនួន ៦០ភាគរយ ហើយ ៧៣ភាគរយ នៃបុរសអត់ការងារធ្វើ ស្ថិតនៅក្នុងក្រុមអាយុ ១៥-២៤ឆ្នាំ ។ អត្រានារីអត់ការងារធ្វើ មាននៅក្នុងក្រុមអាយុជាច្រើនខុសៗគ្នា ហើយមានអត្រាខ្ពស់បំផុតនៅក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ និង ៣៥-៣៩ឆ្នាំ (LFS ឆ្នាំ២០០១) ។

**តារាង ២.២ : *អត្រាអ្នកអត់ការងារធ្វើនៅឆ្នាំ២០០១ (% កំលាំងពលកម្ម)***

| | កំលាំងពលកម្មសរុបអាយុ ១៥ឆ្នាំឡើង | | | អាយុពី ១៥ ទៅ ២៤ឆ្នាំ | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| ជនបទ | ១,៧ | ២,០ | ១,៤ | ២,៧ | ២,៧ | ២,៨ |
| ភ្នំពេញ | ១,៨ | ២,២ | ១,៤ | ៤,៦ | ៤,២ | ៤,៨ |
| ទីប្រជុំជន | ១,៧ | ២,១ | ១,៩ | ៤,៥ | ៤,៥ | ៤,៨ |
| កម្ពុជា | ១,៧ | ២,២ | ១,៥ | ៣,០ | ៣,០ | ៣,០ |

**ប្រភព:** LFS, ឆ្នាំ២០០១

អត្រាអ្នកអត់ការងារធ្វើសរុប ហាក់ដូចជាមិនខ្ពស់ប៉ុន្មានទេនៅក្នុងទីផ្សារពលកម្មកម្ពុជា ដោយសារប្រជាជនភាគច្រើន មិនអាចរស់នៅដោយ *អត់ការងារ*ធ្វើបានទេ ។ ការអត់ការងារធ្វើក្នុងចំណោមយុវជន និងការងារមិនគ្រប់ម៉ោង គឺជាបញ្ហាដ៏ចំបង ទោះបីជាមានពត៌មានតិចតួចស្តីពីបញ្ហាការងារមិនគ្រប់ម៉ោងក៏ដោយ ។ សូចនាករមួយស្តីពីទំហំការងារមិនគ្រប់ម៉ោងនេះ អាចជាសមាមាត្រនៃអ្នកមានការងារធ្វើ ដែលមានលទ្ធភាពធ្វើការងារក្រៅម៉ោងបន្ថែមទៀត ។ នៅឆ្នាំ២០០១ ចំនួន ៣០ភាគរយ នៃអ្នកមានការងារធ្វើទាំងអស់បានរាយការណ៍ថា ពួកគេអាចមានលទ្ធភាពធ្វើការងារក្រៅម៉ោងបន្ថែម ហើយចំនួន ៩ភាគរយទៀត កំពុងស្វែងរកការងារក្រៅម៉ោង ។ នៅក្នុងប្រភេទទាំងពីរនេះ មានអត្រាបុរសខ្ពស់ជាងនារី (គឺ ៣៦ភាគរយ មានលទ្ធភាពធ្វើការងារក្រៅម៉ោង និង ១២ភាគរយ កំពុងស្វែងរកការងារក្រៅម៉ោង) ហើយអត្រានៅតំបន់ជនបទ និងទីប្រជុំជនដទៃទៀត មានកំរិតខ្ពស់ជាងនៅទីក្រុងភ្នំពេញ (ពោលគឺ ៨ភាគរយ និង ៣ភាគរយ) (LFS ឆ្នាំ២០០១) ។ សូចនាករមួយទៀត ស្តីពីអត្រាការងារក្រៅម៉ោង គឺជាការប្រែប្រួលសមាមាត្រនៃកំលាំងពលកម្ម នៅក្នុងការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ ដែលនឹងពិភាក្សានៅក្នុងផ្នែកខាងក្រោយនេះ ។

## ២.១.៤ អត្រានារីធ្វើការងារគ្មានប្រាក់កំរៃនៅក្នុងគ្រួសារមានចំនួនច្រើន... ប៉ុន្តែអត្រាបុរសធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ កំពុងកើនឡើង

តាមការអង្កេតកំលាំងពលកម្មឆ្នាំ២០០១ បានឱ្យដឹងថា ៥៣ភាគរយនៃនារីដែលសកម្មក្នុងវិស័យសេដ្ឋកិច្ច និង ៣២ភាគរយ នៃបុរសដែលសកម្មក្នុងវិស័យសេដ្ឋកិច្ច បានធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ។ ភាគច្រើននៃការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ គឺការងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលក្នុងនោះ ៤៧ភាគរយ នៃនារីដែលជាកំលាំងពលកម្មក្នុងការងារសេដ្ឋកិច្ច និង ២៩ភាគរយនៃបុរសដែលជាកំលាំងពលកម្មក្នុងការងារសេដ្ឋកិច្ចត្រូវបានចាត់ចូលជាអ្នកធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ (ក្រាហ្វិក ២.៦)។

**ក្រាហ្វិក ២.៦ : ស្ថានភាពការងារ តាមភេទ និងក្រុមឧស្សាហកម្មចំបង**




**ប្រភព:** LFS ឆ្នាំ២០០១

ទោះបីជាអ្នកធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារភាគច្រើន ជានារីក៏ដោយ ក៏សមាមាត្រនៃកំលាំងពលកម្មនារីនៅក្នុងប្រភេទការងារនេះ បានថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ (ក្រាហ្វិក ២.៧) ប្រហែលបណ្តាលមកពីកំណើនឱកាសការងារមានប្រាក់កំរៃសំរាប់នារីនៅក្នុងវិស័យកាត់ដេរ។ ក្នុងពេលជាមួយគ្នានេះ សមាមាត្រនៃកំលាំងពលកម្មបុរសដែលស្ថិតក្នុងប្រភេទការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ បានកើនឡើងគឺឆ្លុះបញ្ចាំងឱ្យឃើញអំពីកង្វះឱកាសការងារសំរាប់បុរស ក្រៅពីការងារគ្រួសារ។

ស្ថានភាពការងារខុសគ្នារវាងនារី និងបុរស នៅតែកើតមានទាំងនៅក្នុងតំបន់ជនបទ និងទីក្រុង/ទីប្រជុំជន ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វិក ២.៨។ ក្រៅពីវិស័យកសិកម្ម បុរសទទួលបានការងារមានប្រាក់កំរៃច្រើនជាងនារី (៥២ភាគរយនៃការងារក្រៅពីកសិកម្ម) ជាពិសេសនៅទីក្រុងភ្នំពេញ (៦០ភាគរយ)។ នៅទីក្រុង/ទីប្រជុំជន សមាមាត្ររបស់នារីនៅក្នុងការងារអាជីវកម្មផ្ទាល់ខ្លួន មានកំរិតខ្ពស់ជាងបុរស (៥០ភាគរយ) ប៉ុន្តែនារីទំនងជាធ្វើការងារអាជីវកម្មផ្ទាល់ខ្លួន ច្រើនជាងបុរស (៤៥ភាគរយ) នៅគ្រប់ទីកន្លែងទាំងអស់។ អត្រានារីធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ នៅតែមានកំរិតខ្ពស់ជាងបុរសនៅគ្រប់ទីកន្លែងទាំងអស់ (២២ភាគរយ)។

### ក្រាហ្វិក ២.៧ : អ្នកធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០១




ប្រភព: ជំរឿន ឆ្នាំ១៩៩៨, CSES ឆ្នាំ១៩៩៩, LFS ឆ្នាំ២០០០, LFS ឆ្នាំ២០០១

### ក្រាហ្វិក ២.៨ : ស្ថានភាពការងារក្នុងវិស័យផ្សេងៗក្រៅពីកសិកម្ម តាមទីកន្លែង និងភេទ ឆ្នាំ២០០១




ប្រភព: LFS, ឆ្នាំ២០០១

## ២.១.៥ អត្រានារីក្នុងការងារមានប្រាក់កំរៃ កំពុងតែកើនឡើង...ប៉ុន្តែអតុល្យភាពយេនឌ័រ នៅតែកើតមាន

ទោះបីជាមានការកើនឡើងក៏ដោយ ក៏ទីផ្សារពលកម្មមានប្រាក់កំរៃ នៅតែមានទំហំតូចនៅកម្ពុជា ពោលគឺ មានឱកាសការងារមានប្រាក់កំរៃតិចតួចសំរាប់បុរស ឬនារី ។ មានតែ ១៦ភាគរយ នៃប្រជាជនកម្ពុជាដែលមានការងារធ្វើប៉ុណ្ណោះ ដែលជាអ្នកធ្វើការមានប្រាក់កំរៃ ពោលគឺ បុរស ១៩ភាគរយ និងនារី ១៤ភាគរយ (LFS, ឆ្នាំ២០០១) ។

### ក្រាហ្វិក២.៩: ភាគរយនៃកំលាំងពលកម្មក្នុងការងារមានប្រាក់កំរៃ




ប្រភព: CSES (ឆ្នាំ១៩៩៦, ឆ្នាំ១៩៩៧, ឆ្នាំ១៩៩៩),
ជំរឿន ឆ្នាំ១៩៩៨, LFS (ឆ្នាំ២000, ឆ្នាំ២00១)

### ក្រាហ្វិក២.១០: អត្រានារីក្នុងការងារមានប្រាក់កំរៃ




ប្រភព: CSES (ឆ្នាំ១៩៩៦, ឆ្នាំ១៩៩៧, ឆ្នាំ១៩៩៩),
ជំរឿន ឆ្នាំ១៩៩៨, LFS (ឆ្នាំ២000, ឆ្នាំ២00១)

ទោះបីជាឥឡូវនេះ នារីកំពុងតែចូលរួមកាន់តែច្រើននៅក្នុងទីផ្សារពលកម្មមានប្រាក់កំរៃ (ក្រាហ្វិក ២.៩) ហើយអត្រានារីក្នុងការងារមានប្រាក់កំរៃបានកើនឡើងគួរឱ្យកត់សំគាល់ក៏ដោយ (ក្រាហ្វិក ២.១០) ក៏កំណើនឱកាសការងារមានប្រាក់កំរៃសំរាប់នារី ភាគច្រើនមានតែនៅក្នុងឧស្សាហកម្មកាត់ដេរតែប៉ុណ្ណោះ (ក្រាហ្វិក ២.១១) ។ ការងារមានប្រាក់កំរៃក្នុងវិស័យកសិកម្ម បានកើនឡើងសំរាប់ទាំងនារី និងបុរស ។ កំណើននេះ ប្រហែលជាមានទំនាក់ទំនងទៅនឹងការប្រែប្រួលផ្នែកផលិតកម្មកសិកម្មទីផ្សារក្នុងទ្រង់ទ្រាយធំ និង/ឬកំណើនការបាត់បង់ដីធ្លី ។ ការងារមានប្រាក់កំរៃក្នុងវិស័យសេវាកម្ម មានការប្រែប្រួលបន្តិចបន្តួច ។ ការងារមានប្រាក់កំរៃក្នុងវិស័យរដ្ឋបាលសាធារណៈ/ការពារជាតិ អប់រំ និងសុខាភិបាល/សង្គមកិច្ច មានចំនួន ៦០ ភាគរយ នៃការងារមានប្រាក់កំរៃនៅក្នុងវិស័យសេវាកម្មៈ បុរសទទួលបានការងារ ៧៨ភាគរយ នៃការងារសរុបនៅក្នុងវិស័យទាំងបីនេះ ។ ដោយសារមានកំណើនតិចតួចក្នុងវិស័យនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ឱកាសការងារថ្មីៗដែលជាការងាររបស់បុរសនៅក្នុងវិស័យសេដ្ឋកិច្ចមានតិចតួច ។

### ក្រាហ្វិក ២.១១ : ចំនួនអ្នកមានការងារមានប្រាក់កំរៃធ្វើ ពីឆ្នាំ១៩៩៨ ដល់ ២០០១




**សំគាល់:** ដោយសារមិនមានស្ថិតិស្តីពីការងារនៅក្នុងជួររាជរដ្ឋាភិបាល វិស័យរដ្ឋបាល/ការពារជាតិ អប់រំ និងសុខាភិបាល/សង្គមកិច្ច ត្រូវបានយកមកប្រើប្រាស់ជំនួសឱ្យ "វិស័យសាធារណៈ" ទោះបីជាមានការទទួលស្គាល់ថា វិស័យអប់រំ និង សុខាភិបាល កំពុងតែត្រូវក្លាយទៅឯកជនភាវូបនីយកម្មកាន់តែច្រើនឡើងក៏ដោយ ។

**ប្រភព:** ជំរឿនប្រជារាស្ត្រឆ្នាំ១៩៩៨ និង LFS ឆ្នាំ២០០០ និង ឆ្នាំ២០០១

ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (ដោយ ADB ឆ្នាំ២០០១) នៅប្រទេសកម្ពុជា បានផ្តល់នូវទិន្នន័យគុណភាពមួយចំនួនស្តីពីវិសមភាពយេនឌ័រនៅក្នុងទីផ្សារការងារផ្លូវការ ។ អ្នកចូលរួមក្នុងក្រុមវាយតំលៃភាពក្រីក្រយល់ថា មានឱកាសការងារមានប្រាក់កំរៃតិចតួច សំរាប់ប្រជាជនក្រីក្រទូទៅ ហើយឱកាសការងារសំរាប់នារីក្រីក្រនោះរឹតតែមានតិចទៅទៀត ។ តាមទំនៀមទំលាប់យុវជន ត្រូវបានគេជំរុញឱ្យរកការងារមានប្រាក់កំរៃធ្វើដែលតាមធម្មតាតំរូវឱ្យយុវជនមករកការងារធ្វើនៅទីក្រុង ចំណែកនារីវិញត្រូវបានគេរារាំង ហើយឱកាសការងារសំរាប់នារីក្មេងៗនៅក្នុងរោងចក្រកាត់ដេរ មានលក្ខណៈផ្ទុយទៅនឹងទំនៀមទំលាប់នេះ ។

ដោយស្របទៅនឹងស្ថិតិជាតិ អ្នកចូលរួមក្នុងដំណើរការវាយតំលៃភាពក្រីក្រមានជំនឿថា ឥឡូវនេះឱកាសការងារមានប្រាក់កំរៃសំរាប់នារីអាចមានច្រើនជាងបុរស ដោយយោងទៅតាមកំណើនឧស្សាហកម្មកាត់ដេរដែលពេលនោះកំពុងរីកចំរើន ។ ស្របពេលជាមួយគ្នានោះផងដែរ ជាចុងបញ្ចប់ អ្នកចូលរួមមានយោបល់ថា កម្មកររោងចក្រកាត់ដេរក្មេងៗ អាចនឹងមានស្ថានភាពល្អប្រសើរជាង ប្រសិនបើពួកគេធ្វើការនៅក្នុងភូមិរបស់ពួកគេ ។ នេះគឺដោយសារមានការ

ភ័យខ្លាចថា ប្រសិនបើក្មេងស្រីធ្វើដំណើរមកទីក្រុង/ទីប្រជុំជន ពួកគេនឹង "ដើរខុសផ្លូវ" ហើយនឹងបាត់បង់ព្រហ្មចារីយ៍ មុនពេលរៀបអាពាហ៍ពិពាហ៍ "ត្រឹមត្រូវ" តាមប្រពៃណី (ADB ឆ្នាំ២០០១)។

នៅឆ្នាំ២០០១ មនុស្សជាង ១ លាននាក់បន្ថែមធ្វើការងារមានប្រាក់កំរៃ។ ទាក់ទងនឹងកំលាំងពលកម្មដែលតាមការប៉ាន់ស្មានថានឹងកើនឡើងពី ២២៥.០០០-២៥០.០០០នាក់ក្នុងមួយឆ្នាំ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ (Sok et al, ឆ្នាំ២០០១) អនាគតមិនច្បាស់លាស់នៃឧស្សាហកម្មកាត់ដេរ (ដែលមាន ២០ភាគរយនៃការងារមានប្រាក់កំរៃសរុប) ការកាត់បន្ថយកងទ័ព ក៏ដូចជាកំណែទំរង់រដ្ឋបាល កត្តាទាំងនេះ នឹងធ្វើឱ្យមានការលំបាកចំពោះទីផ្សារការងារផ្លូវការ ក្នុងការស្រូបយកកំលាំងពលកម្មឱ្យបានច្រើន បើសិនពុំមានការវិនិយោគថ្មីប្រកបដោយនិរន្តភាពនោះទេ។ កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតឱ្យមានការងារដើម្បីប្រកបរបរចិញ្ចឹមជីវិតជានិរន្តភាព សំរាប់កំលាំងពលកម្មកម្ពុជាភាគច្រើន ពុំគួរមើលតែលើការងារក្នុងវិស័យផ្លូវការនោះទេ។

## ២.១.៦ ប្រភេទការងារ និងឧស្សាហកម្ម ដែលបែងចែកតាមភេទ

ប្រមាណជា ៧០ភាគរយនៃកំលាំងពលកម្ម ប្រកបការងារកសិកម្មដែលជាការងារសំខាន់របស់ខ្លួន។ ក្រៅពីវិស័យកសិកម្ម មានការបែងចែកការងារទៅតាមភេទ ដោយនារីធ្វើការងារនារីតាមទំនៀមទំលាប់ក្នុងចំនួនតិចតួច ដែលរួមមាន អាជីវកម្ម សិប្បកម្ម ដេរប៉ាក់ និងសិល្បៈ។ មានការពង្រីកឱកាសការងារក្រៅពីកសិកម្មសំរាប់បុរស និងនារី តាំងពីឆ្នាំ១៩៩៨ មក (ក្រាហ្វិក ២.១២)។ ទោះជាយ៉ាងណាក៏ដោយ កំណើនការងារភាគច្រើនសំរាប់នារី គឺមាននៅក្នុងការងារនារីតាមទំនៀមទំលាប់ប៉ុណ្ណោះ។ គេសង្កេតឃើញមាននារីមួយចំនួនតូចនៅក្នុង "ការងារការិយាល័យ" (ឧទាហរណ៍ : អ្នកប្រកបការងារវិជ្ជាជីវៈ អ្នកបច្ចេកទេស ស្មៀន) ឬនៅក្នុងតំណែងធ្វើសេចក្តីសំរេចជាន់ខ្ពស់។ជំរឿនប្រជារាស្ត្រ ឆ្នាំ១៩៩៨ បានផ្តល់នូវទិន្នន័យពិស្តារអំពីការងារ ដែលទិន្នន័យទាំងនេះ បានជួយដល់ការវិភាគស៊ីជំរៅអំពីវិសមភាពយេនឌ័រ ក្នុងវិស័យការងារ។

**ឧទាហរណ៍: ក្រៅពីការងារកសិកម្ម:**

- ៣៣ភាគរយ នៃនារីនៅក្នុងការងារក្រៅពីកសិកម្ម ធ្វើការងារមានប្រាក់កំរៃ។
- ៤៩ភាគរយ នៃការងារក្រៅពីកសិកម្មសំរាប់នារីគឺ ប្រកបអាជីវកម្ម: នារី ២២ភាគរយ ប្រកបអាជីវកម្មលក់រាយផ្ទាល់ខ្លួន ហើយ ១៧ភាគរយ ប្រកបអាជីវកម្មលក់ដូរផ្ទាល់ខ្លួននៅតាមចិញ្ចើមថ្នល់។ នារី ៦ភាគរយ ជាអ្នកធ្វើការងារគ្មានប្រាក់កំរៃសំរាប់គ្រួសារ ដោយប្រកបអាជីវកម្មលក់រាយ ហើយ ៤ភាគរយទៀត ជាអ្នកធ្វើការងារគ្មានប្រាក់កំរៃសំរាប់គ្រួសារ ដោយប្រកបអាជីវកម្មជាអ្នកលក់ដូរនៅតាមចិញ្ចើមថ្នល់។
- ការងារផ្សេងទៀតដែលមានសារៈសំខាន់ចំពោះនារីរួមមាន ការកាត់ដេរ (៣ភាគរយ) ការកែច្នៃម្ហូបអាហារ (៣ភាគរយ) តម្បាញ (៣ភាគរយ) និងសិប្បកម្ម (១ភាគរយ)។ ទោះបីជាមុខរបរទាំងនេះ ជាការងារសំខាន់ ទំហំតូច ក្រៅពីការងារកសិកម្មក៏ដោយ ក៏ការងារទាំងនេះ ត្រូវបានគេទទួលស្គាល់ជាទូទៅថា ជាប្រភពចំណូលសំខាន់ទី២ សំរាប់នារី ជាពិសេសនៅតំបន់ជនបទ។

## ក្រាហ្វិក ២.១២ : ការងារតាមប្រភេទមុខរបរ




ប្រភព: ជំរឿនឆ្នាំ១៩៩៨ - LFS ឆ្នាំ២០០០ និង ឆ្នាំ២០០១

ផ្ទុយទៅវិញ នៅក្នុងជំរឿនឆ្នាំ១៩៩៨ ក្នុងចំណោមបុរសដែលធ្វើការងារសំខាន់ក្រៅពីកសិកម្មមាន ៦១ភាគរយជាអ្នកធ្វើការមានប្រាក់កំរៃ ។ មុខរបរសំខាន់ៗផ្សេងទៀតសំរាប់បុរស រួមមាន អ្នកបើកបរយានយន្ត និងការីម៉ាស៊ីនចល័ត (៧ភាគរយនៃការងារ ក្រៅពីកសិកម្ម) ជំនួយការនៅតាមហាង និងអ្នកលក់ដូរនៅតាមទីផ្សារ (៧ភាគរយ) អ្នកលក់ដូរនៅតាមចិញ្ចើមផ្លូវ (៣ភាគរយ) ឈ្មួញលោហធាតុ និងគ្រឿងយន្ត (៣ភាគរយ) និងពលករ (៣ភាគរយ) ។

ទោះបីជាពុំទាន់មាននៅក្នុងស្ថិតិការងារផ្លូវការក៏ដោយ ក៏ឧស្សាហកម្មផ្លូវភេទដែលកំពុងតែរីកដុះដាលនេះ គឺជាបញ្ហាមួយតំរូវឱ្យមានការចាប់អារម្មណ៍ជាពិសេស ។ តាមការប៉ាន់ស្មានមាននារីចំនួន ១០០.០០០នាក់ កំពុងធ្វើការក្នុងឧស្សាហកម្មផ្លូវភេទនៅកម្ពុជា ។ ដូចនារីដទៃទៀតក្នុងផ្នែកការងារមិនផ្លូវការដែរ នារីទាំងនេះ ប្រឈមមុខនឹងការរំលោភបំពាន ដែលមានចាប់ពីការបៀតបៀនយាយី រហូតដល់ការធ្វើអាជីវកម្ម និងអំពើហឹង្សា។[២] វិស័យការងារមិនផ្លូវការ រួមទាំងឧស្សាហកម្មផ្លូវភេទផង មិនត្រូវបានចែងនៅក្នុងច្បាប់ការងារ ឬផ្តល់នូវកិច្ចការពារដោយសង្គមឡើយ ។ នារីរកស៊ីផ្លូវភេទ ដែលភាគច្រើនត្រូវគេបង្ខំ ឬលក់ឱ្យទៅបំរើការងារបែបនេះ ដោយសារភាពក្រីក្រ ជាទូទៅត្រូវបានគ្រួសារ និងសហគមន៍របស់ពួកគេមិនរាប់រក (សូមមើលជំពូកទី៧) ។

[២] ផ្នែកលើមតិដែលផ្តល់ដោយអង្គការពលកម្មអន្តរជាតិប្រចាំទីក្រុងបាងកក ខែមករា ឆ្នាំ២០០២

## ២.១.៧ ការគាំទ្របន្តិចបន្តួចចំពោះការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច/អាជីវកម្មខ្នាតតូច ដែលពុំត្រូវបានគេយកចិត្តទុកដាក់ មានសារៈសំខាន់បំផុតចំពោះនារី

ការពិភាក្សាអំពីការបង្កើតការងារ និងកំណើនសេដ្ឋកិច្ច ទំនងជាផ្តោតទៅលើទីផ្សារការងារផ្លូវការ (ការងារមានប្រាក់កំរៃ) និងវិស័យកសិកម្ម ។ គេហាក់ដូចជាមើលរំលង អ្នកប្រកបមុខរបរដោយខ្លួនឯង ជាពិសេសនៅក្នុងសហគ្រាសខ្នាតតូច និងវិស័យសេដ្ឋកិច្ចមិនផ្លូវការ ។ ដូចដែលបានកត់សំគាល់តាំងពីដំបូងរួចមកហើយ ក្រៅពីវិស័យកសិកម្ម បុរសទំនងជាស្វែងរកការងារមានប្រាក់កំរៃ (បុរស ៥២ភាគរយ មានការងារក្រៅពីវិស័យកសិកម្ម) ចំណែកនារី ទំនងជាពាក់ព័ន្ធច្រើននឹងការប្រកបមុខរបរដោយខ្លួនឯង (នារី ៤៥ភាគរយ នៃនារីដែលធ្វើការងារក្រៅពីកសិកម្ម) ឬការងារអាជីវកម្មគ្មានប្រាក់កំរៃក្នុងគ្រួសារ (២២ភាគរយ) ។ អាជីវកម្មលើវិស័យមិនផ្លូវការ ជាប្រភពចំណូលសំខាន់ទីពីរ សំរាប់គ្រួសារជាច្រើន ។ អាស្រ័យហេតុនេះ កង្វះការគាំទ្រចំពោះការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច គឺជាបញ្ហាយេនឌ័រដ៏ចំបងមួយ ។

សហគ្រាសខ្នាតតូចទាំងអស់នៅក្នុងវិស័យមិនផ្លូវការ កំពុងប្រឈមមុខនឹងបញ្ហាប្រហាក់ប្រហែលគ្នា:

- សហគ្រាសទាំងនោះ ពុំត្រូវបានគេយកចិត្តទុកដាក់ ទោះបីអាជីវកម្មទាំងនេះទទួលបានការត្រួតពិនិត្យខ្លះៗដែរ ប៉ុន្តែពុំសូវទទួលបានការគាំទ្រទេ ។
- លទ្ធភាពទទួលបានឥណទានមានកំរិត ជាពិសេសទុនបង្វិលដែលត្រូវការចាំបាច់សំរាប់បង្កើត និងពង្រីកអាជីវកម្ម ។
- លទ្ធភាពទទួលបានទីផ្សារ ឬលទ្ធភាពទទួលបានពត៌មានទីផ្សារមានកំរិត ។

ជាសកល មានបទពិសោធន៍មួយចំនួនធំ ដែលទាក់ទងនឹងការបង្កើតសេវានានាដើម្បីដោះស្រាយប្រភេទបញ្ហាទាំងនេះ ។ ប៉ុន្តែក្នុងខណៈដែលអ្នកជំនាញក្នុងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូចអន្តរជាតិ កំពុងពិភាក្សាអំពីវិធីធ្វើឱ្យសេវាអភិវឌ្ឍន៍អាជីវកម្មដែលមានស្រាប់ ឱ្យកាន់តែមាននិរន្តរភាព និងពង្រឹងទីផ្សារសំរាប់សេវាទាំងនេះ មានការអង្កេតថ្មីមួយ ដែលត្រូវបានធ្វើឡើងដោយអង្គការពលកម្មអន្តរជាតិ (ILO) បានរកឃើញថា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ការផ្គត់ផ្គង់សេវាប្រភេទទាំងនេះ មានតិចតួចប៉ុណ្ណោះ ។

## ២.១.៨ នារី មានចំនួនតិចតួចនៅក្នុងការងារវិជ្ជាជីវៈ និងក្នុងតំណែងធ្វើសេចក្តីសំរេច

នារីដែលមានកំរិតវប្បធម៌ខ្ពស់ មានសមត្ថភាពរកការងារការិយាល័យបានធ្វើ ។ ទោះជាយ៉ាងណាក៏ដោយ នារីនៅតែមានចំនួនតិច ហើយជាទូទៅ មិនបានទទួលតំណែងធ្វើសេចក្តីសំរេចទេ ។ នារីមានចំនួនតិចតួចនៅក្នុងការងារដែលមានឋានៈដូចជា ការងារវិជ្ជាជីវៈ តំណែងធ្វើសេចក្តីសំរេច ឬតំណែងគ្រប់គ្រង ។ ប្រហែលមួយភាគបីនៃអ្នកប្រកបមុខវិជ្ជាជីវៈគឺជានារី ហើយមាននារីតែ ១៤ភាគរយប៉ុណ្ណោះក្នុងចំណោមអ្នកតាក់តែងច្បាប់ មន្ត្រីជាន់ខ្ពស់ និងអ្នកគ្រប់គ្រង ។ នារីចំនួនតិចជាង ២ភាគរយ ដែលសកម្មក្នុងវិស័យសេដ្ឋកិច្ច ទទួលបានការងារនៅក្នុងវិស័យសាធារណៈ ដូចជា រដ្ឋបាលសាធារណៈ/ការពារជាតិ អប់រំ និងសុខាភិបាល/សង្គមកិច្ច បើប្រៀបធៀបជាមួយនឹងបុរស ដែលមាន ៨ភាគរយ (LFS ឆ្នាំ២០០១) (សូមមើលជំពូកទី៨) ។

## ២.១.៩ កំរិតវប្បធម៌ មានឥទ្ធិពលប៉ះពាល់លើប្រាក់ចំណូល និង ឱកាសការងារ

ជំរើសការងារសំរាប់បុរស និងនារី ត្រូវកំណត់ទៅតាមកំរិតវប្បធម៌របស់ពួកគេ (Urashima ឆ្នាំ២០០២)។ កំរិតវប្បធម៌នេះរួមមាន ការអប់រំក្នុងប្រព័ន្ធ (ពីបឋមសិក្សារហូតដល់មហាវិទ្យាល័យ) និងការអប់រំក្រៅប្រព័ន្ធ។

អ្នកដែលមិនចេះអក្សរ ឬមានកំរិតវប្បធម៌ទាបជាងបឋមសិក្សា មានចំនួនច្រើនលើសលុបនៅក្នុងការងារកសិកម្ម ឬនេសាទ ដែលជាមុខរបរសំខាន់របស់ពួកគេ។ នៅពេលដែលគេមានកំរិតវប្បធម៌កាន់តែខ្ពស់ ឱកាសបើកចំហរសំរាប់ការងារផ្សេងទៀត ក៏មានច្រើនដែរ (ក្រាហ្វិក ២.១៣)។ ឱកាសនេះមាននៅក្នុងវិស័យកាត់ដេរ ដែលទំនងជាផ្តល់ការងារដល់នារីដែលមានកំរិតវប្បធម៌ខ្ពស់ (Sok et al ឆ្នាំ២០០១)។

ទោះបីជាមានកំរិតវប្បធម៌ដូចគ្នាក៏ដោយ ក៏ជំរើសការងាររវាងនារី និងបុរស ក៏នៅតែមានភាពខុសគ្នាដដែល។ ឧទាហរណ៍: ចំពោះនារីដែលមិនដែលបានសិក្សា ឬបោះបង់ចោលការសិក្សាមុនចប់សាលាបឋមសិក្សា ការងារទូទៅសំរាប់ពួកគេក្រៅពីការងារកសិកម្មមានដូចជា អ្នកជំនួយការលក់ដូរនៅតាមហាង និងអ្នកលក់ដូរនៅតាមទីផ្សារ អ្នកលក់ដូរនៅតាមចិញ្ចើមផ្លូវ ឬការងារសិប្បកម្ម។ បុរសដែលមានកំរិតវប្បធម៌ដូចគ្នានេះ ធ្វើការងារជាអ្នកបើកបរយានយន្ត កម្មករសំណង់ កម្មករ ឬជាទាហាន។

**ក្រាហ្វិក ២.១៣ : កំរិតវប្បធម៌កាន់តែខ្ពស់ ទទួលបានឱកាសការងារកាន់តែច្រើន**




ប្រភព: ជំរឿន ឆ្នាំ១៩៩៨

ចំពោះកំរិតវប្បធម៌បឋមសិក្សា ឱកាសការងារមានច្រើនសំរាប់នារី និងបុរស ហើយសមាមាត្របុរស និងនារីនៅក្នុងការងារកសិកម្ម និងនេសាទបានធ្លាក់ចុះ។ ចំពោះនារី ជំរើសការងារក្រៅពីការងារកសិកម្មគឺ ការលក់ដូរ និងសិប្បកម្ម ប៉ុន្តែការងាររោងចក្រដូចជា ការងារនៅក្នុងឧស្សាហកម្មកាត់ដេរ ក៏បើកចំហរសំរាប់ពួកគេផងដែរ។ បុរសដែលមានកំរិតវប្បធម៌នៅកំរិតនេះ ធ្វើការងារផ្សេងមួយចំនួនដូចជា អ្នកលក់ដូរ ឬប៉ូលីស អ្នកបើកបរយានយន្ត កម្មករ ឬការងារសំណង់។

ចំពោះកំរិតវប្បធម៌ដែលខ្ពស់ជាងនេះ ឱកាសការងារសំរាប់នារី និងបុរស គឺការងារការិយាល័យ ។ ក្នុងចំណោមអ្នកមានកំរិតវប្បធម៌ខ្ពស់ ដែលធ្វើការងារការិយាល័យ នារីមានសមាមាត្រ (៤០ភាគរយ) ខ្ពស់ជាងបុរស (៣៤ភាគរយ) ទោះបីជាបុរសដែលមានកំរិតវប្បធម៌កំរិតនេះ មានចំនួនច្រើនជាងនារី (បុរស៣/នារី១) ក៏ដោយ (ជំរឿន ១៩៩៨) ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងចំណោមមន្ត្រីជាន់ខ្ពស់ និងអ្នកគ្រប់គ្រង ចំនួនសមាមាត្រនារី និងបុរសដែលមានកំរិតវប្បធម៌ខ្ពស់ មានចំនួនស្មើរតែស្មើគ្នា ពោលគឺ នារី ៦ភាគរយ ចំណែកបុរសមាន ៧ភាគរយ ។ ក្រៅពីការងារការិយាល័យ ជំរើសការងារសំរាប់នារីដែលមានកំរិតវប្បធម៌ខ្ពស់ គឺដូចគ្នានឹងជំរើសការងាររបស់នារីដែលមានកំរិតវប្បធម៌ទាបដែរ ហើយជំរើសការងារ សំរាប់បុរសដែលកំរិតវប្បធម៌ខ្ពស់ ដូចគ្នានឹងជំរើសការងារសំរាប់បុរសដែលកំរិតវប្បធម៌ទាបដែរ៖ អ្នកបើកបរយានយន្ត កម្មករសំណង់ កម្មករ អ្នកជំនួយការតាមហាង និងតាមទីផ្សារ ប៉ូលីស ឬទាហាន ។

គំលាតយេនឌ័រក្នុងការទទួលបានការអប់រំ ជាមូលហេតុចំបងចំពោះឱកាសការងាររបស់នារី ។ នារីដែលមានកំរិតវប្បធម៌ខ្ពស់ អាចប្រកួតប្រជែងជាមួយបុរសក្នុងការរកការងារ ។ ទោះជាយ៉ាងណាក៏ដោយ នារីដែលមានកំរិតវប្បធម៌ខ្ពស់មានចំនួនតិច ដូច្នេះនារីដែលអាចប្រកួតប្រជែង ក៏មានចំនួនតិចដែរ ។ ការធ្វើឱ្យមានសមធម៌យេនឌ័រនៅក្នុងប្រព័ន្ធអប់រំក្នុងប្រព័ន្ធ មានសារៈសំខាន់ណាស់ក្នុងការសំរេចឱ្យបាននូវសមភាពយេនឌ័រ នៅក្នុងវិស័យការងារសំរាប់រយៈពេលយូរ ។ បញ្ហាចំពោះមុខ គឺការបង្កើនឱកាសការងារសំរាប់នារីនៅក្នុងកំលាំងពលកម្ម តំរូវឱ្យមានការយកចិត្តទុកដាក់ថែមទៀត ទៅលើគំលាតយេនឌ័រនៅក្នុងអក្ខរភាព និងការអប់រំដែលប៉ះពាល់ដល់ជំរើសការងារ ។

## ២.១.១០ នារីទទួលបានប្រាក់កំរៃតិចជាងបុរស

ជាមធ្យម និងបន្ទាប់ពីបានពិនិត្យមើលបទពិសោធន៍ទៅតាមអាយុ និងការអប់រំរបស់បុគ្គលម្នាក់ៗ ប្រាក់កំរៃរបស់បុរស មានកំរិតខ្ពស់ជាងប្រាក់កំរៃរបស់នារីចំនួន ៣៣ភាគរយ ។ ប្រាក់កំរៃខុសគ្នាច្រើនបំផុតរវាងបុរស និងនារី មាននៅក្នុងចំណោមអ្នកមានការងារធ្វើស្ថិតក្នុងក្រុមអាយុ ១៥-២៩ឆ្នាំ ដែលមិនបានសិក្សាទាល់តែសោះ (៧៥ភាគរយ) ចំណែកប្រាក់កំរៃខុសគ្នាតិចបំផុត គឺនៅក្នុងចំណោមអ្នកមានការងារធ្វើស្ថិតក្នុងក្រុមអាយុ ៣០-៣៩ឆ្នាំ ដែលមានកំរិតវប្បធម៌ត្រឹមអនុវិទ្យាល័យ (ក្រសួងផែនការ ឆ្នាំ១៩៩៩) ដែលបង្ហាញឱ្យឃើញថា មានការរើសអើងយ៉ាងខ្លាំងចំពោះប្រាក់កំរៃរបស់នារី និងក្មេងស្រី ជាពិសេសនៅលើទីផ្សារពលកម្មកម្ពុជា ។ ប្រាក់កំរៃជាមធ្យមប្រចាំថ្ងៃសំរាប់បុរសនៅក្នុងការងារនេសាទ គឺប្រហែល ៥.០០០រៀល (១,២៥ដុល្លា) ចំណែកនារីអាចរកបានតែ ៨៣ភាគរយ នៃចំនួននោះប៉ុណ្ណោះ៖ នៅក្នុងការងារកែច្នៃត្រីសាច់ បុរសអាចរកប្រាក់បាន ៤.១៥០រៀល (១,១៣ដុល្លា) ក្នុងមួយថ្ងៃ ចំណែកនារីរកបានតែ ៦៣ភាគរយ នៃចំនួននោះប៉ុណ្ណោះ (CDRI ឆ្នាំ២០០៣) ។

ការវាយតំលៃភាពក្រីក្រដែលមានការចូលរួម (ADB ឆ្នាំ២០០១) នៅកម្ពុជាបានរកឃើញថា នៅកន្លែងដែលការងារមានប្រាក់កំរៃតិចតួច ជាទូទៅនារីទទួលបានប្រាក់កំរៃតិចជាងបុរស ទោះបីជានារីធ្វើការងារដូចបុរសក៏ដោយ ។ បុរសរកបានប្រាក់កំរៃរហូតដល់ ៥.០០០រៀល (១,២៥ដុល្លាអាមេរិក) ក្នុងមួយថ្ងៃ ដោយធ្វើជាកម្មករធម្មតា ចំណែកនារីវិញ ទទួលបានប្រាក់កំរៃតែ ២.៥០០រៀលប៉ុណ្ណោះ សំរាប់ការងារដូចគ្នានេះ ។ នៅក្នុងការវាយតំលៃភាពក្រីក្របុរសមកពីគ្រប់តំបន់ទាំងអស់នៅទូទាំងប្រទេស ដែលបានចូលរួមក្នុងការធ្វើសម្ភាសន៍បានយល់ឃើញថា គំលាតនេះកើតឡើង ពីព្រោះ៖

- "មានការងារមួយចំនួនដែលនារី មិនអាចធ្វើបាន"
- "នារីសំរាកច្រើនក្នុងពេលធ្វើការងារប្រចាំថ្ងៃ"
- "វាមិនមានបញ្ហាអ្វីទេ ព្រោះប្រាក់កំរៃទាំងនេះ នឹងវិលត្រឡប់ចូលទៅក្នុងហិរញ្ញវត្ថុគ្រួសារ"។

ភាពខុសគ្នានៃប្រាក់កំរៃដែលទាក់ទងនឹងកំរិតវប្បធម៌ មានចំនួនច្រើនសំរាប់នារីជាងបុរសៈ ក្នុងខណៈដែលបុរសមានកំរិតវប្បធម៌ត្រឹមបឋមសិក្សា ទទួលបានប្រាក់បៀវត្សរ៍ប្រចាំឆ្នាំ ខ្ពស់ជាងបុរសដែលមិនបានសិក្សាចំនួន ១០ភាគរយ ចំណែកឯនារីដែលបានរៀនចប់បឋមសិក្សា ទទួលបានប្រាក់បៀវត្សរ៍ប្រចាំឆ្នាំ ខ្ពស់ជាងនារីដែលមិនបានសិក្សាចំនួន ៣២ភាគរយ។ ប្រាក់បៀវត្សរ៍ រឹតតែខ្ពស់ជាងនេះទៅទៀត ចំពោះអ្នកដែលរៀនចប់មធ្យមសិក្សាទុតិយភូមិ និងមហាវិទ្យាល័យ ពោលគឺ បុរសទទួលបាន ៤២ភាគរយ និងនារីទទួលបាន ៨០ភាគរយ បើប្រៀបធៀបទៅនឹងបៀវត្សរ៍របស់បុរស និងនារីដែលមិនបានសិក្សា (ក្រសួងផែនការ ឆ្នាំ១៩៩៩)។

## ២.១.១១ យុវជនក្មេងចំនួនកាន់តែច្រើនឡើង កំពុងមករកការងារធ្វើនៅទីក្រុង

ទីផ្សារពលកម្មនៅជនបទនៃប្រទេសកម្ពុជា មានលក្ខណៈមិនច្បាស់លាស់ និងប្រែប្រួលយ៉ាងឆាប់រហ័ស។ តាមរបាយការណ៍របស់វិទ្យាស្ថានកម្ពុជាអភិវឌ្ឍន៍ធនធានមនុស្ស (CDRI - Chan et al ឆ្នាំ១៩៩៩) ប្រជាជនក្រីក្រត្រូវបង្ខំចិត្តពឹងផ្អែកទៅលើទីផ្សារពលកម្មសំរាប់មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ជាជាងការងារកសិកម្មលក្ខណៈគ្រួសារ។ ប្រសិនបើឱកាសការងារក្នុងមូលដ្ឋានមានគ្រប់គ្រាន់ ការមករកការងារធ្វើនៅទីក្រុង ក៏មានកំរិតទាបដែរ។ ប្រសិនបើតំរូវការពលកម្មនៅក្នុងមូលដ្ឋានមានកំរិតទាប ការមករកការងារធ្វើនៅទីក្រុង គឺជាដំណោះស្រាយតែមួយគត់ សំរាប់អ្នកដែលអត់ការងារធ្វើ។

តាមជំរឿនប្រជារាស្ត្រឆ្នាំ១៩៩៨ អ្នកមករកការងារធ្វើនៅទីក្រុងចំនួនជាង ៨០ភាគរយ ស្ថិតក្នុងអាយុធ្វើការ (១៥-៦៤)។ នៅក្នុងចំណោមមករកការងារធ្វើនៅទីក្រុងដែលមានអាយុ ១៥-១៩ឆ្នាំ នារីមានចំនួនច្រើនជាងបុរស។ ប៉ុន្តែចំនួននារីដែលមករកការងារធ្វើនៅទីក្រុង បានថយចុះ នៅពេលដែលពួកគេឈានចូលដល់អាយុ ២០-៣៩ឆ្នាំ។ តាមលទ្ធផលនៃការស្រាវជ្រាវថ្មីៗ របស់អង្គការ Oxfam ហុងកុង WAC ឆ្នាំ២០០៣ តួលេខនេះបង្ហាញឱ្យឃើញថា តំរូវការ និងការចេញទៅធ្វើការរបស់នារីក្មេងៗដែលមិនទាន់រៀបការ មានកំរិតខ្ពស់ ហើយទន្ទឹមនឹងនេះ តួលេខនេះក៏បានបង្ហាញឱ្យឃើញថា នារី រៀបការរួច និងនារីមានកូន កំពុងតែប្រឈមមុខនឹងលក្ខខ័ណ្ឌសេដ្ឋកិច្ច និងសង្គម។

ស្ថិតិថ្មីៗភាគច្រើន ស្តីពីចំនួនប្រជាជនដែលធ្វើចំណាកស្រុកពីភូមិរបស់ពួកគេទៅទីក្រុង ឬទៅតំបន់ជនបទផ្សេងទៀត ចាប់តាំងពីឆ្នាំ១៩៩៨។ គេមានជំនឿជាទូទៅថា ការធ្វើចំណាកស្រុកកំពុងតែមានការកើនឡើង (Oxfam ហុងកុង WAC ឆ្នាំ២០០៣)។ ឥឡូវនេះ នារីដែលមករកការងារធ្វើនៅទីក្រុងមានកាន់តែច្រើន ទោះបីជាជំរើសការងាររបស់ពួកគេ គ្មានអ្វីក្រៅពីការងារកាត់ដេរ និងឧស្សាហកម្មផ្លូវភេទក៏ដោយ។ ផ្អែកលើការអង្កេតស្តីពីនារីនៅក្នុងការងារទាំងនេះ បានប៉ាន់ប្រមាណថា មាននារីជាង ២៥០.០០០នាក់ បានចាកចេញពីភូមិរបស់ខ្លួន ដើម្បីស្វែងរកការងារមានប្រាក់កំរៃ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។

និន្នាការរបស់ប្រជាជនក្រីក្រក្នុងការចូលទៅក្នុងទីផ្សារពលកម្មផ្លូវការ ដែលមានប្រាក់កំរៃ បានចាប់ផ្តើមកែប្រែទំនៀមទំលាប់បែងចែកការងារទៅតាមយេនឌ័រ និងបាននាំទៅដល់ការចូលរួមក្នុងការងារមានប្រាក់កំរៃជាផ្លូវការនៅលើទីផ្សារពលកម្ម ដោយបំបាត់ចោលរូបភាពចាស់នៃការបែងចែកការងារ និងការធ្វើការងារប្រវាស់ដៃនៅតាមភូមិ។ ការងារប្រវាស់ដៃ (តាមធម្មតា មានរូបភាពជាការទូទាត់តាមឥណទាន) ត្រូវបានអនុវត្តភាគច្រើនដោយនារី។ ការងារមានប្រាក់កំរៃកាន់តែកើនឡើង ដូច្នេះការអនុវត្តន៏ច្បាប់ការងារឱ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត កាន់តែមានសារៈសំខាន់សំរាប់កម្មករនៅគ្រប់ផ្នែកទាំងអស់នៃវិស័យសេដ្ឋកិច្ច។

*"យើងចាំបាច់ត្រូវចេញពីភូមិ ពីព្រោះនៅទីនោះគ្មានការងារធ្វើទេ។ ប៉ុន្តែធ្វើបែបនេះ កំសត់ណាស់ ដោយសារយើងមិនអាចរក្សាទំនាក់ទំនងដោយងាយស្រួលជាមួយគ្រួសារ។ យើងមិនស្គាល់អ្វីៗនៅទីក្រុងធំនោះទេ ហើយយើងងាយត្រូវបោកប្រាស់ដោយមនុស្សអាក្រក់ រួមទាំងពួកកំលោះៗដែលកេងយកចំណេញពីស្នេហា ដោយពួកគេធ្វើឱ្យយើងបាត់បង់កិត្តិយស... យើងក៏ត្រូវធ្វើការងារជាច្រើនម៉ោង ហើយមិនហ៊ានតវ៉ានៅពេលយើងងឺតមុខ ឬឈឺ ព្រោះយើងដឹងថា នេះជាកាតព្វកិច្ចរបស់យើង"។ នេះជាសំដីដកស្រង់របស់កម្មការិនីរោងចក្រកាត់ដេរនៅក្នុងរបាយការណ៍វាយតំលៃភាពក្រីក្រ ដែលមានការចូលរួម (ADB ឆ្នាំ២០០១)។*

## ២.១.១២ ឧស្សាហកម្មកាត់ដេរ មានឥទ្ធិពលយ៉ាងខ្លាំងក្លានៅលើជីវិតរស់នៅរបស់នារី

ដូចដែលបានពិភាក្សាខាងដើម មានការប្រែប្រួលនៃការចូលរួមរបស់នារីនៅក្នុងទីផ្សារពលកម្មផ្លូវការ ទន្ទឹមពេលដែលមានការកើនឡើងយ៉ាងឆាប់រហ័សនូវឧស្សាហកម្មកាត់ដេរ។ បច្ចុប្បន្ន មាននារីក្មេងៗប្រមាណ ១៨០.០០០នាក់បានចូលធ្វើការនៅក្នុងរោងចក្រកាត់ដេរជាង ២០០កន្លែង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការងារនេះបានបង្កើតឱ្យមានឱកាសសេដ្ឋកិច្ចសំខាន់ៗសំរាប់នារីក្មេងៗ ដែលមិនធ្លាប់មានតាំងពីមុនពាក់កណ្តាលទសវត្សរ៍ ឆ្នាំ១៩៩០ មក។ ការអង្កេតមួយ (Sok, et al,. ឆ្នាំ២០០១) ដែលធ្វើឡើងដោយ CDRI បានបង្ហាញថា កម្មកររោងចក្រកាត់ដេរមានកំរិតវប្បធម៌ខ្ពស់ មានចំនួន ៦១ ភាគរយ បានរៀនចប់បឋមសិក្សា ៣១ភាគរយ បានរៀនចប់អនុវិទ្យាល័យ និង ៨ភាគរយ ទទួលបានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ។

ឧស្សាហកម្មកាត់ដេរមាន ៩៤ភាគរយនៃកំណើនឧស្សាហកម្មចាប់តាំងពីឆ្នាំ១៩៩៨។ ឧស្សាហកម្មកាត់ដេរមានការកើនឡើង ដោយសារមានកិច្ចព្រមព្រៀងជាមួយនឹងសហព័ន្ធអឺរ៉ុប និងដោយសារសហរដ្ឋអាមេរិក បានផ្តល់ឱ្យព្រះរាជាណាចក្រកម្ពុជា នូវឋានៈជាប្រទេសដែលទទួលបានការអនុគ្រោះបំផុតនៅឆ្នាំ១៩៩៧។ នៅឆ្នាំ១៩៩៩ ព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក បានចុះកិច្ចព្រមព្រៀងផ្តល់កូតាសំរាប់ការនាំចេញសំលៀកបំពាក់ជាពិសេស ដោយសារសហរដ្ឋអាមេរិកមានបំណងចង់ការពារឧស្សាហកម្មកាត់ដេររបស់ខ្លួន។ កិច្ចព្រមព្រៀងនេះបានដាក់បញ្ចូលទំនាក់ទំនងកូតាដែលមិនធ្លាប់មានពីមុនមក សំដៅអនុវត្តស្តង់ដារការងារ និងបន្ត រហូតដល់ដំណាច់ឆ្នាំ២០០៤។ ដោយចាប់ផ្តើមពីបាតដៃទទេ រោងចក្របានរីកដុះដាលក្លាយទៅជាឧស្សាហកម្មដែលមានទឹកប្រាក់ ១,២

ពាន់លានដុល្លារអាមេរិកក្នុងរយៈពេល ៥ឆ្នាំ ដោយផ្តល់ការងារឱ្យប្រជាជនបានជិត ២០០.០០០នាក់ ដែលត្រូវចំណាយទៅលើប្រាក់ខែក្នុងមួយខែៗគឺ ១២លានដុល្លារអាមេរិក ជាមធ្យម ។

នៅដំណាច់ឆ្នាំ២០០៤ កិច្ចព្រមព្រៀងវាយនភណ្ឌ (Multi Fibers Agreement) សំរាប់ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នឹងលុបចោលកូតាទាំងអស់នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ ។ សមាជិកភាពរបស់ប្រទេសចិននៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក និងការធ្វើប្រក្រតីភាវូបនីយកម្មទំនាក់ទំនងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងវៀតណាម គឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរទៅលើឧស្សាហកម្មកាត់ដេរសំលៀកបំពាក់របស់កម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា នឹងអាចប្រកួតប្រជែងនៅក្នុងវិនិយោគថ្មីៗ ដោយផ្អែកលើការគោរពសិទ្ធិជាមូលដ្ឋានរបស់កម្មករ និងកំពុងតែកសាងកេរ្តិ៍ឈ្មោះរបស់ខ្លួន ។ កម្មករនៅក្នុងវិស័យកាត់ដេរ ទទួលបានប្រាក់ខែខ្ពស់បើប្រៀបធៀបទៅនឹងកម្មករក្នុងវិស័យផ្លូវការ និងមិនផ្លូវការ និងមន្ត្រីរាជការ (ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០០១) ។ លើសពីនេះទៀត ប្រាក់ខែអប្បបរិមានៅកម្ពុជាពោលគឺ ៤៥ដុល្លារអាមេរិកក្នុងមួយខែ (សំរាប់កម្មករកាត់ដេរ) ដោយផ្អែកលើការងារ ៤៨ ម៉ោងក្នុងមួយសប្តាហ៍ មានកំរិតខ្ពស់ជាងប្រាក់ខែនៅក្នុងប្រទេសផ្សេងទៀត ក្នុងតំបន់ដែលជាដៃគូប្រកួតប្រជែងដោយរួមទាំង បង់ក្លាដេស ឥណ្ឌា និងឥណ្ឌូនេស៊ី ។ ប៉ុន្តែអត្រានេះ មានកំរិតទាបជាងអត្រានៅក្នុងប្រទេសដែលមានការអភិវឌ្ឍន៍ជាងប្រទេសកម្ពុជា ដូចជា ថៃឡង់ ជាដើម (សូមមើលតារាង ២.៣) ។

ដូចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរ ការងាររបស់នារីនៅក្នុងឧស្សាហកម្មកាត់ដេរ ត្រូវបានលើកយកមកពិភាក្សាយ៉ាងទូលំទូលាយនៅកម្ពុជា ដោយសារវាមានផលប៉ះពាល់ផ្នែកសង្គម ។ ទោះបីជារោងចក្រទាំងនេះ បានផ្តល់នូវឱកាសការងារថ្មីៗដល់នារី និងតំរូវឱ្យមានការគ្រប់គ្រងដោយគោរពតាម "ក្រមសីលធម៌" ពោលគឺ អនុលោមទៅតាមស្តង់ដារការងារក៏ដោយ ក៏គេសង្កេតឃើញមានផលប៉ះពាល់អវិជ្ជមានមួយចំនួន ។ ទោះបីជាការអង្កេតថ្មីៗនេះ (Reed ឆ្នាំ២០០១) របស់អង្គការពលកម្មអន្តរជាតិ (ILO) នៅតាមរោងចក្រកាត់ដេរនៅកម្ពុជា រកពុំទាន់ឃើញភស្តុតាងបញ្ជាក់អំពីពលកម្មកុមារ ពលកម្មដោយបង្ខំ ឬការបៀតបៀនផ្លូវភេទក៏ដោយ ក៏ការអង្កេតនេះ បានរកឃើញករណីធ្វើការបន្ថែមម៉ោងដោយបង្ខំ ការរើសអើងប្រឆាំងនឹងសហជីព និងការទូទាត់ប្រាក់បៀវត្សរ៍ពុំត្រឹមត្រូវ ។

**តារាង ២.៣ : ម៉ោងធ្វើការ និងប្រាក់កំរៃនៅក្នុងឧស្សាហកម្មកាត់ដេរ នៅតាមបណ្តាប្រទេសអាស៊ានមួយចំនួន**

| ប្រទេស | ឆ្នាំ | ម៉ោងធ្វើការ តាមច្បាប់ | ប្រាក់កំរៃអប្បបរិមាដែល កំណត់ដោយច្បាប់ (គិតជាដុល្លាអាមេរិក) | ប្រាក់ខែជាមធ្យម ក្នុងមួយខែ (គិតជាដុល្លាអាមេរិក) | អត្រាប្រាក់កំរៃ តាមម៉ោង (គិតជាដុល្លាអាមេរិក) | ប្រាក់កំរៃពី អប្បបរិមាទៅមធ្យម (គិតជាដុល្លាអាមេរិក) |
|---|---|---|---|---|---|---|
| ម៉ាឡេស៊ី | ១៩៩៥ | ៤៨ | គ្មាន | ២៩៦ | ១,៤២ | គ្មាន |
| ចិន | ១៩៩៧ | ៤០ | ១២-៣៩ | ១៩១ | ១,១៤ | ៦-២០ |
| ហ្វីលីពីន | ១៩៩៩ | ៤៨ | ១៣០ | ១៨២ | ០,៨៨ | ៧១ |
| ថៃឡង់ | ១៩៩៩ | ៤៨ | ៩៣-១០៩ | ១០៦ | ០,៥១ | ៨៨-១០៣ |
| ស្រីលង្កា | ១៩៩៨ | ៤៥ | ២៩-៣៧ | ៦៣ | ០,៣១ | ៤៦-៥៩ |
| កម្ពុជា | ២០០០ | ៤៨ | ៥០[ក] | ៦១ | ០,២៩ | ៨២ |
| វៀតណាម | ២០០០ | ៤៨ | ៤៥ | ៦០ | ០,២៩ | ៧៥ |
| ឥណ្ឌា | ១៩៩៩ | ៤៨ | ៦-៥៤ | ៥៧ | ០,២៧ | ១១-៩៥ |
| ឥណ្ឌូនេស៊ី | ២០០០ | ៤០ | ៤៣[ខ] | ៤៦ | ០,២៥ | ៩៤ |
| បង់ក្លាដេស | ១៩៩៦ | ៤៨ | ១២-៧៦ | ៤០ | ០,១៩ | ៣០-៩០ |

**សំគាល់: ក** នៅក្នុងតារាងនេះ ប្រាក់ឧបត្ថម្ភសំរាប់ការចូលរួមពេញលេញចំនួន ៥ដុល្លាអាមេរិក ត្រូវបានដាក់បញ្ចូលទៅក្នុងអត្រាប្រាក់កំរៃអប្បបរិមា។

**ខ** ប្រាក់កំរៃអប្បបរិមានៅទីក្រុងហ្សាការតា។

**ប្រភព:** CDRI; US DoL, Bureau of International Labor Affairs; the Indonesian DoM, ឆ្នាំ២០០១

ការសិក្សាស្រាវជ្រាវមួយរបស់អង្គការឃែរ (CARE) ដែលបានធ្វើនៅឆ្នាំ ១៩៩៩ បានរកឃើញបញ្ហាស្រដៀងគ្នានេះ ហើយបានកត់សំគាល់ឃើញថា កម្មកររោងចក្រកាត់ដេរទាំងពីរភេទ មានភាពស្ទាក់ស្ទើរមិនហ៊ាននិយាយអ្វីទាក់ទងនឹងបញ្ហាទាំងនេះទេ។ ការស្រាវជ្រាវថ្មីៗដែលត្រូវបានធ្វើឡើងដោយអង្គការ Oxfam Hong Kong និងអង្គការកម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ (Womyn's Agenda for Change) បានរកឃើញថា ទោះបីជាឧស្សាហកម្មកាត់ដេរពិតជាបានផ្តល់ការងារមានប្រាក់កំរៃនៅក្រៅភូមិក៏ដោយ ក៏កម្មករត្រូវបានគេមើលងាយ និងត្រូវធ្វើការក្នុងស្ថានភាពលំបាកលំបិនះ

- ៥០ភាគរយនៃកម្មកររោងចក្រ ទទួលបានប្រាក់ខែតិចជាង ៤៥ដុល្លាអាមេរិកក្នុងមួយខែ (បៀវត្សរ៍អប្បបរិមា)។ ជាមធ្យម កម្មករទទួលបាន ៣៥ដុល្លាអាមេរិក។
- កម្មករទាំងអស់ ដែលបានចូលរួមធ្វើសម្ភាសន៍បាននិយាយថា ពួកគេត្រូវគេបង្ខំឱ្យធ្វើការថែមម៉ោង។
- ដំបូង នារីមានចិត្តរំភើបរីករាយដោយបានចាកចេញពីភូមិរបស់ខ្លួន និងបានរួចផុតពីការគ្រប់គ្រងរបស់គ្រួសារពួកគេ ប៉ុន្តែក្រោយមក ពួកគេចាប់ផ្តើមមានអារម្មណ៍មិនល្អ និងនឿយណាយ។ ប៉ុន្តែ ពួកគេពិបាកនឹងវិលត្រលប់ទៅភូមិរបស់ពួកគេវិញណាស់ ដោយសារប្រជាជនក្នុងភូមិអាចគិតថា ពួកគេឥឡូវនេះ ក្លាយជា "នារីមិនល្អ ពីព្រោះពួកគេបានទៅភ្នំពេញ និងបានរួមរស់ជាមួយបុរសទៅហើយ"។

- ការឧបត្ថម្ភគាំទ្រដល់គ្រួសាររបស់ពួកគេ គឺជាសំពាធដ៏ធ្ងន់ធ្ងរ៖ ៦០ភាគរយនៃប្រាក់ដែលពួកគេរកបាន ត្រូវផ្ញើទៅគ្រួសាររបស់ពួកគេ ដោយពួកគេទុកតែបន្តិចបន្តួចសំរាប់ទិញអាហារទទួលទាន សំរាប់ការស្នាក់នៅ ការកំសាន្ត និងតំរូវការផ្សេងទៀត។
- មានការកើនឡើងនូវអំពើឆក់ប្លន់ទៅលើកម្មកររោងចក្រ បង្កឡើងដោយជនពាលដែលរង់ចាំនៅខាងក្រៅរោងចក្រនៅថ្ងៃបើកប្រាក់ខែ។

ជាមួយនឹងកំណើនឧស្សាហកម្មកាត់ដេរ ចលនាសហជីពពាណិជ្ជកម្ម ក៏បានពង្រីកផងដែរ។ ឥឡូវនេះ មានសហជីពជាង ១០០ ដែលមានទំនាក់ទំនងនឹងឧស្សាហកម្មកាត់ដេរ ហើយប្រមាណ ១០ភាគរយនៃកម្មករ បានចូលជាសមាជិកសហជីព។ សមាជិកភាគច្រើន គឺជាកម្មកររោងចក្រកាត់ដេរ ពោលគឺ នារីក្មេងៗដែលមកពីតាមខេត្តនានា ធ្វើការនៅក្នុងក្រុង និងនៅជាយក្រុងភ្នំពេញ។ ទោះបីជា ៩០ភាគរយនៃសមាជិកសហជីពជានារីក៏ដោយ ក៏នៅក្នុងតំណែងដឹកនាំថ្នាក់ជាតិ មាននារីតែ ២នាក់ប៉ុណ្ណោះ (ILO ឆ្នាំ២០០១)។ ប្រធាន អនុប្រធាន និងអគ្គលេខាធិការសហជីព មិនមែនជាអ្នកធ្វើការនៅក្នុងរោងចក្រកាត់ដេរទេ។ នារីដែលធ្វើការលើសពី ៥០ម៉ោងក្នុងមួយសប្តាហ៍ និងទទួលបានប្រាក់ ៥០ដុល្លាអាមេរិកក្នុងមួយខែ កម្រនឹងមានពេលវេលាទំនេរសំរាប់ចូលរួមក្នុងសកម្មភាពសហជីពណាស់។ នារីកំរនឹងសុំច្បាប់សំរាកដើម្បីចូលរួមក្នុងសកម្មភាពសហជីពណាស់ ពីព្រោះថា នារីពុំត្រូវបានគេអនុញ្ញាតិឱ្យទៅចូលរួមក្នុងសកម្មភាពសហជីពទាំងនោះទេ។ មានសេចក្តីរាយការណ៍ថា ក្នុងករណីខ្លះ ការចូលរួមក្នុងសិក្ខាសាលាអប់រំរបស់សហជីព នាំឱ្យមានការបញ្ឈប់កម្មករពីការងារ (Oxfam ហុងកុង WAC ឆ្នាំ២០០១)។

## ២.១.១៣ គោលនយោបាយការងារ និងពាណិជ្ជកម្ម មានឥទ្ធិពលខុសគ្នាលើបុរស និងនារី

ការពិភាក្សាអំពីការងារពាណិជ្ជកម្ម និងការនាំចេញនៅកម្ពុជា បានផ្តោតជាពិសេសទៅលើឧស្សាហកម្មកាត់ដេរ ដូចដែលបានលើកឡើងនៅខាងដើម ដោយសារឧស្សាហកម្មនេះ ស្រូបយក ៩៤ភាគរយ នៃកំណើននៅក្នុងវិស័យឧស្សាហកម្មតាំងពីឆ្នាំ១៩៩៨ ពោលគឺ មានកំរិតខ្ពស់ជាងពាក់កណ្តាលនៃកំណើនរួមពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០១ ហើយបានផ្តល់ការងារមានប្រាក់កំរៃដល់នារីចំនួនប្រមាណ ១៨០.០០០នាក់។ ទោះជាយ៉ាងណាក៏ដោយ គេត្រូវកំណត់ពីលក្ខណៈមួយចំនួនទាក់ទងនឹងកំណើននេះ៖ កំណើន និងការបង្កើនឱ្យមានការងារមានមូលដ្ឋានតូចចង្អៀត។ ឧស្សាហកម្មដែលមានការនាំចូលខ្ពស់ មិនមានទំនាក់ទំនងនៅក្នុងសេដ្ឋកិច្ចក្នុងស្រុកទេ ហើយការរីកចំរើន មានតែនៅទីក្រុង ដែលនាំឱ្យមានការមករកការងារធ្វើនៅទីក្រុង។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មដល់ជនក្រីក្រ និងឆ្លើយតបទៅនឹងយេនឌ័រ ចាំបាច់ត្រូវផ្តល់ឱកាសការងារដល់នារី និងបុរស នៅតំបន់ជនបទទាំងក្នុងវិស័យកសិកម្ម និងវិស័យផ្សេងក្រៅពីកសិកម្ម។

រាជរដ្ឋាភិបាលកំពុងសហការជាមួយសមាគមអង្គការពហុភាគី (អង្គការពាណិជ្ជកម្មពិភពលោក ធនាគារពិភពលោក សន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងកិច្ចអភិវឌ្ឍន៍ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ និងកម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ) ក្នុងគោលបំណងរៀបចំឱ្យមានក្របខ័ណ្ឌរួមមួយ។ ទិសដៅនៃ

ក្របខ័ណ្ឌរួមនេះ គឺដើម្បីដាក់បញ្ចូលការងារពាណិជ្ជកម្ម ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ ដោយរួមទាំងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រផង ហើយជួយសំរបសំរួលដល់ការផ្តល់ជំនួយបច្ចេកទេស ទាក់ទងនឹងពាណិជ្ជកម្មដែលមានទំនាក់ទំនងទៅនឹងការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា។ ការសិក្សាស្រាវជ្រាវ និងគំរោងសាកល្បង ត្រូវបានអនុវត្តដោយផ្តោតទៅលើកសិកម្មចំរុះ និងកសិកម្មកែច្នៃ សិប្បកម្ម ការនេសាទទឹកសាបឧស្សាហកម្ម កាត់ដេរ ទេសចរណ៍ និងសេវាពលកម្ម។ ទោះបីជាមានការកំនត់ថា កំណើនពាណិជ្ជកម្ម នឹងធ្វើឱ្យមានកំណើនឱកាសការងារក៏ដោយ ប៉ុន្តែមានការផ្តោតការយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះលើផលប៉ះពាល់នៃការងារនៅក្នុងគំរោងវិនិយោគដែលបានស្នើឡើង ជាពិសេសគុណភាព ឬបញ្ហាយេនឌ័រ នៅក្នុងការងារនេះ។

ទោះបីជាការវិភាគយេនឌ័រ មិនត្រូវបានគេដាក់បញ្ចូលទៅក្នុងការរៀបចំក្របខ័ណ្ឌរួមនេះក៏ដោយ ក៏មានបញ្ហាយេនឌ័រមួយចំនួនត្រូវបានលើកយកមកពិចារណា នៅក្នុងផ្នែកនីមួយៗដូចដែលបានលើកឡើងខាងលើ។ បញ្ហាដែលទាក់ទងនឹងវិស័យកាត់ដេរ ត្រូវបានលើកឡើងរួចហើយ ហើយបន្ទាប់មក ត្រូវផ្តោតទៅលើបញ្ហាដែលទាក់ទងនឹងផលិតកម្មសិប្បកម្ម កសិកម្មកែច្នៃ ទេសចរណ៍ និងសេវាពលកម្ម។

កសិកម្មកែច្នៃ និងផលិតកម្មសិប្បកម្ម គឺជាការងារជាប្រពៃណីរបស់នារី។ នារីមានចំនួនជាងពាក់កណ្តាលនៃកំលាំងពលកម្មនៅក្នុងផ្នែកកែច្នៃម្ហូបអាហារ។ ដោយសារឧស្សាហកម្មនេះ ត្រូវបានពង្រីក និងត្រូវបានធ្វើយន្តកម្មដើម្បីឆ្លើយតបទៅនឹងតំរូវការទីផ្សារនាំចេញ និងត្រូវប្រកួតប្រជែងនៅលើទីផ្សារក្នុងស្រុកដែលកាន់តែមានការរីកចំរើនខ្លាំងឡើងនេះ មានសំណួរមួយចំនួនត្រូវបានលើកឡើង ទាក់ទងនឹងបញ្ហានានាក្នុងការបង្កើតការងារ ជាពិសេសការងារសំរាប់នារី។ តើការងារថ្មីដែលត្រូវបង្កើត មានចំនួនប៉ុន្មាន? តើការងារទាំងនេះ ត្រូវបង្កើតនៅក្នុងស្ថាប័ន ឬវិស័យណា? តើឱកាសការងារថ្មីនេះ នឹងមានរូបរាងជាការងារមានកិច្ចសន្យា ការងារមានប្រាក់កំរៃ ឬជាអ្នកគ្រប់គ្រងនិងសហគ្រិន? ការងារធ្វើដោយប្រើគ្រឿងយន្ត គឺជាការងារជាប្រពៃណីរបស់បុរស តើឧស្សាហកម្មកែច្នៃម្ហូបអាហារតាមលក្ខណៈប្រពៃណី មានផលប៉ះពាល់ដូចម្តេចខ្លះទៅលើនារី? តើមានវិធានការអ្វីខ្លះដែលត្រូវអនុវត្តដើម្បីជំរុញឱ្យកំលាំងពលកម្មដែលមានក្នុងពេលបច្ចុប្បន្ននៅក្នុងវិស័យទាំងនេះ មានលទ្ធភាពអភិវឌ្ឍន៍ជំនាញ និងផលិតផលរបស់ខ្លួន ដើម្បីទទួលផលប្រយោជន៍ពីកិច្ចខំប្រឹងប្រែងអភិវឌ្ឍន៍ពាណិជ្ជកម្ម?

តាមការប៉ាន់ស្មាន នារីមានចំនួន ៧៥ភាគរយ ជាកំលាំងពលកម្មនៅក្នុងការងារសិប្បកម្ម។ ក្រៅពីអ្នកប្រកបរបរសិប្បកម្ម ដែលជាការងារសំខាន់របស់ពួកគេ ការងារសិប្បកម្មនេះ ក៏ជាប្រភពចំណូលសំខាន់ទីពីរសំរាប់នារីនៅតំបន់ជនបទផងដែរ។ សំនួរប្រហាក់ប្រហែលដែលពាក់ពន្ធ័នឹងកសិកម្មកែច្នៃ គឺចាំបាច់ត្រូវតែលើកឡើងនៅក្នុងវិស័យសិប្បកម្មនេះផងដែរៈ តើមានការងារថ្មីប៉ុន្មាន? តើការងារថ្មីទាំងនោះ ត្រូវបង្កើតនៅក្នុងស្ថាប័ន ឬវិស័យណា? តើនឹងមានលក្ខខ័ណ្ឌការងារដូចម្តេច? តើនឹងមានបញ្ហាអ្វីខ្លះ ចំពោះអ្នកធ្វើការងារនៅក្នុងឧស្សាហកម្មតាមបែបប្រពៃណី? ដូចដែលគេបានដឹងរួចហើយថា ផលិតកម្មសិប្បកម្មត្រូវបានគ្រប់គ្រងដោយនារី ហើយបុរសជាភ្នាក់ងារសកម្មនៅក្នុងការសំរបសំរួលដើម្បីទទួលបានវត្ថុធាតុដើម និងទីផ្សារ តើតួនាទីយេនឌ័រ និងផលប្រយោជន៍ នឹងត្រូវបែងចែកដូចម្តេចនៅពេលដែលវិស័យនេះមានការកើនឡើង?

ទាក់ទងនឹងការអភិវឌ្ឍន៍វិស័យទេសចរណ៍ វិស័យនេះ បានបង្កើតឱ្យមានទំនាក់ទំនងមួយចំនួនទៅនឹងឧស្សាហកម្មផ្សេងទៀតជាច្រើន។ ការងារជាក់ស្តែងមានដូចជា ការងារនៅតាមសណ្ឋាគារ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍ សេវាដឹកជញ្ជូន និងការនាំភ្ញៀវទេសចរ។ លើសពីនេះ ការរីកចំរើនផ្នែកទេសចរណ៍ បាននាំមកនូវការរីកចំរើនប្រកបដោយសក្តានុពលភាពដល់វិស័យមួយចំនួនទៀត ដូចជា កសិកម្ម នេសាទ និងសិប្បកម្ម។ នៅក្នុងផ្នែកសណ្ឋាគារ និងភោជនីយដ្ឋានមួយចំនួន មានតុល្យភាពសមធម៌រវាងបុគ្គលិកបុរស និងនារី។ តែទោះជាយ៉ាងណាក៏ដោយ នារីមួយចំនួនតូចប៉ុណ្ណោះ មានកំរិតវប្បធម៌ ឬជំនាញភាសាបរទេស សំរាប់ប្រកួតប្រជែងដើម្បីយកតំណែងខ្ពស់ៗ នៅក្នុងផ្នែកសណ្ឋាគារ ឬជាអ្នកនាំភ្ញៀវទេសចរ ឬនៅក្នុងទីភ្នាក់ងារទេសចរណ៍ ហើយភាគច្រើនទទួលបានការងារជាអ្នកថែទាំសំអាតផ្ទះ ជាអ្នកបំរើនៅតាមភោជនីយដ្ឋាន ជានារីឃោសនាស្រាបៀរ និងតំណែងជាន់ទាបក្នុងផ្នែកផ្សេងៗ។ សេវាដឹកជញ្ជូនជាវិស័យមួយ ដែលមានបុរសច្រើនបំផុត។

ទោះបីជារាជរដ្ឋាភិបាល កំពុងតែលើកកំពស់ទេសចរណ៍វប្បធម៌ និងអេកូទេសចរណ៍ក៏ដោយ ក៏យ៉ាងហោចណាស់ផ្នែកមួយនៃកំណើននាពេលបច្ចុប្បន្ននៅក្នុងវិស័យនេះ មានទំនាក់ទំនងទៅនឹងវិស័យទេសចរណ៍ផ្លូវភេទ។ ទន្ទឹមនឹងនេះ មានការកើនឡើងនូវការព្រួយបារម្ភណ៍ថា កម្ពុជាជាកន្លែងសំរាប់អំពើអនាចារកុមារ ហេតុដូច្នេះ ក្នុងខណៈការអភិវឌ្ឍន៍វិស័យទេសចរណ៍ នឹងបង្កើតឱ្យមានឱកាសការងារថ្មីជាច្រើន ប៉ុន្តែហានិភ័យថ្មីៗ ក៏នឹងកើតមានឡើងផងដែរ។ វិសមភាពដែលនៅតែមាននៅក្នុងលទ្ធភាពទទួលបានឱកាសថ្មីៗ បណ្តាលមកពីកំរិតវប្បធម៌ទាប និងជំរើសការងារដែលមានឧបសគ្គដោយសារវប្បធម៌សង្គម បានរារាំងនារីមិនឱ្យទទួលបានតំណែងក្នុងវិស័យនេះ។

សក្តានុពលភាពនៃការនាំចេញជាផ្លូវការនូវសេវាពលកម្ម ជាទូទៅ ត្រូវជួបប្រទះឧបសគ្គផ្នែកកំរិតវប្បធម៌ និងជំនាញ ដោយនារីត្រូវបាត់បង់ឧត្តមភាពក្នុងផ្នែកនេះ។ ការនាំចេញជាផ្លូវការនូវកំលាំងពលកម្ម ដែលមានកំរិតវប្បធម៌ និងសមត្ថភាពភាសាបរទេសទាប អាចធ្វើឱ្យកំលាំងពលកម្មទាំងនោះ ប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងកំរិតមួយខ្ពស់ ដូចជា ការកេងប្រវ័ញ្ច ឬការធ្វើអាជីវកម្ម និងការរំលោភបំពាន។ ការនាំចេញកំលាំងពលកម្មជាលក្ខណៈ មិនផ្លូវការកើតមានជាទូទៅ ជាពិសេសការនាំចេញទៅប្រទេសថៃឡង់។ នេះគឺជា "អាជីវកម្មផ្លូវងងឹត" ហើយរួមបញ្ចូលទាំងការជួញដូរមនុស្សឆ្លងកាត់ព្រំដែន និង "ការបោកប្រាស់" កម្មករដែលស្ម័គ្រចិត្តធ្វើដំណើរទៅកាន់ប្រទេសថ្មី ដើម្បីស្វែងរកការងារឱ្យធ្លាក់ចូលទៅក្នុងសេវគតិភាព (ទាសករ) ឬធ្លាក់ចូលក្នុងឧស្សាហកម្មផ្លូវភេទ។ ទាក់ទងនឹងវិស័យទេសចរណ៍ ការនាំចេញកំលាំងពលកម្ម ផ្តល់នូវឱកាសការងារថ្មី ប៉ុន្តែក៏មានហានិភ័យថ្មីៗផងដែរ។

ដោយសារជំនួយបច្ចេកទេសសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មទាំងនេះ មានការវិវត្តន៍ទៅមុខ ជាការចាំបាច់ត្រូវពិនិត្យមើលឱ្យបានដិតដល់លើទិដ្ឋភាពយេនឌ័រនៅក្នុងការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម។ ការធានាឱ្យមានលទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានឱកាសការងារថ្មី ដែលកើតចេញមកពីកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ទំនងជាតំរូវឱ្យមានការធានាឱ្យនារីមានលទ្ធភាពទទួលបានការបណ្តុះបណ្តាលសមស្រប សំដៅជួយឱ្យនារីមានលទ្ធភាពចូលរួមប្រកួតប្រជែងដណ្តើមឱកាសការងារថ្មីៗ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការអប់រំឧត្តមសិក្សាសំរាប់នារី និងការពិចារណាឡើងវិញទៅលើថាតើឥរិយាបថប្រពៃណី ដែលទាក់ទងនឹងការងាររបស់ "បុរស" និង "នារី" គួរតែអនុវត្តបែបណា នៅក្នុងវិស័យឧស្សាហកម្មដែលកំពុងតែរីកលូតលាស់នេះ។

## ២.១.១៤ តើតំបន់ប្រតិបត្តិការនាំចេញ ដែលត្រូវបានស្នើឡើង ផ្តល់ផលប្រយោជន៍ដល់នារីដែរឬទេ?

រាជរដ្ឋាភិបាលកម្ពុជា កំពុងតែធ្វើការចរចាជាមួយនឹងភាគីថៃឡង់ ដើម្បីបង្កើតឱ្យមានតំបន់ប្រតិបត្តិការនាំចេញ (EPZ) ដែលអាចហៅថា តំបន់ពាណិជ្ជកម្មសេរី និងតំបន់សេដ្ឋកិច្ចពិសេស ។ តំបន់ប្រតិបត្តិការនាំចេញ គឺជាដំណើរការអន្តរជាតិ ដែលត្រូវបានបង្កើតឡើង ដើម្បីទាក់ទាញវិនិយោគទុនបរទេសឱ្យចូលមកតំបន់ដែលមានឧស្សាហកម្មតិចតួច ឬគ្មានសោះ ។ ប្រទេសម្ចាស់ផ្ទះ នឹងផ្តល់នូវការលើកទឹកចិត្តពិសេសដូចជា ការលើកលែងពន្ធ និងការព្យួរការអនុវត្តន៍ច្បាប់ការងារក្នុងស្រុក (ជាផ្លូវការ ឬមិនផ្លូវការ) ដើម្បីទាក់ទាញអ្នកវិនិយោគទុនបរទេស ឱ្យចូលមកក្នុងតំបន់ឧស្សាហកម្មទាំងនេះ ។ នេះអាចជាបញ្ហាយេនឌ័រដ៏ចំបងព្រោះថា កម្មករភាគច្រើននៅក្នុងតំបន់ទាំងនេះ មានរហូតដល់ ៨០ភាគរយនៅក្នុងប្រទេសដទៃទៀត ជានារី (AMRC ឆ្នាំ១៩៩៨ និង Daeren ឆ្នាំ១៩៩៧ ។

កត្តាដ៏សំខាន់ និងស្រួចស្រាវបំផុតនៃតំបន់ប្រតិបត្តិការនាំចេញ (EPZ) គឺទំនាក់ទំនង និងស្តង់ដារការងារ ។ ប្រទេសជាម្ចាស់តំបន់ឧស្សាហកម្មនេះ ដែលរួមមាន បង់ក្លាដេស ប៉ាណាម៉ា និងស៊ីមបាវ៉េ បានប្រើប្រាស់បទដ្ឋានពិសេស (មានកំរិតទាប) ដែលអនុវត្តតែនៅក្នុងតំបន់នោះ ដើម្បីជំនួសច្បាប់ការងារក្នុងស្រុក (ILO ឆ្នាំ១៩៩៨) ។ ផលវិបាកចំពោះនារីអាចមានទំហំធំធេង ដោយសារនារីផ្តល់នូវកំលាំងពលកម្មយ៉ាងច្រើននៅក្នុងតំបន់ទាំងនេះ ហើយស្តង់ដារការងារទាប អាចបង្ករឱ្យមានការលំបាកកាន់តែច្រើន ។

តំបន់ប្រតិបត្តិការនាំចេញ (EPZ) មិនចាំបាច់ធ្វើប្រតិបត្តិការ ដោយប្រើប្រាស់ស្តង់ដារការងារទាប ដើម្បីទាក់ទាញអ្នកវិនិយោគនោះទេ ។ របាយការណ៍ដែលត្រូវបានរៀបចំឡើង ដោយអង្គការពលកម្មអន្តរជាតិ (ILO) បានកត់សំគាល់ថា គេអាចបង្កើតឱ្យមានតំបន់ប្រតិបត្តិការនាំចេញ (EPZ) ដែលនឹងទាក់ទាញវិនិយោគបរទេស ដោយត្រូវការពារសិទ្ធិរបស់កម្មករផងដែរ (AMRC ឆ្នាំ១៩៩៨) ។ នៅក្នុងឧទាហរណ៍ដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ ការរក្សាស្ថានភាពការងារល្អ ត្រូវផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយឧស្សាហកម្មច្បាស់លាស់ ការលើកទឹកចិត្តហេដ្ឋារចនាសម្ព័ន្ធសមស្រប និងធនធានមនុស្ស ។ អង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ កំពុងធ្វើការវាយតំលៃអំពីផលប៉ះពាល់ផ្នែកសង្គមកិច្ចនៃតំបន់ប្រតិបត្តិការនាំចេញ (EPZ) នៅកោះកុង ហើយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតកំពុងតែពិនិត្យតាមដានការរៀបចំសំណើសុំផ្សេងទៀត សំរាប់ការបង្កើតតំបន់ប្រតិបត្តិការនាំចេញ (EPZ) នៅកម្ពុជា ។

## ២.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ផ្តោតជាសំខាន់ទៅលើការរក្សាស្ថេរភាព ការពង្រឹងវិស័យធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ការអនុវត្តនីតិវិធានការកំណែទំរង់សារពើពន្ធ ការធានាឱ្យមានការគ្រប់គ្រងត្រឹមត្រូវលើទ្រព្យសម្បត្តិរដ្ឋ និងការបង្កើនការវិនិយោគសាធារណៈ ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម និងធនធានមនុស្ស។ ទិសដៅនៃការអភិវឌ្ឍន៍ជាតិ ដូចដែលបានបង្ហាញជូននៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងផែនការអភិវឌ្ឍន៍សង្គមកិច្ច សេដ្ឋកិច្ច ប្រាំឆ្នាំលើកទី២ ពីឆ្នាំ២០០១-២០០៥ ផ្តោតការយកចិត្តទុកដាក់ទៅលើកំណើនសេដ្ឋកិច្ច ដែលមានលក្ខណៈទូលំទូលាយល្មមនឹងដាក់បញ្ចូលវិស័យនានា ដែលប្រជាជនក្រីក្រទទួលបានមុខរបរចិញ្ចឹមជីវិត ការអភិវឌ្ឍន៍សង្គមនិងវប្បធម៌ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាព ព្រមទាំងការគ្រប់គ្រងបរិស្ថានឱ្យបានត្រឹមត្រូវ។

ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ពឹងផ្អែកទៅលើកំណើនសេដ្ឋកិច្ច។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្របានចែងថាៈ *"កំណើនសេដ្ឋកិច្ចអាចសំរេចបាន ដោយមិនចាំបាច់មានការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែការកាត់បន្ថយភាពក្រីក្រ មិនអាចសំរេចបានដោយគ្មានកំណើនសេដ្ឋកិច្ចទេ។ កំណើនសេដ្ឋកិច្ច គឺជាអាវុធមួយប្រភេទដែលមានឥទ្ធិពលបំផុត សំរាប់ប្រយុទ្ធនឹងភាពក្រីក្រ"*។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តអនុវត្តគោលនយោបាយ ដែលពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ធ្វើវិភាជធនធានទៅវិស័យនានាដែលកាន់តែមានប្រសិទ្ធិភាព និងជំរុញឱ្យមានការធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងសេដ្ឋកិច្ចពិភពលោក។

រាជរដ្ឋាភិបាល កំពុងតែបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មដល់ជនក្រីក្រ ហើយកំពុងតែរៀបចំខ្លួនត្រៀមចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ រាជរដ្ឋាភិបាល ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (ASEAN Free Trade Agreement) ដែលតំរូវឱ្យមានការកាត់បន្ថយពន្ធគយជាបន្តបន្ទាប់ ឱ្យដល់កំរិតសូន្យនៅតាមបណ្តាប្រទេសអាស៊ានទាំង១០។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មដល់ជនក្រីក្រ មានមូលដ្ឋានលើទស្សនៈគន្លឹះបី ដូចជាៈ

១) ការផ្លាស់ប្តូរតុល្យភាពនៃការផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយ ពីបញ្ហាលទ្ធភាពទីផ្សារ និងកំណែទំរង់ម៉ាក្រូសេដ្ឋកិច្ចសំរាប់ពាណិជ្ជកម្ម ទៅជាបញ្ហាសមត្ថភាពផ្គត់ផ្គង់មីក្រូសេដ្ឋកិច្ច។

២) ការផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា ទៅលើការផ្តល់ជំនួយគាំទ្រផ្នែកកសាងសមត្ថភាពដល់សហគ្រាសនាំចេញ និងកំរិតនាំចេញ (ការអភិវឌ្ឍន៍វិស័យឯកជនសំរាប់ពាណិជ្ជកម្ម)។ និង

៣) ការសង្កត់ធ្ងន់ទៅលើការធ្វើវិមជ្ឈការសនិទានកម្ម និងតាមភូមិសាស្ត្រ លើអាជីវកម្មនាំចេញនៅកម្ពុជា។ ការលើកទឹកចិត្ត និងការទាក់ទាញការវិនិយោគ និងសហគ្រិនភាពក្នុងវិស័យនានានៅជនបទ ត្រូវបានចាត់ទុកថាមានសារៈសំខាន់ពិសេស។

# ជំពូកទី ៣

# នារី កសិកម្ម និង ធនធានជនបទ

កម្ពុជានាពេលបច្ចុប្បន្ន ........ ៧១
៣.១ ស្ថានភាព និន្នាការ និង បញ្ហា ........ ៧២
៣.១.១ នារីមានតួនាទីសំខាន់នៅក្នុងផលិតកម្មកសិកម្ម ........ ៧៤
៣.១.២ នារីមានតួនាទីប្រកបដោយសក្តានុពលភាពយ៉ាងសំខាន់ ក្នុងការកាត់បន្ថយអសន្តិសុខស្បៀង ........ ៧៥
៣.១.៣ សេវាផ្សព្វផ្សាយមានកំរិតអប្បបរមា នារីទទួលបានសេវាផ្សព្វផ្សាយតិចជាងបុរស ........ ៧៦
៣.១.៤ ឱកាសតិចតួចក្នុងការទទួលបានធនធានធម្មជាតិ កំពុងគំរាមកំហែងដល់ការប្រកបរបរចិញ្ចឹមជីវិត ... ៧៩
៣.១.៥ ទោះបីជាមានច្បាប់ដីធ្លីថ្មីដែលយកចិត្តទុកដាក់លើយេនឌ័រ ប៉ុន្តែនារីនៅតែងាយរងគ្រោះ ដោយសារតែសិទ្ធិនារីក្នុងការទទួលបានដី មិនត្រូវបានគេយកចិត្តទុកដាក់ ........ ៧៩
៣.១.៦ ឱកាសទទួលបានសេវាហិរញ្ញវត្ថុ និងសេវាមិនមែនហិរញ្ញវត្ថុ មានកំរិតតិចតួចបំផុត ........ ៨២
៣.១.៧ ផ្លូវ និងគមនាគមន៍ជនបទជាអាទិភាពសំរាប់នារី និងបុរស ........ ៨៣
៣.១.៨ នារីផ្តល់អាទិភាពលើការផ្គត់ផ្គង់ទឹកស្អាត ........ ៨៤
៣.១.៩ នារីមិនមានតំណាងរបស់ខ្លួននៅក្នុងតួនាទីធ្វើសេចក្តីសំរេចក្នុងវិស័យកសិកម្ម និងជួរមន្ត្រីរាជការស៊ីវិល ៨៥
៣.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ........ ៨៦

# ជំពូកទី ៣ ៖ នារី កសិកម្ម និង ធនធានជនបទ

## កម្ពុជានាពេលបច្ចុប្បន្ន[១]

| សូចនាករ | តំលៃ |
|---|---|
| ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ | ១១,៥ |
| អត្រាអ្នកនៅក្នុងបន្ទុកគ្រួសារនៅជនបទ | ៩០ |
| ភាគរយនៃនារីជនបទធ្វើការងារគ្មានប្រាក់កំរៃសំរាប់គ្រួសារ | ៤៦ |
| ភាគរយនៃនារីជនបទធ្វើការក្នុងវិស័យកសិកម្ម | ៨៩ |
| ភាគរយនៃនារីធ្វើការក្នុងវិស័យកសិកម្មលក្ខណៈគ្រួសារ | ៥៦ |
| ភាគរយនៃនារីធ្វើការក្នុងវិស័យកសិកម្មសំរាប់លក់ក្នុងទីផ្សារ | ៥៤ |
| ភាគរយនៃនារីដែលទទួលបានផលពីសេវាផ្សព្វផ្សាយកសិកម្ម | ១០ |
| ភាគរយនៃនារីជាអ្នកផ្សព្វផ្សាយកសិកម្ម | ៥-១០ |
| ភាគរយនៃនិស្សិតនារីនៅសកលវិទ្យាល័យភូមិន្ទកសិកម្ម | ១៧ |
| ភាគរយនៃនារីជាមេគ្រួសារដែលគ្មានដីស្រែចំការ | ២១ |
| ភាគរយនៃ "ស្ត្រីមេម៉ាយដោយសារសង្គ្រាម" ដែលគ្មានដីស្រែចំការ | ៥០ |
| ភាគរយនៃកម្មសិទ្ធិដីធ្លី ដែលមានឈ្មោះប្តី និងប្រពន្ធ តាំងពីឆ្នាំ២០០១ | ៧៨ |
| ភាគរយនៃការចំណាយក្នុងគ្រួសារពីប្រាក់ចំណូលដែលនារីរកបាន | ជាង៥០ |
| ប្រាក់បៀវត្សរបស់នារីប្រៀបធៀបជាមួយបុរសក្នុងការងារកែច្នៃផលិតផលត្រី | ៦៣ |
| ភាគរយនៃអ្នកខ្ចីឥណទានខ្នាតតូចជានារី | ៧០-៨៥ |
| ភាគរយនៃប្រជាជនដែលរស់នៅជនបទ មានទឹកស្អាតប្រើប្រាស់ | ២៥ |
| ចំនួនម៉ោងជាមធ្យមដែលនារីចំណាយលើការដងទឹកប្រចាំថ្ងៃ | ១-២ |
| ភាគរយនៃសមាជិកគណៈកម្មាធិការទឹកស្អាតក្នុងភូមិជានារី | ៦០ |
| ភាគរយនៃប្រជាជននៅជនបទដែលមានបង្គន់អនាម័យ | ១០ |
| ភាគរយនៃជំនួយអភិវឌ្ឍន៍ជាផ្លូវការ (ODA) សំរាប់វិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ ឆ្នាំ២០០១ | ២១ |
| ភាគរយនៃថវិកាជាតិសំរាប់វិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ ឆ្នាំ២០០២ | ៤ |
| ចំណែកនៃផលិតផលកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្នុងផលិតផលសរុបក្នុងស្រុក | ៣៣ |

[១] ប្រភព៖ Biddulph ឆ្នាំ២០០០៖ របាយការណ៍ស្តីពីការបាត់បង់ដី និងការស្រាវជ្រាវអភិវឌ្ឍន៍។ Beresford et al. ឆ្នាំ២០០៣៖ សេដ្ឋកិច្ចមាក្រូ និងការកាត់បន្ថយភាពក្រីក្រ នៅកម្ពុជា។ CSD ឆ្នាំ២០០២៖ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣-២០០៥។ IFAPER ឆ្នាំ២០០២៖ បញ្ហាយេនឌ័រនៅក្នុងការធ្វើផែនការ និងថវិកា។ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០២a៖ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររយៈពេល ៥ឆ្នាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០២-០៦។ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ឆ្នាំ២០០២៖ នារី និងការបណ្តុះបណ្តាលសំរាប់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និង IOM ឆ្នាំ២០០២៖ កម្មវិធីជួយស្ត្រីមេម៉ាយ៖ ការអង្កេតអំពីតម្រូវការ និងធនធានរបាយការណ៍ និងការវិភាគ។ អង្គភាពបច្ចេកទេសត្រួតពិនិត្យភាពក្រីក្រ (PMATU) ឆ្នាំ២០០៣។ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០២៖ គណនេយ្យជាតិកម្ពុជា។ Walter, A ឆ្នាំ២០០០ ការរៀនសូត្រពីកម្មវិធីសមាហរណកម្មសន្សំប្រាក់ និងឥណទាននៅកម្ពុជា។ កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ២០០១៖ ការសិក្សាអំពីក្មេងស្រី និងការសិក្សា របស់កម្មវិធីស្បៀងអាហារពិភពលោក

## ៣.១ ស្ថានភាព និន្នាការ និង បញ្ហា

ក្នុងពេលថ្មីៗនេះ វិស័យសេដ្ឋកិច្ចកើនឡើងតែនៅក្នុងទីក្រុង ឬទីប្រជុំជន ប៉ុន្តែសេដ្ឋកិច្ចនៅជនបទមានការកើនឡើងបន្តិចបន្តួចប៉ុណ្ណោះ។ ប្រជាជនក្រីក្រប្រមាណ ៩០ភាគរយ រស់នៅក្នុងតំបន់ជនបទ ហើយប្រជាពលរដ្ឋដែលក្រីក្របំផុតគឺជាកសិករ និងគ្រួសារដែលមានមេគ្រួសារទទួលបានការអប់រំតិចតួច ឬគ្មានការអប់រំក្នុងប្រពន្ធ័។ គ្រួសារដែលក្រីក្របំផុតនៅកម្ពុជាមិនមានទ្រព្យសម្បត្តិអ្វីឡើយ និងមានកូនច្រើន នាំឱ្យសមាជិកក្នុងបន្ទុកមានកំរិតខ្ពស់ (ចំនួនកុមារធៀបនឹងចំនួនអ្នករកប្រាក់ចំណូលក្នុងគ្រួសារមួយ) ធ្វើឱ្យប្រាក់ចំណូលដែលសមាជិកគ្រួសារម្នាក់ៗរកបាន មិនគ្រប់គ្រាន់សំរាប់គ្រួសារ។ អត្រាសមាជិកក្នុងបន្ទុកនៅតំបន់ជនបទ គឺមានចំនួន ៩០ភាគរយ (Beresford et al, ឆ្នាំ២០០៣)។ សន្តិសុខស្បៀងគឺជាបញ្ហាធ្ងន់ធ្ងរសំរាប់ប្រជាជនក្រីក្របំផុត: ប្រជាជនចំនួន ៣៦ភាគរយ រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ដែលរកចំណូលបានតែ ០,៤៦ដុល្លា ក្នុងមួយថ្ងៃ និង ១១ភាគរយ រស់នៅក្រោមបន្ទាត់នៃភាពខ្វះខាតម្ហូបអាហារ (អង្គភាពបច្ចេកទេសត្រួតពិនិត្យ និងវិភាគភាពក្រីក្រ - PMATU ឆ្នាំ២០០៣)។

វិស័យកសិកម្ម គឺជាខ្សឿនសេដ្ឋកិច្ច (backbone) នៅកម្ពុជា។ ប្រជាជនមួយភាគធំ នៅតែពឹងផ្អែកលើវិស័យកសិកម្មសំរាប់ការប្រកបរបរចិញ្ចឹមជីវិត។ កសិករភាគច្រើនមានដីស្រែចំការតិចតួច ដែលមានទំហំតិចជាងពីរហិចតា។ វិស័យកសិកម្មចូលរួមចំណែក ៣៣ភាគរយ ក្នុងផលិតផលសរុបក្នុងស្រុក និងជាប្រភពសំខាន់ដែលផ្តល់ការងារដល់កំលាំងពលកម្មចំនួន ៧៣ភាគរយ នៃកំលាំងពលកម្មសរុប។ ទោះបីជាវិស័យកសិកម្ម ជាប្រភពសំខាន់នៃការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនមួយចំនួនធំក៏ដោយ ក៏វិស័យនេះកើនឡើងប្រចាំឆ្នាំ ជាមធ្យមតែ ៣,៦ភាគរយប៉ុណ្ណោះ - មានចំនួនពាក់កណ្តាលនៃកំណើនផលិតផលសរុបក្នុងស្រុក ក្នុងបណ្តាឆ្នាំថ្មីៗនេះ។

ផលិតភាពកសិកម្ម មានកំរិតទាបបំផុត រាប់ទាំងកំលាំងពលកម្ម (ប្រហែល ១៦៦ដុល្លាអាមេរិកក្នុងកម្មករម្នាក់ក្នុងមួយឆ្នាំ) និងដី (៤៨០ដុល្លាអាមេរិកក្នុង១ហិកតា)។ ផលិតភាពកសិកម្ម ងាយរងគ្រោះដោយសារជំងឺ និងការផ្លាស់ប្តូរអាកាសធាតុក្នុងកំរិតខ្ពស់។ មូលហេតុខ្លះ ដែលបណ្តាលឱ្យផលិតភាពកសិកម្មមានកំរិតទាប មានដូចជា:

- *ផលិតកម្ម មានកំរិតទាប* ដោយសារការស្រាវជ្រាវ និងប្រពន្ធ័ផ្សព្វផ្សាយនៅទន់ខ្សោយ ប្រពន្ធ័ធារាសាស្ត្រ និងប្រពន្ធ័គ្រប់គ្រងទឹកនៅមិនទាន់គ្រប់គ្រាន់ សត្វល្អិត និងជំងឺសត្វចិញ្ចឹម គុណភាពគ្រាប់ពូជអន់ ផលិតកម្មសត្វចិញ្ចឹម និងការកែច្នៃកសិកម្ម នៅមានការខ្វះខាត ផលិតផលនេសាទមិនទាន់មាននិរន្តរភាព។

- *ផលិតកម្មក្រោយពេលប្រមូលផល និងទីផ្សារនៅទន់ខ្សោយ* ដោយសារការបាត់បង់មានកំរិតខ្ពស់ (ដោយសារការស្តុកទុកមិនបានល្អ មានការខូចខាត និងសត្វល្អិតបំផ្លាញ) ចំណេះដឹងអំពីការកែច្នៃ និងទីផ្សារនៅមានកំរិតតិចតួច សមាគមអាជីវកម្ម និងកសិករមានចំនួនតិចតួច ខ្វះស្ថាប័នគាំទ្រ និងខ្វះឱកាសទទួលបានពត៌មានអំពីទីផ្សារ។

- *ការវិនិយោគទុន នៅមានកំរិតទាប* ដោយសារដីធ្លីមួយចំនួន មិនមានកម្មសិទ្ធិច្បាស់លាស់ និងដីមានទំហំតូច មិនមានដើមទុន អំពើពុករលួយ និងការជួលដី ការខ្វះខាតពត៌មានស្តីអំពីស្ថានភាពផ្អែកច្បាប់ និងគោលនយោបាយ។

- *ភាពងាយរងគ្រោះ* របស់គ្រួសារនៅជនបទ ដោយសារខ្វះពត៌មានអំពីទីផ្សារ គោលនយោបាយ និងកម្មវិធី ប្រពន្ធ័ហិរញ្ញវត្ថុនៅទន់ខ្សោយ និងខ្វះខាតសេវាហិរញ្ញវត្ថុ ការប្រើប្រាស់ព្រៃឈើ ការនេសាទក្នុងសហគមន៍ និងធនធានផ្សេងៗទៀតនៅតាមឃុំនៅមានកំរិត ដីធ្លីមានមីន និងប្រពន្ធ័ផ្តល់ពត៌មានជាមុន អំពីគ្រោះធម្មជាតិនៅទន់ខ្សោយ ។

នារី មានចំនួនជាងពាក់កណ្តាលក្នុងកំលាំងពលកម្មកសិកម្ម ហេតុដូច្នេះ កិច្ចខិតខំប្រឹងប្រែងបង្កើនផលិតភាពកសិកម្មចាំបាច់ត្រូវយកចិត្តទុកដាក់ និងឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ។ នៅក្នុងតំបន់ជនបទ មានតែនារីចំនួន ៤ភាគរយ និងបុរសចំនួន ១០ភាគរយ ប៉ុណ្ណោះ ប្រកបការងារដែលមានប្រាក់កំរៃ ។ ផ្នែកការងារផ្លូវការ អាចស្រូបយកបានតែ ៥ភាគរយ នៃកំលាំងពលកម្មសរុបប៉ុណ្ណោះ ។ ៩៤ភាគរយ នៃកម្មករថ្មីចំនួន ២៥០.០០០នាក់ ដែលចូលរួមចំណែកក្នុងកំលាំងពលកម្មរាល់ឆ្នាំ ពឹងផ្អែកទៅលើការងារក្រៅផ្លូវការ ដូចជា ការងារកសិកម្មលក្ខណៈគ្រួសារ ដែលផលិតកម្ម និងប្រាក់ចំណូលមានកំរិតទាប (ចាន់ ឆ្នាំ២០០៣) ។ ដោយសារអត្រាកំណើតមានកំរិតខ្ពស់នៅជនបទ និងអត្រាកំណើនប្រជាជននាពេលអនាគតធ្វើឱ្យមានការព្រួយបារម្ភអំពីផលិតភាព និងដីដែលមានកំរិត និងផលលំបាក ក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនជំនាន់ក្រោយ ។

ការរីកចំរើនក្នុងការប្រកបរបរចិញ្ចឹមជីវិតនៅជនបទ ត្រូវរាំងស្ទះ ដោយមិនមានហេដ្ឋារចនាសម្ពន្ធ័គ្រប់គ្រាន់ (ផ្លូវ ការចែកចាយទឹក) សេវាសង្គម (ការអប់រំ សុខាភិបាល) និងសេវាសេដ្ឋកិច្ច (ការផ្សព្វផ្សាយអំពីកសិកម្ម ការគាំទ្រផ្នែកបច្ចេកទេស អភិវឌ្ឍន៍សហគ្រាសហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ) ។ នារី ជួបឧបសគ្គច្រើនជាងបុរស ដោយសារតែកង្វះសេវាទាំងនេះ ដែលធ្វើឱ្យនារីមិនមានលទ្ធភាពបង្កើនជាអតិបរមានូវកំរិតនៃផលិតភាព និងតំលៃតបស្នងទៅនឹងពលកម្មរបស់ខ្លួន ។

នៅពេលដែលធ្វើការពិនិត្យលើការប្រកបរបរចិញ្ចឹមជីវិតនៅជនបទ សំខាន់ត្រូវមើលដល់ប្រពៃណីនៃការធ្វើស្រែចំការរបស់កសិករ ។ ប្រជាពលរដ្ឋនៅជនបទត្រូវចំណាយពេលជាមធ្យមពី ៤ ទៅ ៥ខែ (រយៈពេលតិចជាងកន្លះឆ្នាំ) លើការងារធ្វើស្រែ និងដាំដំណាំផ្សេងៗទៀត និងរកប្រាក់ចំណូលបានតែមួយភាគបី នៃប្រាក់ចំណូលសរុបរបស់ពួកគេ ។ កសិករលក់ផលិតផលរបស់គេទៅឱ្យអ្នកជំនួញ ឬម្ចាស់ម៉ាស៊ីនកិនស្រូវ ។ ផលិតកម្មទ្រង់ទ្រាយតូច និងជាលក្ខណៈគ្រួសារ ធ្វើឱ្យគាត់ពុំមានលទ្ធភាពក្នុងការទាមទារតំលៃ និងត្រូវលក់ផលិតផលក្នុងតំលៃទាប ។ ប្រជាពលរដ្ឋ ប្រកបរបរចិញ្ចឹមជីវិត និងរកប្រាក់ចំណូលដោយសារការនេសាទ ការដើររកម្ហូប និងរបស់របរផ្សេងៗទៀតក្រៅពីម្ហូប ប្រកបរបរអាជីវកម្ម និងការលក់កំលាំងពលកម្មដើម្បីរកប្រាក់ចំណូលតាមរដូវកាល ។ (Achapya et al ឆ្នាំ២០០២; Beresford et al, ឆ្នាំ២០០៣) ។

ការកើនឡើងនៃភាពស្ទើរតែគ្មានដីធ្លី គ្មានដីធ្លី គួបផ្សំឱកាសតិចតួចក្នុងការប្រើប្រាស់ធនធានរួម ដូច្នេះ ចំនួនមនុស្សដែលកាន់តែកើនឡើង ជាពិសេស នារី នឹងធ្វើឱ្យគ្រួសារនៅជនបទមិនមានធនធានផលិតកម្មអ្វី ក្រៅពីកំលាំងពលកម្មផ្ទាល់របស់ខ្លួន និងមិនអាចដោះស្រាយបញ្ហាភាពក្រីក្របានឡើយ ល្គឹកណាគ្មានការបង្កើនការងារបន្ថែមនៅជនបទ ក្រៅពីការងារធ្វើស្រែចំការ (Beresford et al, ឆ្នាំ២០០៣) ។

អ្នកស្រាវជ្រាវដែលកំពុងធ្វើការស្រាវជ្រាវអំពីតួនាទីយេនឌ័រក្នុងការគ្រប់គ្រងធនធានធម្មជាតិ នៅតំបន់បឹងទន្លេសាបបានរកឃើញថា នារី និងកុមារីនៅជនបទ ចូលរួមចំណែកច្រើនជាងបុរស និងកុមារាក្នុងសកម្មភាពរកប្រាក់ចំណូលក្នុងផ្នែក

កសិកម្ម និងព្រៃឈើ ក៏ដូចជាសកម្មភាពផ្សេងៗទៀត ប៉ុន្តែបុរស ទទួលបានការគ្រប់គ្រង ច្រើនជាងនារី លើផលប្រយោជន៍នៃធនធានផលិតកម្មទាំងនោះ (GAD/C និង FAO, ឆ្នាំ១៩៩៥) ។

ការប៉ាន់ប្រមាណអំពីយេនឌ័រនៅក្នុងជំពូកនេះ នឹងពិនិត្យលើបញ្ហាយេនឌ័រដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី សេវាកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ សេវាហិរញ្ញវត្ថុ និងសេវាមិនមែនហិរញ្ញវត្ថុ ដែលប៉ះពាល់ដល់ឱកាសរបស់នារី ចូលរួមក្នុងសកម្មភាពកសិកម្ម សកម្មភាពក្រៅពីស្រែចំការ និងសកម្មភាពទីផ្សារ ដែលឈានទៅរកការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀងជាទូទៅ ។

### តើអ្វីជាបញ្ហាកង្វល់របស់នារី និងបុរសនៅជនបទ ?

ការពិគ្រោះយោបល់មួយចំនួនស្តីពី "ការកាត់បន្ថយភាពក្រីក្រដើម្បីស្ត្រី" ត្រូវបានរៀបចំឡើងដោយអង្គការចំរើនស្ត្រី ជាអង្គការក្រៅរដ្ឋាភិបាល ជាផ្នែកមួយនៃដំណើរការរៀបចំតាក់តែងយុទ្ធសាស្ត្រថ្នាក់ជាតិកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ លទ្ធផលនៃការពិគ្រោះយោបល់ជាទូទៅនៅក្នុងខេត្តចំនួន៦ បានបង្ហាញឱ្យឃើញថា នារី និងបុរស មានបញ្ហាកង្វល់ប្រហាក់ប្រហែលគ្នា ដែលក្នុងនោះមានបញ្ហាជាអាទិភាព ៥ ដូចជា សន្តិសុខស្បៀង ផ្លូវគមនាគមន៍នៅជនបទមិនល្អ ទឹកមិនស្អាត ការទទួលបានដី ប៉ុន្តែគ្មានកម្មសិទ្ធិ និងដីមានមីន។ ការពិគ្រោះយោបល់បន្ថែមជាមួយនារីនៅថ្នាក់ឃុំ និងភូមិ ក្នុងខេត្តកំពង់ចាម បានឱ្យអាទិភាពលើការសាងសង់ផ្លូវសាធារណៈ ហើយបុរសឱ្យអាទិភាពលើការជីកអណ្តូងទឹក ដែលអណ្តូងទាំងនោះនឹងអាចជីកលើដីឯកជន។ (ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឆ្នាំ២០០៣ b)

### ៣.១.១ នារីមានតួនាទីសំខាន់នៅក្នុងផលិតកម្មកសិកម្ម

៧៣ ភាគរយ នៃកំលាំងពលកម្ម ធ្វើការងារកសិកម្ម។ ជិត ៨០ភាគរយ នៃកំលាំងពលកម្មទាំងនោះ ធ្វើការងារកសិកម្មលក្ខណៈគ្រួសារ ដែលមាននារី ៥៦ភាគរយ ជាកំលាំងពលកម្មក្នុងការងារកសិកម្មជាលក្ខណៈគ្រួសារ និង ៥៤ភាគរយ នៅក្នុងកំលាំងពលកម្មការងារកសិកម្មទីផ្សារ។ ភាគច្រើននៃនារីទាំងនេះ ជាអ្នកធ្វើការងារគ្មានប្រាក់កំរៃក្នុងគ្រួសារ (LFS, ឆ្នាំ២០០១) ។ នារីជាមេគ្រួសារភាគច្រើន ធ្វើការងារកសិកម្ម បើប្រៀបធៀបជាមួយនឹងបុរសជាមេគ្រួសារ ហើយនារីជាមេគ្រួសារទាំងនេះ មិនមានដីស្រែចំការ ឬមានដីតិចតួច។ នារី មានតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យកសិកម្ម ប៉ុន្តែនារីមានឱកាសតិចតួចក្នុងការទទួលបានធនធាន និងទ្រព្យសម្បត្តិដែលអាចជួយបង្កើនសក្តានុពលភាពរបស់នារី ឱ្យអាចបង្កើនផលិតភាព សន្តិសុខស្បៀងឱ្យកាន់តែល្អប្រសើរ និងឈានទៅកាត់បន្ថយភាពក្រីក្រ។

## ៣.១.២ នារីមានតួនាទីប្រកបដោយសក្តានុពលភាពយ៉ាងសំខាន់ ក្នុងការកាត់បន្ថយ អសន្តិសុខស្បៀង

យេនឌ័រ សន្តិសុខស្បៀង និងភាពក្រីក្រ ជាបញ្ហាដែលពាក់ព័ន្ធគ្នា។ ការប៉ាន់ប្រមាណអំពីភាពក្រីក្រដោយមានការចូលរួម (ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០០១) បានកំណត់និយមន័យភាពក្រីក្រ គឺការមិនមានអង្ករ និងម្ហូបអាហារគ្រប់គ្រាន់ក្នុងរយៈពេលក្នុងមួយឆ្នាំ (១២ខែ) និងជាភាពអត់ឃ្លានជានិច្ចកាល ក្នុងលក្ខខណ្ឌរ៉ាំរ៉ៃ ដែលពួកគេមិនអាចគេចរួច លើកលែងតែសំរាប់រយៈពេលបណ្តោះអាសន្នតែប៉ុណ្ណោះ។ ដោយសារភាពអត់ឃ្លាន ប្រជាជនក្រីក្រ ពុំអាចបំពេញបានតាមតម្រូវការរបស់ខ្លួនឡើយ ដូចជា លទ្ធភាពដើម្បីបញ្ជូនកូនទាំងអស់ទៅសាលារៀន ចំណាយចាំបាច់សំរាប់ការថែទាំសុខភាព និងការបំពេញកាតព្វកិច្ចខាងផ្នែកវប្បធម៌ប្រពៃណី (ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០០១)។ ប្រជាជន ដែលរងគ្រោះដោយអសន្តិសុខស្បៀងរ៉ាំរ៉ៃ រួមមាន កសិករជាលក្ខណៈគ្រួសារ អ្នកគ្មានដីធ្លី ឬមានដីធ្លីតិចតួច ក្រុមប្រជាជនក្រីក្រនៅតាមទីប្រជុំជន និងក្រុមងាយរងគ្រោះផ្សេងៗទៀត។ សន្តិសុខស្បៀងមួយរយៈពេលខ្លី ប៉ះពាល់ដល់ប្រជាជនដែលកំពុងប្រឈមមុខនឹងគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត។ ការវិភាគយេនឌ័រនៅក្នុងផ្នែកសន្តិសុខស្បៀង រួមមានពីរផ្នែក: ផលប៉ះពាល់ខុសៗគ្នានៃអសន្តិសុខស្បៀងទៅលើ នារី និងបុរស និងតួនាទីរបស់នារី និងបុរសក្នុងការរក្សាសន្តិសុខស្បៀងគ្រួសារ។ ១១ភាគរយ នៃប្រជាជនកម្ពុជារស់នៅក្រោមបន្ទាត់នៃការខ្វះខាតស្បៀង (PMATU ឆ្នាំ២០០៣) ។ ប៉ុន្តែការវាស់ស្ទង់នេះ មិនបានបង្ហាញអំពីភាពខុសគ្នា នៃការរងគ្រោះរបស់នារី និងបុរសឡើយ។ ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី១ នារីប្រើប្រាស់ស្បៀងសំខាន់ (អង្ករ) និងម្ហូបអាហារបន្ទាប់ (សាច់ និងស៊ុត) តិចជាងបុរស។ ក្រសួងសុខាភិបាលកំពុងពិនិត្យឃើញថា នារីមានសន្ទស្សន៍ម៉ាសរាងកាយទាប និងមានអត្រាជំងឺស្លេកស្លាំងខ្វះជាតិដែកកំរិតខ្ពស់។ នេះមានន័យថា នារី អាចនឹងងាយរងគ្រោះដោយសារភាពអត់ឃ្លាន និងអសន្តិសុខស្បៀង មានលក្ខណៈខុសពីបុរស (សូមមើលជំពូក៥)។

ការពិភាក្សាអំពីសន្តិសុខស្បៀង បានផ្តោតលើភាពខុសគ្នារវាង ឱកាសទទួលបានស្បៀង និងស្បៀងដែលមាន។ ការសិក្សានាពេលថ្មីៗនេះបង្ហាញឱ្យឃើញថា ខេត្ត-ក្រុងចំនួនជិតពាក់កណ្តាលក្នុងចំណោមខេត្ត-ក្រុងចំនួន ២៤ គឺជាតំបន់ដែលមានស្បៀងតិចតួចបំផុត។ ទោះបីជានៅក្នុងខេត្តដែលផលិតបានស្រូវច្រើនជាងគេ ក៏មានឃុំចំនួន ៣០ភាគរយប្រឈមមុខនឹងការខ្វះខាតស្បៀងរ៉ាំរ៉ៃ (យ ជ ក ភ ឆ្នាំ២០០២a)។ ប្រទេសកម្ពុជា អាចផលិតស្រូវលើសពីតម្រូវការជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩៥ និងអាចនាំចេញទៅក្រៅផងដែរ ដូច្នេះបញ្ហាស្បៀងដែលមាន មិនជាបញ្ហាអ្វីឡើយ។ ប៉ុន្តែបញ្ហានោះគឺការពង្រឹងលទ្ធភាពរបស់គ្រួសារនីមួយៗ ក្នុងការទទួលបានស្បៀងដែលមាន តាមរយៈការពង្រឹងលទ្ធភាពរបស់គ្រួសារក្នុងការទិញស្បៀងទាំងនោះ។ ដើម្បីធ្វើឱ្យស្ថានភាពនេះប្រសើរឡើង ត្រូវការចាំបាច់នូវយុទ្ធសាស្ត្រដើម្បីបង្កើនផលិតភាពរបស់គ្រួសារ (តាមរយៈឱកាសទទួលបានដីធ្លី និងដើមទុនផ្សេងៗ) ឬបង្កើនចំណូលគ្រួសារ។ ដូចដែលបានរៀបរាប់ពីមុនរួចមកហើយថា ចំណូលជាងពាក់កណ្តាលដែលនារីរកបាន ត្រូវចំណាយសំរាប់គ្រួសារ ហើយនារី និងកុមារី ចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលច្រើនជាងបុរស និងកុមារា។ នេះមានន័យថា យុទ្ធសាស្ត្រដើម្បីកាត់បន្ថយភាពអត់ឃ្លាន និងអសន្តិសុខស្បៀង ត្រូវផ្តល់អាទិភាពលើការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចរបស់នារី និងការបង្កើនការយល់ដឹងរបស់នារី អំពីសុខភាព និងអាហារូបត្ថម្ភ ព្រោះថា នារី ដើរតួយ៉ាងសំខាន់បំផុតក្នុងការផ្តល់ម្ហូបអាហារ និងអាហារូបត្ថម្ភគ្រប់គ្រាន់ នៅក្នុងគ្រួសារ។

ក្នុងឆ្នាំ១៩៩៧ គ្រួសារនៅជនបទ បានចំណាយ ៧១ភាគរយ នៃការចំណាយសរុបប្រចាំខែលើម្ហូបអាហារ ។ អត្រាប្រជាជនក្រីក្របំផុតចំនួនពាក់កណ្តាល បានចំណាយ ២០-៣០ភាគរយនៃចំណាយសរុបប្រចាំខែរបស់ខ្លួនសំរាប់ទិញអង្ករ ។ ដូច្នេះហើយ គោលនយោបាយដែលអនុគ្រោះដល់តំលៃអង្ករ នឹងជួយបង្កើនការប្រើប្រាស់របស់គ្រួសារក្រីក្រ (Beresfordet al, ឆ្នាំ២០០៣) ។

## ៣.១.៣ សេវាផ្សព្វផ្សាយមានកំរិតអប្បបរមា នារីទទួលបានសេវាផ្សព្វផ្សាយតិចជាងបុរស

ទោះបីជាចំនួនភាគច្រើននៃកសិករ និងកម្មករក្នុងផ្នែកក្រៅផ្លូវការ ជានារី ប៉ុន្តែនារីចំនួនតិចបំផុត បានទទួលផលប្រយោជន៍ពីសេវាកសិកម្ម សេវាកម្ម និងទ្រព្យសម្បត្តិផ្សេងៗទៀត ពាក់ព័ន្ធនឹងការប្រកបរបរចិញ្ចឹមជីវិតនៅជនបទ ។ ជាទូទៅសេវាផ្សព្វផ្សាយអំពីកសិកម្ម នៅមានកំរិតទាបបំផុត ។ ក្នុងឆ្នាំ២០០២ មានតែកសិករចំនួន ២០.០០០នាក់ប៉ុណ្ណោះ (ស្មើនឹង ០,៧ភាគរយនៃកសិករទាំងអស់) ចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយ ។ តាមរយៈលទ្ធផលនេះ យើងនឹងត្រូវការរយៈពេល ៦៥ឆ្នាំ ដើម្បីឱ្យកសិករចំនួនពាក់កណ្តាលនៃអត្រាសរុបចំនួន ២,៦លាននាក់ នៅកម្ពុជាទទួលបានសេវាផ្សព្វផ្សាយកសិកម្ម (ធនាគារពិភពលោក ឆ្នាំ២០០៣b) ។ ឱកាសទទួលបានសេវាផ្សព្វផ្សាយដែលមានគុណភាព គឺជាបញ្ហាធ្ងន់ធ្ងរចំពោះកសិករជាបុរស និងនារី ។ នារី ទទួលបានឱកាសតិចតួចណាស់ ក្នុងការទទួលបានសេវាផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដែលមានតិចតួចនេះ ។ លើសពីនេះ តាមការប៉ាន់ប្រមាណ មាននារីចំនួនតែ ១០ភាគរយ ប៉ុណ្ណោះ ជាអ្នកទទួលផលប្រយោជន៍ពីសេវាផ្សព្វផ្សាយ ។ ការផ្សព្វផ្សាយពតិមានដើម្បីឱ្យកសិករទទួលបានសេវាផ្សព្វផ្សាយកសិកម្ម នៅមានកំរិតបំផុត ។ ដោយផ្អែកលើពតិមានទទួលបាន និងការពិភាក្សាជាមួយតំណាងស្ថាប័នរដ្ឋាភិបាល និងភ្នាក់ងារអ្នកផ្តល់ជំនួយ ដែលធ្វើការក្នុងវិស័យនេះ បានបង្ហាញឱ្យឃើញនូវមូលហេតុមួយចំនួនដែលធ្វើឱ្យនារីទទួលបានសេវាផ្សព្វផ្សាយតិចតួច ដូចជា ៖

- ការស្រាវជ្រាវ និងការផ្សព្វផ្សាយអំពីកសិកម្ម មិនបានផ្តោតលើសកម្មភាពរបស់នារីជាកសិករ ។ បុរស និងនារីមានជំនាញការងារខុសៗគ្នា (តារាង៣.១) ។ ជាទូទៅ ការងាររបស់បុរសជាការងារដែលពាក់ព័ន្ធនឹងការប្រើកំលាំងកាយ ឬការប្រើបច្ចេកទេស និងគ្រឿងម៉ាស៊ីន ។ ឧទាហរណ៍ ៖ ក្នុងការងារធ្វើស្រែ នារីទទួលខុសត្រូវលើការរៀបចំពូជស្រូវ និងស្តុង (ការត្រាំពូជ ដកស្ទូង ទុកដាក់ស្រូវ និងព្រួសពូជស្រូវ) ដកស្ទូង និងការងារត្រួតពិនិត្យសត្វល្អិតដែលមិនត្រូវការបច្ចេកទេសខ្ពស់ ។ បុរសទទួលខុសត្រូវក្នុងការភ្ជួររាស់ដី ធារាសាស្ត្រ បាញ់ថ្នាំសម្លាប់សត្វល្អិត និងបាញ់ជី (Norris et al., ឆ្នាំ២០០១) ។

## តារាង ៣.១ : ការបែងចែកពលកម្មការងារយេនឌ័រ

| ការងារ | នារី | បុរស |
|---|---|---|
| **ការងារផលិត** | | |
| *ការងារធ្វើស្រែ* | | |
| រៀបចំដីធ្លី | + | ++ |
| ផ្ទាប់ស្រូវពូជ | + | – |
| រោយសំអាតស្រូវពូជ | + | – |
| រៀបចំទុកដាក់ពូជស្រូវ | ++ | – |
| បោចស្ទូង | ++ | + |
| ព្រួសពូជស្រូវ | ++ | + |
| ស្ទូង | ++ | + |
| បញ្ចេញ បញ្ចូលទឹក | + | ++ |
| ការគ្រប់គ្រងស្រែ | + | ++ |
| ដាក់ជី | + | + |
| ច្រូតស្រូវ | ++ | + |
| បោកស្រូវ | + | + |
| *ចិញ្ចឹមសត្វ* | | |
| ចិញ្ចឹមជ្រូក មាន់ | ++ | + |
| ចិញ្ចឹមគោ | + | ++ |
| កាត់ស្មៅសំរាប់ចំណីសត្វ | + | + |
| *ដាំបន្លែ និងដំណាំហូបផ្លែ* | ++ | + |
| **ការងារគ្មានប្រាក់កំរៃ** | | |
| រកអុសដុត | ++ | + |
| ដងទឹក | + | ++ |
| កាត់ដេរ ប៉ះសំលៀកបំពាក់ | + | – |
| រៀបចំ និងធ្វើម្ហូប | ++ | + |
| សំអាតក្នុងផ្ទះ និងទីធ្លាផ្ទះ | + | – |
| មើលថែទាំកូន | ++ | + |
| **ការងារសរុប** | | |
| ++ ធ្វើការងារច្រើនជាងគេ | ១០ | ៥ |
| + ធ្វើការងារជាមធ្យម | ១២ | ១២ |
| – ធ្វើការងារតិចតួច | ០ | ៥ |

**សំគាល់:** ការវិភាគនេះមិនបានបញ្ចូលការងារក្រៅពីធ្វើស្រែចំការ ដែលបុរស និងនារីចូលរួមយ៉ាងសកម្ម និងមានតួនាទីខុសៗគ្នា ។ (សូមមើលជំពូកទី២)

**ប្រភព :** ផ្អែកលើការពិភាក្សាតាមភូមិក្នុងខេត្តស្វាយរៀង និងព្រៃវែង ដែលត្រូវបានធ្វើឡើងជាផ្នែកមួយនៃបេសកកម្មរៀបចំគំរោងកាត់បន្ថយភាពក្រីក្រនៅជនបទរបស់ IFAD ឯកសារស្រាវជ្រាវទី២ ការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ ឆ្នាំ២០០៣

- កសិករត្រូវធ្វើដំណើរជាមធ្យមចំងាយ ៩ គីឡូម៉ែត្រ ពីភូមិទៅស្រុក ដើម្បីទទួលបានសេវាផ្សព្វផ្សាយ ។ សំរាប់កសិករក្រីក្របំផុត ចំងាយពីភូមិទៅស្រុកជាមធ្យម ១៣គីឡូម៉ែត្រ ។ មានតែភូមិចំនួន ៣ភាគរយប៉ុណ្ណោះ មានអ្នកផ្សព្វផ្សាយអំពីកសិកម្ម និងភូមិចំនួន ៧ភាគរយ មានសេវាឥណទាន ។ ដោយសារបញ្ហាសុវត្ថិភាព នារី មានការរារែកក្នុងការធ្វើដំណើរ ហើយលើសពីនេះ នារីមានតួនាទីក្នុងការដាំស្ល និងមើលថែទាំកូនដែលធ្វើឱ្យនារី មានការលំបាកក្នុងការចាកចេញពីផ្ទះរយៈពេលលើសពីពីរ ឬបីម៉ោង ។

- ដោយសារទំនៀមទំលាប់ប្រពៃណី បុគ្គលិកផ្សព្វផ្សាយជាបុរសភាគច្រើន មានការលំបាកក្នុងការធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយនារីជាកសិករ ។ ជាទម្លាប់ បុរស ជាអ្នកទទួលបានការបណ្តុះបណ្តាល និងសេវាផ្សព្វផ្សាយ ប៉ុន្តែប្រពន្ធជាអ្នកទទួលខុសត្រូវលើការងារទាំងនោះ ។ ការផ្ទេរចំណេះដឹងថ្មីពីប្តីទៅដល់ប្រពន្ធ កំរនឹងមានប្រសិទ្ធិភាពណាស់ ។ ភ្នាក់ងារផ្សព្វផ្សាយជានារី អាចធ្វើការទំនាក់ទំនងយ៉ាងងាយស្រួលជាមួយកសិករជានារី ។ ប្រទេសកម្ពុជាក៏ដូចជាប្រទេសផ្សេងៗនៅក្នុងពិភពលោកដែរ តាមការប៉ាន់ប្រមាណ មាននារីចំនួនតែ ៥ ទៅ ១០ភាគរយ ជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ( ធនាគារពិភពលោក ឆ្នាំ២០០២) ។ ភ្នាក់ងារផ្សព្វផ្សាយជានារី មានចំនួនតិច បើប្រៀបធៀបទៅនឹងចំនួននារីចូលរួមក្នុងវិស័យកសិកម្ម ( ជាង ៥០ភាគរយ) អាចធ្វើឱ្យកសិករនារីមានការលំបាកក្នុងការទទួលបានពត៌មានចាំបាច់ ដើម្បីបង្កើនផលិតកម្មកសិកម្ម ដែលការងារនេះជាការទទួលខុសត្រូវយ៉ាងសំខាន់របស់នារី ។ បញ្ហានេះ ធ្វើឱ្យនារីជាកសិករ ពុំមានលទ្ធភាពតាមទាន់ការអភិវឌ្ឍន៍ក្នុងវិស័យនេះនាពេលអនាគត (ADB, ឆ្នាំ២០០៣) ។

- ការផ្សព្វផ្សាយពត៌មាន ច្រើនតែរៀបចំឡើងសំរាប់ប្រជាពលរដ្ឋដែលចេះអក្សរ[២] ។ នៅកម្ពុជា មាននារីចំនួន ៧១ ភាគរយ និងបុរសចំនួន ៥០ភាគរយ ជាអនក្ខរជន (UNDP/UNESCO, ២០០០) ។ ចំណុចនេះមានសារៈសំខាន់ណាស់សំរាប់ការរៀបចំគំរោង និងការចែកចាយសេវាផ្សព្វផ្សាយៈ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយពត៌មានត្រូវរៀបចំដើម្បីឱ្យកសិករដែលមានការអប់រំតិចតួច ឬគ្មានការអប់រំអាចទទួលយកបាន ។ សំរាប់នារីដែលមិនអាចធ្វើដំណើរឆ្ងាយដូចបុរស បានសំណូមពរ ឱ្យមានការិយាល័យសំរាប់ផ្តល់ពត៌មានអំពីផលិតកម្មកសិកម្ម ការកែច្នៃកសិកម្ម និងទីផ្សារ និងសំណូមពរឱ្យមានការផ្តល់ពត៌មានឱ្យបានដល់ទីកន្លែងដែលនារីរស់នៅ ដោយមិនត្រូវសន្និដ្ឋានថា នារីនឹងអាចធ្វើដំណើរមកចូលរួមប្រជុំ ការបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗទៀតបាននោះទេ (ADB, ឆ្នាំ២០០៣) ។

**"គ្រាន់តែខ្ញុំមិនចេះអាន និងសរសេរ មិនមែនមានន័យថា ខ្ញុំមិនអាចរៀន តាមរយៈការសង្កេតពីអ្វីដែលត្រូវធ្វើនោះទេ។ នៅពេលនោះ ខ្ញុំអាចយកអ្វីដែលខ្ញុំបានរៀន មកសាកល្បងនៅតាមកន្លែងជាក់ស្តែង និងពិនិត្យមើលថាតើមធ្យោបាយនោះអាចប្រើប្រាស់បានដែរឬទេ....។ វាមិនជាការចាំបាច់ឱ្យមានបុរសក្នុងភូមិទទួលការបណ្តុះបណ្តាល ហើយបន្ទាប់មក ឱ្យបុរស**

---

[២] ឆ្នាំមុនឯកសារចំនួន៩៧.៨៨៩ ត្រូវបានចែកចាយ ។ មានការផ្សព្វផ្សាយតាមវិទ្យុចំនួន ១០ដង និងទូរទស្សន៍ ១១ដង ( ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ២០០២) ។ នៅជនបទគ្រួសារចំនួន ៤១% មានវិទ្យុប្រើ និង ២០% មានទូរទស្សន៍ប្រើ - អង្កេតសង្គមកិច្ច សេដ្ឋកិច្ចនៅកម្ពុជា ឆ្នាំ១៩៩៩) ។

ទាំងនោះមកបង្រៀនខ្ញុំទេ ពីព្រោះពួកគាត់មិនមែនជាអ្នកធ្វើការងារនេះផង" នារីម្នាក់នៅខេត្តស្វាយរៀង បានអះអាងនៅក្នុងដំណើរការវាយតម្លៃប៉ាន់ប្រមាណភាពក្រីក្រដោយមានការចូលរួម ( ADB ឆ្នាំ២០០១)។

## ៣.១.៤ ឱកាសតិចតួចក្នុងការទទួលបានធនធានធម្មជាតិ កំពុងគំរាមកំហែងដល់ការប្រកបរបរចិញ្ចឹមជីវិត

នារី និងកុមារនៅក្នុងគ្រួសារក្រីក្រគ្មានដីធ្លី ជាពិសេស គ្រួសារដែលនារីជាមេគ្រួសារ ទៅរកខ្យង ត្រី អុសដុត វល្លិ និងដើមឈើផ្សេងៗទៀត សំរាប់ប្រើប្រាស់ និងលក់។ សកម្មភាពទាំងនេះ មានសារៈសំខាន់ណាស់ចំពោះសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋក្រីក្រ ប៉ុន្តែកំពុងរងនូវការគំរាមកំហែងពីភាពហិនហោចនៃបរិដ្ឋាន និងការគ្រប់គ្រងមិនបានល្អរបស់សហគមន៍ទៅលើធនធានធម្មជាតិ (Kim et al, ឆ្នាំ២០០៣)។ តាមរយៈការសិក្សាក្នុងពេលថ្មីៗនេះ អំពីយេនឌ័រ និងកសិកម្មក្នុងខេត្តព្រៃវែង និងស្វាយរៀង បានបង្ហាញឱ្យឃើញថា គ្រួសារដែលនារីជាមេគ្រួសារនៅក្នុងតំបន់ជនបទ ពឹងផ្អែកស្ទើរតែទាំងស្រុងលើការប្រមូលធនធានព្រៃឈើ សំរាប់យកមកដូរជាមួយអង្ករ។ នារីកាន់តែមានការលំបាកក្នុងការទទួលផលពីធនធានធម្មជាតិ រួមផ្សំនឹងការគ្មានដីធ្លី ដូច្នេះនារីនឹងជួបការលំបាកយ៉ាងខ្លាំងចំពោះបញ្ហាសន្តិសុខស្បៀង (IFAD, ឆ្នាំ២០០៣)។

## ៣.១.៥ ទោះបីជាមានច្បាប់ដីធ្លីថ្មីដែលយកចិត្តទុកដាក់លើយេនឌ័រ ប៉ុន្តែនារីនៅតែងាយរងគ្រោះដោយសារតែសិទ្ធិនារីក្នុងការទទួលបានដី មិនត្រូវបានគេយកចិត្តទុកដាក់

ការប្រកបរបរចិញ្ចឹមជីវិតនៅជនបទ គឺពឹងផ្អែកទាំងស្រុងលើដីធ្លី និងធនធានធម្មជាតិផ្សេងៗទៀត។ ដូច្នេះការបាត់បង់ឱកាសទទួលបានធនធានទាំងពីរនេះ បណ្តាលឱ្យមានភាពក្រីក្រ និងអសន្តិសុខស្បៀងរ៉ាំរ៉ៃ ឬមួយរយៈពេល (Kim et al, ឆ្នាំ២០០៣)។ នៅក្នុងការសិក្សាអំពីដីធ្លីរបស់អង្គការ Oxfam បានធ្វើការសាកសួរសហគមន៍ឱ្យកំណត់និយមន័យនៃភាពក្រីក្រ លទ្ធផលបង្ហាញឱ្យឃើញថា ភាពគ្មានដី ឬមានដីតិចតួច ជាលក្ខណៈវិនិច្ឆ័យចំបងមួយនៃភាពក្រីក្រ។ ភាពគ្មានដី និងស្ទើរតែគ្មានដី គឺជាសូចនាករនៃភាពក្រីក្រនៅជនបទ។

វិសមភាពក្នុងការបែងចែកដីធ្លី: ម្ចាស់ដីចំនួន ២០-៣០ភាគរយ កាន់កាប់លើដីចំនួន ៧០ភាគរយ ចំណែកឯប្រជាពលរដ្ឋក្រីក្របំផុតចំនួន ៤០ភាគរយ កាន់កាប់ដីតែ ១០ភាគរយប៉ុណ្ណោះ (Beresford et al, ឆ្នាំ២០០៣)។ ប្រហែល ២០ភាគរយ នៃគ្រួសារនៅជនបទ មិនមានដី និង ២៥ ភាគរយ នៃគ្រួសារជនបទមានដីដែលមានទំហំតូចជាង ០,៥ ហិកតា ដីដែលមានទំហំតូចជាង ១ហិកតា ចាត់ទុកថា មិនគ្រប់គ្រាន់សំរាប់ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។ ៤៥ភាគរយនៃគ្រួសារនៅជនបទ ត្រូវបានចាត់ទុកថា មិនមានដី ឬស្ទើរតែគ្មានដី និងងាយរងគ្រោះដោយសារអសន្តិសុខស្បៀងបំផុត។ តាមការប៉ាន់ប្រមាណ ការបាត់បង់ដី កំពុងតែកើនឡើងប្រហែល ២ភាគរយរៀងរាល់ឆ្នាំ (Kim et al, ឆ្នាំ២០០៣)។

មានដីតិចតួច គ្មានដី និងអត្រាផលិតផលស្រូវមិនអំណោយផល ជាកត្តាបណ្តាលឱ្យមានការខ្វះខាតស្រូវសំរាប់គ្រួសារនៅគ្រប់ករិត។ ទំហំដីតូចមិនអាចទាក់ទាញវិនិយោគទុន និងមិនផ្តល់ផលិតភាពខ្ពស់។ កសិករមួយចំនួនគ្មានមធ្យោបាយ ឬគ្មានបច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីវិនិយោគទុន និងទទួលបានផលពីដី ដែលមានទំហំតូចនោះបានឡើយ។ ដូច្នេះ កសិករដែលមានដីទំហំតូចទាំងនោះ ទទួលបានផលិតភាពទាប និងរកប្រាក់ចំណេញបានតិច (Kim et al, ឆ្នាំ២០០២)។

ដោយសារឥទ្ធិពលនៃសង្គ្រាមជិតបីទសវត្សរ៍ និងការផ្លាស់ប្តូរលំនៅដ្ឋានក្នុងស្រុក ធ្វើឱ្យកំណែទម្រង់ដីធ្លីមានការលំបាកយ៉ាងខ្លាំង។ ការគ្រប់គ្រងដីធ្លីនៅកម្ពុជា ត្រូវបានផ្លាស់ប្តូរដោយទំនោរទៅរកការធ្វើកម្មសិទ្ធិដីធ្លី ជាទ្រព្យសម្បត្តិឯកជន លើកលែងតែក្នុងសម័យកាលអាណានិគម។ កម្មសិទ្ធិដី និងផែនទីសុរិយោដី ត្រូវបានបំផ្លាញចោលនៅក្នុងទសវត្សទី៧០។ ដីត្រូវបានបែងចែកនៅដើមទសវត្សទី៨០ ការបែងចែកនេះបានផ្តល់សិទ្ធិ មានករិតក្នុងការប្រើប្រាស់ដី ប៉ុន្តែមិនមានកម្មសិទ្ធិទេ។ សិទ្ធិរបស់បុគ្គលក្នុងការទទួលបានកម្មសិទ្ធិដី ត្រូវបានបង្កើតឡើងវិញនៅឆ្នាំ១៩៨៩ ហើយច្បាប់ភូមិបាលត្រូវបានបង្កើតឡើង និងអនុវត្តនៅឆ្នាំ១៩៩២។ ប្រពន្ធ័ពីរត្រូវបានបង្កើតឡើង គឺការទទួលបានកម្មសិទ្ធិដីធ្លីតាមទំនៀមទំលាប់ និងតាមប្រពន្ធ័ផ្លូវការដែលប្រជាជនត្រូវចំណាយប្រាក់ជាច្រើន ដែលភាគច្រើនជាការចំណាយក្រៅផ្លូវការ ដើម្បីទទួលបានកម្មសិទ្ធិដីធ្លីជាផ្លូវការ។ ក្រឹត្យក្រមមិនច្បាស់លាស់ និងការអនុត្តន៏ច្រើនបែបបទក្នុងការចុះបញ្ជីដីធ្លីបណ្តាលឱ្យមានអំពើពុករលួយ យោងតាមការវាយតំលៃផ្នែកសង្គមកិច្ច ដែលធ្វើឡើងក្នុងឆ្នាំ១៩៩៩ ក្នុងការរៀបចំគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) ដោយមានការឧបត្ថម្ភពីធនាគារពិភពលោក សហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) និងរដ្ឋាភិបាលហ្វាំងឡង់។ ប្រជាជនដែលទទួលបានឱកាសតិចតួចបំផុតក្នុងការទទួលបានកម្មសិទ្ធិដីធ្លី គឺជាប្រជាជនក្រីក្រ និងគ្មានលទ្ធភាពក្នុងការទាមទារសិទ្ធិរបស់ខ្លួន ដូចជានារីជាដើម។ ការវាយតំលៃផ្នែកសង្គមកិច្ចរបស់គំរោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី បានរកឃើញថា នារី ជាពិសេស នារីជាមេគ្រួសារងាយរងគ្រោះ ដោយសារមិនមានគេយកចិត្តទុកដាក់ទៅលើសិទ្ធិរបស់គាត់ ជាពិសេស ដោយសារការខ្វះខាតការយល់ដឹងអំពីសិទ្ធិដីធ្លី និងនីតិវិធីចុះឈ្មោះកម្មសិទ្ធិដីធ្លី (ធនាគារពិភពលោក ឆ្នាំ២០០២h)។

ការធ្វើសេរីភាវូបនីយកម្មក្នុងឆ្នាំ១៩៨៩ និងភាពច្របូកច្របល់ដែលជាលទ្ធផលនៃការផ្តល់កម្មសិទ្ធិដី ដោយសារដំណើរការចុះឈ្មោះមិនច្បាស់លាស់ ធ្វើឱ្យផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិនារីលើកម្មសិទ្ធិដីធ្លី ជាពិសេសនារីជាមេគ្រួសារ (Kusakabe et al. ឆ្នាំ១៩៩៥)។ កំណែទម្រង់ដីធ្លី ត្រូវបានគេរិះគន់ថា មានផលប៉ះពាល់ដោយអចេតនាលើគ្រួសារដែលនារីជាមេគ្រួសារ (ដែលមានសមាជិកពេញកំលាំងពលកម្មចំនួនតិច) ពីព្រោះថាការបែងចែកដីសំរាប់ធ្វើកសិកម្មអាស្រ័យលើទំហំនៃគ្រួសារ។ ហេតុដូច្នេះហើយធ្វើឱ្យគ្រួសារដែលមាននារីជាមេគ្រួសារ ទទួលបានដីស្រែដែលមានទំហំតូចពេកមិនអាចផលិតស្បៀងឱ្យបានគ្រប់គ្រាន់ បន្ទាប់មកជំពាក់បំណុលគេ លក់ដី និងអស់ដីស្រែ។ "ស្ត្រីមេម៉ាយដោយសារសង្គ្រាម" មានដីតិចតួចជាងប្រជាជនទូទៅ: ក្នុងចំណោមស្ត្រីមេម៉ាយដែលមានដីចំនួន ៨៤ ភាគរយ មានដីតិចជាង០,៥ហិកតា។ ស្ត្រីមេម៉ាយដោយសារសង្គ្រាមជិតពាក់កណ្តាល ពុំមានដី (Harding ឆ្នាំ២០០០)។ តាមការសិក្សារបស់ Oxfam អង់គ្លេសបានរកឃើញថា គ្រួសារដែលគ្មានដីភាគច្រើន គឺជាគ្រួសារដែលមាននារីជាមេគ្រួសារ។ តាមរយៈគំរូនៃការអង្កេតគ្រួសារមួយក្នុងចំណោមគ្រួសារចំនួនប្រាំបី ពុំមានដី ប៉ុន្តែតួលេខរបស់គ្រួសារដែលមាននារីជាមេគ្រួសារគឺ ២១ ភាគរយ ឬគ្រួសារមួយក្នុងចំណោមគ្រួសារចំនួនប្រាំ។ ការអង្កេតរបស់កម្មវិធីស្បៀង

អាហារពិភពលោក ធ្វើឡើងក្នុងឆ្នាំ១៩៩៧ បង្ហាញឱ្យឃើញថា អត្រាគ្រួសារដែលមាននារីជាមេគ្រួសារ ចំនួនពីរដងច្រើនជាងគ្រួសារដែលមានបុរសជាមេគ្រួសារ បានលក់ដីរបស់ខ្លួន។ ភាគច្រើនគឺជា "ការលក់ដោយបង្ខំ" ព្រោះគ្រួសារត្រូវបង្ខំចិត្តលក់ដីរបស់ខ្លួន ជំងឺ គឺជាមូលហេតុចំបងនៃការលក់ដី (Biddulph, ឆ្នាំ២០០០) ។

នារីជាមេគ្រួសារ ប្រឈមមុខនឹងការលំបាកជាច្រើនពាក់ពន្ធ័នឹងបញ្ហាដីធ្លី ។ សិទ្ធិនារីក្នុងការកាន់កាប់ដី នៅទន់ខ្សោយ ដោយសារនារីមានឋានៈទាបនៅក្នុងគ្រួសារ ហើយបញ្ជីសិទ្ធិកាន់កាប់ដីមានតែឈ្មោះរបស់បុរសជាមេគ្រួសារ ។ ក្នុងករណីលែងលះ ប្តីស្លាប់ ឬគ្រួសារបែកបាក់ នារីអាចនឹងបាត់បង់សិទ្ធិកាន់កាប់ដីរបស់ខ្លួន ដែលនេះ ជាទូទៅបណ្តាលឱ្យនារី និងកុមារធ្លាក់ក្នុងភាពក្រីក្រ ។

ចាប់តាំងពីឆ្នាំ១៩៩៣ មក កម្មសិទ្ធិដីធ្លីចំនួន ៦២០.០០០ ត្រូវបានចេញឱ្យប្រើប្រាស់ ប៉ុន្តែភាគច្រើនមានតែឈ្មោះរបស់បុរសជាមេគ្រួសារ ។ ច្បាប់ភូមិបាលថ្មី ត្រូវបានអនុម័តក្នុងឆ្នាំ២០០១ រួមមានវិធានការមួយដើម្បីធានាឱ្យបានថាមានទាំងឈ្មោះនារី និងបុរសនៅក្នុងកម្មសិទ្ធិដី ។ ចាប់តាំងពីពេលនោះមក កម្មសិទ្ធិដីថ្មីចំនួន ៨០.០០០ ត្រូវបានចេញឱ្យប្រើប្រាស់ទៅតាមនីតិវិធីថ្មី ។ តាមការអង្កេតនាពេលថ្មីៗនេះ បង្ហាញឱ្យឃើញថា ក្នុងចំណោមកម្មសិទ្ធិចំនួន ២០.០០០ កម្មសិទ្ធិថ្មីមានប្រមាណ ៧៨ភាគរយ ដែលមានឈ្មោះទាំងនារី និងបុរសនៅក្នុងគ្រួសារ (LMAP ឆ្នាំ២០០៣) ។

ទោះបីជាការដាក់ឈ្មោះទាំងពីរនាក់ នារី និងបុរសនៅក្នុងកម្មសិទ្ធិដីធ្លីនេះបង្ហាញឱ្យឃើញថា ប្រពន្ធមានសិទ្ធិស្របច្បាប់លើដីទាំងនោះ ប៉ុន្តែទំនៀមទំលាប់នៃការអនុវត្តន៍ និងការពង្រឹងច្បាប់ មិនបានទទួលស្គាល់សិទ្ធិទាំងនេះឱ្យបានពេញលេញឡើយ ។ ទោះបីជានារីមានសិទ្ធិលើដីធ្លី ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែង សិទ្ធិទាំងនេះ អាចត្រូវបានគេមិនទទួលស្គាល់ដោយសារកត្តាសង្គម និងវប្បធម៌ដែលមានភាពលំអៀងយេនឌ័រ ។ តាមការសិក្សាមួយ បានឱ្យដឹងថា នារី ជាញឹកញាប់ចាំបាច់ត្រូវសុំការអនុញ្ញាតពីប្តី ក្នុងការបញ្ចូលឈ្មោះរបស់ខ្លួនក្នុងកម្មសិទ្ធិដី ។ ជាគោលការណ៍ បើសិនជានារី និងបុរសបានរួមគ្នាចុះបញ្ជីកម្មសិទ្ធិដីធ្លី ភាគីទាំងពីរ ត្រូវចុះហត្ថលេខានៅពេលធ្វើការផ្ទេរកម្មសិទ្ធិដីនោះ ប៉ុន្តែការអនុវត្តន៍ជាក់ស្តែង គោលការណ៍នេះនៅទន់ខ្សោយ ហើយនារីងាយរងគ្រោះក្នុងការបាត់បង់សិទ្ធិក្នុងការធ្វើសេចក្តីសំរេច និងទុកឱ្យប្តីធ្វើសេចក្តីសំរេច (IFAD, ឆ្នាំ២០០៣) ។ ជាធម្មតា នៅក្នុងគ្រួសារ បុរសមានអំណាចក្នុងការសំរេចចិត្តច្រើនជាងនារី ដែលកត្តានេះធ្វើឱ្យបុរសមានភាពងាយស្រួលក្នុងការលក់ដូរដី ដោយគ្មានការព្រមព្រៀងពីប្រពន្ធ ។ ក្នុងករណីនេះ នារីនឹងប្រឈមមុខនឹងការបាត់បង់ឱកាសក្នុងការតវ៉ាចំពោះការសំរេចចិត្តរបស់ភាគីតែម្ខាងដែលបានលក់ដី ធ្វើឱ្យនារីមិនត្រឹមតែបាត់បង់ធនធាន ដើម្បីប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួនតែប៉ុណ្ណោះទេ ថែមទាំងមិនបានទទួលនូវប្រាក់កំរៃពីការលក់ដីនេះទៀតផង ។ ដោយសារអក្ខរភាពរបស់នារីនៅមានកំរិតទាប នារីបាត់បង់ឱកាសក្នុងការទទួលបានពតិមានគ្រប់គ្រាន់អំពីបញ្ហាដីធ្លី ការលក់ដូរដី និងសិទ្ធិ ។

នៅក្នុងរចនាសម្ពន្ធ័ស្ថាប័នពាក់ពន្ធ័ និងបញ្ហាដីធ្លី ពុំទាន់មានតំណាងនារីដើម្បីបំរើផលប្រយោជន៏របស់នារីនៅឡើយទេ ដូចជា ក្រុមប្រឹក្សាគោលនយោបាយភូមិបាល គណៈកម្មាធិការសុរិយោដី ដើម្បីដំណោះស្រាយបញ្ហាវិវាទដីធ្លី និងប្រធានឃុំ ។ ពេលថ្មីៗនេះ គំរោង LMAP បានផ្តល់អនុសាសន៏ថា ដើម្បីជំរុញការចូលរួមរបស់នារីនៅក្នុងគណៈកម្មាធិការខេត្ត និងសុរិយោដីស្រុក និងលេខាធិការដ្ឋានសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរតែផ្តល់អាទិភាពគាំទ្រយ៉ាងហោចណាស់មាននារី ចំនួន ៣០ភាគរយ នៅក្នុងជួរគណៈកម្មាធិការទាំងនេះ ។

សម្បទានដីរដ្ឋ កំពុងត្រូវបានគេយកទៅពិភាក្សានៅថ្នាក់ជាតិ ដើម្បីដោះស្រាយបញ្ហាគ្មានដី និងបាត់បង់ដី។ នៅកម្ពុជា មានដីគ្រប់គ្រាន់សំរាប់បំពេញសេចក្តីត្រូវការរបស់គ្រួសារ ដែលបាត់បង់ដីធ្លីនាពេលបច្ចុប្បន្ន (So et al, ឆ្នាំ២០០២)។ ប៉ុន្តែមិនអាចធ្វើការសន្មត់ថា នារីនឹងទទួលបានផលប្រយោជន៍ស្មើភាពនៅក្នុងកំណែទម្រង់នេះឡើយ បើសិនជាគ្មានវិធានការដែលមានគោលដៅច្បាស់លាស់ ដើម្បីធានាឱ្យបានថា កំណែទម្រង់នេះមានការពិចារណាគិតគូរដល់ផលប្រយោជន៍របស់នារី។ ការងារនេះ ទាមទារឱ្យមានការសិក្សាច្បាស់លាស់ថា ដីទំនេរសំរាប់បែងចែកដល់គ្រួសារដែលគ្មានដីនោះ អាចឱ្យគ្រួសារទាំងនេះប្រកបរបរកសិកម្មដោយនិរន្តរភាព ហើយតើគ្រួសារក្រីក្រទាំងនោះនឹងជ្រើសរើសរស់នៅក្នុងដីទំនេរ ដែលបំរុងនឹងចែកចាយដល់គាត់ដែរឬទេ។

ដីគឺជាធនធានសំខាន់មួយ ប៉ុន្តែការកាត់បន្ថយភាពក្រីក្រនៅជនបទ ក៏អាស្រ័យលើដើមទុន និងសេវាផ្សេងៗទៀត ដើម្បីបង្កើនផលិតភាពរបស់ដីក្នុងកំរិតអតិបរមា និងផ្តល់ប្រភពរកប្រាក់ចំណូលដល់ប្រជាជន ដែលគ្មានដីដែលកំពុងតែកើនឡើង។

## ៣.១.៦ ឱកាសទទួលបានសេវាហិរញ្ញវត្ថុ និងសេវាមិនមែនហិរញ្ញវត្ថុ មានកំរិតតិចតួចបំផុត

កម្មវិធីឥណទាន មានដំណើរការល្អនៅកម្ពុជា ប៉ុន្តែមិនទាន់គ្របដណ្តប់បានទូលំទូលាយនៅឡើយ។ ស្ថាប័នផ្លូវការមិនអាចផ្តល់សេវាដល់ប្រជាជនក្រីក្របាននៅឡើយ។ អ្នកផ្តល់សេវាឥណទានខ្នាតតូចពាក់កណ្តាលផ្លូវការជាក់ស្តែង គឺជាអ្នកផ្តល់សេវាហិរញ្ញវត្ថុ (ភាគច្រើនជាឥណទាន) នៅក្នុងតំបន់ជនបទ។ ក្របខ័ណ្ឌច្បាប់ថ្មីមួយ ត្រូវបានបង្កើតឡើងសំរាប់ស្ថាប័នហិរញ្ញវត្ថុខ្នាតតូចនៅកម្ពុជា ប៉ុន្តែឱកាសរបស់ប្រជាជនក្រីក្រនៅជនបទ ក្នុងការទទួលបានសេវាហិរញ្ញវត្ថុនៅតែមានកំរិតតិចតួចបំផុត។ បច្ចុប្បន្នភ្នាក់ងារផ្តល់សេវាចំនួនប្រាំ ក្លាយទៅជាស្ថាប័នហិរញ្ញវត្ថុជាផ្លូវការ និងផ្តល់សេវាប្រហែល ៨៥ភាគរយ នៃសេវាឥណទានសរុប។ មានភ្នាក់ងារផ្តល់សេវាចំនួន ៤៨ ផ្សេងទៀត ជាអ្នកផ្តល់សេវា ដោយបានចុះឈ្មោះត្រឹមត្រូវ។ ភ្នាក់ងារផ្តល់សេវាទាំងនេះ គ្របដណ្តប់ប្រហែល ២០ភាគរយ នៃគ្រួសារសរុប ប៉ុន្តែការគ្របដណ្តប់នេះមិនមានលក្ខណៈស្មើគ្នាឡើយ - ឧទាហរណ៍ ស្រុកខ្លះពុំមានសេវាឥណទានមួយសោះ ចំណែកស្រុកខ្លះមានបីបួន។ តាមរយៈការសិក្សារបស់ CDRI និង Oxfam អង់គ្លេស និងហុងកុង កម្មវិធីឥណទានដែលមិនមានការដាក់គោលដៅត្រឹមត្រូវ ច្រើនតែផ្តល់គ្រោះថ្នាក់ជាងការផ្តល់ផលល្អ ដោយធ្វើឱ្យអ្នកខ្ចីប្រាក់ក្រីក្រ គ្មានលទ្ធភាពអាចគ្រប់គ្រងបំណុលបាន ហើយនាំទៅរកការបាត់បង់ដីធ្លី។ អត្រាការប្រាក់របស់អ្នកផ្តល់សេវាឯកជនមានកំរិតខ្ពស់ ប៉ុន្តែអ្នកខ្ចីប្រាក់ពុំមានជំរើសផ្សេងពីនេះ។

នៅក្នុងកម្មវិធីឥណទានភាគច្រើន តាមការប៉ាន់ប្រមាណ មានសមាជិកចំនួន ៧០-៨៥ភាគរយ ជានារី (Walter, ឆ្នាំ២០០០)។ ដោយសារនារីជាអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារ និងត្រូវបានគេទុកចិត្តផ្តល់សេវាឥណទាន ដូច្នេះធ្វើឱ្យនារីភាគច្រើនជាអ្នកខ្ចីប្រាក់។ តាមការប៉ាន់ប្រមាណ នារីជាសមាជិកដែលមានសមាមាត្រខ្ពស់នៅក្នុងកម្មវិធីឥណទាន ប៉ុន្តែនារីពុំសូវបានចូលរួមចំណែកក្នុងការធ្វើសេចក្តីសំរេច ហើយនារី ទទួលបានតែប្រាក់កម្ចីដែលមានចំនួនតិចតួច (Catalla, ឆ្នាំ២០០១)។

មានកម្មវិធីឥណទានមួយចំនួន ផ្តោតគោលដៅតែលើនារី ដើម្បីផ្តល់អំណាចដល់នារី ក្នុងការធ្វើសេចក្តីសំរេចដោយខ្លួនឯងជាជាងពឹងផ្អែកលើការសំរេចចិត្តរបស់សមាជិកក្នុងគ្រួសារ ។ នៅពេលដែលនារីដែលជាមេគ្រួសារ ត្រូវបានគេបញ្ចូលជាសមាជិកកម្មវិធីឥណទាន នារីទាំងនោះទទួលបានផលប្រយោជន៍ទាំងផ្នែកឥណទាន និងសង្គម ។ ក្នុងកម្មវិធីដែលមានគោលដៅលើបុរស និងនារី ក្នុងការទទួលបានប្រាក់កំចី ដោយផ្អែកលើភាពទុកចិត្តលើខ្លួនឯងរបស់បុគ្គលនីមួយៗ និងជំនាញក្នុងការចរចារ នារីជាសមាជិកទទួលបានតែប្រាក់កម្ចីដែលមានចំនួនតិចតួច និងមិនទៀងទាត់ដូចបុរស ។ ម្យ៉ាងទៀតជាទំនៀមទំលាប់ គ្រួសារតែងតែឱ្យបុរសទៅចូលរួមក្នុងកិច្ចប្រជុំធ្វើសេចក្តីសំរេចសំខាន់ៗ ដូច្នេះធ្វើឱ្យនារី និងជាពិសេស នារីជាមេគ្រួសារ មានការលំបាកក្នុងការចូលរួម ។ ផលប្រយោជន៍នៃកម្មវិធីឥណទានដែលគ្រប់គ្រងមិនល្អ គឺនៅក្នុងកណ្តាប់ដៃរបស់អ្នកមាន ឬបុរសដែលមានអំណាច ដូច្នេះពេលខ្លះមិនបានរាប់បញ្ចូលនារី និងបុរសក្រីក្រឡើយ (Walter, ឆ្នាំ២០០០) ។

មានសេវាផ្សេងៗទៀតដែលមានសារៈសំខាន់ (ស្មើ ឬលើសពីសេវាឥណទាន) ចំពោះនារីក្រីក្រ ដូចជា កម្មវិធីសន្សំប្រាក់ដែលអាចឱ្យនារីមានលទ្ធភាពគ្រប់គ្រងចំណូលផ្ទាល់ខ្លួន និងក្នុងគ្រួសារដែលជាសំណាញ់សុវត្ថិភាពមួយអាចយកទៅប្រើប្រាស់ ដើម្បីដោះស្រាយក្នុងកាលៈទេសៈមានវិបត្តិ ។ សេវាផ្សេងៗទៀតក្រៅពីហិរញ្ញវត្ថុ មានដូចជា ការបណ្តុះបណ្តាលជំនាញអភិវឌ្ឍន៍សហគ្រាសខ្នាតតូច ក៏មានសារៈសំខាន់ក្នុងការបង្កើន ចំណូលក្រៅពីរបរធ្វើស្រែចំការ និងទីផ្សារ ។ ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម បង្ហាញឱ្យឃើញថា នារីមានចំណាប់អារម្មណ៍លើកម្មវិធីឥណទាន និងសន្សំប្រាក់ និងមានផែនការជាក់លាក់ក្នុងការចំណាយប្រាក់ទាំងនេះ ប៉ុន្តែមានតែមួយភាគបីនៃអ្នកផ្តល់ចម្លើយប៉ុណ្ណោះ ទទួលបានឱកាសទាំងនេះ ( ADB, ឆ្នាំ២០០១) ។

## ៣.១.៧ ផ្លូវ និងគមនាគមន៍ជនបទ ជាអាទិភាពសំរាប់នារី និងបុរស

ផ្លូវ និងគមនាគមន៍ជនបទ ជារួម ត្រូវបានចាត់ទុកថា ជាអាទិភាពសំរាប់បុរស និងនារី (ADB ឆ្នាំ២០០១ ចំរើនស្រ្តី ឆ្នាំ២០០២) ។ ហេដ្ឋារចនាសម្ពន្ធ័មិនទាន់គ្រប់គ្រាន់ ធ្វើឱ្យមានការលំបាកក្នុងការទៅដល់ទីផ្សារ សាលារៀន និងគ្លីនិកសុខភាព និងរកចំណូលបានទាប ម្ហូបអាហារមានតំលៃខ្ពស់ ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រី មានកំរិតទាប និងអត្រាស្លាប់របស់មាតាមានកំរិតខ្ពស់ ។ ហេដ្ឋារចនាសម្ពន្ធ័មិនទាន់គ្រប់គ្រាន់ ធ្វើឱ្យការដឹកជញ្ជូនមានតំលៃខ្ពស់នៅកម្ពុជា ផលិតផលខ្លះមិនអាចដឹកជញ្ជូនបាន ពុំមានទីផ្សារ និងមានតំលៃទាប ធ្វើឱ្យអសន្តិសុខស្បៀងកាន់តែធ្ងន់ធ្ងរឡើង ។

ការធ្វើដំណើរ និងការដឹកជញ្ជូន ត្រូវបានបែងចែកស្មើៗគ្នារវាងបុរស និងនារី ប៉ុន្តែក៏មានលក្ខណៈខុសគ្នាដែរដូចជា: នារីធ្វើដំណើរច្រើនជាងបុរស ដឹកជញ្ជូនរបស់ធ្ងន់ និងចំណាយពេលច្រើនក្នុងការដង/រែកទឹក និងទៅផ្សារដោយពុំមានផ្លូវល្អសំរាប់ការធ្វើដំណើរ ។ បុរសមិនសូវធ្វើដំណើរច្រើនដូចនារី ប៉ុន្តែការធ្វើដំណើររបស់បុរសមានរយៈពេលយូរ និងចំណាយពេលវេលាច្រើន ដូចជា ទៅនេសាទត្រី ច្រូតស្រូវ និងការងារផ្សេងៗទៀត ក្រៅពីផ្នែកកសិកម្ម (ក្រសួងអភិវឌ្ឍន៍ជនបទ/ILO, ឆ្នាំ២០០០) ។ ដោយសារបញ្ហាសុវត្ថិភាពក្នុងការធ្វើដំណើរ និងតួនាទីទទួលខុសត្រូវនៅក្នុងគ្រួសារ ការធ្វើដំណើរចំងាយជិត គឺជាកត្តាសំខាន់ដែលនារីអាចមានឱកាសទទួលបានទីផ្សារ និងសេវានានា ។

### ៣.១.៨ នារីផ្តល់អាទិភាពលើការផ្គត់ផ្គង់ទឹកស្អាត

នៅកម្ពុជា មានតែប្រជាជន ២៩ភាគរយ ប៉ុណ្ណោះ ទទួលបានទឹកស្អាតសំរាប់ប្រើប្រាស់ – គ្រួសារនៅទីក្រុង ឬទីប្រជុំជនចំនួន ៥៣ភាគរយ និងប្រជាជននៅជនបទចំនួន ២៥ភាគរយ (ធនាគារពិភពលោក ឆ្នាំ២០០៣) ។ តាមការប៉ាន់ប្រមាណបង្ហាញឱ្យឃើញថា ប្រជាជនកម្ពុជា ចំណាយរយៈពេលមួយ ឬពីរម៉ោងក្នុងមួយថ្ងៃ ដើម្បីទៅរែក/ដឹកទឹក ហើយភាគច្រើន នារីជាអ្នកធ្វើការងារនេះ (ការពិគ្រោះយោបល់របស់ក្រសួងអភិវឌ្ឍន៍ជនបទ) ។ នារីទាំងអស់ដែលបានចូលរួមក្នុងការវាយតំលៃភាពក្រីក្រដោយមានការចូលរួម បាននិយាយថា នៅក្នុងរដូវប្រាំង ក្នុងមួយថ្ងៃៗ គាត់ត្រូវចំណាយពេលជាច្រើន ក្នុងការទៅដងទឹកសំរាប់ដាំស្ល បោកខោអាវ និងសំរាប់ងូត គឺជិតស្មើពីរដងនៃពេលវេលាដែលត្រូវចំណាយក្នុងរដូវវស្សា (ADB, ឆ្នាំ២០០១) ។ ការវាយតំលៃភាពក្រីក្រ ក៏បានបង្ហាញឱ្យឃើញនូវភាពខុសគ្នានៃយេនឌ័រក្នុងការផ្តល់អាទិភាពលើសេវាផ្គត់ផ្គង់ទឹកនៅកំរិតសហគមន៍ ។ នារី ចង់ឱ្យមានភាពងាយស្រួលក្នុងការទទួលបានទឹកស្អាតសំរាប់ផឹក ដាំស្ល និងងូត នារីមិនចង់ចំណាយពេលវេលាច្រើនទៅដងទឹកសំរាប់តម្រូវការប្រចាំថ្ងៃឡើយ ។ ពេលវេលាចំណាយលើការដងទឹក មិនមែនជាបញ្ហាកង្វល់ចំបងចំពោះបុរសឡើយ ។ បុរសបានស្នើសុំឱ្យបង្កើតប្រពន្ធ័ធារាសាស្ត្រសំរាប់ស្រោចស្រពស្រូវ និងដំណាំ ប៉ុន្តែពុំមែនសំរាប់កសិកម្មជាលក្ខណៈគ្រួសារ ដែលនឹងផ្តល់ផលប្រយោជន៏ដល់នារីឡើយ ។ ក្រសួងអភិវឌ្ឍន៍ជនបទ កំពុងអនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកស្អាត ដែលធានាឱ្យបានថា មាននារីបីរូប និងបុរសពីររូប ជាសមាជិកគណៈកម្មការទឹកស្អាតក្នុងភូមិ និងធានាឱ្យមានប្រភពទឹកស្អាតក្នុងរវាងចម្ងាយពី ១០០ ទៅ ១៥០ម៉ែត្រ ។

ចម្ងាយក្នុងការទៅរែក/ដឹកទឹក និងតំលៃរបស់ទឹក សុទ្ធតែប៉ះពាល់ដល់ឱកាសក្នុងការទទួលបានទឹកស្អាតសំរាប់ប្រើប្រាស់ ។ បញ្ហាកង្វល់ដែលបានលើកឡើងគឺថា បើសិនជាអ្នកប្រើប្រាស់ទឹក ត្រូវចំណាយប្រាក់ច្រើនទៅលើសេវាផ្គត់ផ្គង់ទឹកឯកជន គ្រួសារក្រីក្រដែលគ្មានចំណូល នឹងមិនប្រើប្រាស់សេវានោះឡើយ ។ ក្នុងករណីនេះ បន្ទុករបស់នារីក្នុងការទៅដងទឹក មិនអាចកាត់បន្ថយបានឡើយ ។ ដូច្នេះគួរតែអនុវត្តកម្មវិធីកែលំអថ្មី ផ្តល់ទឹក ដោយមិនគិតថ្លៃដល់ប្រជាជនក្រីក្រ និងរកប្រាក់ចំណូល ពីការតម្លើងថ្លៃទឹក ចំពោះសហគ្រាសឯកជន ។

មានតែប្រជាជន ១៨ ភាគរយប៉ុណ្ណោះ មានបង្គន់អនាម័យប្រើប្រាស់ ប្រជាជននៅទីក្រុង ឬទីប្រជុំជនចំនួន ៥៨ ភាគរយ និងតំបន់ជនបទ ១០ ភាគរយ ។ ការសិក្សានាពេលថ្មីៗនេះ របស់កម្មវិធីស្បៀងអាហារពិភពលោក បានបង្ហាញឱ្យឃើញនូវបញ្ហាដែលពាក់ពន្ធ័គ្នា រវាងសាលាដែលគ្មានបង្គន់ដាច់ដោយឡែកសំរាប់ក្មេងស្រី និងវត្តមានសិក្សារបស់ក្មេងស្រី (WFP, ឆ្នាំ២០០១) (សូមមើលជំពូក៤) ។ ឱកាសទទួលបានទឹកស្អាត និងបង្គន់អនាម័យប្រើប្រាស់ ប៉ះពាល់ ជាច្រើនដល់បញ្ហាសុខភាពរបស់នារី កុមារ និងគ្រួសាររបស់គេ ។

## ៣.១.៩ នារីមិនមានតំណាងរបស់ខ្លួននៅក្នុងតួនាទីធ្វើសេចក្ដីសំរេច ក្នុងវិស័យកសិកម្ម និងជួរមន្ត្រីរាជការស៊ីវិល

ភាគច្រើននៃកសិករ គឺជានារី ប៉ុន្តែនារីជាកសិករមួយភាគតូចប៉ុណ្ណោះ ជាអ្នកទទួលបានផលពីសេវាកសិកម្ម និងជាអ្នកផ្ដល់សេវាកសិកម្ម ។ ការចូលរួមចំណែកយ៉ាងសំខាន់របស់នារីនៅក្នុងវិស័យកសិកម្ម និងកិច្ចអភិវឌ្ឍន៍ជនបទ មានចំនួនខុសគ្នានឹងការចូលរួមចំណែករបស់នារីក្នុងការធ្វើសេចក្ដីសំរេច និងជួរមន្ត្រីរាជការស៊ីវិល ។ នារីមានចំនួនជាង៥០ភាគរយ នៃអ្នកប្រកបរបរកសិកម្មលក្ខណៈគ្រួសារ និងកសិកម្មសំរាប់ទីផ្សារសរុប ប៉ុន្តែនារីជាមន្ត្រីរាជការនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទមានតែ ២០ភាគរយប៉ុណ្ណោះ ហើយភាគច្រើនស្ថិតក្នុងតួនាទីផ្នែករដ្ឋបាល ។ មាននារី ចំនួនតិចតួចប៉ុណ្ណោះ ស្ថិតក្នុងតួនាទីជាអ្នកធ្វើសេចក្ដីសំរេច ឬទំនាក់ទំនងដោយផ្ទាល់ជាមួយកសិករ ។ ដូចដែលបានរៀបរាប់ខាងលើ ដែលតាមការប៉ាន់ប្រមាណ គឺមានតែ ៥ ទៅ ១០ភាគរយនៃភ្នាក់ងារផ្សព្វផ្សាយកសិកម្មសរុបជានារី ( ធនាគារពិភពលោក ឆ្នាំ២០០២) ។ ក្នុងឆ្នាំសិក្សា២០០២-២០០៣ និស្សិតនារីមានតែ ១៧ភាគរយក្នុងចំណោមនិស្សិត សរុបនៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង បើប្រៀបធៀបទៅនឹងឆ្នាំសិក្សា២០០១-២០០២ បានកើនឡើងចំនួន ៦ភាគរយ ( ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៣) ។ ការកើនឡើងនេះ ដោយសារសាកលវិទ្យាល័យភូមិន្ទ កសិកម្ម បានអនុម័តគោលនយោបាយមួយ ដើម្បីជំរុញលើកទឹកចិត្តឱ្យមានយ៉ាងហោចណាស់ និស្សិតនារីចំនួន ៣០ភាគរយ ( គំរោង LMAP, ឆ្នាំ២០០៣) ។

តាមរយៈការអង្កេតនាពេលថ្មីៗនេះ បង្ហាញឱ្យដឹងថា មន្ត្រីរាជការជានារីនៅក្នុងក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទមួយចំនួនធំ មិនបានទទួលឱកាសបណ្ដុះបណ្ដាលនៅឡើយ ។ ការអង្កេតបានបង្ហាញឱ្យឃើញថា មន្ត្រីរាជការនារី នៅថ្នាក់ខេត្តមានចំនួនតែ ២ភាគរយប៉ុណ្ណោះ មានបរិញ្ញាប័ត្រ និងចំនួន ១៩ភាគរយមិនបានបញ្ចប់បឋមសិក្សា ។ ក្រោយពេលដែលមន្ត្រីរាជការនារីទាំងនេះ ទទួលបានការបណ្ដុះបណ្ដាល មានតែ ១៩ភាគរយប៉ុណ្ណោះ បានទទួលតួនាទីខ្ពស់ ទទួលបានការគោរព និងការទទួលខុសត្រូវផ្នែកជំនាញវិជ្ជាជីវៈបន្ថែម ( ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ឆ្នាំ២០០២a) ។

**ក្រាហ្វិក ៣.១: នារីក្នុងវិស័យកសិកម្ម: ជាកសិករមានចំនួនច្រើន មន្ត្រីការិយាល័យមានចំនួនតិច**




## ៣.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

វិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ មានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយភាពក្រីក្រ និងការរីកចំរើនផ្នែកសេដ្ឋកិច្ច ប៉ុន្តែវិភាជថវិកាជាតិដល់វិស័យនេះ មានចំនួនតិចតួច។ កសិកម្ម និងការអភិវឌ្ឍន៍ជនបទគឺជាអាទិភាពពីរក្នុងចំណោមអាទិភាពចំនួនបួន នៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច លើកទីពីរ ប៉ុន្តែ នៅក្នុងចំណែកនៃការចំណាយសរុបនាពេលថ្មីៗនេះ សំរាប់ឆ្នាំ២០០៣ កសិកម្មមាន ២,៣ភាគរយ និងអភិវឌ្ឍន៍ជនបទមាន ១,១ភាគរយ បើប្រៀបធៀបទៅនឹងការចំណាយលើការការពារជាតិ និងសន្តិសុខមានចំនួន ២២ភាគរយ (Beresford et al, ឆ្នាំ២០០៣)។ វិភាជថវិកាជាតិសំរាប់វិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទក្នុងឆ្នាំ២០០២ មានចំនួន ៤ភាគរយ អប់រំ ១៨ភាគរយ និងសុខាភិបាល ១១ភាគរយ (យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ទំព័រ១៦៤)។ ការវិភាជជំនួយអភិវឌ្ឍន៍បរទេសក្នុងរយៈពេលដប់ឆ្នាំកន្លងមកមានដូចជា: ៩.៥ភាគរយ សំរាប់អប់រំ ១៤ភាគរយ សំរាប់សុខាភិបាល ៧.៥ភាគរយ សំរាប់កសិកម្ម និង ១៣ភាគរយ សំរាប់ការអភិវឌ្ឍន៍ជនបទ (CDC, ឆ្នាំ២០០២)។

ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ គឺជាក្រសួងដែលធ្វើការងារដោយផ្ទាល់ក្នុងការអភិវឌ្ឍន៍កសិកម្ម និងសេដ្ឋកិច្ចជនបទ។ នៅមានក្រសួងមួយចំនួនទៀត ដើរតួយ៉ាងសំខាន់ក្នុងការងារនេះដែរ ដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧត្តុនិយម ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងពាណិជ្ជកម្ម ដើរតួយ៉ាងសំខាន់ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មជួយជនក្រីក្រ ដែលផ្តោតការយកចិត្តទុកដាក់លើកសិពាណិជ្ជកម្ម និងការកែច្នៃកសិផល ជាវិស័យសំរាប់កំណើនសេដ្ឋកិច្ចប្រកបដោយសក្តានុពលភាព។ ស្ថាប័ន និងយន្តការដែលគាំទ្រវិស័យកសិកម្ម ដូចជា កម្មវិធីផ្សព្វផ្សាយ ប្រឈមមុខយ៉ាងធ្ងន់ធ្ងរនឹងបញ្ហាហិរញ្ញវត្ថុ រួមមាន ប្រាក់បៀវត្សតិចតួចសំរាប់បុគ្គលិក និងយន្តការគណនេយ្យភាពនៅទន់ខ្សោយ (គ្រប់នាយកដ្ឋានទាំងអស់នៃស្ថាប័នរដ្ឋមានស្ថានភាពប្រហាក់ប្រហែលគ្នា)។ ជាលទ្ធផលធ្វើឱ្យស្ថាប័នទាំងនេះ ខ្វះខាតបុគ្គលិកដែលមាន

ជំនាញ និងអត្រាអវត្តមានរបស់បុគ្គលិកមានកំរិតខ្ពស់ ជាពិសេស នៅតាមជនបទ ជាកន្លែងដែលត្រូវការបុគ្គលិកមកបំរើការងារបំផុត ។ ការអនុវត្តន៍សកម្មភាពនៅមានកំរិត អាស្រ័យដោយមានការគាំទ្រពីគំរោងអភិវឌ្ឍន៍ជាក់លាក់មួយចំនួន ។

គំរោងមួយចំនួននៅក្នុងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបញ្ចូលសមាសភាគយេនឌ័រ និងអនុវត្តទទួលបានជោគជ័យ ឧទាហរណ៍ដូចជា:

- *គំរោងសមាហរណកម្មនៃការគ្រប់គ្រងកត្តាចង្រៃស្រូវក្នុងស្រុក:* ៤៤ភាគរយ នៃកសិករសរុបចំនួន ៤.១៣៧ ដែលទទួលបានការបណ្តុះបណ្តាល ជានារី ។ អត្រាជោគជ័យមានកំរិតខ្ពស់នេះ ដោយសារតែពេលវេលានៃការបណ្តុះបណ្តាលមានលក្ខណៈសមស្របសំរាប់នារីជាកសិករ ការជ្រើសរើសគ្រូបណ្តុះបណ្តាលជានារី ការផ្តល់ការបណ្តុះបណ្តាលបង្កើនការយល់ដឹងអំពីយេនឌ័រ ដល់គ្រូបណ្តុះបណ្តាលទាំងអស់ និងបង្កើនការខិតខំប្រឹងប្រែងជំរុញលើកទឹកចិត្តឱ្យនារីបានចូលរួមក្នុងការបណ្តុះបណ្តាល ។

- *គំរោងបង្កើនគុណភាពកសិកម្ម (AQIP - មូលនិធិអូស្ត្រាលី):* គំរោងនេះបានបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រយេនឌ័រ និងការអភិវឌ្ឍន៍ ដែលទាមទារឱ្យមានការគិតគូរដល់បញ្ហាយេនឌ័រនៅក្នុងគ្រប់ដំណាក់កាលនៃគំរោង និងត្រូវយកចិត្តទុកដាក់ដើម្បីធានាថា បុរស និងនារីបានចូលរួមនៅគ្រប់កំរិតនៃការធ្វើផែនការការអនុវត្តន៍ និងវាយតំលៃសកម្មភាពគំរោង ក៏ដូចជាជូរគណៈកម្មការធ្វើសេចក្តីសំរេច សមាគម និងក្រុមការងារ ។

- *គំរោងផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី (CAAEP -មូលនិធិអូស្ត្រាលី):* ភាគរយរបស់អ្នកផ្សព្វផ្សាយជានារីបានកើនឡើងដល់ ១៨ ភាគរយ នៅក្នុងស្រុកគោលដៅ និងសកម្មភាពពិសេសផ្សេងៗទៀត ត្រូវបានអនុវត្ត ដើម្បីជួយសំរួលដល់នារីជាកសិករដែលមានកំរិតអក្ខរកម្មទាប ។ ១៥ភាគរយ នៃកសិករសរុបដែលទទួលបានសេវាផ្សព្វផ្សាយ ពីភ្នាក់ងារផ្សព្វផ្សាយ គឺជានារី ។

- *គំរោងថ្លៃប្រឹខិតផលិតផលកសិកម្ម (APIP - ធនាគារពិភពលោក):* ប្រហែល ៤១ភាគរយនៃអ្នកចូលរួមក្នុងកម្មវិធីពិសោធន៍ក្នុង និងក្រៅស្រែដល់កសិករ ការបណ្តុះបណ្តាលកសិករ និងការបង្ហាញជានារី ។ ៩០ភាគរយ នៃបុគ្គលិកនារីទាំងអស់ ទទួលបានការបណ្តុះបណ្តាល ។

- *គំរោងស្រោចស្រពអាហារូបត្ថម្ភ និងសុខភាព (WIN_FAO):* បានបណ្តុះបណ្តាលកសិករចំនួន ២៣៩នាក់លើជំនាញផលិតកម្មគ្រួសារ (សួនបន្លែគ្រួសារ ដំណាំសំរាប់លក់ដូរ ចិញ្ចឹមសត្វ និងការគ្រប់គ្រងទឹក) ក្នុងចំណោមកសិករទាំងអស់ កសិករនារីមានចំនួន ១៨៧នាក់ (៧៨ភាគរយ) ។ កសិករចំនួន១៨៨ (នារី ៨០ភាគរយ) ទទួលបានការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសត្វល្អិត ក្នុងការដាំដុះបន្លែ និងកសិករចំនួន ១៥០នាក់ (នារី៥៩ភាគរយ) អំពីការគ្រប់គ្រងសត្វល្អិតក្នុងការប្រមូលផលស្រូវ ។ គំរោងនេះ ក៏បានសំរបសំរួលក្នុងការបង្កើតក្រុមកសិករចំនួន ១០ក្រុម ដែលមាននារីជាអ្នកដឹកនាំ ។ សហគមន៍កសិករ អ្នកប្រើប្រាស់ទឹកចំនួន១៥ (៥សហគមន៍ ដឹកនាំដោយនារី) ។ ក្រុមកសិករអ្នកប្រើប្រាស់ទឹកចំនួន១៦ (ក្រុមចំនួន ១៥ដឹកនាំដោយនារី) ។ អ្នកចូលរួមក្នុងគំរោងនៅគ្រប់កំរិត បានចូលរួមក្នុងការបណ្តុះបណ្តាលអំពីយេនឌ័រ ។

បុគ្គលិកដៃគូសហការរបស់គំរោងនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានទទួលការបណ្តុះបណ្តាលអំពីបញ្ហាយេនឌ័រ ដែលស្របទៅនឹងបរិបទនៅក្នុងគំរោងរបស់ខ្លួន (រួមទាំងជនបង្គោលយេនឌ័រពីររូប ដែលទទួលបានការបណ្តុះបណ្តាលពីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន) ។ ការកើនឡើងនូវការយល់ដឹងអំពីយេនឌ័រ និងការប្តេជ្ញាចិត្តក្នុងការបញ្រ្ជាបយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងគោលដៅនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។ លើសពីនេះ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបង្កើតក្រុមការងារយេនឌ័រដែលមានតួនាទីយ៉ាងសំខាន់ ក្នុងការសំរបសំរួលសកម្មភាពពាក់ពន្ធ័នឹងយេនឌ័រនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងមានឱកាសក្នុងការផ្លាស់ប្តូរបទពិសោធន៏រវាងគំរោងនានា និងគាំទ្រដល់ការរៀនសូត្ររបស់ស្ថាប័ន លើបញ្ហាយេនឌ័រ និងកិច្ចអភិវឌ្ឍន៏កសិកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ នាពេលបច្ចុប្បន្ននេះ សមាជិកក្រុមមានការយល់ដឹងអំពីទស្សនៈយេនឌ័រ និងជំនាញ វិភាគយេនឌ័រនៅមានកំរិត ។ ប្រាក់កម្ចីថ្មីរបស់ធនាគារអភិវឌ្ឍន៏អាស៊ី ដល់កម្មវិធីអភិវឌ្ឍន៏វិស័យកសិកម្ម (ASDP) នឹង រួមបញ្ចូលទាំងការគាំទ្រដល់ការកសាងសមត្ថភាពរបស់ក្រុមគោលដៅយេនឌ័រនៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងការបង្កើត និងការអនុវត្តន៏យុទ្ធសាស្ត្របញ្រ្ជាបយេនឌ័រ ។ កម្មវិធីអភិវឌ្ឍន៏វិស័យកសិកម្មក៏នឹងរួមបញ្ចូលទាំងវិធានការ មួយចំនួន ដើម្បីបង្កើនការបញ្រ្ជាបយេនឌ័រដូចជាៈ

- ប្រាក់កម្ចីរយៈពេល៥ឆ្នាំ ទាមទារឱ្យរដ្ឋាភិបាលបង្កើតនូវសេវារកការងារជាផ្លូវការ សំរាប់និស្សិតដែលបញ្ចប់ការសិក្សាផ្នែកកសិកម្មដែលត្រូវបានក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទទទួលយកជាមន្ត្រីរាជការរបស់ក្រសួង ។ សេវាការងារនេះ នឹងចាប់ផ្តើមដំណើរការនៅថ្នាក់ស្រុកជាអប្បបរមាចំនួន៣ឆ្នាំ ។ ប្រាក់កម្ចីនឹងត្រូវប្រើប្រាស់ជាប្រាក់បៀវត្ស ក៏សំរាប់ឧបត្ថម្ភដល់និស្សិតបញ្ចប់ការសិក្សាទាំងនោះចំនួន ៦០នាក់ ដែលក្នុងនោះពាក់កណ្តាលត្រូវតែជានារី ។
- កម្មវិធីអភិវឌ្ឍន៏វិស័យកសិកម្មនឹងផ្តល់ការផ្សព្វផ្សាយ និងឥណទានដល់ក្រុមកសិករក្នុងខេត្តចំនួនបួន ហើយក្រុមកសិករទាំងនោះ ត្រូវមានចំនួនកសិករបុរស និងនារីស្មើគ្នា ។ គំរោងនឹងផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រដល់បុគ្គលិកកម្មវិធី និងកសិករ ។
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន នឹងជាសមាជិកមួយរូបនៅក្នុងលេខាធិការដ្ឋាន ។ មន្ទីរកិច្ចការនារី និងអតីតយុទ្ធជននៅក្នុងខេត្តដែលកម្មវិធីនេះដំណើរការ នឹងជាសមាជិកគណៈកម្មការការងារ ដើម្បីអភិវឌ្ឍន៏សហគ្រាសកសិកម្ម (agro-enterprise) ។ សេវាកម្មសហគ្រាសកសិកម្ម នឹងត្រូវបានបង្កើតឡើង នៅក្នុងមជ្ឈមណ្ឌលស្រ្តីក្នុងកិច្ចអភិវឌ្ឍន៏ ។

ក្រសួងអភិវឌ្ឍន៏ជនបទ ក៏បានដំណើរការងារប្រហាក់ប្រហែលនេះដែរ ដោយក្រសួងបានអនុម័តសកម្មភាពផ្តួចផ្តើមមួយចំនួនដើម្បីធ្វើសមាហរណកម្មបញ្ហាយេនឌ័រទៅក្នុងកម្មវិធីរបស់ក្រសួង ។ ក្រសួងអភិវឌ្ឍន៏ជនបទ មានតួនាទីទទួលខុសត្រូវក្នុងការគាំទ្រដល់គណៈកម្មាធិការអភិវឌ្ឍន៏ភូមិ និងទាមទារឱ្យមាននារីយ៉ាងតិចចំនួន ៤០ភាគរយ ជាសមាជិកនៅក្នុងគណៈកម្មាធិការនេះ (សូមមើលជំពូក៨) ។ ក្រសួង ក៏បានរៀបចំសេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្ត្រទឹកស្អាត និងអនាម័យ ដែលផ្តោតទៅលើសារៈសំខាន់ ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់នារី និងបុរស និងធានាឱ្យមាននារីជាសមាជិកមួយភាគធំ នៅក្នុងជួរគណៈកម្មការទឹកស្អាតក្នុងភូមិ ។

ការសន្និដ្ឋានពាក់ពន្ធ័នឹងបញ្ហាវិនិយោគទុនសាធារណៈ មានកំរិតទាបនៅក្នុងវិស័យកសិកម្ម គឺថាវិស័យឯកជន នឹងវិនិយោគទុនក្នុងការអភិវឌ្ឍន៍កសិកម្ម និងវិស័យជនបទ ក្នុងគោលបំណងបង្កើនការនាំចេញប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏វិស័យឯកជនមិនប្រាកដថា អាច ឬមានឆន្ទៈនឹងផលិតផលិតផលសេដ្ឋកិច្ចសាធារណៈ ដែលចាំបាច់សំរាប់ការអភិវឌ្ឍន៍ជនបទក្នុងទ្រង់ទ្រាយធំ និងប្រកបដោយនិរន្តរភាពនោះទេ។ លើសពីនេះទៀតមិនប្រាកដថា វិស័យឯកជន នឹងផ្តោតសារៈសំខាន់របស់ខ្លួនដោយស្ម័គ្រចិត្ត ទៅលើការអនុវត្តន៍គោលដៅកាត់បន្ថយភាពក្រីក្រ និងសមភាពយេនឌ័រ ការងារទាំងនេះ ដែលពុំអាចឆ្លើយតបទៅនឹងរចនាសម្ពន្ធ័សេដ្ឋកិច្ចទីផ្សារជាស្វ័យប្រវត្តិបានឡើយ។ ដូច្នេះហើយមានការពិភាក្សាអំពីភាពចាំបាច់ដែលរាជរដ្ឋាភិបាល ត្រូវផ្តល់ការលើកទឹកចិត្តដល់អ្នកវិនិយោគឯកជន ដើម្បីធានាថាគោលដៅទាំនេះជាចំណុចសំខាន់របស់យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច ពាក់ព័ន្ធនិងវិស័យឯកជន។

ការកើនឡើងនៃការផ្គត់ផ្គង់សេវាសង្គម អាចនឹងមិនផ្តល់លទ្ធផលតាមការចង់បាន បើសិនជាប្រជាជន មានជីវភាពក្រីក្រគ្មានលទ្ធភាពចាប់យកផលប្រយោជន៍ពីសេវាទាំងនោះ។ ការធ្លាក់ចុះនៃការវិនិយោគទុន ក្នុងការប្រកបរបរចិញ្ចឹមជីវិតនៅជនបទ នឹងប៉ះពាល់ដល់លទ្ធផលនៃការវិនិយោគទុនក្នុងវិស័យសង្គម ដូចជា សុខាភិបាល និងអប់រំជាដើម។ កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនប្រាក់ចំណូលជនបទ នឹងធ្វើឱ្យតម្រូវការសេវាសង្គមកើនឡើង ដែលនេះនឹងផ្តល់លទ្ធផលជាវិជ្ជមានក្នុងផ្នែកសុខភាព និងការអប់រំរបស់ប្រជាជនក្រីក្រ។ ករណីនេះអាចជាការពិត ក្នុងកាលៈទេសៈដែលតំលៃនៃសេវាដែលនារីនិងកុមារីត្រូវការ មានលក្ខណៈអនុគ្រោះដល់នារី និងកុមារី (កំណត់តំលៃ) ប្រៀបធៀបជាមួយនឹងតំលៃសំរាប់បុរស និងកុមារា (Beresford et al, ឆ្នាំ២០០៣)។

## គោលដៅ និងសូចនាករឆ្លើយតបនៅនឹងយេនឌ័រសំរាប់ការអភិវឌ្ឍន៍ជនបទ និង វិស័យកសិកម្ម នៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ យ.ជ.ក.ភ ឆ្នាំ២០០៣-២០០៥

- ជំពូកស្តីពីការអភិវឌ្ឍន៍កសិកម្មនៅក្នុង យ.ជ.ក.ភ បានដាក់ចេញនូវគោលដៅជាក់លាក់មួយចំនួន ពាក់ព័ន្ធនឹងការចូលរួមរបស់នារីនៅក្នុងសេវាកសិកម្ម។ គោលដៅទាំងនោះ រួមមាន ការបញ្ចូលនារីចំនួន ៣០-៥០ភាគរយ ទៅក្នុងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងបសុពេទ្យ និងការបណ្តុះបណ្តាលផ្សេងៗទៀត ក្នុងការប្រើប្រាស់គ្រឿងម៉ាស៊ីនកសិកម្ម ការគ្រប់គ្រងដីមានជីវជាតិ និងការអភិរក្សការប្រើថ្នាំសំលាប់សត្វល្អិតប្រកបដោយសុវត្ថិភាព IPM ផលិតកម្ម និងអាជីវកម្មកសិកម្ម ផលិតកម្មបន្លែ និងការដាំបន្លែជាលក្ខណៈគ្រួសារ ការកែច្នៃ ម្ហូបអាហារពីផលិតផលកសិកម្ម។
- ជំពូកស្តីពីការអភិវឌ្ឍន៍ផ្នែកឯកជន បានសំណូមពរឱ្យការផ្សព្វផ្សាយកសិកម្មដែលផ្តោតគោលដៅលើកសិករជាអ្នកផលិត និងអ្នកលក់ដូរតាមទីផ្សារ គួរតែបញ្ចូលកម្មវិធីផ្សព្វផ្សាយ ពិសេសអំពីយេនឌ័រ ដោយផ្តោតលើនារីដែលជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការងារធ្វើស្រែតាមលក្ខណៈប្រពៃណីនេសាទ (ដូចជាការងារបន្ទាប់ពីនេសាទ និងទីផ្សារ) និងអ្នកលក់ដូរនៅទីផ្សារ។
- ជំពូកស្តីពីវិមជ្ឈការ និងការបង្កើនអភិបាលកិច្ចមូលដ្ឋាន បានសំណូមពរឱ្យមានការបង្កើតសហជីពកសិកម្ម សាកល្បងនៅក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ដើម្បីបង្កើនក្នុងការស្តុកទុកស្បៀងប្រកបដោយស្ថេរភាព និងកំណត់តំលៃសំរាប់ផលិតផល និងសមាជិក ៤៥ភាគរយ ក្នុងគណៈកម្មាធិការគួរតែជានារី។
- ជំពូកស្តីពីការធានាឱ្យបាននូវសន្តិសុខស្បៀងមានគោលដៅជាយុទ្ធសាស្ត្រ ដើម្បីបង្កើនសន្តិសុខស្បៀង ជាពិសេសសំរាប់នារី និងកុមារក្រីក្រ និងចែងថា កម្មវិធីពិសេសស្តីពីសន្តិសុខស្បៀង ត្រូវធានាឱ្យមាននារី ៥០ភាគរយជាអ្នកទទួលផលពីកម្មវិធីទាំងនេះ ផ្តល់ការបណ្តុះ បណ្តាលផ្នែកកសិកម្មដោយអនុវត្តផ្ទាល់ក្នុងស្រែ ដល់កសិករចំនួន ៤០ ភាគរយ និងកសិករ ចំនួន ៥០ភាគរយ នឹងទទួលផលពីកម្មវិធីចិញ្ចឹមសត្វ។
- ជំពូកស្តីពីការអភិវឌ្ឍន៍ផ្លូវ និងគមនាគមន៍ ដាក់គោលដៅឱ្យមាននារីចំនួន ៤៥ភាគរយ ជាអ្នកទទួលបានការងារធ្វើនៅក្នុងគំរោងសាងសង់ផ្លូវ។
- ជំពូកស្តីពី ការបង្កើនឱកាសទទួលបានដីធ្លី ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍន៍ធារាសាស្ត្រ និងទឹកស្អាត និងអនាម័យ មិនបានបញ្ចូលលក្ខណៈពិសេសណាមួយអំពីនារី ឬយេនឌ័រឡើយ។

ជំពូកស្តីពីការបង្កើនសមធមិយេនឌ័រ មានចែងដូចតទៅ: សិទ្ធិស្មើភាពរបស់នារី និងអតីតយុទ្ធជននៅក្នុងការទទួលបានធនធាន និងឱកាសសេដ្ឋកិច្ច ការចូលរួមដោយសមធមិនៅក្នុងដំណើរការ ធ្វើសេចក្តីសំរេចថ្នាក់ជាតិ ការធ្វើផែនការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ។ បង្កើតឱកាសផ្សេងៗក្នុងការប្រកបរបរចិញ្ចឹមជីវិត និងបង្កើនសមត្ថភាពរបស់សហគ្រិន និងកម្មករនារី។ បង្កើនឱកាសរបស់នារីក្នុងការទទួលបានដីធ្លី។ ផ្តល់កម្មវិធីបណ្តុះបណ្តាលដល់សហគ្រាសខ្នាតតូច។ រៀបចំសមាគមកសិករដោយមានសមាជិកភាពនារីចំនួន ៥០ភាគរយ។ យន្តការគាំទ្រសំរាប់នារីក្នុងសហជីពពាណិជ្ជកម្ម និងជំនួញ។

# ជំពូកទី ៤

# គំលាតយេនឌ័រ នៅក្នុងវិស័យអប់រំ


កម្ពុជានាពេលបច្ចុប្បន្ន ........ ៩៣

៤.១ ស្ថានភាព និន្នាការ និង បញ្ហា ........ ៩៣

៤.១.១ គំលាតយេនឌ័រនៅក្នុងវិស័យអប់រំ កើនឡើងទៅតាមកំរិតនៃការសិក្សា ........ ៩៤

៤.១.២ ការចុះឈ្មោះចូលរៀនកំពុងកើនឡើងនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ........ ៩៥

៤.១.៣ ការកើនឡើងយ៉ាងឆាប់រហ័សនៃការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីមកពីឃុំដែលក្រីក្របំផុត ........ ៩៦

៤.១.៤ អត្រាគង់វង្ស និងបញ្ចប់ការសិក្សារបស់ក្មេងស្រីមានកំរិតទាបជាងក្មេងប្រុស ........ ៩៧

៤.១.៥ មានការខ្វះខាតគ្រូបង្រៀនខ្លាំងនៅជនបទ ជាពិសេសគ្រូបង្រៀនជានារី ........ ៩៩

៤.១.៦ គំលាតយេនឌ័រ និងភាពខុសគ្នានៃប្រាក់ចំណូល នៅតែពុំមានការផ្លាស់ប្តូរ នៅក្នុងកំរិតមធ្យមសិក្សាទុតិយភូមិ ........ ១០០

៤.១.៧ អត្រាចុះឈ្មោះចូលរៀនពិតធ្លាក់ចុះនៅកំរិតមធ្យមសិក្សាទុតិយភូមិ ជាពិសេសក្មេងប្រុស ........ ១០១

៤.១.៨ មូលហេតុដែលនាំឱ្យមានគំលាតយេនឌ័រនៅកំរិតមធ្យមសិក្សា ........ ១០២

៤.១.៩ គំលាតយេនឌ័រ មានទំហំកាន់តែធំ នៅកំរិតឧត្តមសិក្សា ........ ១០៥

៤.១.១០ គំលាតយេនឌ័រនៅក្នុងអត្រាអក្ខរកម្ម កើនឡើងទៅតាមអាយុរបស់ប្រជាជន ........ ១០៦

៤.១.១១ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅមានកំរិត ជាពិសេសសំរាប់នារី ........ ១០៧

៤.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ........ ១០៨

# ជំពូកទី ៤ : គំលាតយេនឌ័រ នៅក្នុងវិស័យអប់រំ

## កម្ពុជានាពេលបច្ចុប្បន្ន[១]

| សូចនាករ | តំលៃ |
|---|---|
| ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅថ្នាក់បឋម ឆ្នាំ២០០២ (ភាគរយនៃកុមាររវាងអាយុ៦-១១ឆ្នាំ) | ៨៤ |
| ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅថ្នាក់មធ្យមសិក្សាបឋមភូមិ ឆ្នាំ២០០២ (ភាគរយនៃកុមាររវាងអាយុ១២-១៧ឆ្នាំ) | ១៦ |
| អត្រាអក្ខរជនមនុស្សពេញវ័យនារី ១៩៩៨ | ៤១ |
| ចំនួនសាលារៀនកំរិតបឋមសិក្សា | ៥.៧៤១ |
| ចំនួនសាលារៀនកំរិតមធ្យមសិក្សា | ៥៣៤ |
| ចំនួនសាលារៀនមធ្យមសិក្សាទុតិយភូមិ | ១៦៣ |
| ចំនួនគ្រូបង្រៀនសរុប | ៧០.៦០៨ |
| ភាគរយនៃគ្រូបង្រៀនជានារី | ៣៨ |
| ចំនួនសិស្សដែលគ្រូមួយនាក់បង្រៀន | ៤៦ |
| ភាគរយនៃថវិកាជាតិសំរាប់វិស័យអប់រំ | ១៨,២ |

## ៤.១ ស្ថានភាព និន្នាការ និង បញ្ហា

បញ្ហាយេនឌ័រនៅក្នុងវិស័យអប់រំ ត្រូវបានរៀបចំជាឯកសារយ៉ាងច្បាស់លាស់។ បើប្រៀបធៀបទៅនឹងស្តង់ដារក្នុងតំបន់ កំរិតអប់រំទូទៅរបស់បុរស និងនារីនៅកម្ពុជានៅមានកំរិតទាបបំផុត ហើយនេះគឺជាបញ្ហាគ្រិះចំពោះការអភិវឌ្ឍន៍នៅក្នុងប្រទេស។ ទោះបីជាមានការរីកចំរើនជាក់ស្តែងនៅក្នុងរយៈពេលបីបួនឆ្នាំកន្លងមកនេះក៏ដោយ ប៉ុន្តែប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ នៅតែមានអត្រាចុះឈ្មោះចូលរៀនទាបនៅក្នុងតំបន់អាស៊ីខាងកើត។

ការទទួលបានការអប់រំ គឺជាបញ្ហាយេនឌ័រដ៏សំខាន់មួយ បុរសមានចំនួនច្រើនជាងនារី បានទទួលការអប់រំ។ គំលាតយេនឌ័រនៅក្នុងវិស័យអប់រំ កាន់តែមានទំហំធំនៅក្នុងចំណោមប្រជាជនក្រីក្រ និងនៅតាមតំបន់ជនបទ។

---

[១] ប្រភព: ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០២: ប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ
ជំរឿន ឆ្នាំ១៩៩៨,
ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០២: ការពិនិត្យឡើងវិញនៃកម្មវិធីសិក្សាវិស័យអប់រំ ឆ្នាំ២០០២

គំលាតយេនឌ័រនៅក្នុងការអប់រំ ផ្តល់ផលវិបាកដល់នារីក្នុងការទទួលបានឱកាសការងារ (សូមមើលជំពូកទី២)។ បើសិនជានារីទទួលបានការអប់រំ នារីអាចមានលទ្ធភាពប្រកួតប្រជែងជាមួយបុរសក្នុងការទទួលបានឱកាសការងារ។ តាមរយៈស្ថិតិដែលទទួលបានបង្ហាញឱ្យឃើញថា នារីដែលមានការអប់រំ ធ្វើឱ្យមានការអភិវឌ្ឍនីកចំរើនក្នុងផ្នែកជាច្រើន។ ក្រៅពីជួយបង្កើនផលិតភាពក្នុងវិស័យសេដ្ឋកិច្ចរបស់នារី អត្រាស្លាប់របស់កុមារ និងម្តាយ និងទំហំគ្រួសារ ត្រូវបានកាត់បន្ថយ អាហារូបត្ថម្ភ និងសុខភាពនៅក្នុងគ្រួសារ មានលក្ខណៈល្អប្រសើរ រួមទាំងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងធានាឱ្យបានថា មនុស្សជំនាន់ក្រោយ នឹងទទួលបានការអប់រំ (UNDP, ឆ្នាំ២០០៣)។ ជំពូកនេះ នឹងផ្តោតលើបញ្ហាយេនឌ័រក្នុងការទទួលបានការអប់រំជាទូទៅ។

ប្រទេសកម្ពុជា មានគោលដៅសំរេចឱ្យបាននូវការអប់រំបឋមសិក្សា និងមធ្យមសិក្សាជាសកលក្នុងឆ្នាំ២០១០ ដោយការអនុវត្តនីកម្មវិធីអប់រំសំរាប់ទាំងអស់គ្នា។ កម្មវិធីអប់រំសំរាប់ទាំងអស់គ្នា ផ្តល់ការអប់រំជាមូលដ្ឋានរយៈពេល ៩ឆ្នាំ ដោយរាប់ពីថ្នាក់បឋមសិក្សា ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ និងមធ្យមសិក្សា ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩។ ការយកចិត្តទុកដាក់ និងការវិភាជធនធាន គឺជាគោលដៅ ដើម្បីឈានទៅសំរេចគោលដៅរបស់កម្មវិធីអប់រំសំរាប់ទាំងអស់គ្នា។

នៅកម្ពុជា ការអប់រំគឺជាផ្នែកចំបងនៅក្នុងវិស័យសាធារណៈ លើកលែងតែថ្នាក់ឧត្តមសិក្សា (ការពិនិត្យឡើងវិញនៃកម្មវិធីគាំទ្រវិស័យអប់រំ ឆ្នាំ២០០២)។ ការអប់រំគឺត្រូវបានផ្តល់ជូនដោយមិនគិតថ្លៃសំរាប់ប្រជាជនទាំងអស់ ប៉ុន្តែការអនុវត្តនីជាក់ស្តែង គឺនៅតែមានការបង់ថ្លៃជាផ្លូវការ និងក្រៅផ្លូវការមួយចំនួន។

## ៤.១.១ គំលាតយេនឌ័រនៅក្នុងវិស័យអប់រំ កើនឡើងទៅតាមកំរិតនៃការសិក្សា

នៅកម្ពុជា គំលាតរវាងក្មេងប្រុស និងក្មេងស្រីកាន់តែកើនឡើងគួរឱ្យកត់សំគាល់ នៅពេលដែលពួកគេឈានទៅដល់កំរិតសិក្សាកាន់តែខ្ពស់។ នៅថ្នាក់មត្តេយ្យ និងបឋមសិក្សា ការចុះឈ្មោះចូលរៀនរបស់ក្មេងប្រុស និងក្មេងស្រីមានចំនួនសឹងតែស្មើគ្នា ប៉ុន្តែនៅថ្នាក់មធ្យមសិក្សាបឋមភូមិ[២] បើក្មេងប្រុសមានចំនួន ១០០នាក់ ក្មេងស្រីមានតែ ៦៣នាក់ប៉ុណ្ណោះ (សូមមើលក្រាហ្វិក ៤.១) បានចុះឈ្មោះចូលរៀន។ នៅថ្នាក់មធ្យមសិក្សាទុតិយភូមិ និងថ្នាក់ឧត្តមសិក្សា ក្មេងប្រុសមានចំនួន ១០០នាក់ បានចុះឈ្មោះចូលរៀន ចំណែកឯក្មេងស្រីមានតិចជាង ៥០នាក់ បានចុះឈ្មោះចូលរៀន (EMIS, ឆ្នាំ២០០១/២០០២)។ មូលហេតុនៃអត្រាខុសគ្នានេះ នឹងពិភាក្សានៅក្នុងផ្នែកបន្ទាប់។

[២] ទិន្នន័យទាំងអស់នៅក្នុងជំពូកនេះ ដកស្រង់ចេញពីប្រព័ន្ធពត៌មានគ្រប់គ្រងអប់រំ (EMIS) រៀបចំរាល់ឆ្នាំដោយក្រសួង អ.យ.ក សំរាប់គ្រប់កំរិតសិក្សា និងការពិនិត្យឡើងវិញ កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០២ លើកលែងតែមានការ ចែងខុសពីនេះ

**ក្រាហ្វិក ៤.១: សមភាពយេនឌ័រនៅក្នុងគ្រប់កំរិតទាំងអស់នៃការអប់រំ**




**សំគាល់:** ទិន្នន័យថ្នាក់ឧត្តមសិក្សា ក្នុងឆ្នាំសិក្សា២០០២/២០០៣

**ប្រភព:** EMIS, ឆ្នាំ២០០១/២០០២ នាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា

## ៤.១.២ ការចុះឈ្មោះចូលរៀនកំពុងកើនឡើងនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ

នៅថ្នាក់បឋមសិក្សា អត្រាចុះឈ្មោះចូលរៀនពិតរបស់ក្មេងប្រុស និងក្មេងស្រី គឺមានចំនួនប្រហាក់ប្រហែលគ្នា: ក្នុងឆ្នាំសិក្សា ២០០២-២០០៣ មានក្មេងប្រុសចំនួន ៩០ភាគរយ និងក្មេងស្រីចំនួន ៨៤ភាគរយ បានចុះឈ្មោះចូលរៀន (ក្រាហ្វិក ៤.២) ។ ទោះបីជាអត្រាចុះឈ្មោះចូលរៀនពិតនៅទីក្រុង ឬទីប្រជុំជន និងជនបទ នៅកំរិតបឋមសិក្សា មិនខុសគ្នាក៏ដោយ ក៏អត្រាចុះឈ្មោះចូលរៀនពិតនៅតំបន់ដាច់ស្រយាលមានចំនួនទាបគឺ ៧១ភាគរយ ។ គំលាតយេនឌ័រ នៅក្នុងតំបន់ដាច់ស្រយាលមានទំហំពុំសូវធំប៉ុន្មានទេ ដោយសារតែការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីមានចំនួន ៦៧ ភាគរយ ។ ប៉ុន្តែតាមតួរលេខថ្មីៗនេះ ស្តីអំពីការចុះឈ្មោះចូលរៀនពិតបង្ហាញឱ្យឃើញថា គំលាតយេនឌ័រកំពុងតែរួមតូច ដោយសារអត្រាក្មេងស្រីចុះឈ្មោះចូលរៀន មានកំរិតខ្ពស់ជាងក្មេងប្រុសបន្តិចបន្តួច (ក្រសួងអប់រំ យុវជន និងកីឡា) ។ ក្នុងកំឡុងឆ្នាំ១៩៩៨ និងឆ្នាំ២០០២ សមាមាត្រក្មេងស្រីចូលរៀនថ្នាក់បឋមសិក្សាកើនឡើង ៣ភាគរយ ។

អត្រាចុះឈ្មោះចូលរៀនពិត នៅកំរិតមធ្យមសិក្សាបឋមភូមិ មានចំនួនទាប (ក្រាហ្វិក៤.២) ។ នៅកម្ពុជា ក្មេង ១នាក់ ក្នុងចំណោមក្មេង ៥នាក់ និងក្មេងស្រី ១នាក់ ក្នុងចំណោមក្មេងស្រី ៦នាក់ ក្នុងក្រុមដែលមានអាយុប្រហាក់ប្រហែលគ្នា បានចុះឈ្មោះចូលរៀនកំរិតមធ្យមសិក្សាបឋមភូមិ ។ អត្រាចុះឈ្មោះចូលរៀនពិតនៅតំបន់ដាច់ស្រយាល តិចជាងអត្រាចុះឈ្មោះចូលរៀននៅទីក្រុងចំនួនមួយក្នុងចំណោមកុមារ១០០នាក់ ។ នៅតំបន់ជនបទ គំលាតយេនឌ័រ នៅក្នុងអត្រាចុះឈ្មោះចូលរៀនពិត គឺមានកំរិតខ្ពស់ជាងនៅទីក្រុង ឬទីប្រជុំជន ក្មេងប្រុស ១៩ភាគរយ ក្មេងស្រី ១៣ភាគរយ ។

**ក្រាហ្វិក ៤.២: អត្រាចុះឈ្មោះចូលរៀនពិត ពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ២០០១**




**ប្រភព:** ក្រសួងអប់រំ យុវជន និងកីឡា

## ៤.១.៣ ការកើនឡើងយ៉ាងឆាប់រហ័សនូវការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីមកពីឃុំដែលក្រីក្របំផុត

ក្នុងកំឡុងពេល២ ឬ៣ឆ្នាំនេះ ចំនួនចុះឈ្មោះចូលរៀនរបស់ក្មេងប្រុស និងក្មេងស្រីក្រីក្រនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ បានកើនឡើងគួរឱ្យកត់សំគាល់។ ចំនួនកុមារចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាមកពីបណ្តាឃុំដែលជាឃុំក្រីក្របំផុត កើនឡើងប្រហែលពី ៣០០.០០០នាក់ ក្នុងឆ្នាំ១៩៩៩ ទៅ ៤២៣.០០០នាក់ ក្នុងឆ្នាំ២០០១។ នេះបង្ហាញឱ្យឃើញថា ការចុះឈ្មោះចូលរៀនបានកើនឡើងចំនួន ១៣ភាគរយ នៅឆ្នាំ២០០០ និង ២៤ភាគរយ ក្នុងឆ្នាំ២០០១។ នៅក្នុងឃុំបញ្ចូភាគមានបំផុត ការចុះឈ្មោះចូលរៀនបានកើនឡើងចំនួន ៥ភាគរយ ក្នុងឆ្នាំ២០០០ និង៧ភាគរយ ក្នុងឆ្នាំ២០០១។ អត្រាកើនឡើងមិនសូវខុសគ្នាប៉ុន្មានទេ រវាងអត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រី ធៀបទៅនឹងអត្រាចុះឈ្មោះចូលរៀនរបស់ក្មេងប្រុស នៅក្នុងឃុំបញ្ចូភាគមានបំផុត ប៉ុន្តែការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅក្នុងឃុំបញ្ចូភាគក្រីក្របំផុត កើនឡើងក្នុងកំរិតខ្ពស់ជាងក្មេងស្រីមកពីមជ្ឈដ្ឋានផ្សេងៗទៀត។ ក្នុងឆ្នាំ២០០១ អត្រាកើនឡើងនៃការចុះឈ្មោះចូលរៀនរបស់ ក្មេងស្រីមកពីឃុំបញ្ចូភាគក្រីក្របំផុតគឺ ២៦ភាគរយ ដែលក្នុងឆ្នាំ២០០០ មានតែ ១៥ភាគរយ (ESSP Review, ឆ្នាំ២០០២)។

នៅមធ្យមសិក្សាបឋមភូមិ ចំនួនកុមារចុះឈ្មោះចូលរៀន មកពីឃុំបញ្ចូភាគក្រីក្របំផុតកើនឡើងពី ១១.៨០០នាក់ ក្នុងឆ្នាំ១៩៩៩ ដល់ ២០.០០០នាក់ ក្នុងឆ្នាំ២០០១។ អត្រាចុះឈ្មោះចូលរៀនសរុបនៅមធ្យមសិក្សាបឋមភូមិ បន្តកើនឡើងនៅគ្រប់បញ្ចូភាគទាំងអស់ ដែលក្នុងនោះបញ្ចូភាគក្រីក្របំផុត មានអត្រាកើនឡើងខ្ពស់បំផុតគឺ ៣៨ភាគរយក្នុងឆ្នាំសិក្សា

២០០១-២០០២។ នៅក្នុងគ្រប់បញ្ចូភាគទាំងអស់ ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រី នៅថ្នាក់មធ្យមសិក្សាបឋមភូមិ កើនឡើងយ៉ាងខ្លាំងនៅក្នុងបណ្តាឆ្នាំកន្លងមក។ ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីបញ្ចូភាគក្រីក្របំផុត កើនឡើងពីរដង ពី ៣.៣០២នាក់ ក្នុងឆ្នាំសិក្សា១៩៩៩-២០០០ ដល់ ៦.៥៤៧ ក្នុងឆ្នាំសិក្សា២០០១-២០០២ គឺអត្រាកើនឡើង ៣០ភាគរយ ក្នុងរវាងឆ្នាំសិក្សា១៩៩៩-២០០០ និងឆ្នាំសិក្សា២០០០-២០០១ និង ៥០ភាគរយ ក្នុងរវាងឆ្នាំសិក្សា ២០០០-២០០១ និងឆ្នាំសិក្សា២០០១-២០០២ (ESSP Review ឆ្នាំ២០០២)។ ទិន្នន័យទាំងនេះ បានបង្ហាញឱ្យឃើញថា កម្មវិធីកំពុងកាត់បន្ថយគំលាតយេនឌ័រ និងភាពខុសគ្នានៃក្រុមដែលមានប្រាក់ ចំណូលខុសគ្នា ក្នុងការទទួលបានការអប់រំ ប៉ុន្តែការចុះឈ្មោះចូលរៀនទូទៅ និងការចុះឈ្មោះចូលរៀនពិតរបស់ក្មេងស្រី នៅមធ្យមសិក្សាបឋមភូមិ នៅមានកំរិតទាបណាស់។ សិស្សមកពីបញ្ចូភាគក្រីក្របំផុតមានតែចំនួន ៦ភាគរយប៉ុណ្ណោះ រៀននៅមធ្យមសិក្សាបឋមភូមិ បើប្រៀបធៀបទៅនឹងសិស្សមកពីបញ្ចូភាគមានបំផុត គឺមានចំនួន ៣៧ភាគរយ។

## *៤.១.៤ អត្រាគង់វង្ស និងបញ្ចប់ការសិក្សារបស់ក្មេងស្រី មានកំរិតទាបជាងក្មេងប្រុស*

នៅកម្ពុជា អត្រាចុះឈ្មោះចូលរៀនពិត មិនមែនជារូបភាពមួយពេញលេញនៃការទទួលបានការអប់រំឡើយ ពីព្រោះថា ការចុះឈ្មោះចូលរៀនពិត បញ្ចូលទាំងសមាមាត្រនៃសិស្សដែលមានអាយុលើស ជាពិសេសនៅកំរិតមធ្យមសិក្សាបឋមភូមិ។ ការចុះឈ្មោះចូលរៀនដែលមានអាយុលើស បណ្តាលមកពីការចាប់ផ្តើមចូលរៀនយឺត អត្រាត្រួតថ្នាក់ខ្ពស់ និងការរៀនមិនជាប់លាប់ ជាពិសេសចំពោះសិស្សនារី (Bredenburg et al., ឆ្នាំ២០០៣)។ ក្នុងឆ្នាំសិក្សា២០០១-២០០២ ក្មេងស្រីចំនួន ២៩ភាគរយ និងក្មេងប្រុសចំនួន ៣២ភាគរយ ដែលបានចុះឈ្មោះចូលរៀននៅកំរិតបឋមសិក្សា និងក្មេងស្រីចំនួន ៣៦ភាគរយ និងក្មេងប្រុសចំនួន ៤៦ភាគរយ ដែលបានចុះឈ្មោះចូលរៀននៅកំរិតមធ្យមសិក្សាបឋមភូមិ គឺមានអាយុលើស (EMIS, ឆ្នាំ២០០២)។

អត្រាចុះឈ្មោះចូលរៀននៅកំរិតបឋមសិក្សារបស់ក្មេងស្រី និងក្មេងប្រុសមានចំនួនប្រហាក់ប្រហែលគ្នា ប៉ុន្តែអត្រាដ៏ខ្ពស់នៃសិស្សបោះបង់ការសិក្សាកំរិតខ្ពស់ និងអត្រាគង់វង្សកំរិតទាប នៅតែជាបញ្ហាយេនឌ័រដ៏សំខាន់នៅកំរិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ អត្រាគង់វង្សមានកំរិតខុសៗគ្នាទៅតាម នាយកដ្ឋាន ផ្សេងៗ នៅក្នុងក្រសួងអប់រំ យុវជន និងកីឡា។ ឧទាហរណ៍ ក្នុងឆ្នាំសិក្សា២០០១-២០០២ ក្រសួងអប់រំ យុវជន និងកីឡា បានរាយការណ៍ថា ក្មេងស្រីចំនួន ៤៨ភាគរយ និងក្មេងប្រុសចំនួន ៥១ភាគរយនៃក្មេងស្រី-ប្រុសទាំងអស់ ដែលបានចុះឈ្មោះចូលរៀននៅថ្នាក់ទី១ បានបញ្ចប់ថ្នាក់ទី៦។ ទិន្នន័យផ្សេងៗទៀត ពីលេខាធិការដ្ឋានអប់រំ សំរាប់ទាំងអស់គ្នាក្នុងឆ្នាំ២០០២ (Bredenburg et al., ឆ្នាំ២០០៣) បង្ហាញឱ្យឃើញថា អត្រាគង់វង្សក្នុងឆ្នាំសិក្សាដដែល ក្មេងស្រីមានចំនួន ៥៧ភាគរយ និងក្មេងប្រុសមានចំនួន ៦១ភាគរយ។

ក្នុងឆ្នាំ២០០២ តាមការវិភាគជាក្រុមមួយដែលធ្វើឡើងដោយក្រុមការងារយេនឌ័ររបស់ក្រសួងអប់រំ យុវជន និងកីឡា សំរាប់រយៈពេល៧ឆ្នាំ ចាប់ផ្តើមពីឆ្នាំសិក្សា១៩៩៥-១៩៩៦ បានបង្ហាញឱ្យឃើញថា អត្រាគង់វង្សរបស់ក្មេងប្រុសគឺ៣៤ភាគរយ ក្មេងស្រីគឺ៣២ភាគរយ នៅថ្នាក់ទី៥ ក្មេងប្រុស៣០ភាគរយ ក្មេងស្រី២៧ភាគរយ នៅថ្នាក់ទី៦ និងក្មេងប្រុស២៦ភាគរយ ក្មេងស្រី២១ភាគរយ នៅថ្នាក់ទី៧ (សូមមើលក្រាហ្វិក ៤.៣)។

ជោគជ័យមួយដែលជាលទ្ធផលនៃការអនុវត្តន៍កម្មវិធី និងគោលនយោបាយថ្មីៗនៅក្នុងវិស័យអប់រំ ក្នុងរយៈពេល ២ឆ្នាំកន្លងមកនេះ គឺការកាត់បន្ថយអត្រាសិស្សរៀនត្រួតថ្នាក់នៅក្នុងគ្រប់កំរិត និងគ្រប់តំបន់ទាំងអស់។ ការកាត់បន្ថយនេះ ជាលទ្ធផលនៃការអនុវត្តន៍ដំណើរការថ្នាក់បំប៉នបន្ថែម សំរាប់សិស្សដែលប្រឡងធ្លាក់នៅ ក្នុងពេលវិស្សមកាល និងមានប្រាក់ឧបត្ថម្ភលើកទឹកចិត្តជាពិសេសសំរាប់គ្រូ។ ការធ្លាក់ចុះនៃអត្រាសិស្សរៀនត្រួតថ្នាក់ នឹងបង្កើនឱ្យមានសមភាពយេនឌ័រនៅក្នុងការអប់រំ។ ការកាត់បន្ថយពេលវេលាដែលមិនចាំបាច់សំរាប់ក្មេងស្រី អាចបញ្ចប់ការសិក្សាជាមូលដ្ឋានគ្រឹះ គឺជួយកាត់បន្ថយពេលវេលា និងប្រាក់ដែលត្រូវចំណាយសំរាប់រៀន ជាពិសេសក្មេងស្រីដែលមានអាយុច្រើន។ ការរៀនត្រួតថ្នាក់ត្រូវចំណាយទាំងពេលវេលា និងលុយកាក់ជាច្រើន។ ការចុះឈ្មោះចូលរៀនដែលមានអាយុលើស អាចនឹងកាត់បន្ថយបានដោយការអនុវត្តន៍កម្មវិធី និងគោលនយោបាយថ្មីៗ នៅក្នុងវិស័យអប់រំ។

អត្រាក្មេងស្រីបោះបង់ចោលការសិក្សានៅកំរិតបឋមសិក្សា គឺក្នុងចន្លោះ ១៣ និង ១៤ភាគរយ ក្នុងកំឡុងពេល ៨ឆ្នាំកន្លងមកនេះ (Bredenburg et al., ឆ្នាំ២០០៣)។ អត្រាក្មេងប្រុសបោះបង់ចោលការសិក្សា មានកំរិតទាបជាងក្មេងស្រីក្នុងកំឡុងឆ្នាំ១៩៩៣ ដល់២០០១ គឺក្នុងរវាង ៨ ទៅ ១២ភាគរយ។ នៅថ្នាក់មធ្យមសិក្សាបឋមភូមិ អត្រាសិស្សបោះបង់ចោលការសិក្សា ធ្លាក់ចុះយ៉ាងខ្លាំង (ក្រាហ្វិក៤.៤)។ អត្រាក្មេងប្រុស និងក្មេងស្រីបោះបង់ចោលការសិក្សាមានគំលាតតូច។

**ក្រាហ្វិក ៤.៣: អត្រាគង់វង្សរបស់ក្មេងប្រុស/ក្មេងស្រីនៅតាមថ្នាក់ (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៧)**




**ប្រភព:** Bredenburg et al., ឆ្នាំ២០០៣

ទោះបីជាអត្រាបោះបង់ចោលការសិក្សាបានធ្លាក់ចុះ នៅកំរិតមធ្យមសិក្សាបឋមភូមិក៏ដោយ ក៏គំលាតយេនឌ័រដែលនៅតែមាននៅក្នុងគ្រប់កំរិតទាំងអស់នៃការសិក្សា បង្ហាញឱ្យឃើញថា នៅមានកត្តាផ្សេងៗទៀតដែលបន្តរាំងស្ទះដល់ការបញ្ចប់ការសិក្សាជាមូលដ្ឋានគ្រឹះរបស់ក្មេងស្រី ដូចជាតំលៃនៃការសិក្សា ចម្ងាយពីផ្ទះទៅសាលារៀន និងការទទួលខុសត្រូវក្នុងការងារផ្ទះ។

**ក្រាហ្វិក ៤.៤: អត្រាសិស្សបោះបង់ចោលការសិក្សានៅកំរិតមធ្យមសិក្សាបឋមភូមិ**




**ប្រភព:** Bredenburg et al., ឆ្នាំ២០០៣

## *៤.១.៥ មានការខ្វះខាតគ្រូបង្រៀនខ្លាំងនៅជនបទ ជាពិសេសគ្រូបង្រៀនជានារី*

យុទ្ធវិធីគន្លឹះមួយដើម្បីបង្កើនការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅក្នុងការសិក្សាជាមូលដ្ឋានគ្រឹះ គឺការបង្កើនចំនួនគ្រូបង្រៀនជានារី ។ ចំនួនគ្រូបង្រៀននៅថ្នាក់បឋមសិក្សា បានកើនឡើងចំនួន ៧ភាគរយ តាំងពីឆ្នាំ១៩៩៣ មក ហើយគ្រូបង្រៀននៅកំរិតមធ្យមសិក្សាកើនឡើងចំនួន ២៣ភាគរយ ក្នុងរវាងឆ្នាំ១៩៩៦ និង ២០០១ ។ ការកើនឡើងនៃចំនួនគ្រូបង្រៀន ធ្វើឱ្យមានការកើនឡើងនៃការចុះឈ្មោះចូលរៀននៅកំរិតបឋមសិក្សា មានចំនួន ៦៧ភាគរយ និងកំរិតមធ្យមសិក្សាមានចំនួន ១២៤ភាគរយ ។ ជាលទ្ធផល ធ្វើឱ្យផលធៀបសិស្ស និងគ្រូបង្រៀន (PTR) កើនឡើងយ៉ាងខ្លាំង ។ នៅក្នុងឆ្នាំ២០០២ ផ្អែកតាមស្ថិតិពីរដ្ឋាភិបាល ផលធៀបសិស្ស និងគ្រូបង្រៀនគឺ ៥៦/១ នៅកំរិតបឋមសិក្សា ដែលបង្ហាញឱ្យឃើញនូវការខ្វះខាតគ្រូបង្រៀន គឺមានកំរិតខ្ពស់នៅជនបទ និងតំបន់ដាច់ស្រយាល ប៉ុន្តែមានភាពល្អប្រសើរនៅកំរិតមធ្យមសិក្សា ដែលមានផលធៀបសិស្ស-គ្រូ ២២/១ (Bredenburg et al. ឆ្នាំ២០០៣) ។

ក្រសួងអប់រំ យុវជន និងកីឡា មានគោលដៅបង្កើនសមភាពយេនឌ័រក្នុងចំណោមគ្រូបង្រៀន ដែលមានការកើនឡើងមួយចំនួនតូចនៅថ្នាក់ជាតិ ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ ។ សមភាពយេនឌ័របានកើនពី ០,៤៩ ទៅ ០,៦៤ (គ្រូបង្រៀនជានារី ប្រៀបធៀបនឹងគ្រូបង្រៀនជាបុរស១រូប) ក្នុងចំណោមគ្រូបឋមសិក្សា និងកើនឡើងពី ០,៣៧ ទៅ ០,៤២ ក្នុងចំណោមគ្រូមធ្យមសិក្សា (Bredenburg et al., ឆ្នាំ២០០៣) ។ តួរលេខថ្នាក់ជាតិ អាចនឹងធ្វើឱ្យមានការយល់ច្រលំ: ព្រោះថានៅទីក្រុង ឬទីប្រជុំជនអត្រាគ្រូបង្រៀនជានារី ប្រៀបធៀបជាមួយគ្រូបង្រៀនបុរសគឺលើសពី ១នាក់ ប៉ុន្តែនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល គឺមានកំរិតទាបណាស់ ។ មូលហេតុចំបងដែលបណ្តាលឱ្យគ្រូបង្រៀនជានារីមានចំនួនតិចនៅក្នុងតំបន់ជនបទ គឺថាមាននារីជនបទក្នុងចំនួនតិចប៉ុណ្ណោះបានដាក់ពាក្យ និងមាន

កិរិតវប្បធម៌ទាប មិនអាចធ្វើជាគ្រូបង្រៀន ចំណែកឯនារីទីក្រុងដែលជាគ្រូបង្រៀន មានការព្រួយបារម្ភអំពីសន្តិសុខនៅក្នុងតំបន់ជនបទ ហើយប្រាក់លើកទឹកចិត្តមានចំនួនតិចតួចសំរាប់ទាក់ទាញគ្រូនៅទីក្រុង ឱ្យទៅបង្រៀននៅជនបទ ។ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ជាប្រាក់លើកទឹកចិត្ត ដើម្បីទាក់ទាញគ្រូទៅបង្រៀននៅសាលារៀននៅជនបទ និងអនុវត្តការបង្រៀនច្រើនថ្នាក់ (ប្រើប្រាស់ធនធានដែលមានឱ្យបានគ្រប់គ្រាន់) ។ ប៉ុន្តែយុទ្ធសាស្ត្រនេះហាក់ដូចជាមិនសូវមានឥទ្ធិពលប៉ុន្មានទេ ព្រោះការអនុវត្តន៍មានទ្រង់ទ្រាយតូច (Breden-burg et al., ឆ្នាំ២០០៣) ។

## ៤.១.៦ គំលាតយេនឌ័រ និងភាពខុសគ្នានៃប្រាក់ចំណូល នៅតែពុំមានការផ្លាស់ប្តូរ នៅក្នុងកំរិតមធ្យមសិក្សាទុតិយភូមិ

ចំនួនក្មេងប្រុស និងក្មេងស្រី ដែលបានចុះឈ្មោះចូលរៀននៅកំរិតមធ្យមសិក្សាទុតិយភូមិបាន និងកំពុងកើនឡើង (ក្រាហ្វិក ៤.៥) ។ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលនៃការកាត់បន្ថយគំលាតយេនឌ័រ និងក្រុមចំណាត់ថ្នាក់តាមប្រាក់ចំណូលដែលទទួលបាននៅកំរិតមធ្យមសិក្សាបឋមភូមិ មិនដូចគ្នានឹងលទ្ធផលទទួលបាននៅកំរិតមធ្យមសិក្សាទុតិយភូមិឡើយ ។ អត្រាចុះឈ្មោះចូលរៀននៅក្នុងបញ្ចភាគក្រីក្របំផុត កើនឡើងពី ១ ទៅ ២ភាគរយ ក្នុងរវាងឆ្នាំ១៩៩៩ ដល់ ២០០១ ប៉ុន្តែអត្រាចុះឈ្មោះចូលរៀនក្នុងបញ្ចភាគមានបំផុត ធ្លាក់ចុះពី ៦៣ មក ៥៧ភាគរយ ។ ចំនួនក្មេងស្រីនៅកំរិតមធ្យមសិក្សាទុតិយភូមិកើនឡើង ជាពិសេសនៅតំបន់ជនបទ ប៉ុន្តែផលធៀបរវាងក្មេងប្រុស និងក្មេងស្រីនៅតែមានកំរិតទាប និងនៅតែគ្មានការផ្លាស់ប្តូរ ក្នុងរយៈពេល៧ឆ្នាំកន្លងមកនេះ ។ ទិន្នន័យដំបូងសំរាប់ឆ្នាំសិក្សា ២០០២-២០០៣ បានបង្ហាញឱ្យឃើញថា នៅដើមឆ្នាំអាចនឹងមានការធ្លាក់ចុះ ប៉ុន្តែនឹងកើនឡើងនៅឆ្នាំ២០០៣ (ក្រាហ្វិក៤.៦) ។

**ក្រាហ្វិក ៤.៥: ចំនួនសិស្សដែលបានចុះឈ្មោះនៅកំរិតមធ្យមសិក្សាទុតិយភូមិ**




**ប្រភព:** ក្រសួងអប់រំ យុវជន និងកីឡា

**ក្រាហ្វិក ៤.៦: ការប្រៀបធៀបអត្រាក្មេងប្រុស ជាមួយនឹងក្មេងស្រី នៅតាមតំបន់**




**ប្រភព:** ក្រសួងអប់រំ យុវជន និងកីឡា

## *៤.១.៧ អត្រាចុះឈ្មោះចូលរៀនពិតធ្លាក់ចុះនៅកំរិតមធ្យមសិក្សាទុតិយភូមិ ជាពិសេសក្មេងប្រុស*

ការចុះឈ្មោះចូលរៀនពិតនៅកំរិតមធ្យមសិក្សាទុតិយភូមិកើនឡើងក្នុងឆ្នាំ១៩៩៩ ហើយបន្ទាប់មក ធ្លាក់ចុះទាំងអត្រារបស់ក្មេងប្រុស និងក្មេងស្រី (ក្រាហ្វិក ៤.៧) ប៉ុន្តែអត្រារបស់ក្មេងប្រុសធ្លាក់ចុះលឿនជាង ។ បច្ចុប្បន្នអត្រាចុះឈ្មោះបានកើនឡើងតែបន្តិចបន្តួចលើសពីឆ្នាំសិក្សា ១៩៩៦-១៩៩៧ តែប៉ុណ្ណោះ ជាពិសេសអត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រី ដែលពីមុនមានការកើនឡើងក្នុងចំនួនតិចតួច ។ មូលហេតុនៃអត្រាទាបនៅកំរិតមធ្យមសិក្សាទុតិយភូមិត្រូវបានពន្យល់ដោយផ្នែកៗប៉ុណ្ណោះ ។ ជាក់ស្តែងក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់មួយភាគធំនៃធនធានរបស់ក្រសួង និងផ្តោតការយកចិត្តទុកដាក់លើការពង្រីកការអប់រំជាមូលដ្ឋាន ប៉ុន្តែក្រសួងយកចិត្តទុកដាក់តិចតួចនៅកំរិតមធ្យមសិក្សាទុតិយភូមិ ។

**ក្រាហ្វិក ៤.៧: អត្រាចុះឈ្មោះចូលរៀនពិត នៅកំរិតមធ្យមសិក្សាទុតិយភូមិ**




**ប្រភព:** ក្រសួងអប់រំ យុវជន និងកីឡា

## ៤.១.៨ មូលហេតុដែលនាំឱ្យមានគំលាតយេនឌ័រនៅកំរិតមធ្យមសិក្សា

ការប៉ាន់ប្រមាណរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកផ្តល់ជំនួយ បានរកឃើញនូវមូលហេតុមួយចំនួន ដែលនាំឱ្យមានគម្លាតយេនឌ័រ នៅក្នុងការចុះឈ្មោះចូលរៀន ដែលមានដូចខាងក្រោមនេះ:

### តំលៃចំណាយលើការសិក្សា

តាមការសិក្សាជាច្រើនបង្ហាញឱ្យឃើញថា បញ្ហាអសមត្ថភាពរបស់គ្រួសារក្នុងការចំណាយដោយផ្ទាល់ និងដោយប្រយោលលើការសិក្សា គឺជាមូលហេតុចំបងដែលក្មេងស្រីមិនអាចទៅសាលាបាន ។ ចំណាយជាប្រចាំរបស់ផ្នែកឯកជនលើវិស័យអប់រំសាធារណៈមានចំនួន ៦៤ភាគរយ នៃចំណាយសរុបជាប្រចាំលើវិស័យអប់រំ ។ ការចំណាយឯកជនសំរាប់កុមារ១នាក់នៅក្នុងកំរិតបឋមសិក្សា មានចំនួន ៧៩ភាគរយ នៃចំណាយទុនក្រៅពីម្ហូបអាហារ សំរាប់មនុស្ស១នាក់ របស់ប្រជាជនក្រីក្របំផុតចំនួន ២០ភាគរយ ។ ចំណាយក្នុង១នាក់សំរាប់ថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា គឺច្រើនជាង ២ទៅ ៧ដង នៃចំណាយសំរាប់ការប្រើប្រាស់ក្រៅពីម្ហូប របស់ប្រជាជនក្រីក្របំផុត ចំនួន ២០ភាគរយ (Vinky ឆ្នាំ២00២, ឯកសារស្តីពីការពិនិត្យលើចំណាយសាធារណៈ ក្នុងជំពូកស្តីពីវិស័យអប់រំ) ។

ទោះបីជាតំលៃផ្ទាល់នៃការសិក្សាមានតំលៃដូចគ្នាសំរាប់ក្មេងប្រុស និងក្មេងស្រីក៏ដោយ ក៏ជាទូទៅឪពុកម្តាយគិតថា ការសិក្សាសំរាប់ក្មេងស្រីត្រូវចំណាយច្រើនជាង និងទទួលបានផលតិចជាងក្មេងប្រុស ។ នៅក្នុងកាលៈទេសៈដែលគ្រួសារក្រីក្រគ្មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីបញ្ជូនកូនទាំងអស់ឱ្យទៅរៀន គ្រួសារទាំងនោះ ច្រើនតែបញ្ជូនកូនប្រុស

ឱ្យទៅរៀន ។ នៅក្នុងគ្រួសារភាគច្រើន ក្មេងស្រីត្រូវចំណាយពេលវេលាទៅរៀនរបស់ខ្លួន មកជួយធ្វើការងារស្រែចំការ មើលថែទាំបងប្អូនតូចៗ និងការងារផ្ទះផ្សេងៗ ដូច្នេះម្តាយរបស់នាង អាចទៅប្រកបរបររកប្រាក់ចំណូលសំរាប់គ្រួសារ ។ ដោយសារបុរសច្រើនធ្វើការងារដែលទាមទារកំលាំងខ្លាំង ឬប្រើម៉ាស៊ីន កំលាំងពលកម្មរបស់ក្មេងប្រុស មិនសូវយកទៅជួយជំនួសកំលាំងពលកម្មរបស់ឪពុករបស់ខ្លួន ដូចកំលាំងពលកម្មរបស់ក្មេងស្រី ដែលអាចយកទៅជំនួសកំលាំងពលកម្មរបស់ម្តាយជាញឹកញាប់នោះទេ ។ ឱកាសការងារកើនឡើងទៅតាមអាយុរបស់សមាជិកគ្រួសារ ជាពិសេសនៅពេលមានការងាររកប្រាក់ចំណូលសំរាប់គ្រួសារ ដូចជារោងចក្រកាត់ដេរ ដែលផ្តល់ឱកាសរកប្រាក់ចំណូលកាន់តែច្រើន ជាជាងការទៅសិក្សា ។

## ចម្ងាយពីផ្ទះនៅសាលារៀន

ចម្ងាយផ្លូវទៅសាលារៀន នៅតែជាឧបសគ្គក្នុងការទទួលបានការអប់រំកំរិតមធ្យមសិក្សា ។ គ្រួសារមួយចំនួនធំរស់នៅចម្ងាយ១គីឡូម៉ែត្រពីសាលាបឋមសិក្សា ប៉ុន្តែមានតែ ០,០៥ភាគរយ នៃភូមិទាំងអស់ មានសាលាមធ្យមសិក្សាបឋមភូមិមួយ និង ០,០១ភាគរយ មានសាលាមធ្យមសិក្សាទុតិយភូមិមួយ (ក្រសួងផែនការ, ឆ្នាំ១៩៩៧) ។ ក្នុងរវាងឆ្នាំ១៩៩៧ ដល់ ឆ្នាំ២០០២ មិនមានការសាងសង់សាលារៀនថ្មីទេ ។

៣៩ភាគរយ នៃសិស្សថ្នាក់ទី៦ ដែលមានលទ្ធភាពអាចចូលរៀនកំរិតមធ្យមសិក្សាបឋមភូមិ រស់នៅចម្ងាយយ៉ាងតិចណាស់ ៣គីឡូម៉ែត្រពីសាលារៀន និងចំនួន ១០ភាគរយ រស់នៅចម្ងាយយ៉ាងហោចណាស់ ១០គីឡូម៉ែត្រពីអនុវិទ្យាល័យដែលនៅជិតបំផុត (មូលនិធិជប៉ុនសំរាប់ការកាត់បន្ថយភាពក្រីក្រ និងមូលនិធិ ADB, ឆ្នាំ២០០១) ។ ដោយគុណភាពរបស់ផ្លូវនៅជនបទមិនល្អ ចម្ងាយទៅសាលារៀនគឺជាឧបសគ្គយ៉ាងធំ នៅក្នុងចំណោមសិស្សភាគច្រើនដែលគ្មានសូម្បីតែកង់សំរាប់ការធ្វើដំណើរ ។ ក្មេងប្រុសអាចរស់នៅក្នុងវត្ត នៅពេលបន្តការសិក្សានៅកំរិតមធ្យមសិក្សា ប៉ុន្តែគ្មានប្រពន្ធ័ជួយដល់ការស្នាក់នៅរបស់ក្មេងស្រីឡើយ ។ ទោះបីជាចម្ងាយទៅអនុវិទ្យាល័យមិនជាឆ្ងាយប៉ុន្មានក៏ដោយ ក៏ឪពុកម្តាយមានការព្រួយបារម្ភអំពីសុវត្ថិភាពរាងកាយ និងសីលធម៌របស់ក្មេងស្រី នៅពេលដើរទៅសាលារៀន (Velasco, ឆ្នាំ២០០១ និងមូលនិធិជប៉ុនសំរាប់ការកាត់បន្ថយភាពក្រីក្រ និងមូលនិធិ ADB, ឆ្នាំ២០០១) ។ ការស្ទង់មតិមួយនៅឆ្នាំ១៩៩៨ បង្ហាញឱ្យឃើញថា ៦២ភាគរយនៃមេផ្ទះ និយាយថា គាត់មានការព្រួយបារម្ភអំពីសន្តិសុខរបស់កូនស្រីគាត់នៅពេលធ្វើដំណើរទៅសាលារៀន ។ ភាគរយនេះមានកំរិតខ្ពស់នៅទីក្រុង ឬទីប្រជុំជន (៥៧ភាគរយ) ជាងនៅតំបន់ជនបទ (៣៨ភាគរយ) (ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ CARE) ។

## ការខ្វះបង្គន់អនាម័យ

នៅទូទាំងប្រទេស សាលាបឋមសិក្សាចំនួន ៦៥ភាគរយ និងវិទ្យាល័យចំនួន ១៣ភាគរយ គ្មានបង្គន់អនាម័យ (EMIS, ឆ្នាំ២០០១) ។ ស្ថានភាពនេះ ធ្វើឱ្យមានបញ្ហាខ្មាស់អៀន ជាពិសេសសំរាប់ក្មេងស្រីជំទង់ ។ អត្រាចុះឈ្មោះចូលរៀនហួសអាយុមានកំរិតខ្ពស់ ដូច្នេះការខ្វះបង្គន់អនាម័យ និងប៉ះពាល់ដល់ការចុះឈ្មោះចូលរៀនកំរិតបឋមសិក្សា ។

## ខ្វះគ្រូបង្រៀនជានារី និងគ្រូជាគំរូល្អ

ការខ្វះគ្រូបង្រៀនជានារី និងគំរូល្អជានារី ជាពិសេសនៅតំបន់ជនបទ គឺជាកត្តាបន្ថែមដែលធ្វើឱ្យនារីមិនមានការលើកទឹកចិត្តក្នុងការទៅសាលារៀន។ តាមរយៈ Bredenburg et al. ឆ្នាំ២០០៣ បង្ហាញឱ្យឃើញថា "នៅពីក្រោយឧបសគ្គផ្នែកសេដ្ឋកិច្ចលើការសិក្សារបស់ក្មេងស្រី គឺមានគំនិត និងឥរិយាបថរបស់សង្គមចំពោះឋានៈ សមត្ថភាព និងបញ្ញារបស់បុរស (ក្មេងប្រុសមានកិរិតខ្ពស់ជាង)។ ឥរិយាបថទាំងនេះ បន្តកើតឡើងមិនត្រឹមតែក្នុងចំណោមឪពុកម្តាយប៉ុណ្ណោះទេ ប៉ុន្តែក៏កើតឡើងនៅក្នុងចំណោមគ្រូផងដែរ។ ដូច្នេះបរិស្ថានបែបនេះ គឺអាចពង្រឹងទស្សនៈវិស័យអំពីគំរូយេនឌ័រ"។

កម្មវិធីសិក្សា សៀវភៅសិក្សា និងកត្តាក្នុងសាលាផ្សេងៗទៀត ដែលបន្តឱ្យមានឥរិយាបថមិនសមរម្យចំពោះយេនឌ័រ កំពុងត្រូវបានធ្វើការស្រាវជ្រាវ និងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង។ ឧទាហរណ៍ ភាគច្រើននៃការរៀបចំសៀវភៅសិក្សាបច្ចុប្បន្ន មិនបានដាក់បញ្ចូលនូវបញ្ហាអំពីយេនឌ័រឡើយ (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០១)។

## ការនិយមបញ្ជូនកូនប្រុសឱ្យទៅរៀន

ការសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ CARE ក្នុងឆ្នាំ១៩៩៨ បង្ហាញឱ្យឃើញថា មេផ្ទះចំនួន៤៦ភាគរយយល់ស្របថា ក្មេងប្រុសមានបញ្ញាជាងក្មេងស្រី និង ៦១ភាគរយនិយាយថា ការអប់រំសំរាប់ក្មេងប្រុសសំខាន់ជាងក្មេងស្រី។ លទ្ធផលដូចគ្នាត្រូវបានរកឃើញនៅក្នុងអង្កេតប្រជាសាស្ត្រ និងសុខាភិបាលនៅកម្ពុជា និងការសិក្សាផ្សេងៗ ទោះបីជានៅក្នុងការអង្កេតទាំងនោះ ឪពុកម្តាយនិយាយថា គាត់ក៏ចង់ឱ្យកូនស្រីរបស់គាត់ទទួលបានការសិក្សាដែរ (ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ CARE)។

## ក្មេងស្រីជាអ្នកមើលថែនាំបងប្អូន

ក្មេងស្រីភាគច្រើន ទទួលតួនាទីជាអ្នកមើលថែទាំគ្រួសារ នៅពេលគ្រួសារមានបញ្ហាអ្វីមួយ (Velasco, ឆ្នាំ២០០១) ឧទាហរណ៍ ពេលគ្រួសារមានជំងឺ ឬស្លាប់ដោយសារជំងឺអេដស៍ ឬជំងឺផ្សេងៗទៀត ដែលតម្រូវឱ្យគ្រួសារត្រូវទាញកុមារចេញពីសាលារៀន ជាពិសេសក្មេងស្រី (គណៈកម្មការអឺរ៉ុប ឆ្នាំ២០០២)។ ជាចុងក្រោយ ក្មេងស្រីត្រូវចាកចេញពីសាលារៀនទាំងនៅវ័យក្មេង ព្រោះក្មេងស្រី (ឬឪពុកម្តាយ) សំរេចចិត្តថា ពួកគេត្រូវរៀបការ។

> "បញ្ជូនកូនប្រុសរបស់អ្នកទៅសាលារៀនដែលនៅឆ្ងាយពីផ្ទះ ប្រសិនបើអ្នកមានប្រាក់... នេះគឺជាយោបល់ល្អណាស់ ហើយពួកគេអាចមានអនាគតល្អប្រសើរ ប៉ុន្តែតើនឹងមានរឿងអ្វីកើតឡើងចំពោះកូនស្រី បើអ្នកបញ្ជូនពួកគេទៅឆ្ងាយ? ប្រហែលវាអាចត្រលប់មកភូមិវិញដោយមានផ្ទៃពោះផងក៏មិនដឹង។ នៅស្រុកខ្មែរគ្មាននរណាម្នាក់ បញ្ជូនកូនស្រីទៅរៀននៅឆ្ងាយឡើយ" បុរសម្នាក់រស់នៅក្នុងខេត្តកណ្តាល ផ្តល់ការសំភាសន៍នៅក្នុងរបាយការណ៍ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (**ADB, ឆ្នាំ២០០១**)។

## ៤.១.៩ គំលាតយេនឌ័រ មានទំហំកាន់តែធំ នៅកំរិតឧត្តមសិក្សា

ប្រជាជនកម្ពុជាចំនួនតែ ០,២ភាគរយប៉ុណ្ណោះ បានចូលរៀននៅកំរិតក្រោយមធ្យមសិក្សា ( ជំរឿន ឆ្នាំ១៩៩៨) ។ ទោះបីជាយ៉ាងណាក៏ដោយ ការចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យបានកើនឡើងតាំងពីឆ្នាំ១៩៩៩ នៅពេលដែលរដ្ឋាភិបាលអនុញ្ញាតឱ្យមានមហាវិទ្យាល័យឯកជន ។ មហាវិទ្យាល័យឯកជនមួយចំនួន មានសាខានៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្ត ។

ដោយសារតែក្មេងស្រីដែលបានបញ្ចប់ថ្នាក់មធ្យមសិក្សា មានចំនួនតិចជាងក្មេងប្រុស ដូច្នេះសិស្សប្រុសមានចំនួនភាគច្រើននៅកំរិតឧត្តមសិក្សា ។ សមភាពយេនឌ័រនៅកំរិតឧត្តមសិក្សា នឹងមិនអាចទទួលបានជោគជ័យឡើយ ល្គឹគណាមិនមានក្មេងស្រីចំនួនច្រើន បញ្ចប់ការសិក្សានៅកំរិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិនោះទេ ។ ជាការពិតណាស់ដែលការរីកដុះដាលនៃមហាវិទ្យាល័យឯកជនក្នុងកំឡុងពេល បីបួនឆ្នាំកន្លងមកនេះ ទាំងនៅភ្នំពេញ និងតាមបណ្តាខេត្តនានា បានជួយបង្កើនការផ្តល់សេវាសិក្សាថ្នាក់ឧត្តម ដែលពីមុនមានតែនៅក្នុងសាលារដ្ឋនៅក្នុងទីក្រុង ។ ការអភិវឌ្ឍន៍នេះបានជួយដល់ក្មេងស្រី ទោះបីជាការចូលរៀនរបស់ក្មេងស្រីនៅកំរិតឧត្តមសិក្សា មានការកើនឡើងតិចតួចក៏ដោយ ។ ក្មេងស្រីដែលមានឧបសគ្គដោយសារបញ្ហាសន្តិសុខ និងបញ្ហាធ្វើដំណើរមកភ្នំពេញ មានលទ្ធភាពបន្តការសិក្សានៅក្នុងខេត្តរបស់ខ្លួន ។

ក្នុងរយៈពេលបីបួនឆ្នាំកន្លងមកនេះ សមាមាត្រសិស្សនារី បានកើនឡើងប្រហែល ២៧ភាគរយ នៅគ្រប់វិទ្យាស្ថានទាំងអស់ ( ក្រាហ្វិក ៤.៨) ។ ភស្តុតាង គឺការកើនឡើងនៅក្នុងវិទ្យាស្ថានឧត្តមសិក្សាចំនួនពីរដែលពីមុន ភាគរយនៃសិស្សនារីមានចំនួនតិចបំផុតៈ គឺវិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញ និងសាលាភូមិន្ទកសិកម្ម ។

**ក្រាហ្វិក ៤.៨: សមាមាត្រសិស្សនារី នៅកំរិតឧត្តមសិក្សា**




ប្រភពៈ ក្រសួងអប់រំ យុវជន និងកីឡា

## ៤.១.១០ គំលាតយេនឌ័រនៅក្នុងអត្រាអក្ខរកម្ម កើនឡើងទៅតាមអាយុរបស់ប្រជាជន

អក្ខរកម្ម គឺពាក់ពន្ធ័ជាមួយនឹងការទទួលបានឱកាសសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ ឧទាហរណ៍ ការទំនាក់ទំនងផ្សព្វផ្សាយពតិមានអំពីកសិកម្ម មានទំនោរទៅរកប្រជាជនដែលចេះអក្សរ ( ធនាគារពិភពលោក ឆ្នាំ២០០២i) ដូច្នេះ យុទ្ធវិធីទំនាក់ទំនងផ្សព្វផ្សាយពតិមាននេះ មិនអាចចូលទៅដល់នារី និងបុរសនៅជនបទដែលមិនចេះអក្សរបានឡើយ (CSES, ឆ្នាំ១៩៩៩) ។ គំលាតយេនឌ័រក្នុងអត្រាអក្ខរកម្មក្នុងចំណោមប្រជាជនអាយុពី១៥ ទៅ២៤ឆ្នាំ បាននឹងកំពុងធ្លាក់ចុះជាបន្តបន្ទាប់ ហើយតាមរយៈទិន្នន័យបច្ចុប្បន្នបង្ហាញឱ្យឃើញថា អត្រាអក្ខរកម្មរបស់ក្មេងប្រុសគឺ ៨៧ភាគរយ និងក្មេងស្រី ៧៧ភាគរយ ។ បើសិនជានិន្នាការបច្ចុប្បន្ននេះ បន្តរហូតគំលាតយេនឌ័រ នឹងត្រូវបានលុបបំបាត់ក្នុងពេលឆាប់ៗនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាមិនទាន់ទទួលបានជោគជ័យឱ្យមានអត្រាអក្ខរកម្ម ១០០ ភាគរយក្នុងចំណោមក្រុមនេះ ហើយតួរលេខថ្នាក់ជាតិ មិនបានបង្ហាញអំពីគំលាតនៅតាមខេត្ត និងតាមតំបន់ឡើយ ។

ក្នុងចំណោមនុស្សពេញវ័យ នារីជាអនក្ខរជននៅតែមានចំនួនច្រើនជាងបុរស ហើយគំលាតកាន់តែធំសំរាប់នារីវ័យចំណាស់ ( ក្រាហ្វិក ៤.៩) ។

អត្រាអក្ខរកម្មជាក់ស្តែងអាចនឹងទាបជាងតួរលេខបង្ហាញនៅក្នុងក្រហ្វិក ៤.៩ ។ ការប៉ាន់ប្រមាណនាពេលថ្មីៗនេះ បង្ហាញឱ្យឃើញថា បុរសចំនួន ២៥ភាគរយ និងនារីចំនួន ៤៥ភាគរយ ( ស្មើនឹង៣៦ ជាទូទៅ) ជាអនក្ខរជនទាំងស្រុង បុរស ២៦ភាគរយ និងនារី ២៨ភាគរយ ( ស្មើនឹង២៧ភាគរយជាទូទៅ) ជាពាក់កណ្តាលអក្ខរជន ។ បូកផ្នែកទាំងពីរបញ្ចូលគ្នាឃើញថា បុរស៥០ភាគរយ និងនារី៧១ភាគរយ នៅកម្ពុជាគឺជាអនក្ខរជន ( UNDP/UNESCO, ឆ្នាំ ២០០០) ។ អត្រាអនក្ខរកម្មខ្ពស់ ជាពិសេស នារីវ័យចំណាស់ ធ្វើឱ្យមានការលំបាកសំរាប់ការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គមនៅកម្ពុជា ។ នារីដែលជាអនក្ខរជន មិនមានលទ្ធភាពចូលរួមចំណែកក្នុងការអភិវឌ្ឍន៏នៅកម្ពុជា និងទទួលបានផលស្មើគ្នា ដូចអ្នកដទៃទៀតឡើយ ។ ពេលថ្មីៗនេះ ផែនការរបស់រដ្ឋាភិបាលដើម្បីកាត់បន្ថយអនក្ខរភាព មិនបានយកចិត្តទុកដាក់លើកម្មវិធីអក្ខរកម្ម សំរាប់នារីវ័យចំណាស់ឱ្យបានគ្រប់គ្រាន់នៅឡើយ ។

**ក្រាហ្វិក ៤.៩: អត្រាអក្ខរកម្ម បែងចែកតាមអាយុ**




ប្រភព: ជំរឿន ឆ្នាំ១៩៩៨

### ៤.១.១១ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ នៅមានកំរិត ជាពិសេសសំរាប់នារី

កម្ពុជា បានដំណើរការយ៉ាងសកម្មនូវកម្មវិធីអប់រំក្រៅប្រពន្ធ័ (NFE) តាំងពីទសវត្សឆ្នាំ១៩៨០ ដែលកម្មវិធីនេះ ដំណើរការដោយនាយកដ្ឋានពិសេសមួយនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ។ ក្នុងកំឡុងទសវត្សឆ្នាំ១៩៩០ ក្រសួង អ.យ.ក ផ្តោតការយកចិត្តទុកដាក់តែលើកម្មវិធីអប់រំក្នុងប្រពន្ធ័ ជាពិសេសការអប់រំជាមូលដ្ឋានដោយមិនយកចិត្តទុកដាក់លើកម្មវិធីអប់រំក្រៅប្រព័ន្ធ ។ ក្នុងឆ្នាំ១៩៩៤ វិនិយោគសរុបក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ មានចំនួនតិចជាង ១ភាគរយ នៃការវិនិយោគទុនសរុបលើវិស័យអប់រំ បើធ្វើការប្រៀបធៀប កំរិតបឋមសិក្សាទទួលបាន ៥៤ភាគរយ និងកំរិតឧត្តមសិក្សាទទួលបាន ១២ភាគរយ (Breden- burg et al, ឆ្នាំ២០០៣) ។

ទោះបីជាវិនិយោគក្នុងការអប់រំក្រៅប្រពន្ធ័ បានកើនឡើងតាំងពីឆ្នាំ១៩៩៦ ជាពិសេស ដោយសារមានមូលនិធិប្រទេសអ្នកផ្តល់ជំនួយ ប៉ុន្តែការវិនិយោគទុនសំរាប់ការអប់រំក្រៅប្រពន្ធ័នេះ មានតែ ៣ភាគរយនៃការវិនិយោគទុនសរុបលើវិស័យអប់រំក្នុងឆ្នាំ១៩៩៩ ។ ការវិនិយោគទុនសាធារណៈលើការអប់រំក្រៅប្រពន្ធ័ មិនមានការអភិវឌ្ឍន៍ឡើយ ក្នុងកំឡុងទសវត្សឆ្នាំ១៩៩០ (Bredenburg et al, ឆ្នាំ២០០៣) ។ ក្នុងកំឡុងពេលនោះ តួនាទីរបស់រដ្ឋាភិបាលគឺការសំរបសំរួលនៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ ដែលទទួលការឧបត្ថម្ភ និងដំណើរការដោយអង្គការក្រៅរដ្ឋាភិបាល ។ កម្មវិធីនេះ បើកចំហរដល់អនក្ខរជនពេញវ័យទាំងពីរភេទ ប៉ុន្តែការអនុវត្តន៍ជាក់ស្តែង សិស្សភាគច្រើនជានារី និងយ៉ាងហោចណាស់ សិស្សចំនួន១ភាគ៤ មានវ័យក្មេងដែលមានអាយុ តិចជាង១៨ឆ្នាំ (Desiree Jongsma, ឆ្នាំ២០០៣, ការទំនាក់ទំនងពតិមានផ្ទាល់ខ្លួន) ។

តាមការប៉ាន់ប្រមាណរបស់ ILO អំពីយេនឌ័រ និងការបង្កើនការងារ (Urashima, ឆ្នាំ២០០២) បង្ហាញឱ្យឃើញថា ទំហំ និងវិសាលភាពដែលមានកំរិត នៅក្នុងការបណ្តុះបណ្តាលជំនាញនៅទូទាំងប្រទេស មានផលប៉ះពាល់ដល់នារីយ៉ាងធ្ងន់ធ្ងរ ។ ទោះបីជាមជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ ផ្តោតគោលដៅផ្តល់ការបណ្តុះបណ្តាលដល់នារី ហើយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានផ្តោតការយកចិត្តទាក់ដាក់ជាពិសេសលើក្រុមនារីងាយរងគ្រោះ (ឧ. ដោយសារអំពើហឹង្សាក្នុងគ្រួសារ គ្មានផ្ទះសំបែង អ្នកលក់ដូរតូចតាច ។ល ។ ប៉ុន្តែទំហំនៃកម្មវិធីទាំងនេះ នៅមានកំរិត ។ ភាគច្រើននៃជំនាញដែលផ្តល់ គឺជាជំនាញប្រពៃណី "នារី" (ឧ. កាត់ដេរ អ៊ុតសក់ ត្បាញ) ។ ការបណ្តុះបណ្តាលភាគច្រើន ដំណើរការនៅក្នុងមជ្ឈមណ្ឌល ដូច្នេះធ្វើឱ្យនារីភាគច្រើនមានការលំបាកក្នុងការមកចូលរួមការបណ្តុះបណ្តាល ។ កំរិតនៃការចេះអក្សរ និងការអប់រំទាប គឺជាឧបសគ្គធ្វើឱ្យនារីមិនអាចចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល ។ កម្មវិធីអក្ខរកម្ម កំរនឹងត្រូវបានគេដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញណាស់ (ILO, ឆ្នាំ២០០១) ។

## ៤.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

ក្នុងកំឡុងឆ្នាំ ១៩៩៩ ដល់ ២០០២ ក្រសួងអ.យ.ក បានបង្កើតក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រលើវិស័យអប់រំ ដោយមានអាទិភាពអភិវឌ្ឍន៍តាមវិស័យទូទៅ គោលដៅអនុវិស័យ និងផែនការចំណាយរយៈពេលមធ្យម លើវិស័យអប់រំ សំរាប់ឆ្នាំ២០០១-២០០៥។ ក្រសួងអ.យ.ក បានបង្កើតផែនការយុទ្ធសាស្ត្រអប់រំ (ESP) ឆ្នាំ២០០១-២០០៥ និងកម្មវិធីគាំទ្រវិស័យអប់រំ (ESSP) ឆ្នាំ២០០២-២០០៦ ដោយមានការពិនិត្យឡើងវិញ និងវាយតំលៃដោយអ្នកពាក់ពន្ធ័ផ្សេងៗ។ នាពេលថ្មីៗនេះ រដ្ឋាភិបាលក៏បានរៀបចំផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥ ដែលបានផ្សព្វផ្សាយនៅខែមិថុនា ឆ្នាំ២០០៣។

កម្មវិធីគាំទ្រវិស័យអប់រំ ផ្តោតលើការធ្វើកំណែទម្រង់សំខាន់ៗ លើកម្មវិធីសកម្មភាពជាអាទិភាពចំនួន ១២ (PAP) ក្នុងគោលបំណងបង្កើនឱកាសទទួលបានការអប់រំ សំរាប់ក្រុមដែលងាយរងគ្រោះទាំងអស់។ កម្មវិធី PAP ផ្តោតលើការជួយប្រជាជនក្រីក្រ និងបង្ហាញឱ្យឃើញនូវការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការឆ្លើយតបទៅនឹងបញ្ហាផ្តល់ជូន និងតម្រូវការក្នុងការសិក្សា និងការកាត់បន្ថយភាពក្រីក្រ (Bredenburg et al, ឆ្នាំ២០០៣)។ ប៉ុន្តែកម្មវិធីទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាឱកាសទទួលបានការអប់រំជាទូទៅ មិនបានសំដៅលើអតុល្យភាពយេនឌ័រក្នុងការទទួលបានការអប់រំជាពិសេសក្មេងស្រីឡើយ។ ក្រសួងចាត់ទុកបញ្ហាយេនឌ័រជាបញ្ហាអន្តរវិស័យនៅក្នុងគ្រប់វិស័យទាំងអស់ និងបានបញ្ចូលបញ្ហាយេនឌ័រ ទៅក្នុងផែនការជាតិកម្មវិធីអប់រំសំរាប់ទាំងអស់គ្នា (Bredenburg et al, ឆ្នាំ២០០៣)។ នៅឆ្នាំ២០០១ ក្រសួង អ.យ.ក បានបង្កើនក្រុមការងារយេនឌ័រ ដើម្បីធ្វើការសំរបសំរួលយ៉ាងជិតស្និទ្ធជាមួយអ្នកផ្តល់ជំនួយ និងដៃគូសហការអង្គការក្រៅរដ្ឋាភិបាល។ ក្រុមការងារយេនឌ័របានបង្កើនយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ រួមមាន៖

- ធានានូវឱកាសស្មើគ្នាក្នុងការទទួលបានការសិក្សាសំរាប់ក្មេងស្រី
- បង្កើនសមធម៌យេនឌ័រក្នុងការគ្រប់គ្រង និងការចែកចាយសេវាអប់រំ និង
- ពង្រឹងសមត្ថភាពបច្ចេកទេស ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងការរៀបចំកម្មវិធី និងគោលនយោបាយអប់រំ។

រដ្ឋាភិបាលទទួលស្គាល់ថា ការអប់រំ គឺជាវិស័យអាទិភាព១ ក្នុងចំណោមវិស័យអាទិភាព៤ (វិស័យផ្សេងៗទៀតគឺសុខាភិបាល អភិវឌ្ឍន៍ជនបទ និងកសិកម្ម) និងបានបង្កើនការវិភាជថវិកាជាប្រចាំសំរាប់វិស័យអប់រំពី ១៣.៦ភាគរយ ក្នុងឆ្នាំ២០០០ ទៅ ១៥.៧ភាគរយ ក្នុងឆ្នាំ២០០១ និង ១៨.២ភាគរយ ក្នុងឆ្នាំ២០០២ (ក្រសួង អ.ជ.ក ២០០២b) និងមានគំរោងនឹងបង្កើនបន្ថែមប្រហែល ១ភាគ៥ នៃថវិកាជាប្រចាំ ក្នុងឆ្នាំ២០០៥។

ថវិកាជាប្រចាំសំរាប់ការអប់រំជាមូលដ្ឋាន ត្រូវបានគ្រោងនឹងបង្កើនបន្ថែមទ្វេរដងពី ១៨០ពាន់លានរៀល ក្នុងឆ្នាំ២០០១ ទៅ ៣៧៧ពាន់លានរៀល ក្នុងឆ្នាំ២០០៥ (តារាង៤.១)។ ចំណាយលើការអប់រំជាមូលដ្ឋាន ត្រូវបានគ្រោងក្នុងចំនួនរវាង ៧០ ដល់ ៧៨ភាគរយ នៃចំណាយសរុបលើវិស័យសាធារណៈ ដោយស្របទៅតាមអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រអប់រំ។ ចំណែកថវិកាមិនមែនជាប្រាក់បៀវត្សរ៍របស់វិស័យអប់រំនឹងកើនពី ២៦ភាគរយ ទៅ ៤២ភាគរយ ក្នុង រវាងឆ្នាំ ២០០១ ដល់ ២០០៥។ ចំណុចសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានដល់ផែនការយុទ្ធសាស្ត្រអប់រំ គឺការបង្កើនទំហំ និងចំណែកនៃចំណាយមិនមែនជាប្រាក់បៀវត្សរ៍ ក្នុងការធានាឱ្យបាននូវការរីកចំរើន ជានិរន្តរនូវគុណភាពនៃការអប់រំ។

**តារាង ៤.១: ការបែងចែកចូលនិធិថវិកាសាធារណៈ តាមអនុវិស័យ (គិតជា១០០០លានរៀល)**(BILLION *RIELS*)

| | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ |
|---|---|---|---|---|---|
| រដ្ឋបាល | ៣៣.៦ | ៤២.០ | ៥១.៣ | ៦១.២ | ៧៤.០ |
| មត្តេយ្យសិក្សា | ៣.៥ | ៤.២ | ៥.០ | ៦.០ | ៧.១ |
| អប់រំជាមូលដ្ឋាន | ១៨០.២ | ២៦៦.៦ | ៣២៧.៥ | ៣៥៦.៣ | ៣៧៦.៨ |
| ចំណាយលើប្រាក់បៀវត្សរ៍ | ១៣៣.៨ | ១៧៩.៨ | ១៩៩.៤ | ២១០.៤ | ២១៩.១ |
| មិនមែនជាប្រាក់បៀវត្សរ៍ (រួមទាំងការប្រឡង) | ៤៦.៤ | ៨៦.៨ | ១២៨.១ | ១៤៦.០ | ១៥៧.៧ |
| មធ្យមសិក្សាទុតិយភូមិ | ១៤.៣ | ១៧.៣ | ៣២.០ | ៤៤.០ | ៦៥.០ |
| ថ្នាក់ក្រោយមធ្យមសិក្សា | ១២.២ | ១៣.៣ | ១៤.៤ | ១៥.៩ | ១៧.៩ |
| Total | **២៤៣.៨** | **៣៤៣.៥** | **៤៣០.២** | **៤៨៣.៤** | **៥៤០.៩** |

**ប្រភព:** ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៦

## យុទ្ធសាស្ត្រសំរាប់បង្កើនការអប់រំជាមូលដ្ឋាន:

- កាត់បន្ថយចំណាយរបស់ឪពុកម្តាយសិស្សលើការអប់រំជាមូលដ្ឋាន ដោយលុបបំបាត់ការបង់ថ្លៃ ចំពោះការចុះឈ្មោះចូលរៀន និងការផ្តល់ថវិកាដំណើរការសាលារៀន។ យុទ្ធសាស្ត្រនេះ ត្រូវបានអនុវត្តតាំងពីខែតុលា ឆ្នាំ២០០១ ប៉ុន្តែដូចដែលបានរៀបរាប់រួចមកហើយថា ក្នុងការអនុវត្តន៍ជាក់ស្តែង មិនអាចចៀសផុតពីការចំណាយផ្លូវការ និងក្រៅផ្លូវការមួយចំនួនឡើយ។
- បង្កើនអត្រាឡើងថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ទី៦ និងអត្រាឆ្លងភូមិសិក្សាពីទី៦ ទៅទី៧ តាមរយៈការបើកថ្នាក់បំប៉នពង្រឹងវិធានការដើម្បីធ្វើឱ្យវត្តមានរបស់សិស្ស និងគ្រូកាន់តែប្រសើរឡើង ក្នុងកាលវិភាគសិក្សាមានភាពទន់ភ្លន់ (បត់បែន)។
- កាត់បន្ថយអត្រាសិស្សបោះបង់ចោលការសិក្សា ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ តាមរយៈការមិនគិតថ្លៃ ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្របំផុត និងតាមយុទ្ធសាស្ត្រផ្តល់ការលើកទឹកចិត្តបន្ថែម ឧ.កម្មវិធីផ្តល់អាហារូបត្ថម្ភតាមសាលារៀន និងការថែទាំសុខភាពសិស្ស ដោយរួមជាមួយអង្គការក្រៅរដ្ឋាភិបាល និងអ្នកចូលរួមដទៃទៀត។
- បង្កើនឱកាសក្នុងការចូលរៀនថ្នាក់ទី១ និងបង្កើនឱកាសដល់សិស្សដែលបានបោះបង់ចោលការសិក្សា ឱ្យចូលរៀនថ្នាក់ទី៤ ដល់ថ្នាក់ទី៦ តាមរយៈការបង្កើតថ្នាក់ត្រៀមសំរាប់ចូលរៀនថ្នាក់ទី១ ទូទាំងប្រទេស និងការពង្រីកកម្មវិធីសមាហរណកម្ម។
- សាងសង់ថ្នាក់រៀនថ្មី និងផ្តល់បន្ទប់រៀនបន្ថែម និងដំណើរការបង្រៀនថ្នាក់គួបនៅក្នុងភូមិ និងឃុំ ដែលសាលារៀនមានមិនគ្រប់កំរិតបឋមសិក្សា។

- បង្កើនប្រសិទ្ធិភាពក្នុងការធ្វើផែនការអប់រំ និងការពង្រាយបុគ្គលិកបង្រៀន មិនបង្រៀនតាមរយៈ (១) រដ្ឋាភិបាលបានយល់ព្រមលើបទដ្ឋានបន្ថែមបុគ្គលិកស្របតាមផលធៀបសិស្សគ្រូ និងផលធៀបថ្នាក់គ្រូ (២) សេចក្តីណែនាំអំពីការជ្រើសរើសបុគ្គលិកជំនាញសំរាប់សាលារៀន និង (៣) ពង្រឹងយន្តការអនុវត្តបទដ្ឋាននានា ។ គោលដៅនេះសំដៅកាត់បន្ថយអត្រាផលធៀបសិស្ស-គ្រូ ឱ្យមកនៅត្រឹម ៤៨នាក់ ក្នុងឆ្នាំ២០០៣ ។
- លទ្ធភាពទទួលបានសម្ភារៈផ្គត់ផ្គង់ដែលបានជ្រើសរើស និងសៀវភៅសិក្សាសំខាន់ៗ តាមរយៈការផ្តល់ថវិកាពីរាជរដ្ឋាភិបាលប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ ។
- ធានាការផ្គត់ផ្គង់គ្រូបង្រៀននៅតំបន់ដាច់ស្រយាល និងគ្រប់ជនជាតិភាគតិចឱ្យបានគ្រប់គ្រាន់ តាមរយៈការជ្រើសរើសគរុសិស្សនៅក្នុងតំបន់នោះ ផ្តល់ការលើកទឹកចិត្តជាពិសេស និងល័ក្ខខ័ណ្ឌជ្រើសរើសគរុសិស្ស គរុនិសិត្ស និងរយៈពេលនៃកម្មវិធីបង្រៀន ។

## អន្តរាគមន៍ពិសេស ត្រូវបានរៀបចំឡើងដើម្បីបង្កើនសមភាពយេនឌ័រ

- ដោយសារចម្ងាយផ្លូវទៅសាលា គឺជាឧបសគ្គចំបងសំរាប់ក្មេងស្រី ដូច្នេះការបង្កើនចំនួនសាលារៀន នៅក្នុងតំបន់ជនបទ នឹងអាចបង្កើនចំនួនសិស្សចូលរៀននៅកំរិតមធ្យមសិក្សា ។ ក្រសួងអ.យ.ក មានផែនការសាងសង់អនុវិទ្យាល័យចំនួន ២៨៥ នៅតំបន់ជនបទ ដែលមិនទាន់មានអនុវិទ្យាល័យនៅឡើយ ។ សាលារៀនថ្មីទាំងនេះនឹងអាចទទួលសិស្សថ្មីបានចំនួន ៨៤.០០០នាក់ ក្នុង១ឆ្នាំ ហើយសាលារៀនទាំងនេះ នឹងមិនឆ្ងាយសំរាប់សិស្សទាំងអស់នោះទេ ។ យ៉ាងហោចបំផុតអនុវិទ្យាល័យទាំងនោះ ស្ថិតក្នុងចម្ងាយស្មើគ្នានឹងចម្ងាយទៅសាលាបឋមសិក្សាដែលមាននៅក្នុងតំបន់ជនបទទាំងនោះ ។
- អាហារូបករណ៍ផ្តោតគោលដៅលើក្មេងស្រី ។ កម្មវិធីសាកល្បងមួយ បានដំណើរការក្នុងឆ្នាំ២០០០ ជាកម្មវិធីអាហារូបករណ៍សំរាប់ក្មេងស្រី ទទួលបានជោគជ័យទាំងការបង្កើនការចុះឈ្មោះចូលរៀន និងការនៅរៀនជាប់លាប់ ។ កម្មវិធីនោះគ្រប់គ្រងដោយអង្គការ NGO ក្នុងស្រុក គឺសមាគមកម្ពុជា សំរាប់ការអប់រំនៅបឋមសិក្សា (KAPE) បានឧបត្ថម្ភដល់គ្រួសារក្រីក្រ ដើម្បីអាចបន្តបញ្ជូនកូនចូលរៀនថ្នាក់ក្រោយបឋមសិក្សា ។ ផ្អែកលើជោគជ័យនៅក្នុងកម្មវិធីនេះ ធនាគារអភិវឌ្ឍន៍អាស៊ី សហការជាមួយមូលនិធិជប៉ុនដើម្បីការកាត់បន្ថយភាពក្រីក្រ នឹងជួយក្រសួងអប់រំក្នុងការឧបត្ថម្ភ ដល់ការពង្រីកកម្មវិធីថ្នាក់ជាតិ ផ្តល់អាហារូបករណ៍ដល់ក្មេងស្រី ដល់វិទ្យាល័យចំនួន៧៥ ។ កម្មវិធីនេះ នឹងដំណើរការសាកល្បងនៅក្នុងអនុវិទ្យាល័យចំនួន ១០០ និងពង្រីកទៅគ្រប់អនុវិទ្យាល័យទាំងអស់ក្នុងឆ្នាំ២០០៣ ។ ក្នុងរយៈពេលយូរ (២០០៦-២០១០) នឹងមានសិស្សកាន់តែច្រើនអាចបន្តដល់ថ្នាក់ក្រោយមធ្យមសិក្សា ហើយពេលនោះកម្មវិធី នឹងបន្តគ្របដណ្តប់លើថ្នាក់ក្រោយមធ្យមសិក្សាទៀត ។ កម្មវិធីអាហារូបករណ៍នេះ ទទួលបានការឧបត្ថម្ភពីមូលនិធិជប៉ុនសំរាប់ការកាត់បន្ថយភាពក្រីក្រ ដែលមានទំនាក់ទំនងជាមួយកម្មវិធីវិស័យអប់រំរបស់ ADB ។ លើសពីនេះ មានកម្មវិធីអាហារូបករណ៍ទ្រង់ទ្រាយតូចមួយចំនួនទៀតដំណើរការ (នៅក្រៅក្រសួងអ.យ.ក) ដោយ UNICEF, CARE និងសមាគមកម្ពុជាសំរាប់ការអប់រំនៅបឋមសិក្សា (KAPE) ។

- វិទ្យាល័យដែលមានស្រាប់ចំនួន ៤៥កន្លែង នឹងត្រូវបានពង្រីកបន្ថែម ដើម្បីទទួលសិស្សមកពីតំបន់ជនបទ។ ទោះបីជាមិនទាន់មានការធ្វើគំរោងពិស្តារជាក់លាក់ និងធ្វើគំរោងអំពីតំលៃចំណាយក៏ដោយ ក៏ផែនការនេះមានគំរោងនឹងឧបត្ថម្ភដល់ការធ្វើដំណើរ និងការស្នាក់នៅសំរាប់សិស្ស។ ដោយសារបញ្ហាចម្ងាយផ្លូវគឺជាឧបសគ្គចំបងដល់ការសិក្សារបស់ក្មេងស្រី ការបង្កើនចំនួនថ្នាក់រៀនអាចនឹងមិនជួយធ្វើឱ្យស្ថានភាពរបស់ក្មេងស្រីបានល្អប្រសើរឡើយ។

ដើម្បីឆ្លើយតបទៅនឹងសមធមិយេនឌ័រក្នុងឆ្នាំ២០០១ ក្រសួងអ.យ.ក បានបង្កើតការិយាល័យកម្មវិធីអប់រំពិសេសនៅក្នុងនាយកដ្ឋានមត្តេយ្យសិក្សា និងបឋមសិក្សា។ ការិយាល័យនេះមានតួនាទីទទួលខុសត្រូវ ក្នុងការលើកកំពស់ឱកាសទទួលបានការសិក្សាស្មើគ្នាសំរាប់ក្មេងស្រី ជនជាតិភាគតិច ប្រជាជនក្រីក្រ និងជនពិការ។

កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០១ បានបញ្ចូលកម្មវិធីអប់រំក្រៅប្រពន្ធ័ពីរដាច់ដោយឡែកពីគ្នាៈ ការអប់រំក្រៅប្រពន្ធ័ជាធម្មតា និងកម្មវិធីរយៈពេលខ្លី មានគោលបំណងបញ្ជូនសិស្សដែលបោះបង់ចោលការសិក្សា ថ្នាក់ទី៤ ដល់ទី៦ មកចូលរៀននៅក្នុងការអប់រំក្នុងប្រពន្ធ័វិញ។ លើសពីនេះ នាយកដ្ឋានអប់រំក្រៅប្រពន្ធ័ មានផែនការពង្រឹងសមត្ថភាពដល់ប្រពន្ធ័សិក្សា ដោយការបណ្តុះបណ្តាលគ្រូបង្រៀន និងត្រួតពិនិត្យកម្មវិធីទាំងពីរនេះ។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានថវិកាសំរាប់កម្មវិធីក្នុងឆ្នាំ២០០១ទេ ហើយកម្មវិធី ESSP ឆ្នាំ២០០២ បានពិនិត្យកែលំអឡើងវិញលើគោលដៅ និងថវិការបស់កម្មវិធី។ នៅក្នុងកម្មវិធីអប់រំក្រៅប្រពន្ធ័ ក្រសួងអ.យ.ក មានផែនការបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតំបន់ជនបទ និងបង្កើតមជ្ឈមណ្ឌលរៀនសូត្រនៅតាមសហគមន៍ ដោយផ្តល់ថ្នាក់អក្ខរកម្មដល់មនុស្សពេញវ័យ (Bredenburg et al., ឆ្នាំ២០០៣)។

# ជំពូកទី ៥

# បញ្ហាយេនឌ័រ ក្នុងវិស័យសុខាភិបាល


កម្ពុជានាពេលបច្ចុប្បន្ន ........ ១១៥

**៥.១ ស្ថានភាព និន្នាការ និង បញ្ហា** ........ ១១៥

៥.១.១ នារីបាត់បង់ឧត្តមភាពនៅក្នុងលទ្ធភាពទទួលបានសេវាសុខភាពជាមូលដ្ឋាន ........ ១១៧

៥.១.២ លទ្ធភាពទាបក្នុងការទទួលបានសេវាសុខភាព មានទំនាក់ទំនងជិតស្និទទៅនឹងភាពក្រីក្រ និងការអប់រំរបស់នារី ........ ១១៧

៥.១.៣ អត្រាមរណភាពមាតានៅកម្ពុជា គឺមានកំរិតខ្ពស់បំផុតនៅក្នុងតំបន់ ........ ១១៩

៥.១.៤ ស្ថានភាពអាហារូបត្ថម្ភរបស់នារី មានកំរិតទាប ........ ១២១

៥.១.៥ តំរូវការផែនការគ្រួសារ និងការពន្យារកំណើតដែលមិនទាន់ឆ្លើយតប នៅតែមានកំរិតខ្ពស់ ........ ១២២

៥.១.៦ នារីមិនបានទទួលការថែទាំក្នុងពេលមានផ្ទៃពោះ និងពេលសំរាលកូនប្រកបដោយសុវត្ថិភាពទេ ... ១២៥

៥.១.៧ កង្វះបុគ្គលិកឆ្មបជំនាញ និងការបែងចែកបុគ្គលិកពេទ្យមិនបានគ្រប់គ្រាន់ ........ ១២៥

៥.១.៨ យុវជនក្មេងៗក្នុងចំនួនច្រើនជាងនារីត្រូវស្លាប់ ឬទទួលគ្រោះថ្នាក់ជាយថាហេតុ ........ ១២៧

៥.១.៩ ពិការភាព និងការញៀនថ្នាំញៀន មានផលប៉ះពាល់លើបុរសច្រើនជាងនារី ........ ១២៧

**៥.២ យុទ្ធសាស្ត្រ និង គោលនយោបាយរបស់រាជរដ្ឋាភិបាល** ........ ១២៨

# ជំពូកទី ៥ : បញ្ហាយេនឌ័រ ក្នុងវិស័យសុខាភិបាល

## កម្ពុជានាពេលបច្ចុប្បន្ន[១]

| សូចនាករ | តំលៃ |
|---|---|
| អត្រាមរណភាពមាតានៅឆ្នាំ១៩៩៤-២០០០ (ក្នុងចំណោម ១០០,០០០ កំណើតរស់) | ៤៣៧ |
| អត្រាមរណភាពទារកនៅឆ្នាំ១៩៩៥-២០០០ (ក្នុង ១០០០ កំណើតរស់) | ៩៥ |
| អត្រាកំណើតសំរាប់នារីម្នាក់ក្នុងឆ្នាំ២០០២ | ៤ |
| អាយុមធ្យមរបស់នារីឆ្នាំ១៩៩៨ (ចំនួនឆ្នាំ) | ៥៨ |
| ការធ្វើវិភាជថវិកា គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុបសំរាប់ការថែទាំសុខភាព ក្នុងឆ្នាំ២០០២ | ១.២ |
| ថវិកាជាតិសំរាប់វិស័យសុខាភិបាល គិតជាភាគរយនៃថវិកាវាជរដ្ឋាភិបាល | ១០.៩ |
| ចំនួនអ្នកជំងឺដែលស្ថិតក្រោមការព្យាបាលរបស់វេជ្ជបណ្ឌិតម្នាក់ ឆ្នាំ១៩៩៨ | ៦,៨០៨ |
| ចំនួនអ្នកជំងឺដែលស្ថិតក្រោមការថែទាំព្យាបាលរបស់បុគ្គលិកសុខាភិបាលម្នាក់ ឆ្នាំ១៩៩៨ | ៥៩៨ |

## ៥.១ ស្ថានភាព និន្នាការ និង បញ្ហា

ការផ្តល់សេវាសុខភាពប្រកបដោយគុណភាពដល់ប្រជាជនកម្ពុជា គឺជាបញ្ហាប្រឈមមុខដ៏ចំបងមួយ ដែលទាក់ទងនឹងកិច្ចអភិវឌ្ឍន៍។ បុរស និងនារី មានអាយុមធ្យមទាប (គឺបុរសមាន ៥៤.៥ឆ្នាំ និងនារីមាន ៥៨.៣ឆ្នាំ) ដែលបណ្តាលមកពីអត្រាមរណភាពទារក និងកុមារមានកំរិតខ្ពស់ អត្រាមរណភាពមាតាមានកំរិតខ្ពស់ និងអត្រាដ៏ខ្ពស់នៃករណីជំងឺដែលអាចបង្ការបានដូចជា ជំងឺគ្រុនចាញ់ និងជំងឺរបេងជាដើម។ ក្នុងចំណោមទារក ១០នាក់ មានទារកម្នាក់ស្លាប់ក្រោមអាយុមួយខួប ហើយកង្វះអាហារូបត្ថម្ភ និងការឈឺថ្កាត់ គឺជាបញ្ហាដែលកើតមានជាទូទៅ។ សេវាសុខភាពដែលមានក្នុងពេលបច្ចុប្បន្ននេះ មិនបានឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាជនទេ ហើយលទ្ធភាពទទួលបានសេវានេះ និងបញ្ហាហិរញ្ញវត្ថុរបស់ប្រជាជនក្រីក្រ នៅតែជាបញ្ហាចំបង (ធនាគារពិភពលោកឆ្នាំ២០០២a)។ តាមលទ្ធផលនៃការវាយតំលៃភាពក្រីក្រនៅកម្ពុជា (ធនាគារពិភពលោក និងក្រសួងផែនការឆ្នាំ១៩៩៩) បានឱ្យដឹងថា មានប្រជាជនក្រីក្រតែ ១២ភាគរយប៉ុណ្ណោះ ដែលទទួលបានការលើកលែងការបង់ថ្លៃសេវាសាធារណៈ បើប្រៀបធៀបជាមួយនឹងក្រុមបញ្ចភាគដែលមានចំណូលខ្ពស់បំផុតមានចំនួន ២៦ភាគរយ។ ចំណាយសំរាប់គ្រួសារគឺមាន ៧៣ភាគរយនៃចំណាយសរុបសំរាប់សុខភាព ដែលជាសមាមាត្រមួយខ្ពស់បំផុតនៅលើពិភពលោក (ផែនការជាយុទ្ធសាស្ត្ររបស់វិស័យសុខាភិបាលឆ្នាំ២០០៣-២០០៧ លេខ១-៤, លេខ៣ នៃក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រសួងសុខាភិបាល)។

---

[១] ប្រភព: ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា ឆ្នាំ២០០០
ជំរឿនប្រជារាស្ត្រទូទៅ ឆ្នាំ១៩៩៨
ក្រសួងសុខាភិបាល ឆ្នាំ២០០៣: ការពិនិត្យឡើងវិញប្រចាំឆ្នាំ លើវិស័យសុខាភិបាល

វិបត្តិសុខភាពអាចបំផ្លាញគ្រួសារក្រីក្រពោលគឺ ក្នុងរយៈពេលកន្លងទៅថ្មីៗនេះ ប្រជាជនចំនួន ៤៦ភាគរយ បានបាត់បង់ដីធ្លីរបស់ខ្លួន ដោយសារតែជំពាក់បំណុលគេ ឬចងការប្រាក់គេយកមកមើលជំងឺ (យោងតាមការអង្កេតដែលត្រូវបានធ្វើឡើងដោយអង្គការ Oxfam កម្ពុជា (Oxfam Cambodia) និងក្រសួងអភិវឌ្ឍន៍ជនបទ នៅឆ្នាំ២០០០) ។ ការបង់ថ្លៃក្រៅផ្លូវការ តំលៃដឹកជញ្ជូន និងឱកាសរកប្រាក់ចំណូល បានធ្វើឱ្យគ្រួសារក្រីក្រកាន់តែបាត់បង់លទ្ធភាពទទួលបានសេវាសុខភាព ។ គុណភាពទាប និងភាពមិនអាចទុកចិត្តបាន នៅតែបន្តរាំងដល់ការប្រើប្រាស់សេវាសុខភាព ។

នៅឆ្នាំ១៩៩៧ ក្រសួងសុខាភិបាល បានអនុវត្តការទូទាត់ថ្លៃប្រើប្រាស់សេវា ក្នុងគោលបំណងកាត់បន្ថយការបង់ថ្លៃក្រៅផ្លូវការ រកចំណូល និងលើកកំពស់គុណភាពសេវា ។ អ្នកជំងឺដែលមិនមានលទ្ធភាពបង់ថ្លៃសេវាសុខភាពត្រូវបានលើកលែងការបង់ថ្លៃសេវានានា ។ តាមការអនុវត្តន៍ជាក់ស្តែងការលើកលែងនេះ នៅពុំទាន់បានអនុវត្តចំពោះប្រជាជនក្រីក្រទូទៅទេ ហើយការបង់ថ្លៃក្រៅផ្លូវការនៅតែពុំទាន់បានលុបបំបាត់ចោល សូម្បីតែនៅតាមមន្ទីរពេទ្យ ដែលមានការត្រួតពិនិត្យយ៉ាងជិតដល់ក៏ដោយ ។ លើសពីនេះទៀតមានការព្រួយបារម្ភថា ប្រព័ន្ធបង់ថ្លៃសេវា បានធ្វើឱ្យបុគ្គលិកបង្វែរអាទិភាពឆ្ពោះទៅរកអន្តរាគមន៍ រកប្រាក់ចំណូល ជាជាងប្រសិទ្ធិភាពនៃការព្យាបាលអ្នកជំងឺដូចជា ការថែទាំបង្ការជាដើម (Medecins San Frontier ឆ្នាំ២០០០) ។ បញ្ហាមួយទាក់ទងនឹងប្រព័ន្ធនេះគឺ សិទ្ធិទទួលបានការលើកលែងការបង់ថ្លៃសេវា អាស្រ័យទៅលើបុគ្គលិក មន្ទីរពេទ្យជាអ្នកសំរេច ដែលបានចាត់ទុកការលើកលែងការបង់ថ្លៃនេះថា ជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់មន្ទីរពេទ្យ ។

នារីខ្មែរប្រឈមមុខនឹងបញ្ហាសុខភាពបន្តពូជ នារីខ្មែរទំនងជាមិនទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ ហើយទំនងជាងាយឆ្លងមេរោគហ៊ីវច្រើនជាងបុរស ។ លើសពីនេះទៀត មានភ័ស្តុតាងកាន់តែច្រើនឡើងដែលបញ្ជាក់ថា នារីក្នុងអត្រាមួយដ៏ខ្ពស់ងាយទទួលរងគ្រោះដោយអំពើហឹង្សាគ្រប់ប្រភេទ ។ ភ័ស្តុតាងក៏បានបង្ហាញផងដែរថា បុរសមានលទ្ធភាពច្រើនជាងនារីក្នុងការទទួលបានការថែទាំសុខភាព ហើយថវិកាជាច្រើនរបស់គ្រួសារ ត្រូវបានចំណាយទៅលើការថែទាំសុខភាពរបស់បុរសច្រើនជាងនារី ទោះបីជាតំរូវការផ្នែកសុខភាពរបស់នារីមានខ្ពស់ជាងបុរស ព្រោះថា នារីមានតំរូវការបន្ថែមទៀតក្នុងការថែទាំសុខភាពបន្តពូជរបស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ តំរូវការរបស់នារីនៅតែមានទំហំធំធេង ជាងបុរស ទោះបីជាបុរសអាចប្រឈមមុខនឹងបញ្ហាសុខភាពមួយចំនួន ដូចជា ជំងឺគ្រុនចាញ់ និងគ្រោះថ្នាក់ផ្សេងទៀតក៏ដោយ ។ ទំនាក់ទំនងរវាងបញ្ហាសុខភាពរបស់បុរស និងនារី មានទំនាក់ទំនងនឹងតួនាទីរបស់យេនឌ័រ ដូចដែលបានកំណត់ សំរាប់បុរស និងនារី នៅកម្ពុជា និងឋានៈទាបរបស់នារីនៅក្នុងគ្រួសារ ។ ផ្នែកនេះ ពិភាក្សាលើបញ្ហាយេនឌ័រទាក់ទងនឹងការថែទាំសុខភាព ។ គួរកត់សំគាល់ថា ទិដ្ឋភាពយេនឌ័រទាក់ទងនឹងជំងឺអេដស៍ និងអំពើហឹង្សាក្នុងគ្រួសារ ត្រូវបានលើកយកមកពិភាក្សានៅក្នុងជំពូកដោយឡែកពីគ្នាពីព្រោះថា គេត្រូវពិនិត្យមើលឱ្យបានល្អិតល្អន់ ដោយហេតុថា បញ្ហាទាំងនេះ ពុំមែនតែជាបញ្ហាសុខភាពមួយមុខប៉ុណ្ណោះទេ ។

## ៥.១.១ នារីបាត់បង់ឱកាសច្រើនជាងក្នុងលទ្ធភាពទទួលបានសេវាសុខភាពជាមូលដ្ឋាន

នៅកម្ពុជា លទ្ធភាពទទួលបានសេវាសុខភាពជាមូលដ្ឋាន គឺជាបញ្ហាភាពក្រីក្រផង និងបញ្ហាយេនឌ័រផង។ សេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យលើចំណាយសាធារណៈ នៅក្នុងវិស័យសុខាភិបាលបានឱ្យដឹងថា បុរសទទួលបានផលប្រយោជន៍ច្រើនជាងនារី ពីការចំណាយលើសុខភាព (ធនាគារពិភពលោក ឆ្នាំ២០០២ b)។ នៅកម្ពុជា អត្រាប្រើប្រាស់សេវាវេជ្ជសាស្ត្រ និងចំណាយទៅលើបញ្ហាសុខភាពសំរាប់បុរស និងនារី គឺប្រហាក់ប្រហែលគ្នា។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រសិនបើពិចារណាទៅលើការថែទាំសុខភាពបន្តពូជ តំរូវការថែទាំសុខភាពរបស់នារី គឺមានទំហំធំធេងជាងបុរស។ ហេតុដូច្នេះ អត្រាប្រើប្រាស់ និងចំណាយស្មើគ្នាបង្ហាញឱ្យឃើញថា នារី ទទួលបានផលប្រយោជន៍ផ្នែកសុខភាពតិចជាងបុរស។

តាមការវាយតំលៃភាពក្រីក្រដែលមានការចូលរួម បានឱ្យដឹងថា មានភាពលំអៀងផ្នែកយេនឌ័រ នៅក្នុងរបៀបដែលសហគមន៍ក្រីក្រធ្វើការដោះស្រាយបញ្ហាសុខភាពរបស់នារី។ អ្នកចូលរួមសំភាសន៍មួយចំនួនបាននិយាយថា ប្រសិនបើបុរសក៏ឈឺ ហើយនារីក៏មានជំងឺ គ្រួសារទំនងជាបញ្ជូនបុរសទៅមន្ទីរពេទ្យជាជាងបញ្ជូននារី ពីព្រោះថា នារីត្រូវនៅចាត់ចែងក្នុងគ្រួសារ (ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០០១)។

> *"យើងមិនអាចធ្វើអ្វីបានដោយគ្មានស្ត្រីនៅក្នុងគ្រួសារឡើយ ទោះបីស្ត្រីមានជំងឺជាទំងន់ក៏ដោយ ពីព្រោះស្ត្រីជាអ្នកមេផ្ទះ... ។ ប៉ុន្តែយើងក៏មិនចង់បញ្ជូននរណាម្នាក់ទៅមន្ទីរពេទ្យដែលនៅឆ្ងាយនោះឡើយ ពីព្រោះទីកន្លែងទាំងនោះក៏មិនល្អដែរ"* ។សំដីរបស់បុរសម្នាក់ រស់នៅខេត្តរតនៈគិរីដែលបានលើកឡើងនៅក្នុងរបាយការណ៍វាយតំលៃភាពក្រីក្រដែលមានការចូលរួម (ADB ឆ្នាំ២០០១)។

## ៥.១.២ លទ្ធភាពទាបក្នុងការទទួលបានសេវាសុខភាព មានទំនាក់ទំនងជិតស្និទ្ធនៅនឹងភាពក្រីក្រ និងការអប់រំរបស់នារី

តាមការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា (CDHS ឆ្នាំ២០០០) នារីជាង ៩៥ភាគរយ ត្រូវបានរាយការណ៍ថា មានបញ្ហាមួយ ឬច្រើនទាក់ទងនឹងលទ្ធភាពទទួលបានការថែទាំសុខភាពរបស់ពួកគេ។ បញ្ហាទូទៅបំផុតនោះ គឺការគ្មានលទ្ធភាពបង់ថ្លៃសេវាថែទាំសុខភាព (តាមការអង្កេតមាននារីចំនួន ៨៨ភាគរយ)។ ចំណាយទាំងនេះ រួមមានថ្លៃប្រើប្រាស់សេវា និងចំណាយមិនផ្ទាល់មួយចំនួនទៀត ដូចជា ការចំណាយលើការធ្វើដំណើរជាដើម។ ចំងាយទៅមណ្ឌលសុខភាព និងចំណាយលើថ្លៃធ្វើដំណើរត្រូវបាននារីជាង ៤០ភាគរយ ដែលបានចូលរួមអង្កេតកន្លងមក ចាត់ទុកថា ជាឧបសគ្គចំពោះពួកគេ។ ក្នុងចំណោមនារីដែលប្រើប្រាស់សេវាថែទាំសុខភាព មាននារី ៨០ភាគរយ បានប្រើប្រាស់ប្រាក់សន្សំ ចងការប្រាក់ពីអ្នកដទៃ ឬលក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដើម្បីបង់ថ្លៃសេវាសុខភាព។ តាមការអង្កេតមួយដែលត្រូវបានធ្វើឡើងនៅឆ្នាំ២០០០ បានឱ្យដឹងថា ប្រជាជនប្រមាណ ៤៦ភាគរយ បានបាត់បង់ដីធ្លីរបស់ខ្លួន ក្នុងរយៈពេលកន្លងទៅថ្មីៗនេះ ដោយសារជំពាក់បំណុលគេពោលគឺ ចងការប្រាក់ពីអ្នកដទៃ យកទៅបង់ថ្លៃសេវាសុខភាពរបស់ពួកគេ (ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងគ្រប់គ្រងដែនដី នគររូបនីយកម្ម និងសំណង់ និងអង្គការ Oxfam និងគណៈកម្មការសហប្រតិបត្តិការកម្ពុជា ហៅកាត់ថា CCC)។

នារីក្រីក្រភាគច្រើន មានលទ្ធភាពទាបក្នុងការទទួលបានសេវាសុខភាព នៅមុន និងក្នុងអំឡុងពេលមានផ្ទៃពោះ និងពេលសំរាលកូន។ នារីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រ ទទួលបានសេវាថែទាំសុខភាពពីបុគ្គលិកពេទ្យជំនាញ ក្នុងពេលសំរាលកូន តិចជាងនារីនៅក្នុងគ្រួសារធូរធារប្រមាណ ៤ដងកន្លះ ដែលធ្វើឱ្យពួកគេប្រឈមមុខនឹងគ្រោះថ្នាក់នៃការស្លាប់ក្នុងកំរិតខ្ពស់ (ក្រាហ្វិក ៥.១) ។ នារីនៅក្នុងគ្រួសារក្រីក្រ ទទួលបានការថែទាំតិចតួច ទាំងនៅក្នុងទីក្រុង និងនៅជនបទ (CDHS ឆ្នាំ២000) ។ ការចំណាយគឺជាឧបសគ្គចំបង ក្នុងការប្រើប្រាស់សេវាថែទាំសុខភាព។

**ក្រាហ្វិក ៥.១: លទ្ធភាពទទួលបានសេវាថែទាំសុខភាពរបស់នារី តាមកំរិតនៃប្រាក់ចំណូល**




**ប្រភព:** National Health Survey, ឆ្នាំ១៩៩៨

នារីដែលមានកំរិតសិក្សាទាប ទំនងជាទទួលបានសេវាថែទាំសុខភាពតិចតួច ជាពិសេសសេវាថែទាំរក្សាគភ៌ និងជំនួយពីបុគ្គលិកពេទ្យដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ក្នុងពេលសំរាលកូន (ក្រាហ្វិក ៥.២) ។ នារីភាគច្រើនដែលមិនបានរៀនសូត្រសោះបាននិយាយថា ការចំណាយគឺជាឧបសគ្គមួយក្នុងការប្រើប្រាស់សេវាថែទាំសុខភាព (CDHS ឆ្នាំ២000) ។ នារីប្រហែលពាក់កណ្តាល ក្នុងចំណោមនារីដែលបានចូលរួមក្នុងការអង្កេត ហើយដែលមានកំរិតសិក្សាត្រឹមថ្នាក់បឋមសិក្សា បានរាយការណ៍ថា ចំណាយលើការធ្វើដំណើរ គឺជាបញ្ហាមួយសំរាប់ពួកគេ បើប្រៀបធៀបជាមួយនឹងនារីចំនួន ១/៤ (មួយភាគបួន) ដែលមានកំរិតសិក្សាត្រឹមមធ្យមសិក្សា ឬក៏លើសពីនេះ។

**ក្រាហ្វិក ៥.២: លទ្ធភាពទទួលបានសេវាសុខភាព នៅតាមកម្រិតសិក្សារបស់នារី**




ប្រភព: CDHS, ឆ្នាំ២០០០

## ៥.១.៣ អត្រាមរណភាពមាតានៅកម្ពុជា គឺមានកម្រិតខ្ពស់បំផុតនៅក្នុងតំបន់

តាមការប្រៀបធៀបអត្រាមរណភាពមាតានៅកម្ពុជា ជាមួយនឹងប្រទេសជិតខាង បានបង្ហាញថា នារីខ្មែរភាគច្រើន ប្រឈមមុខនឹងគ្រោះថ្នាក់ដល់ជីវិតក្នុងកម្រិតមួយខ្ពស់ ដែលបណ្តាលមកពីការមានផ្ទៃពោះ និងបញ្ហាផ្សេងទៀត ដែលទាក់ទងនឹងការសំរាលកូន (ក្រាហ្វិក ៥.៣) ។ នារីខ្មែរប្រមាណជា ២.០០០នាក់ ស្លាប់បាត់បង់ជីវិតជារៀងរាល់ឆ្នាំ ដោយសារការមានផ្ទៃពោះ និងបញ្ហាដែលទាក់ទងនឹងការសំរាលកូន (ការប៉ាន់ស្មានដោយផ្អែកលើអត្រាមរណភាពមាតា និងអត្រាកំណើតមិនគ្រប់ខែ) រួមទាំងការស្លាប់ដែលបណ្តាលមកពីការរំលូតកូន ការធ្លាក់ឈាម និងជំងឺព្រាយក្រឡាភ្លើង ។ ការស្លាប់ភាគច្រើន គឺបណ្តាលមកពីបុព្វហេតុដែលអាចបង្ការ ឬទប់ស្កាត់បាន ហើយការស្លាប់នេះ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើចំណូល និងសុខុមាលភាពរបស់គ្រួសារ ។ ក្នុងរយៈពេល ៧ឆ្នាំ មុនពេលមានការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០០ ក្នុងចំណោមនារីខ្មែរ ៥នាក់ដែលស្លាប់បាត់បង់ជីវិត មានម្នាក់ស្លាប់ដោយសារបញ្ហាទាក់ទងនឹងការមានផ្ទៃពោះ ឬការសំរាលកូន ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ អត្រាមរណភាពមាតានៅកម្ពុជាបានធ្លាក់ចុះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏អត្រានេះនៅតែមានកម្រិតខ្ពស់ដដែល ដោយតាមការប៉ាន់ស្មានក្នុងចំណោមនារីចំនួន ១០០.០០០នាក់ ដែលបានផ្តល់កំណើតដល់ទារក មាននារីចំនួន ៤៣៧នាក់ បានស្លាប់ ។ មរណភាពមាតា គឺជាសូចនាករដ៏សំខាន់បំផុតមួយទាក់ទងនឹងសុខភាពនារី ។ សូចនាករនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីលទ្ធភាពទទួលបាន និងវត្តមានសេវាសុខភាព ដែលមានទំនាក់ទំនងជាមួយនឹងកម្រិតវប្បធម៌របស់នារី និងផ្តល់នូវពតិមានយ៉ាងទូលំទូលាយ ទាក់ទងនឹងការបែងចែងធនធានរបស់រដ្ឋ និងធនធានរបស់គ្រួសារសំរាប់ការថែទាំសុខភាពរបស់នារីជាពិសេស សេវាថែទាំបង្ការ ។ នៅកម្ពុជា អត្រាមរណភាពមាតាក្នុងកម្រិតមួយខ្ពស់ ក៏បង្ហាញឱ្យឃើញថា ការយកចិត្តទុកដាក់ និងការឱ្យតំលៃទៅលើសុខភាពរបស់នារី នៅមានកម្រិតទាប ។

ទិន្នន័យស្តីពីអត្រាមរណភាពមាតា មិនទាន់ទទួលបានពីតាមខេត្តនៅឡើយទេ។ ប៉ុន្តែនារីដែលរស់នៅតាមសហគមន៍ក្នុងតំបន់ដាច់ស្រយាល និងនៅតាមជនបទ ប្រឈមមុខនឹងគ្រោះថ្នាក់ស្លាប់ក្នុងពេលមាតុភាពក្នុងកំរិតមួយខ្ពស់ ដោយសារនៅក្នុងតំបន់ទាំងនេះ ពុំសូវមានសេវាសុខភាពទេ។

ជំនឿប្រពៃណីទាក់ទងនឹងការមានផ្ទៃពោះ ការសំរាលកូន និងការថែទាំទារកនិងកុមារ ជួនកាលសង្កត់ធ្ងន់ទៅលើការអនុវត្តន៍តាមទំនៀមទំលាប់ប្រពៃណី ដែលទំនៀមទំលាប់មួយចំនួន អាចបង្កឱ្យមានគ្រោះថ្នាក់។ គ្រួសារយល់ថាការមានផ្ទៃពោះ និងការសំរាលកូនគឺជារឿងធម្មតា ដូច្នេះគ្រួសារមិនយកចិត្តទុកដាក់ជាពិសេស ឬក៏ខ្វល់ខ្វាយអ្វីឡើយ។ នារីភាគច្រើន នៅតែធ្វើការងារច្រើនម៉ោង ក្នុងពេលមានផ្ទៃពោះ និងក្រោយពេលសំរាលកូនរួច ដោយជារឿយៗត្រូវលើកវត្ថុធ្ងន់ៗ ឬធ្វើការងារដែលត្រូវបញ្ចេញកំលាំងពលកម្មខ្លាំងក្លាទៀតផង។ ជំនឿប្រពៃណី ក៏បានរារាំងនារីមិនឱ្យប្រើប្រាស់សេវាថែទាំរក្សាគភ៌ និងការជួយជ្រោមជ្រែងពីគ្រូពេទ្យជំនាញក្នុងពេលសំរាលកូន។ ពុំទាន់មានការសិក្សាស្រាវជ្រាវឱ្យបានច្បាស់លាស់ ទៅលើជំនឿប្រពៃណីទាំងនេះទេ ដូច្នេះការស្រាវជ្រាវបន្ថែម ប្រហែលជាអាចផ្តល់នូវពត៌មានបន្ថែម ទាក់ទងនឹងមូលហេតុនៃការនិយមទៅលើការថែទាំសុខភាពតាមក្បួនបុរាណ។

### ក្រាហ្វិក ៥.៣: ការប្រៀបធៀបអត្រាមរណ:ភាពមាតា និងទារកនៅក្នុងតំបន់




**ប្រភព:** ធនាគារពិភពលោក ឆ្នាំ២០០២: បញ្ហាយេនឌ័រនៅក្នុងការធ្វើផែនការ និងការចំណាយ

ក្រៅពីជំនឿប្រពៃណី កត្តាផ្សេងទៀតដូចជា គុណភាពទាបនៃសេវាថែទាំសុខភាព ស្ថានភាពមិនល្អនៃផ្លូវថ្នល់នៅជនបទ និងកង្វះមធ្យោបាយដឹកជញ្ជូន ព្រមទាំងកង្វះលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ បានរួមចំណែកធ្វើឱ្យអត្រាមរណភាពមាតាមានកំរិតខ្ពស់។ នៅផ្នែកបន្តបន្ទាប់នេះ គេបានពិនិត្យមើលបុព្វហេតុផ្ទាល់មួយចំនួនទៀតដូចជា កង្វះអាហារូបត្ថម្ភរបស់នារី ជាពិសេស ក្នុងអំឡុងពេលមានផ្ទៃពោះ និងអំឡុងពេលបំបៅដោះកូន កង្វះលទ្ធភាពទទួលបានសេវាពន្យារកំណើត និងពត៌មានទាក់ទងនឹងការធ្វើផែនការគ្រួសារ ការផ្គត់ផ្គង់ និងសេវាព្រមទាំងកង្វះលទ្ធភាពទទួលបានសេវាសុខភាពមាតា និងសេវាដែលមានគុណភាព។

## ៥.១.៤ ស្ថានភាពអាហារូបត្ថម្ភរបស់នារី មានកំរិតទាប

អង្កេតប្រជាសាស្ត្រ និងសុខភាព (CDHS ឆ្នាំ២០០០) បានធ្វើការវិភាគទៅលើស្ថានភាពអាហារូបត្ថម្ភរបស់នារី ដោយពិនិត្យមើលការទទួលទានមីក្រូជីវជាតិ ឬកង្វះអាហារូបត្ថម្ភទូទៅ (ក្រាហ្វិក ៥.៤)។ យោងតាមរង្វាស់ទម្ងន់រាងកាយ និងភាគរយនៃនារីដែលក្រិន និង/ឬមានជំងឺស្លេកស្លាំង ខ្វះជាតិដែក សមាមាត្រនារីដែលខ្វះអាហារូបត្ថម្ភមានកំរិតខ្ពស់។ តាមការអង្កេតអំពីអាហារូបត្ថម្ភជាតិ ដែលត្រូវបានធ្វើឡើងដោយអង្គការ Hellen Keller អន្តរជាតិ នៅឆ្នាំ២០០១ បានឱ្យដឹងថា ពី ១-៧ភាគរយនៃនារីមានផ្ទៃពោះ និងនារីបំបៅដោះកូន មានជំងឺខ្វាក់មាន់ដែលជារោគសញ្ញាដំបូងនៃកង្វះជីវជាតិ "អា"។ តាមការសិក្សាស្រាវជ្រាវមួយ ដែលត្រូវបានធ្វើឡើងនៅក្នុងខេត្តព្រះវិហារ ក៏បានបង្ហាញឱ្យឃើញផងដែរថា ការចិញ្ចឹមបីបាច់ក្មេងស្រី ខុសពីការចិញ្ចឹមបីបាច់ក្មេងប្រុស ដែលនាំឱ្យក្មេងស្រីប្រឈមមុខនឹងកង្វះអាហារូបត្ថម្ភក្នុងកំរិតមួយខ្ពស់ ទោះបីជាលទ្ធផលនៃការអង្កេតនេះ មិនអាចឆ្លុះបញ្ចាំងទិដ្ឋភាពនៅទូទាំងប្រទេសបានក៏ដោយ (Taylor ឆ្នាំ២០០៣)។ កង្វះអាហារូបត្ថម្ភនៅក្នុងចំណោមនារី និងកុមារ គឺជាលទ្ធផលនៃការទទួលទានអាហារតិចតួចពុំគ្រប់គ្រាន់ និងជំងឺ (ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ឆ្នាំ២០០៣-២០០៧)។ កង្វះអាហារូបត្ថម្ភធ្វើឱ្យមានជំងឺកាន់តែច្រើន ហើយសារធាតុចិញ្ចឹមសរីរាង្គ ត្រូវបានបំផ្លាញចោលក្នុងពេលមានជំងឺ។ សារធាតុចិញ្ចឹមសរីរាង្គរបស់នារី ត្រូវបំផ្លាញចោលក្នុងកំរិតមួយខ្ពស់ ក្នុងអំឡុងពេលមានផ្ទៃពោះ និងពេលសំរាលកូន លុះត្រាតែនារីទទួលអាហារដែលសំបូរជីវជាតិ ទើបអាចបំពេញបានដូចដើមវិញ។

មូលហេតុចំបងដែលនាំឱ្យមានកង្វះអាហារូបត្ថម្ភ រួមមាន អសន្តិសុខស្បៀង (ខ្វះស្បៀងពីរ-បីខែ ក្នុង ១ឆ្នាំ គ្រួសារជាច្រើន មិនមានបាយទទួលទានគ្រប់គ្រាន់) កង្វះលទ្ធភាពប្រើប្រាស់ទឹកស្អាត និងកង្វះអនាម័យ (អាហារមិនស្អាត) និងកង្វះអាហារសំបូរជីវជាតិទទួលទានក្នុងអំឡុងពេលមានផ្ទៃពោះ និងបំបៅដោះកូន។ ទិន្នន័យស្តីពីការប្រើប្រាស់ស្បៀងនៅតាមគ្រួសារនៅកម្ពុជាបង្ហាញថា នារីទំនងជាទទួលទានអាហារដូចជា បាយ ស៊ុត និងត្រី ក្នុងចំនួនមួយតិចជាងរបស់ប្តីពួកគេ ជាពិសេសក្នុងពេលខ្វះខាតស្បៀង។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ សមស្របទៅនឹងលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីការប្រើប្រាស់ស្បៀងនៅតាមគ្រួសារ ដែលត្រូវបានធ្វើឡើង នៅក្នុងប្រទេសផ្សេងទៀតជាច្រើន ដែលបុរសតែងតែទទួលបានអាហារច្រើនជាងនារី ដោយសារនារីមានឋានៈ ក្នុងសង្គមទាបជាងបុរស ព្រមទាំងមានជំនឿថា បុរសត្រូវការអាហារច្រើនជាង ឬថាបុរសធ្វើការខ្លាំងជាងនារី ដូច្នេះពួកគេសមនឹងទទួលរបបអាហារច្រើនជាង។

**ក្រាហ្វិក ៥.៤: ស្ថានភាពអាហារូបត្ថម្ភរបស់នារីសំរាប់សូចនាករមួយចំនួន**




**សំគាល់:** IDA = ជំងឺខ្វះជាតិដែក

**ប្រភព:** ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០ (DHS ឆ្នាំ២០០០)

នៅកម្ពុជា អត្រាកំណើតខ្ពស់ និងឋានៈក្នុងគ្រួសារទាបរបស់នារី ធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភរបស់នារីមានកំរិតទាប ។

## ៥.១.៥ តំរូវការផែនការគ្រួសារ និងការពន្យារកំណើត ដែលមិនទាន់ឆ្លើយតបនៅតែមានកំរិតខ្ពស់

អត្រាកំណើតសរុបនៅតែមានអត្រាខ្ពស់ ទោះបីជាអត្រានេះ បានធ្លាក់ចុះនៅទូទាំងប្រទេសក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះក៏ដោយ ។ ជាមធ្យម នារីម្នាក់មានកូនចំនួន ៤នាក់ ប៉ុន្តែតួលេខនេះ អាចខុសគ្នាជាមួយនឹងតួលេខនៅតាមខេត្ត ។ ឧទាហរណ៍ : អត្រាកំណើតនៅភ្នំពេញ មានការធ្លាក់ចុះយ៉ាងលឿន ប៉ុន្តែនៅតាមខេត្តមួយចំនួន ដូចជារតនៈគីរី និងមណ្ឌលគីរី អត្រាកំណើតមានការកើនឡើង (ផែនការយុទ្ធសាស្ត្រនៃវិស័យសុខាភិបាល ឆ្នាំ២០០៣-២០០៧) (រូបភាព ៥.៥) ។ តាមការអង្កេតប្រជាសាស្ត្រ និងសុខភាព (CDHS) ឆ្នាំ២០០០ បានបង្ហាញថា នារីប្រមាណ ៨ភាគរយ ក្នុងក្រុមអាយុពី ១៥-១៩ឆ្នាំ ដែលបានចូលរួមក្នុងការអង្កេត គឺជាម្តាយ ឬជានារីមានផ្ទៃពោះ ចំណែកនៅខេត្តមណ្ឌលគីរី និងរតនគីរីវិញ មានរហូតដល់ ២០ភាគរយឯណោះ ។

ទោះបីជាមានការរីកចំរើនខ្លះៗ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះក៏ដោយ ក៏លទ្ធភាពប្រើប្រាស់សេវាពន្យារកំណើត នៅមានកំរិតនៅឡើយ ។ មាននារីតែ ២៤ភាគរយប៉ុណ្ណោះ ដែលប្រើប្រាស់មធ្យោបាយពន្យារកំណើត ហើយមាននារីតែ ១៩ភាគរយប៉ុណ្ណោះ ដែលបានប្រើប្រាស់មធ្យោបាយពន្យារកំណើតបែបទំនើប (CDHS ឆ្នាំ២០០០) ។ តំរូវការសេវា ផ្នែកផែនការគ្រួសារដែលមិនទាន់បានឆ្លើយតបមានកំរិតខ្ពស់ពោលគឺ មាននារី ៣៣ភាគរយ បាននិយាយថា ពួកគេ ចង់កំណត់ចំនួនកូន ឬក៏ចង់ពន្យារកំណើត ។ ទោះបីជាមានការពិភាក្សាគ្នាតិចតួចរវាងប្តី និងប្រពន្ធក៏ដោយ ក៏ការពន្យារកំណើត ទំនងជាមានការទទួលស្គាល់ជាទូទៅ ។ ការអង្កេតដែលត្រូវបានធ្វើឡើងដោយក្រសួងសុខាភិបាល បានបង្ហាញថា នារីចំនួន ៦៨ភាគរយ មានជំនឿថា ពួកគេ និងប្តីរបស់ពួកគេ បានព្រមព្រៀងឱ្យមាន ការពន្យារកំណើត ហើយនារី ៨៤ភាគរយទៀត បាននិយាយថា ពួកគេបានសំរេចចិត្តដោយខ្លួនឯង ឬមានការចូលរួម ពីប្តីរបស់ពួកគេលើការប្រើប្រាស់មធ្យោបាយពន្យារកំណើត (រូបភាព ៥.៦) ។

**រូបភាព ៥.៥: អត្រាកំណើតសរុប បែងចែកទៅតាមខេត្ត**




**ប្រភព:** ការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០០ (CDHS, ឆ្នាំ២០០០)

### រូបភាព ៩.៦: ការប្រើប្រាស់មធ្យោបាយពន្យារកំណើត បែងចែកទៅតាមខេត្ត




**ប្រភព:** ការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០០ (CDHS, ឆ្នាំ២០០០)

អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទាប ក៏មានន័យថា នារីខ្មែរភាគច្រើនប្រើប្រាស់វិធីពន្យារកំណើតតាមបែបបុរាណ ដែលមានគ្រោះថ្នាក់បំផុត ដើម្បីបញ្ឈប់ការមានផ្ទៃពោះមិនតាមផែនការ។ ប្រហែល ១/៣ (មួយភាគបី) នៃការរំលូតកូន ត្រូវបានធ្វើឡើងនៅតាមផ្ទះ។ ការរំលូតកូនតាមវិធីបែបនេះ គឺជាបុព្វហេតុចំបងមួយ ដែលធ្វើឱ្យអត្រាមរណភាពមាតាមានកំរិតខ្ពស់នៅកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០០២a)។

ពាក្យចចាមអារាម និងទស្សនៈភ័ន្តច្រឡំចំពោះមធ្យោបាយពន្យារកំណើតតាមបែបទំនើប នៅតែកើតមានក្នុងចំណោមនារីៗ ហើយអ្នកដែលបានស្វែងរកសេវាពន្យារកំណើត ត្រូវប្រឈមមុខនឹងឧបសគ្គមួយចំនួន ដូចជាការមាក់ងាយជាដើម ដោយសារមនុស្សភាគច្រើនមានជំនឿថា មានតែនារីរកស៊ីផ្លូវភេទទេ ដែលប្រើមធ្យោបាយពន្យារកំណើត ឬមានន័យថា មានតែប្តីប្រពន្ធដែលមិនទុកចិត្តគ្នាទេដែលប្រើវិធីនេះ។ បណ្តាញអ្នកស្ម័គ្រចិត្តនារីដែលបានផ្តល់ការអប់រំដល់សហគមន៍ (ហើយជារឿយៗ រួមបញ្ចូលទាំងការផ្តល់ការប្រឹក្សា ការពិគ្រោះយោបល់ និងការណែនាំអំពីវិធីពន្យារកំណើត) ត្រូវបានយកមកអនុវត្តសាកល្បង ប៉ុន្តែជាការចាំបាច់ត្រូវធ្វើការវាយតំលៃ និងពង្រីកឱ្យបានទូលំទូលាយនៅទូទាំងប្រទេស។

## ៥.១.៦ នារី មិនបានទទួលការថែទាំក្នុងពេលមានផ្ទៃពោះ និងពេលសំរាលកូន ប្រកបដោយសុវត្ថិភាពទេ

ការថែទាំរក្សាគភ៌ ការសំរាលកូនប្រកបដោយសុវត្ថិភាព និងការថែទាំក្រោយពេលសំរាលកូន ជាផ្នែកសំខាន់នៃសេវាសុខភាព ដើម្បីជួយសង្គ្រោះជីវិតម្តាយ ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា (CDHS) ឆ្នាំ២០០០ បានឱ្យដឹងថា មាននារីតែ ៣៨ភាគរយប៉ុណ្ណោះ ដែលទទួលបានសេវាថែទាំរក្សាគភ៌ ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ។ លទ្ធភាពប្រើប្រាស់សេវាថែទាំរក្សាគភ៌ ជាពិសេសនៅតាមតំបន់ជនបទមានកំរិតតិចណាស់ៈ នារីចំនួនពាក់កណ្តាលនៅជនបទ ទទួលបានសេវាថែទាំរក្សាគភ៌ ដូចនារីនៅទីក្រុងដែរ ។ នៅខេត្តដាច់ស្រយាលដូចជា ខេត្តរតនគីរី និងមណ្ឌលគីរី ក្នុងចំណោមនារី ៦នាក់ មាននារីតែ ១នាក់ប៉ុណ្ណោះ ដែលទទួលសេវាថែទាំរក្សាគភ៌ ។ ក្នុងរយៈពេល ៥ឆ្នាំមុនពេលមានការអង្កេតរបស់ក្រសួងសុខាភិបាល ក្នុងចំណោមនារីដែលបានសំរាលកូនរួចទាំងអស់ មាននារីចំនួន ២០ភាគរយ បានលេបថ្នាំជីវជាតិដែក នារី ៣០ភាគរយ ទទួលបានការចាក់ថ្នាំការពារតេតាណូស ២ ឬច្រើនដង ហើយមាននារីតែ ២ភាគរយប៉ុណ្ណោះ ដែលទទួលបានថ្នាំការពារជំងឺគ្រុនចាញ់ ។

តាមការអង្កេតរបស់ក្រសួងសុខភិបាលបានឱ្យដឹងថា មាននារីតែ ៣២ភាគរយប៉ុណ្ណោះ ដែលទទួលបានជំនួយពីឆ្មបជំនាញក្នុងពេលសំរាលកូន បើប្រៀបធៀបទៅតាមខេត្ត មានគំលាតគួរឱ្យកត់សំគាល់ (រូបភាព ៥.៧) ។ ការសំរាលកូនប្រមាណជា ៨៥ភាគរយ នៅកម្ពុជា ត្រូវបានធ្វើឡើងនៅតាមផ្ទះ ហើយការសំរាលកូនជាច្រើនទៀត ធ្វើឡើងដោយឆ្មបបូរាណប៉ុណ្ណោះ ។

ប្រហែលពាក់កណ្តាលនៃនារីខ្មែរ មិនទទួលបានការថែទាំរក្សាគភ៌ទេ ។ ការដេកអាំងភ្លើងនៅពេលសំរាលកូន (នារីត្រូវបានគ្របដណ្តប់ដោយក្រណាត់ក្តៅឧណ្ហៗ ក្រោយពីសំរាលកូនរួចហើយ គេងជិតភ្លើង ឬ គេងលើគ្រែដែលមានក្រាលកន្ទេលដាក់លើភ្លើងធ្យូងក្តៅឧណ្ហៗដុតនៅពីក្រោម) ត្រូវបានគេអនុវត្តជាញឹកញាប់ៈ នារីចំនួន ៨៨ភាគរយមានទំលាប់ដេកអាំងភ្លើង ផ្អែកតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០០០ ដោយមាននារី ២/៣ (ពីរភាគបី) ដេកអាំងភ្លើងរយៈពេលពី ២ ទៅ ៣ថ្ងៃ ។ ក្នុងអំឡុងពេលនេះ តាមធម្មតានារី មិនត្រូវបានអនុញ្ញាតឱ្យងូតទឹកទេ ហើយទារកត្រូវគេបញ្ចុកទឹកលាយស្ករ ឬទឹកទទេ ។

## ៥.១.៧ កង្វះបុគ្គលិកឆ្មបជំនាញ និង ការបែងចែកបុគ្គលិកពេទ្យមិនបានគ្រប់គ្រាន់

វិស័យសុខាភិបាល មានបុគ្គលិកតិចតួច និងពុំមានជំនាញគ្រប់គ្រាន់ ។ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិឆ្នាំ ២០០៣-២០០៧ របស់ខ្លួន ក្រសួងសុខាភិបាលបានបើកវគ្គបណ្តុះបណ្តាលជាមូលដ្ឋាន ដើម្បីបង្កើនចំនួនឆ្មប និងបំប៉នចំណេះដឹងដើម្បីពង្រឹងសមត្ថភាព និងជំនាញដល់ឆ្មបដែលធ្លាប់បានទទួលការបណ្តុះបណ្តាលរួចហើយ ។ ទោះបីជាមានការបណ្តុះបណ្តាលបែបនេះក៏ដោយ ក៏ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ចំនួនគិលានុប្បដ្ឋាក/គិលានុប្បដ្ឋាកយិការ និងឆ្មបនៅក្នុងវិស័យសុខាភិបាល បានធ្លាក់ចុះ ៨.៤ភាគរយ ។ ការបណ្តុះបណ្តាលនៅតែជាបញ្ហាប្រឈមមុខមួយ ហើយឆ្មបដែលទទួលបានការបណ្តុះបណ្តាល ក៏នៅខ្វះខាតជំនាញចាំបាច់មួយចំនួនទៀតដែរ ។

## រូបភាព ៥.៧: ការសំរាលកូន ដែលមានជំនួយពីឆ្មបជំនាញ




ប្រភព: ការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០០ (CDHS, ឆ្នាំ២០០០)

## តារាង ៥.១: កំលាំងពលកម្មរបស់ក្រសួងសុខាភិបាលនៅឆ្នាំ១៩៩៦-២០០១

| | ១៩៩៦ | ១៩៩៨ | ២០០០ | ២០០១ | ភាគរយនៃការប្រែប្រួល |
|---|---|---|---|---|---|
| វេជ្ជបណ្ឌិត | ១.២៤៧ | ១.៧១១ | ១.៨៧៨ | ២.០៥៥ | ៦៥% |
| ពេទ្យជំនួយការ | ១.៤៥៨ | ១.៦៩៩ | ១.៦០៨ | ១.៤២៥ | -២% |
| គិលានុបដ្ឋាកមធ្យម និងឆ្មបមធ្យម | ៥.៦៨៥ | ៦.២១៤ | ៦.០៣៩ | ៦.១២៦ | ៨% |
| គិលានុបដ្ឋាកបឋម និងឆ្មបបឋម | ៥.៩៤៥ | ៥.៤៧៥ | ៥.១៤៩ | ៤.៩៧៩ | -១៦% |
| បុគ្គលិកផ្សេងទៀត | ១.២៥៩ | ១.៤៩៤ | ១.៣២២ | ១.៣៤២ | ៧% |
| ចំនួនបុគ្គលិកសុខាភិបាលសរុប | ១៥.៥៩៤ | ១៦.៥៩៣ | ១៥.៩៩៦ | ១៥.៩២៧ | ២% |
| បុគ្គលិកផ្សេងទៀត | ២.៦៣៩ | ២.២៨៣ | ១.៩៦៤ | ១.៨៨៣ | -២៩% |
| បុគ្គលិកសរុបនៅក្នុងវិស័យសុខាភិបាល | ១៨.២៣៣ | ១៨.៨៧៦ | ១៧.៩៦០ | ១៧.៨១០ | -២% |

ប្រភព: នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល

ឆ្នប់ដែលទើបតែបញ្ចប់ការសិក្សា ទំនងជាមិនព្រមទៅធ្វើការនៅជនបទទេ ជាពិសេសតំបន់ដាច់ស្រយាល និងតំបន់ឆ្ងាយៗព្រោះថា គេមិនអាចរកប្រាក់បានច្រើន និងការព្រួយបារម្ភអំពីបញ្ហាសន្តិសុខ ។ ការពិនិត្យ និងការផ្តល់សេវានៅមូលដ្ឋាន មិនមានភាពទៀងទាត់ទេ ដោយសារកង្វះថវិកា និងចំងាយផ្លូវពីភូមិទៅមណ្ឌលសុខភាពឆ្ងាយ ។

## ៥.១.៨ យុវជនក្មេងៗក្នុងចំនួនច្រើនជាងនារីត្រូវស្លាប់ ឬទទួលគ្រោះថ្នាក់ដោយថារហេតុ

មានទិន្នន័យ ឬការវិភាគតិចតួចណាស់ ដែលផ្តោតទៅលើបញ្ហាសុខភាព និងគ្រោះថ្នាក់ផ្សេងៗដែលបុរស និងនារីប្រឈមមុខ ។ នៅកម្ពុជា បុរសឆាប់ស្លាប់ជាងនារី ។ អាយុមធ្យមគិតចាប់ពីពេលកើតគឺ ៥៨.៣ឆ្នាំ ចំពោះនារី និង ៥៤.១ឆ្នាំ ចំពោះបុរស (ជំរឿនឆ្នាំ១៩៩៨) ។ បុរសដែលស្លាប់នៅអាយុ ១៥- ៤៩ឆ្នាំ មានចំនួនច្រើនជាងនារីៈ អត្រាមរណភាពបុរសនៅអាយុ ១៥-៤៩ឆ្នាំ គឺ ៤,៨នាក់ក្នុង ១.០០០នាក់ ចំណែកឯនារីវិញមានតែ ៣,៥នាក់ក្នុង ១០០០នាក់ ។

បុរសដែលទទួលគ្រោះថ្នាក់ដោយថាហេតុ មានចំនួនស្មើនឹង ២ដងនៃចំនួននារីដែលបង្ហាញឱ្យឃើញថា បុរសទំនងជាមានការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ ។ ១ភាគរយនៃបុរសទាំងអស់ទទួលរងគ្រោះថ្នាក់ក្នុងរយៈពេល ១២ខែមុន បើប្រៀបធៀបទៅនឹងនារីដែលមានតែ ០.៥ភាគរយប៉ុណ្ណោះ (ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០០០) ។ បុព្វហេតុដែលបណ្តាលឱ្យស្លាប់ និងមានគ្រោះថ្នាក់មានលក្ខណៈខុសគ្នាទៅតាមភេទៈ

- បុព្វហេតុចំបងបំផុតទីមួយដែលបណ្តាលឱ្យស្លាប់ ឬរងរបួស គឺគ្រោះថ្នាក់ចរាចរ ។
- ចំពោះបុរស បុព្វហេតុចំបងបំផុតទីពីរដែលបណ្តាលឱ្យស្លាប់ ឬរងរបួស គឺការធ្លាក់ពីលើដើមឈើ ឬពីអាគារ ។
- បុរសដែលស្លាប់ដោយសារគ្រាប់មីន មានចំនួនច្រើនជាងនារី ៤ដង ។
- បុរសដែលត្រូវស្លាប់ ឬរងរបួសដោយការបាញ់ប្រហារ មានចំនួនតិចតួច ។

## ៥.១.៩ ពិការភាព និងការញៀនថ្នាំញៀន មានផលប៉ះពាល់លើបុរសច្រើនជាងនារី

បុរសពិការរូបរាងកាយ មានចំនួនច្រើនជាងនារី ២ដង (ជាសរុប ២ភាគរយនៃចំនួនប្រជាជនសរុប ត្រូវពិការរូបរាងកាយ) ។ ភាពខុសគ្នាខ្លាំង គឺដោយសារគ្រោះថ្នាក់ដោយសារគ្រាប់មីន និងគ្រោះថ្នាក់ដោយសារគ្រាប់កាំភ្លើង ។ ការស្លាប់ និងពិការភាពរបស់បុរស ក៏មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើក្រុមគ្រួសាររបស់ពួកគេ ។ ការខ្វះមនុស្សប្រុសពេញវ័យដែលមានកំលាំងពលំមាំមួននៅក្នុងគ្រួសារ ធ្វើឱ្យសមាជិកគ្រួសារបាត់បង់ឱកាសរកចំណូល និងចូលរួមក្នុងជីវភាពសហគមន៍ និងការធ្វើសេចក្តីសំរេច ។

ទិន្នន័យស្តីពីការប្រើប្រាស់បំពានគ្រឿងញៀនទៅតាមភេទ មិនទាន់មាននៅឡើយ ។ ប៉ុន្តែយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បានលើកឡើងពីការកើនឡើងនូវការប្រើប្រាស់ថ្នាំញៀន ជាពិសេសក្នុងចំណោមយុវជន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាបន្ថែមទៀត ។

## ៥.២ យុទ្ធសាស្ត្រ និង គោលនយោបាយរបស់រាជរដ្ឋាភិបាល

ក្រសួងសុខាភិបាល បានរៀបចំយុទ្ធសាស្ត្រទូទាំងវិស័យសំរាប់ឆ្នាំ២០០៣-២០០៧ ដែលផ្តោតទៅលើការលើកកំពស់សុខភាពម្តាយ និងទារក។ យុទ្ធសាស្ត្រទាំង ៨ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ត្រូវបានកំណត់នៅក្នុងផ្នែកនានា នៃការផ្តល់សេវាសុខភាព ការផ្លាស់ប្តូរការប្រព្រឹត្តិ ការលើកកំពស់គុណភាព ការអភិវឌ្ឍន៍ធនធានមនុស្ស ហិរញ្ញប្បទានសុខាភិបាល និងការអភិវឌ្ឍន៍ស្ថាប័ន។ មានការផ្តោតការយកចិត្តទុកដាក់ទៅលើសមធម៌សុខភាព សិទ្ធិក្នុងការទទួលបានសេវាសុខភាព និងការផ្តល់សេវាដល់ប្រជាពលរដ្ឋក្រីក្រ។ ការពិនិត្យវាយតំលៃប្រចាំឆ្នាំរបស់វិស័យសុខាភិបាលនៅឆ្នាំ២០០៣ បានពិនិត្យមើលចំណុចគោលសំរាប់វាស់ស្ទង់ និងសមិទ្ធិផលដែលសំរេចបានក៏ដូចជា ផ្នែកនានាដែលត្រូវផ្តោតការយកចិត្តទុកដាក់។

តាំងពីពេលចាប់ផ្តើមនៅឆ្នាំ១៩៩៦ មក ក្រសួងសុខាភិបាលបានផ្តល់មូលនិធិទៅឱ្យសកម្មភាពគាំទ្រសុខភាពនៅថ្នាក់ពីរគឺ មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកស្រុក។ យុទ្ធសាស្ត្របច្ចុប្បន្ន ផ្តោតទៅលើការពង្រឹងប្រព័ន្ធដែលមានស្រាប់ ដើម្បីឱ្យមណ្ឌលសុខភាពទាំងអស់ មានលទ្ធភាពអាចផ្តល់កញ្ចប់សកម្មភាពគាំទ្រសុខភាពបឋម (MPA) ចំណែកមន្ទីរពេទ្យបង្អែកស្រុកទាំងអស់ អាចផ្តល់កញ្ចប់សកម្មភាពគាំទ្រសុខភាពបំពេញបន្ថែម (CPA)។ កញ្ចប់សកម្មភាពគាំទ្រសុខភាពបឋម និងកញ្ចប់សកម្មភាពគាំទ្រសុខភាពបំពេញបន្ថែម ផ្តោតការយកចិត្តទុកដាក់ទៅលើតំរូវការ គាំពារមាតា និងទារក។ ផ្អែកតាមថវិកាឆ្នាំ២០០២ ក្នុងចំណោមមន្ទីរពេទ្យខេត្ត និងស្រុកចំនួន ៤៨កន្លែង មន្ទីរពេទ្យចំនួន ៤០ភាគរយ អាចផ្តល់កញ្ចប់សកម្មភាពគាំទ្រសុខភាពបំពេញបន្ថែម ចំណែក ៨២ភាគរយ នៃមណ្ឌលសុខភាពចំនួន ៩៩១កន្លែង អាចផ្តល់កញ្ចប់សកម្មភាពគាំទ្រសុខភាពបឋម។ កញ្ចប់សកម្មភាពគាំទ្រសុខភាពបឋម ផ្តោតជាសំខាន់ទៅលើ សុខភាពកុមារ អាហារូបត្ថម្ភ សុខភាពមាតា និងការកំចាត់ជំងឺឆ្លង (ជាពិសេសជំងឺអេដស៍) និងក្នុងករណីធ្ងន់ធ្ងរត្រូវបញ្ជូនទៅមន្ទីរពេទ្យ។

ក្រៅពីប្រព័ន្ធពហុព្យាបាលរបស់មណ្ឌលសុខភាព និងមន្ទីរពេទ្យ កម្មវិធីពិសេសមួយដែលមានទិសដៅលើកកំពស់សុខភាពមាតា និងទារក (អនុវត្តដោយមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក)។ កម្មវិធីនេះ ផ្តោតទៅលើផ្នែកសំខាន់ៗ ៤ ដូចជា អាហារូបត្ថម្ភ ការពន្យារកំណើត ការចាក់ថ្នាំបង្ការ និងជំងឺរលាកផ្លូវដង្ហើម។ កម្មវិធីជាតិបានបើកវគ្គបណ្តុះបណ្តាលដល់បុគ្គលិកមណ្ឌលសុខភាព និងបុគ្គលិកមន្ទីរពេទ្យ ហើយបានសំរបសំរួលដល់ការអនុវត្តន៍ការងារក្នុងផ្នែកទាំង៤នេះ។ កម្មវិធីនេះ មិនបានផ្តល់សេវាណាមួយដោយផ្ទាល់ ឬក៏ផ្តល់ប្រាក់បៀវត្សរ៍ ដល់បុគ្គលិកដែលមានភារកិច្ចថែទាំអ្នកជំងឺនៅក្នុងផ្នែកទាំង៤នេះទេ។

នៅកម្ពុជា ហិរញ្ញប្បទានសុខាភិបាលដ៏លើសលុប ត្រូវធ្លាក់ចូលទៅក្នុងផ្នែកឯកជនដោយមនុស្សម្នាក់ ត្រូវចំណាយ ២៤ដុល្លារអាមេរិក ក្នុង ១ឆ្នាំទៅលើការថែទាំសុខភាពនៅក្នុងផ្នែកនេះ។ ចំណាយប្រចាំឆ្នាំទៅលើសុខាភិបាលសាធារណៈ មានកំរិតទាបៈ ថវិកាដែលត្រូវបែងចែកទៅឱ្យវិស័យសុខាភិបាលមានតែ ១ភាគរយនៃផលិតផលក្នុងស្រុកសរុបប៉ុណ្ណោះ។ នៅឆ្នាំ២០០១ រាជរដ្ឋាភិបាលបានចំណាយ ៩៨.២លានដុល្លាអាមេរិក ក្នុងនោះជំនួយបរទេសមាន ៦៥.៣លានដុល្លាអាមេរិក។ មិនមានការបែងចែកថវិកាជាទៀងទាត់ពីថ្នាក់កណ្តាល ទៅឱ្យថ្នាក់ខេត្ត និងថ្នាក់ស្រុកទេ។ ៥៣ភាគរយនៃថវិកាសរុប សំរាប់វិស័យសុខាភិបាល ត្រូវបានផ្តល់ជូនទៅឱ្យមន្ទីរសុខាភិបាលខេត្ត។ បៀវត្សរ៍នៅក្នុងវិស័យសុខាភិបាល

មានកំរិតទាប ។ នៅចន្លោះពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០១ ប្រាក់បៀវត្សរ៍បានធ្លាក់ចុះ ធៀបទៅនឹងចំណាយសរុបលើផ្នែកសុខភាព ។ នៅឆ្នាំ២០០១ ប្រាក់បៀវត្សរ៍មានចំនួនតិចជាង ១០ភាគរយ នៃចំណាយដែលជាកំរិតមួយទាបជាងគេបំផុតនៅក្នុងពិភពលោក ។ តាមការប្រៀបធៀប នៅវៀតណាមដែលជាប្រទេសជិតខាង ប្រាក់បៀវត្សរ៍មាន ២៣ភាគរយ ចំណែកនៅបង់ក្លាដេសមាន ៤៥ភាគរយ ( ធនាគារពិភពលោកឆ្នាំ២០០១- HEU និង MAU ឆ្នាំ២០០១) ។ ប្រាក់បៀវត្សរ៍នៅតែមានកំរិតទាប ទោះបីជាការទូទាត់ថ្លៃសេវាពីអ្នកប្រើប្រាស់ និងប្រាក់ឧបត្ថម្ភមួយចំនួនក៏ដោយ ( សំរាប់ការផ្សព្វផ្សាយពិតមាន និងសកម្មភាពផ្សេងទៀត) សំរាប់បន្ថែមទៅលើប្រាក់បៀវត្សរ៍សុទ្ធលើសពីកំរិតនេះក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ មានការលើកទឹកចិត្តតិចតួចសំរាប់ការបំពេញការងារ ហើយបុគ្គលិកជាច្រើន មិនបានបំពេញភារកិច្ចរបស់ខ្លួនទេ ។ ទន្ទឹមនឹងនេះ ដោយសារតែប្រាក់បៀវត្សរ៍ទាប បុគ្គលិកជាច្រើន បានឆក់ឱកាសដែលគោលនយោបាយ បានអនុញ្ញាតឱ្យពួកគេអាចសុំច្បាប់សំរាករហូតដល់ ៤ឆ្នាំ ដោយមិនទទួលបៀវត្សរ៍ពីរដ្ឋដើម្បីធ្វើការ ឬបើកអាជីវកម្មនៅក្នុងផ្នែកឯកជន ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងអំឡុងពេលនេះ មុខតំណែងរបស់ពួកគេត្រូវទុកទំនេរ ។[២]

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រទទួលស្គាល់ថា "ការបង្ការទប់ស្កាត់ភាពក្រីក្រ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រពឹងផ្អែកជាសំខាន់ទៅលើកំណែទំរង់ប្រព័ន្ធទូទាត់ និងលើកលែងការបង់ថ្លៃសេវា និងការផ្តល់លទ្ធភាពទទួលបានសេវាថែទាំសុខភាពដែលមានគុណភាពខ្ពស់ដល់ប្រជាពលរដ្ឋក្រីក្រ" ។ ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្រសួងសុខាភិបាលត្រូវធានាថា សេវាត្រូវបានផ្តល់ជូនដល់ប្រជាពលរដ្ឋក្រីក្រ រួមទាំងការបែងចែកធនធានជាថ្មីឡើងវិញ ដើម្បីឱ្យបានទៅដល់តំបន់ភូមិសាស្ត្រដែលមានប្រជាពលរដ្ឋក្រីក្រច្រើន ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បានរៀបរាប់អំពីសកម្មភាពពង្រីក និងលើកកំពស់ការប្រើប្រាស់សេវាសុខភាពនៅក្នុងតំបន់ទាំងនេះ បង្កើនលទ្ធភាពទទួលបាន និងលទ្ធភាពប្រើប្រាស់សេវាសំខាន់ៗ និងផ្តល់ពត៌មានជំរុញឱ្យមានការចូលរួមកាន់តែច្រើន និងផ្តល់សិទ្ធិអំណាចឱ្យដល់ប្រជាពលរដ្ឋក្រីក្រដើម្បីធ្វើការជ្រើសរើសឱ្យបានត្រឹមត្រូវ ។

[២] ទំនាក់ទំនងផ្ទាល់ខ្លួន - Juliet Fleishi មន្ត្រីបច្ចេកទេសរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០០៣ ។

# ជំពូកទី ៦

# បញ្ហាយេនឌ័រ និង ជំងឺអេដស៍


កម្ពុជានាពេលបច្ចុប្បន្ន ........ ១៣៣

៦.១ ស្ថានភាព បញ្ហា និង និន្នាការ ........ ១៣៣

៦.១.១ អត្រាឆ្លងថ្មីបានថយចុះនៅក្នុងចំណោមបុរស ចំណែកនៅក្នុងចំណោមនារីវិញ អត្រានេះនៅថេរ ... ១៣៤

៦.១.២ អត្រាឆ្លងមេរោគអេដស៍ក្នុងចំណោមនារីរកស៊ីផ្លូវភេទ បានថយចុះនៅពេលដែលមានការកើនឡើងនូវការប្រើប្រាស់ស្រោមអនាម័យ ........ ១៣៦

៦.១.៣ អត្រានៃការឆ្លងមេរោគអេដស៍ មានការថយចុះក្នុងចំណោមនារីដែលទទួលសេវាថែរក្សាគភ៌ ...... ១៣៧

៦.១.៤ ផ្លូវនៃការចំលងមេរោគអេដស៍ កំពុងតែមានការផ្លាស់ប្តូរ ........ ១៣៩

៦.១.៥ នារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ នៅតែប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍ ........ ១៤០

៦.១.៦ នារីរៀបការរួច ប្រឈមមុខនឹងគ្រោះថ្នាក់ច្រើន ........ ១៤០

៦.១.៧ ទស្សនះយេនឌ័រមិនត្រឹមត្រូវ មានឥទ្ធិពលលើការប្រព្រឹត្តិផ្លូវភេទរបស់បុរស ........ ១៤១

៦.១.៨ នារីទទួលបន្ទុកថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ........ ១៤១

៦.១.៩ លទ្ធភាពទទួលបានការព្យាបាលប្រឆាំងនឹងមេរោគអេដស៍នៅមានកំរិត ........ ១៤២

៦.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ........ ១៤២

# ជំពូកទី ៦ : បញ្ហាយេនឌ័រ និង ជំងឺអេដស៍

## កម្ពុជានាពេលបច្ចុប្បន្ន[១]

| សូចនាករ | តំលៃ |
|---|---|
| អត្រាឆ្លងមេរោគអេដស៍ទូទាំងប្រទេស (ភាគរយ) | ២.៦ |
| ចំនួនអ្នកផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍នៅឆ្នាំ២០០២ | ១៥៧,៤៨៣ នាក់ |
| ចំនួននារីដែលផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍នៅឆ្នាំ២០០២ | ៧៥,៤៤៨ នាក់ |

## ៦.១ ស្ថានភាព បញ្ហា និង និន្នាការ

តាមសេចក្តីរាយការណ៍បានឱ្យដឹងថា នៅកម្ពុជាមានករណីឆ្លងមេរោគអេដស៍/អេដស៍ដំបូងនៅឆ្នាំ១៩៩១ ហើយអត្រានៃការឆ្លងមេរោគនេះ បានកើនឡើងយ៉ាងលឿនក្នុងទសវត្សរ៍នោះ ។ តាមការប៉ាន់ស្មាន អត្រាឆ្លងមេរោគអេដស៍នៅកម្ពុជាមានកំរិតទាបគឺ ៨ភាគរយ ដែលបង្ហាញឱ្យឃើញថា បញ្ហានេះទំនងជាមានការកើនឡើង (ផ្អែកតាមរបាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជាឆ្នាំ២០០១) ។ នៅកម្ពុជា មានអត្រានៃការឆ្លងមេរោគអេដស៍/អេដស៍ខ្ពស់ជាងគេបំផុតនៅក្នុងអាស៊ីអាគ្នេយ៍ ទោះបីជាអត្រារីករាលដាលនេះ បានថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះក៏ដោយ ។ ការរីករាលដាលនៃមេរោគនេះភាគច្រើន គឺឆ្លងតាមរយៈការរួមភេទ ។

ចាប់តាំងពីឆ្នាំ១៩៩៧ មក អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យទូទាំងប្រទេសបានថយចុះជាលំដាប់ (ក្រាហ្វិក ៦.១) ពោលគឺ ពី ៣.៣ភាគរយ មកនៅត្រឹម ២.៦ភាគរយ (ផ្អែកតាមរបាយការណ៍ឆ្នាំ២០០១ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើរស្បែក និងកាមរោគ) ។ ចំនួនអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍បានថយចុះពី ២១០.០០០នាក់ នៅឆ្នាំ១៩៩៧ មកនៅត្រឹម ១៥៧,៤៨៣នាក់ នៅឆ្នាំ២០០២ ក្នុងនោះមានបុរស ៨២.០៣៧នាក់ និងនារី ៧៥.៤៤៨នាក់ (NCHADS ឆ្នាំ២០០២) ។ ដោយឡែក គេសង្កេតឃើញមានការរីកចំរើនយ៉ាងខ្លាំង នូវការទប់ស្កាត់ការឆ្លងមេរោគអេដស៍នៅក្នុងចំណោមនារីរកស៊ីផ្លូវភេទ និងអតិថិជនរបស់ពួកគេ ។ ប្រតិបត្តិការនេះ សំរេចបានជោគជ័យតាមរយៈកម្មវិធីបង្កើនការយល់ដឹងអំពីការប្រើប្រាស់ស្រោមអនាម័យ លទ្ធភាពប្រើប្រាស់ស្រោមអនាម័យ និងគុណភាពការផ្តល់ការព្យាបាលជំងឺកាមរោគ ការធានាឱ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ (ឧទាហរណ៍ : ម្ចាស់ផ្ទះបន និងនគរបាល) និងការគ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធិភាពនៅផ្ទះបន ។

[១] ប្រភព : មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើស្បែក និងកាមរោគ ឆ្នាំ២០០២: ការអង្កេតតាមដានការប្រព្រឹត្តិ និន្នាការពីឆ្នាំ១៩៩៧-២០០១

ទោះបីជាអត្រាអ្នកឆ្លងមេរោគអេដស៍/ជំងឺអេដស៍ មានការថយចុះ ដែលជាលទ្ធផលនៃការថយចុះនៃអត្រាអ្នកឆ្លងថ្មី និងដោយសារអ្នកជំងឺអេដស៍មុនៗបានស្លាប់បាត់ទៅក៏ដោយ ក៏ការរីករាលដាលនៃមេរោគអេដស៍ នៅតែគំរាមកំហែងចំពោះការអភិវឌ្ឍន៍មនុស្សនៅកម្ពុជា (NCHADS ឆ្នាំ២០០២) ។ ការរីករាលដាលនៃមេរោគអេដស៍ អាចមានការវិវត្តន៍យ៉ាងលឿនដែលមិនអាចប៉ាន់ស្មានបានជាមុន (UNGASS ឆ្នាំ២០០៣) ។ ដោយឡែក នារីអាចប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍នៅក្នុងចំណងទាក់ទងយូរអង្វែងក្នុងអាពាហ៍ពិពាហ៍ និងក្រៅអាពាហ៍ពិពាហ៍ (UNGASS ឆ្នាំ២០០៣) ។ ជាការចាំបាច់ត្រូវមានយុទ្ធសាស្ត្របង្ការថ្មី ដើម្បីធ្វើឱ្យនិន្នាការនៃការីករាលដាលបន្តធ្លាក់ចុះតទៅទៀត ។ ជាចុងក្រោយនេះ មនុស្សមួយចំនួនធំនៅកម្ពុជា មានផ្ទុកមេរោគអេដស៍ ហើយការពង្រីកលទ្ធភាពប្រើប្រាស់សេវាថៃទាំ សេវាគាំទ្រ និងការព្យាបាលសំរាប់បុរស និងនារីទាំងនោះគឺជាតំរូវការបន្ទាន់ ។

## ក្រាហ្វិក ៦.១: អត្រាមនុស្សពេញវ័យឆ្លងមេរោគអេដស៍




**ប្រភព:** មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ (NCHADS ឆ្នាំ២០០២)

### ៦.១.១ អត្រាឆ្លងថ្មីបានថយចុះនៅក្នុងចំណោមបុរស ចំណែកនៅក្នុងចំណោមនារីវិញ អត្រានេះនៅថេរ

ចំនួនអ្នកទើបឆ្លងមេរោគអេដស៍ថ្មីក្នុងមួយឆ្នាំៗ ហាក់ដូចជាមានការថយចុះ តាំងពីឆ្នាំ១៩៩៤ មក ក្នុងចំណោមបុរស និងតាំងពីឆ្នាំ១៩៩៦ មកក្នុងចំណោមនារី (HSS ឆ្នាំ២០០២) ។ ទោះជាយ៉ាងណាក៏ដោយ ក៏ទិន្នន័យស្ដីពីអ្នកដែលឆ្លងថ្មីនៅមានកំរិត ដោយសារមិនមានការអង្កេតតាមដាននៅក្នុងចំណោម បុរសដែលរួមភេទជាមួយនឹងបុរស ប៉ុន្តែការអង្កេតទ្រង់ទ្រាយតូចមួយដែលត្រូវបានធ្វើឡើងដោយអង្គការ សុខភាពគ្រួសារអន្តរជាតិ (Family Health International) បានបង្ហាញឱ្យឃើញថា អត្រានៃការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមបុរសមាន ១៤ ភាគរយ ។ ចំនួនបុរសដែលកំពុងផ្ទុកមេរោគអេដស៍ ត្រូវបានធ្លាក់ចុះតាំងពីឆ្នាំ១៩៩៧ មក ចំណែកឯចំនួននារី ដែលឆ្លង

មេរោគអេដស៍បន្តកើនឡើង ហើយកំពុងតែចាប់ផ្តើមនៅថេរ (ក្រាហ្វិក ៦.២ និង៦.៣)។ នៅកម្ពុជា ក្រុមដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់មានដូចជា នារីរកស៊ីផ្លូវភេទ និងអតិថិជនរបស់ពួកគេ។ ការអង្កេតអត្រានៃការឆ្លងមេរោគអេដស៍ ប្រមូលបានពត៌មានពីក្រុមមួយចំនួនដូចជា នគរបាល យោធា និងនារីរកស៊ីផ្លូវភេទ ព្រមទាំងនារីដែលទទួលការថែទាំរក្សាគភ៌។

## ក្រាហ្វិក ៦.២: ចំនួននារីដែលឆ្លងមេរោគអេដស៍




ប្រភព: ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២០០២ (HIV sentinel survey, ឆ្នាំ២០០២)

## ក្រាហ្វិក ៦.៣: ចំនួនបុរសដែលឆ្លងមេរោគអេដស៍




ប្រភព: ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២០០២ (HIV sentinel survey, ឆ្នាំ២០០២)

ដើម្បីពន្យល់អំពីការរីកចំរើនក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៏ ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ កថាខ័ណ្ឌក្រោយៗនេះ ផ្តោតទៅលើនារីរកស៊ីផ្លូវភេទផ្ទាល់ និងនារីមានផ្ទៃពោះដែលទទួលសេវាថែរក្សាគភ៌ ។

## ៦.១.២ អត្រាឆ្លងមេរោគអេដស៍ក្នុងចំណោមនារីរកស៊ីផ្លូវភេទ បានថយចុះនៅពេលដែលមានការកើនឡើងនូវការប្រើប្រាស់ស្រោមអនាម័យ

នៅកម្ពុជា ការចំលងមេរោគអេដស៏ពីនារីរកស៊ីផ្លូវភេទទៅអតិថិជន មានសមាមាត្រខ្ពស់នៅទសវត្សរ៏ឆ្នាំ១៩៩០ ។ នៅឆ្នាំ១៩៩៨ ជិតពាក់កណ្តាលនៃនារីរកស៊ីផ្លូវភេទ មានផ្ទុកមេរោគអេដស៏ ។ ការធ្លាក់ចុះនៃអត្រាឆ្លងដែលគួរឱ្យកត់សំគាល់នោះ គឺនៅក្នុងចំណោមនារីរកស៊ីផ្លូវភេទពោលគឺ ពី ៤២.៦ នៅឆ្នាំ១៩៩៨ មកនៅត្រឹម ២៨.៨ នៅឆ្នាំ ២០០២ ។ ការស្លាប់របស់អ្នកជំងឺអេដស៏ អាចជាផ្នែកមួយនៃការធ្លាក់ចុះអត្រានៃការឆ្លងមេរោគអេដស៏ ឬជំងឺអេដស៏ (CHDR ឆ្នាំ២០០១) ។ ប៉ុន្តែការប្រើប្រាស់ស្រោមអនាម័យទាំងភ្ញៀវ និងនារីរកស៊ីផ្លូវភេទ បានកើនឡើងជាលំដាប់រហូតជិតដល់ ៩០ភាគរយ នៅឆ្នាំ២០០២ (NCHADS ឆ្នាំ២០០២) ។ ដោយផ្អែកតាមរបាយការណ៏ដែលទទួលបានក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ បានជំរុញឱ្យមានការព្រមព្រៀងលើការប្រើវិធីសាស្ត្រការបង្ការមេរោគអេដស៏នៅតាមផ្ទះបន ដែលធ្វើឱ្យមានការកើនឡើងយ៉ាងលឿននូវការប្រើប្រាស់ស្រោមអនាម័យ (ក្រាហ្វិក ៦.៤) ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានរបាយការណ៏ដែលគួរឱ្យចាប់អារម្មណ៏ថាអតិថិជនបានវាយដំនារីរកស៊ីផ្លូវភេទ ដែលទទូចសុំឱ្យពួកគេប្រើប្រាស់ស្រោមអនាម័យ ។

យើងគួរតែមានការព្រួយបារម្ភចំពោះការរីករាលដាលនៃជំងឺអេដស៏ ពីព្រោះថា នារីក្មេងៗ និងនារីរកស៊ីផ្លូវភេទថ្មីៗជាច្រើន បានចូលទៅក្នុងឧស្សាហកម្មភេទ ។ ជាការចាំបាច់ត្រូវបន្តការអប់រំអំពីការបង្ការមេរោគអេដស៏ ។ លើសពីនេះទៀត តម្រូវការការរកស៊ីផ្លូវភេទនៅក្រៅផ្ទះបននៅតែបន្តកើតមាន ហើយការភ័យខ្លាចឆ្លងមេរោគអេដស៏ក៏កំពុងតែរីករាលដាលខ្លាំងក្លាដែរ ។ ការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមនារីរកស៊ីផ្លូវភេទមិនផ្ទាល់ (នារីក្មេងៗដែលធ្វើជាអ្នកឃោសនាស្រាបៀរ (ស្រីឡង់សេ) អ្នកចំរៀងខារ៉ាអូខេ ។ល ។ ប៉ុន្តែបំរើសេវាផ្លូវភេទ) មានប្រហែលតែ ៥៦ភាគរយប៉ុណ្ណោះ ដូច្នេះជាការចាំបាច់ត្រូវធ្វើការអប់រំបន្ថែមទៀត ដើម្បីបង្កើនការប្រើប្រាស់ស្រោមអនាម័យនៅក្នុងក្រុមទាំងនេះ (NCHADS ឆ្នាំ២០០២) ។ បញ្ហាដែលគួរឱ្យព្រួយបារម្ភដែរនោះ គឺមានរបាយការណ៏ទាក់ទងនឹងអំពើហឹង្សា និងការរំលោភរបស់ក្រុមបងធំទៅលើនារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ដែលរារាំងដល់ការប្រើប្រាស់ស្រោមអនាម័យ (PSI ឆ្នាំ២០០២ និង GAD-C ឆ្នាំ២០០៣) ។

*"ខ្ញុំធ្វើជានារីរកស៊ីផ្លូវភេទដើម្បីចិញ្ចឹមគ្រួសារខ្ញុំ។ គ្មានអ្វីផ្សេងទៀតដែលខ្ញុំអាចធ្វើបាននោះឡើយ បើពុំនោះទេគ្រួសារខ្ញុំនឹងឈឺចាប់។ ខ្ញុំមានជំងឺអេដស៍ ហើយអាចស្លាប់មុនពេលដែលគ្រួសាររបស់ខ្ញុំអាចថែរក្សាខ្លួនឯង។ នេះគឺជាស្ថានភាពគួរឱ្យខ្លាចណាស់ ប៉ុន្តែខ្ញុំមិនអាចធ្វើអ្វីបានឡើយ...ខ្ញុំគិតថា នេះគឺជាស្ថានភាពរបស់អ្នកក្រីក្រជាច្រើន"*។ **នេះជាសំដីរបស់នារីម្នាក់ដែលមានអាយុជាង ២០ឆ្នាំ នៅក្នុងរបាយការណ៍ស្តីពីការវាយតំលៃភាពក្រីក្រ (ADB ឆ្នាំ២០០១)។**

**ក្រាហ្វិក ៦.៤: អត្រាឆ្លងមេរោគអេដស៍ និងការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមនារីរកស៊ីផ្លូវភេទផ្ទាល់**




**សំគាល់:** BSS មានន័យថា ការអង្កេតតាមដានការប្រព្រឹត្តិ

**ប្រភព:** ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២០០២ (HIV sentinel survey, ឆ្នាំ២០០២)

## ៦.១.៣ អត្រានៃការឆ្លងមេរោគអេដស៍ មានការថយចុះក្នុងចំណោមនារីដែលទទួលសេវាថែរក្សាគភ៌

អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីដែលទទួលសេវាថែរក្សាគភ៌ ជាពិសេសក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ ត្រូវបានចាត់ទុកថាជាការឆ្លងថ្មី និងជាចលនានៃការរីករាលដាលចូលទៅក្នុងចំណោមប្រជាជនទូទៅ ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើរស្បែក និងកាមរោគ (ឆ្នាំ២០០២) បានប៉ាន់ស្មានឃើញថា នារីមានផ្ទៃពោះប្រហែល ៩៥ភាគរយ ទទួលបានសេវាថែរក្សាគភ៌ (បើប្រៀបធៀបជាមួយនឹងតួលេខរបស់ CDHS ឆ្នាំ២០០០ ដែលមានតែ ៣៨ភាគរយ) ។ អត្រានៃការឆ្លងមេរោគហ៊ីវ ក្នុងចំណោមនារីមានផ្ទៃពោះ ដែលទទួលបានសេវាថែរក្សាគភ៌ ហាក់ដូចជានៅថេរ ពោលគឺ ២.៦ភាគរយ (សូមមើលក្រាហ្វិក ៦.៥) ។

### ក្រាហ្វិក ៦.៥: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីដែលទទួលការថែរក្សាគភ៌




**ប្រភព:** មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគឆ្នាំ២00២ (NCHADS ឆ្នាំ២00២)

អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីមានផ្ទៃពោះ ខុសប្លែងគ្នាពីខេត្តមួយទៅខេត្តមួយទៀត ហើយខេត្តដែលនៅជិតព្រំដែនប្រទេសថៃ (ក្រាហ្វិក ៦.៦) មានអត្រានៃការឆ្លងខ្ពស់ជាងគេបំផុត ដោយសារខេត្តទាំងនោះមានកម្មករ និងពលករដែលធ្វើទេសន្តរប្រវេសន៍ និងប្រជាជនចល័តច្រើន ។ ប្រជាពលរដ្ឋខ្មែរចំនួន ៥ម៉ឺននាក់ ធ្វើការនៅក្នុងប្រទេសថៃដូចជា កម្មករសំណង់ កសិករ ឬអ្នកជើរកប៉ាល់សមុទ្រ (អង្គការ PATH បានលើកឡើងពីបញ្ហានេះក្នុង UNGASS ឆ្នាំ២00៣) ។ នៅខេត្តរតនគីរី អត្រានៃការឆ្លងក៏មានកំរិតខ្ពស់ដែរ ដោយសារតែមានប្រជាជនចល័តនៅទីនោះ ។

### ក្រាហ្វិក ៦.៦: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងតំបន់ ក្នុងចំណោមនារីមានផ្ទៃពោះដែលទទួលការថែរក្សាគភ៌




**ប្រភព:** ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២00២ (HIV sentinel survey, ឆ្នាំ២00២)

អត្រានៃការឆ្លងក្នុងចំណោមនារីមានផ្ទៃពោះ មានកំរិតខ្ពស់បំផុតនៅក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ ( ក្រាហ្វិក ៦.៧) ។

**ក្រាហ្វិក ៦.៧: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីមានផ្ទៃពោះ**




## ៦.១.៤ ផ្លូវនៃការចំលងមេរោគអេដស៍ កំពុងតែមានការផ្លាស់ប្តូរ

ទោះបីជាផ្លូវនៃការចំលងមេរោគអេដស៍ កំពុងធ្លាក់ចុះ ប៉ុន្តែ ការចំលងពីម្តាយទៅកូន និងការចំលងពីប្តីទៅប្រពន្ធ ពុំបានធ្លាក់ចុះឡើយ ហើយនារី និងកុមារចំនួនកាន់តែច្រើនឡើង ជាជនងាយរងគ្រោះដោយសារការឆ្លងមេរោគអេដស៍ ។

**ក្រាហ្វិក ៦.៨: ផ្លូវនៃការចំលងមេរោគអេដស៍ទៅតាមពេលវេលា**




ប្រភព: ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២០០២ (HIV sentinel survey, ឆ្នាំ២០០២)

## ៦.១.៥ នារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ នៅតែប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍

តាមការប៉ាន់ស្មានទៅកម្ពុជា ស្តីពីចំនួននារីរកស៊ីផ្លូវភេទ មានចំនួនខុសៗគ្នា ប៉ុន្តែតាមប្រភពរបស់ UNDP ឆ្នាំ ២០០១ បានប៉ាន់ប្រមាណថា មាននារីរកស៊ីផ្លូវភេទចំនួន ១០០.០០០នាក់។ នារីរកស៊ីផ្លូវភេទភាគច្រើន ត្រូវគេបង្ខំ ឬបោកប្រាស់ឱ្យធ្លាក់ចូលទៅក្នុងមុខរបរនេះ។ ទោះបីជាពុំទាន់មានទិន្នន័យជាក់ស្តែង ប៉ុន្តែមានការព្រួយបារម្ភថា នារីវ័យក្មេងកាន់តែច្រើនឡើង កំពុងធ្លាក់ខ្លួនប្រកបរបររកស៊ីផ្លូវភេទ។ ដោយផ្អែកលើលទ្ធផលនៃអង្កេត ស្តីពីការប្រព្រឹត្តិ (BSS ឆ្នាំ២០០០) បានបង្ហាញថា សមាមាត្រដ៏ធំមួយនៃបុរសក្នុងក្រុមដែលប្រឈមមុខនឹង គ្រោះថ្នាក់ខ្ពស់ (ដូចជា យោធា នគរបាល និងអ្នករត់ម៉ូតូឌុប) បានទៅរកនារីរកស៊ីផ្លូវភេទម្តងម្កាលក្នុងជីវិតរបស់ ពួកគេ ១៧-៣០ ភាគរយ ក្នុងឆ្នាំកន្លងទៅ និង ៨-២០ភាគរយ ក្នុងខែកន្លងមក។

តាមលទ្ធផលនៃការស្រាវជ្រាវថ្មីៗ (PSI ឆ្នាំ២០០២) ក៏បានបង្ហាញផងដែរពីស្ថានភាពមួយចំនួនដែលនាំទៅដល់ ការរកស៊ីផ្លូវភេទ រួមទាំងទំនាក់ទំនងយូរអង្វែងជាមួយ "សង្សារ"។ ទំនាក់ទំនងជាសង្សារ គឺផ្អែកទៅលើកំរិតនៃការ ទុកចិត្ត និងការស្រលាញ់គ្នាទៅវិញទៅមក ដោយមានការសន្មត់អំពី "ទំនៀមទំលាប់រៀបការតែប្រពន្ធមួយ ឬប្តីមួយ" របស់នារី និងបុរសដែលត្រូវរៀបការជាមួយនឹងនរណាម្នាក់ (PSI ឆ្នាំ២០០២)។

កត្តាទាំងនេះ បានបង្កឱ្យមានការលំបាកចំពោះនារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ ក្នុងការចរចាជាមួយបុរសឱ្យ ប្រើប្រាស់ស្រោមអនាម័យក្នុងពេលរួមភេទ។ យុទ្ធនាការឃោសនាសង្គម ហាក់ដូចជាបានរួមចំណែកបង្កើនការ ប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមអតិថិជន និងនារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ ដូច្នេះចាំបាច់ត្រូវខិតខំ ប្រឹងប្រែងឱ្យមានការបន្ត និងបង្កើនការប្រើប្រាស់ស្រោមអនាម័យ ក្នុងចំណោមអតិថិជន និងនារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់។

## ៦.១.៦ នារីរៀបការរួច ប្រឈមមុខនឹងគ្រោះថ្នាក់ច្រើន

នារីរៀបការរួច ប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍កាន់តែច្រើនឡើង ហើយនៅក្នុងក្រុមនេះហើយដែល មេរោគអេដស៍ មានការរីករាលដាលយ៉ាងលឿន។ ការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមនារីរៀបការរួច មានតែ ១ភាគរយប៉ុណ្ណោះ។ ស្រោមអនាម័យពាក់ព័ន្ធទៅនឹងកង្វះការទុកចិត្ត ការមិនស្មោះត្រង់ និងជំងឺ: ការសុំឱ្យប្តីប្រើ ស្រោមអនាម័យ មានន័យថា សង្ស័យថាប្តីមិនស្មោះត្រង់។ ការពិភាក្សាអំពីការពន្យារកំណើតនៅក្នុងចំណោមនារី រៀបការរួចមានកំរិតទាប ដោយនារីភាគច្រើនបានពិភាក្សាអំពីការពន្យារកំណើតជាមួយប្តីរបស់ខ្លួន តែម្តង ឬពីរដង ក្នុងមួយឆ្នាំ ឬអត់សោះ (ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០០០)។ ការផ្សព្វផ្សាយអំពីការប្រើប្រាស់ ស្រោមអនាម័យនៅមានកំរិត។

## ៦.១.៧ ទស្សនៈយេនឌ័រមិនត្រឹមត្រូវ មានឥទ្ធិពលលើការប្រព្រឹត្តផ្លូវភេទរបស់បុរស

ទស្សនៈយេនឌ័រមិនត្រឹមត្រូវទាក់ទងនឹងសុខភាពផ្លូវភេទ និងការប្រព្រឹត្តផ្លូវភេទ ធ្វើឱ្យមេរោគអេដស៍ កាន់តែរីករាលដាលខ្លាំងឡើងនៅកម្ពុជា។ សង្គមកម្ពុជា មិនអនុញ្ញាតឱ្យមានសកម្មភាពរួមភេទមុនពេលរៀបការទេ ហើយព្រហ្មចារីយ៍របស់នារី ត្រូវបានចាត់ទុកថាជារបស់ចាំបាច់មុនពេលរៀបការ។ តំលៃនៅក្នុងសង្គមរបស់នារីខ្មែរ គឺភាពរម្យទម ការចេះស្តាប់ដំបូន្មាន និងការមិនយកចិត្តទុកដាក់ខាងផ្លូវភេទ។ នារីដែលបាត់បង់ព្រហ្មចារីយ៍មុនពេលរៀបការ ត្រូវបានគេចាត់ទុកថាជា "ស្រីដែលបាត់បង់កិត្តិយស" ហើយមានកេរ្តិ៍ឈ្មោះមិនល្អ។ ទន្ទឹមនឹងនេះ បុរសខ្មែរមួយចំនួនចាត់ទុកការទៅរកនារីរកស៊ីផ្លូវភេទ និងការរួមភេទក្រៅអាពាហ៍ពិពាហ៍ ជាផ្នែកមួយនៃសកម្មភាពធម្មតារបស់មនុស្សប្រុស (GAD-C ឆ្នាំ២០០៣) ដែលត្រូវបានគេទទួលស្គាល់នៅពេលចាកចេញឆ្ងាយពីផ្ទះ និងជាផ្នែកមួយនៃលក្ខណៈរបស់មនុស្សប្រុស។ ការទៅរកនារីរកស៊ីផ្លូវភេទ តាមការបបួលរបស់មិត្តភ័ក្រ្ត មានកំរិតខ្ពស់នៅក្នុងចំណោមក្រុមបុរសមួយចំនួន។ ការឱ្យនិយមន័យអំពីភេទប្រុស បានជំរុញឱ្យមនុស្សប្រុសមានប្រៀបជាង មានអំណាច និងរួមភេទជាមួយនារីមិនរើសមុខដែលធ្វើឱ្យនារី មានការលំបាកក្នុងការចរចាអំពីការប្រើប្រាស់ស្រោមអនាម័យ។ ហេតុដូច្នេះ ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ឱ្យមានប្រសិទ្ធិភាព អន្តរាគមន៍នានា ត្រូវដោះស្រាយបញ្ហាអំពីនិយមន័យនៃភាពជាមនុស្សប្រុសពេញលក្ខណៈ និងបទដ្ឋានសង្គមទាក់ទងនឹងការប្រព្រឹត្តិផ្លូវភេទរបស់មនុស្សប្រុស។

## ៦.១.៨ នារី ទទួលបន្ទុកថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

តាមធម្មតា បន្ទុកថែទាំកុមារកំព្រាដោយសារជំងឺអេដស៍ ត្រូវធ្លាក់ទៅលើម្តាយមីង និងជីដូន ដោយពួកគាត់ត្រូវចំណាយពេលវេលា និងធនធានបន្ថែម ជាពិសេសនៅក្នុងគ្រួសារក្រីក្រ។ នារីរៀបការរួចដែលឆ្លងមេរោគអេដស៍ពីប្តី ហើយជំងឺរបស់ប្តីខ្លួនកំពុងវិវត្តន៍ទៅភាពធ្ងន់ធ្ងរ ត្រូវជាប់រវល់តែនឹងការថែទាំប្តី ហើយទន្ទឹមនឹងនេះដែរ នារីទាំងនោះក៏ចេះតែធ្លាក់ខ្លួនឈឺធ្ងន់ទៅៗ ដោយសារជំងឺមានការវិវត្តន៍ក្នុងសរីរាង្គកាយរបស់ពួកគេ។ ទោះបីជាមិនមានទិន្នន័យស្តីពីក្មេងស្រីបោះបង់ចោលការសិក្សា ដើម្បីមកនៅថែទាំសមាជិកគ្រួសារដែលមានជំងឺអេដស៍ក៏ដោយ ក៏លទ្ធផលនៃការស្រាវជ្រាវជាច្រើនបានបង្ហាញថា បញ្ហានេះបានកើតមានឡើងជាទូទៅ (Bredenburg et al ឆ្នាំ២០០៣ និង Velaso ឆ្នាំ២០០២)។ ប្រជាជនកម្ពុជាភាគច្រើន មិនមានលទ្ធភាពទទួលថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ទេ (ART-ថ្នាំពន្យារការស្លាប់) ឬសូម្បីតែការព្យាបាលជំងឺឱ្យបានទៀងទាត់ ក៏គ្មានដែរ។ ចំពោះប្រជាជនកម្ពុជាភាគច្រើន ការព្យាបាលជំងឺឱកាសនិយមដូចជា ជំងឺរលាកសួត ជំងឺរាគរូស និងជំងឺ Toxoplasmosis ត្រូវធ្វើឡើងតែនៅតាមផ្ទះ។ ជំងឺទាំងអស់នេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា និងការថែទាំជាប្រចាំពីសំណាក់នារី និងក្មេងស្រីនៅក្នុងគ្រួសារ។

### ៦.១.៩ លទ្ធភាពទទួលបានការព្យាបាលប្រឆាំងនឹងមេរោគអេដស៍នៅមានកំរិត

ថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ អាចរកទិញបាននៅតាមឱសថស្ថាននានា និងពីអ្នកលក់ដុំនៅទីក្រុងភ្នំពេញ និងកន្លែងផ្សេងទៀត ដោយមិនចាំបាច់មានវេជ្ជបញ្ជា។ តំលៃថ្នាំពន្យាការស្លាប់នេះ ប្រែប្រួលក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ បច្ចុប្បន្ន តំលៃថ្នាំប្រឆាំងមេរោគអេដស៍ដែលដាក់លក់នៅតាមឱសថស្ថាននានាក្នុងទីក្រុងភ្នំពេញ បានកើនឡើងពី ៤០ដុល្លាអាមេរិក ទៅ ៥០ដុល្លាអាមេរិក ក្នុង១ខែ ចំណែកការសិក្សាស្រាវជ្រាវអំពីតំលៃថ្នាំ ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០២ បានបង្ហាញថា តំលៃនៅលើទីផ្សារសំរាប់ព្យាបាលរយៈពេលមួយខែគឺ ៦០ដុល្លាអាមេរិក ដែលនឹងអាចឡើងរហូតដល់ ៦០០ដុល្លាអាមេរិក សំរាប់ថ្នាំប្រឆាំងមេរោគអេដស៍ ដែលផ្សំឡើងដោយថ្នាំបីប្រភេទ (Triple Therapy) (ប្រព័ន្ធសហប្រជាជាតិឆ្នាំ២០០២)។ តំលៃដ៏ខ្ពស់បែបនេះ ជាឧបសគ្គចំពោះប្រជាជនកម្ពុជាភាគច្រើន។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន កំពុងផ្តល់ថ្នាំ ART ដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលតំរូវឱ្យពួកគេបង់ប្រាក់បន្តិចបន្តួច ឬមិនបាច់បង់ប្រាក់ ប៉ុន្តែកម្មវិធីនេះ មិនទាន់ដំណើរការទំលំទូលាយនៅឡើយ។

ទោះបីជាថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ ART មាននៅជនបទក៏ដោយ ក៏នៅក្រោមប្រព័ន្ធសុខាភិបាលបច្ចុប្បន្ន នារីពុំសូវទទួលបានការព្យាបាលនេះទេ ព្រោះថា ជាទូទៅ នារីពុំសូវមានលទ្ធភាពទទួលបានប្រើប្រាស់សេវាសុខភាពទេ។ លើសពីនេះទៀតនារីជាច្រើន មិនបានទៅធ្វើតេស្តឈាមរកមេរោគអេដស៍ទេ រហូតដល់ដំណាក់កាលវិវត្តន៍ចុងក្រោយនៃជំងឺ ដែលមានន័យថា នារីអាចនឹងពុំបានទទួលការថែទាំ និងការគាំទ្រត្រឹមត្រូវនៅក្នុងដំណាក់កាលដំបូងនៃជំងឺទេ (ប្រព័ន្ធសហប្រជាជាតិ ឆ្នាំ២០០២)។ ការព្រួយបារម្ភមួយទៀត គឺថាការប្រើប្រាស់ថ្នាំប្រឆាំងនឹងមេរោគដេអេដស៍ មិនត្រឹមត្រូវតាមកាលកំណត់ ឬការប្រើប្រាស់ថ្នាំក្លែងក្លាយ អាចធ្វើឱ្យមានការកើនឡើងនូវភាពស៊ាំនឹងថ្នាំ (ប្រព័ន្ធសហប្រជាជាតិ ឆ្នាំ២០០២)។ នារីក្រីក្រមានកំរិតវប្បធម៌ទាប ដែលរស់នៅតំបន់ដាច់ស្រយាលទំនងជាងាយទទួលរងគ្រោះបំផុត ។

ការប្រើប្រាស់ថ្នាំបង្ការមេរោគ ណេវីរ៉ាពីន (nevirapine) មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយការចំលងពីម្តាយទៅកូន។ ទោះជាយ៉ាងណាក៏ដោយ នារីមានផ្ទៃពោះ និងនារីឆ្លងទន្លេរួច នៅតែមានបញ្ហាទាក់ទងនឹងលទ្ធភាពទទួលបានថ្នាំ និងសេវាព្យាបាលនេះ។

## ៦.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

នៅឆ្នាំ១៩៩១ រាជរដ្ឋាភិបាល បានបង្កើតឡើងនូវកម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ ហើយក្រោយមកនៅឆ្នាំ១៩៩៤ គណៈកម្មាធិការខេត្ត-ក្រុងប្រយុទ្ធនឹងជំងឺអេដស៍ ក៏ត្រូវបានបង្កើតឡើងផងដែរ។ កន្លងទៅថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើរស្បែក និងកាមរោគ (NCHADS) ដើម្បីតាមដាន និងគ្រប់គ្រងការរីករាលដាលនៃមេរោគអេដស៍នៅទូទាំងប្រទេស។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គឺជាស្ថាប័នពហុវិស័យមួយ ដែលមានតំណាងមកពីក្រសួងពាក់ព័ន្ធទាំងអស់ចំនួន ២៦។

អាជ្ញាធរនេះ មានភារកិច្ចសំរបសំរួលគ្រប់សកម្មភាពសំខាន់ៗរបស់ក្រសួងពាក់ព័ន្ធ រៀបចំអនុសាសន៍ គោលនយោបាយ និង ធានាឱ្យមានការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវពត៌មាន និងផ្សព្វផ្សាយពត៌មាន ។ អាជ្ញាធរបានខិតខំប្រឹងប្រែងរៀបចំយុទ្ធវិធីពហុវិស័យ ដែលមានលក្ខណៈទូលំទូលាយ ឧទាហរណ៍ៈ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការពារជាតិ មានផែនការជាយុទ្ធសាស្ត្រសំរាប់ដោះស្រាយបញ្ហាអេដស៍ ។ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក៏កំពុងតែអនុវត្តសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ហើយក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក៏មានផែនការចាប់ផ្តើមអនុវត្តសកម្មភាពដូចគ្នានេះដែរ ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើរស្បែក និងកាមរោគ ទទួលខុសត្រូវចំពោះប្រព័ន្ធពិនិត្យតាមដានសុខភាពប្រជាជន និងរៀបចំផែនការ និងកម្មវិធីសំរាប់បង្ការមេរោគអេដស៍/ជំងឺអេដស៍ ។

ផែនការជាយុទ្ធសាស្ត្រឆ្នាំ២០០១-២០០៥ សំរាប់បង្ការ និងថែទាំអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ និងជំងឺកាមរោគ ត្រូវការថវិកាប្រហែល ៦,៥លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ដែលត្រូវផ្តល់ជូនតាមរយៈវិស័យសុខាភិបាល ដើម្បីគាំទ្រដល់សកម្មភាពនានា ។ អ្នកជំនួយទ្វេភាគី ទីភ្នាក់ងារពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន មានកម្មវិធីបង្ការមេរោគអេដស៍/ជំងឺអេដស៍ និងកំពុងរង់ចាំមូលនិធិបន្ថែម ជាពិសេស សំរាប់ការថែទាំ និងគាំទ្រ ។ ផែនការជាតិសំរាប់ផ្តល់លទ្ធភាពទទួលបានការថែទាំ ការគាំទ្រ និងការព្យាបាលជាប្រព័ន្ធ ត្រូវបានបង្កើតឡើង រួមទាំងការផ្តល់ថ្នាំ ART ដោយឥតគិតថ្លៃ ។ ទោះបីជាចំនួនអ្នកទទួលបានការព្យាបាលដោយឥតគិតថ្លៃ កំពុងតែកើនឡើង ប៉ុន្តែការរីកចំរើនមានតិចតួចប៉ុណ្ណោះ ។

ក្រសួងសុខាភិបាល ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាទាក់ទងនឹងការប្រយុទ្ធនឹងជំងឺអេដស៍ ។ នៅថ្នាក់ខេត្ត-ក្រុង មន្ទីរសុខាភិបាល និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខេត្ត-ក្រុងនិមួយៗ បានរៀបចំគោលនយោបាយ ព្រមទាំងសំរបសំរួល និងអនុវត្តសកម្មភាពបង្ការនានា ។

ដោយពិនិត្យឃើញមានការចំណាយខ្ពស់ទៅលើជំងឺរុំារ៉ៃសំរាប់ប្រជាជនក្រីក្រ ជាពិសេសនារី យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បានកំណត់នូវអាទិភាព ៤ សំរាប់ការកាត់បន្ថយភាពក្រីក្រដូចជា ៖

១) ពង្រីកប្រព័ន្ធថែទាំឱ្យដល់ក្រុមអ្នកក្រីក្របំផុត ដើម្បីឱ្យពួកគេមានលទ្ធភាពទទួលបានការព្យាបាលសមស្របក្នុងតំលៃមួយទាប ។

២) អនុវត្តកម្មវិធីបង្ការនៅក្នុងសហគមន៍នេសាទ និងកម្មករ/ពលករទេសន្តរប្រវេសន៍ ។

៣) ធានាឱ្យមានការប្តេជ្ញាចិត្តពីអ្នកនយោបាយសំខាន់ៗ ចំពោះការបង្ការមេរោគអេដស៍/ជំងឺអេដស៍ និងការថែទាំអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ។ និង

៤) ពង្រឹងការធ្វើវិមជ្ឈការថវិកា និងពង្រឹងរចនាសម្ព័ន្ធខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ។

# ជំពូកទី ៦

# បញ្ហាយេនឌ័រ និង ជំងឺអេដស៍


**កម្ពុជានាពេលបច្ចុប្បន្ន** ........................................ ១៣៣

**៦.១ ស្ថានភាព បញ្ហា និង និន្នាការ** ........................................ ១៣៣

៦.១.១ អត្រាឆ្លងថ្មីបានថយចុះនៅក្នុងចំណោមបុរស ចំណែកនៅក្នុងចំណោមនារីវិញ អត្រានេះនៅថេរ ... ១៣៤

៦.១.២ អត្រាឆ្លងមេរោគអេដស៍ក្នុងចំណោមនារីរកស៊ីផ្លូវភេទ បានថយចុះនៅពេលដែលមានការកើនឡើងនូវការប្រើប្រាស់ស្រោមអនាម័យ ........................................ ១៣៦

៦.១.៣ អត្រានៃការឆ្លងមេរោគអេដស៍ មានការថយចុះក្នុងចំណោមនារីដែលទទួលសេវាថៃរក្សាគភ៌ ...... ១៣៧

៦.១.៤ ផ្លូវនៃការចំលងមេរោគអេដស៍ កំពុងតែមានការផ្លាស់ប្តូរ ........................................ ១៣៩

៦.១.៥ នារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ នៅតែប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍ ................ ១៤០

៦.១.៦ នារីរៀបការរួច ប្រឈមមុខនឹងគ្រោះថ្នាក់ច្រើន ........................................ ១៤០

៦.១.៧ ទស្សនះយេនឌ័រមិនត្រឹមត្រូវ មានឥទ្ធិពលលើការប្រព្រឹត្តិផ្លូវភេទរបស់បុរស ........................ ១៤១

៦.១.៨ នារីទទួលបន្ទុកថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ........................ ១៤១

៦.១.៩ លទ្ធភាពទទួលបានការព្យាបាលប្រឆាំងនឹងមេរោគអេដស៍នៅមានកំរិត ........................ ១៤២

**៦.២ គោលនយោបាយ និង យុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល** ........................................ ១៤២

# ជំពូកទី ៦ : បញ្ហាមេរោគអេដស៍ និង ជំងឺអេដស៍

## កម្ពុជានាពេលបច្ចុប្បន្ន[១]

| សូចនាករ | តំលៃ |
|---|---|
| អត្រាឆ្លងមេរោគអេដស៍ទូទាំងប្រទេស (ភាគរយ) | ២.៦ |
| ចំនួនអ្នកផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍នៅឆ្នាំ២០០២ | ១៥៧.៤៨៣ នាក់ |
| ចំនួននារីដែលផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍នៅឆ្នាំ២០០២ | ៧៥.៤៤៨ នាក់ |

## ៦.១ ស្ថានភាព បញ្ហា និង និន្នាការ

តាមសេចក្តីរាយការណ៍បានឱ្យដឹងថា នៅកម្ពុជាមានករណីឆ្លងមេរោគអេដស៍/អេដស៍ដំបូងនៅឆ្នាំ១៩៩១ ហើយអត្រានៃការឆ្លងមេរោគនេះ បានកើនឡើងយ៉ាងលឿនក្នុងទសវត្សរ៍នោះ ។ តាមការប៉ាន់ស្មាន អត្រាឆ្លងមេរោគអេដស៍នៅកម្ពុជាមានកំរិតទាបគឺ ៨ភាគរយ ដែលបង្ហាញឱ្យឃើញថា បញ្ហានេះទំនងជាមានការកើនឡើង (ផ្អែកតាមរបាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជាឆ្នាំ២០០១) ។ នៅកម្ពុជា មានអត្រានៃការឆ្លងមេរោគអេដស៍/អេដស៍ខ្ពស់ជាងគេបំផុតនៅក្នុងអាស៊ីអាគ្នេយ៍ ទោះបីជាអត្រារីករាលដាលនេះ បានថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះក៏ដោយ ។ ការរីករាលដាលនៃមេរោគនេះភាគច្រើន គឺឆ្លងតាមរយៈការរួមភេទ ។

ចាប់តាំងពីឆ្នាំ១៩៩៧ មក អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យទូទាំងប្រទេសបានថយចុះជាលំដាប់ (ក្រាហ្វិក ៦.១) ពោលគឺ ពី ៣.៣ភាគរយ មកនៅត្រឹម ២.៦ភាគរយ (ផ្អែកតាមរបាយការណ៍ឆ្នាំ២០០១ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើរស្បែក និងកាមរោគ) ។ ចំនួនអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍បានថយចុះពី ២១០.០០០នាក់ នៅឆ្នាំ១៩៩៧ មកនៅត្រឹម ១៥៧.៤៨៣នាក់ នៅឆ្នាំ២០០២ ក្នុងនោះមានបុរស ៨២.០៣៧នាក់ និងនារី ៧៥.៤៤៨នាក់ (NCHADS ឆ្នាំ២០០២) ។ ដោយឡែក គេសង្កេតឃើញមានការរីកចំរើនយ៉ាងខ្លាំង នូវការទប់ស្កាត់ការឆ្លងមេរោគអេដស៍នៅក្នុងចំណោមនារីរកស៊ីផ្លូវភេទ និងអតិថិជនរបស់ពួកគេ ។ ប្រតិបត្តិការនេះ សំរេចបានជោគជ័យតាមរយៈកម្មវិធីបង្កើនការយល់ដឹងអំពីការប្រើប្រាស់ស្រោមអនាម័យ លទ្ធភាពប្រើប្រាស់ស្រោមអនាម័យ និងគុណភាពការផ្តល់ការព្យាបាលជំងឺកាមរោគ ការធានាឱ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ (ឧទាហរណ៍ : ម្ចាស់ផ្ទះបន និងនគរបាល) និងការគ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធិភាពនៅផ្ទះបន ។

---

[១] ប្រភព : មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើស្បែក និងកាមរោគ ឆ្នាំ២០០២: ការអង្កេតតាមដានការប្រព្រឹត្តិ និន្នាការពីឆ្នាំ១៩៩៧-២០០១

ទោះបីជាអត្រាអ្នកឆ្លងមេរោគអេដស៍/ជំងឺអេដស៍ មានការថយចុះ ដែលជាលទ្ធផលនៃការថយចុះនៃអត្រាអ្នកឆ្លងថ្មី និងដោយសារអ្នកជំងឺអេដស៍មុនៗបានស្លាប់បាត់ទៅក៏ដោយ ក៏ការរីករាលដាលនៃមេរោគអេដស៍ នៅតែគំរាមកំហែងចំពោះការអភិវឌ្ឍន៍មនុស្សនៅកម្ពុជា (NCHADS ឆ្នាំ២០០២) ។ ការរីករាលដាលនៃមេរោគអេដស៍ អាចមានការវិវត្តន៍យ៉ាងលឿនដែលមិនអាចប៉ាន់ស្មានបានជាមុន (UNGASS ឆ្នាំ២០០៣) ។ ដោយឡែក នារីអាចប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍នៅក្នុងចំណងទាក់ទងយូរអង្វែងក្នុងអាពាហ៍ពិពាហ៍ និងក្រៅអាពាហ៍ពិពាហ៍ (UNGASS ឆ្នាំ២០០៣) ។ ជាការចាំបាច់ត្រូវមានយុទ្ធសាស្ត្របង្ការថ្មី ដើម្បីធ្វើឱ្យនិន្នាការនៃការីករាលដាលបន្តធ្លាក់ចុះតទៅទៀត ។ ជាចុងក្រោយនេះ មនុស្សមួយចំនួនធំនៅកម្ពុជា មានផ្ទុកមេរោគអេដស៍ ហើយការពង្រីកលទ្ធភាពប្រើប្រាស់សេវាថែទាំ សេវាគាំទ្រ និងការព្យាបាលសំរាប់បុរស និងនារីទាំងនោះគឺជាតំរូវការបន្ទាន់ ។

**ក្រាហ្វិក ៦.១: អត្រាមនុស្សពេញវ័យឆ្លងមេរោគអេដស៍**




**ប្រភព:** មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ (NCHADS ឆ្នាំ២០០២)

## ៦.១.១ អត្រាឆ្លងថ្មីបានថយចុះនៅក្នុងចំណោមបុរស ចំណែកនៅក្នុងចំណោមនារីវិញ អត្រានេះនៅថេរ

ចំនួនអ្នកទើបឆ្លងមេរោគអេដស៍ថ្មីក្នុងមួយឆ្នាំៗ ហាក់ដូចជាមានការថយចុះ តាំងពីឆ្នាំ១៩៩៤ មក ក្នុងចំណោមបុរស និងតាំងពីឆ្នាំ១៩៩៦ មកក្នុងចំណោមនារី (HSS ឆ្នាំ២០០២) ។ ទោះជាយ៉ាងណាក៏ដោយ ក៏ទិន្នន័យស្ដីពីអ្នកដែលឆ្លងថ្មីនៅមានកំរិត ដោយសារមិនមានការអង្កេតតាមដាននៅក្នុងចំណោម បុរសដែលរួមភេទជាមួយនឹងបុរស ប៉ុន្តែការអង្កេតទ្រង់ទ្រាយតូចមួយដែលត្រូវបានធ្វើឡើងដោយអង្គការ សុខភាពគ្រួសារអន្តរជាតិ (Family Health International) បានបង្ហាញឱ្យឃើញថា អត្រានៃការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមបុរសមាន ១៤ ភាគរយ ។ ចំនួនបុរសដែលកំពុងផ្ទុកមេរោគអេដស៍ ត្រូវបានធ្លាក់ចុះតាំងពីឆ្នាំ១៩៩៧ មក ចំណែកឯចំនួននារី ដែលឆ្លង

មេរោគអេដស៍បន្តកើនឡើង ហើយកំពុងតែចាប់ផ្តើមនៅថេរ (ក្រាហ្វិក ៦.២ និង៦.៣)។ នៅកម្ពុជា ក្រុមដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់មានដូចជា នារីរកស៊ីផ្លូវភេទ និងអតិថិជនរបស់ពួកគេ។ ការអង្កេតអត្រានៃការឆ្លងមេរោគអេដស៍ ប្រមូលបានពត៌មានពីក្រុមមួយចំនួនដូចជា នគរបាល យោធា និងនារីរកស៊ីផ្លូវភេទ ព្រមទាំងនារីដែលទទួលការថែទាំរក្សាគភ៌។

### ក្រាហ្វិក ៦.២: ចំនួននារីដែលឆ្លងមេរោគអេដស៍




ប្រភព: ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២០០២ (HIV sentinel survey, ឆ្នាំ២០០២)

### ក្រាហ្វិក ៦.៣: ចំនួនបុរសដែលឆ្លងមេរោគអេដស៍




ប្រភព: ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២០០២ (HIV sentinel survey, ឆ្នាំ២០០២)

ដើម្បីពន្យល់អំពីការរីកចំរើនក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ កថាខ័ណ្ឌក្រោយៗនេះ ផ្តោតទៅលើនារីរកស៊ីផ្លូវភេទផ្ទាល់ និងនារីមានផ្ទៃពោះដែលទទួលសេវាថែរក្សាគភ៌ ។

## ៦.១.២ អត្រាឆ្លងមេរោគអេដស៍ក្នុងចំណោមនារីរកស៊ីផ្លូវភេទ បានថយចុះនៅពេលដែលមានការកើនឡើងនូវការប្រើប្រាស់ស្រោមអនាម័យ

នៅកម្ពុជា ការចំលងមេរោគអេដស៍ពីនារីរកស៊ីផ្លូវភេទទៅអតិថិជន មានសមាមាត្រខ្ពស់នៅទសវត្សរ៍ឆ្នាំ១៩៩០ ។ នៅឆ្នាំ១៩៩៨ ជិតពាក់កណ្តាលនៃនារីរកស៊ីផ្លូវភេទ មានផ្ទុកមេរោគអេដស៍ ។ ការធ្លាក់ចុះនៃអត្រាឆ្លងដែលគួរឱ្យកត់សំគាល់នោះ គឺនៅក្នុងចំណោមនារីរកស៊ីផ្លូវភេទពោលគឺ ពី ៤២.៦ នៅឆ្នាំ១៩៩៨ មកនៅត្រឹម ២៨.៨ នៅឆ្នាំ ២០០២ ។ ការស្លាប់របស់អ្នកជំងឺអេដស៍ អាចជាផ្នែកមួយនៃការធ្លាក់ចុះអត្រានៃការឆ្លងមេរោគអេដស៍ ឬជំងឺអេដស៍ (CHDR ឆ្នាំ២០០១) ។ ប៉ុន្តែការប្រើប្រាស់ស្រោមអនាម័យទាំងភ្ញៀវ និងនារីរកស៊ីផ្លូវភេទ បានកើនឡើងជាលំដាប់ រហូតជិតដល់ ៩០ភាគរយ នៅឆ្នាំ២០០២ (NCHADS ឆ្នាំ២០០២) ។ ដោយផ្អែកតាមរបាយការណ៍ដែលទទួលបានក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ បានជំរុញឱ្យមានការព្រមព្រៀងលើការប្រើវិធីសាស្ត្រការបង្ការមេរោគអេដស៍នៅតាមផ្ទះបន ដែលធ្វើឱ្យមានការកើនឡើងយ៉ាងលឿននូវការប្រើប្រាស់ស្រោមអនាម័យ (ក្រាហ្វិក ៦.៤) ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានរបាយការណ៍ដែលគួរឱ្យចាប់អារម្មណ៍ថា អតិថិជនបានវាយដំនារីរកស៊ីផ្លូវភេទ ដែលទទូចសុំឱ្យពួកគេប្រើប្រាស់ស្រោមអនាម័យ ។

យើងគួរតែមានការព្រួយបារម្ភចំពោះការរីករាលដាលនៃជំងឺអេដស៍ ពីព្រោះថា នារីក្មេងៗ និងនារីរកស៊ីផ្លូវភេទថ្មីៗជាច្រើន បានចូលទៅក្នុងឧស្សាហកម្មភេទ ។ ជាការចាំបាច់ត្រូវបន្តការអប់រំអំពីការបង្ការមេរោគអេដស៍ ។ លើសពីនេះទៀត តម្រូវការការរកស៊ីផ្លូវភេទនៅក្រៅផ្ទះបននៅតែបន្តកើតមាន ហើយការភ័យខ្លាចឆ្លងមេរោគអេដស៍ក៏កំពុងតែរីករាលដាលខ្លាំងក្លាដែរ ។ ការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមនារីរកស៊ីផ្លូវភេទមិនផ្ទាល់ (នារីក្មេងៗដែលធ្វើជាអ្នកឃោសនាស្រាបៀរ (ស្រីឡង់សេ) អ្នកចំរៀងខារ៉ាអូខេ ។ល ។ ប៉ុន្តែបំរើសេវាផ្លូវភេទ) មានប្រហែលតែ ៥៦ភាគរយប៉ុណ្ណោះ ដូច្នេះជាការចាំបាច់ត្រូវធ្វើការអប់រំបន្ថែមទៀត ដើម្បីបង្កើនការប្រើប្រាស់ស្រោមអនាម័យនៅក្នុងក្រុមទាំងនេះ (NCHADS ឆ្នាំ២០០២) ។ បញ្ហាដែលគួរឱ្យព្រួយបារម្ភដែរនោះ គឺមានរបាយការណ៍ទាក់ទងនឹងអំពើហឹង្សា និងការរំលោភរបស់ក្រុមបងធំទៅលើនារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ដែលរារាំងដល់ការប្រើប្រាស់ស្រោមអនាម័យ (PSI ឆ្នាំ២០០២ និង GAD-C ឆ្នាំ២០០៣) ។

*"ខ្ញុំធ្វើជានារីរកស៊ីផ្លូវភេទដើម្បីចិញ្ចឹមគ្រួសារខ្ញុំ។ គ្មានអ្វីផ្សេងទៀតដែលខ្ញុំអាចធ្វើបាននោះឡើយ បើពុំនោះទេគ្រួសារខ្ញុំនឹងឈឺចាប់។ ខ្ញុំមានជំងឺអេដស៍ ហើយអាចស្លាប់មុនពេលដែលគ្រួសាររបស់ខ្ញុំអាចថែរក្សាខ្លួនឯង។ នេះគឺជាស្ថានភាពគួរឱ្យខ្លាចណាស់ ប៉ុន្តែខ្ញុំមិនអាចធ្វើអ្វីបានឡើយ...ខ្ញុំគិតថា នេះគឺជាស្ថានភាពរបស់អ្នកក្រីក្រជាច្រើន"*។ **នេះជាសំដីរបស់នារីម្នាក់ដែលមានអាយុជាង ២០ឆ្នាំ នៅក្នុងរបាយការណ៍ស្តីពីការវាយតំលៃភាពក្រីក្រ (ADB ឆ្នាំ២០០១)។**

**ក្រាហ្វិក ៦.៩: អត្រាឆ្លងមេរោគអេដស៍ និងការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមនារីរកស៊ីផ្លូវភេទផ្ទាល់**




**សំគាល់:** BSS មានន័យថា ការអង្កេតតាមដានការប្រព្រឹត្តិ

**ប្រភព:** ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២០០២ (HIV sentinel survey, ឆ្នាំ២០០២)

## ៦.១.៣ អត្រានៃការឆ្លងមេរោគអេដស៍ មានការថយចុះក្នុងចំណោមនារីដែលទទួលសេវាថែរក្សាគភ៌

អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីដែលទទួលសេវាថែរក្សាគភ៌ ជាពិសេសក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ ត្រូវបានចាត់ទុកថាជាការឆ្លងថ្មី និងជាចលនានៃការរីករាលដាលចូលទៅក្នុងចំណោមប្រជាជនទូទៅ ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើរស្បែក និងកាមរោគ (ឆ្នាំ២០០២) បានប៉ាន់ស្មានឃើញថា នារីមានផ្ទៃពោះប្រហែល ៤៥ភាគរយ ទទួលបានសេវាថែរក្សាគភ៌ (បើប្រៀបធៀបជាមួយនឹងតួលេខរបស់ CDHS ឆ្នាំ២០០០ ដែលមានតែ ៣៨ភាគរយ) ។ អត្រានៃការឆ្លងមេរោគហ៊ីវ ក្នុងចំណោមនារីមានផ្ទៃពោះ ដែលទទួលបានសេវាថែរក្សាគភ៌ ហាក់ដូចជានៅថេរ ពោលគឺ ២.៦ភាគរយ (សូមមើលក្រាហ្វិក ៦.៥) ។

**ក្រាហ្វិក ៦.៥: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីដែលទទួលការថែរក្សាគភ៌**




**ប្រភព:** មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគឆ្នាំ២00២ (NCHADS ឆ្នាំ២00២)

អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីមានផ្ទៃពោះ ខុសប្លែងគ្នាពីខេត្តមួយទៅខេត្តមួយទៀត ហើយខេត្តដែលនៅជិតព្រំដែនប្រទេសថៃ (ក្រាហ្វិក ៦.៦) មានអត្រានៃការឆ្លងខ្ពស់ជាងគេបំផុត ដោយសារខេត្តទាំងនោះមានកម្មករ និងពលករដែលធ្វើទេសន្តរប្រវេសន៍ និងប្រជាជនចល័តច្រើន ។ ប្រជាពលរដ្ឋខ្មែរចំនួន ៥ម៉ឺននាក់ ធ្វើការនៅក្នុងប្រទេសថៃដូចជា កម្មករសំណង់ កសិករ ឬអ្នកដើរកប៉ាល់សមុទ្រ (អង្គការ PATH បានលើកឡើងពីបញ្ហានេះក្នុង UNGASS ឆ្នាំ២00៣) ។ នៅខេត្តរតនគិរី អត្រានៃការឆ្លងក៏មានកំរិតខ្ពស់ដែរ ដោយសារតែមានប្រជាជនចល័តនៅទីនោះ ។

**ក្រាហ្វិក ៦.៦: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងតំបន់ ក្នុងចំណោមនារីមានផ្ទៃពោះដែលទទួលការថែរក្សាគភ៌**




**ប្រភព:** ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២00២ (HIV sentinel survey, ឆ្នាំ២00២)

អត្រានៃការឆ្លងក្នុងចំណោមនារីមានផ្ទៃពោះ មានកំរិតខ្ពស់បំផុតនៅក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ ( ក្រាហ្វិក ៦.៧) ។

**ក្រាហ្វិក ៦.៧: អត្រានៃការឆ្លងមេរោគអេដស៍ក្នុងចំណោមនារីមានផ្ទៃពោះ**




## ៦.១.៤ ផ្លូវនៃការចំលងមេរោគអេដស៍ កំពុងតែមានការផ្លាស់ប្តូរ

ទោះបីជាផ្លូវនៃការចំលងមេរោគអេដស៍ កំពុងធ្លាក់ចុះ ប៉ុន្តែ ការចំលងពីម្តាយទៅកូន និងការចំលងពីប្តីទៅប្រពន្ធ ពុំបានធ្លាក់ចុះឡើយ ហើយនារី និងកុមារចំនួនកាន់តែច្រើនឡើង ជាជនងាយរងគ្រោះដោយសារការឆ្លងមេរោគ អេដស៍ ។

**ក្រាហ្វិក ៦.៨: ផ្លូវនៃការចំលងមេរោគអេដស៍ទៅតាមពេលវេលា**




ប្រភព: ការអង្កេតតាមដានការឆ្លងមេរោគអេដស៍ឆ្នាំ២០០២ (HIV sentinel survey, ឆ្នាំ២០០២)

## ៦.១.៥ នារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ នៅតែប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍

តាមការប៉ាន់ស្មានទៅកម្ពុជា ស្តីពីចំនួននារីរកស៊ីផ្លូវភេទ មានចំនួនខុសៗគ្នា ប៉ុន្តែតាមប្រភពរបស់ UNDP ឆ្នាំ ២០០១ បានប៉ាន់ប្រមាណថា មាននារីរកស៊ីផ្លូវភេទចំនួន ១០០.០០០នាក់។ នារីរកស៊ីផ្លូវភេទភាគច្រើន ត្រូវគេបង្ខំ ឬបោកប្រាស់ឱ្យធ្លាក់ចូលទៅក្នុងមុខរបរនេះ។ ទោះបីជាពុំទាន់មានទិន្នន័យជាក់ស្តែង ប៉ុន្តែមានការព្រួយបារម្ភថា នារីវ័យក្មេងកាន់តែច្រើនឡើង កំពុងធ្លាក់ខ្លួនប្រកបរបររកស៊ីផ្លូវភេទ។ ដោយផ្អែកលើលទ្ធផលនៃអង្កេត ស្តីពីការប្រព្រឹត្តិ (BSS ឆ្នាំ២០០០) បានបង្ហាញថា សមាមាត្រដ៏ធំមួយនៃបុរសក្នុងក្រុមដែលប្រឈមមុខនឹង គ្រោះថ្នាក់ខ្ពស់ (ដូចជា យោធា នគរបាល និងអ្នករត់ម៉ូតូឌុប) បានទៅរកនារីរកស៊ីផ្លូវភេទម្តងម្កាលក្នុងជីវិតរបស់ ពួកគេ ១៧-៣០ ភាគរយ ក្នុងឆ្នាំកន្លងទៅ និង ៨-២០ភាគរយ ក្នុងខែកន្លងមក។

តាមលទ្ធផលនៃការស្រាវជ្រាវថ្មីៗ (PSI ឆ្នាំ២០០២) ក៏បានបង្ហាញផងដែរពីស្ថានភាពមួយចំនួនដែលនាំទៅដល់ ការរកស៊ីផ្លូវភេទ រួមទាំងទំនាក់ទំនងយូរអង្វែងជាមួយ "សង្សារ"។ ទំនាក់ទំនងជាសង្សារ គឺផ្អែកទៅលើកំរិតនៃការ ទុកចិត្ត និងការស្រលាញ់គ្នាទៅវិញទៅមក ដោយមានការសន្មត់អំពី "ទំនៀមទំលាប់រៀបការតែប្រពន្ធមួយ ឬប្តីមួយ" របស់នារី និងបុរសដែលត្រូវរៀបការជាមួយនឹងនរណាម្នាក់ (PSI ឆ្នាំ២០០២)។

កត្តាទាំងនេះ បានបង្កឱ្យមានការលំបាកចំពោះនារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ ក្នុងការចរចាជាមួយបុរសឱ្យ ប្រើប្រាស់ស្រោមអនាម័យក្នុងពេលរួមភេទ។ យុទ្ធនាការឃោសនាសង្គម ហាក់ដូចជាបានរួមចំណែកបង្កើនការ ប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមអតិថិជន និងនារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់ ដូច្នេះចាំបាច់ត្រូវខិតខំ ប្រឹងប្រែងឱ្យមានការបន្ត និងបង្កើនការប្រើប្រាស់ស្រោមអនាម័យ ក្នុងចំណោមអតិថិជន និងនារីរកស៊ីផ្លូវភេទផ្ទាល់ និងមិនផ្ទាល់។

## ៦.១.៦ នារីរៀបការរួច ប្រឈមមុខនឹងគ្រោះថ្នាក់ច្រើន

នារីរៀបការរួច ប្រឈមមុខនឹងការឆ្លងនៃមេរោគអេដស៍កាន់តែច្រើនឡើង ហើយនៅក្នុងក្រុមនេះហើយដែល មេរោគអេដស៍ មានការរីករាលដាលយ៉ាងលឿន។ ការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមនារីរៀបការរួច មានតែ ១ភាគរយប៉ុណ្ណោះ។ ស្រោមអនាម័យពាក់ព័ន្ធទៅនឹងកង្វះការទុកចិត្ត ការមិនស្មោះត្រង់ និងជំងឺ៖ ការសុំឱ្យប្តីប្រើ ស្រោមអនាម័យ មានន័យថា សង្ស័យថាប្តីមិនស្មោះត្រង់។ ការពិភាក្សាអំពីការពន្យារកំណើតនៅក្នុងចំណោមនារី រៀបការរួចមានកំរិតទាប ដោយនារីភាគច្រើនបានពិភាក្សាអំពីការពន្យារកំណើតជាមួយប្តីរបស់ខ្លួន តែម្តង ឬពីរដង ក្នុងមួយឆ្នាំ ឬអត់សោះ (ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០០០)។ ការផ្សព្វផ្សាយអំពីការប្រើប្រាស់ ស្រោមអនាម័យនៅមានកំរិត។

## ៦.១.៧ ទស្សនៈយេនឌ័រមិនត្រឹមត្រូវ មានឥទ្ធិពលលើការប្រព្រឹត្តផ្លូវភេទរបស់បុរស

ទស្សនៈយេនឌ័រមិនត្រឹមត្រូវទាក់ទងនឹងសុខភាពផ្លូវភេទ និងការប្រព្រឹត្តផ្លូវភេទ ធ្វើឱ្យមេរោគអេដស៍ កាន់តែរីករាលដាលខ្លាំងឡើងនៅកម្ពុជា។ សង្គមកម្ពុជា មិនអនុញ្ញាតឱ្យមានសកម្មភាពរួមភេទមុនពេលរៀបការទេ ហើយព្រហ្មចារីយ៍របស់នារី ត្រូវបានចាត់ទុកថាជារបស់ចាំបាច់មុនពេលរៀបការ។ តំលៃនៅក្នុងសង្គមរបស់នារីខ្មែរ គឺភាពរម្យទម ការចេះស្តាប់ដំបូន្មាន និងការមិនយកចិត្តទុកដាក់ខាងផ្លូវភេទ។ នារីដែលបាត់បង់ព្រហ្មចារីយ៍មុនពេលរៀបការ ត្រូវបានគេចាត់ទុកថាជា "ស្រីដែលបាត់បង់កិត្តិយស" ហើយមានកេរ្តិ៍ឈ្មោះមិនល្អ។ ទន្ទឹមនឹងនេះ បុរសខ្មែរមួយចំនួនចាត់ទុកការទៅរកនារីរកស៊ីផ្លូវភេទ និងការរួមភេទក្រៅអាពាហ៍ពិពាហ៍ ជាផ្នែកមួយនៃសកម្មភាពធម្មតារបស់មនុស្សប្រុស (GAD-C ឆ្នាំ២០០៣) ដែលត្រូវបានគេទទួលស្គាល់នៅពេលចាកចេញឆ្ងាយពីផ្ទះ និងជាផ្នែកមួយនៃលក្ខណៈរបស់មនុស្សប្រុស។ ការទៅរកនារីរកស៊ីផ្លូវភេទ តាមការបបួលរបស់មិត្តភក្រ្ត មានកំរិតខ្ពស់នៅក្នុងចំណោមក្រុមបុរសមួយចំនួន។ ការឱ្យនិយមន័យអំពីភេទប្រុស បានជំរុញឱ្យមនុស្សប្រុសមានប្រៀបជាង មានអំណាច និងរួមភេទជាមួយនារីមិនរើសមុខដែលធ្វើឱ្យនារី មានការលំបាកក្នុងការចរចាអំពីការប្រើប្រាស់ស្រោមអនាម័យ។ ហេតុដូច្នេះ ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ឱ្យមានប្រសិទ្ធិភាព អន្តរាគមន៍នានា ត្រូវដោះស្រាយបញ្ហាអំពីនិយមន័យនៃភាពជាមនុស្សប្រុសពេញលក្ខណៈ និងបទដ្ឋានសង្គមទាក់ទងនឹងការប្រព្រឹត្តផ្លូវភេទរបស់មនុស្សប្រុស។

## ៦.១.៨ នារី ទទួលបន្ទុកថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

តាមធម្មតា បន្ទុកថែទាំកុមារកំព្រាដោយសារជំងឺអេដស៍ ត្រូវធ្លាក់ទៅលើម្តាយមីង និងជីដូន ដោយពួកគាត់ត្រូវចំណាយពេលវេលា និងធនធានបន្ថែម ជាពិសេសនៅក្នុងគ្រួសារក្រីក្រ។ នារីរៀបការរួចដែលឆ្លងមេរោគអេដស៍ពីប្តី ហើយជំងឺរបស់ប្តីខ្លួនកំពុងវិវត្តន៍ទៅភាពធ្ងន់ធ្ងរ ត្រូវជាប់រវល់តែនឹងការថែទាំប្តី ហើយទន្ទឹមនឹងនេះដែរ នារីទាំងនោះក៏ចេះតែធ្លាក់ខ្លួនឈឺធ្ងន់ទៅៗ ដោយសារជំងឺមានការវិវត្តន៍ក្នុងសរីរាង្គកាយរបស់ពួកគេ។ ទោះបីជាមិនមានទិន្នន័យស្តីពីក្មេងស្រីបោះបង់ចោលការសិក្សា ដើម្បីមកនៅថែទាំសមាជិកគ្រួសារដែលមានជំងឺអេដស៍ក៏ដោយ ក៏លទ្ធផលនៃការស្រាវជ្រាវជាច្រើនបានបង្ហាញថា បញ្ហានេះបានកើតមានឡើងជាទូទៅ (Bredenburg et al ឆ្នាំ២០០៣ និង Velaso ឆ្នាំ២០០២)។ ប្រជាជនកម្ពុជាភាគច្រើន មិនមានលទ្ធភាពទទួលថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ទេ (ART-ថ្នាំពន្យារការស្លាប់) ឬសូម្បីតែការព្យាបាលជំងឺឱ្យបានទៀងទាត់ ក៏គ្មានដែរ។ ចំពោះប្រជាជនកម្ពុជាភាគច្រើន ការព្យបាលជំងឺឱកាសនិយមដូចជា ជំងឺរលាកសួត ជំងឺរាគរូស និងជំងឺ Toxoplasmosis ត្រូវធ្វើឡើងតែនៅតាមផ្ទះ។ ជំងឺទាំងអស់នេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា និងការថែទាំជាប្រចាំពីសំណាក់នារី និងក្មេងស្រីនៅក្នុងគ្រួសារ។

### ៦.១.៩ លទ្ធភាពទទួលបានការព្យាបាលប្រឆាំងនឹងមេរោគអេដស៍នៅមានកំរិត

ថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ អាចរកទិញបាននៅតាមឱសថស្ថាននានា និងពីអ្នកលក់ដុំនៅទីក្រុងភ្នំពេញ និងកន្លែងផ្សេងទៀត ដោយមិនចាំបាច់មានវេជ្ជបញ្ជា។ តំលៃថ្នាំពន្យាការស្លាប់នេះ ប្រែប្រួលក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ បច្ចុប្បន្ន តំលៃថ្នាំប្រឆាំងមេរោគអេដស៍ដែលដាក់លក់នៅតាមឱសថស្ថាននានាក្នុងទីក្រុងភ្នំពេញ បានកើនឡើងពី ៤០ដុល្លាអាមេរិក ទៅ ៥០ដុល្លាអាមេរិក ក្នុង១ខែ ចំណែកការសិក្សាស្រាវជ្រាវអំពីតំលៃថ្នាំ ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០២ បានបង្ហាញថា តំលៃនៅលើទីផ្សារសំរាប់ព្យាបាលរយៈពេលមួយខែគឺ ៦០ដុល្លាអាមេរិក ដែលនឹងអាចឡើងរហូតដល់ ៦០០ដុល្លាអាមេរិក សំរាប់ថ្នាំប្រឆាំងមេរោគអេដស៍ ដែលផ្សំឡើងដោយថ្នាំបីប្រភេទ (Triple Therapy) (ប្រព័ន្ធសហប្រជាជាតិឆ្នាំ២០០២)។ តំលៃដ៏ខ្ពស់បែបនេះ ជាឧបសគ្គចំពោះប្រជាជនកម្ពុជាភាគច្រើន។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន កំពុងផ្តល់ថ្នាំ ART ដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលតំរូវឱ្យពួកគេបង់ប្រាក់បន្តិចបន្តួច ឬមិនបាច់បង់ប្រាក់ ប៉ុន្តែកម្មវិធីនេះ មិនទាន់ដំណើរការទំលំទូលាយនៅឡើយ។

ទោះបីជាថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ ART មាននៅជនបទក៏ដោយ ក៏នៅក្រោមប្រព័ន្ធសុខាភិបាលបច្ចុប្បន្ន នារីពុំសូវទទួលបានការព្យាបាលនេះទេ ព្រោះថា ជាទូទៅ នារីពុំសូវមានលទ្ធភាពទទួលបានប្រើប្រាស់សេវាសុខភាពទេ។ លើសពីនេះទៀតនារីជាច្រើន មិនបានទៅធ្វើតេស្តឈាមរកមេរោគអេដស៍ទេ រហូតដល់ដំណាក់កាលវិវត្តន៍ចុងក្រោយនៃជំងឺ ដែលមានន័យថា នារីអាចនឹងពុំបានទទួលការថែទាំ និងការគាំទ្រត្រឹមត្រូវនៅក្នុងដំណាក់កាលដំបូងនៃជំងឺទេ (ប្រព័ន្ធសហប្រជាជាតិ ឆ្នាំ២០០២)។ ការព្រួយបារម្ភមួយទៀត គឺថាការប្រើប្រាស់ថ្នាំប្រឆាំងនឹងមេរោគដេអដស៍ មិនត្រឹមត្រូវតាមកាលកំណត់ ឬការប្រើប្រាស់ថ្នាំក្លែងក្លាយ អាចធ្វើឱ្យមានការកើនឡើងនូវភាពស៊ាំនឹងថ្នាំ (ប្រព័ន្ធសហប្រជាជាតិ ឆ្នាំ២០០២)។ នារីក្រីក្រមានកំរិតវប្បធម៌ទាប ដែលរស់នៅតំបន់ដាច់ស្រយាលទំនងជាងាយទទួលរងគ្រោះបំផុត ។

ការប្រើប្រាស់ថ្នាំបង្ការមេរោគ ណេវីរ៉ាពីន (nevirapine) មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយការចំលងពីម្តាយទៅកូន។ ទោះជាយ៉ាងណាក៏ដោយ នារីមានផ្ទៃពោះ និងនារីឆ្លងទន្លេរួច នៅតែមានបញ្ហាទាក់ទងនឹងលទ្ធភាពទទួលបានថ្នាំ និងសេវាព្យាបាលនេះ។

## ៦.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

នៅឆ្នាំ១៩៩១ រាជរដ្ឋាភិបាល បានបង្កើតឡើងនូវកម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ ហើយក្រោយមកនៅឆ្នាំ១៩៩៤ គណៈកម្មាធិការខេត្ត-ក្រុងប្រយុទ្ធនឹងជំងឺអេដស៍ ក៏ត្រូវបានបង្កើតឡើងផងដែរ។ កន្លងទៅថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើរស្បែក និងកាមរោគ (NCHADS) ដើម្បីតាមដាន និងគ្រប់គ្រងការរីករាលដាលនៃមេរោគអេដស៍នៅទូទាំងប្រទេស។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គឺជាស្ថាប័នពហុវិស័យមួយ ដែលមានតំណាងមកពីក្រសួងពាក់ព័ន្ធទាំងអស់ចំនួន ២៦។

អាជ្ញាធរនេះ មានភារកិច្ចសំរបសំរួលគ្រប់សកម្មភាពសំខាន់ៗរបស់ក្រសួងពាក់ព័ន្ធ រៀបចំអនុសាសន៍ គោលនយោបាយ និង ធានាឱ្យមានការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវពត៌មាន និងផ្សព្វផ្សាយពត៌មាន។ អាជ្ញាធរបានខិតខំប្រឹងប្រែងរៀបចំយុទ្ធវិធីពហុវិស័យ ដែលមានលក្ខណៈទូលំទូលាយ ឧទាហរណ៍ៈ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការពារជាតិ មានផែនការជាយុទ្ធសាស្រ្តសំរាប់ដោះស្រាយបញ្ហាអេដស៍។ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក៏កំពុងតែអនុវត្តសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ហើយក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក៏មានផែនការចាប់ផ្តើមអនុវត្តសកម្មភាពដូចគ្នានេះដែរ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើរស្បែក និងកាមរោគ ទទួលខុសត្រូវចំពោះប្រព័ន្ធពិនិត្យតាមដានសុខភាពប្រជាជន និងរៀបចំផែនការ និងកម្មវិធីសំរាប់បង្ការមេរោគអេដស៍/ជំងឺអេដស៍។

ផែនការជាយុទ្ធសាស្រ្តឆ្នាំ២០០១-២០០៥ សំរាប់បង្ការ និងថែទាំអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ និងជំងឺកាមរោគ ត្រូវការថវិកាប្រហែល ៦,៥លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ដែលត្រូវផ្តល់ជូនតាមរយៈវិស័យសុខាភិបាល ដើម្បីគាំទ្រដល់សកម្មភាពនានា។ អ្នកជំនួយទ្វេភាគី ទីភ្នាក់ងារពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន មានកម្មវិធីបង្ការមេរោគអេដស៍/ជំងឺអេដស៍ និងកំពុងរង់ចាំមូលនិធិបន្ថែម ជាពិសេស សំរាប់ការថែទាំ និងគាំទ្រ។ ផែនការជាតិសំរាប់ផ្តល់លទ្ធភាពទទួលបានការថែទាំ ការគាំទ្រ និងការព្យាបាលជាប្រព័ន្ធ ត្រូវបានបង្កើតឡើង រួមទាំងការផ្តល់ថ្នាំ ART ដោយឥតគិតថ្លៃ។ ទោះបីជាចំនួនអ្នកទទួលបានការព្យាបាលដោយឥតគិតថ្លៃ កំពុងតែកើនឡើង ប៉ុន្តែការរីកចំរើនមានតិចតួចប៉ុណ្ណោះ។

ក្រសួងសុខាភិបាល ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាទាក់ទងនឹងការប្រយុទ្ធនឹងជំងឺអេដស៍។ នៅថ្នាក់ខេត្ត-ក្រុង មន្ទីរសុខាភិបាល និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខេត្ត-ក្រុងនិមួយៗ បានរៀបចំគោលនយោបាយ ព្រមទាំងសំរបសំរួល និងអនុវត្តសកម្មភាពបង្ការនានា។

ដោយពិនិត្យឃើញមានការចំណាយខ្ពស់ទៅលើជំងឺរ៉ាំរ៉ៃសំរាប់ប្រជាជនក្រីក្រ ជាពិសេសនារី យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ បានកំណត់នូវអាទិភាព ៤ សំរាប់ការកាត់បន្ថយភាពក្រីក្រដូចជា ៖

១) ពង្រីកប្រព័ន្ធថែទាំឱ្យដល់ក្រុមអ្នកក្រីក្របំផុត ដើម្បីឱ្យពួកគេមានលទ្ធភាពទទួលបានការព្យាបាលសមស្របក្នុងតំលៃមួយទាប។

២) អនុវត្តកម្មវិធីបង្ការនៅក្នុងសហគមន៍នេសាទ និងកម្មករ/ពលករទេសន្តរប្រវេសន៍។

៣) ធានាឱ្យមានការប្តេជ្ញាចិត្តពីអ្នកនយោបាយសំខាន់ៗ ចំពោះការបង្ការមេរោគអេដស៍/ជំងឺអេដស៍ និងការថែទាំអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍។ និង

៤) ពង្រឹងការធ្វើវិមជ្ឈការថវិកា និងពង្រឹងរចនាសម្ព័ន្ធខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ។

ទទួលបានឡើយ ព្រោះថាមានតែករណីមួយចំនួនតូចប៉ុណ្ណោះ ត្រូវបញ្ជូនទៅតុលាការដើម្បីរកយុត្តិធម៌។ ដោយសារជនរងគ្រោះមានជំនួយតិចតួច ជនរងគ្រោះត្រូវទទួលយកស្ថានភាពរបស់ខ្លួន។ បញ្ហានេះធ្វើឱ្យមានករណីជាច្រើនមិនត្រូវបានគេរាយការណ៍ និងធ្វើឱ្យមានការលំបាកក្នុងការប្រមូលពត៌មាន និងចាត់វិធានការដើម្បីដោះស្រាយឧបទ្ទវហេតុទាំងនេះ។

ការកើនឡើងនៃការរាយការណ៍អំពីអំពើហិង្សា ពុំមែនមានន័យថា មានការកើនឡើងនៃអំពើហិង្សានោះទេ។ នៅពេលដែលបញ្ហានេះ ក្លាយទៅជាបញ្ហាសាធារណៈពេលនោះ ការកើនឡើងនៃការរាយការណ៍ គឺជាសូចនាករវិជ្ជមានមួយបង្ហាញឱ្យឃើញថា ជនរងគ្រោះដែលនៅមានជីវិតចាប់ផ្តើមទទួលស្គាល់ និងប្រឈមមុខនិងឥរិយាបថ ដែលចាត់ទុកថាជាអំពើហិង្សា។ នេះគឺជាជំហានដំបូងដ៏សំខាន់ក្នុងការបំបែកភាពស្ងៀមស្ងាត់ជុំវិញអំពើហិង្សានេះ។ ភ្នាក់ងារភាគច្រើនដែលកំពុងដំណើរការងារក្នុងផ្នែកនេះ ជឿថា អំពើហិង្សាលើនារី កើតឡើងនៅគ្រប់ទីកន្លែងនៅកម្ពុជា និងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត។ ភ្នាក់ងារទាំងនោះបានឱ្យយោបល់ថា ការខ្វះខាតស្ថិតិដែលគួរឱ្យទុកចិត្តបាន ពុំគួរយកធ្វើជាឧបសគ្គរាំងដល់ការដំណើរការសកម្មភាពច្បាស់លាស់ និងម៉ឺងម៉ាត់ដើម្បីទប់ស្កាត់អំពើហិង្សាលើនារី និងផ្តល់ការគាំទ្រដល់ជនរងគ្រោះដែលនៅមានជីវិតឡើយ។

## ៧.១.១ ការទទួលយកអំពើហិង្សាក្នុងគ្រួសារ

ការសិក្សាមួយចំនួន បានបង្ហាញឱ្យឃើញថា អំពើហិង្សាក្នុងគ្រួសារកើតឡើងនៅទូទាំងប្រទេស។ ការអង្កេតប្រជាសាស្ត្រ និងសុខភាព (CDHS) បង្ហាញឱ្យឃើញថា នារីម្នាក់ក្នុងចំណោមនារី៤នាក់ (២៣ភាគរយ) ដែលធ្លាប់រៀបការ និងក្មេងស្រីអាយុពី១៥-៤៩ឆ្នាំ បានរាយការណ៍ថា ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយតាំងពីអាយុ ១៥ឆ្នាំ និងមានម្នាក់ក្នុងចំណោម៧នាក់ (១៥ភាគរយ) ទទួលរងគ្រោះដោយសារអំពើហិង្សាកាលពី១២ខែ មុនការអង្កេតនេះ។ ទោះបីជាអំពើហិង្សាមានលក្ខណៈខុសគ្នាបន្តិចបន្តួចរវាងនារីនៅទីក្រុង ឬទីប្រជុំជន និងនារី នៅជនបទ ឬតាមឋានៈការងាររបស់នារី ប៉ុន្តែការសិក្សាបង្ហាញឱ្យឃើញថា កំរិតនៃឧបទ្ទវហេតុធ្លាក់ចុះចំពោះនារី ដែលមានការអប់រំយ៉ាងតិចបំផុតត្រឹមកំរិតមធ្យមសិក្សា ឬនារីដែលរស់នៅជិតឪពុកម្តាយ (ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឆ្នាំ២០០៣d)។

បញ្ហាមួយនៃអំពើហិង្សាក្នុងគ្រួសារ គឺជនរងគ្រោះទទួលយកនូវអំពើហិង្សានេះ។ នៅក្នុងស្ថានភាពមានការរំលោភបំពានក្នុងគ្រួសារ នារី ច្រើនតែទៅពិភាក្សាបញ្ហាប្តីរបស់ខ្លួនជាមួយមិត្តភក្តិ ប៉ុន្តែមិនព្រមពិភាក្សាបញ្ហានេះជាមួយអាជ្ញាធរមូលដ្ឋានឡើយ (Giles, ឆ្នាំ២០០៣)។ នៅក្នុងសង្គមកម្ពុជា បុរស និងនារី ពេលខ្លះយល់ស្របថា បើសិនជាប្រពន្ធនិយាយដោយមិនគោរពប្តី ស្រែកដាក់ប្តីក្នុងចំណោមសាធារណៈជន ស្រែកជេរ ប្រើអំពើហិង្សាលើកូន ឬមិនមើលថែទាំកូន នោះប្តីមានសិទ្ធិវាយប្រពន្ធ (Giles, ឆ្នាំ២០០៣)។ ប៉ុន្តែបុរស និងនារីក៏យល់ស្របថា ការវាយដំប្រពន្ធ រហូតបណ្តាលឱ្យមានរបួសធ្ងន់ធ្ងរ គឺមិនអាចទទួលយកបានឡើយ (Giles, ឆ្នាំ២០០៣)។

នារីជាច្រើនអាចទទួលយកអធ្យាស្រ័យ និងគិតថាសមហេតុផលចំពោះការបំពារបំពានក្នុងកំរិតណាមួយនោះដែលបង្កឡើងដោយប្តីរបស់ខ្លួនៈ នារី១នាក់ក្នុងចំណោម៣នាក់ (៣៥ភាគរយ) យល់ស្របថា យ៉ាងហោចណាស់មានមូលហេតុសមរម្យមួយដែលធ្វើឱ្យប្តីវាយប្រពន្ធ។ ករណីនេះកើនឡើងទៅតាមអាយុ រយៈពេលនៃអាពាហ៍ពិពាហ៍ និងចំនួនកូន និងធ្លាក់ចុះក្នុងចំណោមនារីនៅទីក្រុង ឬទីប្រជុំជនដែលមានការអប់រំខ្ពស់ (CDHS, ឆ្នាំ២០០០)។ លទ្ធផលនេះ

## ៧.១.៣ អំពើរំលោភៈ អំពើហឹង្សាក្នុងបរិដ្ឋាននៃការមិនយកទោសពៃរ៍

ជនរងគ្រោះដោយការរំលោភ មានការលំបាកក្នុងការរាយការណ៍ដល់អាជ្ញាធរ ឬស្វែងរកជំនួយ ។ តួលេខដែលប្រមូលបាន គឺជាការបង្ហាញឱ្យឃើញអំពីបញ្ហានេះ ប៉ុន្តែតួលេខនេះមានចំនួនតិចតួចណាស់ ។ របាយការណ៍ប្រចាំឆ្នាំ ២០០២ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជារបស់អង្គការ ADHOC បានបង្ហាញអំពីអំពើហឹង្សាលើនារី និងកុមារ ។ ឧបទ្ទវហេតុនៃការរំលោភដែលបានរាយការណ៍នៅក្នុងខេត្តចំនួន ១២ កើនឡើងពី ១៨២ ករណី ក្នុងឆ្នាំ២០០១ ទៅ ២៧០ ករណីក្នុងឆ្នាំ២០០២ ។ ចំនួនករណីរំលោភដែលបានរាយការណ៍ទៅមជ្ឈមណ្ឌលកម្ពុជាជួយស្ត្រីមានវិបត្តិ (CWCC) បានកើនឡើងទ្វេដងដល់ ២២៧ករណីក្នុងកំឡុងខែមករា ឆ្នាំ២០០១ ដល់ខែមេសា ឆ្នាំ២០០២ បើប្រៀបធៀបទៅនឹងឆ្នាំមុន ។ ក្នុងចំណោមករណីទាំងនេះ ៦៥ភាគរយនៃជនរងគ្រោះ មានអាយុតិចជាង ១៨ឆ្នាំ ហើយ ១២ភាគរយនៃជនល្មើស គឺជាសាច់សារលោហិត ឬសាច់ថ្លៃរបស់ជនរងគ្រោះ (បណ្តាញអង្គការអភិវឌ្ឍន៍ និងយេនឌ័រ និងក្រសួងក.ន.អ ឆ្នាំ២០០២) និងដកស្រង់ចេញពីបទឧទ្ទេសនាមស្តីពី "អំពើរំលោភ និងច្បាប់" បង្ហាញដោយ It Phum, CWCC) ។

ក្រមព្រហ្មទណ្ឌចាត់ទុកបទរំលោភជាបទឧក្រិដ្ឋ ជាអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ និងជាបទឧក្រិដ្ឋមជ្ឈឹមមួយ ។ មាត្រា ៣៣ ចែងថាៈ ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនម្នាក់ទៀត ទោះភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកពីបទឧក្រិដ្ឋពី ៥ឆ្នាំ ទៅ១០ឆ្នាំ ។ ប៉ុន្តែមាត្រា៣៣ មិនបានចែងអំពីការសេពកាមជាមួយនារីក្រោមអាយុតាមផ្លូវច្បាប់ (ការរួមភេទដោយការស្ម័គ្រចិត្តជាមួយអនីតិជន) ឡើយ ។

អំពើរំលោភ គឺជាបញ្ហាធ្ងន់ធ្ងរមួយនៅកម្ពុជា ប៉ុន្តែកំរនឹងមានករណីណាមួយ អាចនាំទៅរកការចាប់ខ្លួនជនល្មើសឡើយ ។ នៅពេលដំណើរការចាប់ខ្លួនជនល្មើស ជនសង្ស័យកំរនឹងត្រូវបានគេរកឃើញថាមានទោសណាស់ ។ ក្នុងករណីរំលោភ និងបៀតបៀនដល់កេរ្តិ៍ខ្មាស់ចំនួន ១០៩ ករណី ដែលអង្គការ LICADHO បានធ្វើការស៊ើបអង្កេតក្នុងកំឡុងខែមករា ឆ្នាំ១៩៩៩ ដល់ខែមិនា ឆ្នាំ២០០០ មានតែចំនួន ៥១ភាគរយប៉ុណ្ណោះ ត្រូវបានកាត់ក្តីជំរះតាមមធ្យោបាយមួយចំនួន (ដូចជាតាមផ្លូវច្បាប់ ឬតាមផ្លូវផ្សេងៗទៀត) និងបិទករណី ។ ៤១ភាគរយនៃករណីដែលបានបិទ ត្រូវបានដោះស្រាយដោយការសងជំងឺចិត្តជាប្រាក់ ។ ក្នុងចំណោមករណីដែលមិនទាន់បានដោះស្រាយ ២៦ភាគរយនៃជនល្មើសបានរត់គេចខ្លួន ហើយករណីនៅសល់កំពុងធ្វើការស៊ើបអង្កេត ឬកំពុងរង់ចាំការកាត់ក្តីរយៈពេល១ ឬ២ឆ្នាំ ក្រោយពីបទរំលោភកើតឡើង (O'Connell, ឆ្នាំ២០០១) ។

គ្រួសារភាគច្រើន មិនចង់ទាក់ទងទៅអាជ្ញាធរក្នុងករណីរំលោភឡើយ ដោយសារមានភាពអាម៉ាស់ និងការឈឺចាប់នៅក្នុងសង្គមៈ ជនរងគ្រោះដោយអំពើរំលោភ ត្រូវបានគេចាត់ទុកថាជា "ស្រីខូចខាត" ។ គ្រួសារភាគច្រើនតែងតែការពារកិត្តិយសរបស់គ្រួសារ និងដោះស្រាយនៅក្រៅតុលាការ ដោយព្រមទទួលយកការសងជំងឺចិត្ត ។ ជនរងគ្រោះដោយអំពើរំលោភជាច្រើន ត្រូវធ្លាក់ទៅក្នុងរបររកស៊ីផ្លូវភេទ (លីកាដូរ ឆ្នាំ២០០១) ។

តាមការស្រាវជ្រាវនាពេលថ្មីៗនេះ (អង្គការបំរើសុខភាពពិភពលោក ឆ្នាំ២០០២ និង GADC ឆ្នាំ២០០៣) បង្ហាញនូវរូបភាពមួយនៃការកើនឡើងចំនួនយុវជនវ័យក្មេង ប្រព្រឹត្តិបទរំលោភលើនារីរកស៊ីផ្លូវភេទ កម្មការីនីរោងចក្រ ឬស្រី

### ៧.១.៤ ជនរងគ្រោះដោយការជួញដូរ ទទួលយកការស្តីបន្ទោស

ការជួញដូរនារី និងកុមារ នៅក្នុងប្រទេស និងឆ្លងកាត់ព្រំដែន កាន់តែកើនឡើងៈ កម្ពុជាជាប្រទេសបញ្ជូន ទទួលយក និងឆ្លងកាត់នៃការជួញដូរ។ មជ្ឈមណ្ឌលជួយស្ត្រីមានវិបត្តិនៅកម្ពុជា បានប៉ាន់ប្រមាណថា មាននារី និងកុមារចំនួន ១០០.០០០នាក់ កំពុងត្រូវបានគេជួញដូរនៅក្នុងប្រទេសកម្ពុជា។ តួលេខនេះរួមបញ្ចូលទាំងនារីដែលត្រូវបានជួញដូរនៅក្នុងប្រទេសកម្ពុជា និងនារីដែលត្រូវបានជួញដូរមកពីប្រទេសជិតខាង ជាពិសេសប្រទេសវៀតណាម។ តាមការប៉ាន់ប្រមាណបច្ចុប្បន្ននេះ នៅកម្ពុជា មាននារីជនជាតិវៀតណាមចំនួនពី ២០.០០០ ទៅ ៣០.០០០នាក់ ប្រកបរបរ ជាអ្នកស៊ីរកស៊ីផ្លូវភេទ។ អង្គការ ADHOC បានឱ្យដឹងថា ករណីជួញដូរបានកើនឡើងពី ៩៦ករណី ក្នុងឆ្នាំ២០០១ ទៅ ១៥៨ ករណី ឆ្នាំ២០០២។

ការជួញដូរសំរាប់អាជីវកម្មផ្លូវភេទមួយចំនួនធំ កើតឡើងនៅក្នុងប្រទេស ប៉ុន្តែកុមារកម្ពុជាជាច្រើន ក៏ត្រូវបានគេជួញដូរទៅក្នុងប្រទេសថៃ (ក្រសួងផែនការ ឆ្នាំ១៩៩៨)។ តាមរបាយការណ៍របស់មជ្ឈមណ្ឌលជួយស្ត្រីមានវិបត្តិនៅកម្ពុជា ក្នុងមួយខែ៧មាននារី និងកុមារចំនួន ៨០០នាក់ ត្រូវបានគេជួញដូរ ឬរត់ពន្ធមនុស្សទៅក្នុងប្រទេសថៃ ហើយនារី និងកុមារប្រហែល ៤០០នាក់ ត្រូវបានអាជ្ញាធរថៃ បញ្ជូនមកប្រទេសកម្ពុជាវិញជារៀងរាល់ខែ។

ក្រុមសិទ្ធិមនុស្សអន្តរជាតិ និងប្រទេសអ្នកផ្តល់ជំនួយ មានការចាប់អារម្មណ៍យ៉ាងខ្លាំងលើបញ្ហាជួញដូរក្នុងឆ្នាំកន្លងមកនេះ។ ក្នុងខែសីហា ឆ្នាំ២០០២ លោកស្រី Mary Robinson ប្រធានឧត្តមស្នងការសិទ្ធិមនុស្សសហប្រជាជាតិ បានប្រាប់ទៅរដ្ឋសភាថា នៅកម្ពុជា អ្នកប្រព្រឹត្តិអំពើជួញដូរ អាចប្រព្រឹត្តិអំពើជួញដូរដោយមិនមានការយកទោសពៃរ៍ ដោយសារការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ និងមានករណីខ្លះកាន់តែកើនឡើងដោយសារអំពើពុករលួយ (BBC, ឆ្នាំ២០០២)។

របាយការណ៍ឆ្នាំ២០០២ ស្តីពីការជួញដូរនៅក្នុងប្រទេសនានា (២០០២) របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក បង្ហាញឱ្យឃើញថា ចំនួនប្រទេសដែលត្រូវបានគេចាត់ទុកថាមានការជួញដូរខ្លាំងក្លាបំផុត (ប្រទេសលំដាប់ថ្នាក់ទី៣-Tier III countries) ធ្លាក់ចុះពី ២៣ មក ១៤។ ប្រទេសកម្ពុជា បានក្លាយពីប្រទេសលំដាប់ថ្នាក់ទី២ ទៅប្រទេសលំដាប់ថ្នាក់ទី៣ នៅក្នុងចំណោមប្រទេសដែលមាន "បញ្ហាធ្ងន់ធ្ងរពាក់ពន្ធ័នឹងការជួញដូរមនុស្ស និងមិនបានអនុវត្តតាមស្តង់ដារក្នុងកំរិតអប្បបរមា ដើម្បីប្រឆាំងនឹងបញ្ហាទាំងនេះ ហើយបច្ចុប្បន្នមិនបានធ្វើការប្រឹងប្រែងឱ្យខ្លាំងក្លា ដើម្បីប្រឆាំងនឹងបញ្ហាទាំងនេះ"។ របាយការណ៍ប្រចាំឆ្នាំនេះ គឺជាអង្គធាតុមួយនៃច្បាប់ស្តីពីការការពារជនរងគ្រោះអាមេរិកកាំងដោយសារការជួញដូរ និងអំពើហឹង្សា ឆ្នាំ២០០០។ នៅឆ្នាំទីបីក្នុងកំឡុងពេលអនុវត្តច្បាប់នេះ គឺក្នុងឆ្នាំ២០០៣ ច្បាប់នឹងដាក់ទណ្ឌកម្មដល់ប្រទេសណាដែលស្ថិតក្នុងលំដាប់ថ្នាក់ទី៣។ ការដាក់ទណ្ឌកម្ម គឺជាការកំរិតចំពោះជំនួយមិនមែនជាជំនួយមនុស្សធម៌ និងមិនមែនជាផ្នែកពាណិជ្ជកម្ម និងធ្វើការជំទាស់ក្នុងជំហររបស់សហរដ្ឋអាមេរិក មិនឱ្យស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ផ្តល់ប្រាក់កម្ចីដល់ប្រទេសនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០០៣ បានកាត់បន្ថយពីប្រទេសលំដាប់ទី៣ មកជាប្រទេសលំដាប់ទី២ ដោយសាររដ្ឋាភិបាលបានបង្ហាញឱ្យឃើញនូវ "ការខិតខំយ៉ាងខ្លាំងក្លានៅក្នុងផ្នែកពេស្យាចារ" (ក្រសួងការបរទេសសហរដ្ឋអាមេរិក ឆ្នាំ២០០៣)។

## ៧.១.៥ ភាពក្រីក្រ និងបញ្ហាសង្គម នាំឱ្យមានការកើនឡើងនៃអាជីវកម្មផ្លូវភេទ

ការប៉ាន់ប្រមាណរបស់អង្គការផ្សេងៗ អំពីចំនួននារីរកស៊ីផ្លូវភេទ ទទួលបានតួលេខខុសៗគ្នា ប៉ុន្តែរបាយការណ៍អភិវឌ្ឍន៍មនុស្សរបស់ UNDP ឆ្នាំ២០០១ បង្ហាញឱ្យឃើញថា នៅក្នុងប្រទេសកម្ពុជា មាននារីរកស៊ីផ្លូវភេទចំនួន ១០០.០០០នាក់។ អង្គការផ្សេងៗទៀតនិយាយថា តួលេខពិតប្រាកដ គឺខ្ពស់ជាងនេះ ដោយសារទិន្នន័យពុំគួរឱ្យជឿជាក់ ការរាយការណ៍នៅខ្វះចន្លោះដោយសារការបិទបាំង និងពេលខ្លះការងារនេះជា"ការងារទីពីរ" និងការកើនឡើងចំនួននៃ "អ្នករកស៊ីផ្លូវភេទដោយប្រយោល"។

ការសិក្សាមួយក្នុងឆ្នាំ១៩៩៨ មាននារីមួយចំនួនតិចប៉ុណ្ណោះ ប្រកបរបរផ្លូវភេទដោយ "ស្ម័គ្រចិត្ត" (ADB, ឆ្នាំ១៩៩៨) ៤៧ភាគរយ ត្រូវគេយកទៅលក់ និង ៣៤ភាគរយទៀត បានចាកចេញពីផ្ទះដោយសារភាពក្រីក្រ និងគិតថា ពុំមានវិធីផ្សេងៗទៀតដើម្បីរកប្រាក់។ នារីមួយចំនួនជាជនរងគ្រោះដោយសារអំពើរំលោភ ហើយត្រូវសហគមន៍របស់ពួកគេចាត់ទុកថាជា "ស្រីខូច" និងគិតថាខ្លួនគ្មានមធ្យោបាយប្រកបរបរចិញ្ចឹមជីវិតផ្សេងពីនេះ។ នារីមួយចំនួនធំ ត្រូវគ្រួសារយកទៅលក់ ឬចាញ់បោកពួកជួញដូរ និងជាញឹកញាប់ជំពាក់បំណុលម្ចាស់ផ្ទះបន។ ជាទូទៅនារីវ័យក្មេងទាំងនេះមានកំរិតសិក្សាទាប ដូច្នេះពួកគេមិនមានឱកាសការងារផ្សេងពីនេះឡើយ។ ស្ថានភាពភាពក្រីក្រ ហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់មិនទាន់មានការអភិវឌ្ឍន៍ និងការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ ធ្វើឱ្យមានការកើនឡើងនៃអាជីវកម្មផ្លូវភេទ (PADV, ឆ្នាំ១៩៩៥, UNICEF, ឆ្នាំ១៩៩៦)។

នៅកម្ពុជា ពេស្យាកម្មជាអំពើមិនខុសច្បាប់ទេ ប៉ុន្តែការបង្កើត ឬការទាញយកប្រាក់ចំណេញពីពេស្យាកម្ម គឺជាអំពើខុសច្បាប់។ ជារឿងដែលមិនគួរឱ្យជឿ ដែលអ្នកដែលត្រូវទទួលទោស គឺជាអ្នកដែលមិនបានរំលោភច្បាប់ ប៉ុន្តែអ្នកដែលពាក់ពន្ធ័នឹងអំពើខុសច្បាប់ រួចផុតពីការដាក់ទោស ដោយការមិនយកទោស ឬការសូកលុយ។

## ៧.១.៦ តម្រូវការអាជីវកម្មរកស៊ីផ្លូវភេទកើនឡើង

នៅកម្ពុជា របររកស៊ីផ្លូវភេទមានតាំងពីប៉ុន្មានឆ្នាំមុន ហើយបច្ចុប្បន្នចំនួននារីរកស៊ីផ្លូវភេទកាន់តែច្រើនឡើង។

ការមកដល់នៃកងរក្សាសន្តិភាពរបស់សហប្រជាជាតិ ប្រហែល ២២.០០០នាក់ និងជនបរទេសមួយចំនួនធំនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ បណ្តាលឱ្យមានការកើនឡើង និងការមិនយកទោសចំពោះការប្រកបរបររកស៊ីផ្លូវភេទដែលមានពីមុន ប៉ុន្តែក្នុងស្ថានភាពលាក់កំបាំង (Kumar, Baldwin និង Benjamin, ឆ្នាំ២០០០)។ បន្ទាប់ពីបេសកម្មរបស់ UN ត្រូវបញ្ចប់ របររកស៊ីផ្លូវភេទមួយចំនួនបន្តកើនឡើង ពីព្រោះដោយសារតម្រូវការថ្មីនៃទេសចរណ៍ផ្លូវភេទមកពីបរទេស ប៉ុន្តែការកើនឡើងនៃប្រាក់ចំណូលរបស់បុរសកម្ពុជា ក៏បង្កើនតម្រូវការផ្លូវភេទនៅក្នុងប្រទេសដែរ (Ledgerwood, ឆ្នាំ១៩៩៤)។

## ៧.២ គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

ដើម្បីធានាឱ្យបានថា នារី និងកុមារីទទួលបានការការពារផ្លូវច្បាប់ និងការបង្កើនការយល់ដឹងរបស់សហគមន៍អំពីបញ្ហាយេនឌ័ររាជរដ្ឋាភិបាលត្រូវ :

- បង្កើតច្បាប់ថ្មី ធ្វើវិសោធនកម្មច្បាប់ដែលមានភាពលំអៀងយេនឌ័រ និងផ្តល់ការបណ្តុះបណ្តាលដល់តុលាការ និងភ្នាក់ងារអនុវត្តច្បាប់ អនុម័តច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំងនឹងការជួញដូរ ធ្វើវិសោធនកម្មច្បាប់ការងារ និងច្បាប់ ឬបទបញ្ញត្តិផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងយេនឌ័រ ។
- កាត់បន្ថយឧបទ្ទវហេតុនៃអំពើហឹង្សាក្នុងគ្រួសារ និងការជួញដូរមនុស្ស ។
- គាំទ្រយុទ្ធនាការបង្កើនការយល់ដឹងសាធារណៈ ដើម្បីបង្កើនសមធម៌ និងសមភាពយេនឌ័រ តាមរយៈសារពត៌មានគ្រប់រូបភាព ។

សេចក្តីព្រាងច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ ត្រូវបានអនុម័តនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងខែមិថុនា ឆ្នាំ២០០២ និងបានដាក់ជូនទៅរដ្ឋសភា ដោយនាយករដ្ឋមន្ត្រី នៅក្នុងខែកក្កដា ។ ដំណើរការការពារសេចក្តីព្រាងច្បាប់នេះបានរៀបចំធ្វើឡើងបីបួនដង ដើម្បីទទួលបានការអនុម័តពីរដ្ឋសភា ប៉ុន្តែមិនទាន់បានជោគជ័យនៅឡើយ ។ ក្នុងពេលការពារនៅក្នុងរដ្ឋសភា ផ្នែកខ្លះនៃច្បាប់ត្រូវបានធ្វើវិសោធនកម្ម ដែលធ្វើឱ្យប្រសិទ្ធិភាពសំខាន់ៗរបស់ច្បាប់ ត្រូវបានកាត់បន្ថយ ឧទាហរណ៍ ការមិនរាប់បញ្ចូលនូវអំពើរំលោភក្នុងចំណងអាពាហ៍ពិពាហ៍ និងអនុសាសន៍ឱ្យបញ្ចូលចំណុចមួយគឺការវាយសហព័ទ្ធ ឬកូន ក្នុង "គោលបំណងអប់រំ ឬដាក់ទណ្ឌកម្ម" ពុំចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌឡើយ ។ អនុសាសន៍ផ្សេងទៀតដូចជា: អ្វីដែលកើតឡើងនៅក្នុងផ្ទះ គឺជារឿង "ឯកជន" ហើយច្បាប់គួរតែគាំទ្រចំពោះដំណោះស្រាយដោយការចរចារ ដែល ដំណោះស្រាយនេះពុំមានប្រសិទ្ធិភាព ក្នុងការធ្វើឱ្យជនល្មើសរៀងចាលឡើយ ។ ដោយសារការបោះឆ្នោត ធ្វើឱ្យពុំមានវេលាសំរាប់ការពិភាក្សាលើសេចក្តីព្រាងច្បាប់បន្តទៀត ។ ក្រសួង ក.ន.អ នឹងធ្វើការពិចារណាថាតើត្រូវដាក់ជូនច្បាប់ថ្មីទៅរដ្ឋាភិបាលថ្មី ដែលទើបតែជាប់ឆ្នោតម្តងទៀត ឬកំណត់រកយន្តការបទបញ្ញត្តិផ្សេងៗទៀត ដើម្បីដោះស្រាយបញ្ហាអំពើហឹង្សាក្នុងគ្រួសារ ។

ក្នុងពេលរៀបចំដើម្បីឱ្យមានការអនុម័តលើសេចក្តីព្រាងច្បាប់នេះ ក្រសួងក.ន.អ បានបង្កើតក្រុមប្រឹក្សាផ្តល់យោបល់ ដែលមានអនុក្រុមការងារបី ទទួលខុសត្រូវក្នុងការផ្សព្វផ្សាយពត៌មានអំពីច្បាប់ ជំនួយ និងការគាំទ្រចំពោះជនរងគ្រោះ និងការបណ្តុះបណ្តាលដល់អាជ្ញាធរមានសមត្ថកិច្ចដែលមានចែងនៅក្នុងច្បាប់ ។

ក្រុមប្រឹក្សាផ្តល់យោបល់ បានរៀបចំផែនការសកម្មភាពជាតិ ដើម្បីគាំទ្រដល់ការអនុវត្តន៍ច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

នៅថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាឃុំសង្កាត់មានតួនាទីដោះស្រាយករណីអំពើហឹង្សាក្នុងគ្រួសារ ។ សេចក្តីព្រាងច្បាប់ចែងថា អាជ្ញាធរសាធារណៈ រួមមាន ក្រុមប្រឹក្សាឃុំ/សង្កាត់ មានតួនាទីចូលធ្វើអន្តរាគមន៍ភ្លាមៗ ដើម្បីការពារជនរងគ្រោះដោយបំបែកជនរងគ្រោះ ឬជនល្មើសពីកន្លែងកើតហេតុ ផ្តល់ជំនួយ និងពត៌មានដល់ជនរងគ្រោះអំពីសិទ្ធិរបស់ពួកគេ ។

និងត្រូវបានរដ្ឋាភិបាលចុះហត្ថលេខាក្នុងខែវិច្ឆិកា ឆ្នាំ២០០១។ ក្រសួងក.ន.អ បានផ្តល់អនុសាសន៍សំខាន់ៗ ដើម្បីឱ្យមានការធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់នេះ។

ក្រសួង ក.ន.អ បានរៀបចំគំរោងស្នើសុំមួយ ក្នុងគោលបំណងដោះស្រាយបញ្ហាជួញដូរ តាមរយៈវិធានការចំរុះមួយចំនួន (សេចក្តីព្រាងរបាយការណ៍ស្តីពីការពង្រឹងយន្តការ និងយុទ្ធសាស្ត្រដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ)។ វិធានការទាំងនោះរួមមាន (i) វិធានការទប់ស្កាត់ ដូចជា ការផ្សព្វផ្សាយពត៌មាន និងការបណ្តុះបណ្តាលលើកកំពស់ការយល់ដឹង ការតស៊ូមតិ ។ល។ (ii) វិធានការការពារដូចជា កំណែទម្រង់វិស័យច្បាប់ និងតុលាការ ការពង្រឹងច្បាប់ និងសហប្រតិបត្តិការតាមបណ្តោយព្រំដែន (iii) ការធ្វើឱ្យអារម្មណ៍ផ្លូវចិត្តត្រឡប់មកកាន់ភាពដើមវិញ ការស្តារនីតិសម្បទា និងវិធានការសមាហរណកម្ម ដូចជាផ្តល់សេវាដោយផ្ទាល់ និងសមាហរណកម្មទៅក្នុងសហគមន៍ និង (iv) សហប្រតិបត្តិការ និងសំរបសំរួលជាមួយក្រសួងពាក់ពន្ធ័ផ្សេងៗទៀត ដូចជា ក្រសួងមហាផ្ទៃ នគរបាល និងអង្គការក្រៅរដ្ឋាភិបាល។

ក្រសួង ក.ន.អ មានផែនការពង្រឹងការអនុវត្តន៍ច្បាប់ជួញដូរ។ អនុស្សរណៈនៃការយោគយល់ រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម នឹងត្រូវយកទៅពិភាក្សា ដែលអនុស្សរណៈនេះប្រហាក់ប្រហែលនឹងអនុស្សរណៈនៃការយោគយល់ជាមួយប្រទេសថៃ ដែលត្រូវបានរៀបចំនៅក្នុងឆ្នាំ១៩៩៩ អនុស្សរណៈនៃការយោគយល់នេះ បានដាក់ចេញនូវគោលការណ៍ និងនីតិវិធីសំរាប់ភ្នាក់ងារនៅក្នុងប្រទេសទាំងពីរ សហការគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និងនារី។ អនុស្សរណៈនៃការយោគយល់ បានបញ្ចូលទាំងការបណ្តុះបណ្តាលមន្ត្រីដូចជា នគរបាលមូលដ្ឋាន មន្ត្រីអន្តោប្រវេសន៍ នគរបាលតាមបណ្តោយព្រំដែន មន្ត្រីសុខុមាលភាពសាធារណៈ ព្រះរាជអាជ្ញាសាធារណៈ ចៅក្រម វេជ្ជបណ្ឌិត និងមន្ត្រីសុខាភិបាល មកពីក្រសួងសុខាភិបាល តំណាងមកពីស្ថាប័ន/អង្គភាពអប់រំពាក់ពន្ធ័ផ្សេងៗទៀត តំណាងមកពីក្រសួងមហាផ្ទៃ និងតំណាងមកពីអង្គការឯកជន។ ក្រសួង ក.ន.អ នឹងផ្តល់ការបណ្តុះបណ្តាលអប់រំដល់អាជ្ញាធរអ្នកអនុវត្តន៍ច្បាប់។ ក្រសួង ក.ន.អ និងក្រសួងមហាផ្ទៃ នឹងផ្តួចផ្តើមយុទ្ធនាការបង្កើនការយល់ដឹងរបស់សាធារណៈជន។ តួនាទីរបស់នគរបាលក្នុងការស៊ើបអង្កេតសារធាតុព្រហ្មទណ្ឌ ពាក់ពន្ធ័នឹងដំណើរការជួញដូរ រួមទាំងដំណើរការជួញដូរនៅតាមបណ្តោយព្រំដែន នឹងត្រូវបានពង្រឹង។

ដើម្បីជួយបង្កើនភាពអង់អាច អប់រំ និងគាំទ្រនារីនៅក្នុងឧស្សាហកម្មផ្លូវភេទ បណ្តាញការងាររបស់នារី ដើម្បីសាមគ្គីភាព (WNU) ត្រូវបានបង្កើតឡើងក្នុងខែមិថុនា ឆ្នាំ២០០០ ដោយមានជំនួយពីអង្គការក្រៅរដ្ឋាភិបាលចំនួនប្រាំ រួមមាន អង្គការ Oxfam និងអង្គការសុខភាពគ្រួសារ (កាសែត Phnom Penh Post, AP និង FHI, ឆ្នាំ២០០២)។ បច្ចុប្បន្នបណ្តាញការងារនេះ មាននារីជាង ៣.០០០នាក់ ចូលរួមក្នុងសកម្មភាព និងកម្មវិធីបណ្តុះបណ្តាល រួមមាន កម្មវិធីសន្សំប្រាក់ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជំនាញតស៊ូមតិដើម្បីឱ្យមានការប្រើប្រាស់ស្រោមអនាម័យ និងបច្ចេកទេសចៀសវាងពីអំពើហឹង្សា។ បណ្តាញ WNU ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងស្លាកស្នាមឈឺចាប់ និងការដាក់ឱ្យនៅក្រៅសង្គម ដែលនារីរកស៊ីផ្លូវភេទកំពុងប្រឈមមុខ ហើយបណ្តាញ WNU នេះ ទទួលបានជោគជ័យក្នុងការបញ្ចេញសំលេងឱ្យនារីទាំងនោះ។ ការផ្តល់ជាសំលេង និងមូលដ្ឋាននៃអំណាចក្នុងការសំដែងចេញនូវគំនិតយោបល់ គឺជាវិធីដ៏មានប្រសិទ្ធិភាព ក្នុងការផ្តល់ដល់នារីរកស៊ីផ្លូវភេទ នូវកំលាំងប្រយុទ្ធប្រឆាំងនឹងការរើសអើង និងអំពើហឹង្សាដែលនារីទាំងនោះ ទទួលការឈឺចាប់ជារៀងរាល់ថ្ងៃ។

# ៨.១ ស្ថានភាព និន្នាការ និង បញ្ហា

## ៨.១.១ រចនាសម្ព័ន្ធរាជរដ្ឋាភិបាល និងប្រព័ន្ធវិមជ្ឈការ

ប្រព័ន្ធអភិបាលកិច្ចបច្ចុប្បន្ន មានលក្ខណៈថ្មីស្រឡាងសំរាប់ប្រទេសកម្ពុជា ។ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ សិទ្ធិរបស់ពលរដ្ឋកម្ពុជា ត្រូវបានការពារដោយស្ថាប័នអំណាចបីដាច់ដោយឡែកពីគ្នាគឺ អង្គការនីតិបញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងតុលាការ ។

***នីតិបញ្ញត្តិ:*** រដ្ឋធម្មនុញ្ញបានចែងថា រដ្ឋសភាដែលជាសភាជាតិ មានអំណាចខាងនីតិបញ្ញត្តិ ។ សភាជាតិ មានសមាជិកយ៉ាងតិចចំនួន ១២០រូប ( រាជរដ្ឋាភិបាលអាណត្តិឆ្នាំ១៩៩៩-២០០៣ សមាជិករដ្ឋសភាមានចំនួន ១២៣រូប) ដែលត្រូវបានជ្រើសតាំងឡើងតាមរយៈការបោះឆ្នោត ហើយមានអាណត្តិ៥ឆ្នាំ ។ ក្នុងខែមីនា ឆ្នាំ១៩៩៩ រដ្ឋធម្មនុញ្ញ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីបង្កើតអង្គការនីតិបញ្ញត្តិទី២ គឺព្រឹទ្ធសភា ។ សមាជិកព្រឹទ្ធសភាលើកដំបូង មានចំនួន ៦១រូបត្រូវបានតែងតាំងដោយគណបក្សធំៗទាំងបី និងព្រះមហាក្សត្រ ។ ច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញនោះបានចែងថា បន្ទាប់ពីអាណត្តិបច្ចុប្បន្នដែលនឹងបញ្ចប់នៅឆ្នាំ២០០៤ សមាជិកព្រឹទ្ធសភានឹងត្រូវជ្រើសតាំងតាមរយៈការបោះឆ្នោត ។ បច្ចុប្បន្ននេះ មិនទាន់មានច្បាប់សំរាប់ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា ដែលចូលជាធរមាននៅឡើយទេ សេចក្តីព្រាងច្បាប់ថ្មីមួយស្តីពីការតែងតាំងសមាជិកព្រឹទ្ធសភា គឺនៅរង់ចាំការប្រជុំពិភាក្សារបស់សភាជាតិ នៅដើមឆ្នាំ២០០៤ នេះ ។

***នីតិប្រតិបត្តិ:*** អង្គការនីតិប្រតិបត្តិរបស់រដ្ឋាភិបាល គឺទទួលបន្ទុកប្រតិបត្តិរួមចំពោះគោលនយោបាយ និងកម្មវិធីជាតិ ហើយទទួលខុសត្រូវចំពោះមុខសភាជាតិ ។ មានក្រសួងចំនួន ២៤ និងទីស្តីការគណៈរដ្ឋមន្ត្រី១ នៅក្នុងរាជរដ្ឋាភិបាលអាណត្តិឆ្នាំ១៩៩៩-២០០៣ ។ ក្រសួងដែលស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីមួយរូប គឺមានចំនួន ២២ក្រសួង ចំណែកក្រសួង២ ( ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ) មានសហរដ្ឋមន្ត្រី ហើយក៏មានរដ្ឋមន្ត្រី១រូប ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ រដ្ឋមន្ត្រី ត្រូវអមដោយរដ្ឋលេខាធិការ២រូប និងអនុរដ្ឋលេខាធិការ៥រូប លើកលែងតែនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃ ដែលមានរដ្ឋលេខាធិការចំនួន ៤រូប ។ ក្រសួងមហាផ្ទៃ ទទួលបន្ទុកគ្រប់គ្រងខេត្ត-ក្រុងទាំងអស់ ។ អភិបាលខេត្ត-ក្រុង ត្រូវតែងតាំងដោយរដ្ឋាភិបាល ។ ខុទ្ទកាល័យត្រូវតែងតាំងដោយព្រះមហាក្សត្រ ដោយមានការផ្តល់អនុសាសន៍ពីប្រធាន និងអនុប្រធានរដ្ឋសភាជាតិ ។

***តុលាការ:*** ត្រូវបានបង្កើតឡើងជាអង្គការឯករាជ្យមួយរបស់រដ្ឋាភិបាល ។ ចៅក្រមត្រូវតែងតាំងដោយព្រះមហាក្សត្រ ដោយមានការផ្តល់អនុសាសន៍ ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលព្រះមហាក្សត្រគង់ជាអធិបតី ហើយមិនអាចត្រូវបានបណ្តេញចេញពីមុខងារឡើយ ។

ក្នុងកំឡុងប៉ុន្មានឆ្នាំកន្លងមកនេះ កម្ពុជាមានការរីកចំរើនលើការអភិវឌ្ឍន៍ប្រព័ន្ធបោះឆ្នោតរដ្ឋាភិបាលចំនួន២ក៏រិត ជាពិសេសការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់តាមលទ្ធិប្រជាធិបតេយ្យ កាលពីខែកុម្ភៈ ឆ្នាំ២០០២ ។ ការណ៍ដែលខេត្ត-ក្រុង ពុំសូវទទួលបានការយកចិត្តទុកដាក់លើកំណែទម្រង់ នេះហើយជាបញ្ហា ព្រោះថា ខេត្ត-ក្រុង ដើរតួសំខាន់ជាភ្នាក់ងារថ្នាក់មូលដ្ឋានក្នុងការចែកចាយសេវាអាទិភាពរបស់ថ្នាក់ជាតិ ។ រាជរដ្ឋាភិបាលកំពុងតែចាប់ផ្តើមដំណើរការអភិវឌ្ឍន៍គោលនយោបាយវិមជ្ឈការ ។

## ៨.១.៣ ចំនួននារីចូលរួមក្នុងរដ្ឋសភា មានការកើនឡើងតិចតួច

បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងសមាជិកសភានៅកម្ពុជា ក្នុងខែកក្កដា ឆ្នាំ២០០៣ នារីចំនួន ១២,២ភាគរយ ត្រូវបានជាប់ឆ្នោតនៅថ្នាក់ជាតិ ។ នេះគឺជាអត្រាមួយដែលខ្ពស់ជាងពេលណាៗទាំងអស់ ចាប់តាំងពីប្រព័ន្ធបច្ចុប្បន្ន ត្រូវបានអនុវត្តនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ មក ។ ទោះជាយ៉ាងណាក៏ដោយ ភាគរយនារីដែលជាប់ឆ្នោតនៅឆ្នាំ២០០៣ មានចំនួនលើស ភាគរយនារីដែលជាប់ឆ្នោតនៅឆ្នាំ១៩៩៨ តិចតួចប៉ុណ្ណោះ ដោយនៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ នោះ មាននារីចំនួន ១១.៥ភាគរយ បានជាប់ឆ្នោត ។ ក្នុងចំណោមបេក្ខភាពឈរឈ្មោះបោះឆ្នោតឆ្នាំ១៩៩៣ នារីមានចំនួន ៥ភាគរយ ហើយមាននារីតែ ៥រូបប៉ុណ្ណោះ បានជាប់ឆ្នោតក្នុងចំណោមសមាជិកសភាទាំងអស់ចំនួន ៨៧រូប ។

**ក្រាហ្វិក ៨.២ : នារីជាសមាជិកសភា តាំងពីឆ្នាំ១៩៩៣ មក**




**សំគាល់:** សំរាប់ការបោះឆ្នោតឆ្នាំ១៩៩៨ ពុំទាន់មានទិន្នន័យអំពីភាគរយរបស់បេក្ខនារីនៅឡើយ ។ ពុំមានខ្ទង់សំរាប់បេក្ខជនព្រឹទ្ធសភាទេ ពីព្រោះថា ក្នុងឆ្នាំ១៩៩៩ ព្រឹទ្ធសភា ត្រូវបានតែងតាំង ។

**ប្រភព:** ប្រព័ន្ធផ្សព្វផ្សាយពតិមាន ឆ្នាំ២០០៣ ក្រសួង ក.ន.អ និង PMATU ឆ្នាំ២០០៣ ( ទំនាក់ទំនងពតិមានដោយផ្ទាល់ខ្លួន) ។

## ៨.១.៤ បញ្ជីគណបក្ស និងលទ្ធផលនៃការបោះឆ្នោត

នៅខែមិថុនា ឆ្នាំ២០០៣ តាមការវិភាគលើបញ្ជីរបស់គណបក្សធំៗទាំងបី ដូចជា គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច បានបង្ហាញថា មាននារីប្រមាណ ១១ភាគរយ នៅក្នុងបញ្ជីអាទិភាព ហើយចំនួន ១១ភាគរយ នៅក្នុងចំណោមលំដាប់លេខរៀងខ្ពស់ពី១-៥ របស់គណបក្សធំៗទាំងបី ។ តាមការវិភាគនៅថ្នាក់ខេត្ត បានបង្ហាញថា ខេត្តដែលមានចំនួនភាគរយបេក្ខភាពនារីខ្ពស់បំផុត គឺ ខេត្តរតនគិរី និងក្រចេះ ។ ចំនួនភាគរយទាបបំផុត គឺខេត្តស្ទឹងត្រែង និងព្រះវិហារ ដែលមិនមានបេក្ខភាពនារីទាល់តែសោះ ។ លទ្ធផលនៃការបោះឆ្នោតកាលពីខែកក្កដា ឆ្នាំ២០០៣ មានដូចខាងក្រោម :

## តារាង ៨.១ បេក្ខភាពនារីក្នុងបញ្ជីគណបក្ស និង ភាគរយបេក្ខភាពនារី នៅតាមខេត្ត-ក្រុង

| ខេត្ត-ក្រុង | គណបក្សប្រជាជន | គណបក្សសមរង្ស៊ី | គណបក្សហ៊្វុនស៊ិនប៉ិច | គណបក្សទាំងបី |
|---|---|---|---|---|
| បន្ទាយមានជ័យ | ៨ | ១៧ | ០ | ៨ |
| បាត់ដំបង | ១៩ | ៦ | ៦ | ១០ |
| កំពង់ចាម | ១១ | ១៧ | ១១ | ១៣ |
| កំពង់ឆ្នាំង | ១៣ | ១២ | ០ | ៨ |
| កំពង់ស្ពឺ | ២៥ | - | ១៧ | ១៤ |
| កំពង់ធំ | ១៧ | ៨ | ៨ | ១១ |
| កំពត | ២៥ | - | ០ | ៨ |
| កណ្ដាល | ៩ | ៩ | ១៤ | ១១ |
| កោះកុង | ២៥ | - | ០ | ៨ |
| ក្រចេះ | ១៧ | - | ៤៣ | ២០ |
| មណ្ឌលគិរី | ២៥ | - | ២០ | ១៥ |
| ភ្នំពេញ | ១៧ | ៨ | ១២ | ១៣ |
| ព្រះវិហារ | - | - | ០ | - |
| ព្រៃវែង | ៥ | ១៤ | ៩ | ៩ |
| ពោធិសាត់ | ១៣ | ១២ | ០ | ៨ |
| រតនគិរី | ៥០ | ២៥ | ២៥ | ៣៣ |
| សៀមរាប | ១៧ | ៨ | ៨ | ១១ |
| ក្រុងព្រះសីហនុ | ២៥ | - | ១៧ | ១៤ |
| ស្ទឹងត្រែង | - | - | ០ | |
| ស្វាយរៀង | ៣០ | ១០ | ០ | ១៣ |
| តាកែវ | ១៣ | - | ០ | ៤ |
| កែប | ២០ | - | ២៥ | ១៥ |
| ប៉ៃលិន | - | ២៥ | ២០ | ១៥ |
| ឧត្ដរមានជ័យ | - | ២០ | ០ | ៧ |

**ប្រភព:** ទិន្នន័យឆ្នាំ២០០៣ ដកស្រង់ចេញពីរ៉ិបសៃរបស់គណបក្សធំៗបី (ផ្ដល់ដោយ PMATU)

**តារាង ៨.២: ការបញ្ចូលនារីសមាជិករដ្ឋសភា នៅក្នុងថ្នូរគណៈកម្មការរដ្ឋសភា ខែមិថុនា ឆ្នាំ២០០៣**

| គណៈកម្មការជំនាញ | រដ្ឋសភាជាតិ (ប្រធាន១ សមាជិក៨) | | ព្រឹទ្ធសភា (ប្រធាន១ សមាជិក៤) | |
|---|---|---|---|---|
| | ប្រធាន | សមាជិក | ប្រធាន | សមាជិក |
| ការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង | | ២ | ១ | ១ |
| ហិរញ្ញវត្ថុ និងធនាគារ | | ០ | | ១ |
| សេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍជនបទ បរិស្ថាន និងធនធានទឹក | ១ | ០ | | ០ |
| មហាផ្ទៃ ការពារជាតិ ស៊ើបអង្កេត ប្រឆាំងអំពើពុករលួយ | | ០ | | ០ |
| ការបរទេស សហប្រតិបត្តិការអន្តរជាតិ ពត៌មាន និងឃោសនាការ | ១ | ០ | ១ | ១ |
| នីតិកម្ម | | ០ | | ១ |
| អប់រំ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ | | ១ | | ០ |
| សុខុមាលភាពសាធារណៈ សង្គមកិច្ច ការងារ កិច្ចការនារី | ១ | ៣ | | ២ |
| សាធារណៈការ ដឹកជញ្ជូន ទូរគមនាគមន៍ប្រៃសនីយ៍ ឧស្សាហកម្ម ថាមពល រ៉ែ និងពាណិជ្ជកម្ម | | ១ | | ០ |

**ប្រភព:** ប្រពន្ធ័ផ្សព្វផ្សាយពត៌មាន ឆ្នាំ២០០៣ Who's Who in Cambodia, year 2003 – 2004 Business Handbook

## *៨.១.៦ នារីចំនួនតិចតួចបំផុត កាន់មុខតំណែងតាមការតែងតាំងដោយគណបក្សនយោបាយ នៅថ្នាក់ជាតិ និងខេត្ត*

តំណែងខ្ពស់បំផុតក្នុងរដ្ឋាភិបាល ដូចជារដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ គឺតែងតាំងដោយគណបក្សនយោបាយពីបញ្ជីគណបក្ស បន្ទាប់ពីការបោះឆ្នោត។

បន្ទាប់ពីការបោះឆ្នោតជាតិ ឆ្នាំ១៩៩៣ គ្មានរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត-ក្រុង ជានារីទេ។ បន្ទាប់ពីការបោះឆ្នោតជាតិ ឆ្នាំ១៩៩៨ មានរដ្ឋមន្ត្រីជានារីចំនួន ២រូប ក្នុងចំណោមរដ្ឋមន្ត្រីចំនួន ២៧រូប (២៥ក្រសួង) និងរដ្ឋលេខាធិការជានារីចំនួន ៣រូបក្នុងចំណោម ៥៤រូប ។ តាមក្រាហ្វិក ៨.៥ បង្ហាញឱ្យឃើញថា តំណាងរបស់នារីនៅក្នុងមុខតំណែងដែលមានសិទ្ធិធ្វើសេចក្តីសំរេចនៅថ្នាក់ជាតិ មានការកើនឡើង។ ការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលកម្ម ឆ្នាំ១៩៩៩ Gorman ឆ្នាំ១៩៩៩)។

នាពេលថ្មីៗនេះ បង្ហាញឱ្យឃើញថា បើសិនជាគ្មានការបោះបង់ចោលការសិក្សាទេនោះ ក្នុងឆ្នាំ២០០៥ នឹងមានចៅក្រមចំនួន ៥០រូបបន្ថែមទៀត ក្នុងនោះមាននារី ៦រូប (ADB ឆ្នាំ២០០៣)។

មានតំរូវការយ៉ាងខ្លាំងក្នុងការបង្កើនចំនួននារីនៅក្នុងប្រព័ន្ធតុលាការ ព្រមទាំងធានាឱ្យបានថា ប្រព័ន្ធតុលាការនេះមានការឆ្លើយតបកាន់តែច្រើនថែមទៀតទៅនឹងយេនឌ័រ។ អ្នកផ្តល់ជំនួយមួយចំនួន កំពុងតែគាំទ្រកម្មវិធីនានាដើម្បីដោះស្រាយបញ្ហាទាំងនេះ ដូចជា អង្គការ GTZ និង UNDP កំពុងគាំទ្រការលើកកំពស់តួនាទីរបស់នារីនៅក្នុងប្រព័ន្ធតុលាការ តាមរយៈកម្មវិធីអាហារូបករណ៍ (Fellowship) ជួយនិស្សិតនារីក្នុងការរៀបចំដើម្បីប្រលងចូលក្នុងកម្មវិធីបណ្តុះបណ្តាលវគ្គចៅក្រម និងព្រះរាជអាជ្ញា នឹងផ្តល់អាហារូបករណ៍ផ្សេងៗទៀត ដើម្បីឱ្យនារីបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលចៅក្រមរយៈពេល២ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីនេះ ចាំបាច់ត្រូវពង្រីកបន្ថែមដោយបញ្ចូលនូវការរៀបចំសំរាប់ការធ្វើសំភាសន៍ផងដែរ ព្រោះថានៅក្នុងដំណាក់កាលធ្វើសំភាសន៍នេះ និស្សិតស្រីភាគច្រើនឆ្លើយពុំបានល្អ ធ្វើឱ្យបាត់បង់ឱកាសអាហារូបករណ៍។

## ៨.១.៨ នារីត្រូវប្រឈមមុខនឹងការរើសអើងក្នុងជួរមន្ត្រីរាជការ

ក្នុងចំណោមមន្ត្រីរាជការទាំងអស់ នារីមានចំនួនតែ ៣១ភាគរយប៉ុណ្ណោះ (ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ឆ្នាំ២០០៣ - CAR)។ ពុំទាន់មានទិន្នន័យស្តីពីចំនួននារី ស្ថិតក្នុងតំណែងផ្សេងៗ នៅក្នុងជួរមន្ត្រីរាជការទេ ប៉ុន្តែការវាយតំលៃមួយស្តីពីនារីនៅក្នុងតំណែងមន្ត្រីរាជការជាន់ខ្ពស់នៅក្នុងក្រសួងពាក់ព័ន្ធចំនួន ១០ ដែលរួមមានក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ សម្បទា បានបង្ហាញថា មាននារីចំនួន ៩ភាគរយ នៅក្នុងតំណែងមន្ត្រីរាជការជាន់ខ្ពស់ (ក្រាហ្វិក ៨.៦)។ ការវាយតំលៃនេះ មិនបានរាប់បញ្ចូលក្រសួងកិច្ចការនារី និងអតីតយុទ្ធជនទេ ពីព្រោះក្រសួងនេះ ពុំមានតំណាងរបស់នារី នៅក្នុងក្រសួងពាក់ព័ន្ធសំខាន់ៗទេ។ ក្នុងចំណោមក្រសួងដែលត្រូវបានធ្វើអង្កេត ពុំមាននារីជាអគ្គនាយកទេ ហើយនារីចំនួន ១១ភាគរយ ជាអគ្គនាយករង នារី ១០ភាគរយ ជាប្រធាននាយកដ្ឋាន និងនារី ១០ភាគរយ ជាអនុប្រធាននាយកដ្ឋាន។

(GAP), យ.ជ.ក.ភ និងផែនការអភិវឌ្ឍន៍សង្គមកិច្ច និងសេដ្ឋកិច្ចលើកទី២ (SEDPII) (Beresford et al. ឆ្នាំ ២០០៣) ។ ក្រុមបេសកកម្មអាទិភាពនេះ គឺជាក្រុមមន្ត្រីរាជការដែលត្រូវបានជួលដើម្បីឱ្យអនុវត្តការងារទៅតាមពេលវេលាដែលបានកំណត់ និងទទួលបានប្រាក់ឧបត្ថម្ភប្រមាណ ២៤០០ដុល្លា ក្នុង ១ឆ្នាំ (Beresford et al. ឆ្នាំ ២០០៣) ។ ក្នុងខណៈពេលដែលការរៀបចំពិតប្រាកដសំរាប់ក្រុមបេសកកម្មអាទិភាព ស្ថិតនៅក្នុងការពិភាក្សានៅឡើយនោះ មានការប៉ាន់ប្រមាណថានឹងមានមន្ត្រីរាជការចំនួន ១០០០នាក់ មកពីក្រសួងអាទិភាពនានា នឹងត្រូវជ្រើសរើសដើម្បីបង្កើតបានជាក្រុមនេះ ។ វិធានការក្នុងការបង្កើនបេក្ខភាពនារី ពុំទាន់បានពិភាក្សានៅឡើយ ។ ក្រសួងខ្លះពិភាក្សាជាចំហរអំពីសារៈសំខាន់នៃការលើកកំពស់តួនាទីរបស់នារី នៅក្នុងមុខតំណែងធ្វើសេចក្តីសំរេច ប៉ុន្តែពុំបានបង្ហាញឱ្យឃើញនៅក្នុងផែនការជាយុទ្ធសាស្ត្ររបស់ពួកគេឡើយ ។

ដោយសារនារី មានតំណែងតូចទាបនៅក្នុងវិស័យសាធារណៈ ដូច្នេះការព្រួយបារម្ភនោះគឺថា នារីអាចនឹងទទួលរងឥទ្ធិពលជាអវិជ្ជមានពីដំណើរការកំណែទំរង់នេះ ប្រសិនបើពុំមានវិធានការជាក់លាក់ ដើម្បីធានាឱ្យមានសមធម៌យេនឌ័រទេនោះ ។ ឧទាហរណ៍ ដូចជាការអនុវត្តន៍សកម្មភាពវិជ្ជមាននៅក្នុងយន្តការរបស់ក្រុមបេសកកម្មអាទិភាពនេះ ដោយការអនុវត្តន៍សមធម៌យេនឌ័រ ជាលក្ខណៈវិនិច្ឆ័យសំរាប់ដំណើរការ និងលទ្ធផលរំពឹងទុកនៃកំណែទំរង់ដែលត្រូវអនុវត្តដោយក្រុមបេសកកម្មអាទិភាព ។

## ៨.១.១០ នារីជាមន្ត្រីរាជការ ខ្វះលទ្ធភាពទទួលបានការបណ្តុះបណ្តាល

ឧបសគ្គចំបងមួយ គឺអត្រារបស់ក្មេងស្រី និងនារីមានកំរិតទាប នៅកំរិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា ។ បច្ចុប្បន្នចំនួនតែ ០.៤ភាគរយប៉ុណ្ណោះ នៅក្នុងចំណោមកំលាំងពលកម្មសរុប មានកំរិតសិក្សាបរិញ្ញាប័ត្រ: នារី ០.២ភាគរយ និងបុរស ០.៧ភាគរយ ។ ក្នុងចំណោមនិស្សិតចប់បរិញ្ញាប័ត្រ នារីមានចំនួន ២០ភាគរយ ។

ដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តំរូវឱ្យមានកំរិតបរិញ្ញាប័ត្រ សំរាប់ការតែងតាំងក្នុងតំណែងមន្ត្រីរាជការជាន់ខ្ពស់ ដូច្នេះគំលាតយេនឌ័រនៅក្នុងជួរមន្ត្រីរាជការសាធារណៈ គឺមួយចំនួនពាក់ព័ន្ធទៅនឹងគំលាតយេនឌ័រនៅក្នុងការសិក្សាកំរិតឧត្តម (ជំពូកទី៤ ស្តីពីវិសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ) ។

*...និងអនុសាសន៍ដូចខាងក្រោម ៖*

- បង្កើនចំនួននារី ក្នុងគណៈកម្មាធិការវាយតំលៃការងារដើម្បីដំឡើងតួនាទី ព្រមទាំងនៅក្នុងតំណែងសំខាន់ៗផ្សេងទៀត (នៅក្នុងអង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)។
- កំណត់កូតាសំរាប់ការជ្រើសរើស និងដំឡើងតួនាទីនារី ព្រមទាំងបង្កើតឱ្យមានសមធម៌នៅក្នុងការជ្រើសរើស និងការដំឡើងតួនាទី។ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលគួរតែពង្រឹងតំណែងរបស់នារីនៅក្នុងក្រសួងទាំងអស់។
- បង្កើនការយល់ដឹងអំពីយេនឌ័រ ក្នុងចំណោមអ្នកធ្វើគោលនយោបាយជាន់ខ្ពស់ ដោយឱ្យពួកគេចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗ ស្តីពីយេនឌ័រ។
- រៀបចំថវិកាសំរាប់ការលើកកំពស់យេនឌ័រ និងសកម្មភាពត្រួតពិនិត្យ។
- តម្លាភាព និងសមធម៌នៅក្នុងដំណើរការកំណែទំរង់រដ្ឋបាលៈ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR) ត្រូវពិនិត្យ និងកែលំអឡើងវិញនូវរាល់ឯកសារមុខងារសាធារណៈទាំងអស់ (ដែលរួមមានគោលនយោបាយ ស្តីពីការជ្រើសរើសបុគ្គលិក ប្រាក់បៀវត្ស និងការដំឡើងតួនាទី) ដែលមានភាពលំអៀងយេនឌ័រ។
- បង្កើតគោលនយោបាយស្តីពីការឈប់សំរាកបិតុភាពសំរាប់បុរស ហើយជំរុញឱ្យបុរសចូលរួមចែករំលែកទទួលខុសត្រូវការងារផ្ទះ។
- បង្កើតគោលនយោបាយជាតិ ស្តីពីការបញ្ជ្រាបយេនឌ័រ ពីថ្នាក់កណ្តាលទៅដល់ថ្នាក់មូលដ្ឋាន។
- ច្បាប់ដែលទាក់ទងទៅនឹងយេនឌ័រ (ឧ. ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ) ត្រូវធ្វើការអនុម័តដោយមិនមានការពន្យាពេល។ ត្រូវធ្វើការហាមឃាត់ការផ្សព្វផ្សាយរូបភាពអាសអាភាស នៅក្នុងប្រព័ន្ធផ្សព្វផ្សាយពត៌មាន។
- ចាំបាច់ត្រូវបង្កើនលទ្ធភាពរបស់នារី ក្នុងការទទួលបានការបណ្តុះបណ្តាល និងឱកាសអប់រំនានា ដើម្បីលប់បំបាត់ "គំលាតសមត្ថភាព"។
- ក្នុងខែតុលា ឆ្នាំ២០០១ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានរៀបចំកិច្ចពិភាក្សាជាមួយមន្ត្រីរាជការបុរស-នារី និងទីប្រឹក្សាថ្នាក់ជាតិ ដែលធ្វើការក្នុងគំរោងនានា ដែលផ្តល់មូលនិធិ ដោយធនាគារពិភពលោក។ នារីមួយចំនួននៅក្នុងតំណែងគ្រប់គ្រង បាននិយាយជាចំហរ និងផ្ទាល់ខ្លួនអំពីបញ្ហានានា ដែលពួកគេបានប្រឈមមុខ។ យោបល់ទាំងនោះរួមមាន ៖
- នារីតែងតែត្រូវបានគេចាត់ទុកថា មានសមត្ថភាពទាបជាងបុរស។
- នារីមានការលំបាកក្នុងការសុំការគាំទ្រពីបុរសជាអ្នករួមការងារ ដូច្នេះ ដោយសារតែគ្មានការគាំទ្រពីបុរសនេះហើយ ដែលនារីពុំអាចសំរេចគោលដៅរបស់ខ្លួនបាន។
- នារីជាញឹកញាប់ខ្វះការគាំទ្រពីមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ ហើយនារីត្រូវដោះស្រាយជាមួយអ្នករួមការងារជាបុរសដែលតួនាទីរបស់គាត់ ត្រូវបានផ្តល់ឱ្យទៅនារីវិញ ហើយបុរសទាំងនោះពុំពេញចិត្តនឹងជោគជ័យរបស់នារីឡើយ។

## ក្រាហ្វិក ៤.៨ : ការចូលរួមរបស់បុរស និងនារីនៅក្នុងវគ្គបណ្ដុះបណ្ដាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល

**មន្ត្រីថ្នាក់ខ្ពស់**




**និស្សិត មន្ត្រីថ្នាក់កណ្ដាល**




ប្រភព: សាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០០៣

## ក្រាហ្វិក ៤.៩ : ការចូលរួមរបស់បុរស និងនារីនៅក្នុងវគ្គបណ្ដុះបណ្ដាលបន្តនៅសាលាភូមិន្ទរដ្ឋបាល

**មន្ត្រីថ្នាក់ខ្ពស់**




ប្រភព: សាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០០៣

## ៨.១.១១ លទ្ធផលនៃការចូលរួមរបស់នារីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ដំបូងបង្អស់ ពុំទាន់បានពេញចិត្តនៅឡើយ

ក្នុងការរៀបចំឱ្យមានការបោះឆ្នោតឃុំ-សង្កាត់ក្នុងខែកុម្ភៈ ឆ្នាំ២០០២ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងកម្មវិធីសិលា បានផ្តល់ជាអនុសាសន៏ឱ្យមានការអនុវត្តន៏កូតាចំនួន ៣០ភាគរយសំរាប់នារី ។ ក្នុងខណៈពេលដែលមេដឹកនាំគណបក្សនីមួយៗ បានឯកភាពជាសាធារណៈទៅលើគោលការណ៏ ដែលថានារីត្រូវទទួលបានតំណាងត្រឹមត្រូវ ហើយចាំបាច់ត្រូវបង្កើនការចូលរួមរបស់នារីនៅក្នុងឆាកនយោបាយ ប៉ុន្តែសម្តេចនាយករដ្ឋមន្ត្រី ពុំបានឯកភាពជាមួយនឹងសំណើរឱ្យមានប្រព័ន្ធកូតា ៣០ភាគរយនោះទេ (Coffel et al ឆ្នាំ២០០០) ។

ដោយការគាំទ្រក្រៅផ្លូវការចំពោះការអនុវត្តន៏ប្រពន្ឋ័កូតាសំរាប់នារី និងការខិតខំប្រឹងប្រែងមួយចំនួនរបស់អង្គការក្រៅរដ្ឋាភិបាល ដែលបានចូលទៅបណ្តុះបណ្តាលបេក្ខភាពនារីមកពីគណបក្សទាំងអស់ ប៉ុន្តែដោយផ្អែកលើទស្សនះវិស័យយេនឌ័រ លទ្ធផលនៃការបោះឆ្នោតឃុំ-សង្កាត់ ធ្វើឱ្យមានការខកចិត្តយ៉ាងខ្លាំង ។ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ សរុបចំនួន ១១២៥៧នាក់ ត្រូវបានជាប់ឆ្នោតនៅក្នុងឃុំ-សង្កាត់ចំនួន ១៦២១ ។ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាទាំងនេះ នារីមាន ចំនួនសរុប ៩៥១នាក់ ( ៨.៥ភាគរយ) ។ ប៉ុន្តែនៅក្រោមប្រព័ន្ធប្រធានឃុំ-សង្កាត់ពីមុន នារីមានចំនួនតែ ៩នាក់ ឬ ០.៥ភាគរយប៉ុណ្ណោះ ក្នុងចំណោមប្រធានឃុំ-សង្កាត់សរុប១៦២១ (UNIFEM, ឆ្នាំ២០០៣) ។ តាមការប្រៀបធៀបនេះ ការចូលរួមរបស់នារីតាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ បានបង្ហាញនូវការរីកចំរើនមួយចំនួន ។

នៅក្នុងការបោះឆ្នោតឆ្នាំ២០០២ មានបេក្ខភាពនារីចំនួនតែ ១៦ភាគរយប៉ុណ្ណោះ ហើយដោយយោងទៅតាមការពិគ្រោះយោបល់ជាមួយនារីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងខេត្តកំពង់ចាម នារីហាក់ដូចជាត្រូវបានគេដាក់នៅក្នុងលេខរៀងលំដាប់ក្រោមក្នុងបញ្ជីគណបក្ស ។ ប្រព័ន្ធសំរាប់ការកំណត់តំណែងបេក្ខភាពនៅលើបញ្ជី គឺផ្អែកលើ "ការស្ទាបស្ទង់ប្រជាប្រិយភាព" ក្នុងចំណោមប្រជាជនក្នុងសហគមន៏ ។ នីតិវិធីបោះឆ្នោត និងប្រព័ន្ធសមាមាត្រមិនបានផ្តល់ឱ្យបុរស ឬនារីនូវឱកាសដើម្បីចូលរួមជាបេក្ខភាពឯករាជ្យបានទេ ។ ដូច្នេះ ក្នុងខណៈការបណ្តុះបណ្តាលបេក្ខភាពនារីគឺពិតជាកំលាំងមួយ ដើម្បីការផ្លាស់ប្តូរជាវិជ្ជមានសំរាប់សមត្ថភាពដឹកនាំរបស់នារី ប៉ុន្តែការបណ្តុះបណ្តាលពុំទាន់បានគ្រប់គ្រាន់នៅឡើយទេ ។ ដើម្បីបង្កើនចំនួននារីនៅក្នុងតំណែងជ្រើសតាំង គឺផ្អែកទៅលើការប្តេជ្ញាចិត្តរបស់គណបក្សនីមួយៗ ក្នុងការបង្កើនចំនួនបេក្ខភាពនារី និងការដាក់ឈ្មោះរបស់នារីនៅលំដាប់ខ្ពស់ក្នុងបញ្ជីគណបក្ស ។

តាមការប៉ាន់ប្រមាណមានឃុំ-សង្កាត់ចំនួនប្រហែលជា១ភាគបីនៃឃុំ-សង្កាត់ទាំងអស់ មាននារីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ដោយទទួលស្គាល់ថា ចំនួននារីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់នៅមានកំរិត និងតម្រូវឱ្យមានការបង្កើនតំណាងរបស់នារីនោះ មាត្រា១៩ នៃអនុក្រឹតលេខ២២ ស្តីពីវិមជ្ឈការថែងថា ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែតែងតាំងសមាជិកក្រុមប្រឹក្សាជានារី១រូប ទទួលខុសត្រូវលើកិច្ចការនារី និងកុមារ ។ បើសិនជានៅក្នុងឃុំ-សង្កាត់ណាដែលពុំមាននារីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ឃុំ-សង្កាត់នោះត្រូវតែងតាំងនារី១រូបដោយពុំចាំបាច់បោះឆ្នោត ដើម្បីទទួលខុសត្រូវលើកិច្ចការនារី និងកុមារ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវពិភាក្សាជាមួយ

## ៨.១.១២ ការចូលរួមរបស់នារីនៅថ្នាក់ភូមិ មានលក្ខណៈល្អប្រសើរបំផុត

បទបញ្ញត្តិស្តីពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ក៏បានចែងអំពីការបង្កើតគណៈកម្មាធិការផែនការ និងថវិកា ដែលក្នុងនោះ មានតំណាង ២រូប (បុរស១រូប និងនារី១រូប) មកពីភូមិនីមួយៗ។ ក្នុងភូមិដែលមានគណៈកម្មការអភិវឌ្ឍន៍ភូមិស្រាប់ សមាជិកគណៈកម្មការនេះ អាចក្លាយទៅជាសមាជិកគណៈកម្មាធិការផែនការ និងថវិកា។

មុនពេលបោះឆ្នោតឃុំ-សង្កាត់ ភូមិជាច្រើន មានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិមួយ។ រចនាសម្ព័ន្ធគណៈកម្មាធិការអភិវឌ្ឍន៍ភូមិនេះ គឺមានបុរស ៣នាក់ និងនារី ២នាក់ ដូច្នេះកូតាសំរាប់បុរសគឺ ៦០ភាគរយ ហើយកូតាសំរាប់នារីមាន ៤០ភាគរយ។ ប្រព័ន្ធវិមជ្ឈការ ត្រូវបានអនុវត្តនៅក្នុងកម្មវិធីសិលា មកដល់ឆ្នាំ២០០១ បានទទួលជោគជ័យយ៉ាងធំធេងក្នុងការបង្កើនការចូលរួមរបស់ប្រជាជនក្នុងអភិបាលកិច្ច ហើយជាពិសេសការបង្កើនការចូលរួមរបស់នារីនៅក្នុងការធ្វើសេចក្តីសំរេច។ ទិន្នន័យពីជំរឿនឆ្នាំ១៩៩៨ បង្ហាញថា ការចូលរួមរបស់នារីនៅក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិមានចាប់ពី ៣១ភាគរយ នៅក្នុងខេត្តសៀមរាបដល់ ៤៦ភាគរយ ក្នុងខេត្តបន្ទាយមានជ័យ។ ភស្តុតាងជាក់ស្តែង គឺសហគមន៍អ្នកផ្តល់ជំនួយ និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានបង្ហាញឱ្យឃើញថា នៅដំណាក់កាលទី១ នៃដំណើរការវិមជ្ឈការ ការចូលរួមយ៉ាងសកម្មរបស់នារីនៅក្នុងការធ្វើសេចក្តីសំរេច បានកើនឡើង ហើយជំរើស និងការរៀបចំបង្កើតគំរោង បានឆ្លើយតបទៅនឹងតំរូវការរបស់អ្នកគាំទ្រជានារី កាន់តែល្អប្រសើរឡើង។ មុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងឆ្នាំ២០០២ គណៈកម្មាធិការ និងក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ-សង្កាត់ (រួមមានបុរសម្នាក់ និងនារីម្នាក់ មកពីគណៈកម្មាធិការអភិវឌ្ឍន៍ភូមិនីមួយៗ) គឺជាយន្តការរបស់គំរោង និងមិនមែនជារដ្ឋអំណាចមូលដ្ឋានដែលត្រូវបានបោះឆ្នោតជ្រើសតាំងតាមផ្លូវការនោះទេ។

មានភាពខុសគ្នាយ៉ាងខ្លាំងរវាងអត្រានៃការចូលរួមរបស់នារីនៅក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (៤០ភាគរយ) និងក្រុមប្រឹក្សាឃុំ-សង្កាត់ (៨.៤ភាគរយ) គឺដោយហេតុថា គំរោង UNDP/CARERE បានទាមទារឱ្យមានកូតាចំនួន ៤០ភាគរយ សំរាប់នារីក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ រីឯចំនួនកូតា ៣០ភាគរយ សំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានស្នើឡើងដោយកម្មវិធីសិលា និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ត្រូវបានច្រានចោល។

ក្នុងអំឡុងកិច្ចប្រជុំពិភាក្សាតាមក្រុម (ខេត្តកំពង់ចាម ថ្ងៃ២-៣ ខែមិថុនា ឆ្នាំ២០០៣) ជាមួយនារីជាសមាជិកនៃគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងក្រុមប្រឹក្សាឃុំ-សង្កាត់ បានបង្ហាញថា នារីនៅក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិមានអារម្មណ៍ថា ពួកគេត្រូវបានប្រជាជនក្នុងសហគមន៍គោរពយ៉ាងខ្លាំង។ នារីដែលបានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់និយាយថា អ្នកភូមិមានជំនឿលើនារីខ្លាំងជាងបុរស ពីព្រោះនារីត្រូវបានគេគិតថា មានភាពស្មោះត្រង់ និងតស៊ូនឹងការងារ។ នារីនៅក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិមានអារម្មណ៍ថា ខ្លួនគាត់ត្រូវបានគេផ្តល់អំណាចក្នុងការបញ្ចេញកង្វល់របស់ពួកគេ ជាងនារីនៅថ្នាក់ខ្ពស់ ដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មាធិការប្រតិបត្តិខេត្ត។ នារីមួយចំនួននៅក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ បានឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ប៉ុន្តែមានចំនួនតិចតួចប៉ុណ្ណោះ ត្រូវបានជាប់ឆ្នោត ពីព្រោះឈ្មោះរបស់នារីទាំងនោះ ត្រូវបានដាក់ក្នុងលំដាប់លេខរៀងទាបនៅក្នុងបញ្ជីគណបក្ស។

**តារាង ៨.៧: ស្ថានភាពរីកចំរើនក្នុងការសំរេចបានគោលដៅសមធម៌យេនឌ័រនៃផែនការសកម្មភាពរដ្ឋាភិបាលកិច្ច**

| គោលដៅ | ភាពរីកចំរើនរហូតដល់បច្ចុប្បន្ន ចាប់តាំងពីឆ្នាំ២០០១ |
|---|---|
| ក្របខ័ណ្ឌការងារផ្លូវច្បាប់សំរាប់ការជួញដូរមនុស្សបានចូលជាធរមាន | រាជរដ្ឋាភិបាលកំពុងធ្វើវិសោធនកម្ម ច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស |
| | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១ បានសរសេរ និងផ្ញើជូនរបាយការណ៍ជាតិលើកទី១ លើកទី២ និងលើកទី៣ស្តីពី CEDAW និងកំពុងផ្សព្វផ្សាយពត៌មានអំពីរបាយការណ៍នេះ នៅតាមបណ្តាលខេត្ត។ ក្រុមប្រឹក្សានេះនៅខ្វះខាតធនធន។ |
| ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ត្រូវបានអនុម័ត | ត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី ប៉ុន្តែស្ថិតនៅក្នុងរដ្ឋសភាជាតិ ដែលនឹងត្រូវចាប់ផ្តើមបន្តការពិភាក្សារឡើងវិញបន្ទាប់ពីការបោះឆ្នោត នៅខែកក្កដា ឆ្នាំ២០០៣ |
| ចំនួននារីនៅក្នុងការធ្វើសេចក្តីសំរេច ទាំងក្នុងវិស័យសាធារណៈ និងឯកជន មានការកើនឡើង | តំណាងរបស់នារីនៅតែមានកំរិតអប្បបរិមាដដែល |
| ការចូលរួមរបស់នារីនៅក្នុងវិស័យសាធារណៈកើនឡើង | សូចនាករ មាននៅក្នុងឯកសារ **គអសក** |

មានការរីកចំរើនតិចតួចក្នុងការសំរេចបាននូវគោលដៅដែលបានកំណត់ ជាពិសេសពុំទាន់មានភាពរីកចំរើនក្នុងការបង្កើនចំនួននារីនៅក្នុងតំណែងធ្វើសេចក្តីសំរេចនោះទេ។ ការពិគ្រោះយោបល់របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនជាមួយមន្ត្រីរាជការជាន់ខ្ពស់ បានផ្តល់ជាអនុសាសន៍ថា ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR) ត្រូវផ្តល់ស្ថិតិដែលមានការបែងចែកតាមភេទស្តីពីមន្ត្រីរាជការ ហើយ CAR ត្រូវពិនិត្យ និងកែសំរួលឡើងវិញដើម្បីបញ្ចូលទស្សនៈយេនឌ័រទៅក្នុងនីតិវិធី និងគោលនយោបាយរបស់ខ្លួនក្នុងការជ្រើសរើស និងដំឡើងតួនាទី។ ការពិគ្រោះយោបល់បានស្នើសុំឱ្យមានសកម្មភាពវិជ្ជមាន រួមមានកូតានៅក្នុងដំណើរការកំណែទំរង់រដ្ឋបាលសាធារណៈ ដើម្បីបង្កើនសមធម៌យេនឌ័រ។ ក្រៅពីការប្តេជ្ញាចិត្តខាងនយោបាយ ដំណើរការនេះទាមទារនូវតម្លាភាព និងការទទួលខុសត្រូវដែលជាល័ក្ខខ័ណ្ឌចាំបាច់ ប៉ុន្តែពុំទាន់ជាលក្ខខ័ណ្ឌគ្រប់គ្រាន់នៅឡើយទេ ដើម្បីបង្កើនការចូលរួម និងសំលេងរបស់នារី ក្នុងការធ្វើសេចក្តីសំរេច។

## *៨.២.២ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក)*

ក្រសួង ក.ន.អ បានធ្វើការយ៉ាងខ្លាំងក្លាលើក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុង គអសក និងពង្រីកចំណុចដៅទី៣ : លើកកំពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី។ ចំណុចដៅ និងសូចនាករសំរាប់កំរិតនយោបាយក៏ដូចជាតួនាទីនៅក្នុងមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំ។ ដើម្បីសំរេចបាននូវចំណុចដៅទាំងនេះ ទាមទារឱ្យមាននូវឆន្ទៈផ្នែកនយោបាយ និងទាមទារឱ្យក្រសួង ក.ន.អ និងអង្គការនារី មានយុទ្ធសាស្រ្តតស៊ូមតិយ៉ាងខ្លាំងក្លា គឺត្រូវធ្វើឱ្យគណបក្សនយោបាយទទួលស្គាល់នូវតម្រូវការ ឱ្យនារីជាបេក្ខជនមានឈ្មោះនៅក្នុងលំដាប់លេខរៀងខ្ពស់ ពី១-៥

# ឧបសម្ព័ន្ធ ៖ ភេទភាពនារីនៅក្នុងបញ្ជីគណបក្ស ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅខែកក្កដា ឆ្នាំ២០០៣

| ខេត្ត | ចំនួន | បញ្ជីអាទិភាព | | ក្នុងលំដាប់លេខរៀងពី ១-៥ | | បញ្ជីបំរុង | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អាសនៈ | បុរស | នារី | អាសនៈ | នារី | បុរស | នារី | សរុប | បុរស | នារី | សរុប | %នារី |
| **គណបក្សសមរង្ស៊ី** | | | | | | | | | | | | |
| បន្ទាយមានជ័យ | ៦ | ៥ | ១ | ៥ | ១ | ៥ | ១ | ៦ | ១០ | ២ | ១២ | ១៦.៧ |
| បាត់ដំបង | ៨ | ៨ | - | ៥ | - | ៧ | ១ | ៨ | ១៥ | ១ | ១៦ | ៦.៣ |
| កំពង់ចាម | ១៨ | ១៥ | ៣ | ៥ | ១ | ១៥ | ៣ | ១៨ | ៣០ | ៦ | ៣៦ | ១៦.៧ |
| កំពង់ឆ្នាំង | ៤ | ៤ | - | ៤ | - | ៣ | ១ | ៤ | ៧ | ១ | ៨ | ១២.៥ |
| កំពង់ស្ពឺ | ៦ | ៦ | - | ៥ | - | ៦ | - | ៦ | ១២ | - | ១២ | - |
| កំពង់ធំ | ៦ | ៦ | - | ៥ | - | ៥ | ១ | ៦ | ១១ | ១ | ១២ | ៨.៣ |
| កំពត | ៦ | ៦ | - | ៥ | - | ៦ | - | ៦ | ១២ | - | ១២ | - |
| កណ្តាល | ១១ | ៩ | ២ | ៥ | ២ | ១១ | - | ១១ | ២០ | ២ | ២២ | ៩.១ |
| កោះកុង | ១ | ១ | - | ១ | - | ៣ | - | ៣ | ៤ | - | ៤ | - |
| ក្រចេះ | ៣ | ៣ | - | ៣ | - | ៣ | - | ៣ | ៦ | - | ៦ | - |
| មណ្ឌលគិរី | ១ | ១ | - | ១ | - | ៣ | - | ៣ | ៤ | - | ៤ | - |
| ភ្នំពេញ | ១២ | ១០ | ២ | ៥ | ១ | ១២ | - | ១២ | ២២ | ២ | ២៤ | ៨.៣ |
| ព្រះវិហារ | ១ | ១ | - | ១ | - | ៣ | - | ៣ | ៤ | - | ៤ | - |
| ព្រៃវែង | ១១ | ៩ | ២ | ៥ | ១ | ១០ | ១ | ១១ | ១៩ | ៣ | ២២ | ១៣.៦ |
| ពោធិសាត់ | ៤ | ៤ | - | ៤ | - | ៣ | ១ | ៤ | ៧ | ១ | ៨ | ១២.៥ |
| រតនគិរី | ១ | ១ | - | ១ | - | ២ | ១ | ៣ | ៣ | ១ | ៤ | ២៥ |
| សៀមរាប | ៦ | ៥ | ១ | ៥ | ១ | ៦ | - | ៦ | ១១ | ១ | ១២ | ៨.៣ |
| ក្រុងព្រះសីហនុ | ១ | ១ | - | ១ | - | ៣ | - | ៣ | ៤ | - | ៤ | - |
| ស្ទឹងត្រែង | ១ | ១ | - | ១ | - | ៣ | - | ៣ | ៤ | - | ៤ | - |
| ស្វាយរៀង | ៥ | ៥ | - | ៥ | - | ៤ | ១ | ៥ | ៩ | ១ | ១០ | ១០ |
| តាកែវ | ៨ | ៨ | - | ៥ | - | ៨ | - | ៨ | ១៦ | - | ១៦ | - |
| កែប | ១ | ១ | - | ១ | - | ៤ | - | ៤ | ៥ | - | ៥ | - |
| ប៉ៃលិន | ១ | - | ១ | ១ | ១ | ៣ | - | ៣ | ៣ | ១ | ៤ | ២៥ |
| ឧត្តរមានជ័យ | ១ | - | ១ | ១ | ១ | ៤ | - | ៤ | ៤ | ១ | ៥ | ២០ |
| សរុប | ១២៣ | ១១០ | ១៣ | ៨០ | ៩ | ១៣២ | ១១ | ១៤៣ | ២៤២ | ២៤ | ២៦៦ | |
| %នារី | | ១០.៦% | | ១១.៣% | | ៧.៧% | | | ៩.០% | | | |
| %នារីក្នុងលំដាប់លេខរៀងពី ១-៥ | | | | ៦៩.២% | | | | | | | | |

| ខេត្ត | ចំនួន | បញ្ជីអាទិភាព | | ក្នុងលំដាប់លេខរៀងពី ១-៥ | | បញ្ជីបំរុង | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អាសនៈ | បុរស | នារី | អាសនៈ | នារី | បុរស | នារី | សរុប | បុរស | នារី | សរុប | %នារី |
| **គណបក្សប្រជាជនកម្ពុជា** | | | | | | | | | | | | |
| បន្ទាយមានជ័យ | ៦ | ៦ | | ៥ | | ៥ | ១ | ៦ | ១១ | ១ | ១២ | ៨.៣ |
| បាត់ដំបង | ៨ | ៦ | ២ | ៥ | ១ | ៧ | ១ | ៨ | ១៣ | ៣ | ១៦ | ១៨.៨ |
| កំពង់ចាម | ១៨ | ១៦ | ២ | ៥ | | ១៦ | ២ | ១៨ | ៣២ | ៤ | ៣៦ | ១១.១ |
| កំពង់ឆ្នាំង | ៤ | ៤ | - | ៤ | - | ៣ | ១ | ៤ | ៧ | ១ | ៨ | ១២.៥ |
| កំពង់ស្ពឺ | ៦ | ៥ | ១ | ៥ | ១ | ៤ | ២ | ៦ | ៩ | ៣ | ១២ | ២៥ |
| កំពង់ធំ | ៦ | ៦ | - | ៥ | - | ៤ | ២ | ៦ | ១០ | ២ | ១២ | ១៦.៧ |
| កំពត | ៦ | ៥ | ១ | ៥ | ១ | ៤ | ២ | ៦ | ៩ | ៣ | ១២ | ២៥ |
| កណ្ដាល | ១១ | ៩ | ២ | ៥ | ១ | ១១ | - | ១១ | ២០ | ២ | ២២ | ៩.១ |
| កោះកុង | ១ | ១ | - | ១ | - | ២ | ១ | ៣ | ៣ | ១ | ៤ | ២៥ |
| ក្រចេះ | ៣ | ៣ | - | ៣ | - | ២ | ១ | ៣ | ៥ | ១ | ៦ | ១៦.៧ |
| មណ្ឌលគីរី | ១ | ១ | - | ១ | - | ២ | ១ | ៣ | ៣ | ១ | ៤ | ២៥ |
| ភ្នំពេញ | ១២ | ១១ | ១ | ៥ | | ៩ | ៣ | ១២ | ២០ | ៤ | ២៤ | ១៦.៧ |
| ព្រះវិហារ | ១ | ១ | - | ១ | - | ៣ | - | ៣ | ៤ | - | ៤ | - |
| ព្រៃវែង | ១១ | ១១ | | ៥ | | ១០ | ១ | ១១ | ២១ | ១ | ២២ | ៤.៥ |
| ពោធិសាត់ | ៤ | ៤ | - | ៤ | - | ៣ | ១ | ៤ | ៧ | ១ | ៨ | ១២.៥ |
| រតនគីរី | ១ | ១ | - | ១ | - | ១ | ២ | ៣ | ២ | ២ | ៤ | ៥០ |
| សៀមរាប | ៦ | ៥ | ១ | ៥ | ១ | ៥ | ១ | ៦ | ១០ | ២ | ១២ | ១៦.៧ |
| ក្រុងព្រះសីហនុ | ១ | ១ | - | ១ | - | ២ | ១ | ៣ | ៣ | ១ | ៤ | ២៥ |
| ស្ទឹងត្រែង | ១ | ១ | - | ១ | - | ៣ | - | ៣ | ៤ | - | ៤ | - |
| ស្វាយរៀង | ៥ | ២ | ៣ | ៥ | ៣ | ៥ | | ៥ | ៧ | ៣ | ១០ | ៣០ |
| តាកែវ | ៨ | ៧ | ១ | ៥ | ១ | ៧ | ១ | ៨ | ១៤ | ២ | ១៦ | ១២.៥ |
| កែប | ១ | ១ | - | ១ | | ៣ | ១ | ៤ | ៤ | ១ | ៥ | ២០ |
| ប៉ៃលិន | ១ | ១ | | ១ | | ៣ | - | ៣ | ៤ | - | ៤ | - |
| ឧត្ដរមានជ័យ | ១ | ១ | | ១ | | ៣ | - | ៣ | ៤ | - | ៤ | - |
| សរុប | ១២៣ | ១០៩ | ១៤ | ៨០ | ៩ | ១១៧ | ២៥ | ១៤២ | ២២៦ | ៣៩ | ២៦៥ | |
| %នារី | | | ១១.៤% | | ១១.៣% | | ១៤.៦% | | | ១៤.៧% | | |
| **%នារីក្នុងលំដាប់លេខរៀងពី ១_៥** | | | | | ៦៤.៣% | | | | | | | |

# ជំពូកទី ៩

# ការបញ្ជ្រាបយេនឌ័រៈ បរិបទស្ថាប័ន និង គោលនយោបាយ


៩.១ ក្របខណ្ឌច្បាប់ ........ ១៩១

៩.២ ក្របខណ្ឌស្ថាប័ន ........ ១៩៣

៩.២.១ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ........ ១៩៣

៩.២.២ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ........ ១៩៧

៩.២.៣ បទពិសោធន៍របស់ក្រសួងពាក់ពន្ធ័ក្នុងការបញ្ជ្រាបយេនឌ័រ ........ ១៩៨

៩.២.៤ អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល ........ ១៩៩

៩.៣ គោលនយោបាយជាតិ និង ដំណើរការធ្វើផែនការយុទ្ធសាស្ត្រ ........ ២០០

៩.៣.១ ផែនការអភិវឌ្ឍន៍សង្គមកិច្ច សេដ្ឋកិច្ច លើកទី២ (SEDP II) ........ ២០១

៩.៣.២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (យ.ជ.ក.ភ) ........ ២០១

៩.៣.៣ ក្របខណ្ឌការងាររួមបញ្ចូលគ្នា — យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មដល់ជនក្រីក្រ ........ ២០៣

៩.៣.៤ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក) ........ ២០៤

៩.៣.៥ ការគ្រោងថវិកា និង ការវិភាជថវិកា ........ ២០៤

៩.៣.៦ ប្រពន្ធ័ស្ថិតិជាតិ ........ ២០៥

# ជំពូកទី ៩ : ការបញ្ជ្រាបយេនឌ័រៈ បរិបទស្ថាប័ន និង គោលនយោបាយ

ស្ថាប័នសង្គមកិច្ច ច្បាប់ និងសេដ្ឋកិច្ច កំណត់លទ្ធភាពរបស់នារី និងបុរសក្នុងការទទួលបានធនធាន កល្លានុពលភាព អំណាច ពាក់ពន្ធ័នឹងការធ្វើសេចក្តីសំរេច និងផលប្រយោជន៍ពីលទ្ធផលនៃកិច្ចអភិវឌ្ឍន៍។ កំណែទំរង់ស្ថាប័ន ដើម្បីផ្តល់ដល់នារី និងបុរសនូវសិទ្ធិ និងឱកាសស្មើគ្នា គឺជាសមាសភាគសំខាន់ក្នុងការលើកកំពស់សមភាពយេនឌ័រ។ ជំពូកនេះ នឹងបង្ហាញអំពីក្របខ័ណ្ឌច្បាប់ និងច្បាប់នានា ដែលត្រូវបានតាក់តែងឡើង ដើម្បីដោះស្រាយគំលាតយេនឌ័រ និងការរៀបចំស្ថាប័នរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាយេនឌ័រ។ ជំពូកនេះក៏បានថែងអំពីការដោះស្រាយបញ្ហាយេនឌ័រនៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗរបស់រដ្ឋាភិបាល និងដាក់បញ្ចូលទៅក្នុងដំណើរធ្វើផែនការ និងការវិភាជថវិកា។

## ៩.១ ក្របខ័ណ្ឌច្បាប់

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ថែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ" (មាត្រា៣១)។ ដូច្នេះបង្ហាញឱ្យឃើញថា បុរស និងនារីមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ ចូលរួមចំណែកស្មើគ្នានៅក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌។ សមភាពក្នុងអាពាហ៍ពិពាហ៍ និងនៅក្នុងគ្រួសារ ការងារ និងទទួលបានប្រាក់ឈ្នួល។ រដ្ឋធម្មនុញ្ញក៏បានថែងអំពីវិធានការប្រឆាំងនឹងការរើសអើងប្រឆាំងនឹងយេនឌ័រ និងការកេងប្រវ័ញ្ច។ ច្បាប់មួយចំនួនដែលបំរើដល់ផលប្រយោជន៍របស់នារី ត្រូវបានអនុម័ត ឬតាក់តែង មានដូចជាៈ

> រដ្ឋាភិបាលបានធ្វើវិសោធនកម្មច្បាប់ជាតិ ស្តីពីការរំលូតកូន ដោយកំណត់អនុញ្ញាតការរំលូតកូនបានតែចំពោះគភិណាដែលមានអាយុតិចជាង១៤សប្តាហ៍ ដោយគ្មានការកំហិតចំពោះមូលហេតុណាមួយឡើយ។ ពីមុនច្បាប់អនុញ្ញាតឱ្យមានការរំលូតកូន តែក្នុងករណីដើម្បីសង្គ្រោះជីវិតរបស់នារីប៉ុណ្ណោះ។
>
> ក្រមការងារឆ្នាំ១៩៩៧ ទទួលស្គាល់បញ្ហាយេនឌ័រ និងផ្តល់សិទ្ធិសេរីភាពដល់នារី នៅក្នុងការងារ។ យុទ្ធវិធីនេះគឺជាអ្នកការពារ មិនមែនត្រឹមតែផ្អែកលើសិទ្ធិប៉ុណ្ណោះទេ។ នៅក្នុងច្បាប់ នារី និងកុមារ ត្រូវបានការការពារមិនឱ្យធ្វើការងារដែលបណ្តាលឱ្យមាន "គ្រោះថ្នាក់" (មាត្រា១៧៧) ហើយនារីទទួលបានការការពារជាពិសេសក្នុងកំឡុងពេលមានគភ៌។ ការរើសអើងប្រឆាំងនឹងនារី និងការកេងប្រវ័ញ្ចនារី ត្រូវបានហាមឃាត់។
>
> ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ អនុញ្ញាតឱ្យមានការលែងលះ បើសិនជាមានមូលហេតុពាក់ព័ន្ធនឹង "ភាពឃោរឃៅ និងការវាយដំ" (មាត្រា៣៩)។ ច្បាប់ទទួលស្គាល់ទ្រព្យសម្បត្តិរបស់បុរស និងនារីដែលមាន មុនពេលអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិរួម និងអាចទទួលបានទ្រព្យសម្បត្តិនៅពេលលែងលះ។ នីតិវិធី បទបញ្ញត្តិ និងហេតុផលពាក់ពន្ធ័នឹងការលែងលះ មិនបានថែងពិស្តារគ្រប់គ្រាន់នៅក្នុងច្បាប់នៅឡើយទេ និងបណ្តាលឱ្យមានបញ្ហាទូទៅមួយចំនួន ដូចជា "ការបាត់បង់អំណាចជាឪពុកម្តាយ" (Schimmel, និង Ruenger, ឆ្នាំ២០០១)។ នាពេលថ្មីៗនេះ ក្រមស្តីពីគ្រួសារ កំពុងត្រូវបានរៀបចំដោយមានជំនួយពីរដ្ឋាភិបាលជប៉ុន។

សេចក្តីព្រាងច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានដាក់ជូនទៅរដ្ឋសភា នៅខែកក្កដា ឆ្នាំ២០០២។ នៅមុនពេលថ្ងៃបោះឆ្នោតខែកក្កដា ឆ្នាំ២០០៣នេះ បទបញ្ញត្តិមួយចំនួននៅក្នុងច្បាប់ត្រូវបានដំណើរការការពារនៅក្នុងរដ្ឋសភា និងធ្វើវិសោធនកម្ម។ សេចក្តីព្រាងនេះមិនទាន់អនុម័តទៅជាច្បាប់នៅឡើយ ដោយសារពុំទាន់មានរដ្ឋសភា (ជំពូកទី៧)។

ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស មិនបានផ្តល់នូវក្របខ័ណ្ឌផ្លូវច្បាប់គ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបទៅនឹងបញ្ហាជួញដូរឡើយ ប៉ុន្តែច្បាប់ថ្មីស្តីពីការបង្ក្រាបអំពើលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស កំពុងត្រូវបានធ្វើពង្រាង (ជំពូកទី៧)។

ច្បាប់ដីធ្លីថ្មី ចែងថា នារី និងបុរស មានសិទ្ធិចុះហត្ថលេខារួមគ្នាលើកម្មសិទ្ធិដីធ្លី (ជំពូកទី២)។

ប្រទេសកម្ពុជាជាប្រទេសហត្ថលេខីនៅក្នុងផែនការសកម្មភាពទីក្រុងប៉េកាំង និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី (CEDAW) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ដោយគ្មានការបំរុង។ ពង្រាងរបាយការណ៍ជាតិដំបូងលើកទី២ និងទី៣ បានដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣ និងប្រើពេលអស់៧ខែ ទើបទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រី។ អនុលោមទៅតាមមាត្រា១៨នៃអនុសញ្ញា របាយការណ៍ត្រូវបង្ហាញអំពីសកម្មភាពរបស់អាជ្ញាធរសាធារណៈ ដើម្បីឱ្យនារីបានអនុវត្តសិទ្ធិរបស់គេនៅកម្ពុជា។ របាយការណ៍ត្រូវបង្ហាញអំពីស្ថានភាពបច្ចុប្បន្នរបស់នារីកម្ពុជា និងវិធានការជាក់ស្តែងដែលបាន និងកំពុងអនុវត្ត ចាប់តាំងពីអនុសញ្ញាចូលជាធរមាន។ របាយការណ៍នេះនឹងត្រូវផ្ញើទៅគណៈកម្មាធិការសហប្រជាជាតិទទួលបន្ទុក លើកកំពស់ស្ថានភាពរបស់នារី នៅក្នុងខែមករា ឆ្នាំ២០០៤។

បទពិសោធន៍នៃសេចក្តីព្រាងច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ និងសេចក្តីរបាយការណ៍ស្តីពីអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងរាល់ទម្រង់នៃអំពើហឹង្សាប្រឆាំងនឹងនារី បង្ហាញឱ្យឃើញថា គឺចាំបាច់ត្រូវការការតស៊ូមតិជាច្រើនទៀតជាមួយរដ្ឋាភិបាល និងសមាជិកសភា ដើម្បីបង្កើតបរិយាកាសគោលនយោបាយសំរាប់ការពារនារី។ នៅមានច្បាប់បច្ចុប្បន្នមួយចំនួនទៀតដែលមានលក្ខណៈលំអៀងយេនឌ័រ ដូចជាច្បាប់ស្តីពីប្រាក់បៀវត្សរ៍ឧបត្ថម្ភដល់មន្ត្រីរាជការបុរស ដែលមានសហព័ទ្ធជាបន្ទុកក្នុងគ្រួសារ ប៉ុន្តែច្បាប់នេះមិនបានអនុវត្តចំពោះមន្ត្រីរាជការនារី ដែលមានសហព័ទ្ធជាបន្ទុកក្នុងគ្រួសារឡើយ។

នៅមានកិច្ចការជាច្រើនដែលត្រូវអនុវត្ត ដើម្បីបង្កើតឱ្យបាននូវប្រពន្ធ័យុត្តិធម៌មួយដែលអាចទុកចិត្តបាន ដើម្បីបង្កើនតំលៃយុត្តិធម៌របស់តុលាការ និងបង្កើនការអនុវត្តន៍ច្បាប់។ បញ្ហាកំណែទំរង់ផ្នែកច្បាប់ ដែលបានចែងនៅក្នុងផែនការសកម្មភាពអភិបាលកិច្ច (GAP) បានបង្ហាញអំពីគំលាត និងភាពមិនរលូននៅក្នុងច្បាប់ ការខ្វះខាតក្នុងការផ្សព្វផ្សាយពត៌មានអំពីច្បាប់ ដំណើរការតាក់តែងច្បាប់មានរយៈពេលយូរ ការប្រើប្រាស់ក្រិត្យ និងអនុក្រិត្យច្រើនពេក ខ្វះសមត្ថភាពក្នុងការធ្វើសេចក្តីព្រាងច្បាប់ និងខ្វះការចូលរួមរបស់អ្នកពាក់ពន្ធ័ក្នុងដំណើរការនីតិកម្ម។

## ៩.២ ក្របខ័ណ្ឌស្ថាប័ន

### ៩.២.១ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

**ជីវប្រវត្តិ:** ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន (ក.ក.ន.អ) គឺជាយន្តការជាតិ ដើម្បីលើកកំពស់តួនាទី និងឋានៈរបស់នារី និងអតីតយុទ្ធជននៅកម្ពុជា។ នៅមុនការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងប៉ារីស ឆ្នាំ១៩៩១ បណ្តាញការងារសមាគមនារី បានពង្រីកដល់ថ្នាក់ភូមិ។ ក្រោយការបោះឆ្នោតសកល ឆ្នាំ១៩៩៣ លេខាធិការដ្ឋាន កិច្ចការនារី ត្រូវបានបង្កើតឡើង ដោយមានតួនាទីជាច្រើននៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ក្នុងឆ្នាំ១៩៩៦ លេខាធិការដ្ឋានកិច្ចការនារី ត្រូវបានដំឡើងទៅជាក្រសួងកិច្ចការនារី និងមានការតែងតាំងរដ្ឋមន្ត្រីមួយរូប។ នៅក្នុងឆ្នាំ១៩៩៨ អាណត្តិរបស់ក្រសួងត្រូវបានបញ្ចូលកិច្ចការអតីតយុទ្ធជន និងបានដូរឈ្មោះទៅជាក្រសួងកិច្ចការនារី និងអតីតយុទ្ធជននៅក្នុងឆ្នាំ១៩៩៩។

**តួនាទី និងអាណត្តិរបស់ក្រសួង:** ក.ក.ន.អ មានតួនាទីក្នុងការសំរបសំរួល និងត្រួតពិនិត្យលើកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយគំលាតយេនឌ័រ និងធានាឱ្យបានថា ប្រទេសកម្ពុជា សំរេចបាននូវសមភាពយេនឌ័រ។ អាណត្តិចំបងរបស់ក្រសួង គឺធ្វើឱ្យមានឥទ្ធិពល និងផ្តល់ការណែនាំដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រ ទៅក្នុងក្រសួងពាក់ពន្ធ័ និងស្ថាប័នរដ្ឋបាលគ្រប់កំរិត។ នៅថ្នាក់ខេត្ត និងឃុំ ក្រសួងអនុវត្តអាណត្តិរបស់ខ្លួនតាមរយៈមន្ទីរកិច្ចការនារី និងអតីតយុទ្ធជន និងជនបង្គោលយេនឌ័រ ទទួលខុសត្រូវលើបញ្ហានារី និងកុមារ នៅក្នុងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ (សូមមើលជំពូកទី៨)។ ជាដំបូង ក្រសួងប្រើប្រាស់យុទ្ធវិធីអនុវត្តគំរោងដោយផ្ទាល់។ ប៉ុន្តែក្នុងកំឡុងបីបួនឆ្នាំកន្លងមក ក្រសួងបានបង្កើនតួនាទីរបស់ខ្លួន ទៅជាអ្នកសំរបសំរួលក្នុងការគៀងគរការគាំទ្រផ្នែកនយោបាយ និងហិរញ្ញវត្ថុ សំរាប់ការផ្តល់សេវា និងគោលនយោបាយ ដែលឆ្លើយតបទៅនឹងតម្រូវការពិសេសរបស់នារី និងអតីតយុទ្ធជន ឱ្យបានកាន់តែល្អប្រសើរ។ ដោយសារតួនាទីរបស់ក្រសួងក្នុងការផ្តល់សេវាដោយផ្ទាល់មានកំរិត ក្រសួងកំពុងឈានឆ្ពោះទៅរកតួនាទីជាអ្នកជំរុញ ដើម្បីឱ្យមានការផ្លាស់ប្តូរនៅក្នុងកំរិតស្ថាបន័ និងគោលនយោបាយ។

**យុទ្ធសាស្ត្រ និងអាទិភាព:** ក្នុងឆ្នាំ១៩៩៩ ក.ក.ន.អ បានរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ ហៅថា **នារីរតនៈ** ២០០១-២០០៥ ("**នារីជារតនៈសម្បត្តិ**") ដែលមានវិស័យអាទិភាព៥គឺ: ការបញ្ជ្រាបយេនឌ័រ សុខភាព និងអាហារូបត្ថម្ភ អប់រំ និងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច ការការពារផ្លូវច្បាប់ និងការគ្រប់គ្រង និងនារីក្នុងការធ្វើសេចក្តីសំរេច។ ការផ្តោតការយកចិត្តទុកដាក់ចំបងរបស់ក្រសួង គឺការពង្រឹងសមត្ថភាព និងគាំទ្រដើម្បីការអភិវឌ្ឍន៍គោលនយោបាយ នៅក្នុងក្រសួងពាក់ពន្ធ័ជាអាទិភាព រួមមាន ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៏ជនបទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យរបស់ក្រសួងនីមួយៗ។ មន្ត្រីរាជការ ក្រសួង ក.ន.អ បានធ្វើការបណ្តុះបណ្តាលយ៉ាងទៀងទាត់នូវកម្មវិធីនានា ដែលពាក់ពន្ធ័នឹងយេនឌ័រនៅក្នុងក្រសួងពាក់ពន្ធ័ និងមន្ទីរខេត្តមួយចំនួន។ ក្រសួង ក.ន.អ ជាសមាជិកនៅក្នុងគណៈកម្មាធិការអន្តរក្រសួង និងមានតួនាទីយ៉ាងសកម្ម ជាពិសេសក្នុងការកាត់បន្ថយភាពក្រីក្រ វិស័យអប់រំ និងសុខាភិបាល។ ក្រសួង ក.ន.អ ក៏មានតួនាទីយ៉ាងសកម្មនៅក្នុងការរៀបចំ និងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា និងកំពុង

ពិនិត្យលើការរៀបចំយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដោយផ្អែកលើទស្សនៈវិស័យយេនឌ័រ។ ក្នុងខែសីហា ឆ្នាំ២០០៣ ក្រសួង ក.ន.អ ត្រូវបានរាជរដ្ឋាភិបាលបញ្ចូលទៅជាក្រសួងអាទិភាពមួយ ក្នុងចំណោមក្រសួងអាទិភាព ចំនួន៦ នៅក្នុងក្របខណ្ឌចំណាយរយៈពេលមធ្យម ដែលក្នុងនោះក្រសួងផ្សេង៧ទៀតគឺ ក្រសួងអប់រំយុវជន និងកីឡា សុខាភិបាល កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិវឌ្ឍន៍ជនបទ និងយុត្តិធម៌។

នៅក្នុងមហាសន្និបាតបូកសរុបថ្នាក់ជាតិលើកដំបូងរបស់ក្រសួងក្នុងខែមេសា ឆ្នាំ២០០៣ អ្នកចូលរួម/មន្ត្រីរាជការរបស់ក្រសួង បានរៀបចំជាសំណើរថ្មីៗ ស្តីពីទិសដៅសំរាប់អនាគតសំរាប់ក្រសួង និងបានបង្ហាញសំណើរនេះ ជូនដល់នាយករដ្ឋមន្ត្រី។ ក្របខណ្ឌនៃសំណើរទិសដៅអនាគត មានគោលបំណងចំនួន៥ គឺៈ

១. **ការកាត់បន្ថយភាពក្រីក្រសំរាប់នារី និងអតីតយុទ្ធជនៈ** ធានាឱ្យបានថា យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (យ.ជ.ក.ក) នឹងកាត់បន្ថយគំលាតយេនឌ័រ និងបង្កើតសូចនាករសមរម្យ និងត្រួតពិនិត្យលើ (យ.ជ.ក.ក) ដោយផ្អែកលើទស្សនៈយេនឌ័រ។

២. **សមាហរណកម្មយោធារំសាយ និងគ្រួសាររបស់ពួកគេ**

៣. **ការបង្កើនអភិបាលកិច្ចល្អ វិមជ្ឈការ និងសហវិមជ្ឈការៈ** បង្កើនការយល់ដឹងអំពីមូលហេតុនៃ គំលាតយេនឌ័រ និងបង្កើតយុទ្ធសាស្ត្រ ដើម្បីឆ្លើយតបបញ្ហាគំលាតយេនឌ័រទាំងនេះ នៅគ្រប់កំរិតទាំងអស់នៅក្នុងរដ្ឋាភិបាល រដ្ឋបាល និងសង្គមស៊ីវិល។ បង្កើត និងអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ដើម្បីពង្រឹងគោលនយោបាយ និងកម្មវិធីនានា។ នៅក្នុងបរិបទប្រព័ន្ធវិមជ្ឈការ និងសហវិមជ្ឈការ ក្រសួងត្រូវធ្វើយ៉ាងណាឱ្យមានថវិកាគ្រប់គ្រាន់នៅក្នុងកំរិតនីមួយៗ ដើម្បីឆ្លើយតបទៅនឹងគំលាតយេនឌ័រ។

៤. **កំណែរទំរង់វិស័យច្បាប់ៈ** បង្កើនកិច្ចការពារផ្លូវច្បាប់ដល់នារី និងកុមារ ប្រឆាំងនឹងការកេងប្រវ័ញ្ចគ្រប់រូបភាព។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ គួរតែទទួលបានការអនុម័ត និងគួរតែរៀបចំច្បាប់ថ្មីប្រឆាំងនឹងការជួញដូរ។ ត្រូវធ្វើវិសោធនកម្មលើច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់ការងារ និងក្រមព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ដែលក្រសួងយុត្តិធម៌កំពុងពង្រាង និងទាមទារការបង្កើនសហប្រតិបត្តិការរវាងក្រសួងយុត្តិធម៌ ក្រសួងក.ន.អ និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។ ពង្រឹងការអនុវត្តន៍ច្បាប់តាមរយៈ ការសហការជាមួយក្រសួងមហាផ្ទៃ ជាពិសេសដើម្បីការពារជនរងគ្រោះ ចោទប្រកាន់ និងដាក់ទោសជនល្មើសក្នុងការជួញដូរនារី និងកុមារី។

៥. **ការអនុវត្តន៍កំណែរទំរង់រដ្ឋបាល និងការបង្កើនចំនួននារីនៅក្នុងតួនាទីធ្វើសេចក្តីសំរេចៈ** ការតស៊ូមតិឱ្យមានការគាំទ្រ បញ្ចូលទស្សនៈរបស់នារីទៅក្នុងការតាក់តែង និងអនុវត្តន៍គោលនយោបាយ តាមរយៈការបង្កើនចំនួននារីបំរើការងារនៅក្នុងស្ថាប័នរដ្ឋនៅគ្រប់កំរិត និងកសាងសមត្ថភាពរបស់នារី នៅក្នុងការធ្វើសេចក្តីសំរេច និងជំនាញជាអ្នកដឹកនាំ។ ត្រួតពិនិត្យឡើងវិញលើនីតិវិធីរដ្ឋបាល ដែលមានការរើសអើងយេនឌ័រ ក្នុងការជ្រើសរើស និងដំឡើងឋានៈបុគ្គលិក។

**ទិសដៅអនាគត**ទាំងនេះ បានធ្វើឱ្យតួនាទីរបស់ក្រសួង ក.ន.អ ស្របទៅនឹងអាទិភាពជាតិ និងបានពិនិត្យឡើងវិញ លើតួនាទីទទួលខុសត្រូវខ្លះដែលជាន់ជាមួយតួនាទីរបស់ក្រសួងពាក់ពន្ធ័។ **នារីរតន:** នឹងត្រូវពិនិត្យកែលំអឡើងវិញ ឱ្យស្របជាមួយនឹងទិសដៅអនាគត និងចាំបាច់ត្រូវកែលំអរចនាសម្ពន្ធ័មួយចំនួននៅក្នុងក្រសួង។

**សកម្មភាពចំបង:** ក.ក.ន.អ ចូលរួមក្នុងសកម្មភាព៣ គឺ: ធ្វើឱ្យមានឥទ្ធិពលលើយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ មានឥទ្ធិពលលើយុទ្ធសាស្រ្តរបស់ក្រសួង (ពាក់ពន្ធ័) តាមវិស័យ និងអ្នកផ្តល់ជំនួយ និងការអនុវត្តន៍គំរោង។

**ឥទ្ធិពលលើយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ:** ក.ក.ន.អ បានចូលរួមយ៉ាងសកម្ម នៅក្នុងដំណើរការរៀបចំយុទ្ធសាស្រ្តជាតិ២ គឺ: ផែនការអភិវឌ្ឍន៍សង្គមកិច្ច សេដ្ឋកិច្ចលើកទី២ និងយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ (យ.ជ.ក.ក)។ រដ្ឋលេខាធិការមួយរូបរបស់ក្រសួង គឺជាសមាជិកនៅក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ដែលក្រុមប្រឹក្សានេះ ជាអ្នកសំរបសំរួលក្នុងការរៀបចំ និងត្រួតពិនិត្យ យ.ជ.ក.ក។ កិច្ចខិតខំរបស់ក្រសួងទទួលបានជោគជ័យបំផុត ដោយដំណើរការទូទៅក្នុងការរៀបចំយុទ្ធសាស្រ្ត បានផ្តល់ឱកាសឱ្យមានកិច្ចពិគ្រោះយោបល់ និងការផ្តល់អនុសាសន៍។ ក.ក.ន.អ ក៏បានដើរតួយ៉ាងសកម្មនៅក្នុងការរៀបចំច្បាប់ថ្មី១ ដូចជា សេចក្តីព្រាងច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងពង្រាងច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស។ តាមរយៈគំរោងថ្មីរបស់ JICA ក.ក.ន.អ នឹងឈានទៅរកការប្រមូលទិន្នន័យ ការវិភាគ និងការរៀបចំគោលនយោបាយ ការត្រួតពិនិត្យ និងការវាយតំលៃ។

**ឥទ្ធិពលទៅលើក្រសួងតាមវិស័យ:** ក.ក.ន.អ សហការជាមួយក្រសួងពាក់ពន្ធ័សំខាន់១ ដើម្បីបញ្ចូលបញ្ហាយេនឌ័រទៅក្នុងកម្មវិធីរបស់គេ។ ការយល់ដឹងអំពីភាពចាំបាច់ក្នុងការឆ្លើយតបនឹងយេនឌ័រ មានកំរិតខ្ពស់នៅក្នុងស្ថាប័នរដ្ឋ ប៉ុន្តែសមត្ថភាពមន្រ្តីរាជការក្នុងការអនុវត្តន៍នៅមានកំរិត។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ក.ក.ន.អ បាន:

- បង្កើតជនបង្គោលយេនឌ័រនៅក្នុងក្រសួងចំនួន១០ ក្នុងឆ្នាំ២០០០។ ជនបង្គោលយេនឌ័រទាំងនេះ មានតួនាទីខ្ពស់បំផុតគឺ ឋាន:អគ្គនាយករង ហើយអ្នកផ្សេង១ទៀតស្ថិតក្នុងតួនាទីទាប គ្មានអំណាចក្នុងការសំរេច ឬជាមន្រ្តីរាជការជំនាញ។ ជនបង្គោលយេនឌ័រជាច្រើនមិនសូវទទួលបានការអនុម័ត និងគាំទ្រពីថ្នាក់ដឹកនាំនៅក្នុងក្រសួងរបស់ខ្លួនឡើយ។ ជនបង្គោលយេនឌ័រ អនុវត្តតួនាទីដោយឡែកដោយគ្មានការគាំទ្រ ឬថវិកាពីក្រសួង។ ជាលទ្ធផល ជនបង្គោលយេនឌ័រ ពុំមានអំណាចគ្រប់គ្រាន់ក្នុងការបញ្ជ្រាបយេនឌ័រ ប្រកបដោយប្រសិទ្ធិភាពទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ក្រសួងពួកគេឡើយ លើកលែងតែក្រសួងអប់រំ យុវជន និងកីឡា ហើយថ្មី១នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួង អ.យ.ក គឺជាក្រសួងតែមួយគត់ ដែលមានយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រផ្លូវការ និងមានគណ:កម្មាធិការបញ្ជ្រាបយេនឌ័រមួយ ដែលមានប្រធាននៅក្នុងថ្នាក់រដ្ឋលេខាធិការ ហើយក្រសួងកសិកម្មកំពុងបង្កើតគណ:កម្មាធិការនៅក្នុងក្រសួងរបស់ខ្លួន នៅពេលឆាប់១នេះ។
- បង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រ និងក្រុមបណ្តុះបណ្តាលមន្រ្តីរាជការ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ជាពិសេសនៅក្នុងខេត្តដែលមានកម្មវិធីសិលា។
- រៀបចំសិក្ខាសាលាថ្នាក់ជាតិ បណ្តុះបណ្តាលអំពីការបញ្ជ្រាបយេនឌ័រ ទៅក្នុងប្រពន្ធ័ស្ថិតិនៅកម្ពុជា ដែលមានការចូលរួមរបស់ក្រសួងស្ថាប័នរដ្ឋចំនួន១៦ ក្នុងបរិបទដើម្បីកំណត់រក និងបំពេញចន្លោះទិន្នន័យសំរាប់ត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និង យ.ជ.ក.ភ។
- រៀបចំយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រស្តីពីជំងឺអេដស៍ និងយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រសំរាប់កម្មវិធីសិលា (ជំពូកទី៨)។

ដោយសារការយល់ដឹងនៅក្នុងក្រសួងពាក់ព័ន្ធអំពីទស្សនៈវិស័យ និងដំណើរការបញ្ជ្រាបយេនឌ័រ នៅមានកំរិត ក.ក.ន.អ កំពុងបង្កើតផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ សំរាប់អនុវត្តនៅក្នុងស្ថាប័នរដ្ឋទាំងអស់ ដោយចាប់ផ្តើមដំបូងជាមួយក្រសួងអាទិភាព។ គោលដៅចុងក្រោយគឺថា គោលនយោបាយនេះ នឹងក្លាយទៅជាផែនការសកម្មភាពថ្នាក់ជាតិ សំរាប់ការអនុវត្តន៍នៅក្នុងស្ថាប័នរដ្ឋ សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នសាសនា និងវិស័យឯកជន។

**ឥទ្ធិពលទៅលើយុទ្ធសាស្រ្តរបស់អ្នកផ្តល់ជំនួយៈ** ក.ក.ន.អ ជាពិសេសថ្នាក់ដឹកនាំតែងតែដំណើរការពិគ្រោះយោបល់ជាមួយអ្នកផ្តល់ជំនួយ នៅក្នុងដំណាក់ការរៀបចំសំណើសុំគំរោងថ្មីៗ។ ដំណើរការនេះ ធ្វើឱ្យក្រសួងមានឱកាសបង្ហាញអំពីសារៈសំខាន់នៃការឆ្លើយតបនឹងយេនឌ័រ។ ក.ក.ន.អ បានតស៊ូមតិឱ្យមានការគាំទ្របញ្ចូលបញ្ហាយេនឌ័រទៅក្នុងដំណើរការពិនិត្យលើការចំណាយសាធារណៈ និងការប៉ាន់ប្រមាណអំពីហិរញ្ញវត្ថុ របស់ធនាគារពិភពលោក ហើយជាលទ្ធផលបញ្ហាយេនឌ័រត្រូវបានដាក់នៅក្នុងជំពូក១។ ក.ក.ន.អ និងមានការចូលរួមរបស់មន្រ្តីរាជការបានចូលរួមពិគ្រោះយោបល់ និងសហការនៅក្នុងគំរោងបង្កើនការប្រកបរបរចិញ្ចឹមជីវិត ដូចជាគំរោងបង្កើនគុណភាពកសិកម្មរបស់មូលនិធិអូស្រ្តាលី (AusAID) ហើយថ្មីៗនេះ គំរោងថ្មីរបស់ IFAD បានចាប់ផ្តើមនៅក្នុងខេត្តចំនួនពីរ។

**ការអនុវត្តន៍គំរោងៈ** ក.ក.ន.អ ផ្តល់សេវាបណ្តុះបណ្តាលអប់រំផ្នែកច្បាប់ដោយផ្ទាល់ ការតស៊ូមតិស្តីពីសុខភាពបន្តពូជ ឥណទានខ្នាតតូច ការងាររកចំណូល ការជួញដូរ កសិកម្ម និងការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈ និងការជួញដូរ។ ក.ក.ន.អ បន្តអនុវត្តសកម្មភាពមួយចំនួនដើម្បីៈ ធ្វើការសាកល្បងយុទ្ធវិធីថ្មីៗ ក្នុងការផ្តល់សេវា ដោយក្រសួងមានគោលបំណងស្វែងរកយុទ្ធវិធីដែលអនុវត្តបានជោគជ័យ និងបន្ទាប់មកយកទៅអនុវត្តនៅក្នុងក្រសួងពាក់ព័ន្ធ និងដើម្បីស្វែងរកមូលនិធិសំរាប់ការធ្វើទស្សនកិច្ចមើលការអនុវត្តន៍ ដែលការធ្វើទស្សនកិច្ចមានសារៈសំខាន់ សំរាប់ស្វែងយល់អំពីបញ្ហាដែលបុរស និងនារីក្រីក្រប្រឈមមុខ និងជាការបណ្តុះបណ្តាលជាក់ស្តែង សំរាប់បុគ្គលិកមួយចំនួនធំ ដែលមិនទាន់មានបទពិសោធន៍គ្រប់គ្រាន់នៅឡើយ។

**ថវិកា និងការគាំទ្ររបស់អ្នកផ្តល់ជំនួយៈ** ទោះបីជាថវិការបស់ ក.ក.ន.អ មានចំនួនតិចតួច បើប្រៀបធៀបនឹងក្រសួងផ្សេងៗទៀត ប៉ុន្តែថវិការបស់ក្រសួងបានកើនឡើងចំនួន១០ដង ក្នុងរវាងឆ្នាំ១៩៩៩ និង ២០០៣ (កើនឡើងដល់ ១០ពាន់លានរៀល ក្នុងឆ្នាំ២០០២ (ដោយមិនបញ្ចូលនាយកដ្ឋានអតីតយុទ្ធជន)។ ហេតុដូច្នេះ ហើយក្រសួងមានលទ្ធភាពជួលបុគ្គលិក ដែលមានសមត្ថភាពមកបំរើការក្នុងអាណត្តិថ្មីរបស់ក្រសួង។ តួនាទីថ្មីដែលត្រូវជ្រើសរើសមកបំរើការសំរាប់ផ្នែកស្ថិតិ ផែនការ ត្រួតពិនិត្យ និងវាយតំលៃការគ្រប់គ្រងពត៌មាន និងច្បាប់ នឹងអាចជួយបង្កើនសមត្ថភាពធនធានមនុស្សនៅក្នុងក្រសួង។

ដូចនៅក្នុងក្រសួងជាច្រើនដែរ ថវិការបស់ ក.ក.ន.អ អាចចំណាយតែលើការចំណាយរដ្ឋបាល (ប្រាក់ខែបុគ្គលិក ទីកន្លែងធ្វើការ សម្ភារៈការិយាល័យ ។ល។) អ្នកផ្តល់ជំនួយ ឧបត្ថម្ភដល់សកម្មភាពមួយចំនួនធំរបស់ក្រសួង តាមរយៈគំរោងមួយចំនួន។ ក.ក.ន.អ បានទទួលជោគជ័យក្នុងការទាក់ទាញអ្នកផ្តល់ជំនួយ ក្នុងការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដល់កម្មវិធីសំខាន់ៗមួយចំនួន និងទទួលបានប្រហែលជា ២លានដុល្លាក្នុងមួយឆ្នាំៗ។ ជំនួយបរទេស មានសារៈសំខាន់ណាស់សំរាប់ក្រសួង ប៉ុន្តែបុគ្គលិកមួយចំនួនដែលធ្វើការនៅក្នុងគំរោងរបស់អ្នកផ្តល់ជំនួយ ពុំសូវមានពេលវេលាគ្រប់គ្រាន់ធ្វើការវិភាគគោលនយោបាយ ស្វែងរកការគាំទ្រមតិ និងការងាររដ្ឋបាលដែលជាតួនាទីទទួលខុសត្រូវរបស់ខ្លួន។

ក្នុងការប្រឈមមុខនឹងការងារបញ្ជ្រាបយេនឌ័រ ក.ក.ន.អ កំពុងតែខិតខំស្វែងរកតុល្យភាពរវាងការអនុវត្តន៍គំរោង និងការវិភាគគោលនយោបាយ និងការតស៊ូមតិ ជាមួយនិងធនធានដែលមានកំរិត។ ការប្រឈមមុខសំខាន់គឺការស្វែងរកមតិរួម និងការព្រមព្រៀងជាមួយក្រសួងពាក់ព័ន្ធ ដើម្បីឱ្យគោលនយោបាយរបស់ក្រសួងពាក់ព័ន្ធមានការឆ្លើយតបនឹងយេនឌ័រ។ សមត្ថភាពរបស់ ក.ក.ន.អ ក្នុងការផ្តល់យោបល់ផ្នែកបច្ចេកទេសដល់ក្រសួងតាមវិស័យពាក់ពន្ធ័ ដើម្បីឱ្យក្រសួងពាក់ព័ន្ធអាចបង្កើត និងអនុវត្តកម្មវិធីបង្កើនការយល់ដឹងអំពីយេនឌ័រ គឺនៅមានកំរិត ពុំអាចឆ្លើយតបទៅនឹងតម្រូវការផ្សេងៗទៀតជាច្រើន។ ថ្នាក់ដឹកនាំរបស់ក្រសួងទទួលស្គាល់ឥទ្ធិពលយុទ្ធសាស្ត្រនៃការផ្តោតយកចិត្តទុកដាក់លើការបញ្ចូលយេនឌ័រ ទៅក្នុងការងាររបស់ក្រសួងពាក់ព័ន្ធ ប៉ុន្តែក្រសួងក៏បន្តអនុវត្តគំរោងមួយចំនួន ដើម្បីឆ្លើយតបទៅនឹងទំហំនៃតម្រូវការ ដែលមិនទាន់បានបំពេញជូននៅក្នុងវិស័យផ្សេងៗ។

នៅពេលក្រសួងប្តូរគោលដៅរបស់ខ្លួនពីការអនុវត្តន៍ ទៅរកការតស៊ូមតិ និងការត្រួតពិនិត្យ ក្រសួងត្រូវប្រឈមមុខនឹងការប្រកួតប្រជែង និងឧបសគ្គថ្មីៗ។ រចនាសម្ពន្ធ័របស់ក្រសួង នៅតែស្ថិតក្នុងទំរង់នៃការផ្តល់សេវា និងមានតែបុគ្គលិកមួយចំនួនតូចប៉ុណ្ណោះ មានបទពិសោធន៍ក្នុងការវិភាគយេនឌ័រ ការរៀបចំយុទ្ធសាស្ត្រ ឬការផ្តល់យោបល់ក្នុងផ្នែកគោលនយោបាយ។ អាណត្តិថ្មីរបស់ក្រសួង គឺជាឱកាសដ៏សំខាន់សំរាប់ក្រសួង ក្នុងការរៀបចំរចនាសម្ពន្ធ័របស់ក្រសួងឡើងវិញ និងរៀបចំរចនាសម្ព័ន្ធឱ្យស្របទៅនឹងទិសដៅអនាគតរបស់ក្រសួង។

## ៩.២.២ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស) ត្រូវបានបង្កើតឡើងក្នុងខែមិនា ឆ្នាំ២០០១ ដោយព្រះរាជក្រឹត្យ។ ដោយសារ ក.ជ.ក.ស មានសមាជិកតំណាងមកពីស្ថាប័នរដ្ឋចំនួន ១៤ក្រសួង ដែលមានឋានៈជារដ្ឋលេខាធិការ ក្រុមប្រឹក្សាមិនបានតំណាងឱ្យក្រុមផលប្រយោជន៍របស់នារីដោយផ្ទាល់ឡើយ។ តួនាទីរបស់ ក.ជ.ក.ស គឺការតស៊ូមតិ ការត្រួតពិនិត្យ និងវាយតំលៃលើច្បាប់ បទបញ្ញត្តិ និងគោលនយោបាយ របស់រដ្ឋាភិបាលពីទស្សនៈវិស័យយេនឌ័រ និងការត្រួតពិនិត្យលើការអនុវត្តន៍អនុសញ្ញាអន្តរជាតិនានា។ ក.ជ.ក.ស ក៏មានតួនាទីក្នុងការលើកកំពស់ ឋានៈ តួនាទីរបស់នារីនៅកម្ពុជា និងការសរសេររបាយការណ៍ទៅសហប្រជាជាតិ ស្តីអំពីអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារី (CEDAW)។

ដោយសមាជិករបស់ ក.ជ.ក.ស ជាតំណាងជាន់ខ្ពស់មកពីក្រសួងចំនួន១៤ (ភាគច្រើនជាបុរស) ក.ជ.ក.ស មានសក្តានុភាពធ្វើឱ្យមានឥទ្ធិពលក្នុងការរៀបចំ និងការអនុវត្តន៍គោលនយោបាយ និងកម្មវិធីដែលឆ្លើយតបនឹងយេនឌ័រនៅក្នុងក្រសួងទាំងនោះ។ ប៉ុន្តែជាអកុសល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម ដែលជាក្រសួងពីរសំខាន់ក្នុងការបង្កើនឱកាសការងារ និងកាត់បន្ថយភាពក្រីក្រ មិនមែនជាសមាជិកនៅក្នុង ក.ជ.ក.ស ឡើយ។ តួនាទីរបស់ ក.ជ.ក.ស ជាន់នឹងតួនាទីរបស់ក្រសួង ក.ន.អ ដូច្នេះចាំបាច់ត្រូវកែលំអដោយការធ្វើវិសោធនកម្មលើព្រះរាជក្រឹត្យ។ នៅពេលជាមួយគ្នានេះផងដែរ ក.ជ.ក.ស គួរតែបញ្ចូលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម ជាសមាជិករបស់ខ្លួន។

## ៩.២.៣ បទពិសោធន៍របស់ក្រសួងពាក់ពន្ធ័ក្នុងការបញ្ជ្រាបយេនឌ័រ

ក្រសួងពាក់ពន្ធ័មួយចំនួនធំ ផ្តោតលើនារីជាក្រុមគោលដៅ ឬអ្នកទទួលផល ដោយផ្អែកលើទស្សនៈវិស័យយេនឌ័រ។ បញ្ហាយេនឌ័រនៅតែមិនទាន់បានបញ្ជ្រាបបានល្អប្រសើរ នៅក្នុងគោលនយោបាយ និងកម្មវិធីតាមវិស័យនៅឡើយ។ ជាទូទៅបញ្ហាយេនឌ័រ ត្រូវបានគេចាត់ទុកថាជា "បញ្ហា" របស់ក្រសួង ក.ន.អ មិនមែនជាបញ្ហារបស់ក្រសួងតាមវិស័យទាំងអស់ឡើយ។

បច្ចុប្បន្ននេះ ក្រសួង ក.ន.អ កំពុងរៀបចំយុទ្ធសាស្ត្រសំរាប់ការបញ្ជ្រាបយេនឌ័រថ្នាក់ជាតិ។ ក្រសួង ក.ន.អ មានតួនាទីរៀបចំយុទ្ធសាស្ត្រទូលំទូលាយសំរាប់ការបញ្ជ្រាបយេនឌ័រ ហើយក្រសួង និងភ្នាក់ងារទាំងអស់ មានតួនាទីបង្កើតយន្តការដើម្បីដំណើរការងារនេះទៅមុខទៀត។ ក្រសួងចំនួន១០បានតែងតាំងជនបង្គោលយេនឌ័រ ២នាក់ដូចជាក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ផែនការ ទេសចរណ៍ យុត្តិធម៌ សុខាភិបាល ពត៌មាន សង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារយុវនីតិសម្បទា អប់រំ យុវជន និងកីឡា និងមហាផ្ទៃ។ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការឧបត្ថម្ភពីអង្គការ UNICEF បានបង្កើតយន្តការស្ថាប័នមួយ ដើម្បីឆ្លើយតប និងត្រួតពិនិត្យបញ្ហាយេនឌ័រគឺ គណៈកម្មាធិការយេនឌ័រ (Gender Steering Committee) ដែលមានប្រធានជារដ្ឋលេខាធិការ១រូប ហើយគណៈកម្មាធិការបានបង្កើតយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០២-២០០៦ (សូមមើលជំពូកទី៤)។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតក្រុមការងារយេនឌ័រ ដែលមានប្រធានជាអនុរដ្ឋលេខាធិការ១រូប (សូមមើលជំពូកទី៣)។

ដូចដែលបានរៀបរាប់បង្ហាញឱ្យឃើញថា មានការរីកចំរើនគួរឱ្យកត់សំគាល់ ក្នុងការបង្កើតមូលដ្ឋានគ្រឹះ សំរាប់ការបញ្ជ្រាបយេនឌ័រ តាមរយៈការបង្កើតក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយ។ ដោយសារមានការប្រកួតប្រជែងផ្អែកតម្រូវការ បញ្ហាយេនឌ័រមិនត្រូវបានគេចាត់ទុកថាជាបញ្ហាអាទិភាព នៅក្នុងការអភិវឌ្ឍន៍ដ៏ធំធេង និងរបៀបវារៈកំណែទំរង់ឡើយ។ ជាញឹកញាប់ បញ្ហាយេនឌ័រ ត្រូវបានគេគិតថាជាបញ្ហាដែលអ្នកផ្តល់ជំនួយ ចង់ឱ្យរដ្ឋាភិបាល "ធ្វើ" ឬជាការទទួលខុសត្រូវរបស់ក្រសួង ក.ន.អ។ ក្រសួងពាក់ពន្ធ័មួយចំនួនធំ មិនមានសមត្ថភាពក្នុងការវិភាគយេនឌ័រ ហើយជនបង្គោលយេនឌ័រ ទាមទារឱ្យមានការដឹកនាំ និងការគាំទ្រនៅក្នុងក្រសួង ដើម្បីអាចមានឥទ្ធិពលក្នុងការផ្លាស់ប្តូរគោលនយោបាយ និងអំណាចនៅក្នុងក្រសួង។

ការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងស្ថាប័នរដ្ឋ ហាក់ដូចជាតម្រូវការរបស់ប្រទេសអ្នកផ្តល់ជំនួយ ឬត្រូវបានអនុវត្តដោយក្រសួង ក.ន.អ ប៉ុន្តែភាពជាម្ចាស់ការរបស់ក្រសួងប្រតិបត្តិមានកំរិតទាប។ ដោយអវត្តមាននៃការដឹកនាំរបស់ក្រសួងអ្នកផ្តល់ជំនួយដែលឧបត្ថម្ភដល់ក្រសួងណាមួយនោះ ប្រើ និងបង្កើតយុទ្ធវិធីផ្សេងៗ នៅក្នុងគំរោងដែលពួកគេផ្តល់មូលនិធិឧបត្ថម្ភ។ ឧទាហរណ៍ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មានជំនួយមូលនិធិអូស្ត្រាលី ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ASPP) ដំណើរការបញ្ជ្រាបយេនឌ័រទៅក្នុងគំរោងរបស់គេ។ ដោយសារក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មិនមានក្របខ័ណ្ឌបញ្ជ្រាបយេនឌ័រទូលំទូលាយនៅក្នុងក្រសួង ដូច្នេះត្រូវការចាំបាច់នូវការខិតខំប្រឹងប្រែងពីសំណាក់អ្នកផ្តល់ជំនួយ ហើយពេលខ្លះមិនមានការសំរបសំរួលគ្រប់គ្រាន់រវាងអ្នកផ្តល់ជំនួយ។ ករណីនេះបណ្តាលឱ្យមានដំណើរការងារជាន់គ្នា និងបណ្តាលឱ្យមានការបង្កើតនូវប្រពន្ធ័ខុសៗគ្នា ក្នុងការបញ្ជ្រាបយេនឌ័រ។

## ៩.២.៤ អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល

ប្រទេសអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដើរតួនាទីយ៉ាងសំខាន់ នៅក្នុងគ្រប់រូបភាពទាំងអស់នៃការអភិវឌ្ឍន៍នៅកម្ពុជា។ ខាងក្រោមនេះ ជាសកម្មភាពសង្ខេបរបស់ប្រទេសអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដែលដំណើរការបង្កើនសមភាពយេនឌ័រៈ

**អង្គការក្រៅរដ្ឋាភិបាលៈ** អង្គការក្រៅរដ្ឋាភិបាល ដើរតួនាទីយ៉ាងមានតំលៃ ជាអ្នកតស៊ូមតិ និងជាសកម្មជនឯករាជ្យ ដោយផ្តល់ការបណ្តុះបណ្តាល និងដំណើរការស្រាវជ្រាវ និងតស៊ូមតិ។ នាពេលបច្ចុប្បន្ននេះ មានអង្គការក្រៅរដ្ឋាភិបាល ក្នុងស្រុកចំនួន ២៤ អង្គការអន្តរជាតិ ៣១ យកចិត្តទុកដាក់ជាពិសេសលើបញ្ហានារី និងយេនឌ័រ។ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនទៀត ក៏បានដំណើរការបណ្តុះបណ្តាលអំពីយេនឌ័រ ហើយបានបញ្ជូនបុគ្គលិករបស់ខ្លួនទៅទទួលការបណ្តុះបណ្តាលអំពីយេនឌ័រ ឬផ្តោតគោលដៅលើនារី ជាអ្នកទទួលផល។ អង្គការសិទ្ធិមនុស្ស ក៏បានបញ្ចូលបញ្ហាសិទ្ធិនារី ទៅក្នុងកម្មវិធីស្វែងរកការតស៊ូមតិរបស់ខ្លួន និងសហការជាមួយអង្គការរបស់នារី ដែលដំណើរការងារលើបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរភេទ។

បណ្តាញការងារយេនឌ័ររបស់អង្គការក្រៅរដ្ឋាភិបាល ដែលមានឈ្មោះថា បណ្តាញយេនឌ័រ និងកិច្ចអភិវឌ្ឍន៍ (GADNET) និងក្រុមការងារយេនឌ័រនៃវេទិកាអង្គការក្រៅរដ្ឋាភិបាល ធ្វើការសំរបសំរួលលើកិច្ចខិតខំប្រឹងប្រែងរបស់អង្គការក្រៅរដ្ឋាភិបាលមួយចំនួន (អ្នកផ្តល់ជំនួយមានកំរិត) ក្នុងការបញ្ជ្រាបទស្សនៈវិស័យយេនឌ័រ។ ក្រសួង ក.ន.អ ធ្វើជាម្ចាស់ផ្ទះនៅក្នុងវេទិកាចំហរមួយ ដើម្បីសំរបសំរួលសកម្មភាពរបស់ក្រសួង និងអង្គការក្រៅរដ្ឋាភិបាលជាពិសេសនៅក្នុងទិវានារីអន្តរជាតិ។

គណៈកម្មការកម្ពុជាដើម្បីស្ត្រី ត្រូវបានបង្កើតឡើងនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០០ មានអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកចំនួន ៣៣ជាសមាជិក បានផ្តោតយ៉ាងសំខាន់លើការលើកកំពស់ស្ថានភាពរបស់ស្ត្រី និងប្រឆាំងនឹងការជួញដូរនារី និងកុមារ។ គណៈកម្មាធិការ CEDAW របស់អង្គការក្រៅរដ្ឋាភិបាល ដែលមានអង្គការចំរើនស្ត្រី ជាប្រធានមានតួនាទីត្រួតពិនិត្យ និងសរសេររបាយការណ៍ស្តីពីការអនុវត្តន៍អនុសញ្ញា CEDAW។ បណ្តាញការងារបុរសក៏បានចាប់ផ្តើម ដំណើរការងារលើបញ្ហាយេនឌ័រដែរ។

អង្គការចំរើនស្ត្រី បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកំពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ តាមរយៈការផ្តល់ការបណ្តុះបណ្តាលដល់នារីជាបេក្ខជនក្នុងការបោះឆ្នោតឃុំសង្កាត់ និងការបោះឆ្នោតទូទៅ និងផ្តល់ការបណ្តុះបណ្តាលដល់នារីជាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ក្រោយពេលបោះឆ្នោត។ វគ្គបណ្តុះបណ្តាលផ្តោតលើភាពជាអ្នកដឹកនាំ និងជំនាញក្នុងការធ្វើសេចក្តីសំរេច និងការបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រនៅក្នុងច្បាប់ និងគោលនយោបាយនានាដូចជា ច្បាប់ភូមិន្ទបាល ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ និងអំពើហិង្សា។ល។

"សេចក្តីថ្លែងការរបស់អង្គការក្រៅរដ្ឋាភិបាល នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់អំពីកម្ពុជា" ក្នុងឆ្នាំ២០០១ និង២០០២ បានផ្តល់អាទិភាពលើវិស័យជាបន្តបន្ទាប់នេះ ក្នុងការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រដូចជា: អំពើហឹង្សាលើស្ត្រី (ការជួញដូរភេទ អំពើពេស្យាចារដោយបង្ខំ និងអំពើហឹង្សាក្នុងគ្រួសារ) សុខភាព និងអប់រំ (សុខភាពបន្តពូជ និងការអប់រំ) ពលកម្ម និងការងារ (អន្តោប្រវេសន៍ក្នុងស្រុក ការកើនឡើងនៃកំលាំងពលកម្មនារីនៅក្នុងការងារផលិត និងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ) ។

**អ្នកផ្តល់ជំនួយអន្តរជាតិ:** អ្នកផ្តល់ជំនួយអន្តរជាតិមួយភាគធំ មានគោលនយោបាយក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការងាររបស់គេក្នុងកំរិត និងគុណភាពខុសៗគ្នា ។ តារាង ២.១ បង្ហាញអំពីអ្នកផ្តល់ជំនួយមួយចំនួន ដែលគាំទ្រដល់ក្រសួង ក.ន.អ ក្នុងការដោះស្រាយបញ្ហាយេនឌ័រជាក់លាក់ ដូចជា ការជួញដូរស្ត្រី និងកុមារ និងមានអ្នកផ្តល់ជំនួយខ្លះទៀត បង្កើនការបញ្ជ្រាបយេនឌ័រនៅក្នុងគំរោងរបស់ខ្លួន នៅក្នុងក្រសួងតាមវិស័យ ដូចជា ការរៀបចំគំរោងផ្នែកកសិកម្មមួយ ដែលឆ្លើយតបប្រកបដោយសមភាពទៅនឹងតួនាទី និងតម្រូវការ និងឧបសគ្គដែលកសិករជានារី និងបុរសកំពុងប្រឈមមុខ ។ អ្នកផ្តល់ជំនួយសំខាន់ៗមួយចំនួន ទទួលស្គាល់អំពីតម្រូវការក្នុងការផ្តោតការយកចិត្តទុកដាក់លើការផ្លាស់ប្តូរជាយុទ្ធសាស្ត្រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងការធ្វើសេចក្តីសំរេចថ្នាក់ជាតិ ដោយមានយន្តការសមស្រប និងការកសាងសមត្ថភាពដើម្បីគាំទ្រដល់ដំណើរការការងារនេះ ។ អ្នកផ្តល់ជំនួយទាំងនោះមានដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ JICA និងធនាគារពិភពលោក ។ ទោះបីជាយ៉ាងណាក៏ដោយ ចាំបាច់ ត្រូវការជំនួយបន្ថែមនៅក្នុងក្រសួងផ្សេងៗ ដូចជា មូលនិធិសហប្រជាជាតិដើម្បីកុមារនៅក្នុងក្រសួងអ.យ.ក ហើយថ្មីៗនេះ ធនាគារអភិវឌ្ឍន៍ជនបទ ជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដើម្បីផ្តល់អ្នកជំនាញ និងកសាងសមត្ថភាពក្នុងការដំណើរការការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីជាក់លាក់របស់ក្រសួង និងឆ្លើយតបទៅនឹងបញ្ហាថវិកា ការត្រួតពិនិត្យ និងវាយតំលៃ ។ អ្នកផ្តល់ជំនួយចាំបាច់ត្រូវធ្វើការសំរបសំរួលរវាងការងារទាំងអស់នៅក្នុងដំណើរការបញ្ជ្រាបយេនឌ័រ ព្រោះថាបញ្ហាយេនឌ័រ គឺជាបញ្ហាសំខាន់នៅក្នុងគ្រប់វិស័យ ។

បច្ចុប្បន្ននេះ ពុំទាន់មានយន្តការសំរបសំរួលជាផ្លូវការ រវាងអ្នកផ្តល់ជំនួយអន្តរជាតិ និងក្រសួង ក.ន.អ ឬរវាងអ្នកផ្តល់ជំនួយ និងក្រសួងពាក់ពន្ធ័ ។

## ៩.៣ គោលនយោបាយជាតិ និង ដំណើរការធ្វើផែនការយុទ្ធសាស្ត្រ

ក្រសួង ក.ន.អ ក្រសួងពាក់ពន្ធ័ អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ បានខិតខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យបញ្ហាយេនឌ័រត្រូវបានឆ្លើយតប និងកំណត់រកសកម្មភាពសមស្រប នៅក្នុងគោលនយោបាយជាតិ និងដំណើរការធ្វើផែនការយុទ្ធសាស្ត្រ។ រដ្ឋាភិបាលកំពុងតែចាប់ផ្តើមដំណើរការរបៀបវារៈកាត់បន្ថយភាពក្រីក្រ និងកំណែទំរង់ ដែលជាដំណើរការធំទូលំទូលាយ និងមានការប្រកួតប្រជែង ។ ផ្នែកបន្ទាប់នេះ នឹងបង្ហាញអំពីការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រដែលបានពិភាក្សានៅក្នុងជំពូកមុន ។

## ៩.៣.១ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ (SEDP II)

រាជរដ្ឋាភិបាលកម្ពុជា បានទទួលយកការបញ្ជ្រាបយេនឌ័រជាគោលការណ៍មួយ សំរាប់គោលនយោបាយ និងកម្មវិធីរបស់រដ្ឋាភិបាល នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ ២០០១-២០០៥ ដែលបានបញ្ចូលយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន **នារីរតនៈ**។ SEDPII ត្រូវបានរៀបចំក្នុងឆ្នាំ២០០១ ជាគោលការណ៍ក្រសួងផែនការ និងហើយមានការចូលរួមពីក្រសួងពាក់ព័ន្ធសំខាន់ៗមួយចំនួន។ ក្នុងគោលបំណងបញ្ចូលបញ្ហាយេនឌ័រទៅក្នុង SEDPII ក្រសួង ក.ន.អ បានជួបប្រជុំជាមួយក្រសួងពាក់ពន្ធ័ នឹងបានចូលរួមយោបល់ជាលាយលក្ខ័អក្សរ និងចូលរួមក្នុងការពិគ្រោះយោបល់ជាសាធារណៈ។ ទោះបីជាមានសកម្មភាពទាំងនេះក៏ដោយ ក៏នៅក្នុងផែនការសកម្មភាពនៃឯកសារ SEDPII ចុងក្រោយបង្អស់ បានបញ្ចូលបញ្ហាយេនឌ័រតែបន្តិចបន្តួចប៉ុណ្ណោះ។ បញ្ហាយេនឌ័រត្រូវបានបញ្ចូលទៅក្នុងផ្នែកវិភាគបានយ៉ាងល្អ ប៉ុន្តែទំនាក់ទំនងរវាងការវិភាគយេនឌ័រ និងអន្តរាគមន៍តាមវិស័យ ពេលខ្លះនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ហើយការវិភាគយេនឌ័រ ពុំត្រូវបានគេយកទៅប្រើដើម្បីកំណត់យុទ្ធសាស្ត្រ និងរៀបចំសកម្មភាពឡើយ។

## ៩.៣.២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (យ.ជ.ក.ភ)

នៅដើមឆ្នាំ ២០០២ ក្រសួង ក.ន.អ និងតំណាងរបស់ក្រសួងពាក់ពន្ធ័ និងអង្គការក្រៅរដ្ឋាភិបាល បានចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់អាស៊ីខាងកើត ស្តីពីយេនឌ័រ និង យ.ជ.ក.ភ។ នៅក្នុងសិក្ខាសាលានេះ គណៈប្រតិភូបានរៀបចំផែនការសកម្មភាពយេនឌ័រ យ.ជ.ក.ភ ដោយបញ្ចូលនូវសមាសភាគមួយចំនួនដើម្បី :

- ពិនិត្យឡើងវិញលើការរីកចំរើន នៅក្នុងការបញ្ចូលយេនឌ័រទៅក្នុង SEDPII និងយុទ្ធសាស្ត្របណ្តោះអាសន្នសំរាប់ការកាត់បន្ថយភាពក្រីក្រ ។
- ឈានទៅរកការកសាងសមត្ថភាពដល់បុគ្គលិកក្រសួង ក.ន.អ និងក្រុមការងារស្នូល យ.ជ.ក.ភ នៅក្នុងក្រសួងពាក់ពន្ធ័ ដើម្បីយល់ដឹងអំពីបញ្ហាយេនឌ័រ នៅក្នុងបរិបទនៃការកាត់បន្ថយភាពក្រីក្រ។
- ធានាថា អនុសាសន៍របស់សង្គមស៊ីវិលចំពោះ យ.ជ.ក.ភ ត្រូវបានសំរបសំរួល និងឆ្លើយតបនឹងយេនឌ័រ
- ធានាថា ដំណើរការចូលរួមដែលរៀបចំឡើងដោយក្រសួងផែនការ ក្រសួងពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល គឺបញ្ចូលបញ្ហាយេនឌ័រ និងធានាថា សំលេងរបស់ស្ត្រី និងបុរសត្រូវបានគេឮ។
- បង្កើនការយល់ដឹងអំពីយេនឌ័រនៅក្នុងការកាត់បន្ថយភាពក្រីក្រ ដល់អ្នកធ្វើសេចក្តីសំរេចនៅកំរិតកសិករ។
- បង្កើតយុទ្ធវិធី ដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួង ក.ន.អ ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងប្រពន្ធ័ការត្រួតពិនិត្យ និងវាយតំលៃ និងធ្វើយ៉ាងណាឱ្យមានថវិកាដើម្បីឆ្លើយតបនឹងយេនឌ័រ (សំរាប់រយៈពេលមធ្យមដល់រយៈពេលយូរ) ។

ដំណើរការរៀបចំ យ.ជ.ក.ភ បានផ្តល់ឱកាសមួយចំនួនដល់ការបញ្ជ្រាបយេនឌ័រទៅក្នុងឯកសារនេះ ហើយការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ បានកើនឡើងគួរឱ្យកត់សំគាល់ ចាប់តាំងពីដំណើរការ យ.ជ.ក.ភ រយៈពេលខ្លី។ ក្រសួង ក.ន.អ និងអ្នកតស៊ូមតិយេនឌ័រផ្សេងៗទៀត នៅក្នុងសង្គមស៊ីវិលបានចូលរួមចំណែកនៅក្នុងដំណើរការ យ.ជ.ក.ភ ដោយចូលរួមនៅក្នុងក្រុមការងារផ្សេងៗ និងបានបង្ហាញនូវការពេញចិត្តចំពោះកិច្ចខិតខំប្រឹងប្រែង និងការឆ្លើយតបនឹងយេនឌ័ររបស់ក្រសួងមួយចំនួន។ ពេលវេលាសំរាប់ការរៀបចំតារាងផែនការគោលនយោបាយឱ្យបានគ្រប់ជ្រុងជ្រោយ មិនគ្រប់គ្រាន់សំរាប់ការបញ្ចូលគោលដៅ និងសូចនាករ ប៉ុន្តែដោយសារតែឯកសារនេះ ជាឯកសារដំបូង គោលដៅ និងសូចនាករយេនឌ័រ នឹងត្រូវបានបញ្ចូលទៅក្នុងឯកសារក្រោយ ហើយការងារដែលបានធ្វើនៅក្នុង គ.អ.ស នឹងអាចជួយដល់ការងារនេះ។

ទោះបីជានៅមានខ្វះចន្លោះ ប៉ុន្តែអនុសាសន៍របស់ក្រសួង ក.ន.អ ជាច្រើន ត្រូវបានឆ្លើយតបនៅក្នុងឯកសារ។ ផ្នែកមួយស្តីពីយេនឌ័រ ត្រូវបានបញ្ចូលនៅក្នុងឯកសារ ទោះបីជាកន្លែងខ្លះត្រូវបានសំរួលឡើងវិញក៏ដោយ និងមានវិស័យមួយចំនួន បានឆ្លើយតបនឹងយេនឌ័រ។ យុទ្ធសាស្ត្ររបស់វិស័យអប់រំ កសិកម្ម និងអភិវឌ្ឍន៍ជនបទ បានឆ្លើយតបនឹងយេនឌ័រ និងបញ្ចូលសកម្មភាព និងសូចនាករមួយចំនួនឆ្លើយតបនឹងយេនឌ័រ។ ទោះបីជាយ៉ាងណាក៏ដោយបញ្ហាយេនឌ័រ មិនត្រូវបានចែងនៅក្នុងវិស័យអាទិភាពផ្សេងៗទៀត ដូចជាកំណែទំរង់ដីធ្លី កំណែទំរង់ផ្នែកច្បាប់ និងអភិបាលកិច្ច គោលនយោបាយសេដ្ឋកិច្ច ធុនតូច ឬការគ្រប់គ្រងធនធានសាធារណៈ (ថវិកា និងប្រាក់ចំណូលប្រចាំឆ្នាំ)។

មានតំណាងរបស់នារីតិចតួចបំផុត នៅក្នុងដំណើរការពិគ្រោះយោបល់ យ.ជ.ក.ភ ថ្នាក់ខេត្ត ដែលរៀបចំដោយក្រសួងផែនការ។ អង្គការក្រៅរដ្ឋាភិបាលចំរើនស្ត្រី ដោយសហការជាមួយក្រសួង ក.ន.អ បានរៀបចំការពិគ្រោះយោបល់នៅតាមភូមិជាមួយស្ត្រីក្រីក្រ ក្នុងខេត្តចំនួន៦។ អនុសាសន៍ដែលបានពីការពិគ្រោះយោបល់ទាំងនេះ បានយកទៅបង្ហាញ និងពិភាក្សានៅក្នុងក្រសួងវិស័យអាទិភាពរបស់យ.ជ.ក.ភ។

តារាងសកម្មភាពគោលនយោបាយនៅក្នុង យ.ជ.ក.ភ ចែងអំពីវិធានការនានា ដើម្បី:

**បញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងគ្រប់ស្ថាប័នរដ្ឋទាំងអស់ ជាពិសេសស្ថាប័នសុខាភិបាលៈ**

- បង្កើនការស្រាវជ្រាវ និងវិភាគអំពីយេនឌ័រ សំរាប់ការរៀបចំគោលនយោបាយ
- ដំណើការកម្មវិធីអប់រំ និងបណ្តុះបណ្តាលក្នុងការវិភាគយេនឌ័រ ការធ្វើផែនការថវិកា ការអនុវត្តន៍ ការត្រួតពិនិត្យ និងវាយតំលៃសំរាប់ក្រសួង ក.ន.អ កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ សុខាភិបាល អប់រំ យុវជន និងកីឡា អភិវឌ្ឍន៍ជនបទ យុត្តិធម៌ ការពារជាតិ មហាផ្ទៃ។ បង្កើតក្រុមស្នូលដែលយ៉ាងហោចណាស់ មានសមាជិកសំខាន់ៗចំនួន ២០រូប នៅក្នុងក្រសួងក.ន.អ និង១០រូប ពីក្រសួងពាក់ពន្ធ័ នីមួយៗចំនួន ៥ក្រសួង ដើម្បីធានាឱ្យបាននូវការអនុវត្តន៍ការបញ្ជ្រាបយេនឌ័រ។ ក្រសួងពាក់ពន្ធ័ គួរតែមានថវិកាដើម្បីឆ្លើយតបនឹងគំលាតយេនឌ័រ។

**ធានាឱ្យបាននូវការការពារផ្នែកច្បាប់ដល់នារី និងកុមារី និងការយល់ដឹងរបស់សហគមន៍អំពីយេនឌ័រ:**

- តាក់តែងច្បាប់ថ្មី ដូចជាច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារធានាថា ច្បាប់ជួញដូរមនុស្សត្រូវបានឆ្លងធ្វើវិសោធនកម្ម ច្បាប់ដែលលំអៀងយេនឌ័រ និងផ្តល់ការបណ្តុះបណ្តាលដល់តុលាការ និងភ្នាក់ងារអនុវត្តច្បាប់ ។

ធានាថា នារី (និងអតីតយុទ្ធជន) ទទួលបានសិទ្ធិសើភាព ក្នុងការទទួលបានធនធាន និងឱកាសសេដ្ឋកិច្ចនិងបានចូលរួមស្មើភាពនៅក្នុងការធ្វើសេចក្តីសំរេចថ្នាក់ជាតិ ធ្វើផែនការអភិវឌ្ឍន៍ និងដំណើរការកាត់បន្ថយភាពក្រីក្រ ។

- បង្កើតឱកាសផ្សេងៗទៀត សំរាប់ការប្រកបរបរចិញ្ចឹមជីវិត និងបង្កើនសមត្ថភាពរបស់នារីជាសហគ្រិន និងកម្មការិនី ។
- បង្កើនលទ្ធភាពរបស់នារីក្នុងការទទួលបានដីធ្លី ។
- ជួយនារីក្នុងការបង្កើតកម្មវិធីឥណទាន សហគ្រាសមីក្រូ និងខ្នាតតូច និងផ្តល់ការបណ្តុះបណ្តាល ។
- រៀបចំសមាគមកសិករដោយមាននារីជាសមាជិកចំនួន ៥០ភាគរយ ។
- ផ្តួចផ្តើម និងគាំទ្រកម្មវិធីភាពជាអ្នកដឹកនាំសំរាប់នារីនៅក្នុងឆាកនយោបាយ សហជីពពាណិជ្ជកម្ម និងមន្ត្រីរាជការ ។

របាយការណ៍រីកចំរើនប្រចាំឆ្នាំលើកដំបូង កំពុងត្រូវបានរៀបចំតាំងពីដើមឆ្នាំ២០០៤ ។ ដោយសារ យ.ជ.ក.ភ បច្ចុប្បន្នមិនបានចែងឱ្យបានទូលំទូលាយ និងមិនបានបញ្ចូលសកម្មភាពអាទិភាព និងការចំណាយ ដូច្នេះរបាយការណ៍ប្រចាំឆ្នាំលើកដំបូង នឹងត្រូវអភិវឌ្ឍន៍ផ្នែកទាំងនេះ ។

## ៩.៣.៣ ក្របខណ្ឌ័ការងាររួមបញ្ចូលគ្នា - យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មដល់ជនក្រីក្រ

នៅក្នុងការប៉ាន់ប្រមាណនេះ បានកំណត់យកសកម្មភាពសេដ្ឋកិច្ចសំរាប់នារីជនបទ ជាបញ្ហាគន្លឹះមួយ ជាពិសេសក្នុងបរិបទបង្កើនវិស័យពាណិជ្ជកម្ម និងកំណើននៃការនាំចេញ ។ នារីចំនួន ៩០ភាគរយ ជាប្រជាជនក្រីក្រនៅជនបទ ដូច្នេះការបង្កើនផលិតភាព និងចំណូលនៅជនបទ សំរាប់នារីដែលជាកសិករក្រីក្រ គឺជាអាទិភាពយ៉ាងច្បាស់លាស់ ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទី១: ការកាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លាន ។ "យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មដល់ជនក្រីក្រ" ដែលជាក្របខណ្ឌ័គោលនយោបាយរបស់រដ្ឋាភិបាលពាក់ពន្ធ័នឹងពាណិជ្ជកម្ម ចាំបាច់ត្រូវបញ្ចូលការវិភាគបន្ថែមអំពីយេនឌ័រ យុទ្ធសាស្ត្រ និងសូចនាករ ច្បាស់លាស់អំពីការងាររបស់នារី និងការវិភាគថវិកា ។ ប្រពន្ធ័សំរាប់ការវិភាគអំពីឥទ្ធិពល នៃកំណែរទំរង់សេដ្ឋកិច្ចទៅលើនារីដែលក្រីក្រ នៅមិនទាន់មាននៅឡើយ ។ ដូច្នេះការវិភាគយេនឌ័រ ដោយសមហេតុផលអំពីទំនាក់ទំនងរវាងកំណើនពាណិជ្ជកម្ម និងភាពក្រីក្រ ជាពិសេសពាក់ពន្ធ័ទៅនឹងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងការបញ្ចប់កិច្ចព្រមព្រៀង វាយនភ័ណ្ឌ នៅក្នុងឆ្នាំ២០០៤ គឺមានសារ:សំខាន់នៅក្នុងរបៀបវារ:ស្តីពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ។

## ៩.៣.៤ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក)

នៅចុងឆ្នាំ២០០២ អង្គភាពបច្ចេកទេសត្រួតពិនិត្យ និងវិភាគភាពក្រីក្រ (PMATU) នៃក្រសួងផែនការ បានចាប់ផ្តើមដំណើរការរៀបចំឯកសារ គ.អ.ស កម្ពុជា ដើម្បីរៀបចំសរសេររបាយការណ៍ជាតិលើកដំបូងអំពី គ.អ.ស។ ទោះបីជារបាយការណ៍នេះ មិនបានធ្វើឡើងនៅពេលរៀបចំ យ.ជ.ក.ភ ក៏ដោយ ក៏របាយការណ៍នេះ និងអនុសាសន៍គោលនយោបាយ នឹងផ្តល់ខ្លឹមសារសំខាន់សំរាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំអំពី យ.ជ.ក.ភ និងដំណើរការចាត់អាទិភាពសំរាប់ យ.ជ.ក.ភ។ ក្រសួង ក.ន.អ សហការជាមួយមូលនិធិសហប្រជាជាតិដើម្បីនារី បានចូលរួមយ៉ាងសកម្មនៅក្នុងការបញ្ជ្រាបយេនឌ័រ ទៅក្នុងដំណើរការរៀបចំ គ.អ.ស កម្ពុជា តាមរយៈការចូលរួម និងសំរបសំរួលក្នុងការពិគ្រោះយោបល់ ផ្តល់យោបល់ និងការវិភាគទូទៅលើគោលដៅទាំងអស់ និងផ្តល់នូវការវិភាគរួមអំពីយេនឌ័រ ដែលត្រូវបានបញ្ចូលទៅក្នុងឯកសារ ស្តីពីការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជានេះ ដោយមានការឧបត្ថម្ភពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការអភិវឌ្ឍន៍សហប្រជាជាតិ/មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិដើម្បីនារី។ របាយការណ៍ស្តីអំពីការអនុវត្តន៍ គ.អ.ស កម្ពុជា បានបញ្ចូលសូចនាករបន្ថែមស្តីអំពីយេនឌ័រ ដោយមានការវិភាគត្រឹមត្រូវ និងត្រូវបានប្រើប្រាស់ជាគំរូ។

ដំណើរការពិគ្រោះយោបល់ និងការផ្តល់យោបល់ជាទូទៅ និងទូលំទូលាយនៅក្នុងការងារនេះ ធ្វើឱ្យមានការកើនឡើងការយល់ដឹងអំពីបញ្ហាយេនឌ័រ នៅក្នុងអង្គភាព PMATU ក៏ដូចជាអ្នកផ្តល់ជំនួយ ស្ថាប័នរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ដែលបានចូលរួមក្នុងសកម្មភាពរៀបចំ គ.អ.ស កម្ពុជា និងការរៀបចំសរសេរឯកសារប៉ាន់ប្រមាណអំពីបញ្ហាយេនឌ័រនៅកម្ពុជា។

## ៩.៣.៥ ការគ្រោងថវិកា និង ការវិភាជថវិកា

ចំណុចមួយចំនួននៅក្នុងយុទ្ធសាស្ត្រដំបូងបង្អស់ សំរាប់ការបញ្ជ្រាបយេនឌ័រ គឺពាក់ពន្ធ័ទៅនឹងការបញ្ជ្រាបយេនឌ័រនៅក្នុងប្រពន្ធ័ស្ថិតិជាតិ និងការជំរុញដំណើរការរៀបចំថវិកាឱ្យឆ្លើយតបនឹងយេនឌ័រ។

ស្ថាប័នជាច្រើនមានតួនាទីទទួលខុសត្រូវផ្សេងៗពីគ្នា ក្នុងការរៀបចំគោលនយោបាយធ្វើផែនការ កម្មវិធី ការគ្រោងថវិកា និងការត្រួតពិនិត្យលើដំណើរការនៃការចាយវាយថវិកា និងលទ្ធផល។ នៅកម្ពុជា ពុំទាន់មានយន្តការមូលដ្ឋានគ្រឹះដើម្បីធានាថា បញ្ហាពាក់ពន្ធ័នឹងយេនឌ័រ ត្រូវបានបញ្ចូលទៅក្នុងដំណើរការនៃការរៀបចំថវិកាជាតិ ឬបើសិនជាបញ្ហាយេនឌ័រត្រូវបានកំណត់នៅក្នុងការធ្វើផែនការ ដូច្នេះត្រូវមានមូលនិធិសមរម្យ។ ការងារនេះទាមទារឱ្យមានការព្រមព្រៀងនៅថ្នាក់ខ្ពស់បំផុតក្នុងការបង្កើត និងគាំទ្រក្រុមការងារអន្តរក្រសួង ដើម្បីត្រួតពិនិត្យថវិការបស់ក្រសួងពាក់ពន្ធ័ ដោយផ្អែកលើទស្សនៈយេនឌ័រ។ គំរោងថ្មីរបស់ធនាគារពិភពលោកសំរាប់ក្រសួង ក.ន.អ នឹងចាប់ផ្តើមការងារនេះ ហើយនិងគំរោងថ្មីរបស់ UNDP និងមូលនិធិសំរាប់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍មូលនិធិរបស់ជប៉ុន កំពុងធ្វើផែនការ ដើម្បីគាំទ្រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការងារនេះ។

នៅក្នុងក្រសួងជាច្រើន ការប្រមូល និងរាយការណ៍អំពីពត៌មានសំខាន់ៗ មិនទាន់គ្រប់គ្រាន់ ធ្វើឱ្យមានការលំបាកក្នុងការប៉ាន់ប្រមាណអំពីផែនការយុទ្ធសាស្ត្រកំរិតណា ដើម្បីឱ្យស៊ីគ្នានឹងកម្មវិធីដែលមានថវិកាគ្រប់គ្រាន់ ហើយថាតើកម្មវិធីដែលមានថវិកាគ្រប់គ្រាន់ អាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទទួលផលដែលបានគ្រោងទុកបានកំរិតណា។ នៅពេលដែលបញ្ហានេះ ពុំត្រូវបានគេចាត់ទុកថាជាបញ្ហាយេនឌ័រ នោះរឹតតែមានការលំបាកក្នុងការបង្កើតរូបភាពច្បាស់លាស់ នៃបញ្ហាយេនឌ័រក្នុងការចែកចាយសេវាសាធារណៈ។ បញ្ហាពត៌មានកើតឡើងនៅក្នុងកំរិតពីរៈ ទី១ ការដាក់ជំពូកថវិកា (Line Item Budget) ធ្វើឱ្យមានការលំបាកក្នុងការកំណត់ថា ត្រូវចំណាយប៉ុន្មានលើកម្មវិធីពិសេសណាមួយ (ការបែងចែកថវិកា ទៅតាមកម្មវិធីនៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម នឹងជួយដោះស្រាយបញ្ហានេះ)។ ទី២ ដោយសារតែក្រុមគោលដៅមិនត្រូវបានបែងចែកតាមភេទ ដូច្នេះទិន្នន័យអំពីអ្នកទទួលផលនៅក្នុងកម្មវិធីពិសេសនោះ នឹងមិនត្រូវបានគេប្រមូល ឬមិនអាចយកទៅប្រើប្រាស់បាន។ ជាលទ្ធផលធ្វើឱ្យមានការលំបាកក្នុងការកំណត់រកចំនួនស្ថានភាពក្រីក្រ ឬភេទនៃអ្នកទទួលផល និងលំបាកក្នុងការប៉ាន់ប្រមាណប្រសិទ្ធិភាព និងផលប៉ះពាល់នៃការចែកចាយសេវា។ ប៉ុន្តែវិស័យអប់រំ គឺជាករណីលើកលែង ព្រោះវិស័យអប់រំមានប្រព័ន្ធប្រហាក់ប្រហែល ស្តីពីថវិកាតាមកម្មវិធី និងមានទិន្នន័យច្បាស់លាស់អំពីអ្នកទទួលផល។

## ៩.៣.៦ ប្រព័ន្ធស្ថិតិជាតិ

ក្រសួង ក.ន.អ បានចូលរួមក្នុងការផ្តល់យោបល់ទូទៅ នៅក្នុងការអង្កេតសេដ្ឋកិច្ចនៅកម្ពុជា ២00៤ ស្តីពីបញ្ហាយេនឌ័រនៅក្នុងបទដ្ឋានអង្កេត ដែលយោបល់ទាំងនេះ ផ្តោតជាពិសេសលើការប្រមូលទិន្នន័យបែងចែកតាមភេទ និងសមាសភាគថ្មីស្តីពីការប្រើប្រាស់ពេលវេលា ដែលចំណុចនេះត្រូវបានគេដាក់បញ្ចូលបន្ទាប់ពីការផ្តល់យោបល់របស់ក្រសួង។ កម្មវិធីបណ្តុះបណ្តាលមួយត្រូវបានការឧបត្ថម្ភពីគំរោងភាពជាដៃគូដើម្បីសមធម៌យេនឌ័ររបស់ UNDP/ ក ក ន អ និងរៀបចំឡើងដោយ UNIFEM ស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងប្រព័ន្ធស្ថិតិជាតិ និងបានអញ្ជើញមន្ត្រីរាជការថ្នាក់កណ្តាលពីក្រសួង និងភ្នាក់ងារពាក់ព័ន្ធចំនួន១៦ ដើម្បីជំរុញឱ្យមានការប្តេជ្ញាចិត្ត និងការយល់ដឹងអំពីតម្រូវការឱ្យមានទស្សនៈវិស័យយេនឌ័រនៅក្នុងគ្រប់កំរិត នៃការប្រមូល ការបង្ហាញ ការផ្សព្វផ្សាយ និងការវិភាគទិន្នន័យ។ នេះគឺជាការចាប់ផ្តើមដ៏សំខាន់ និងត្រូវការចាំបាច់ការគាំទ្រនៅកំរិតគ្រប់គ្រងជាន់ខ្ពស់នៅក្នុងក្រសួងពាក់ព័ន្ធ។ ការចាប់ផ្តើមនេះ ចាំបាច់ត្រូវផ្សារភ្ជាប់ដោយមានប្រសិទ្ធិភាពនៅក្នុងយន្តការត្រួតពិនិត្យ និងវាយតំលៃដែលនឹងត្រូវបង្កើតឡើងនៅក្នុងប្រព័ន្ធរបាយការណ៍របស់ យ.ជ.ក.ភ និង គ.អ.ស។

**តារាង ៩.១: គំរោងអ្នកផ្តល់ជំនួយដែលកំពុងដំណើរការនៅក្នុងក្រសួងក.ន.អ ២០០៣-០៤**

| ឈ្មោះគំរោង | អ្នកផ្តល់ជំនួយ | រយៈពេល | គោលបំណង/សកម្មភាពសំខាន់ៗ | ថវិកាប្រហាក់ប្រហែល (US$) |
|---|---|---|---|---|
| ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ | UNDP/រាជរដ្ឋាភិបាលហូឡង់ | ២០០១-២០០៤ | កសាងសមត្ថភាពក្រសួងក្នុងការបញ្ជ្រាបយេនឌ័រ កសាងសមត្ថភាពក្រសួងក្នុងការធ្វើផែនការគ្រប់គ្រង និងសំរបសំរួលដំណើរការងារ និងជំនួយបរទេសរបស់ក្រសួង | $៨០០.០០០ |
| គំរោងការលើកស្ទួយមុខរបរស្ត្រីក្រីក្រឱ្យមាននិរន្តរភាព (ADB) | ធនាគារអភិវឌ្ឍន៍អាស៊ី | ២០០៣-២០០៥ (១៨ខែ) | ពង្រឹងសមត្ថភាពក្នុងការតស៊ូមតិដើម្បីបង្កើនភាពអង់អាចក្នុងវិស័យសេដ្ឋកិច្ច។ រៀបចំយុទ្ធវិធី និងសម្ភារៈដើម្បីពង្រីងឱកាសការងាររបស់ស្ត្រី។ ពង្រឹងសមត្ថភាពក្នុងការរៀបចំគោលនយោបាយ និងបណ្តាញការងារ។ ថ្នាក់ជាតិ និងថ្នាក់ខេត្តៈ កំពង់ស្ពឺ តាកែវ កំពង់ឆ្នាំង និងកំពង់ចាម | $៤០០.០០០ |
| លើកកំពស់សិទ្ធិស្ត្រី | GTZ | ២០០២-២០០៥ (ដំណាក់ការដំបូង) | បណ្តុះបណ្តាលផ្នែកច្បាប់នៅក្នុងក.ក.ន.អ និងការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យច្បាប់ដែលបានជ្រើសរើស ថ្នាក់ជាតិ | មូលនិធិប្រទេសអាល្លឺម៉ង់ ដំណាក់ការដំបូងមានចំនួន២.៣ លានអឺរ៉ូ |
| ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរលើស្ត្រី និងកុមារ | អង្គការអន្តោប្រវេសន៍អន្តរជាតិ/ ហូឡង់ | ២០០០-២០០៣ | បណ្តុះបណ្តាលផ្នែកច្បាប់ ការតស៊ូមតិ និងយុទ្ធនាការផ្សព្វផ្សាយពត៌មានប្រទេសចំនួន៦ មានថវិកាចំនួន ១លានដុល្លាអាមេរិក អនុវត្តក្នុងខេត្ត-ក្រុងៈ បន្ទាយមានជ័យ កោះកុង ស្វាយរៀង ប៉ៃលិន ក្រុងព្រះសីហនុ ភ្នំពេញ | $២២០.០០០ |
| យុទ្ធនាការផ្សព្វផ្សាយពត៌មានប្រយុទ្ធប្រឆាំង នឹងការជួញដូរស្ត្រី និងកុមារនៅកម្ពុជា | អង្គការអន្តោប្រវេសន៍អន្តរជាតិ/មូលនិធិសហរដ្ឋអាមេរិក | ២០០៣-២០០៥ | យុទ្ធនាការផ្សព្វផ្សាយពត៌មាន សកម្មភាពតាមភូមិ ដើម្បីបង្កើតបណ្តាញសហគមន៍ បង្កើតទិន្នន័យស្តីពីការជួញដូរ និងបណ្តុះបណ្តាលបុគ្គលិកអំពីការរៀបចំគោលនយោបាយ និងការស្វែងរកការតស៊ូមតិ បណ្តុះបណ្តាលមន្ត្រីមន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្តបាត់ដំបង | $៨៣៩.០០០ |

| ឈ្មោះគំរោង | អ្នកផ្តល់ជំនួយ | រយៈពេល | គោលបំណង/សកម្មភាពសំខាន់ៗ | ថវិកាប្រហាក់ប្រហែល (US$) |
|---|---|---|---|---|
| | | | កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត ក្រុងកែប កណ្តាល មណ្ឌលគីរី ឧត្តរមានជ័យ ព្រះវិហារ ព្រៃវែង ពោធិសាត់ រតនៈគីរី សៀមរាប ស្ទឹងត្រែង តាកែវ | |
| កម្មវិធីជាតិប្រឆាំងអំពើជួញដូរស្ត្រី និងកុមារនៅអនុតំបន់មេគង្គ | UNIAP | ១៩៩៩-២០០៣ (ដំណាក់កាលទី១) | យុទ្ធវិធីថ្មីប្រព័ន្ធគាំទ្រតាមសហគមន៍ តាមរយៈការកសាងសមត្ថភាព ការពង្រឹងច្បាប់ គោលនយោបាយ និងនីតិកម្ម ការវិភាគជាយុទ្ធសាស្ត្រ និងការវាយតំលៃអំពីផលប៉ះពាល់កំរិតថ្នាក់ជាតិ | $១០០.០០០ (ក្នុង ១ឆ្នាំៗ) |
| ការបញ្ជ្រាបយេនឌ័រទៅក្នុងប្រព័ន្ធវិមជ្ឈការ និងសហវិមជ្ឈការ (កម្មវិធីសិលា) | UNDP ភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន | ២០០១-២០០៥ | ការបញ្ជ្រាបយេនឌ័រនៅក្នុងខេត្តទាំងអស់ ការកសាងសមត្ថភាពមន្ទីរខេត្ត និងក្រុមប្រឹក្សាឃុំសង្កាត់ ការត្រួតពិនិត្យ និងវាយតំលៃគ្រប់ខេត្ត-ក្រុង | $៧៥.០០០ |
| កម្មវិធីចែកចាយមធ្យោបាយពន្យារកំណើតនៅសហគមន៍ | UNFPA/ក្រសួងសុខាភិបាល | ២០០១-២០០៣ | ក្រសួង ក.ន.អ បានចុះកិច្ចសន្យាជាមួយក្រសួងសុខាភិបាលក្នុងការផ្តល់សេវាសុខាភាពបន្តពូជ ជាពិសេសការផ្តល់ជូននូវមធ្យោបាយពន្យាកំណើតតាមសហគមន៍ និងការងារទំនាក់ទំនងផ្សព្វផ្សាយពត៌មាន (ក្រសួងសុខាភិបាលជាអ្នកប្រតិបត្តិ) ក្នុងខេត្តកំពង់ឆ្នាំង កណ្តាល ស្វាយរៀង ព្រៃវែង បាត់ដំបង និងកំពត | $២១៧.៦៥៨ |
| អ្នកស្ម័គ្រចិត្តសុខភាពបន្តពូជ | UNFPA | ២០០១-២០០៣ | ក្រសួង ក.ន.អ បានចុះកិច្ចសន្យាជាមួយសមាគមសុខភាពបន្តពូជ (RHAC) ធ្វើការចែកចាយមធ្យោបាយពន្យាកំណើត និងផ្សព្វផ្សាយពត៌មានអប់រំទំនាក់ទំនងតាមសហគមន៍នៅថ្នាក់ខេត្ត-ស្រុក ក្នុងខេត្តកំពង់ចាម កំពង់ឆ្នាំង កំពត កណ្តាល សៀមរាប ព្រៃវែង ស្វាយរៀង បាត់ដំបង | $១៣៨.២៩១ |

| ឈ្មោះគំរោង | អ្នកផ្តល់ជំនួយ | រយៈពេល | គោលបំណង/សកម្មភាពសំខាន់ៗ | ថវិកាប្រហាក់ប្រហែល (US$) |
|---|---|---|---|---|
| គោលនយោបាយហ៊ីវ/អេដស៍ សំរាប់ស្ត្រី និងកុមារី | UNAIDS | ១៩៩៩-២០០៣ | រៀបចំគោលនយោបាយស្តីពីស្ត្រី និងកុមារី និងហ៊ីវ/អេដស៍ និង សិក្ខាសាលាក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន ឧត្តរមានជ័យ ពោធិសាត់ សៀមរាប កំពង់ឆ្នាំង ស្វាយរៀង កោះកុង កំពង់ធំ ព្រៃវែង កំពង់ចាម | $៦៨.៣៤៦ |
| ការស្វែងរកការគាំទ្រមតិលើបញ្ហាយេនឌ័រក្នុងសុខភាពបន្តពូជ | UNFPA | ២០០២-២០០៤ (ខែកុម្ភៈ) | ពង្រឹងសមត្ថភាពស្ថាប័ន និង NGOs ដែលបានជ្រើសរើសក្នុងការស្វែងរកមតិគាំទ្រសមភាពយេនឌ័រនៅក្នុងសុខភាពបន្តពូជ។ បង្កើនការយល់ដឹង និងការប្តេជ្ញាចិត្តរបស់អ្នកតាក់តែងគោលនយោបាយអ្នកធ្វើសេចក្តីសំរេច និងសារពតិមានថ្នាក់ជាតិ | $៧៩៥.៩២០ |
| ការផ្លាស់ប្តូរគោលនយោបាយស្តីពីយេនឌ័រ និងជំងឺអេដស៍/ជំងឺកាមរោគនៅថ្នាក់ឃុំ-សង្កាត់ | គំរោងគោលនយោបាយ | ២០០៣-២០០៤ | ផ្តោតលើនារីក្មេងស្រី និងជំងឺកាមរោគ ជំងឺអេដស៍ក្នុងខេត្តគោលដៅៈ កោះកុង បន្ទាយមានជ័យ សៀមរាប ស្វាយរៀង តាកែវ និងភ្នំពេញ | $២៩.៧៣៧ |
| កម្មវិធីតំបន់អាស៊ីដើម្បីបង្កើនឱកាសការងារសំរាប់ស្ត្រី | ILO/ជប៉ុន | ២០០១-២០០៦ | ពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធនឹងការវិភាគយេនឌ័រនៅក្នុងការងារសកម្មភាពសាកល្បងនៅតាមសហគមន៍ ក្នុងខេត្តតាកែវ កណ្តាល សៀមរាប ភ្នំពេញ (USG, IUWC) | ១លាន |
| ជួយស្ត្រីដើម្បីបង្កើនសន្តិសុខស្បៀង និងសេដ្ឋកិច្ចគ្រួសារ | FAO | ២០០១-២០០៣ | សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ក្រសួង និងថ្នាក់ខេត្ត បណ្តុះបណ្តាលដល់ស្ត្រីជនបទជាគ្រូឧទ្ទេសនាម សាកល្បងការបណ្តុះបណ្តាលដល់ស្ត្រីជនបទចំនួន ២០០នាក់ និងជួយបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យានៅជនបទក្នុងខេត្តកណ្តាល និងកំពង់ឆ្នាំង | $២៤៩.០០០ |
| ការបញ្ជ្រាបយេនឌ័រ និងការបង្កើតគោលនយោបាយតាមរយៈការពង្រឹងសមត្ថភាពពតិមាន និងស្រាវជ្រាវ | JICA | មេសា ២០០៣-២០០៨ | បង្កើតយន្តការប្រកបដោយប្រសិទ្ធិភាព សំរាប់ការបញ្ជ្រាបយេនឌ័រតាមរយៈការពង្រឹងសមត្ថភាពក.ក.ន.អ ជាពិសេសការប្រមូលពតិមាន និងស្រាវជ្រាវ សាកល្បងគំរោងនៅក្នុងខេត្តមួយ ឬពីរៈ ខេត្តកំពង់ចាម និងខេត្តមួយទៀត | $២-$៣ លាន |

| ឈ្មោះគំរោង | អ្នកផ្តល់ជំនួយ | រយៈពេល | គោលបំណង/សកម្មភាពសំខាន់ៗ | ថវិកាប្រហាក់ប្រហែល (US$) |
|---|---|---|---|---|
| គំរោងសាកល្បងអភិវឌ្ឍន៍ទីផ្សារ | NZ ODA | វិច្ឆិកា ២០០២-មេសា ២០០៣ | ការបណ្តុះបណ្តាលជាមូលដ្ឋានអំពីការអភិវឌ្ឍន៍ជំនួញ និងទីផ្សាររកទីផ្សារ/ផ្តល់សេវាប្រឹក្សាអភិវឌ្ឍន៍ទីផ្សារ ការបង្កើតសមាគមអាជីវករក្នុងខេត្តបន្ទាយមានជ័យ (ប៉ោយប៉ែត) | $២២.៩០០ |
| បង្កើនភាពអង់អាចដល់ក្រុមងាយរងគ្រោះតាមរយៈការបណ្តុះបណ្តាលស្តីពីការកែច្នៃម្ហូបអាហារថ្នាក់ភូមិ | FAO | ២០០៣-២០០៥ | អភិវឌ្ឍន៍អាជីវកម្មខ្នាតតូច និងជំនាញទី-ផ្សារដល់ស្ត្រី អតីតយុទ្ធជនពិការ ផ្តល់ការបណ្តុះបណ្តាលដល់គ្រូឧទ្ទេសនាមតាមសហគមន៍ និងមន្ត្រីផ្សព្វផ្សាយស្ថាប័នរដ្ឋ និងបុគ្គលិក NGO/CBO ក្នុងខេត្តកំពង់ចាម គំរោងសាកល្បង | $៣៦៩.០០០ |
| សំលេងរបស់នារីការជ្រើសរើសរបស់នារី | មូលនិធិ Rockefeller | ២០០៣-២០០៤ | ផ្សព្វផ្សាយពតិមានអំពីសុខភាពបន្តពូជ អំពើហិង្សាយេនឌ័រ ការជួញដូរ និងបញ្ហាផ្សេងៗទៀតរបស់នារីថ្នាក់ជាតិ | $៤៩.៣១០ |
| សមាហរណកម្មបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច សហគ្រិនភាព និងការងារសំរាប់នារី (NEEEW) | ILO/អាល្លឺម៉ង់ | ២០០៣-២០០៦ (មិនទាន់ចាប់ផ្តើមនៅឡើយ) | បង្កើនមុខរបរចិញ្ចឹមជីវិតចិរភាព និងឱកាសការងារសមរម្យកាត់បន្ថយភាពក្រីក្រសំរាប់នារី ជាពិសេសការអភិវឌ្ឍន៍មជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ចំនួន៣ ឱ្យទៅជាមជ្ឈមណ្ឌលសហគ្រាសក្នុងខេត្តកំពង់ចាម កំពង់ធំ និងកំពត | $១.៦៩២លាន |
| សមាហរណកម្មបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច សហគ្រិនភាព និងការងារសំរាប់នារី (NEEEW) | ILO/អៀកឡង់ | ២០០៣-២០០៦ | បង្កើនមុខរបរចិញ្ចឹមជីវិតចិរភាព និងឱកាសការងារសមរម្យកាត់បន្ថយភាពក្រីក្រសំរាប់នារី ជាពិសេសការអភិវឌ្ឍន៍មជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍មួយឱ្យទៅជាមជ្ឈមណ្ឌលសហគ្រាសក្នុងខេត្តកំពង់ឆ្នាំង | $១១៥.០០០ |
| ការពិនិត្យ ការរៀបចំផែនការ និងថវិកាឆ្លើយតបនឹងយេនឌ័រក្នុងការអនុវត្តន៍ យ.ជ.ក.ភ | ធនាគារពិភពលោក | ២០០៤-២០០៥ | ពិនិត្យដំណើរការរៀបចំថវិកាជាតិ ផ្តល់មូលនិធិដើម្បីកាត់បន្ថយគំលាតយេនឌ័រ តាមរយៈការវិភាគ និងស្រាវជ្រាវ ការចំណាយការប៉ាន់ប្រមាណផលប៉ះពាល់ និងការត្រួតពិនិត្យលទ្ធផលថ្នាក់ជាតិ | $៣០០.០០០ |

# ជំពូកទី ១០

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍


១០.១ បញ្ហាប្រឈមទាក់ទងនិងការផ្តល់អំណាចក្នុងវិស័យសេដ្ឋកិច្ច នឹងកើនឡើង ព្រោះអត្រាមនុស្សពេញវ័យកាន់តែកើនឡើង ........ ២១៤

១០.២ នារីជនបទពុំមានលទ្ធភាពទទួលបាននូវធនធាន និង សេវាកម្មនានា ដែលអាចជួយពួកគេ ក្នុងការកាត់បន្ថយភាពក្រីក្រ និង ការធានាបាននូវសន្តិសុខស្បៀង ........ ២១៨

១០.៣ វិសមភាពយេនឌ័រក្នុងលទ្ធភាពទទួលបានសេវាសុខភាព និង អប់រំ គឺមានសភាពធ្ងន់ធ្ងរបំផុត ក្នុងចំណោមប្រជាជនក្រីក្រ និង នៅតាមតំបន់ជនបទ ........ ២១៩

១០.៤ ប្រជាជនដែលងាយរងគ្រោះទទួលបានការគាំទ្រតិចតួច ហើយពុំដឹងថា ត្រូវទៅរកជំនួយនៅកន្លែងណា........ ២២២

១០.៥ ស្ថាប័នសង្គម ផ្លូវច្បាប់ និង នយោបាយ បន្តឱ្យមានការរើសអើងយេនឌ័រ និងភាពងាយរងគ្រោះ ........ ២២៥

១០.៦ ស្ថាប័ននៅតែប្រឹងប្រែងក្នុងការបញ្ជ្រាបយេនឌ័រឱ្យមានប្រសិទ្ធិភាព ........ ២២៧

# ជំពូកទី ១០ ៖ សេចក្តីសន្និដ្ឋាន និង អនុសាសន៍

គ្រាន់តែក្នុងមួយទសវត្សរ៍ប៉ុណ្ណោះ ប្រទេសកម្ពុជាបានឈានមួយជំហ៊ានធំនៅក្នុងការកសាងឡើងវិញ នូវធនធានមនុស្ស និងរចនាសម្ព័ន្ធសង្គម ដែលត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរក្នុងអតីតកាលដ៏ឃោរឃៅ។ សូចនាករសង្គមស្តីអំពីវិស័យសុខភាព អប់រំ និងសេដ្ឋកិច្ច បានបង្ហាញឱ្យឃើញនូវភាពរីកចំរើនជាលំដាប់ ហើយក្នុងបណ្តាឆ្នាំកន្លងមកនេះ ស្ថានភាពនៅក្នុងប្រទេសមានស្ថេរភាពល្អប្រសើរ ។

ទោះបីជាយ៉ាងណាក៏ដោយ បច្ចុប្បន្នដំណើរការរីកចំរើននេះអាចស្ថិតក្នុងស្ថានភាពគំរាមកំហែង។ កំណើនកុមារក្នុងទសវត្សរ៍ឆ្នាំ១៩៨០ បានធ្វើឱ្យបច្ចុប្បន្នមានចំនួនប្រជាជនកើនឡើង ដែលស្ថិតក្នុងវ័យស្វែងរកការងារធ្វើ និងវ័យបន្តពូជ។ សេវាសុខភាព និងអប់រំ ចាំបាច់ត្រូវបន្ត និងបង្កើនការផ្តល់សេវាដល់ពួកគេ និងកូនៗរបស់ពួកគេ ហើយចាំបាច់ត្រូវបង្កើនផលិតភាពកសិកម្ម ដើម្បីផ្គត់ផ្គង់ដល់ពួកគេទាំងនោះ។ ហើយសំខាន់បំផុត គឺចាំបាច់ត្រូវបើកឱកាសឱ្យពួកគេចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ បើសិនជាពួកគេទទួលបានឱកាសទាំងនេះ មនុស្សជំនាន់នេះ នឹងក្លាយទៅជាម៉ាស៊ីនដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាកើនឡើង។ បើសិនជាពួកគេពុំទទួលបានឱកាសទាំងនេះទេ ពួកគេ និងកូនៗរបស់ពួកគេ នឹងបង្កើនបន្ទុកកាន់តែធ្ងន់ធ្ងរដល់ប្រទេសជាតិ ហើយការអស់សង្ឃឹមរបស់ពួកគេ នឹងប៉ះពាល់ដល់សន្តិសុខក្នុងសង្គម ។

នៅក្នុងកាលៈទេសៈដ៏សំខាន់នេះ កម្ពុជាពុំគួរទុកឱ្យបញ្ហារើសអើង និងវិសមភាពយេនឌ័រ ដាក់កំរិតទៅលើសក្តានុពលភាពពេញលេញរបស់ប្រទេសនោះឡើយ ។ ការប្រកួតប្រជែងក្នុងការងារ សេវាកម្ម ធនធាន និងទ្រព្យសម្បត្តិ នឹងកើនឡើងយ៉ាងពិតប្រាកដ ហើយបើសិនជាគ្មានការផ្លាស់ប្តូរដើម្បីជួយពួកគេនោះទេ នារីនឹងកាន់តែត្រូវបានគេផាត់ចេញពីសង្គម ។ បើសិនជាបណ្តោយឱ្យករណីនេះកើតឡើង វានឹងមិនត្រឹមតែជាការខាតបង់សំរាប់នារីប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការខាតបង់សំរាប់កូនចៅរបស់ពួកគេ និងសំរាប់សង្គមជាតិកម្ពុជាទាំងមូលផងដែរ ។ ចាំបាច់ត្រូវអនុវត្តវិធានការចំពោះមុខ ដើម្បីទំលាយឧបសគ្គនានា ដែលនៅតែបន្តរាំងដល់ការចូលរួមយ៉ាងសកម្ម និងស្មើភាពរបស់នារី នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ។

ផែនការ និងយុទ្ធសាស្ត្រដែលមានស្រាប់របស់រាជរដ្ឋាភិបាល ក៏បានដាក់ចេញរួចមកហើយនូវសកម្មភាពស្ថាបនាល្អៗជាច្រើន ដើម្បីដោះស្រាយបញ្ហាយេនឌ័រ ។ អនុសាសន៍នៅក្នុងជំពូកនេះ មានគោលបំណងបំពេញបន្ថែមលើសកម្មភាពទាំងនេះ ហើយផ្តោតជាសំខាន់ទៅលើវិស័យមួយចំនួន ដែលមិនទាន់ទទួលបានការយកចិត្តទុកដាក់ឱ្យបានច្រើននៅឡើយ ។ បញ្ហាសំខាន់ៗមួយចំនួន ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងប្រឈមមុខ ក្នុងការខិតខំប្រឹងប្រែងសំរេចឱ្យបាននូវសមភាពយេនឌ័រ មានដូចជា៖

- បញ្ហាប្រឈមមុខក្នុងការផ្តល់អំណាចដល់នារីក្នុងវិស័យសេដ្ឋកិច្ច ក្នុងខណៈពេលដែលចំនួនប្រជាជន និងការប្រកួតប្រជែងកំពុងតែកើនឡើង។ ស្របពេលជាមួយគ្នានេះផងដែរ ឱកាសការងារត្រូវបានផ្តល់ឱ្យទៅបុរសជាសំខាន់ ដើម្បីការពារស្ថេរភាពក្នុងសង្គម ។

- បញ្ហាប្រឈមមុខក្នុងការផ្តល់ធនធាន និងហេដ្ឋារចនាសម្ពន្ធ័ដល់នារីនៅតាមតំបន់ជនបទ ដែលមានប្រជាជនក្រីក្រភាគច្រើនរស់នៅ ហើយដែលនារីដើរតួយ៉ាងសំខាន់ក្នុងការធានាសន្តិសុខស្បៀង និងក្នុងការបង្កើនប្រាក់ចំណូលនៅក្នុងគ្រួសារ ។
- បញ្ហាប្រឈមមុខក្នុងការផ្តល់សេវាចាំបាច់ដូចជាសេវាសុខភាព និងអប់រំ ជាពិសេសដល់នារីនៅតាមតំបន់ជនបទ ។
- បញ្ហាប្រឈមមុខក្នុងការផ្តល់ការថែទាំ និងការគាំទ្រដល់ប្រជាជនដែលងាយរងគ្រោះ ដូចជាអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងជនរងគ្រោះដោយសារអំពើហឹង្សា ។
- បញ្ហាប្រឈមមុខក្នុងការធ្វើឱ្យមានការផ្លាស់ប្តូររចនាសម្ពន្ធ័ក្នុងសង្គមដែលជាការចាំបាច់ ដើម្បីផ្តល់ដល់នារីនូវសំលេងមួយក្នុងកិច្ចអភិវឌ្ឍន៍ និងពង្រឹងតួនាទីរបស់នារីនៅក្នុងសង្គម ដែលនាំឱ្យនារីអាចទទួលបានសិទ្ធិពេញលេញ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួន ដែលប្រទេសកម្ពុជាបានចុះហត្ថលេខា ។
- បញ្ហាប្រឈមមុខក្នុងការឈានទៅរកការបញ្ជ្រាបយេនឌ័រ ទៅក្នុងការធ្វើផែនការ ថវិកា និងដំណើរការអភិវឌ្ឍន៍តាមវិស័យនៅក្នុងស្ថាប័នរដ្ឋ ។

## ១០.១ បញ្ហាប្រឈមទាក់ទងនឹងការផ្តល់អំណាចក្នុងវិស័យសេដ្ឋកិច្ច នឹងកើនឡើងព្រោះអត្រាមនុស្សពេញវ័យកាន់តែកើនឡើង

### *១០.១.១ ចាំបាច់ត្រូវបង្កើនការងារផ្លូវការដែលមានប្រាក់កំរៃជាបន្ទាន់ ដើម្បីស្រូបទាញយកកំលាំងពលកម្មដែលកំពុងកើនឡើង*

កំលាំងពលកម្មកើនឡើងចំនួន៣,៥ ភាគរយ (ឬប្រហែលមួយភាគបួននៃប្រជាជនមួយលាននាក់) ក្នុងមួយឆ្នាំ ប៉ុន្តែឱកាសការងារដែលមានប្រាក់កំរៃនៅមានកំរិតតិចតួចណាស់ និងពុំអាចឆ្លើយតបទៅនឹងកំណើននៃកំលាំងពលកម្មបានឡើយ ។ លទ្ធភាពរបស់ប្រទេសក្នុងការទាក់ទាញវិនិយោគទុនបរទេស គឺជាបញ្ហាសំខាន់ ប៉ុន្តែថ្មីៗនេះ មានការបង្ហាញឱ្យឃើញថា មានការថយចុះនៃវិនិយោគទុនដោយផ្ទាល់ពីបរទេស ។ អភិបាលកិច្ចទន់ខ្សោយ និងការរីករាលដាលនៃអំពើពុករលួយ គឺជាបញ្ហាចំបងដែលបង្អាក់ទឹកចិត្តរបស់អ្នកវិនិយោគ ។

### *១០.១.២ ជំរើសការងារផ្លូវការមួយចំនួនធំ ជាតំរូវការចាំបាច់សំរាប់បុរស និងនារី*

នៅពេលដែលវិស័យកសិកម្មត្រូវបានផ្លាស់ប្តូរពីកសិកម្មជាលក្ខណៈគ្រួសារ ទៅជាកសិកម្មទីផ្សារ ទាំងបុរស និងនារី កំពុងឈានចូលទៅក្នុងការងារមានប្រាក់កំរៃនៅក្នុងវិស័យនេះ ។ ក្រៅពីវិស័យកសិកម្ម មានឱកាសការងារថ្មីមួយចំនួនតូចប៉ុណ្ណោះសំរាប់បុរស ដែលជាមុខរបរតាមលក្ខណៈ "ប្រពៃណី" និងមានការកើនឡើងនូវការរំពឹងទុក

នៅក្នុងសេដ្ឋកិច្ចទីផ្សារ ដែលនេះគឺជាប្រភពនៃការខកចិត្តយ៉ាងខ្លាំង ។ ការទទួលខុសត្រូវរបស់នារី ក្នុងការងារប្រកបរបរចិញ្ចឹមជីវិត នៅក្នុងការងារតាមលក្ខណៈ "ប្រពៃណី" របស់នារីកាន់តែកើនឡើង ក្នុងខណៈដែលនារីនៅតែមានការទទួលខុសត្រូវលើកិច្ចការផ្ទះ និងការថែទាំកូន ឬការមករកការងារធ្វើនៅទីក្រុង/ទីប្រជុំជន ដែលនៅទីនោះនារីនឹងងាយទទួលរងគ្រោះបំផុត ដោយសារការកេងប្រវ័ញ្ច ។ នារីពឹងផ្អែកទាំងស្រុងលើការងារមានប្រាក់កំរៃនៅក្នុងឧស្សាហកម្មកាត់ដេរ ប៉ុន្តែនេះជាការងារមិនទៀងទាត់ ហើយអនាគតនៅពុំទាន់ច្បាស់លាស់នៅឡើយ ។ បើសិនជាវិស័យឧស្សាហកម្មកាត់ដេរនេះបរាជ័យ លទ្ធផលដែលនារីទទួលបាននៅក្នុងវិស័យការងារមានប្រាក់កំរៃ នឹងត្រូវបាត់បង់ទៅវិញ ។ ស្របពេលជាមួយគ្នានេះផងដែរ ឧស្សាហកម្មកាត់ដេរពុំបានផ្តល់ការងារដល់បុរសវ័យក្មេងទេ ហើយបុរសវ័យក្មេងទាំងនេះពុំចូលចិត្តធ្វើការងារនៅក្នុងវិស័យសាធារណៈ ដែលជាការងាររបស់ "បុរស" ទៀតឡើយ ។ ដោយមានការកាត់រំសាយកងទ័ព កំណែទម្រង់រដ្ឋបាល និងឯកជនភាវូបនីយកម្មសេវាកម្ម ធ្វើឱ្យឱកាសការងារនៅក្នុងវិស័យសាធារណៈធ្លាក់ចុះ ។ ភាពអត់ការងារធ្វើ គឺជាកត្តាសំខាន់ដែលបណ្តាលឱ្យមានអសន្តិសុខ និងអស្ថេរភាពសង្គម ដូច្នេះសង្គមនឹងត្រូវប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរ បើសិនជាមនុស្សវ័យក្មេង ជាពិសេសយុវជនពុំអាចរកការងារមានប្រាក់កំរៃធ្វើបាន ។

## ១០.១.៣ ឱកាសការងារនៅតំបន់ជនបទមានកំរិត និងមិនអាចបំពេញតាមតំរូវការ

ប្រជាជនក្រីក្រភាគច្រើនរស់នៅតំបន់ជនបទ ហើយទោះបីជាវិស័យកសិកម្ម គឺជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ ដែលអាចផ្តល់ការងារនៅជនបទក៏ដោយ ក៏វិស័យនេះមិនអាចស្រូបទាញកំលាំងពលកម្មបានច្រើនដែរ បើសិនជាមិនមានការផ្លាស់ប្តូរក្នុងផ្នែកសំខាន់ៗនៅក្នុងវិស័យនេះ ។ មានជំរើសមួយចំនួនតូចប៉ុណ្ណោះ សំរាប់ប្រជាជនក្រីក្រនៅជនបទ ។ ទីផ្សារពលកម្មនៅក្នុងស្រុក មានលក្ខណៈមិនទៀងទាត់ និងផ្លាស់ប្តូរយ៉ាងលឿន ហើយនៅពេលដែលមិនមានឱកាសការងារនៅក្នុងមូលដ្ឋានទេ ការមករកការងារធ្វើនៅទីក្រុង គឺជាជំរើសតែមួយគត់សំរាប់បុរស និងនារីភាគច្រើន ។ កត្តានេះធ្វើឱ្យបុរស និងនារីទាំងនោះ ងាយនឹងទទួលរងគ្រោះដោយអំពើជួញដូរ និងការធ្វើអាជីវកម្ម ។ ឱកាសការងារក្នុងស្រុកក្រៅពីការងារស្រែចំការនៅតាមតំបន់ជនបទ ដែលរួមទាំងឱកាសការងារសំរាប់នារី នឹងអាចជួយកាត់បន្ថយភាពក្រីក្រនៅតាមជនបទ កាត់បន្ថយមូលហេតុមួយដែលបណ្តាលឱ្យមានការជួញដូរមនុស្ស និងជួយអភិវឌ្ឍសហគមន៍ផងដែរ ។

## ១០.១.៤ ឱកាសកើនឡើង ប៉ុន្តែនារីពុំមានសមត្ថភាពប្រកួតប្រជែងចាប់យកឱកាសទាំងនោះ

ការអប់រំ អាចជួយធ្វើឱ្យនារីទទួលបានឱកាសការងារ និងប្រាក់បៀវត្សរ៍ខ្ពស់ ប៉ុន្តែនារីដែលចេះអក្សរ ឬរៀនថ្នាក់ក្រោយបឋមសិក្សា មានចំនួនតិចជាងបុរសយ៉ាងខ្លាំង ។ នារីដែលមានការអប់រំខ្ពស់ អាចប្រកួតប្រជែងជាមួយនឹងបុរសដែលមានកំរិតអប់រំខ្ពស់ដូចគ្នា ប៉ុន្តែនារីភាគច្រើននៅក្នុងកំលាំងពលកម្មបច្ចុប្បន្ន ពុំមានការអប់រំដែលពួកគេត្រូវការដើម្បីឱ្យពួកគេមានលទ្ធភាពទទួលបាននូវឱកាសការងារថ្មីៗបានឡើយ ។

## ១០.១.៥ អនុសាសន៍

- *លើកកំពស់អភិបាលកិច្ចល្អ ដើម្បីបង្កើនវិនិយោគទុនបរទេស និងកំណើនសេដ្ឋកិច្ច*

វិនិយោគទុន និងកិច្ចអភិវឌ្ឍន៍ គឺជាលក្ខខ័ណ្ឌដំបូងសំរាប់ការបង្កើនឱកាសការងារ ដែលនឹងផ្តល់ផលប្រយោជន៍ដល់បុរស និងនារី ។ អភិបាលកិច្ចទន់ខ្សោយ និងអំពើពុករលួយ គឺជាកត្តាបង្អាក់ទឹកចិត្ត ហើយមានការបង្ហាញឱ្យឃើញថា បញ្ហាទាំងពីរនេះកំពុងតែកើនឡើងនៅកម្ពុជា ។ ការបង្កើនអភិបាលកិច្ច និងការដាក់ចេញនូវយុទ្ធសាស្ត្រ ប្រឆាំងនឹងអំពើពុករលួយដែលប្រកបដោយប្រសិទ្ធិភាព គឺជាកត្តាចាំបាច់ក្នុងការជួយឱ្យប្រទេសកម្ពុជា ឆ្ពោះទៅរកអនាគតកាន់តែល្អប្រសើរ ។

- *បង្កើនកិច្ចអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងខិតខំបង្កើនឱកាសការងារនៅតាមតំបន់ជនបទ*

មានកំលាំងពលកម្មភាគច្រើននៅតាមតំបន់ជនបទ ។ ប៉ុន្តែវិស័យកសិកម្ម ពុំអាចផ្តល់ការងារដើម្បីចិញ្ចឹមជីវិតឱ្យឆ្លើយតបទៅតាមកំណើនពលកម្ម ដែលកាន់តែកើនឡើងជាលំដាប់បានឡើយ ។ ការបង្កើតឱកាសការងារថ្មីនៅតាមរោងចក្រនៅទីក្រុង/ទីប្រជុំជន ឬការបង្កើតតំបន់ពាណិជ្ជកម្មនាំចេញ បណ្តាលឱ្យមានការមករកការងារធ្វើនៅទីក្រុង ។ ឥទ្ធិពលសង្គមលើការមករកការងារធ្វើនៅទីក្រុង/ទីប្រជុំជន មានសភាពធ្ងន់ធ្ងរ ជាពិសេសចំពោះនារីវ័យក្មេង ។ ដូច្នេះចាំបាច់ត្រូវបង្កើនការខិតខំប្រឹងប្រែង ដើម្បីបង្កើនឱកាសការងារសំរាប់នារីជនបទ បើអាចទៅរួច ត្រូវផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍ ការដាំដំណាំដែលផ្តល់ប្រាក់ចំណេញច្រើន និងការកែច្នៃផលិតផលកសិកម្ម ។

រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តតាមរយៈ "យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មដល់ជនក្រីក្រ" ដើម្បីបង្កើនផលិតកម្មកសិកម្មច្រើនប្រភេទ និងការកែច្នៃផលិតផលសមស្របដូចជា គ្រាប់ពូជ ថ្នាំរុក្ខជាតិ ដើមឈើហូបផ្លែ ប្រេងរុក្ខជាតិ និងសិប្បកម្មនានា ។ ដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនអំណាចរបស់នារីក្នុងវិស័យសេដ្ឋកិច្ចនៅជនបទ យុទ្ធសាស្ត្រនេះ គួរតែបង្កើនកិច្ចអភិវឌ្ឍន៍តាមបែបវិមជ្ឈការ ដែលផ្តោតទៅលើតំបន់ជនបទដាច់ស្រយាល ដោយពង្រឹងទំនាក់ទំនងពីទីផ្សារទៅនឹងតំបន់ផលិត ហើយធានាឱ្យបានថា នារីត្រូវបានគេផ្តល់ជំនាញ និងពត៌មានចាំបាច់ដើម្បីមានលទ្ធភាពទទួលបាននូវឱកាសការងារថ្មីៗ ដែលជាការងារទទួលបានប្រាក់កំរៃ ឬ ជាការងារដែលដំណើរការដោយខ្លួនឯង ដោយស្របទៅតាមយុទ្ធសាស្ត្រនេះ ។

- *គាំទ្រការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងវិស័យក្រៅផ្លូវការ*

ឱកាសការងារនៅក្នុងវិស័យផ្លូវការ មានទំនោរងាកទៅរកប្រជាជនដែលមានការអប់រំខ្ពស់ ។ ដោយសារការអប់រំរបស់ក្មេងស្រី មានកំរិតទាបជាងក្មេងប្រុសខ្លាំង ដូច្នេះការផ្តល់អំណាចខាងសេដ្ឋកិច្ចដល់នារីភាគច្រើន គឺផ្តោតលើការបង្កើនឱកាសការងារក្រៅពីធ្វើស្រែចំការ ដែលភាគច្រើននៅក្នុងសហគ្រាសខ្នាតតូច និងវិស័យក្រៅផ្លូវការ ។ ការជួយនារីទាំងនេះអាចមានន័យថា ជាការជួយបង្កើនឱកាសរបស់ពួកគេក្នុងការទទួលបានកម្មវិធីបង្រៀនគិតលេខ ទទួលបានឥណទានសមរម្យ និងសេវាអភិវឌ្ឍន៍ជំនួញ ។

- *បង្កើតយុទ្ធសាស្ត្រសំរាប់បង្កើនអក្ខរភាព និងកំរិតជំនាញរបស់នារីនៅក្នុងកំលាំងពលកម្មបច្ចុប្បន្ន*

ដើម្បីសំរេចបាននូវសមភាពយេនឌ័រនៅក្នុងការងារ ក្នុងកំលាំងពលកម្មបច្ចុប្បន្ន ទាមទារឱ្យមានការដោះស្រាយភាពខុសគ្នាយ៉ាងខ្លាំងនៃអត្រាអក្ខរភាព និងកំរិតនៃការអប់រំរវាងនារី និងបុរស ។ ល្គឹកណាគ្មានវិធានការចំពោះមុខដើម្បីដោះស្រាយភាពខុសគ្នាទាំងនេះទេ នោះនារីភាគច្រើននឹងជួបការលំបាកក្នុងការប្រកួតប្រជែងដើម្បីទទួលបានការងារសមរម្យ ដែលការងារទាំងនេះ បានមកពីការបង្កើនវិនិយោគទុនបរទេស ឬការពង្រីកវិស័យពាណិជ្ជកម្ម ។ នារីនឹងបន្តស្ថិតក្នុងការងារកំរិតទាប ដែលទទួលបានប្រាក់កំរៃទាប និងនៅតែងាយរងគ្រោះដោយសារការកេងប្រវ័ញ្ច និងការរំលោភបំពាន ហើយក្តីសង្ឃឹមក្នុងការសំរេចនូវសមភាពយេនឌ័រក្នុងការងារ នឹងត្រូវបានបន្សល់ទុកដល់មនុស្សជំនាន់ក្រោយទៀត ។ កិច្ចអន្តរាគមន៍ គួរតែបញ្ចូលការធ្វើសមាហរណកម្មការបណ្តុះបណ្តាលអក្ខរកម្មជាមូលដ្ឋានទៅក្នុងយុទ្ធសាស្ត្របង្កើនឱកាសការងារ ហើយគាំទ្រកម្មវិធីអប់រំមនុស្សពេញវ័យនៅតាមសហគមន៍ ដើម្បីឆ្លើយតបទៅនឹងស្ថានភាព និងសេចក្តីត្រូវការរបស់មនុស្សពេញវ័យ ដែលខកខានមិនបានទទួលការអប់រំជាមូលដ្ឋាននៅក្នុងយុវវ័យរបស់ពួកគេ ។ គោលនយោបាយអប់រំ ស្តីពីកំលាំងពលកម្មអនាគត ពុំបានផ្តោតការយកចិត្តទុកដាក់លើតម្រូវការអប់រំ និងការបណ្តុះបណ្តាលរបស់នារី ដែលមានភាគច្រើននៅក្នុងកំលាំងពលកម្មបច្ចុប្បន្នឡើយ ។

- *ការដោះស្រាយតម្រូវការកិច្ចការពារសង្គមដល់កម្មការនីមកធ្វើការងារនៅទីក្រុង*

ទោះបីជាលក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរ កំពុងត្រូវបានពិនិត្យយ៉ាងម៉ត់ចត់ក៏ដោយ ក៏ការចាប់អារម្មណ៏ទៅលើគ្រោះថ្នាក់ដែលនារីវ័យក្មេងនៅក្រៅរោងចក្រកំពុងតែប្រឈមមុខ មានតិចតួចប៉ុណ្ណោះ ។ ដោយសារអនាគតរបស់រោងចក្រកាត់ដេរមិនទាន់មានភាពច្បាស់លាស់ ក្រោយឆ្នាំ២០០៤ ដូច្នេះត្រូវរៀបចំផែនការត្រៀមសំរាប់ផ្តល់ឱកាសការងារសមរម្យផ្សេងទៀត សំរាប់កម្មកររោងចក្រទាំងនោះ ។

- *បង្កើនការត្រួតពិនិត្យការអនុវត្តន៍ច្បាប់ការងារ*

ដោយសារការងារទទួលប្រាក់កំរៃមានការកើនឡើង ដូច្នេះចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់ដើម្បីធានាឱ្យបានថា មានការអនុវត្តន៏ស្របទៅនឹងច្បាប់ការងារ ។ ដើម្បីឱ្យស្របទៅនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃការងារទទួលបានប្រាក់បៀវត្សរ៏ក្នុងវិស័យកសិកម្ម ចាំបាច់ត្រូវបង្កើត និងពង្រឹងបទបញ្ញត្តិនានាស្តីអំពីការងារកសិកម្ម និងប្រាក់បៀវត្សរ៏ ដើម្បីទប់ស្កាត់កុំឱ្យមានការកេងប្រវ័ញ្ច លើក្រុមប្រជាជនដែលងាយរងគ្រោះ ដូចជានារី និងកុមារជាដើម ។

## ១០.២ នារីជនបទពុំមានលទ្ធភាពទទួលបាននូវធនធាន និង សេវាកម្មនានា ដែលអាចជួយពួកគេក្នុងការកាត់បន្ថយភាពក្រីក្រ និង ការធានាបាននូវសន្តិសុខស្បៀង

### *១០.២.១ ភាគច្រើននៃកសិករនៅកម្ពុជា គឺជានារីដែលពុំមានលទ្ធភាពទទួលបានធនធានដែលពួកគាត់ត្រូវការ*

ក្រៅពីការងារផ្លូវការ កំណើនប្រជាជនដែលមានការងារធ្វើ បានកើនឡើងចំនួន ៨០ភាគរយ នៅក្នុងអំឡុងឆ្នាំ ១៩៩៣ ដល់ ឆ្នាំ១៩៩៩ ដែលស្មើនឹង ១,២៨លាននាក់ ហើយក្នុងនោះ ៥៣ភាគរយជានារី នៅក្នុងវិស័យកសិកម្ម និងនេសាទ។ បើសិនជានិន្នាការនេះបន្តកើនឡើង ពេលនោះសេវាកម្មនានា (ប្រឹក្សាយោបល់ ទីផ្សារ និងបច្ចេកវិទ្យា) និងធនធានផ្សេងៗ (ឥណទាន ដីធ្លី ដើមទុន) សំរាប់កសិករដែលភាគច្រើនជានារី ចាំបាច់ត្រូវពង្រីក និងធ្វើឱ្យកាន់តែល្អប្រសើរជាងមុន។ ដោយសារតែហេតុនេះហើយ បានជានារីកាន់តែមានលទ្ធភាពតិចតួចជាងបុរស ក្នុងការទទួលបានសេវាផ្សព្វផ្សាយ ដីធ្លី ឬធនធានផ្សេងៗទៀត។ នារីហាក់ដូចជាមានការចូលរួមច្រើនជាងបុរស នៅក្នុងការងារកែច្នៃម្ហូបពីផលិតផលកសិកម្ម អាជីវកម្ម ចិញ្ចឹមសត្វ និងសកម្មភាពផ្សេងៗទៀតសំរាប់ការនាំចេញ។

### *១០.២.២ សេវាកម្មជាមូលដ្ឋានដូចជា ផ្លូវថ្នល់ និងការផ្គត់ផ្គង់ទឹក គឺជាអាទិភាពសំរាប់នារី និងបុរសក្រីក្រ*

ការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន មានផលប៉ះពាល់យ៉ាងខ្លាំងនៅក្នុងសង្គម។ ការទៅរែក/ដឹកទឹក មិនត្រឹមតែជាបន្ទុកលើពេលវេលារបស់នារីប៉ុណ្ណោះទេ ប៉ុន្តែការខ្វះខាតទឹកស្អាតសំរាប់ប្រើប្រាស់ ដែលធ្វើឱ្យមានបញ្ហាសុខភាព និងបណ្តាលឱ្យតួលេខនៃមរណៈភាពមាតា និងកុមារមានសភាពធ្ងន់ធ្ងរ។ ការផ្តល់ទឹកស្អាតសំរាប់ប្រើប្រាស់ធ្វើឱ្យក្មេងស្រី មានឱកាសបានទៅសាលារៀន ហើយផ្លូវថ្នល់ល្អ នឹងជួយបង្កើនលទ្ធភាពក្នុងការធ្វើដំណើរទៅសាលារៀន និងមជ្ឈមណ្ឌលសុខភាព។

### *១០.២.៣ អនុសាសន៍*

- *ចាំបាច់ត្រូវបង្កើតវិធីថ្មីៗ ក្នុងការផ្តល់សេវាកម្មការផ្សព្វផ្សាយ និងពត៌មានកសិកម្មដល់នារី*

សេវាផ្សព្វផ្សាយកសិកម្ម បានផ្តល់ដល់កសិករតែមួយចំនួនតូច ក្នុងចំណោមកសិករជាច្រើនដែលត្រូវការសេវាទាំងនោះ ជាពិសេសគឺនារី។ ចាំបាច់ត្រូវស្វែងរកនូវវិធីថ្មីៗដើម្បីធ្វើយ៉ាងណា ផ្តល់សេវាកម្ម និងពតិមានឱ្យបានដល់នារីដែលជាក្រុមគោលដៅ។ ឧទាហរណ៍ការបញ្ចូលគ្នារវាងសេវាផ្តល់ប្រឹក្សាអំពីកសិកម្ម ជាមួយនឹងសេវាផ្សេងៗទៀត ដូចជាការថែទាំសុខភាព ឬការអប់រំនៅតាមទីផ្សារ ឬកន្លែងដ៏ទៃទៀត ដែលនារីជួបប្រជុំគ្នា និងធ្វើការទំនាក់ទំនងនៅក្នុងសង្គម ហើយផ្សព្វផ្សាយនៅតាមវិស័យឯកជន ឬស្វែងរកវិធីផ្សេងៗទៀត ដើម្បីចែកចាយសេវាឱ្យបានដល់នារីជាជាងការសង្ឃឹមថា នារីអាចមកដល់អ្នកផ្តល់សេវាទាំងនោះបាន។

ការបណ្តុះបណ្តាលអំពីជំនាញធ្វើអាជីវកម្ម និងការផ្តល់សេវាផ្សព្វផ្សាយ ការអភិវឌ្ឍន៍ បច្ចេកវិទ្យា និងពត៌មានទីផ្សារ ចាំបាច់ត្រូវផ្តោតគោលដៅទៅលើនារី។

- ***នារីត្រូវការលទ្ធភាពដែលមានការធានា និងមានលក្ខណៈល្អប្រសើរ ក្នុងការទទួលបានដីធ្លី និងធនធានធម្មជាតិ***

គោលការណ៍នៅក្នុងច្បាប់ភូមិបាលថ្មីចែងថា នារីត្រូវចុះហត្ថលេខារួមគ្នាជាមួយប្តី នៅក្នុងកម្មសិទ្ធិដីធ្លី ប៉ុន្តែច្បាប់នេះ អាចពុំទាន់គ្រប់គ្រាន់នៅឡើយក្នុងការធានា និងការពារសិទ្ធិកាន់កាប់ដីធ្លីរបស់នារី។ ចាំបាច់ត្រូវខិតខំធ្វើយ៉ាងណាដើម្បីធានាថា កម្មសិទ្ធិដីធ្លីមានឈ្មោះប្តី និងប្រពន្ធ ហើយស្វែងយល់ និងដោះស្រាយចំពោះតម្រូវការ និងឧបសគ្គនានារបស់នារីដែលជាមេគ្រួសារ។ ចាំបាច់ត្រូវបង្កើនការយល់ដឹងអំពីសិទ្ធិកាន់កាប់ដីធ្លីរបស់នារី នៅក្នុងចំណោមបុរស និងនារីជាម្ចាស់កម្មសិទ្ធិដីមន្ត្រីសុរិយោដី ប្រធានឃុំសង្កាត់ និងអាជ្ញាធរជាន់ខ្ពស់ ដើម្បីធានាឱ្យបានថាសិទ្ធិកាន់កាប់ដីធ្លីរបស់នារីត្រូវបានគេគោរព។

- ***ចាំបាច់ត្រូវបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលបានធ្វើផែនការនៅថ្នាក់មូលដ្ឋាន ដើម្បីទទួលស្គាល់ និងដោះស្រាយតម្រូវការរបស់បុរស និងនារី***

ត្រូវបញ្ចូលនារី ទៅក្នុងយន្តការដែលបានបង្កើតឡើង ដើម្បីឱ្យនារីបានចូលរួមក្នុងគ្រប់ដំណើរការកំណត់អំពីតម្រូវការនៅតាមមូលដ្ឋាន និងការធ្វើផែនការអភិវឌ្ឍន៍។ នេះជាវិធីដែលប្រកបដោយប្រសិទ្ធិភាពក្នុងការធានាថាតម្រូវការរបស់នារី ត្រូវបានដោះស្រាយ។ ចាំបាច់ត្រូវបន្តគាំទ្រយន្តការនេះ ហើយជំរុញយ៉ាងខ្លាំងក្លាឱ្យនារីបានចូលរួមយ៉ាងសកម្មនៅក្នុងយន្តការនេះ។

## ១០.៣ វិសមភាពយេនឌ័រក្នុងលទ្ធភាពទទួលបានសេវាសុខភាព និង អប់រំ គឺមានសភាពធ្ងន់ធ្ងរបំផុត ក្នុងចំណោមប្រជាជនក្រីក្រ និង នៅតាមតំបន់ជនបទ

### ១០.៣.១ វិសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ មានសភាពធ្ងន់ធ្ងរបំផុតនៅតាមតំបន់ជនបទ និងក្នុងចំណោមប្រជាជនក្រីក្រនៅជនបទ

នៅក្នុងកំរិតបឋមសិក្សាពុំមានការខុសគ្នាប៉ុន្មានទេ រវាងអត្រាចុះឈ្មោះចូលរៀននៅតាមទីក្រុងបទ/ទីប្រជុំជន និងនៅតាមតំបន់ជនបទ ហើយការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅក្នុងបញ្ចភាគក្រីក្របំផុត កើនឡើងលឿនជាងគេបង្អស់ ក្នុងចំណោមបញ្ចភាគផ្សេងៗទៀត។ ប៉ុន្តែការបោះបង់ចោលការសិក្សារបស់ក្មេងស្រី នៅក្នុងកំរិតនេះ មានអត្រាខ្ពស់។ ភាពខុសគ្នារវាងការចុះឈ្មោះចូលរៀនរបស់ក្មេងប្រុស និងក្មេងស្រីនៅថ្នាក់មធ្យមសិក្សាកើនឡើងយ៉ាងខ្លាំង ជាពិសេសនៅតាមតំបន់ជនបទ។ ចាំបាច់ត្រូវបញ្ជូនក្មេងស្រីជនបទ ឱ្យបន្តការសិក្សានៅថ្នាក់មធ្យមសិក្សា ដើម្បីឱ្យពួកគេមានលទ្ធភាពអាចប្រកួតប្រជែងនឹងទីផ្សារការងារ និងដើម្បីបង្កើនជីវភាពរស់នៅរបស់មនុស្សជំនាន់ក្រោយឱ្យបានល្អប្រសើរ។ នារីមួយចំនួនធំដែលមានអាយុលើសពី ៤០ឆ្នាំ មិនចេះអាន ឬសរសេរអក្សរ ហើយអាចមានចំនួនច្រើនជាងនេះ ដែលជាអនក្ខរជន។

## ១០.៣.២ សេវាសុខភាពបច្ចុប្បន្នពុំបានទៅដល់តំបន់ជនបទ ជាពិសេសទៅដល់នារី និងក្មេងស្រីនៅជនបទ

អត្រាមរណៈភាពមាតានៅប្រទេសកម្ពុជា មានចំនួន ៤៣៧នាក់ ក្នុងចំណោមនារីចំនួន ១០០.០០០ ដែលបានសំរាលកូន ហើយកូននៅមានជីវិត គឺជាអត្រាដែលខ្ពស់ជាងគេបំផុតនៅក្នុងតំបន់ ហើយដំណើរការធ្វើឱ្យប្រសើរឡើងនៅមានភាពយឺតយ៉ាវ ។ ទោះបីជាអត្រាប្រើប្រាស់ និងការចំណាយលើការថែទាំសុខភាពមានលក្ខណៈដូចគ្នាសំរាប់បុរស និងនារីប៉ុន្តែសំរាប់សុខភាពបន្តពូជ តម្រូវការរបស់នារីមានច្រើនជាងបុរស ហើយការប្រើប្រាស់គួរតែមានកំរិតខ្ពស់ជាង ។ ជាញឹកញាប់នារីតែងតែនិយាយថា ការចំណាយ និងពេលវេលាសំរាប់ធ្វើដំណើរ គឺជាមូលហេតុមួយដែលធ្វើឱ្យនារីពុំមានលទ្ធភាពទទួលបាននូវការថែទាំសុខភាព ។ ដូច្នេះសេវាទាំងនេះ ចាំបាច់ត្រូវនាំឱ្យបានទៅដល់កន្លែងដែលនារីរស់នៅ ។ សេវាទាំងនេះ រួមមានមធ្យោបាយពន្យាកំណើត ដែលសេវានេះ ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់នារីមួយចំនួនធំនៅឡើយ ហើយបើសិនជាគ្មានសេវានេះទេ អត្រាប្រជាជននឹងកើនឡើង ។

## ១០.៣.៣ អនុសាសន៍

- *ជំរុញក្មេងស្រីឱ្យបានទៅរៀននៅបឋមសិក្សា បង្កើនការចុះឈ្មោះចូលរៀនរបស់ក្មេងស្រី នៅមធ្យមសិក្សា និងផ្តល់ការអប់រំក្រៅប្រពន្ធ័*

សារៈសំខាន់នៃការអប់រំរបស់ក្មេងស្រី ពុំអាចមើលរំលងបានឡើយ ។ ការអប់រំបើកផ្លូវក្នុងការធ្វើឱ្យការប្រកបរបរចិញ្ចឹមជីវិតសំរាប់នារី និងមនុស្សជំនាន់ក្រោយ មានលទ្ធភាពល្អប្រសើរឡើង ។ ការវិនិយោគក្នុងការបញ្ជូនក្មេងស្រីទៅសាលារៀន និងជំរុញក្មេងស្រីឱ្យនៅរៀនជាប់លាប់ គឺជាការវិនិយោគដ៏មានតំលៃ ។ គំរោងប្រពន្ធ័សាលាដើរតួយ៉ាងសំខាន់នៅក្នុងការសំរបសំរួលលទ្ធភាពប្រកបដោយសមធមិសំរាប់ក្មេងស្រី និងក្មេងប្រុស ។ បង្គន់អនាម័យការធ្វើដំណើរមានសុវត្ថិភាព ក្នុងពេលទៅសាលារៀន និងពេលត្រឡប់មកផ្ទះវិញ មានគ្រូបង្រៀនជានារី គឺត្រូវការចាំបាច់ដើម្បីបង្កើនការចុះឈ្មោះ ការចូលរៀនរបស់ក្មេងស្រីឱ្យមានចំនួនច្រើន ។ ការផ្តល់អន្តេវាសិកដ្ឋាន បង្គន់អនាម័យឬអាហារូបករណ៍នៅក្នុងប្រពន្ធ័អប់រំក្នុងប្រពន្ធ័ គឺជាការគ្រប់គ្រាន់ដើម្បីឱ្យមានការផ្លាស់ប្តូរ ។ ការពិនិត្យលើការចំណាយហិរញ្ញវត្ថុក្នុងវិស័យសាធារណៈ ឆ្នាំ២០០៣ បានសំណូមពរឱ្យមានការបែងចែកថវិកាជាក់លាក់ សំរាប់ជួសជុល និងសាងសង់បង្គន់អនាម័យនៅក្នុងសាលារៀនមធ្យមសិក្សាបឋមភូមិបច្ចុប្បន្ន ។

ការកែលំអ និងភាពបត់បែនក្នុងការផ្តល់ធនធាន គឺត្រូវការចាំបាច់មិនត្រឹមតែសំរាប់ការអប់រំក្នុងប្រពន្ធ័ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការចាំបាច់នូវការបែងចែកធនធានបន្ថែម សំរាប់ដំណើរការអន្តរាគមន៍សំរាប់នារី និងក្មេងស្រីដែលបោះបង់ចោលការសិក្សា ជាពិសេសការអប់រំក្រៅប្រពន្ធ័ (Bredenburg et al ឆ្នាំ២០០៣) ។ ចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះការអប់រំក្រៅប្រពន្ធ័ សំរាប់នារីវ័យចំណាស់ដែលជាអនក្ខរជន ។

ចាំបាច់ត្រូវបង្កើនការសំរបសំរួល និងទំនាក់ទំនងរវាងកិច្ចអន្តរាគមន៍នានាដើម្បីសមធមិយេនឌ័រ ។ ឧទាហរណ៍មានសំណូមពរឱ្យមានការសំរបសំរួលរវាងកិច្ចអន្តរាគន៍នានា ដែលផ្តោតលើការផ្លាស់ប្តូរឥរិយាបថ ( ឧ.ការបណ្តុះបណ្តាលបង្កើនចំណេះដឹងយេនឌ័រ) និងការអនុវត្តន៍ដ៏រឹងមាំនូវគោលការណ៍សមធមិយេនឌ័រ ( អាហារូបករណ៍ បំណិនជីវិត ។ល ។)

- *សេវាសុខភាពត្រូវមានតំលៃសមរម្យទៅនឹងលទ្ធភាពរបស់នារីក្រីក្រ*

ការដោះស្រាយចំពោះតំលៃចំណាយ ដែលជាឧបសគ្គរារាំងក្នុងការទទួលបានសេវាថែទាំសុខភាពចាំបាច់ គឺជាបញ្ហាសំខាន់ ។ កម្មវិធីមូលនិធិសមធមិរបស់ក្រសួងសុខាភិបាល ដែលបានសាកល្បងក្នុងស្រុកមួយចំនួន គួរតែពង្រីកបន្ថែមដើម្បីផ្ដល់ការថែទាំសុខភាពជាបន្ទាន់ ចំពោះបញ្ហារោគស្ត្រី និងជំងឺដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិត ។ កម្មវិធីមូលនិធិសមធមិនេះ គឺជាកម្មវិធីថ្មី (ចាប់ពីខែកញ្ញា ឆ្នាំ២០០០) ប៉ុន្តែការអនុវត្តន៍កម្មវិធីនេះកន្លងមកទទួលបានលទ្ធផលជាវិជ្ជមាន ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានប្រជាជនក្រីក្រមួយចំនួនធំ នៅតែពន្យាពេលក្នុងការមកទទួលយកការថែទាំសុខភាពនៅមន្ទីរពេទ្យ ដោយសារការចំណាយដោយប្រយោលផ្សេងៗទៀត មានកំរិតខ្ពស់ (ដូចជាការខាតបង់ពេលវេលាសំរាប់ធ្វើការនៅពេលមកស្នាក់នៅក្នុងមន្ទីរពេទ្យ និងខ្វះលុយសំរាប់ការធ្វើដំណើរមកមន្ទីរពេទ្យ) ។ ចាំបាច់ត្រូវពិនិត្យដោយប្រុងប្រយត្ន័លើការចំណាយមូលនិធិទាំងនេះ ដើម្បីធានាឱ្យមានសមភាព និងធានាឱ្យបានថា នារីអាចទទួលផលពីមូលនិធិនេះ ។ ឧទាហរណ៍មូលនិធិសមធមិត្រូវតែដោះស្រាយរាល់ឧបសគ្គក្នុងការទទួលបានសេវាទាំងនេះ ដូចជា ការចំណាយលើការធ្វើដំណើរទៅមជ្ឈមណ្ឌលសុខភាព និងការពុំព្រមផ្ដល់លទ្ធភាពឱ្យនារីក្រីក្រ ក្នុងការទទួលបានសេវានេះ ។

- *ត្រូវផ្ដល់អាទិភាពដល់ការផ្សព្វផ្សាយ ដែលប្រើវិធីសាស្ត្រសមស្របតាមវប្បធម៌*

ការបង្កើនសកម្មភាពផ្សព្វផ្សាយ និងការអប់រំសុខភាពសមស្របតាមវប្បធមិ ជាពិសេសនៅតំបន់ជនបទ នឹងអាចបានទៅដល់នារីកាន់តែច្រើនឡើង ។ យុទ្ធវិធីមានដូចជា បណ្ដាញការងារតាមក្រុម (បណ្ដាញនារីស្ម័គ្រចិត្ត) និងការចែកចាយតាមសហគមន៍នូវពត៌មាន ស្ដីពីបញ្ហាសុខភាពដល់នារី ត្រូវបានដំណើរការសាកល្បងដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួននៅក្នុងតំបន់ជ្រើសរើស ។ យុទ្ធវិធីទាំងនេះ អាចយកទៅអនុវត្តតាម និងបង្កើនឱ្យបានច្រើន ។ យុទ្ធសាស្ត្រផ្សព្វផ្សាយទាំងនេះ ចាំបាច់ត្រូវធ្វើការពិនិត្យ និងគិតគូរអំពីបញ្ហាវប្បធមិ និងការនិយមរបស់នារី ក្នុងពេលមានគភ៌ និងពេលសំរាលកូន ។ ចាំបាច់ត្រូវបង្កើនធនធានសំរាប់មជ្ឈមណ្ឌលសុខភាពជាមូលដ្ឋាន និងការផ្សព្វផ្សាយនៅតាមតំបន់ភូមិសាស្ត្រដែលពុំទាន់មានសេវាផ្សព្វផ្សាយ ដើម្បីពង្រឹងសេវាចែកចាយមធ្យោបាយពន្យាកំណើត និងមាតុភាពមានសុវត្ថិភាព ។ សេវាផ្សព្វផ្សាយរួមមាន ការចាក់ថ្នាំបង្ការរោគ ការថែទាំសុខភាពមុនពេលសំរាលកូន មធ្យោបាយពន្យាកំណើត ការត្រួតពិនិត្យ និងការពិគ្រោះយោបល់អំពីអាហាររូបត្ថម្ភ ព្រមទាំងសេវាសុខភាពផ្សេងៗទៀត ។

- *ចាំបាច់ត្រូវសាកល្បងយុទ្ធវិធីថ្មីៗ ដើម្បីបង្កើនចំនួនគ្រូពេទ្យឆ្មបនៅតាមតំបន់ជនបទ*

កង្វះគ្រូពេទ្យឆ្មបដែលមានជំនាញ នៅតាមតំបន់មួយចំនួននៅក្នុងប្រទេស នឹងនៅតែជាបញ្ហាចំពោះមុខក្នុងការកាត់បន្ថយអត្រាមរណៈភាពមាតា ។ ការផ្ដល់ការលើកទឹកចិត្តដល់គ្រូពេទ្យឆ្មបថ្មី ឬការឧបត្ថម្ភសមរម្យដើម្បីធ្វើឱ្យប៉ុស្តិ៍ពេទ្យឆ្មបនេះ ទទួលបានការចាប់អារម្មណ៍ ដែលជាកត្តាចាំបាច់បំផុត ។ មធ្យោបាយក្នុងការផ្ដល់វិធានការសន្តិសុខក៏ចាំបាច់ត្រូវអនុវត្តផងដែរ ។ លើសពីនេះ ក៏នៅមានមធ្យោបាយមួយចំនួនក្នុងការបណ្ដុះបណ្ដាលដល់ពេទ្យឆ្មបថ្មី ហើយចាំបាច់ត្រូវពិនិត្យមើលឡើងវិញ លើយុទ្ធសាស្ត្របណ្ដុះបណ្ដាលសំរាប់ការបណ្ដុះបណ្ដាលពេទ្យឆ្មប ។

## ១០.៤ ប្រជាជនដែលងាយរងគ្រោះទទួលបានការគាំទ្រតិចតួច ហើយពុំដឹងថាត្រូវទៅរកជំនួយនៅកន្លែងណា

### ១០.៤.១ ការចម្លងមេរោគអេដស៍/ជំងឺអេដស៍កំពុងកាត់បន្ថយ ប៉ុន្តែការចម្លងកំពុងតែឃាននៅរកក្រុមប្រជាជនផ្សេងទៀតនៅក្នុងសង្គម

ចំនួននារី និងកុមារីកម្ពុជាកាន់តែច្រើន កំពុងប្រឈមមុខនឹងការឆ្លងជំងឺអេដស៍។ នៅក្នុងប្រទេសដែលលទ្ធភាពទទួលបានពតិមាន ការថែទាំ និងការគាំទ្រ និងការព្យាបាល មានកំរិតទាប សិរិយាបថផ្លូវភេទរបស់បុរសដែលប្រថុយនឹងគ្រោះថ្នាក់ មានកំរិតខ្ពស់ ហើយបញ្ហាយេនឌ័រនៅក្នុងវប្បធម៌របស់ប្រទេសកម្ពុជា ធ្វើឱ្យនារីមានការលំបាកក្នុងការចរចារជាមួយបុរសឱ្យប្រើស្រោមអនាម័យ កត្តាទាំងនេះ ធ្វើឱ្យនារីជាអ្នកទទួលរងគ្រោះដោយសារការឆ្លងជំងឺអេដស៍។

រូបភាពនៃការចម្លងជំងឺអេដស៍កំពុងតែផ្លាស់ប្តូរៈ ប្រេវ៉ាឡង់បង្ហាញឱ្យឃើញនូវការកើនឡើងនៅក្នុងគ្រប់ក្រុមទាំងអស់ ប៉ុន្តែនៅពេលជាមួយគ្នានេះផងដែរ នារីដែលរៀបការរួច និងនារីដែលមានទំនាក់ទំនងផ្លូវភេទយូរអង្វែងនៅតែជាក្រុមដែលរងគ្រោះបំផុត និងមានការកើនឡើងយ៉ាងរហ័ស។ ការចម្លងពីម្តាយទៅទារក ពីប្តីទៅភរិយា គឺកំពុងតែកើនឡើងយ៉ាងខ្លាំង។ វិធីសាស្ត្រសំរាប់ទប់ស្កាត់ការរីករាលដាលនៅក្នុងចំណោមក្រុមរងគ្រោះទាំងនេះ មានកំរិត ប៉ុន្តែជាតម្រូវចាំបាច់ជាបន្ទាន់។

ប្រជាជនកម្ពុជាភាគច្រើន មិនមានលទ្ធភាពទទួលថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ទេ (ART-ថ្នាំពន្យារការស្លាប់) ឬសូម្បីតែការព្យាបាលជំងឺឱកាសនិយមឱ្យបានទៀងទាត់ ក៏គ្មានដែរ ដូចជាជំងឺរលាកសួត ជំងឺរាគរូស និងជំងឺ Toxoplasmosis។ ការមើលថែទាំសមាជិកគ្រួសារ ដែលទទួលរងគ្រោះដោយសារជំងឺទាំងអស់នេះ គឺជាបន្ទុកយ៉ាងធ្ងន់ធ្ងរលើពេលវេលា និងធនធានរបស់នារី ដែលធ្វើឱ្យគ្រួសារកាន់តែធ្លាក់ក្នុងសភាពក្រីក្រឡើង។ នារីទទួលបានឱកាសតិចតួចក្នុងការទទួលបានការព្យាបាល ការតាមដាន និងការពិគ្រោះយោបល់។

ការរៀបចំស្ថាប័នបច្ចុប្បន្ន អាចនឹងគ្មានប្រសិទ្ធិភាពក្នុងការទប់ស្កាត់ ពីព្រោះថាការរីករាលដាលនេះ បានប្តូរពីស្ត្រីរកស៊ីផ្លូវភេទទៅក្នុងក្រុមផ្សេងៗទៀតក្នុងសង្គម ព្រមទាំងគ្មានប្រសិទ្ធិភាពក្នុងការផ្សព្វផ្សាយ ឱ្យបានគ្រប់គ្រាន់អំពីការថែទាំ។

### ១០.៤.២ អំពើហិង្សាលើនារី កើតឡើងជារឿយៗ និងច្រើនរូបភាព ហើយសេវាសំរាប់ជួយជនរងគ្រោះមានតិចតួចប៉ុណ្ណោះ

នារី និងកុមារីកម្ពុជា ជាអ្នករងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការបំពារបំពានផ្លូវភេទ និងការជួញដូរពលកម្ម ឬដើម្បីបំរើការងារផ្លូវភេទ។ ក្របខណ្ឌផ្លូវច្បាប់ទន់ខ្សោយ និងគ្មានប្រសិទ្ធិភាពបណ្តាលឱ្យមានវប្បធម៌មិនយកទោស ហើយសេវាកម្ម និងការគាំទ្រមិនគ្រប់គ្រាន់ ធ្វើឱ្យជនរងគ្រោះមានជំរើសតិចតួចប៉ុណ្ណោះ។

វប្បធម៌របស់កម្ពុជា មិនបានដាក់ទោសចំពោះអំពើហិង្សាក្នុងផ្ទះទេ ដូចជាអំពើហិង្សាដែលឪពុកម្តាយធ្វើទៅលើកូន ឬប្តីធ្វើទៅលើភរិយា ជាដើម ។ នារីដែលរៀបការរួចចំនួន ២៣ភាគរយ មានអាយុលើសពី១៥ឆ្នាំ ដែលបានសំភាសនៅក្នុងអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០០ បានរាយការណ៍ថា ពួកគេទទួលការបំពានផ្នែករាងកាយនៅក្នុងផ្ទះ ។ នារីដែលទទួលរងការបំពារបំពាន មានជំរើសតិចតួច ។ បើសិនជានារីទាំងនោះ ពុំមានកម្មសិទ្ធិលើដីធ្លី ឬសម្បត្តិផ្សេងៗទៀតទេនោះ ពួកគេនឹងទទួលរងគ្រោះដោយសារបាត់បង់ការគាំទ្រផ្នែកហិរញ្ញវត្ថុសំរាប់ខ្លួនឯង និងសំរាប់កូន បើសិនជាពួកគេចាកចេញពីប្តីរបស់ពួកគេ ។ បើសិនជាប្តីត្រូវជាប់គុក ភរិយានឹងត្រូវបាត់បង់ចំណូលដែលប្តីត្រូវរកបានក្នុងរយៈពេលជាប់គុក ហើយពុំដឹងថាប្តីអាចដូរឥរិយាបថ ឬអត់ នៅពេលត្រូវដោះលែងពីគុកវិញ ។ សេចក្តីព្រាងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ត្រូវបានពិនិត្យឡើងវិញនៅដើមឆ្នាំ២០០៤ និងពុំទាន់បានឆ្លងរដ្ឋសភាចប់នៅឡើយទេ ។

ជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈ មានការលំបាកក្នុងការរាយការណ៍ ឬស្វែងរកជំនួយៈ ការស្តីបន្ទោសពីសង្គម និងការអាម៉ាស់ក្នុងគ្រួសារ ដោយសារការបាត់បង់ព្រហ្មចារីយ៍ បានបន្តនូវទស្សនៈដែលថា ជនរងគ្រោះដោយសារការរំលោភ គឺជានារីដែលគ្មានតំលៃទៀតហើយ ។ ជនរងគ្រោះដោយសារការរំលោភជាច្រើននាក់ ទទួលយកនូវទស្សនៈអវិជ្ជមានដែលអ្នកដទៃមានចំពោះខ្លួន ហើយបញ្ចប់ជីវិតរបស់ពួកគេនៅក្នុងរបររកស៊ីផ្លូវភេទ ។ នៅកម្ពុជា ទោះបីជាអំពើរំលោភ គឺជាបទឧក្រិដ្ឋ ប៉ុន្តែជនល្មើសកំរនឹងត្រូវគេផ្តន្ទាទោសឡើយ ។ គ្រួសារភាគច្រើនមិនចង់ទាក់ទងទៅអាជ្ញាធរក្នុងករណីរំលោភឡើយ ដោយសារមានភាពអាម៉ាស់ និងការឈឺចាប់នៅក្នុងសង្គមគ្រួសារភាគច្រើនតែងតែការពារកិត្តិយសរបស់គ្រួសារ និងដោះស្រាយនៅក្រៅតុលាការ ដោយព្រមទទួលយកការសងជំងឺចិត្ត ។

ការជួញដូរស្ត្រី និងកុមារនៅក្នុងប្រទេស និងនៅតាមព្រំដែនកាន់តែកើនឡើងៈ កម្ពុជាជាប្រទេសបញ្ជូន ទទួល និងឆ្លងកាត់នៃការជួញដូរ ។ លក្ខខណ្ឌនៃភាពក្រីក្រ ហេដ្ឋារចនាសម្ពន្ធ័ផ្នែកច្បាប់មិនទាន់មានការអភិវឌ្ឍន៍ និងការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ ធ្វើឱ្យមានការកើនឡើងនៃអាជីវកម្មផ្លូវភេទ ។ នៅកម្ពុជា ពេស្យាកម្ម ជាអំពើមិនខុសច្បាប់ទេ ប៉ុន្តែការបង្កើត ឬការទាញយកប្រាក់ចំណេញពី ពេស្យាកម្ម គឺជាអំពើខុសច្បាប់ ។ ជាអកុសល អ្នកដែលរំលោភច្បាប់ ពុំមែនជាអ្នកដែលទទួលទោសឡើយ ។

## ១០.៤.៣ អនុសាសន៍

- ***ផ្តល់ការថែទាំ និងការគាំទ្រដល់ក្រុមងាយរងគ្រោះ រួមទាំងក្រុមដែលរងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍***

កម្មវិធីថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានស្តីពីយេនឌ័រ បរិស្ថាន កសិកម្ម និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័សហគមន៍គួរតែបញ្ចូលសកម្មភាពទប់ស្កាត់ជំងឺអេដស៍ ។ គួរតែបង្កើនការប្រើប្រាស់ស្រោមអនាម័យ ជាមធ្យោបាយក្នុងការពន្យាកំណើត ។ គោលនយោបាយជាតិ ដែលផ្តោតលើការបង្កើនការប្រើប្រាស់ស្រោមអនាម័យ សំរាប់ការពន្យាកំណើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ និងដើម្បីរក្សាទំនាក់ទំនងគ្រួសាររយៈពេលយូរអង្វែង នឹងអាចមានប្រយោជន៍ជាងគ្រាន់តែសំរាប់ការពារមេរោគអេដស៍ ។ វិធីសាស្ត្រនេះ នឹងអាចធ្វើឱ្យនារីហ៊ានសុំឱ្យស្វាមីរបស់នារី ប្រើស្រោមអនាម័យ

ដោយមិនចាំបាច់និយាយដោយផ្ទាល់អំពីបញ្ហាមិនស្មោះត្រង់នោះឡើយ ។ ចាំបាច់ត្រូវអនុវត្តយុទ្ធសាស្ត្រថ្មីៗ ដោយមានគោលដៅទៅលើយុវវ័យ ។ វិធីសាស្ត្រទប់ស្កាត់សំរាប់នារី គឺស្រោមអនាម័យ សំរាប់នារីក៏ចាំបាច់ត្រូវយកមកអនុវត្តនៅកម្ពុជាផងដែរ ។

ការអនុវត្តន៍យុទ្ធសាស្ត្រថែទាំជាប្រចាំ សំរាប់ប្រជាជនដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ទាមទារឱ្យសេវាសុខភាពនៅតាមស្រុកដែលមានដៃគូសហការជាមួយអ្នកពាក់ពន្ធ័ផ្សេងៗទៀត ដែលផ្តល់ការថែទាំចំពោះបញ្ហាមេរោគអេដស៍/ជំងឺអេដស៍ ពង្រីងការចែកចាយសេវារបស់ខ្លួន ។ គន្លឹះសំខាន់មួយនៃយុទ្ធសាស្ត្រនេះ គឺការលើកទឹកចិត្តឱ្យមានការធ្វើតេស្តឈាម ដើម្បីជួយបង្កើនឱកាសសំរាប់ជីវិតដែលមានសុខភាពល្អ និងមានគុណភាព។ ការពង្រីកកម្មវិធីទប់ស្កាត់ការចម្លងពីម្តាយទៅកូន គួរតែបញ្ចូលការបណ្តុះបណ្តាល និងការបង្កើនការពិគ្រោះយោបល់ដោយស្ម័គ្រចិត្ត ដោយសំងាត់ និងយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ និងបង្កើនសេវាធ្វើតេស្តឈាមសំរាប់នារីមានគភ៌ ។ ការបណ្តុះបណ្តាលស្តីពីការថែទាំ និងការគាំទ្រនៅក្នុងសហគមន៍ ចំពោះប្រជាជនដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ក៏ត្រូវការចាំបាច់ផងដែរ ឧទាហរណ៍ដូចជា ការកសាងសមត្ថភាពស្តីពីការផ្តល់ថ្នាំពន្យាជីវិត ។ កម្មវិធីនានា ដូចជាកម្មវិធីថែទាំតាមផ្ទះ អាចមានប្រយោជន៍ក្នុងការកាត់បន្ថយបន្ទុកនៃការថែទាំដោយផ្ទាល់ និងដើរតួយ៉ាងសំខាន់ក្នុងការបង្កើតទំនាក់ទំនងសំរាប់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ ជាមួយនឹងសេវាផ្សេងៗទៀត ។

- *បង្កើតយុទ្ធវិធីដែលមានប្រពន្ធ័ត្រឹមត្រូវ ដើម្បីជួយជនរងគ្រោះដោយសារអំពើហឹង្សា*

គួរតែរៀបចំបង្កើតផែនការថ្នាក់ជាតិរួម និងតាមវិស័យដើម្បីទប់ស្កាត់អំពើហឹង្សាលើនារី និងអនុវត្តដោយមានការចូលរួមពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។ ផែនការគួរតែរួមបញ្ចូលនូវឧបករណ៍ ដើម្បីត្រួតពិនិត្យការអនុវត្តន៍ និងកំណត់ពេលវេលាសំរាប់ផែនការសកម្មភាពនេះ ។ ចាំបាច់ត្រូវប្រមូលទិន្នន័យពីមជ្ឈដ្ឋានផ្សេងៗ ដូចជានៅតាមមន្ទីរពេទ្យ ស្ថានីយ៏នគរបាល មជ្ឈមណ្ឌលសហគមន៍ និងកន្លែងផ្សេងៗទៀត ដែលអាជ្ញាធរធ្វើការទំនាក់ទំនងជាមួយជនរងគ្រោះ និងជនល្មើស ។ ប្រពន្ធ័សុខាភិបាលជាតិ គួរតែបញ្ចូលការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដើម្បីឱ្យបុគ្គលិកអាចផ្តល់ការថែទាំដល់ជនរងគ្រោះ ។ លើសពីនេះទៀត ត្រូវផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដើម្បីធានាឱ្យបានថា សេវាផ្នែកសុខាភិបាល តុលាការ នគរបាល និងសេវាសង្គម អាចជួយជនរងគ្រោះឱ្យបានជាសះស្បើយ មិនធ្វើឱ្យជនរងគ្រោះទទួលការរងគ្រោះបន្តទៀត និងដាក់ទោសជនល្មើសឱ្យរវៀងចាលលែងហ៊ានប្រព្រឹត្តិអំពើល្មើសនេះទៀត ។

នៅថ្នាក់ឃុំសង្កាត់ ចាំបាច់ត្រូវបង្កើនការយល់ដឹងថា អំពើហឹង្សាលើនារី គឺជាឥរិយាបថខុសឆ្គង និងជាបទឧក្រិដ្ឋ ។ ចាំបាច់ត្រូវយកធ្វើជាគំរូ និងពង្រីកគំរោងសាកល្បងក្នុងការផ្តល់ការថែទាំ និងគាំទ្រជនរងគ្រោះដោយសារអំពើហឹង្សា ហើយធ្វើការជាមួយបុរសដែលប្រឆាំងនឹងអំពើហឹង្សាលើនារី ។ បុរសមានតួនាទីសំខាន់នៅក្នុងការរៀបចំបង្កើត និងអនុវត្តផែនការ និងផែនការថ្នាក់មូលដ្ឋាន ស្តីពីការឥស៊ូមតិ និងការទប់ស្កាត់ក្នុងគោលបំណងលុបបំបាត់អំពើហឹង្សាលើនារី ។

## ១០.៥ ស្ថាប័នសង្គម ផ្លូវច្បាប់ និង នយោបាយ បន្តឱ្យមានការរើសអើងយេនឌ័រ និងភាពងាយរងគ្រោះ

### ១០.៥.១ បទដ្ឋានសង្គម និងឥរិយាបថដែលពាក់ព័ន្ធនឹងយេនឌ័រ អាចមានឥទ្ធិពលអវិជ្ជមានលើបុរស និងនារី

បទដ្ឋានសង្គម ឥរិយាបថ និងកត្តាវប្បធម៌ ជំរុញឱ្យមានការឆ្លងមេរោគអេដស៍ អំពើហិង្សាយេនឌ័រ (ការជួញដូរមនុស្ស អំពើហឹង្សាក្នុងគ្រួសារ ការរំលោភ និងអាជីវកម្មផ្លូវភេទ) ហើយក៏ជំរុញឱ្យបុរសប្រឈមមុខនឹងភាពងាយរងគ្រោះផងដែរ។ តួនាទី និងវិសមភាពនៅក្នុងសង្គមនៅតែបន្តកើតមាន ទោះបីជានៅក្នុងសង្គមដែលមានបរិស្ថានសេដ្ឋកិច្ចរីកចំរើនក៏ដោយ។ ការផ្លាស់ប្តូរជាវិជ្ជមាន គឺពាក់ព័ន្ធនិងវប្បធម៌នៅក្នុងសង្គម។ នៅក្នុងសង្គមណាមួយក៏ដោយនារី និងបុរសមានទស្សនៈខុសៗគ្នាអំពីបទដ្ឋាន និងឥរិយាបថ។ ការស្វែងរកតុល្យភាពរវាងទស្សនៈទាំងនេះ នឹងជួយលប់បំបាត់និន្នាការអវិជ្ជមាន។

វិសមភាពដែលបណ្តាលមកពីឥរិយាបថតាមទំនៀមទំលាប់ ចំពោះតួនាទីយេនឌ័រ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងការបែងចែកការងាររវាងនារី និងបុរស និងឋានៈតួនាទីរបស់ពួកគេនៅក្នុងឧស្សាហកម្មផ្សេងៗ។ តាមទំនៀមទំលាប់ប្រពៃណី ក្មេងប្រុសត្រូវបានគេជំរុញលើកទឹកចិត្តឱ្យទៅសាលារៀន ដូច្នេះក្មេងប្រុសអាចមានសមត្ថភាពទទួលបានតួនាទីខ្ពស់តាមបំណង នៅក្នុងស្ថាប័នរដ្ឋាភិបាល ដូចជាការគ្រប់គ្រងរបស់បុរសនៅក្នុងជួរមន្ត្រីរាជការ និងតួនាទីជាអ្នកធ្វើសេចក្តីសំរេច។ ការអប់រំរបស់ក្មេងស្រី ត្រូវបានគេមើលឃើញថា មិនសូវមានសារៈសំខាន់ឡើយនៅក្នុងសង្គមកម្ពុជា ដែលពឹងផ្អែកលើវិស័យកសិកម្មព្រោះថា ក្មេងស្រីទាំងនោះ ធ្វើការតែនៅក្នុងវាលស្រែ មើលថែទាំផ្ទះ និងកូនក្មេង ហើយអាចធ្វើជាអ្នកលក់ដូរតូចតាចនៅក្នុងផ្សារ ឬធ្វើសិប្បកម្មនានា។

### ១០.៥.២ ការចូលរួមរបស់នារីនៅក្នុងការធ្វើសេចក្តីសំរេច នៅគ្រប់កំរិតទាំងអស់ គឺមានសារៈសំខាន់ក្នុងការនាំមកនូវការរីកចំរើន

ការចូលរួមរបស់នារីនៅមានចំនួនតិចតួច នៅក្នុងគ្រប់កំរិតទាំងអស់នៃការធ្វើសេចក្តីសំរេច: ក្នុងស្ថាប័នរដ្ឋាភិបាល រដ្ឋសភា តុលាការ និងនៅថ្នាក់ឃុំសង្កាត់ និងភូមិ។ ល្គឹកណាការចូលរួមរបស់នារីពុំកើនឡើងទេនោះ បរិដ្ឋានសង្គម និង ការទទួលខុសត្រូវដើម្បីសមភាពយេនឌ័រ គឺពុំអាចនាំឱ្យមានការផ្លាស់ប្តូរឡើយ។

### ១០.៥.៣ ប្រព័ន្ធតុលាការ និងស្ថាប័នអនុវត្តច្បាប់ ចាំបាច់ត្រូវមានការទទួលខុសត្រូវតាមរយៈការបង្កើនការត្រួតពិនិត្យ និងធ្វើរបាយការណ៍អំពីសកម្មភាពរបស់ខ្លួន

ទោះបីជាបច្ចុប្បន្នមានក្របខ័ណ្ឌផ្លូវច្បាប់សមរម្យ ដើម្បីលើកស្ទួយសិទ្ធិនារី ប៉ុន្តែការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ វប្បធម៌និទ្ទណ្ឌភាពចំពោះជនល្មើសដែលត្រូវចោទប្រកាន់ និងការផ្សំគំនិតរបស់អ្នកអនុវត្តន៍ច្បាប់ ធ្វើឱ្យប្រជាជនក្រីក្រ ជាពិសេសនារី កាន់តែងាយទទួលរងគ្រោះ ។ នៅក្នុងបរិស្ថានពុករលួយ នារីទទួលបានការគាំទ្រតិចតួចបំផុត ពីប្រព័ន្ធច្បាប់ ហើយនារីមានធនធានតិចតួចបំផុត ដើម្បីដំណើរការទៅតាមផ្លូវច្បាប់ ។

### ១០.៥.៤ អនុសាសន៍

- *ជំរុញឱ្យមានការឯកភាពគ្នាលើអត្ថន័យនៃសមភាពយេនឌ័រ នៅក្នុងបរិបទប្រទេសកម្ពុជា*

ដើម្បីបង្កើតការយល់ដឹងរួមគ្នា លើអត្ថន័យនៃសមភាពយេនឌ័រ និងធ្វើឱ្យស្របទៅតាមតួនាទីយេនឌ័រ តាមប្រពៃណី និងចាំបាច់ត្រូវដំណើរការពិភាក្សាក្នុងចំណោមអ្នកពាក់ព័ន្ធ ដើម្បីបង្កើតនិយមន័យសំរាប់ប្រទេសកម្ពុជា ។ អ្នកតស៊ូមតិដើម្បីយេនឌ័រនៅកម្ពុជា បានដំណើរការងារប្រកបដោយប្រសិទ្ធិភាព នៅក្នុងការពិភាក្សាជុំវិញការបង្កើនសមភាពយេនឌ័រ នៅក្នុងបរិបទប្រពៃណីរបស់ប្រទេសកម្ពុជា ។ ក្រុមអ្នកតស៊ូមតិដើម្បីនារី គួរតែត្រូវបានលើកដំកើង នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងកន្លែងផ្សេងៗទៀត ដើម្បីធ្វើជាគំរូវិជ្ជមាន និងដើម្បីលើកទឹកចិត្តដល់អ្នកដទៃទៀត ។

- *ណែនាំអនុវត្តគោលនយោបាយសកម្មភាពវិជ្ជមាន*

រដ្ឋាភិបាលបានប្តេជ្ញាក្នុងការបង្កើនចំនួននារីនៅក្នុងតួនាទីជាអ្នកធ្វើសេចក្តីសំរេច ប៉ុន្តែ ជោគជ័យបានតែមួយចំនួនតូចប៉ុណ្ណោះ ។ ដោយសារពុំទាន់មានការរីកចំរើន ចាំបាច់ត្រូវចាត់វិធានការចំពោះមុខបន្ថែមទៀត រួមមានសកម្មភាពវិជ្ជមាន ការកំណត់កូតា ការបណ្តុះបណ្តាល ពិសេសសំរាប់នារីជាមន្ត្រីរាជការ ឬ ថ្នាក់ដឹកនាំដែលមានសក្តានុពលភាព នៅក្នុងវិស័យឯកជន និងសង្គមស៊ីវិល ។ ប្រព័ន្ធកូតាជាជំនួយក្នុងការកាត់បន្ថយទំហំ ដែលនារីត្រូវប្រកួតប្រជែងជាមួយបុរស ពីព្រោះថា ដោយសារប្រពៃណី នារីមានការលំបាកក្នុងការប្រកួតប្រជែងជាមួយបុរស ។ នៅក្នុងប្រព័ន្ធកូតា បុរសប្រកួតប្រជែងជាមួយបុរសដើម្បីតួនាទី ហើយនារីប្រកួតប្រជែងជាមួយនារី ។

- *បង្កើនការចូលរួមរបស់នារីនៅថ្នាក់ភូមិ*

នៅថ្នាក់ភូមិ នារីហាក់ដូចជាបានបញ្ចេញគំនិតយោបល់ និងចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសហគមន៍ ។ ការផ្តល់អំណាចដល់នារី ក្នុងការធ្វើដោយផ្ទាល់ជាមួយអ្នកផ្តល់សេវា អាចនាំទៅរកផ្លូវថ្មីៗ ដែលធ្វើឱ្យសេវាទាំងនេះកាន់តែមានប្រសិទ្ធិភាព និងចំគោលដៅដែល ត្រូវការ ។ គួរតែបង្កើនការអនុវត្តន៍វិធីសាស្ត្រថ្មី ក្នុងការចូលទៅដល់នារី តាមរយៈការធ្វើការនៅក្នុងជួរគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ដែលក្នុងនោះបានដាក់ជាកូតាសំរាប់នារី ។

- *ការត្រួតពិនិត្យលើប្រព័ន្ធច្បាប់ និងតុលាការ*

ការបង្កើនជំនួយក្នុងការត្រួតពិនិត្យ តាមដាន និងរាយការណ៍អំពីលទ្ធផលនៃប្រព័ន្ធតុលាការ ជាពិសេសពាក់ព័ន្ធនឹងបទឧក្រិដ្ឋលើនារី នឹងអាចបង្កើនការទទួលខុសត្រូវរបស់ប្រព័ន្ធតុលាការ ជាពិសេសប្រសិនបើការធ្វើរបាយការណ៍ត្រលប់មកវិញ គឺដើម្បីឱ្យអង្គការថ្នាក់លើធ្វើការអនុវត្តបន្ត។ វប្បធម៌នៃភាពស្ងៀមស្ងាត់ជុំវិញបញ្ហាអំពើហិង្សានឹងត្រូវលប់បំបាត់ បើសិនជានារីបានឃើញ និងឮអំពីការផ្តន្ទាទោសដល់ជនល្មើស ហើយជនល្មើសនឹងអាចពុំហ៊ានប្រព្រឹត្តិអំពើល្មើស បើសិនជាពួកគេដឹងថាលទ្ធផល គឺការចោទប្រកាន់ និងការដាក់ទណ្ឌកម្ម។ នៅពេលមានការកើនឡើងនូវចំនួនករណីដែលត្រូវបានគេរាយការណ៍ ចាំបាច់ត្រូវបង្កើតប្រព័ន្ធដើម្បីរៀបចំទុកឯកសារ និងត្រួតពិនិត្យលើលទ្ធផលនៃសកម្មភាពដែលបានអនុវត្តដោយនគរបាល និងតុលាការ។

# ១០.៦ ស្ថាប័ននៅតែប្រឹងប្រែងក្នុងការបញ្ជ្រាបយេនឌ័រឱ្យមានប្រសិទ្ធិភាព

## ១០.៦.១ អភិបាលកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ខេត្ត គឺជាឧបសគ្គចំបងក្នុងការបង្កើនសមភាពយេនឌ័រ

វិស័យសង្គមកិច្ច និងកសិកម្មពុំមានហិរញ្ញវត្ថុគ្រប់គ្រាន់ ហើយថវិកាទាំងនោះពុំអាចចូលទៅដល់អ្នកទទួលផលដែលបានគ្រោងទុក។ ការផ្តល់មូលនិធិមិនទៀងទាត់ ដល់មជ្ឈមណ្ឌលផ្តល់សេវា ជាពិសេសនៅតំបន់ជនបទ បានកាត់បន្ថយប្រសិទ្ធិភាពរបស់សេវា។ ប្រាក់ឧបត្ថម្ភសំរាប់បុគ្គលិករដ្ឋ មានចំនួនតិចតួច ជំរុញឱ្យមានការទារថ្លៃសេវាក្រៅផ្លូវការ។ នៅពេលដែលសេវាមានតំលៃថ្លៃ ឬការចំណាយមានកំរិតខ្ពស់ពេក បើប្រៀបធៀបទៅនឹងលទ្ធផលដែលនឹងទទួលបានត្រឡប់មកវិញ នារីនឹងងាយទទួលការប៉ះពាល់ជាងបុរស។

## ១០.៦.២ ប្រសិទ្ធិភាពរបស់យន្តការបច្ចុប្បន្ន ក្នុងការបញ្ចូលបញ្ហាយេនឌ័រ នៅក្នុងដំណើរការធ្វើថវិកា និងផែនការ គឺនៅមានកំរិត

គោលដៅ ជាពិសេសគោលដៅសំរាប់តុល្យភាពយេនឌ័រ មិនរលូនជាមួយនឹងផែនការចំណាយ។ ជាក់ស្តែងគោលដៅអាចនឹងមិនស្របជាមួយនឹងសមត្ថភាព និងធនធានហិរញ្ញវត្ថុដែលមាន (ធនាគារពិភពលោក ឆ្នាំ២០០២a)។

## ១០.៦.៣ យន្តការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងពាក់ព័ន្ធនៅថ្នាក់ខេត្ត និងដំណើរការតាមផ្នែកៗប៉ុណ្ណោះ

នៅមានការងារជាច្រើនទៀត ដែលត្រូវធ្វើក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងក្រសួងពាក់ព័ន្ធ។ ដោយសារមានការប្រកួតប្រជែងអំពីអាទិភាព និងតម្រូវការ ធ្វើឱ្យបញ្ហាយេនឌ័រ ជាញឹកញាប់មិនត្រូវបានគេចាត់ទុកជាបញ្ហាអាទិភាព ហើយការងារយេនឌ័រជាច្រើន ត្រូវបានដំណើរការដោយអ្នកផ្តល់ជំនួយជាអ្នកជំរុញ។ ក្រសួងអប់រំ យុវជន និងកីឡា

គឺជាក្រសួងតែមួយគត់ ដែលមានយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ខ្លួនផ្ទាល់។ ជំនាញ និងសមត្ថភាពរបស់ក្រសួងផ្សេងៗទៀតក្នុងការបង្កើត និងអនុវត្តការងារនេះនៅមានកំរិត។

## ១០.៦.៤ សមត្ថភាពរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រ នៅក្នុងដំណើរការរៀបចំគោលនយោបាយ នៅមានខ្សោយ

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានដំណើរការជាជំហានៗក្នុងការបង្កើតបណ្តាញការងារ នៅក្នុងក្រសួងពាក់ពន្ធ័តាមវិស័យ ប៉ុន្តែជនបង្គោលយេនឌ័រដែលបានជ្រើសរើស មានតួនាទីទាប និងពុំសូវមានឥទ្ធិពល។ ទោះបីជាជនបង្គោលយេនឌ័រទាំងនោះ ទទួលបានឱកាសចូលរួមក្នុងការពិភាក្សាអំពីគោលនយោបាយ ប៉ុន្តែសមត្ថភាពរបស់ពួកគេក្នុងការធ្វើឱ្យមានឥទ្ធិពលប្រកបដោយប្រសិទ្ធិភាព គឺនៅមានកំរិត ដោយសារពុំទាន់មានសមត្ថភាពក្នុងការវិភាគ និងត្រួតពិនិត្យផលប៉ះពាល់របស់គោលនយោបាយ និងច្បាប់នានា និងសមត្ថភាពក្នុងការស្វែងរកការគាំទ្រមតិឱ្យមានការផ្លាស់ប្តូរ។

## ១០.៦.៥ អនុសាសន៍

- *ត្រូវគាំទ្រយ៉ាងខ្លាំងក្លាដល់ការខិតខំប្រឹងប្រែងដើម្បីបង្កើនការគ្រប់គ្រងការចំណាយសាធារណៈ និងបង្កើនការទទួលខុសត្រូវរបស់អ្នកផ្តល់សេវា*

ការបង្កើនការផ្តល់សេវាអាចនឹងមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើក្មេងស្រី ច្រើនជាងក្មេងប្រុស។

- *បង្កើនយន្តការក្នុងការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងដំណើរការធ្វើផែនការ និងថវិកា*

ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តកិច្ចសហការជាមួយក្រសួងកិច្ចការនារី និងអតីតយុទ្ធជនក្នុងការបង្កើតយន្តការវិភាជថវិកា និងការចំណាយដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ដើម្បីធានាឱ្យបានថា កំណែទម្រង់ និងវិធានការគោលនយោបាយសំខាន់ៗ អាចដោះស្រាយបញ្ហាយេនឌ័រ ហើយថវិកាដែលបានវិភាជរួច មានចំនួនគ្រប់គ្រាន់ ដើម្បីសំរេចគោលបំណងយេនឌ័រ។

- *បង្កើនការប្រមូល និងការវិភាគទិន្នន័យ ដើម្បីធ្វើការត្រួតពិនិត្យលើគោលដៅយេនឌ័រប្រកបដោយប្រសិទ្ធិភាព*

ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (២០០៤-២០០៥) និងការវាយតំលៃភាពក្រីក្រដោយមានការចូលរួមរបស់ធនាគារពិភពលោក/ធនាគារអភិវឌ្ឍន៍អាស៊ី (ជាមួយនឹង CSES ឆ្នាំ២០០៤) គួរតែបញ្ចូលឧបករណ៍ប្រមូលទិន្នន័យទាំងបរិមាណ និងគុណភាពដែលមានការឆ្លើយតបនឹងបញ្ហាយេនឌ័រ។ ការវិភាគឯកសារទាំងពីរនេះ ត្រូវដំណើរការរួមគ្នា និងមានការបញ្ជ្រាបយេនឌ័រ ដោយប្រើប្រាស់បញ្ហាដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ ជាក្របខណ្ឌសំរាប់ការវិភាគ និងជាមូលដ្ឋានសំរាប់ដំណើរការត្រួតពិនិត្យ ក្នុងការកាត់បន្ថយភាពក្រីក្រ និងការរីកចំរើនក្នុងការអនុវត្តន៍ គ.អ.ស។

បញ្ចូលទិន្នន័យស្តីពីការប្រើប្រាស់ពេលវេលានៅក្នុង CSES ឆ្នាំក្រោយ ដើម្បីវាស់ស្ទង់កិច្ចការងារដែលគ្មានប្រាក់កំរៃ និងពុំបានគេមើលឃើញ ដូចជាសកម្មភាពការងារក្នុងផ្ទះ និងការងារសំរាប់គ្រួសារដែលសកម្មភាពទាំងនេះ មិនត្រូវបានគេចាត់ទុកថា ជាការងារនោះទេ ឬពុំត្រូវបានគេបញ្ចូលទៅក្នុងទិន្នន័យ ស្តីពីកំលាំងពលកម្មបច្ចុប្បន្នទេ ។ ធានាឱ្យបានថា ទិន្នន័យកំលាំងពលកម្ម បានបញ្ចូលការងាររបស់នារី ក្នុងការទៅរកអុសដុត និងរែក/ដឹកទឹក ។ ការវិភាគ CSES ឆ្នាំក្រោយ គួរតែបង្ហាញឱ្យឃើញថា សកម្មភាពរបស់នារី ដែលត្រូវគេគិតថា "មិនមែនជាការងារ" បានផ្តល់ជារបស់របរ និងសេវានានា ដែលនឹងត្រូវចំណាយប្រាក់ដើម្បីទិញ បើសិនជាធ្វើនៅទីផ្សារ ប៉ុន្តែនៅពេលដែលការងារទាំងនោះ ទទួលបានប្រាក់កំរៃ ភាគច្រើនបុរសជាអ្នកធ្វើការងារទាំងនោះ ។ សកម្មភាពទាំងនេះ ជាញឹកញាប់ទទួលឥទ្ធិពលពីគោលនយោបាយ ដែលកំណត់វិស័យទីផ្សារជាគោលដៅ ប៉ុន្តែជាញឹកញាប់មានផលប៉ះពាល់ដល់គ្រួសារដោយពុំអាចគេចរួចឡើយ ។

វិទ្យាស្ថានស្ថិតិជាតិ និង PMATU គួរតែពង្រឹង និងកសាងកិច្ចសហការយ៉ាងជិតស្និទជាមួយក្រសួង ក.ន.អ ដែលបានបង្កើតឡើងនៅក្នុងដំណើរការ យ.ជ.ក.ភ និង គ.អ.ស ដើម្បីបង្កើតយន្តការត្រួតពិនិត្យឆ្លើយតបនឹងយេនឌ័រ និងរៀបចំរបាយការណ៍ស្តីពីសមិទ្ធផល ដូចជារបាយការណ៍របស់ យ.ជ.ក.ភ និង គ.អ.ស នៅកម្ពុជា ។

- ***ស្ថាប័នពាក់ពន្ធ័គួរតែបង្កើតផែនការបញ្ជ្រាបយេនឌ័ររបស់ខ្លួនផ្ទាល់ ដោយមានសូចនាករដែលអាចដំណើរការត្រួតពិនិត្យបាន***

ក្រសួងពាក់ពន្ធ័ទាំងអស់ គួរតែបង្កើតផែនការសកម្មភាពសំរាប់ការបញ្ជ្រាបយេនឌ័រ បង្កើតគោលដៅសំរាប់អ្នកទទួលផលប្រយោជន៍ដោយបែងចែកតាមភេទ និងប្រពន្ធ័សំរាប់រាយការណ៍ ជោគជ័យក្នុងការសំរេចបានតាមគោលដៅទាំងនោះ (IFAPER, ឆ្នាំ២០០៣) ។ ប្រពន្ធ័ទាំងនេះ គួរតែយកតាមគំរូរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធសំខាន់ៗផ្សេងទៀត គួរតែរៀបចំជាឯកសារវាយតំលៃ និងចែករំលែកយកនូវបទពិសោធន៍របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតយន្តការបញ្ជ្រាបយេនឌ័ររួចហើយ ។

- ***ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន គួរតែផ្តោតលើការវិភាគគោលនយោបាយ និងការតស៊ូមតិក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រប្រកបដោយនិរន្តរភាព ទៅក្នុងដំណើរការរៀបចំគោលនយោបាយ***

ការរីកចំរើននាពេលថ្មីៗនេះ នៃដំណើរការវិភាគគោលនយោបាយនៅក្នុង យ.ជ.ក.ភ និង គ.អ.ស បានផ្តល់ឱកាសដំបូងដល់ក្រសួង ក.ន.អ ដើម្បីកសាងសមត្ថភាព ។ ការងារបន្ថែមលើការពិនិត្យឡើងវិញលើយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងការជ្រើសរើសអាទិភាព ការរៀបចំក្របខណ្ឌ័ចំណាយរយៈពេលមធ្យម និងកម្មវិធីតាមវិស័យផ្សេងៗទៀត បានផ្តល់ឱកាសមួយទៀតដល់ក្រសួងដើម្បីកសាងសមត្ថភាព ។ ដោយសារក្រសួង ក.ន.អ ពុំមានអំណាចស្ថាប័នគ្រប់គ្រាន់ក្នុងការមានឥទ្ធិពលលើការធ្វើផែនការ និងថវិកាតាមវិស័យ ក្រសួង ក.ន.អ ចាំបាច់ត្រូវពង្រឹងសមត្ថភាពក្នុងការបង្កើនជំនាញវិភាគគោលនយោបាយ តាមវិស័យជាក់លាក់ និងការគាំទ្រផ្នែកនយោបាយ ។ ការពង្រឹងសមត្ថភាព នឹងធ្វើឱ្យក្រសួងកិច្ចការនារី និងអតីតយុទ្ធជន មានសមត្ថភាពក្នុងការតស៊ូមតិឱ្យមានគោលនយោបាយឆ្លើយតបនឹងយេនឌ័រ និងមានការគាំទ្រផ្នែកហិរញ្ញវត្ថុជាចាំបាច់សំរាប់ការងារនេះ ។ ដើម្បីសំរួលដល់ការងារនេះ ក្រសួងពាក់ពន្ធ័ គួរតែបញ្ចូលក្រសួង ក.ន.អ ទៅក្នុងដំណើរការរៀបចំគោលនយោបាយ និងត្រួតពិនិត្យ ហើយផ្តល់ឱ្យក្រសួង ក.ន.អ នូវពត៌មានចាំបាច់ដើម្បីឱ្យក្រសួង ក.ន.អ អាចចូលរួមប្រកបដោយប្រសិទ្ធិភាព ។

សមត្ថភាពក្នុងការវិភាគ និងតស៊ូមតិអំពីយេនឌ័រ គឺត្រូវការជាចាំបាច់ ជាពិសេសនៅក្នុងការវាយតំលៃ និងការត្រួតពិនិត្យអំពីភាពក្រីក្រ (តាមរយៈការវាយតំលៃភាពក្រីក្ររបស់ធនាគារពិភពលោក/ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០០៤) ក្របខ័ណ្ឌគោលនយោបាយ និងកំណែទម្រង់ហិរញ្ញវត្ថុខ្នាតធំ (ជាពិសេសផ្តោតលើគោលនយោបាយពន្ធអាករ និងពាណិជ្ជកម្ម) និងការពិនិត្យឡើងវិញលើក្របខណ្ឌ័យុទ្ធសាស្ត្រអភិវឌ្ឍន៍ ពាណិជ្ជកម្មជួយដល់ជនក្រីក្រ ដើម្បីបញ្ចូលវិធានការគោលនយោបាយដែលឆ្លើយតបនឹងយេនឌ័រ ។

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន គួរតែរៀបចំ និងពង្រឹងរចនាសម្ពន្ធ័ការិយាល័យផ្លូវច្បាប់របស់ខ្លួនឡើងវិញ ដោយមានបុគ្គលិកដែលមានជំនាញផ្នែកច្បាប់ ដែលអាចវិភាគលើច្បាប់ និងបទបញ្ញាតិនានា ដើម្បីរកឱ្យឃើញនូវការលំអៀងយេនឌ័រ ធ្វើវិសោធនកម្មច្បាប់ដើម្បីឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ និងបង្កើតច្បាប់ថ្មី និងត្រួតពិនិត្យការអនុវត្តន៍ច្បាប់ ។ គំរោងរបស់ GTZ ចាំបាច់ត្រូវផ្តោតលើការងារនេះ ។ គំរោងនេះ គួរតែពិចារណាជាពិសេសចំពោះប្រពន្ធ័តុលាការ ដើម្បីធានាឱ្យបានថា សិទ្ធិរបស់នារី ត្រូវបានការពារយ៉ាងពេញលេញ ជាពិសេសដោយផ្តោតទៅលើការលុបបំបាត់នូវរាល់ទម្រង់នៃអំពើហឹង្សាលើនារី ។

- ***អ្នកផ្តល់ជំនួយ គួរតែបន្តធ្វើការក្នុងភាពជាដៃគូជាមួយក្រសួង ក.ន.អ ដើម្បីបង្កើនសហប្រតិបត្តិការ និងប្រសិទ្ធិភាពក្នុងគ្រប់ការងារទាំងអស់របស់ពួកគេ***

អ្នកផ្តល់ជំនួយដោយសហការជាមួយក្រសួង ក.ន.អ ត្រូវបង្កើតក្រុមការងារយេនឌ័រ ជាផ្នែកមួយនៃក្រុមពិគ្រោះយោបល់ ដែលបានបង្កើតឡើង ដើម្បីបង្កើនទំនាក់ទំនងជាមួយអ្នកផ្តល់ជំនួយ ។ អ្នកផ្តល់ជំនួយ និងរដ្ឋាភិបាល គួរតែកំណត់ និងជ្រើសតាំងយ៉ាងហោចណាស់ជនបង្គោលយេនឌ័រតាមវិស័យជាក់លាក់មួយរូបនៅក្នុងក្រុមការងារនីមួយៗ (ដែលមន្ត្រី១រូបនោះ ក៏ជាសមាជិកនៃក្រុមការងារយេនឌ័រផងដែរ) ។ ក្រុមការងារនេះ ត្រូវផ្តល់យោបល់ទៅក្នុងយុទ្ធសាស្ត្រតាមវិស័យរបស់អ្នកផ្តល់ជំនួយទាំងអស់ និងវិស័យសំខាន់ទាំងអស់ ។ អនុសាសន៏នៅក្នុងរបាយការណ៏នេះគួរតែក្លាយទៅជាផែនការសកម្មភាព សំរាប់យុទ្ធសាស្ត្រយេនឌ័រតាមវិស័យនៅក្នុងក្រុមពិគ្រោះយោបល់ ដោយរួមទាំងយុទ្ធសាស្ត្រស្វែងរកជំនួយសំរាប់ប្រទេសកម្ពុជា ជាក្របខណ្ឌ័ជំនួយអភិវឌ្ឍន៏របស់សហប្រជាជាតិ និងយុទ្ធសាស្ត្ររបស់អ្នកផ្តល់ជំនួយផ្សេងៗទៀត ដែលពាក់ពន្ធ័ទៅនឹងគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា គោលដៅទី៨: ជំនួយអភិវឌ្ឍន៏ជាផ្លូវការ និងសេវាសង្គមជាមូលដ្ឋាន ។ អ្នកផ្តល់ជំនួយគួរតែបង្កើតយន្តការសំរាប់វាស់ស្ទង់អំពីកំរិតនៃជំនួយអភិវឌ្ឍន៏ ថាតើជំនួយអភិវឌ្ឍន៏ជាផ្លូវការនេះ បានចូលរួមចំណែកក្នុងការសំរេចគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា ដែលបានបញ្ជ្រាបយេនឌ័ររួចហើយ បានដល់កំរិតណា ។